# ចិត្តវិទ្យាអប់រំ

# Educational Psychology




សម្រាប់គ្រូបង្រៀន និងអ្នកអប់រំបណ្តុះបណ្តាលនានា

**បណ្ឌិត អ៊ឹម សិរីរដ្ឋ**

គ.ស. ២០២៤

# ចិត្តវិទ្យាអប់រំ

# Educational Psychology

Dr. Sereyrath Em
( PhD in Educational Science )

# Educational Psychology

Author: Dr. Sereyrath Em

Genre: Psychology

Published by: English Academic Essay (EAE)

Location: Takeo province

Country: Cambodia

Publication date: 30 June, 2024

Pages: 198

ISBN: 978-9924-9956-1-6

Copyright year: 2024

This page is intentionally left blank.

# មាតិកា


- អារម្ភកថា ........................................ iii
- គណៈកម្មការត្រួតពិនិត្យ ........................................ iv
- មេរៀនទី១ ៖ តើចិត្តវិទ្យាជាអ្វី? ........................................ 1
- មេរៀនទី២ ៖ មូលដ្ឋានសរីរៈនៃបាតុភូតចិត្ត ........................................ 9
- មេរៀនទី៣ ៖ ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្ស ........................................ 21
- មេរៀនទី៤ ៖ លក្ខណៈពិសេសវ័យជំទង់ ........................................ 35
- មេរៀនទី៥ ៖ ឥន្ទ្រីយារម្មណ៍ ........................................ 57
- មេរៀនទី៦ ៖ ប្រត្យក្សារម្មណ៍ ........................................ 68
- មេរៀនទី៧ ៖ លំនឹក ........................................ 86
- មេរៀនទី៨ ៖ ភាសា ( Langue ) ........................................ 118
- មេរៀនទី១០ ៖ ការគិត ........................................ 131
- មេរៀនទី ១១ ៖ រូបារម្មណ៍ ( L' IMAGINATION ) ........................................ 152
- មេរៀនទី១២ ៖ ចិត្តរំភើប និង សញ្ចេតនា ( ÉMOTION ET SENTIMENT ) ........................................ 167
- មេរៀនទី១៣ ៖ ឆន្ទៈ និង អំពើឆន្ទៈ ( LA VOLONTE ET L'ACTE VOLONTAIRE ) ........................................ 180
- ឯកសារពិគ្រោះ ........................................ 188

# អារម្ភកថា

ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន កំពុងយកចិត្តទុកដាក់ដល់ការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយ គុណភាព សមត្ថភាព និង គុណធម៌ គឺជាកត្តាគន្លឹះ សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច ទាំងក្នុងពេលចំពោះមុខ និង អនាគត។

ការអប់រំ គឺជាកូនសោរដ៏សំខាន់ ដើម្បីសម្រេចចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ក្នុងការកសាងសង្គម ដែលមានការអភិវឌ្ឍដោយចីរភាព និង សមធម៌ ការកែលម្អជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ពលរដ្ឋក្នុងសង្គម។ ហេតុនេះហើយ ការវិនិយោគវិស័យអប់រំ ចាំបាច់ត្រូវយកចិត្តទុកដាក់ អភិវឌ្ឍធនធានមនុស្ស ចាប់ពីមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សា។

សៀវភៅចិត្តវិទ្យាទូទៅនេះ ជាសៀវភៅជំនួយស្ដីពីការយល់ដឹងចំពោះវិស័យចិត្តសាស្ត្រដែលទាក់ទងនឹង ដំណើរការប្រព្រឹត្តទៅនៃពុទ្ធិរបស់មនុស្ស ការយល់ដឹងពីចិត្តវិទ្យា ការអភិវឌ្ឍបុគ្គលិកលក្ខណៈ លក្ខណៈពិសេសនៃវ័យជំទង់ និង លក្ខណៈចិត្តរបស់មនុស្សជាដើម។

ដើម្បីលើកកម្ពស់សមត្ថភាពការអប់រំ និង ការបង្រៀនបានល្អ គ្រូបង្រៀនត្រូវមានចំណេះដឹងផ្នែកចិត្តវិទ្យាបន្ថែម ដើម្បីសម្រួលដល់ការសិក្សាស្វែងយល់ពីដំណើរការនៃការបង្រៀន និងធ្វើការស្វែងយល់ពីការសិក្សារបស់សិស្ស និស្សិត។

សៀវភៅនេះយើងខ្ញុំសង្ឃឹមថា នឹងក្លាយជាឯកសារដ៏មានប្រយោជន៍ចំពោះគ្រូបង្រៀននិងអ្នកអប់រំបណ្ដុះបណ្ដាលនានា សម្រាប់ជាជំនួយក្នុងការបង្កើនគំនិត ដើម្បីស្រាវជ្រាវបន្ថែម លើជំនាញរបស់ខ្លួន។

ជាទីបញ្ចប់យើងខ្ញុំ រងចាំទទួលនូវការរិះគន់ស្ថាបនា ដើម្បីឱ្យសៀវភៅនេះកាន់តែមានគុណភាពខ្ពស់។

**បណ្ឌិត អ៊ឹម សិរីវឌ្ឍ**

# គណៈកម្មការត្រួតពិនិត្យ

| ល.រ | គោត្តនាម នាម | សញ្ញាបត្រ |
|---|---|---|
| 1. | លោក **មាច ស៊ីជន** | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ |
| 2. | លោក **មាច ជន់** | បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ |
| 3. | លោក **មាន់ ម៉ៅ** | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ |
| 4. | លោក **ម៉ួន មន** | បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ |

# មេរៀនទី១ ៖ តើចិត្តវិទ្យាជាអ្វី?

៙៚៙

## I- តើចិត្តវិទ្យាជាអ្វី?

### ក- ចិត្តវិទ្យា

- ចិត្តវិទ្យាជាវិទ្យាសាស្ត្រដែលសិក្សាពីបាតុភូតចិត្តជា «ច្បាប់កំណកំណើត និងការលូតលាស់»។
- ចិត្តវិទ្យាជាវិទ្យាសាស្ត្រដែលសិក្សាពីអាកប្បកិរិយា និងដំណើការផ្លូវចិត្ត។

ចិត្តវិទ្យាជាវិទ្យាសាស្ត្រព្រោះវាមាន ៖ កម្មវត្ថុសិក្សាច្បាស់លាស់ កម្មវិធីសិក្សាជាក់លាក់ និងបម្រើឲ្យផលប្រយោជន៍ដល់សង្គមមនុស្ស។

**១- កម្មវត្ថុសិក្សា** ៖ កម្មវត្ថុសិក្សារបស់ចិត្តវិទ្យាគឺបាតុភូតចិត្តរបស់មនុស្ស។ បាតុភូតនេះ កើតឡើងនៅក្នុងខួរក្បាលរបស់មនុស្ស ហើយស្តែងចេញឲ្យឃើញតាមរយៈអំពើ និងសកម្ម ភាព។

**ឧទាហរណ៍** ៖ គ្រូឃើញសិស្សរៀនពូកែសប្បាយចិត្ត។

សិស្សឃើញលទ្ធផលប្រឡងជាប់សប្បាយចិត្ត។

**២- កម្មវិធីសិក្សា** ៖ ដើម្បីសិក្សាពីបាតុភូតចិត្ត គេអាចប្រើវិធីសិក្សាជាច្រើនដូចជា វិធីសង្កេត វិធីពិសោធន៍ វិធីសន្ទនា វិធីធ្វើតេស្ត វិធីសិក្សាផលនៃសកម្មភាព វិធីវិភាគប្រវត្តិរូប វិធីអង្កេតដោយ

សរសេរ.........។ល។

**វិធីសង្កេត ៖** វិធីនេះសិក្សាពីសកម្មភាព (ទឹកមុខ កាយវិកា ពាក្យសំដី.........) របស់មនុស្សម្នាក់ៗ ដើម្បីស្គាល់ពីគុណវិបត្តិ និងគុណសម្បត្តិរបស់មនុស្សនោះ។

**ឧទាហរណ៍** ៖ ការសង្កេតមើលបម្រុងប្រយត្ន័របស់សិស្ស ក្នុងពេលសិក្សាក្នុងថ្នាក់ ការសង្កេតមើលសកម្មភាព របស់សិស្ស (ខ្ជិល ឧស្សាហ៍.........) ។

**វិធីសន្ទនា ៖** ជាវិធីដែលគេត្រូវជួបសំណេះសំណាលជាមួយនឹងមនុស្សណាម្នាក់តាមរយៈសំណួរដែលគេបានគ្រោងទុកជាមុន សំដៅយល់ដឹងបានពីចិត្តគំនិតអាថ៌កំបាំងរបស់មនុស្សនោះ។

**ឧទាហរណ៍** ៖ ការសន្ទនាពីវិធីសិក្សារបស់សិស្សពូកែ ការសន្ទនាពីវិធីបង្រៀនរបស់គ្រូដែលមានបទពិសោធន៍ល្អ។

**វិធីពិសោធន៍ ៖** វិធីនេះមានបំណងបង្កបាតុភូតចិត្តដែលត្រូវសិក្សាដើម្បីអាចសង្កេតពីបម្រែបម្រួលធាតុផ្សេងៗរបស់បាតុភូតនោះ។ វិធីនេះអាចប្រព្រឹត្តិទៅបានក្រោមរូបភាពពីរយ៉ាង គឺពិសោធធម្មតា និងពិសោធនៅក្នុងមន្ទីរពិសោធន៍។ ការពិសោធធម្មតាគេធ្វើឡើងក្នុងជីវភាពរស់នៅ ឬក្នុងសកម្មភាពធម្ម

តារបស់មនុស្ស ដែលគេចង់ពិសោធ ចំណែកឯពិសោធនៅក្នុងមន្ទីរពិសោធន៍ គេធ្វើឡើងនៅក្នុងមន្ទីរពិសោធន៍ក្នុងលក្ខខណ្ឌដែលធ្វើឲ្យលេចឡើងនូវបាតុភូតចិត្តដែលអ្នកពិសោធន៍ចង់បាន។

### ៣- អត្ថប្រយោជន៍របស់ចិត្តវិទ្យា

ចិត្តវិទ្យាមានប្រយោជន៍ច្រើនណាស់ចំពោះជីវភាពរស់នៅក្នុងសង្គម ជាពិសេសសកម្មភាពក្នុងការងារក្នុងការព្យាបាលជម្ងឺ ក្នុងវិស័យយោធា ក្នុងសិល្បៈជាដើម។ល។

**ឧទាហរណ៍** ៖ គ្រូបង្រៀនត្រូវស្គាល់ទឹកចិត្តសិស្ស នាយទាហ៊ានត្រូវស្គាល់ទឹកចិត្តពលទាហ៊ាន និយោជក ដឹងពីទឹកចិត្តកម្មកររបស់ខ្លួន សិល្បករត្រូវស្គាល់ពីចំណង់ចំណូលចិត្តរបស់ទស្សនិកជន។

នៅក្នុងវិស័យអប់រំគ្រប់កម្រិតទាំងអស់ គ្រូបង្រៀនគប្បីស្គាល់ចិត្ត និងយល់ដឹងពីស្ថានភាពរស់នៅរបស់សិស្សខ្លួនឲ្យបានគ្រប់ជ្រុងជ្រោយ សំដៅលើកកម្ពស់គុណភាពអប់រំឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ ដូច្នេះច្បាប់ទាំងឡាយរបស់ចិត្តវិទ្យាក្នុងវិស័យអប់រំសម្រាប់ជាមូលដ្ឋានរបស់គរុកោសល្យក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន និងអ្នកអប់រំគ្រប់កម្រិត។

### ខ- បាតុភូតចិត្តនិងបាតុភូតដទៃទៀត

#### ១- តើបាតុភូតចិត្តជាអ្វី?

បាតុភូតចិត្តជាបាតុភូតទាំងឡាយណាដែលប្រព្រឹត្តទៅនៅក្នុងខួរក្បាលមនុស្សហើយស្តែងចេញមកក្រៅតាមរយៈអំពើ សកម្មភាព ទឹកមុខ កាយវិការ ពាក្យសំដី.........។ល។

**ឧទាហរណ៍** ៖ មនុស្សពីរនាក់ ម្នាក់មានទឹកមុខញញឹម ម្នាក់ទៀតមានទឹកមុខក្រញ៉ូវ

#### ២- តើបាតុភូតដទៃទៀតជាអ្វី?

បាតុភូតដទៃទៀតគឺជាបាតុភូតដែលកើតឡើងពីការជះឥទ្ធិពលទៅវិញទៅមករវាងវត្ថុពីរ។

**ឧទាហរណ៍** ៖ ព្រះអាទិត្យបំភ្លឺផែនដីជាបាតុភូតរូប ទឹកដាំរីងហួតអស់ ជាបាតុភូតគីមី ត្រីស្រង់ពីទឹកងាប់ជាបាតុភូតជីវសាស្ត្រ ផ្គររន្ទះពេលភ្លៀងជាបាតុភូតអគ្គិសនី រថភ្លើងរត់លើផ្លូវដែកជាបាតុភូតមេកានិក។

### គ- លក្ខណៈពិសេសនៃបាតុភូតចិត្តរបស់មនុស្ស

#### ១- ចិត្តជាបាតុភូតសតិអារម្មណ៍

បាតុភូតចិត្តកើតមានតែនៅក្នុងខួរក្បាលរបស់មនុស្សយើងនោះទេ។ បាតុភូតនេះមានចរិតអត្តនោម័ត។ គេមិនអាចមើលឃើញបាតុភូតចិត្តនេះទេយើងមិនអាច ស្ទាប ប៉ះ ថ្លឹង វាស់ និងរាប់ចំនួនក៏មិនបានពោល គឺអរូបិយ។ ដូចសុភាសិតចាស់បូរាណពោលថា«គេអាចស្ទង់ជម្រៅទឹកទន្លេបាន ក៏ប៉ុន្តែគេមិនអាច

ស្ទង់ជម្រៅទឹកចិត្តរបស់មនុស្សបានទេ»។ ដូច្នេះគេមិនអាចសិក្សាចិត្តវិទ្យាតាមរបៀបផ្ទាល់បានទេ ប៉ុន្តែគេអាចសិក្សាវាបានតាមរបៀបប្រយោល ពោល គឺតាមរយៈការសម្ដែងចេញមកក្រៅដូចជា កាយវិការ ទឹកមុខ ពាក្យសំដី សកម្មភាពផ្សេងៗទៀត។ល។

**២- ចិត្តជាបាតុភូតមួយដែលស្ថិតស្ថេរ ហើយជាប់ជំពាក់ជានិច្ចជាមួយមនុស្សយើងម្នាក់ៗ**

មិនថាបុគ្គលណាម្នាក់ឡើយ គឺតែងតែមានរំញោចជានិច្ច។

**ឧទាហរណ៍** ៖ សិស្សកំពុងស្តាប់គ្រូពន្យល់មេរៀន (ប្រើសោតវិញ្ញាណ) សិស្សមានការសប្បាយរីករាយ (ចិត្តរំភើប) ក្រោយមកសិស្សក៏មានសំនួរសួរមកគ្រូ(ប្រើការគិត)។

លើសពីនេះទៅទៀត សព្វថ្ងៃនេះវិទ្យាសាស្ត្របានបកស្រាយបំភ្លឺថា សូម្បីតែនៅពេលសម្រាន្តលក់ក៏មានបាតុភូតចិត្តកើតឡើងនៅក្នុងខួរក្បាលយើងដែរ។ បាតុភូតដែលយើងធ្លាប់ស្គាល់ដូចជាការយល់សប្តិ។ ហើយនៅក្នុងជីវភាពរស់នៅរាល់ថ្ងៃបាតុភូតចិត្តក៏កើតមានឡើងនៅក្នុងខួរក្បាលរបស់យើងជាហូរហែដែរ

**៣- មុខងារទូទៅរបស់ចិត្តមនុស្ស**

ចិត្តមនុស្ស មានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងជីវភាពរស់នៅរាល់ថ្ងៃ។ ចិត្តមនុស្សអាចធ្វើឲ្យមនុស្សប្រកបដោយគុណធម៌ ក៏ប៉ុន្តែវាក៏អាចធ្វើឲ្យមនុស្សទៅជាចុះខ្សោយកម្លាំង ធ្លាក់ខ្លួនឈឺ ហើយរហូតដល់ស្លាប់ក៏មាន។ ហេតុអ្វីបានជាមានករណីនេះ? ពីព្រោះមុខងាររបស់ចិត្ត គឺតម្រង់ទិសដឹកនាំធ្វើនិយតូបនីយកម្មទៅលើអំពើ និងសកម្មភាពរបស់មនុស្ស។

**ឧទាហរណ៍** ៖ កាលណាគ្រូពន្យល់មេរៀនក្នុងថ្នាក់ ឥន្ទ្រីយារម្មណ៍ បម្រុងប្រយ័ត្ន ការត្រិះរិះពិចារណា អាចដើរតួនាទីក្នុងការតម្រង់ទិស។ រីឯឆន្ទៈ ទស្សនៈ និងឧត្តមគតិ អាចបំពេញតួនាទីក្នុងការដឹកនាំ និងនិយតូបនីយកម្មទៅលើអំពើទាំងឡាយ។ ចំណែកឯបំណិនប្រសប់ ភាពម្ចាស់ការ និងទម្លាប់អាចជះឥទ្ធិពលមួយយ៉ាងខ្លាំងទៅលើអំពើ។ និយាយរួមបើមិនមានរូបភាពផ្លូវចិត្តទេនោះវាក៏មិនមានអំពើដែរ។ ដូច្នេះមុខងាររបស់ចិត្តមនុស្សដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពរស់នៅ នៅក្នុងការងារ នៅក្នុងការសិក្សា នៅក្នុងល្បែងកំសាន្ត និងក្នុងទំនាក់ទំនងសង្គមរវាងមនុស្ស និងមនុស្ស។

**II- ធម្មជាតិនៃបាតុភូតចិត្ត**

បញ្ហាជាមូលដ្ឋានគ្រឹះរបស់ចិត្តវិទ្យា គឺថាតើធម្មជាតិនៃបាតុភូតចិត្តជាអ្វីទៅ? នៅក្នុងដំណាក់កាលអភិវឌ្ឍនីមួយៗរបស់សង្គមមនុស្ស គេបានផ្តល់នូវចម្លើយប្លែកៗពីគ្នាចំពោះសំណួរនេះ។ កាលពីសម័យដែលមនុស្សមិនទាន់មានភាពជឿនលឿនមនុស្សមិនទាន់មានសមត្ថភាពនៅចំពោះមុខធម្មជាតិនៅឡើយ បាតុភូតចិត្តត្រូវបានគេចាត់ទុកថាជាឥទ្ធិពលឬជាកម្លាំងរបស់ព្រះអាទិទេព។ លុះដល់ពេលសាសនាចាប់ផ្តើមកើតនៅលើភពផែនដីនេះបាតុភូតចិត្តត្រូវបានគេចាត់ទុកថាជាដង្ហើមរបស់ព្រះអាទិទេព

ទៅវិញ។ សព្វថ្ងៃនេះដោយសារតែវិទ្យាសាស្ត្រមានការអភិវឌ្ឍខ្លាំងទើបមានការប្រានចោលនូវអបិយជំនឿស្ដីអំពីចិត្តរបស់មនុស្ស។ ចិត្តវិទ្យាដែលប្រកបដោយលក្ខណវិទ្យាសាស្ត្របានផ្ដល់ចម្លើយច្បាស់លាស់ចំពោះសំណួរដែលមនុស្សចោទសួរតាំងពីយូរណាស់មកហើយគឺថា «ចិត្តរបស់មនុស្សជាចំណាំងរបស់តថភាពសត្យានុម័តដោយខួរក្បាលរបស់មនុស្ស ហើយចំណាំងដែលមានលក្ខណៈអត្តនោម័តនេះគឺជាធម្មជាតិរបស់សង្គមប្រវត្តិ។

## ក- ចិត្តមនុស្សគឺជាចំណាំងនៃតថភាពសត្យានុម័តរបស់ខួរក្បាល

ចិត្តមនុស្សកើតមកពីរូបភាពនៃតថភាពសត្យានុម័តដែលស្ថិតនៅក្រៅញាណរបស់មនុស្ស ហើយដែលត្រូវបានកត់ត្រាទុកក្នុងខួរក្បាលមនុស្ស។ នេះហើយដែលគេហៅថាបាតុភូតសតិអារម្មណ៍។ ដើម្បីយល់ឲ្យកាន់តែច្បាស់សូមមើលអំណះអំណាងខាងក្រោមនេះ៖

### ១- តើអ្វីទៅជាចំណាំង?

ចំណាំង គឺជាលំនាំអន្តរកម្មរវាងប្រពន្ធ័រូបធាតុពីរក្នុងពេលដំណាលគ្នា ហើយលទ្ធផលដែលកើតចេញពីលំនាំទាំងពីរនេះ។

### ២- តើអ្វីទៅដែលហៅថាតថភាពសត្យានុម័ត

តថភាពសត្យានុម័ត គឺជាអ្វីៗដែលស្ថិតនៅក្រៅញាណរបស់មនុស្ស ហើយជាប្រភពចិត្តរបស់មនុស្ស។ តថភាពសត្យានុម័តត្រូវបានឆ្លុះបញ្ចាំងចូលទៅក្នុងខួរក្បាលរបស់មនុស្ស ហើយបង្កើតបានជារូបភាពចិត្ត។ បើគ្មានតថភាពសត្យានុម័តទេរូបភាពចិត្តនៅក្នុងខួរក្បាលក៏គ្មានដែរ។ ដូច្នេះរូបភាពចិត្តកើតឡើង និងផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធទៅនឹងតថភាពសត្យានុម័តនៅក្នុងខួរក្បាលមនុស្ស បានន័យថារូបភាពចិត្តផ្សារភ្ជាប់ទៅនឹងអ្វីៗ(មនុស្ស សត្វ រុក្ខជាតិ វត្ថុ បាតុភូត) ដែលបុគ្គលម្នាក់ៗមានទំនាក់ទំនងជាមួយនឹងមជ្ឈដ្ឋានជុំវិញខ្លួន ក្នុងជីវភាពរស់នៅនិងក្នុងការងារ។ ចំពោះមនុស្សម្នាក់ៗរូបភាពចិត្តកើតមានគ្រប់ពេលវេលា។

### ៣- ចរិតអត្តនោម័តរបស់ចិត្ត

រូបភាពចិត្តដែលកើតមកពីវត្ថុមួយ ឬបាតុភូតមួយដែលសណ្ឋិតនៅក្នុងខួរក្បាលរបស់មនុស្សម្នាក់តែងតែខុសប្លែកពីមនុស្សម្នាក់ទៀតពីព្រោះការឆ្លុះបញ្ចាំងរូបភាបចូលក្នុងខួរក្បាលមនុស្សម្នាក់នេះ ត្រូវបានផ្លាស់ប្ដូរទៅតាមការយល់ដឹងបទពិសោធន៍ និងវិសេសភាពរបស់បុគ្គលម្នាក់ៗបានន័យថាវត្ថុឬបាតុភូតដែលមនុស្សម្នាក់ៗបានពិនិត្យសង្កេត និងវាយតម្លៃមានភាពខុសប្លែកគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ជួនកាលរង្វាយតម្លៃនេះខុសប្លែកគ្នាទៅតាមចំណង់ចំណូលចិត្ត។ ដូច្នេះបានន័យថា បាតុភូតចិត្តមានរូបភាពអត្តនោម័តពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។

**ឧទាហរណ៍** ៖ បងប្អូនពីរនាក់ ម្នាក់ចូលចិត្តរៀនភាសាអង់គ្លេស ចំណែកម្នាក់ទៀតចូលចិត្តរៀនភាសាបារាំង។ សរុបមកមានន័យថា វត្ថុតែមួយធ្វើឲ្យមនុស្សច្រើននាក់មានរូបភាពចិត្តខុសៗគ្នា។

### ៤- ចិត្តជាមុខងាររបស់ខួរក្បាល

មូលដ្ឋាននៃបាតុភូតចិត្ត គឺខួរក្បាល បើខួរក្បាលមិនធម្មតានាំឲ្យចិត្តរបស់មនុស្សមានលក្ខណៈមិនធម្មតាដែរ ដូចជាអ្នកមានជម្ងឺសរសៃប្រសាទ មនុស្សវិកលចរិត អ្នកវង្វេងស្មារតី។ កាលណាប្រពន្ធ័សរសៃប្រសាទរបស់ឥន្ទ្រីយ៍ទាំងប្រាំនាំព័ត៌មាន ឬរំញោចទៅខួរក្បាល ខួរក្បាលក៏បញ្ជូនព័ត៌មាននោះទៅសរីរាង្គណាមួយឲ្យមានប្រតិកម្ម ពេលនោះហើយដែលមនុស្សយើងបញ្ចេញសកម្មភាព ឬធ្វើអ្វីមួយ។ ដូច្នេះមានន័យថា ចិត្តជាមុខងាររបស់ខួរក្បាល។

### ៥- ចិត្តជាបទពិសោធន៍ដែលបង្កប់អត្ថន័យសង្គមប្រវត្តិ

ចិត្តរបស់មនុស្សជាលទ្ធផលនៃសង្គមប្រវត្តិដោយសារតែសកម្មភាពរបស់បុគ្គលម្នាក់ៗ បានប្រែក្លាយផលប្រយោជន៍រួមរបស់សង្គមប្រវត្តិទៅជាចិត្តរបស់គេម្នាក់ៗ ព្រោះពីជំនាន់មួយទៅជំនាន់មួយទៀត មនុស្សរស់នៅ និងធ្វើសកម្មភាព នៅក្នុងលក្ខខណ្ឌសង្គមប្រវត្តិដ៏ពិតប្រាកដ។ ចិត្តជាសម្បត្តិផ្ទាល់របស់បុគ្គលម្នាក់ៗ។ សម្បត្តិរួមក្នុងសង្គម គឺជាសម្បត្តិរួមរបស់មនុស្សជាតិ។ មនុស្សរស់នៅក្នុងសម័យកាលសង្គមដោយឆ្លងកាត់បទពិសោធន៍ និងព្រឹត្តិការណ៍ផ្សេងៗ ឬហេតុការណ៍ប្រវត្តិសាស្ត្រណាមួយ។ ដូច្នេះចិត្តរបស់មនុស្សបង្កប់នូវខ្លឹមសារសង្គមប្រវត្តិជានិច្ច។ មនុស្សទទួលបទពិសោធន៍ច្រើនពីក្នុងសង្គម ដូចជាចំណេះដឹងសង្គម និងពីវិទ្យាសាស្ត្របច្ចេកទេស។ បទពិសោធន៍ និងចំណេះដឹងសង្គមទាំងនោះតែងតែផ្សារភ្ជាប់ទៅនឹងស្នាដៃស្ថាបត្យកម្ម អក្សរសិល្ប៍ វប្បធម៌ សិល្បៈ និងច្បាប់។ ចំណេះដឹងនិងបទពិសោធន៍ត្រូវបានផ្ទេរឲ្យមនុស្សជំនាន់ក្រោយ ហើយអ្នកជំនាន់ក្រោយបានប្រែក្លាយវាឲ្យទៅជាបទពិសោធន៍ផ្ទាល់ខ្លួនគួបផ្សំនឹងចំណេះដឹងថ្មីៗ ធ្វើឲ្យបទពិសោធន៍ និងស្នាដៃរបស់គេកាន់តែសំបូរបែបឡើង។ ដរាបណាមនុស្សមានទឹកចិត្តក្លាហាន ភ្ជាក់រលឹកចូលរួមយ៉ាងសកម្មក្នុងការងារសង្គម ក្នុងការសិក្សា ក្នុងការប្រតិបត្តិ ដរាបនោះចិត្តរបស់គេកាន់តែមានភាពសំបូរបែបហើយក្លាហានឡើង។

## III- ចំណែកថ្នាក់នៃបាតុភូតចិត្តរបស់មនុស្ស

ពិភពនៅខាងក្រៅខ្លួនរបស់យើងសំបូរបែបណាស់។ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ និងការសិក្សា ចិត្តវិទូបានចែកបាតុភូតចិត្តជាបីប្រភេទ គឺលំនាំចិត្ត សភាពចិត្ត និង លក្ខណៈចិត្ត។

### ក- លំនាំចិត្ត

លំនាំចិត្ត គឺជាបាតុភូតចិត្តដែលកើតឡើងដោយមានការចាប់ផ្តើមការប្រព្រឹត្តិទៅ និងទីបញ្ចប់សំដៅ ប្រែក្លាយអំពើដែលកើតមានពីពិភពខាងក្រៅខ្លួនរបស់មនុស្សទៅជារូបភាពចិត្ត ហើយលំនាំចិត្តនេះ គឺជាប្រភពនៃជីវភាពសតិអារម្មណ៍របស់យើង។ លំនាំចិត្តកើតឡើងបានជាគុណភាពនៃកត្តានិយតករទីមួយ នៃសកម្មភាពរបស់មនុស្ស។ បើគ្មានលំនាំចិត្តទេនោះ ក៏គ្មានសភាពចិត្ត និងលក្ខណៈចិត្តដែរ។ លំនាំចិត្តចែកជា លំនាំចំណេះដឹង លំនាំចិត្តរំភើប និងលំនាំឆន្ទៈ។ ចំណេះដឹង សញ្ចេតនា និងឆន្ទៈ ជះឥទ្ធិពល

ទៅវិញទៅមក ជួនកាលប្រឆាំងគ្នា ជួនកាលចុះសម្រុងនឹងគ្នា ហើយបង្កើតបានជាជីវិតផ្លូវចិត្តដ៏ពេញលេញរបស់បុគ្គលម្នាក់ៗ។ ភាពសុខដុមរវាងទិដ្ឋភាពទាំងបីនេះមានលក្ខណៈសំខាន់ណាស់។ បើលំអៀងទៅលើវិចារញ្ញាណខ្លាំងពេក គេនឹងក្លាយទៅជាមនុស្សរឹងរូស ពីព្រោះគេខ្វះសញ្ចេតនា។ បើគេលំអៀងទៅលើសញ្ចេតនាខ្លាំងពេក គេនឹងបាត់បង់ភាពភ្លឺស្វាង ពីព្រោះគេប្រព្រឹត្តិទៅតាមចិត្តរំភើបជាអត្តនោម័ត។ ប្រសិនបើគេខ្វះឆន្ទៈវិញ នោះគេមិនអាចធ្វើអ្វីបានទាំងអស់ សូម្បីតែមានចំណេះដឹងដ៏ត្រឹមត្រូវ និងសញ្ចេតនាដ៏សំបូរបែបក៏ដោយ។

## ខ- សភាពចិត្ត

សភាពចិត្ត គឺជាបាតុភូតចិត្តដែលប្រព្រឹត្តិទៅរួមជាមួយលំនាំចិត្តជានិច្ច សម្រាប់ឆ្លុះបញ្ចាំង ឲ្យកាន់តែស៊ីជម្រៅ។ សភាពចិត្ត មិនមែនជាបាតុភូតដែលកើតឡើងដាច់ដោយឡែកទេ វាលេចធ្លោឡើងហើយប្រព្រឹត្តិទៅជាមួយលំនាំចិត្ត។ មានសភាពចិត្តកើតឡើងដំណាលគ្នា និងលំនាំចំណេះដឹង(ដូចជាបម្រុងប្រយ័ត្ន) លំនាំសញ្ចេតនា (ដូចជាសភាព ចិត្តដ៏ទូលំទូលាយ) លំនាំឆន្ទះ (ដូចជាភាពញញើតញញើម ឥរិយាបថដែលសម្រួលបាន)។ សភាពចិត្តជះឥទ្ធិពលទៅលើលំនាំចិត្ត ដែលប្រព្រឹត្តិទៅ ក្នុងពេលដំណាលគ្នា វាទទួលរងឥទ្ធិពលពីសកម្មភាពផ្លូវចិត្តដទៃទៀត។

**ឧទាហរណ៍** ៖ កាលណាគេកាន់តែប្រុងប្រយ័ត្ន (សភាពចិត្ត) គេកាន់តែស្តាប់បានច្បាស់លាស់ (លំនាំចិត្ត)។

## គ- លក្ខណៈចិត្ត

លក្ខណៈចិត្ត គឺជាបាតុភូតដែលឆ្លុះបញ្ចាំងជានិច្ចនៅក្នុងលក្ខខណ្ឌ និងក្នុងសកម្មភាពជា កំណត់របស់មនុស្ស ហើយក្លាយទៅជាលក្ខណៈពិសេសដែលស្ថិតនៅបានយូរ និងមានស្ថេរភាព។ លក្ខណៈឆាប់ភ្ញាក់រលឹក ស្មារតីពិនិត្យសង្កេត លំនឹក បញ្ញា ស្នេហាមាតុភូមិ សេចក្តីក្លាហាន ចំណង់ចំណូលចិត្តក្នុងតន្ត្រី ចំណង់ចំណូលចិត្ត ឬតណ្ហាក្នុងការស្រាវជ្រាវ។ល។ ទាំងអស់នេះគឺសុទ្ធតែជាលក្ខណៈចិត្ត។ ដូច្នេះលក្ខណៈចិត្ត ជាបាតុភូតចិត្តដែលមានលក្ខណៈ ដ៏ពិសេសនៅឋិតថេរបានយូរ ហើយធ្វើឲ្យបុគ្គលម្នាក់ៗខុសប្លែកពីបុគ្គលម្នាក់ទៀត។ សំនុំ លក្ខណៈចិត្តដែលមានភាពប្រាកដប្រជានោះ ក្លាយទៅជាលក្ខណៈចិត្តស្មុគស្មាញ មានដូចជា ទំនោរ ចរិត សម្បទា និងឫកពា។ នៅក្នុងជីវភាពប្រតិបត្តិ បាតុភូតចិត្តទាំងនេះ (លំនាំចិត្ត សភាពចិត្ត និងលក្ខណៈចិត្ត) តែងតែមានភាពជាប់ជំពាក់គ្នា មានអន្តរកម្មនឹងគ្នា ហើយស្តែងចេញឲ្យឃើញជីវិតផ្លូវចិត្តទាំងមូលរបស់មនុស្ស។

## សន្និដ្ឋាន

ដូច្នេះបាតុភូតចិត្តជាបាតុភូតសតិអារម្មណ៍ហើយជារូបភាពអត្តនោម័តនៃពិភពសត្យានុម័តដែលកើតមានក្នុងខួរក្បាលរបស់យើងម្នាក់ៗ។ រូបភាពទាំងអស់នេះប្រកាន់យក លក្ខណៈសង្គមប្រវត្តិ ទៅតាមសម័យកាល។ រូបភាពទាំងនេះ មានអំពើរបស់វានៅក្នុងការ តម្រង់ទិស ការដឹកនាំ និងក្នុងនិយតូបនីយ

កម្មនៃអំពើ។ ចិត្តវិទ្យាជាបាតុភូតសតិអារម្មណ៍ មិនមែនជាបាតុភូតសម្ភារទេ ខ្លឹមសាររបស់ចិត្តវិទ្យា គឺជាលទ្ធផលនៃចំណាំងរបស់ពិភពសត្យានុម័ត។ ប៉ុន្តែទោះបីតែបាតុភូតនេះ ជាបាតុភូតសតិអារម្មណ៍ក៏ដោយ ក៏វាត្រូវផ្សារភ្ជាប់ជានិច្ចជាកាលជាមួយ នឹងខួរក្បាល និង លំនាំសរីរៈរបស់សរសៃប្រសាទ បាតុភូតចិត្តប្រកាន់យកនូវលក្ខណៈសង្គមប្រវត្តិតាមសម័យកាលនីមួយៗ។ ទង្វើរបស់បាតុភូតចិត្តស្តែងចេញឲ្យឃើញនៅក្នុងការតម្រង់ទិស ការដឹកនាំ និងនិយតូបនីយកម្មនៃអំពើនីមួយៗរបស់មនុស្ស។

# សំណួរ

១- ចូរឲ្យនិយមន័យរបស់ចិត្តវិទ្យា។ ហេតុអ្វីបានជាគេថាចិត្តវិទ្យាជាវិទ្យាសាស្ត្រមួយ?

២- តើចិត្តវិទ្យាមានវិធីសិក្សាដូចម្តេចខ្លះ?

៣- ដូចម្តេចដែលហៅថាបាតុភូតចិត្ត? តើបាតុភូតនេះកើតឡើងនៅកន្លែងណា?នៅពេលណា?

៤- ចូរពន្យល់ពីចរិតអត្តនោម័តរបស់ចិត្ត។

៥- តើបាតុភូតចិត្តត្រូវបានគេធ្វើចំណែកថ្នាក់ដូចម្តេចខ្លះ? ចូរពន្យល់។

# មេរៀនទី២ ៖ មូលដ្ឋានសរីរៈនៃបាតុភូតចិត្ត

ᨁ❀ᨁ

## I- វត្ថុបំណង

- ក្រោយពីសិក្សាមេរៀនចប់សិស្សនឹង ៖
- បកស្រាយបញ្ញត្តិចិត្តវិទ្យា សរីរៈវិទ្យា និង មុខវិជ្ជាប្រព័ន្ធសរសៃប្រសាទ
- ប្រៀបធៀបចំណុចសំខាន់ៗរបស់ប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស
- មានស្មារតីស្រឡាញ់ចូលចិត្តសិក្សាចិត្តវិទ្យា ដើម្បីចូលរួមអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្សឱ្យទទួលបានលទ្ធផលល្អ ។

## II- សេចក្តីផ្តើម

ក្នុងការសិក្សាក៏ដូចជានៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ យើងត្រូវស្គាល់ពីទំនាក់ទំនងរវាងចិត្តវិទ្យា និងមូលដ្ឋានសរីរៈដែលជាមូលដ្ឋានក្នុងការបង្កើតបាតុភូតចិត្តរបស់មនុស្ស។ លើសពីនេះទៅទៀតយើងអាចស្គាល់ បាតុភូតផ្សេងៗ ដូចជា បាតុភូតរូប មេកានិច គីមី...។

## III- ខ្លឹមសារ

### ក- ទំនាក់ទំនងរវាង ចិត្តវិទ្យា និង សរីរៈវិទ្យា

### ១- ចិត្តវិទ្យា និង សរីរៈវិទ្យាមានទំនាក់ទំនងឯកភាពគ្នា

ចិត្តវិទ្យា និងសរីរៈវិទ្យាជាវិទ្យាសាស្ត្រដែលមានកម្មវត្ថុសិក្សាជាប់ពាក់ព័ន្ធនឹងគ្នា ។ ចិត្តវិទ្យា ជាវិទ្យាសាស្ត្រដែលសិក្សាពីអកប្បកិរិយា និងការលូតលាស់ផ្លូវចិត្ត។ សរីរៈវិទ្យា ជាវិទ្យាសាស្ត្រដែលសិក្សាអំពីលំនាំប្រព្រឹត្តទៅ និងការលូតលាស់នៃសរីរាង្គខាងក្នុង និងខាងក្រៅខ្លួនមនុស្សដូចជា ចលនា និងដំណើរប្រព្រឹត្តទៅនៃបេះដូង សួត ប្រព័ន្ធសរសៃប្រសាទ និងមុខងាររបស់វា ។

បាតុភូតចិត្ត និងសរីរៈវិទ្យាមានទំនាក់ទំនងឯកភាព ។ បើគ្មានសកម្មភាពសរសៃប្រសាទនោះបាតុភូតចិត្តក៏មិនអាចមានដែរ ។ សកម្មភាពសរសៃប្រសាទ និងបាតុភូតសរីរៈជាមូលដ្ឋានរូបរបស់បាតុភូតចិត្ត ។ បាតុភូតចិត្តត្រូវការមូលដ្ឋានរូបមួយ គឺប្រព័ន្ធសរសៃប្រសាទ ។

### ២- ចំណាំងរបស់តថភាពសត្យានុម័ត

ចំណាំងរបស់តថភាពសត្យានុម័ត គឺជាចំណាំងដែលប្រព្រឹត្តមកលើសរីរាង្គវិញ្ញាណរបស់យើងតាមរយៈសកម្មភាពរបស់យើងធ្វើអោយ បាតុភូតចិត្តកើតមានឡើង ។

**ឧទាហរណ៍ ៖** ពន្លឺព្រះអាទិត្យក្តៅខ្លាំងនាំឱ្យយើងរត់ទៅជ្រក់ក្រោមម្លប់ ។

ដើម្បីយល់ស៊ីជម្រៅទៅលើបាតុភូតចិត្ត និងសកម្មភាពផ្លូវចិត្តរបស់មនុស្សតាមលក្ខណៈវិទ្យាសាស្ត្រ យើងត្រូវមានចំណេះដឹងជាមូលដ្ឋានស្តីអំពីមូលដ្ឋានរូបរបស់បាតុភូតចិត្តពោល គឺសំណុំប្រព័ន្ធសរសៃប្រសាទ និងសកម្មភាពសរសៃប្រសាទ ។

## ខ- សញ្ញាណសង្ខេបលើទ្រង់ទ្រាយ និងមុខងាររបស់ប្រព័ន្ធសរសៃប្រសាទ

### ១- ចំនុចសំខាន់ៗស្តីពីប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស

ប្រព័ន្ធសរសៃប្រសាទទទួលបន្ទុកផ្នែកទំនាក់ទំនងរវាងសារពាង្គកាយទាំងមូល និងមជ្ឈដ្ឋានជុំវិញខ្លួនយើងព្រមទាំងតម្រូវការ និងជួយយើងក្នុងការសម្រួលរបស់សរីរាង្គកាយក្នុងការចិញ្ចឹមជីវិតក្នុងជីវភាពរស់នៅទៅតាមមជ្ឈដ្ឋានប្លែកៗ ឬស្ថានភាពសង្គម ។ ប្រព័ន្ធសរសៃប្រសាទចែកចេញជាពីរផ្នែក គឺផ្នែកកណ្តាល និងផ្នែកបរិមណ្ឌល ។

### ក- ប្រព័ន្ធសរសៃប្រសាទផ្នែកកណ្តាល

ប្រព័ន្ធសរសៃប្រសាទផ្នែកកណ្តាលមាន សំណុំខួរក្បាល និងសំណុំខួរឆ្អឹងខ្នង ។ សំណុំខួរក្បាលចែកចេញជាពីរចំហៀងហៅថាអឌ្ឍគោលខួរឆ្វេង និងអឌ្ឍគោលខួរស្តាំ ។ នៅក្នុងអឌ្ឍគោលខួរនីមួយៗផ្នែកខាងក្នុងផ្សំឡើងដោយសារជាតុពណ៌សដែលគ្របដណ្តប់ដោយសារជាតុពណ៌ប្រផេះ ស្រទាប់ស្តើងមានកម្រាស់ ២មម ជាមធ្យម ហៅថាក័រតិចខួរ ឬសំបកខួរ។ ប្រសិនបើគេអាចលាតត្រដាងសំបកខួរនោះបាន គេនឹងបានក្រឡាផ្ទៃទាំងអស់ប្រហែល ២០ដម$^{២}$ ដែលមានទំហំធំជាងផ្ទៃនៃអឌ្ឍគោលខួរ ។




ដងខួរក្បាលមាន ខួរក្បាលកណ្តាលដែលស្ថិតនៅចន្លោះខួរតូច និង អឌ្ឍគោលខួរដែលមានដុំភ្លោះពីរ ហៅថាទុយប៊ែគុលក្វាឌ្រីស៊ុមម៉ូ ។ ខួរតូច ជាសារជាតុក៏មាននៅក្នុងនោះដែរ ខួរកញ្ចឹងក។ ខួរឆ្អឹងខ្នងស្ថិតនៅក្នុងរន្ធឆ្អឹងខ្នង បាប់តាំងពីកញ្ចឹងករហូតដល់ផ្នូកក្បិន ។ បើគេកាត់ខួរឆ្អឹងខ្នងគេនឹងឃើញសារជាតុពណ៌ប្រផេះស្រោបជុំវិញទៅដោយសារជាតុពណ៌ស ។ ប្រពន័ន្ធសរសៃប្រសាទមានតួនាទីសម្រាប់

បញ្ហា និងត្រួតពិនិត្យលើទំនាក់ទំនង គឺសំដៅធានាបាននូវឯកភាពគ្នារវាងសរីរាង្គ ឬអាការៈខាងក្នុងនិងសារពាង្គកាយទាំងមូលរវាងសារពាង្គកាយ និងមជ្ឈដ្ឋានជុំវិញខ្លួន ។ ឯផ្នែកផ្សេងៗ ទៀតនៃប្រព័ន្ធសរសៃប្រសាទកណ្ដាល ដូចជាខួរឆ្អឹងខ្នងសម្រាប់ដឹកនាំអំពើងាយៗ ។

**ឧទាហរណ៍៖** ដៃប៉ះភ្លើងគឺខួរឆ្អឹងខ្នងជាអ្នកបញ្ជាទៅសាច់ដុំឲ្យដកដៃចេញ។

## ខ- ប្រព័ន្ធសរសៃប្រសាទបរិមណ្ឌល ឬប្រព័ន្ធណឺរ៉ូនវេសេតាទីប

ប្រព័ន្ធណឺរ៉ូន-វេសេតាទីប មានពីរចំណែកដែលចាក់ចូលទៅក្នុងសរីរាង្គរបស់យើងគឺ ប្រព័ន្ធអរតូសាំប៉ាទិច និង ប្រព័ន្ធប៉ារ៉ាសាំប៉ាទិច ។ ប្រព័ន្ធអរតូសាំប៉ាទិចបង្កើតឡើងដោយមានមជ្ឈមណ្ឌលប្រសាទស្ថិតនៅត្រង់ផ្នែក ក ខ្នង ធ្នូកក្បិននៃសារធាតុពណ៌ប្រផេះរបស់ខួរឆ្អឹងខ្នង ។ វាភ្ជាប់ទៅនឹងសរីរាង្គខាងក្នុងដូចជាបេះដូង ហើយវាតម្រង់ទៅរកសរសៃឈាមក្រោមស្បែកដោយសារសរសៃប្រសាទអរតូសាំប៉ាទិច ។ ប្រព័ន្ធប៉ារ៉ាសាំប៉ាទិចមានមជ្ឈមណ្ឌលប្រសាទស្ថិតនៅក្នុងខួរកញ្ចឹងក និងកញ្ចូញគូទនៃឆ្អឹងខ្នង។ សរសៃប្រសាទផ្លឺម៉ូកាស្ទ្រិចជាសរសៃប្រសាទប៉ារ៉ាសាំប៉ាទិចដែលសំខាន់ជាងគេបង្អស់។ វាចេញពីខួរកញ្ចឹងក ហើយចាក់ចូលទៅសរីរាង្គខាងក្នុងនៃទ្រូងរបស់យើង។ ប្រព័ន្ធសរសៃប្រសាទបរិមណ្ឌលត្រូវទទួលបន្ទុកជាច្រើនផ្នែកនៅក្នុងសកម្មភាពចឹញ្ចឹមសពាង្គកាយរបស់យើង។




ណឺរ៉ូនជាកោសិកាប្រសាទដែលមានតួមួយស្ថិតនៅក្នុងសារធាតុពណ៌ប្រផេះ ឬក្នុងកង់គ្លីយ៉ុង និងភីបដែលបន្តពីតួកោសិកាទៅក្នុងសារធាតុពណ៌ស ឬក្នុងសរសៃប្រសាទ។ សំណុំណឺរ៉ូនបង្កើតបានជាសរសៃប្រព័ន្ធប្រសាទ។ ណឺរ៉ូននីមួយៗមានតួ និងសាខាជាច្រើន។ តួរបស់វាមានស៊ីតូប្លាស និងណ្វៃយ៉ូមួយ។ បណ្ដោយសាខារបស់ណឺរ៉ូននីមួយៗ មានផ្នែកខ្លី ហៅថាដងឌ្រីត និងផ្នែកវែង ហៅថាអាក់សូន ឬស៊ីឡាំងដ្រាក។ ណឺរ៉ូននីមួយៗ មានអាក់សូនមួយ និងដង់ឌ្រីតជាច្រើន។ ដង់ឌ្រីត គឺជាទ្វារចូល ឯអាក់សូន គឺជាទ្វាចេញរបស់ណឺរ៉ូន។ ត្រង់កន្លែងដែលណឺរ៉ូនជាប់ទាក់ទងគ្នាពីមួយទៅមួយហៅថាស៊ីណាប់។ ដោយសារស៊ីណាប់នេះហើយដែលណឺរ៉ូននីមួយៗ អាចសម្រេចបាននូវទំនាក់ទំនងរវាងខ្លួនវាជាមួយនឹងណឺរ៉ូនដទៃទៀតជាមួយកោសិកាវិញ្ញាណ ជាមួយកោសិកាសាច់ដុំ ឬកោសិកាក្រពេញ ។

ណឺរ៉ូនមានមុខងារពីរយ៉ាង គឺបង្កើតឱ្យមានអាំងភ្លុចប្រសាទកាលណាមានរំញោចពីខាងក្រៅ ហើយផ្ទេរអាំងភ្លុចនោះទៅឱ្យណឺរ៉ូនបន្ទាប់ទៀត។ ស៊ីឡាំងដ្រាក់ប្រជុំគ្នាបង្កើតបានជាបាច់សរសៃប្រសាទ។ សរសៃប្រសាទមានពីរយ៉ាង សរសៃប្រសាទប្រទាញចូលដែលសម្រាប់បញ្ជូនអាំងភ្លុចប្រសាទពីសរីរាង្គឥន្ទ្រីយ៍ទៅឱ្យមជ្ឈមណ្ឌលប្រសាទ និងមួយទៀត គឺសរសៃប្រសាទប្រទាញចេញដែលនាំអាំងភ្លុចប្រសាទចេញពីមជ្ឈមណ្ឌលប្រសាទទៅកាន់សរីរាង្គចលករ។

**ឧទាហរណ៍** ៖ សាច់ដុំដៃ សាច់ដុំជើង ។

ផ្នែកខ្ពស់បំផុតនៃខួរក្បាលដែលប្រកបដោយអឌ្ឍគោលខួរពីរមានសារៈសំខាន់ជាងគេបំផុតហើយដែលគេចាត់ទុកថាជាមូលដ្ឋានរូបនៃសកម្មភាពផ្លូវចិត្តរបស់មនុស្ស។ ប្រព័ន្ធសរសៃប្រសាទជានាសកម្មភាពរូប និងរក្សាដំណើរការប្រព្រឹត្តទៅយ៉ាងសុខដុមនៃសព៌ាង្គកាយទាំងមូលព្រមទាំងសម្របសម្រួលសារព៌ាង្គកាយទៅតាមលក្ខខណ្ឌនៃស្ថានភាព ឬមជ្ឈដ្ឋានជុំវិញខ្លួនដោយសាររ៉េផ្លិចផ្សេងៗ ។




## ២- សញ្ញាណរ៉េផ្លិច-រ៉េផ្លិចឥតលក្ខខណ្ឌ-រ៉េផ្លិចមានលក្ខខណ្ឌ

### ក- សញ្ញាណរ៉េផ្លិច

មជ្ឈដ្ឋាន ឬស្ថានភាពជុំវិញខ្លួនរបស់យើងធ្វើអំពើ ឬប្រព្រឹត្តជានិច្ចមកលើប្រព័ន្ធសរសៃប្រសាទតាមរយៈសរីរាង្គឥន្ទ្រីយ៍របស់យើង។ ដើម្បីមានអត្ថិភាព និងលូតលាស់បានសព៌ាង្គកាយត្រូវធ្វើប្រតិកម្មតបវិញនៅពេលណាដែលវាទទួលរំញោច។ លំនាំបែបនេះគេហៅថា រ៉េផ្លិច។

**ឧទាហរណ៍** ៖ ក្មេងឃ្លានបាយ រសក្រពះធ្វើប្រតិកម្មមកលើផ្ទៃពោះវៀន នាំឱ្យពោះវៀនក្រហាយហើយបណ្តាលឱ្យក្មេងយំ។ រំញោចក្រពះ(សរីរាង្គក្នុង) នាំឱ្យមានប្រតិកម្មក្មេងយំ(រំញោចក្នុង) ។

គ្រូអានអត្ថបទសរសេរតាមអាន សិស្សកត់ត្រាតាម។ រំញោច(សំដីគ្រូ) នាំឱ្យមានប្រតិកម្មសិស្សស្ដាប់ និងសរសេរតាម។

ចាប់តាំងពីសកម្មភាពងាយៗដូចជាសម្រេកក្មេងពេលវាឃ្លានបាយរហូតដល់សកម្មភាពស្មុគស្មាញដូចជាការសិក្សារបស់សិស្សសរសេតាម និងរាល់សកម្មភាពផ្សេងៗ ទៀតរបស់មនុស្សសុទ្ធសឹងជាសកម្មភាពរ៉េផ្លិចទាំងអស់។

**និយមន័យ ៖** រ៉េផ្លិច គឺជាប្រតិកម្មនៃសព៌ាង្គកាយឆ្លើយតបទៅនឹងរំញោចដែលកើតមានពីខាងក្នុង ឬពីខាងក្រៅខ្លួនដែលកើតឡើងដោយផ្នែកណាមួយដ៏ពិតប្រាកដនៃប្រព័ន្ធសរសៃប្រសាទក្នុងខ្លួនមនុស្សយើង។

## ខ- រ៉េផ្លិចឥតលក្ខខណ្ឌ

រ៉េផ្លិចឥតលក្ខខណ្ឌ ជារ៉េផ្លិចមានកំណើត ឬជួនកាលជារ៉េផ្លិចតំណពូជ។ តាំងពីវ័យទារក មនុស្សក៏ដូចជាសត្វ ធ្វើប្រតិកម្មឆ្លើយតបទៅនឹងចំណាំងនៃតថភាពសត្យានុម័តនៃមជ្ឈដ្ឋាន ឬស្ថានភាពជុំវិញខ្លួនដើម្បីមានអត្ថិភាពក្នុងសង្គមដោយសាររ៉េផ្លិចឥតលក្ខខណ្ឌ។ រាល់ប្រតិកម្មនៃខួរឆ្អឹងខ្នងសុទ្ធសឹងជារ៉េផ្លិចឥតលក្ខខណ្ឌ ឬជារ៉េផ្លិចពីកំណើត។ រ៉េផ្លិចរបស់ដងខួរក្បាល ខួរតូច ខួរកញ្ចឹងក ក៏សុទ្ធសឹងជារ៉េផ្លិចឥតលក្ខខណ្ឌដែរ។

**ឧទាហរណ៍ ៖** ដៃប៉ះភ្លើងក្ដៅនាំឱ្យដកចេញភ្លាម ។ មូសខាំយកដៃទះត។ កើតមកចេះយំ ចេះសើច ចេះស្រែក ចេះ....។

រ៉េផ្លិចឥតលក្ខខណ្ឌ មានបន្លាស់ប្ដូរប្រែប្រួលតិចតួចណាស់ ហើយតម្រូវឱ្យមានរំញោចយ៉ាងសមស្របផង ទើបមានអត្ថិភាពបានយ៉ាងប្រសើរក្នុងមជ្ឈដ្ឋានរស់នៅដូចជាសំឡេងអាចទទួលបានដោយត្រចៀក (សំឡេងខ្លាំងពេកធ្វើឱ្យមនុស្សពិបាកទ្រាំ) ពន្លឺអាចទទួលបានដោយសារភ្នែក(ភ្លឺចាំងខ្លាំងពេកភ្នែកមិនអាចទ្រាំទ្របាន)។ល។

## គ- រ៉េផ្លិចមានលក្ខខណ្ឌ

ផ្សេងពីរ៉េផ្លិចឥតលក្ខខណ្ឌ រ៉េផ្លិចមានលក្ខខណ្ឌ កើតមានឡើងក្នុងលក្ខខណ្ឌជាកំណត់។ សរីរៈវិទូជាតិរូស្សីឈ្មោះលោក ប៉ាវឡូវ បានរកឃើញ និងហៅរ៉េផ្លិចនេះថា ជារ៉េផ្លិចមានលក្ខខណ្ឌ ដែលអាចកើតមានឡើង និងបាត់បង់សាបរលាបទៅវិញក្នុងរយៈពេលមួយមិនកំណត់បាន។ លោកប៉ាវឡូវ ១៨៤៦-១៩៣៦ ជាអ្នកប្រាជ្ញសរីរៈវិទ្យានៅវិទ្យាស្ថានលេនីនក្រាដ បានស្រាវជ្រាវរកឃើញរ៉េផ្លិចមានលក្ខខណ្ឌមុនគេ ហើយទទួលបានរង្វាន់ណូបែលក្នុងឆ្នាំ១៩០៤ ។ ដើម្បីសិក្សាពីរ៉េផ្លិចនេះ លោក ប៉ាវឡូវ បានធ្វើពិសោធទៅលើសត្វឆ្កែ ដោយសង្កេតមើលរ៉េផ្លិចក្រពេញទឹកមាត់របស់វា ។

**រូបទី១ ៖** ក្នុងលក្ខខណ្ឌធម្មតា ពន្លឺចង្កៀង ជារំញោចណឹត គ្មានប្រយោជន៍អ្វីទៅលើក្រពេញទឹកមាត់ឆ្កែទេ ។

**រូបទី២ ៖** វត្ថុភ្លោច( សាច់ )ដែលប៉ះអណ្ដាតរបស់ឆ្កែបង្កើតបានជារ៉េផ្លិចទឹកមាត់ហើយនេះជារ៉េផ្លិចឥតលក្ខខណ្ឌធម្មតា ។

**រូបទី៣ ៖** ក្នុងពេលតែមួយ គេផ្ដល់វត្ថុភ្លោចលើអណ្ដាតវាផង និងលើចក្ខុវាផង ។ នៅពេលនេះគេដឹងថានៅចន្លោះមណ្ឌលទាំងពីរនៃកំរតិច និងចន្លោះសរីរាង្គវិភាគគឺ ជីវ្ហាវិញ្ញាណ និងចក្ខុវិញ្ញាណ មានខ្សែបន្ទាត់មួយតភ្ជាប់គ្នារវាងមណ្ឌលទាំងពីរនោះជាបណ្ដោះអាសន្ន ។

**រូបទី៤ ៖** ក្រោយពីបានផ្ដល់រំញោចទាំងពីរនោះជាច្រើនដងក្នុងពេលជាមួយគ្នា គេសង្កេតឃើញខ្សែភ្ជាប់បណ្ដោះអាសន្ននោះស្ថិតនៅក្នុងកំរតិចខួរក្នុងរយៈពេលមួយ ។ លទ្ធផលដែលគេទទួលបានគឺរំញោចដែលណឺត( ពន្លឺចង្កៀង ) ចាប់ផ្ដើមធ្វើឱ្យឆ្កែចេញទឹកមាត់ ។ នេះជារ៉េផ្លិចមានលក្ខខណ្ឌរបស់ឆ្កែ ។




ដូចនេះ យើងឃើញថាសកម្មភាពនៃរ៉េផ្លិចមានកលក្ខខណ្ឌ គឺការបន្សាំសព៌ាង្គកាយទៅនឹងស្ថានភាព ឬមជ្ឈដ្ឋានជុំវិញ ហើយវាមានកម្រិតខ្ពស់ជាងរ៉េផ្លិចឥតលក្ខខណ្ឌ ។ រ៉េផ្លិចមានលក្ខខណ្ឌបង្កើតឡើងដោយកំរតិចខួរពោល គឺសកម្មភាពនៃសរសៃប្រសាទខាងលើ។ ដើម្បីបង្កើតរ៉េផ្លិចមានលក្ខខណ្ឌគេត្រូវមានលក្ខ-ខណ្ឌដូចតទៅ៖

**ចំពោះសត្វ** ៖ ត្រូវពឹងផ្អែកលើបទពិសោធន៍ដែលគេធ្លាប់មានពីមុនមក ។

**ឧទាហរណ៍ ៖** ពេលឮគេនិយាយពីស្វាយខ្ចី ធ្វើឱ្យអ្នកស្ដាប់ចេញទឹកមាត់។ នេះជារ៉េផ្លិចមានលក្ខខណ្ឌព្រោះមនុស្សអ្នកស្ដាប់នោះធ្លាប់បានហូបស្វាយពីមុនបានជាធ្វើឱ្យគេចេញទឹកមាត់ ។ ហើយម្ដងនេះទៀតរស់ជាតិជូរមិនបានប៉ះនឹងអណ្ដាតរបស់គេទេ គេគ្រាន់តែស្ដាប់ឮនឹងត្រចៀក ក៏ធ្វើឱ្យគេចេញទឹកមាត់ដែរ។

**ឧទាហរណ៍ ៖** សិស្សស្តាប់គ្រូធ្វើអត្ថធិប្បាយពីខ្លឹមសារមេរៀនមួយ សិស្សអាចកត់ត្រាបាននូវចំណុចសំខាន់ៗ នៃមេរៀនមកពីសិស្សមានចំណេះដឹង និងសមត្ថភាពពីមុនរួចមកហើយ ។

## ៣- ច្បាប់ផ្សេងៗនៃសកម្មភាពប្រព័ន្ធសរសៃប្រសាទ

គ្រប់សកម្មភាពទាំងអស់របស់ខួរក្បាល និងកំរតិចខួរស្តែងចេញតាមរយៈលំនាំពីរយ៉ាង គឺរំញោច និងការទប់រំញោច។ លំនាំទាំងពីរនេះមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នាជានិច្ច ហើយផ្សារភ្ជាប់នឹងប្រព្រឹត្តទៅតាមច្បាប់ដ៏ជាក់លាក់ដូចតទៅ ៖

### ក- ច្បាប់បម្លែងឱ្យទៅជាការទប់រំញោច

រំញោច គឺជាលំនាំចិត្តដែលធ្វើឱ្យមជ្ឈមណ្ឌលសរសៃប្រសាទ និងផ្នែកដែលទាក់ទងនឹងវាមានសកម្មភាពខ្លាំង ។ សភាពកើតឡើងនៃរំញោចដែលបណ្តាលឱ្យមានប្រតិកម្មមួយចំនួននៃសំពាង្គកាយដូចជា ចលនាសាច់ដុំ ការបញ្ចេញក្រពេញ ការបញ្ចេញសំឡេង ការបញ្ចេញកាយវិការ ការធ្វើអំពើ ឬចលនាទប់ទល់...។

**ឧទាហរណ៍ ៖** ធំក្លិនសម្លឈ្ងុយឆ្ងាញ់នាំឱ្យស្រក់ទឹកមាត់ឃ្លានបាយ នេះគឺជាការបញ្ចេញក្រពេញទឹកមាត់។ អ្នកបរបាញ់ឮសូរសត្វយំ ដើរសំដៅទៅទីកន្លែងនោះ ។ ពេលមូសខាំយកដៃទះមូស។ ពេលឮនរណាម្នាក់ហៅចំឈ្មោះ ងាកមុខទៅរកអ្នកនោះ ។

កាលណាមានរំញោច ចំណុចមួយនៅត្រង់កំរតិចខួរ ត្រូវរំញោចខ្លាំង ឬតិចទៅតាមកម្លាំងនៃរំញោចដែលមនុស្សទទួលបាន ។ កាលណារំញោចមានអាំងតង់ស៊ីតេខ្លាំងពេក ធ្វើអោយមនុស្សភ្ញាក់ព្រើត ។

**ឧទាហរណ៍ ៖** សំឡេងខ្លាំងពេកធ្វើឱ្យយើងភ្ញាក់ ចាក់ក្រឡេក ស្រែកសន្ធាប់។....

កាលណារំញោចមានកម្លាំងមិនសូវជាខ្លាំង ហើយដដែលៗច្រើនដងដូចគ្នានាំឱ្យរំញោចនោះ ត្រូវបានបម្លែងឱ្យទៅជាការទប់រំញោចទៅវិញ។

**ឧទាហរណ៍ ៖** សំឡេងដដែលៗរបស់រថភ្លើងធ្វើឱ្យអ្នកដំណើរដេកលក់ ។ ចម្រៀងបំពេររបស់ម្តាយធ្វើឱ្យកូនដេកលក់។ ស្នូររថភ្លើង( ជាវត្ថុភ្ញោច )ដដែលៗបម្លែងឱ្យទៅជាការទប់រំញោច( កូនដេកលក់ )។

រំញោច និង ការទប់រំញោចជាលំនាំផ្ទុយគ្នាតែវាធ្វើសកម្មភាពប្រព័ន្ធសរសៃប្រសាទរួមបញ្ចូលគ្នា ។ លំនាំទាំងពីរនេះជាប់ពាក់ព័ន្ធគ្នាជានិច្ច ។ លំនាំរបស់រំញោចក្តី លំនាំរបស់ការទប់រំញោចក្តី មិនអាចប្រព្រឹត្តទៅ ឬកើតឡើងតែឯកឯងបាននោះទេ ។ លំនាំទាំងពីរនេះកើតមានឡើងដោយសារំញោចពីខាងក្រៅ ឬខាងក្នុងខ្លួន នៅលើកំរតិចខួរ ។

**ឧទាហរណ៍ ៖** រំញោចខាងក្រៅខ្លួន (ធំក្លិនក្រអូបទឹកអប់ ឬក្លិនផ្កា ក្រឡេករកមើលអ្នកលាបទឹកអប់ ឬ  ក្រឡេករកមើល ផ្កា) ។ ការឮសូរចម្រៀង សំឡេងស្រែកហៅ។.....

រំញោចខាងក្នុងខ្លួន (ចុកពោះ កូរពោះ ឈឺក្រពះ ត្រូវរកគ្រូពេទ្យព្យាបាល)។...

### ខ- សំណាយ និងការផ្ដុំ

កាលណាមានរំញោចទៅនឹងកំរិតចខួរ ត្រង់ចំណុចណាមួយ គេនឹងមានការទប់រំញោចនៅត្រង់មុំនោះ ។ តែបើរំញោច ឬការទប់រំញោចនេះមិនស្ថិតនៅនឹងនរមួយកន្លែងទេ វាអាចរាលដាលទៅដល់ចំណុចដទៃទៀតពាសពេញ កំរិតចខួរ។ នេះគឺជាបាតុភូតនៃសំណាយ ។

**ឧទាហរណ៍ ៖** ឱម៉ាល់ទិច ការឈឺចាប់មិនមែនកើតឡើងតែត្រង់កន្លែងដែលវាទិចទេ វាអាចរាលដាលធ្វើឱ្យយើងឈឺចាប់ដល់ចំណុចផ្សេងៗទៀតក្នុងខ្លួនយើង ។

បើសិនជាអាំងតង់ស៊ីតេ ឬកម្លាំងនៃរំញោចមានកម្រិតមធ្យមពោល គឺមិនខ្លាំងពេក មិនខ្សោយពេក លំនាំនៃរំញោចនេះមិនឈប់នៅត្រង់ចំណុចតែមួយទេ តែវាអាចរាលដាលជុំវិញ កំរិតចខួរ ។ សំណាយនេះកើតឡើងយូរ ឬឆាប់ វាអាស្រ័យទៅតាមកម្លាំងដំបូងនៃរំញោចនោះឯង ។ ក្រោយពីលាតសន្ធឹងសាយភាយដល់ត្រង់ចំណុចព្រំដែនណាមួយដ៏ជាក់លាក់ លំនាំនៃរំញោចទាំងនេះក៏ផ្ដុំគ្នាត្រង់ចំណុចណាមួយពិតប្រាកដ ។ នេះជាបាតុភូតនៃការផ្ដុំរំញោច ឬការទប់រំញោច ។

**ឧទាហរណ៍ ៖** កុមារដែលរៀនសរសេរអក្សរផ្ចង់នៅថ្នាក់ដំបូង យើងសង្កេតឃើញថា ដងប៉ាការ ឬខ្មៅដៃរបស់វាហាក់ដូចជាបញ្ជាទៅខ្នងវាផង ទៅបបូរមាត់ផង ។ កាលណាវាគូសបន្ទាត់ឡើងលើ បបូរមាត់វាខើចឡើងលើ ។ កាលណាវាគូសងាកមកឆ្វេង ឬទៅខាងស្ដាំ វាខំផ្អៀងក ទៅតាម ហើយមាត់វាក៏វៀចតាមនោះដែរ ។

ទាំងនេះបង្ហាញឱ្យឃើញថានៅពេលកុមារផ្ដើមរៀនសរសេរអក្សរផ្ចង់ រំញោចលាតសន្ធឹងហួសព្រំដែនរបស់វាគឺ រំញោចមិនគ្រាន់តែស្ថិតនៅត្រង់មណ្ឌលចក្ខុ និងចលនាដៃរបស់កុមារប៉ុណ្ណោះទេ គឺរំញោចនោះវារាលដាលរហូតដល់ចលនាដងខ្លួន និងបបូរមាត់ទៀតផង ។ លុះដល់កុមារទម្លាប់សរសេររាល់ថ្ងៃទៅ រ៉េផ្លិចទាំងនោះអាចផ្ដាច់ពីគ្នាបានដោយសារតែការផ្ដុំនៃរំញោចត្រង់ចំណុចមួយដ៏សមស្រប ។ លក្ខណៈបែបនេះ ក៏បង្ហាញឱ្យឃើញដូចគ្នាដែរចំពោះមនុស្សធំដែលរៀនជិះកង់ ។

### គ- ច្បាប់ប្រតិឃាត

រំញោចមិនគ្រាន់តែមានសមត្ថភាពបង្កើតបានសំណាយ និងប្រមូលផ្ដុំ ដើម្បីទប់រំញោចប៉ុណ្ណោះទេ តែវាមានសមត្ថភាពផ្លាស់ប្ដូរគ្នាបាន និងជួយគ្នាទៅវិញទៅមកបានផង ។ ករណីបែបនេះហៅថា ប្រតិឃាត ឬអាំងឌុចស្យុងប្រាស់ ។ បាតុភូតប្រតិឃាតនេះ កើតមានឡើងនៅពេលណាដែលមានរំញោចត្រង់ចំណុចណាមួយនៃអឌ្ឍគោលខួរ ៗ កំរិតចខួរ ហើយរំញោចនោះឯងបង្កើតឱ្យមានការទប់ក្នុងតំបន់ជិតខាងនៃចំណុចនោះ ប្រាសមកលើរំញោចដែលរាលដាលនេះ ។

**ឧទាហរណ៍ ៖** កាលណាគេផ្ដោតអារម្មណ៍សម្លឹងមើលផ្ទាំងគំនូរមួយ គេហាក់ដូចជាស្ដាប់មិនឮសំឡេង ដែលកើតឡើងជុំវិញខ្លួនគេ ។ នេះបណ្ដាលមកពីតំបន់ដែលទាក់ទងនឹងចក្ខុន្ទ្រិយារម្មណ៍ មាន

រំញោចខ្លាំងទៅលើផ្ទាំងរូបភាព ហើយរំញោចនេះស្រូបយករំញោចអស់ពីសោតិន្ទ្រីយារម្មណ៍ នាំឱ្យតំបន់សោតិន្ទ្រីយារម្មណ៍ដែលទាក់ទងការស្ដាប់ ក្លាយទៅជាតំបន់ទប់ស្កាត់រំញោចទៅវិញ។

**ឧទាហរណ៍ផ្សេងទៀត ៖** ជក់អានសៀវភៅប្រលោមលោកទាល់តែភ្លេចហូបបាយ ។ ជក់អារម្មណ៍ស្ដាប់គ្រូពន្យល់ទាល់តែភ្លេចកត់ត្រា ឬក៏ផ្ដោតស្មារតីកត់ត្រាខ្លាំងពេក ភ្លេចស្ដាប់គ្រូ ។ កុមារកំពុងហូបបាយយ៉ាងឆ្ងាញ់ ពេលឃើញម្ដាយដែលបែកយូរ ក៏ទុកចានស្លាបព្រាចោល ហើយរត់ទៅឱបម្ដាយ ។

### គ- ច្បាប់នៃប្រព័ន្ធសកម្មភាពរបស់ ក័រតិចខួរ

ក្នុងលក្ខខណ្ឌនៃជីវភាពរស់នៅធម្មតា រំញោចមិនចេះតែកើតឡើងដោយឯកឯងនោះទេ ។ មានរំញោចមួយចំនួនអាចកើតឡើងក្នុងពេលដំណាលគ្នាមកលើសរីរាង្គឥន្ទ្រីយ៍របស់យើង ។ មជ្ឈមណ្ឌលសរសៃប្រសាទមិនអាចបំពេញមុខងារដាច់តែឯងបានទេក្នុងការទទួល និងធ្វើវិភាគទៅលើរំញោចទាំងនោះ ។ ដូចនេះ មជ្ឈមណ្ឌលសរសៃប្រសាទត្រូវមានទំនាក់ទំនងជាមួយនឹងមណ្ឌលទាំងឡាយផ្សេងទៀតនៅលើក័រតិចខួរដើម្បីផ្ដុំរំញោចនឹងទប់រំញោចនោះ ។ សំយោគនៅលើក័រតិចខួរអាចប្រមូលផ្ដុំរំញោច និងប្រតិកម្មដែលនៅដាច់តែឯងឱ្យទៅជាលំនាំមួយពេញលេញដែលគេហៅថាប្រព័ន្ធសកម្មភាពរបស់ក័រតិចខួរ ។ ការវិភាគ និងការធ្វើសំយោគនេះនាំឱ្យមានប្រតិកម្មនៃសព៌ាង្គកាយដែឆ្លើយតបទៅនឹងរំញោច ។ កាលណាយើងជំរុញសកម្មភាពនៃរំញោចមួយសេរីពីសព៌ាង្គកាយរបស់យើង ហើយយើងធ្វើអំពើដដែលនេះឱ្យបានច្រើនដង យើងនឹងបានរ៉េផ្លិចមួយសេរី ដែលកើតឡើងជាបន្តបន្ទាប់គ្នា ។ រ៉េផ្លិចដែលចេះតែប្រព្រឹត្តទៅបែបនេះបើយើងចេះហ្វឹកហ្វឺនវា នោះវានឹងបង្កើតបានជាស្តេរ៉េអូទីបឌីណាមិច ដែលជាមូលដ្ឋានសរីរៈនៃចំណេះធ្វើ អំពើស្វ័យប្រវត្តិ និងទម្លាប់។ ច្បាប់នេះមានអត្ថន័យសំខាន់ណាស់ចំពោះប្រព័ន្ធសកម្មភាពរបស់ក័រតិចខួរដែលគេចាត់ទុកថា ជាមូលដ្ឋានសកម្មភាពរបស់បាតុភូតចិត្ត។ ដោយសារច្បាប់ទាំងនេះ អ្នកប្រាជ្ញសរីរៈវិទ្យាបានស្រាវជ្រាវឃើញថាក័រតិចខួរគួបផ្សំគ្នាជាមួយណឺរ៉ូនរាប់ពាន់ដើម្បីក្ដាប់បាន និងត្រួតពិនិត្យព័ត៌មានបានយ៉ាងទៀងទាត់ទៅលើតំបន់ដែលមានរំញោច និងតំបន់ដែលទប់រំញោច។ តំបន់នីមួយៗមានសមត្ថភាពបម្លែងផ្សេងៗពីគ្នា។ វាអាចជាសំណាយ ជាការផ្ដុំ ឬជាប្រតិឃាត។

**ឧទាហរណ៍ ៖** សិស្សម្នាក់កំពុងធ្វើលំហាត់ធរណីមាត្រ។ មានមិត្តម្នាក់មកបបួលគេទៅដើរលេង។ គេមិនទៅទេ គេសុខចិត្តនៅធ្វើលំហាត់តទៅទៀត លុះត្រាតែក័រតិចខួរអាចធ្វើវិភាគ និងសំយោគបានរហូតទាល់តែគេអាចយល់ច្បាស់ទៅលើទ្រឹស្ដីបទ ឬរូបមន្តណាមួយនោះបានច្បាស់លាស់។

ស្នូរជួងធ្វើឱ្យសិស្សកើតមានប្រតិកម្មរ៉េផ្លិចមួយសេរីដូចជារៀបចំខ្លួនចូលថ្នាក់រៀន ឬចេញលេង ធ្វើពលកម្ម ហាត់ប្រាណ....។

### ៤- ប្រភេទផ្សេងៗ នៃសកម្មភាពរបស់ប្រព័ន្ធសរសៃប្រសាទប្រព័ន្ធសញ្ញាកម្មទាំងពីរ

ច្បាប់ទាំងអស់នៃសកម្មភាពរបស់ប្រព័ន្ធប្រសាទដូចបានរៀបរាប់មកនេះ ត្រូវបានរកឃើញដោយលោក ប៉ាវឡូវ ដែលធ្វើពិសោធទៅលើសត្វ ។ តាមទ្រឹស្តីរបស់គាត់ សកម្មភាពរបស់ប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស ក៏ប្រព្រឹត្តទៅតាមច្បាប់នោះដែរ ដោយគ្រាន់តែមនុស្សមានកម្រិតខ្ពស់ជាងសត្វប៉ុណ្ណោះ ។ សារពាង្គកាយរបស់យើងទទួលរំញោចដែលមានរូបភាពប្លែកៗ ទៅតាមស្ថានភាព ឬមជ្ឈដ្ឋានជុំវិញខ្លួនយើង។ រូបភាពរបស់វត្ថុ ឬបាតុភូតដែលប្រព្រឹត្តផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍របស់យើងបានរក្សារូបភាពរបស់វាឱ្យស្ថិតជាប់លើ អឌ្ឍគោលខួរ ។ រូបភាពវត្ថុ ឬបាតុភូតដែលយើងចាប់ផ្តើមស្គាល់ដំបូងបង្អស់ក្នុងជីវភាពរស់នៅ ហៅថា ប្រព័ន្ធសញ្ញាកម្មទី១ ។ ប្រព័ន្ធសញ្ញាកម្មទី១ នេះកើតមានទាំងមនុស្សទាំងសត្វ ។ បើសត្វគ្មានប្រព័ន្ធសញ្ញាកម្មទី១ នេះទេ បានន័យថាមនុស្សមិនអាចផ្សាំង ឬបង្ហាត់សត្វបានទេ។

**ឧទាហរណ៍ ៖** គុ ទូ កៅអី ឈ្មោះមនុស្ស ឈ្មោះទីកន្លែង ម៉ាករថយន្ត ម៉ាកម៉ូតូ ដែលយើងឃើញជាដំបូងត្រូវបានរក្សារូបភាពរបស់វានៅនឹងអឌ្ឍគោលខួរ ។ សត្វគោ ក្របី សេះ ដំរី ដែលមនុស្សពង្រាបបាន ឬផ្សាំងវាសម្រាប់ប្រើប្រាស់ និងសត្វស្វា ខ្លា តោ.. ដែលគេបង្ហាត់ឲ្យចេះលេងសៀក។

ប៉ុន្តែចំពោះមនុស្ស មានប្រព័ន្ធវាក្យស័ព្ទមួយចំនួនទៀតដូចជា ពាក្យ កន្សោមពាក្យ សំនួនវោហាស័ព្ទ បណ្តុំពាក្យដែលអាចឆ្លុះបញ្ចាំងបានជាប្រយោលទៅលើទំនាក់ទំនងគ្នារវាងវត្ថុ និងបាតុភូត ទៅតាមលក្ខណៈធម្មជាតិរបស់វា ។ ពាក្យសំដីពាក្យសរសេរ កន្សោមពាក្យ ដែលគេប្រើប្រាស់ដោយឆ្លុះបញ្ចាំងជាប្រយោលទៅលើវត្ថុ ឬបាតុភូតដែលគេធ្លាប់បាននិយាយ ឬបានស្គាល់រួចមកហើយនោះ គឺជាប្រព័ន្ធសញ្ញាកម្មទី២ ។

**ឧទាហរណ៍ ៖** គ្រូបង្រៀនសិស្សឱ្យស្គាល់ពីឈ្មោះបន្លែ ស្ពៃក្តោប ខាត់ណា ត្រប់ ប៉េងប៉ោះ ដោយបង្ហាញបន្លែទាំងនេះចំពោះមុខសិស្ស ។ សិស្សស្គាល់ឈ្មោះបន្លែទាំងនោះ ជាលើកដំបូងបង្អស់ ។ នេះជាប្រព័ន្ធសញ្ញាកម្មទី១ ។

រូបភាពបន្លែមទាំងនេះ ស្ថិតជាប់អឌ្ឍគោលខួរ ។ ពេលមួយដែលគ្រូរំឭកឡើងវិញពីឈ្មោះបន្លែទាំងនេះ សិស្សមានសមត្ថភាពស្គាល់ឡើងវិញបានតាមរយៈពាក្យ កន្សោមពាក្យ ឬមានសមត្ថភាពចងចាំហួតដល់អាចគូររូបបានឡើងវិញដោយមិនបាច់មើលឈ្មោះបន្លែដាក់ស្តែង។ ទាំងនេះនេះជាប្រព័ន្ធសញ្ញាកម្មទី២ ។

**ឧទាហរណ៍ ៖** ពេលភ្នែកមើលឃើញផ្លែស្វាយ រូបភាពផ្លែស្វាយជិតជាប់នៅក្នុងខួរក្បាល យើងឱ្យឈ្មោះថាប្រព័ន្ធសញ្ញាកម្មទី១ ។ សញ្ញាកម្មទី១ នេះត្រូវបានជំនួសដោយសញ្ញា ឮ ដែលយើងឱ្យឈ្មោះហៅថាអក្សរ នោះ គឺជាសញ្ញាកម្មទី២ (ផ្លែស្វាយ) ។

ប្រព័ន្ធសញ្ញាកម្មទាំងពីរនេះកើតមាន និងអភិវឌ្ឍឡើងនៅក្នុង ៖

- ការបង្រៀនសិស្សដោយប្រើសម្ភារឧបទេស
- លំនាំកាយពលកម្ម និងបញ្ញាពលកម្ម

- ការហ្វឹកហ្វឺនទៅលើវិស័យណាមួយ
- លំនាំអភិវឌ្ឍន៍នៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ
- លក្ខខណ្ឌចាំបាច់នៃជីវភាពរស់នៅក្នុងសង្គម
- លំនាំនៃការស្វែងយល់ ឬការស្តាប់មជ្ឈដ្ឋានជាច្រើន
- ទំនាក់ទំនងរវាងបុគ្គល និងបុគ្គលក្នុងសង្គម ។

## សន្និដ្ឋាន

ការសិក្សាពីទំនាក់ទំនងរវាងចិត្តវិទ្យា និងសរីរៈវិទ្យាអាចឱ្យយើងទទួលបានចំណេះដឹងជាច្រើន ស្តីពីមុខងាររបស់ប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស រ៉េផ្លិចលក្ខខណ្ឌ រ៉េផ្លិចឥតលក្ខខណ្ឌ និងប្រភេទផ្សេងៗនៃសកម្មភាពរបស់ ប្រព័ន្ធសរសៃប្រសាទ ជាពិសេសគឺយកមកអនុវត្តក្នុងការបង្រៀន និងរៀនប្រកបដោយជោគជ័យ ។

## សំណួរ

១- សរីរៈវិទ្យា និង ចិត្តវិទ្យា មានទំនាក់ទំនងនឹងគ្នាយ៉ាងដូចម្តេចខ្លះ?

២- តើប្រព័ន្ធសរសៃប្រសាទកណ្តាលមានមុខងារដូចម្តេចខ្លះ?

៣- ចូរបកស្រាយពីប្រព័ន្ធសរសៃប្រសាទបរិមណ្ឌល?

៤- តើណឺរ៉ូនមានមុខងារយ៉ាងដូចម្តេចខ្លះ?

៥- តើគ្រូត្រូវធ្វើដូចម្តេចខ្លះដើម្បីអោយសិស្សមានវ៉ៃឆ្លៃមានលក្ខខណ្ឌ?

៦- ចូរបកស្រាយច្បាប់បម្លែងអោយទៅជាការទប់រំញោច?

៧- តើច្បាប់នៃប្រព័ន្ធសកម្មភាពសរសៃប្រសាទមានសារៈប្រយោជន៍យ៉ាងណា ចំពោះមនុស្ស? សូមលើកឧទាហរណ៍មកបញ្ជាក់។

# មេរៀនទី៣ ៖ ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្ស

៚៙៚

## I- ធម្មជាតិរបស់មនុស្ស

### ក- អត្ថន័យនៃការសិក្សាអំពីធម្មជាតិរបស់មនុស្ស

មនុស្ស ជាកម្មវត្ថុសិក្សារបស់វិទ្យាសាស្រ្តជាច្រើនផ្សេងៗគ្នា ដូចជាសេដ្ឋកិច្ចនយោបាយ សិក្សាអំពីមនុស្សក្នុងឋានៈជាកម្លាំងផលិតកម្ម និងកម្លាំងនៃតម្រូវការគ្រឿងឧបភោគនិងសម្ភារ ប្រើប្រាស់។ បុរាណវិទ្យាសិក្សាពីកំណកំណើតមនុស្សទៅតាមសញ្ជាតិផ្សេងៗ និងតំបន់ប្លែកៗ ពីគ្នានៅលើភពផែនដី។ ចិត្តវិទ្យាសិក្សាអំពីសកម្មភាពផ្លូវចិត្តនិងសតិអារម្មណ៍របស់មនុស្ស។ មនុស្សក៏ជាកម្មវត្ថុរបស់គរុកោសល្យទូទៅនៅក្នុងវិស័យអប់រំផងដែរ។ បើយើងមិនយល់ពីធម្មជាតិពិតរបស់មនុស្ស នោះយើងក៏មិនយល់ និងមិនអាចបំពេញកិច្ចការបានល្អក្នុងឋានៈយើងជាអ្នកអប់រំ ជាអ្នកបណ្ដុះបណ្ដាលធនធានមនុស្សដែរ។ ការតម្រង់ទិសធ្វើឱ្យបុគ្គលិកលក្ខណៈរបស់មនុស្សអភិវឌ្ឍឡើង។ ការស្វែងយល់ស៊ីជម្រៅពីធម្មជាតិពិតរបស់មនុស្សជាការងារដ៏មានអត្ថប្រយោជន៍។ វិទ្យាសាស្រ្តអប់រំទាមទារឱ្យយើងជាគ្រូបង្រៀនត្រូវតែស្វែងយល់ពីធម្មជាតិនៃបុគ្គលិកលក្ខណៈរបស់មនុស្សគ្រប់ប្រភេទ (ទាំងល្អ ទាំងអាក្រក់)។ តើបុគ្គលិកលក្ខណៈរបស់គេមានការអភិវឌ្ឍយ៉ាងដូចម្ដេច? តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈ?

### ខ- ធម្មជាតិពិតរបស់មនុស្ស

ពួកមនោនិយមដែលមានជំនឿលើទេវៈ និងអាទិទេព គេជឿថាប្រភពរបស់មនុស្ស ឬធម្មជាតិពិតរបស់មនុស្សកើតមកពីអាទិទេពជាអ្នកបង្កើត ។ ទស្សនវិជ្ជានេះសម្រាប់ជាមូលដ្ឋាននៃសាសនាដែលប្រកាន់ជំនឿថា អាទិទេពជាអ្នកជប់មនុស្សឱ្យកើតនៅលើផែនដី។ ដើម្បីជួយសង្គ្រោះវិញ្ញាណខណ្ឌរបស់គេ គេត្រូវតែចូលទៅសូត្រធម៌ថ្វាយបង្គំព្រះអាទិទេពនៅក្នុងវិហារកាតូលិក ហើយនៅពេលដែលគេស្លាប់ទៅព្រលឹងរបស់គេនឹងទៅចាប់កំណើតនៅឋានសួគ៌ ហើយគេអាចរស់នៅប្រកបដោយសុភមង្គល។

លោក Hegel (1770-1831) ជាអ្នកប្រាជ្ញទស្សនវិជ្ជាតាមបែបតន្ដីនិយមដ៏មហិមាជនជាតិអាឡឺម៉ង់នៅសតវត្សទី១៩ អះអាងថា ពិភពលោក គឺជាលទ្ធផលនៃសកម្មភាព ដែលបង្កើតដោយអាទិទេពដ៏មានតេជានុភាព។ លោកថាឧត្ដមគតិមនុស្ស អភិវឌ្ឍដោយខ្លួនឯង ពេលដែលមនុស្សចាប់កំណើតនៅលើផែនដី។ ក្រោយមកក្នុងកំឡុងពេលដ៏យូរអង្វែង ឧត្ដមគតិនេះឈានទៅបង្កើតជាសង្គមមនុស្ស ។

លោក Ludwig Feuerbach (1904-1872) ជាទស្សនវិទូតន្ដីនិយមជនជាតិអាឡឺម៉ង់ដ៏ល្បីឈ្មោះចុងក្រោយគេបង្អស់ បានស្ដារឡើងវិញនូវគំនិតនេះក្នុងទស្សនៈសម្ភារនិយមរបស់គាត់ ។ លោកបានលើកឡើងថា «ធម្មជាតិមានអត្ថិភាពនៅខាងក្រៅខ្លួនមនុស្សទេ ធម្មជាតិជាសត្វលោកទី១ មុនគេបង្អស់ ហើយមិនស្ថិតនៅរណបអ្វីទាំងអស់ចំពោះមនុស្សវិញជាផ្នែកមួយនៃធម្មជាតិ និងជាផលិតផលនៃការអភិវឌ្ឍរបស់ធម្មជាតិទៅវិញទេ» ។

### ១- ទស្សនៈទានស្តីពីការប្រតិបត្តិ

ទស្សនៈទាននេះសំដៅលុបបំបាត់ចោលនូវចំណុចខ្សោយនៅក្នុងទស្សនវិជ្ជាមនោនិយម សម្ភារនិយម អត្តនោម័ត និងបរមេត្ថនិយម ។ ទស្សនៈប្រតិបត្តិនេះសង្កត់ធ្ងន់ទៅលើចរិតសកម្ម និងអត្តនោម័តរបស់មនុស្សនៅក្នុងទំនាក់ទំនងជាមួយធម្មជាតិ និងសង្គម ។ មនុស្សជាផលិតផលធម្មជាតិ និងជាផលិតផលមានកម្រិតខ្ពស់បំផុតនៅក្នុងដំណើរការអភិវឌ្ឍរបស់ធម្មជាតិ។ ដោយសារតែសកម្មភាពប្រតិបត្តិនេះហើយដែលមនុស្សអាចគ្រប់គ្រង និងប្រែក្លាយលោកបាន ។ មនុស្សមិនគ្រាន់តែប្រែក្លាយវត្ថុនៅក្នុងធម្មជាតិនោះទេ ប៉ុន្តែមនុស្សថែមទាំងបង្កើតវត្ថុថ្មីបានទៀតផង ។

### ២- ទស្សនៈទានស្តីពីធម្មជាតិរបស់មនុស្ស

ទស្សនៈទាននេះត្រូវបានកំណត់ឡើងដោយចំណងទាក់ទងគ្នាក្នុងសង្គមទាំងមូលកាលពីសម័យបុរាណ ។ ទស្សនវិជ្ជាសិក្សាពីធម្មជាតិរបស់មនុស្សដោយចាត់ទុកមនុស្សថាជាសត្វលោកដែលរស់នៅឯកោ ឃ្លាតឆ្ងាយពីចំណងទាក់ទងគ្នាក្នុងសង្គមពិតប្រាកដ ។

មនុស្សមានទិដ្ឋភាពពីរយ៉ាង គឺទិដ្ឋភាពសង្គម និងទិដ្ឋភាពជីវសាស្ត្រ ។ កាលណាគេនិយាយពីធម្មជាតិរបស់មនុស្ស គឺពិតជាត្រូវនិយាយពីធម្មជាតិរបស់សង្គមដែរ ។ ធម្មជាតិរបស់មនុស្សមិនមែនចរិតអរូបិយពីកំណើតដែលកើតមានចំពោះបុគ្គលម្នាក់ៗ ដោយឡែកពីគ្នា នោះទេ ។ នៅក្នុងចរិតដ៏ពិតប្រាកដធម្មជាតិរបស់មនុស្សត្រូវបានកំណត់ឡើងទៅតាមសំយោគនៃទំនាក់ទំនងរបស់គេក្នុងសង្គម ។ ក្នុងចំណោមទំនាក់ទំនងក្នុងសង្គមនេះ គឺមានទំនាក់ទំនងផលិតកម្មដែលផ្តល់នូវទង្វើមួយជាកំណត់ចំពោះធម្មជាតិរបស់មនុស្ស ។ មនុស្សប្រព្រឹត្តិលើធម្មជាតិដើម្បីប្រែក្លាយធម្មជាតិ ហើយក្នុងពេលដំណាលគ្នានោះមនុស្សចេះប្រែក្លាយខ្លួនឯងផង។ ដរាបណាដែលមនុស្សយើងបង្កើតធម្មជាតិ ដរាបនោះធម្មជាតិក៏ជួយបង្កើតមនុស្សវិញដែរ ។ មនុស្សប្រព្រឹត្តិលើសង្គម ហើយប្រែក្លាយលក្ខខណ្ឌរបស់សង្គម ។ ទង្វើរបស់មនុស្សស្តែងចេញឱ្យឃើញក្នុងវិស័យនៃសកម្មភាពជាច្រើន ហើយសកម្មភាពទាំងនោះមានកម្រិតផ្សេងៗពីគ្នា ។ មនុស្សមិនគ្រាន់តែមានទង្វើត្រាប់តាមគ្នាប៉ុណ្ណោះទេ ក៏ប៉ុន្តែមនុស្សមានគំនិតច្នៃប្រឌិតដោយឡែកៗពីគ្នាផងដែរ ។ មនុស្សអាចធ្វើឱ្យសមត្ថភាពរបស់ខ្លួនអភិវឌ្ឍឡើងដោយសេរី ។ ទង្វើរបស់មនុស្សអាស្រ័យទៅតាមរបបគ្រប់គ្រងរបស់សង្គម ។

សរុបសេចក្តីមក ធម្មជាតិពិតរបស់មនុស្ស គឺសំដៅអះអាងថាមនុស្សមានចរិតសកម្មហើយអត្តនោម័ត ។ ទន្ទឹមនឹងនេះដែរ ធម្មជាតិរបស់មនុស្សត្រូវកំណត់ឡើងតាមរយៈការសំយោគនៃទំនាក់ទំនងរបស់គេក្នុងសង្គម ។ ដូច្នេះមនុស្សមានចរិតសង្គមប្រវត្តិផងដែរ ។ បើនិយាយពីធម្មជាតិរបស់មនុស្ស គេមិនអាចកាត់ផ្តាច់មនុស្សចេញពីលក្ខខណ្ឌសង្គមបានទេ ។ ការស្វែងយល់ពីធម្មជាតិរបស់មនុស្សធ្វើឱ្យអ្នកអប់រំមានគំនិតសុទិដ្ឋិនិយម ។

## II- លំនាំនៃការអភិវឌ្ឍ

### ក- សញ្ញាណស្តីពីការអភិវឌ្ឍ

គរុកោសល្យស្វែងយល់ពីការអភិវឌ្ឍរបស់មនុស្ស រីឯការអប់រំមានភារកិច្ចផ្តល់នូវការតម្រង់ទិសដ៏ល្អដល់ការអភិវឌ្ឍនៃបុគ្គលិកលក្ខណ កម្រិតយល់ដឹង និងសីលធម៌របស់មនុស្ស ។ ដូចនេះមានទស្សនៈពីរយ៉ាងដែលលើកឡើងពីការអភិវឌ្ឍរបស់មនុស្ស ៖

**ទស្សនៈទី១** ៖ ចាត់ទុកការអភិវឌ្ឍមនុស្សជាលំនាំមួយនៃបំលាស់ប្តូរសរីរាង្គ និងចិត្តគំនិត ហើយទស្សនៈនេះមិនបានបកស្រាយពន្យល់ពីប្រភពនៃការអភិវឌ្ឍបានទេ ។

**ទស្សនៈទី២** ៖ ចាត់ទុកការអភិវឌ្ឍរបស់មនុស្ស ថាជាលំនាំមួយដ៏ស្មុគស្មាញនៃការផ្លាស់ប្តូរបន្តវេនខាងផ្នែកគុណភាព និងបរិមាណដែលក្នុងនោះកត្តាចាស់ៗហួសសម័យត្រូវបានគេបំភ្លេចចោល ឯកត្តាថ្មីៗ ជឿនលឿននៃបុគ្គលិកលក្ខណៈចេះតែអភិវឌ្ឍឡើង ។ ទំនាស់បាតុភូតចិត្តខាងក្នុងខ្លួនជាមូលហេតុនៃការអភិវឌ្ឍ ហើយតាមរយៈដំណោះស្រាយនៃបដិបក្ខនេះធ្វើឱ្យមនុស្សឆ្លងកាត់ពីបរិមាណទៅគុណភាព ខាងផ្នែកសីលធម៌វិជ្ជជីវៈ ក៏ដូចជាកម្រិតវប្បធម៌ និងបុគ្គលិកលក្ខណចុះសម្រុងក្នុងសង្គម។

### ខ- លំនាំនៃការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្ស

កម្មវត្ថុអប់រំ និងបណ្តុះបណ្តាលធនធានមនុស្ស គឺសិស្សដែលកំពុងរីកលូតលាស់ផ្នែកសរីរាង្គកាយ និងបុគ្គលិកលក្ខណៈ ។ លំនាំនៃការអភិវឌ្ឍនៃបុគ្គលិកលក្ខណរបស់សិស្សប្រព្រឹត្តិទៅពេញមួយជីវិត។ លំនាំនៃការអភិវឌ្ឍនេះ រួមមានបំលាស់ប្តូរផ្នែកសរីរាង្គកាយ និងចិត្តទាំងបរិមាណទាំងគុណភាព ។ បំលាស់ប្តូរផ្នែកសរីរាង្គកាយមានដូចជា ការលូតលាស់ធំធាត់ ការលូតលាស់សាច់ដុំ ប្រពន្ធ័សរសៃប្រសាទ ប្រពន្ធ័សាច់ដុំ ប្រពន្ធ័ឆ្អឹង និងសរីរាង្គខាងក្នុងខ្លួន ។ល។ បំលាស់ផ្លូវផ្នែកផ្លូវចិត្ត មានទំនាក់ទំនងជាដំបូងទៅនឹងការអភិវឌ្ឍសតិអារម្មណ៍។ ការបណ្តុះបណ្តាលផ្នែកចិត្តគំនិតរបស់បុគ្គលម្នាក់ៗ ការបណ្តុះបណ្តាលគុណសម្បត្តិល្អៗ ក្នុងសង្គមដ៏ចាំបាច់ដើម្បីឱ្យមនុស្សចុះសម្រុងក្នុងសង្គម ។

ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗចាប់ពីវ័យកុមារទៅជាលំនាំដ៏ស្មុគស្មាញ លំនាំនេះប្រព្រឹត្តិទៅ ក្រោមឥទ្ធិពលនៃទង្វើខាងក្រៅខ្លួន និងកម្លាំងចលករខាងក្នុងខ្លួនដែលបង្កើតបានជាជំហរជាមូលដ្ឋានគ្រឹះរបស់សិស្សម្នាក់ៗ ក្នុងឋានៈខ្លួនជាសមជិកដែលកំពុងចម្រើនវ័យ ។ ដូច្នេះក្នុងលក្ខខណ្ឌនៃជីវភាពរស់នៅ និងមជ្ឈដ្ឋានអប់រំដូចគ្នាសិស្សម្នាក់ៗកំពុងចម្រើនវ័យ មានការអភិវឌ្ឍផ្នែកបុគ្គលិកលក្ខណដោយឡែកៗពីគ្នា ។ កោសិកាដែលឪពុកម្តាយផ្តល់ឱ្យកូនម្នាក់ៗ ពីកំណើតមានឥទ្ធិពលខ្លាំងណាស់ទៅលើអត្តចរិតនៃប្រតិកម្មខាងក្នុងខ្លួន ។ កោសិកាទាំងនេះហើយដែលផ្តល់នូវប្រភេទសកម្មភាព និងកម្រិតនៃការអភិវឌ្ឍរបស់ប្រពន្ធ័ប្រសាទខុសប្លែកពីគ្នាដែលចេញឱ្យឃើញនូវភាពដោយឡែកៗ ពីគ្នានៃការអភិវឌ្ឍខាងផ្លូវចិត្តគំនិតរបស់សិស្សម្នាក់ៗ ។ ក្នុងលំនាំនៃការអភិវឌ្ឍសិស្សមានទំនាស់ជាមួយនឹងកម្លាំងឥទ្ធិពលខាងក្រៅខ្លួន ដែលធ្វើឱ្យពួកគេត្រូវសម្របសម្រួលជាមួយមជ្ឈដ្ឋានជុំវិញ។ ដូច្នេះ មនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការតម្រង់ទិសទៅតាមតថភាពសត្យានុម័តក្នុងមជ្ឈដ្ឋានរស់នៅ ហើយអាចកំណត់បាននូវការអភិវឌ្ឍនៃបុគ្គលិកលក្ខណរបស់ខ្លួននៅក្នុងលក្ខខណ្ឌកាន់តែប្រសើរឡើង ។

តាមទ្រឹស្តីរបស់លោក Pavlov ការអភិវឌ្ឍបុគ្គលិលក្ខណៈរបស់សិស្សម្នាក់ៗ គឺជាអន្តរកម្មរវាងលំនាំសរសៃប្រសាទខាងក្នុងខ្លួន និងទង្វើខាងក្រៅខ្លួនទៅតាមឥទ្ធិពលនៃតថភាពជុំវិញខ្លួនដែលធ្វើអំពើឥតឈប់ឈរមកលើបុគ្គលម្នាក់ៗ ដែលលោកPavlov ហៅថានេះជាលំនាំដែលមានស្ថេរភាពរវាងរាងកាយ និងមជ្ឈដ្ឋានជុំវិញខ្លួន ។ ការអភិវឌ្ឍបុគ្គលិកលក្ខណសិស្សជាលំនាំនៃបដិបក្ខដ៏ស្មុគស្មាញដែលទទួលរងឥទ្ធិពលពីកត្តាបួន គឺកត្តាតំនពូជ កត្តាមជ្ឈដ្ឋានរស់នៅ កត្តាសកម្មភាពផ្ទាល់ខ្លួន និងកត្តាអប់រំ ។ ថ្វីបើកត្តាទាំងបួននេះមានអន្តរកម្មនឹងគ្នា ហើយជះឥទ្ធិពលរួមទៅលើការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្សក៏ដោយ ក៏យើងជាអ្នកអប់រំត្រូវសិក្សាស្វែងយល់ និងពិនិត្យពិចារណាឱ្យបានដាច់ដោយឡែកអំពីឥទ្ធិពលនៃកត្តានីមួយៗនេះ ។

## III- **កត្តាដែលជះឥទ្ធិពលដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈ**

### **ក- កត្តាតំណពូជ**

មនុស្សទទួលឥទ្ធិពលពីកំណើតនិងតំណពូជដែលជាពន្លករូបធាតុពីធម្មជាតិ ជាពិសេសគឺ លក្ខណៈនៃរូបរាងកាយ និងសរីរៈរបស់ខួរក្បាលព្រមទាំងប្រពន្ធ័សរសៃប្រសាទ ។ ទាំងនេះជាការផ្តល់កំណាកំណើតចំពោះកូនចៅនូវចំណុចជីវសាស្ត្រដូចគ្នាបេះបិទទៅនឹងឪពុកម្តាយ ។ កត្តាពីកំណើតមិនមែនជាកត្តាមិនអាចប្រែប្រួលបានហើយក៏មិនមែនជាកត្តាដែលកំណត់លក្ខខណ្ឌដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈដែរ ។ នៅពេលដែលកើតពីផ្ទៃម្តាយ កុមារម្នាក់ៗ មានកត្តាពីកំណើត និងកត្តាតំណពូជជាកំណត់កាត់តាមឪពុកម្តាយ ដូចជាពណ៌ភ្នែក សក់ ស្បែក ទម្រង់មុខជាដើម ។ លក្ខណៈពិសេសខ្លះទៀតរបស់ប្រពន្ធ័ប្រសាទក៏អាចកាត់តាមឪពុកម្តាយដែរ ។

បើយោងតាមលោក Pavlov តាំងពីកំណើតមនុស្សតែងតែមានលក្ខណៈ និងសភាវគតិពីកំណើតស្រាប់ ។ លក្ខណៈនិងសភាវគតិទាំងនេះស្ថិតនៅរណបនឹងរ៉េផ្លិចឥតលក្ខខណ្ឌដែលក្នុងចំណោមរ៉េផ្លិចទាំងនោះមានការចេះហូបបាយ ចេះផឹកទឹក ការបញ្ចេញទឹកមាត់ពេលឃើញចំណីអាហារ ការដកដៃចេញពីប៉ះកំដៅ និងការបិទភ្នែកពេលត្រូវពន្លឺចាំងជាដើម ។ លក្ខណៈដោយឡែករបស់មនុស្សមានដូចជាចលនាឈរ ការអភិវឌ្ឍភាសា  សមត្ថភាពគិតនិង ការងារ ហើយអាចអភិវឌ្ឍបាននៅពេលដែលមនុស្សមានទំនាក់ទំនងជាមួយមនុស្សឯទៀត ក្នុងសង្គមតែប៉ុណ្ណោះ ។

**ឧទាហរណ៍** ៖ កុមារ Amala និង Kamala ដែលម្តាយយកទៅចោលក្នុងព្រៃ ហើយរស់នៅជាមួយសត្វខ្លាឃ្មុំអស់រយៈពេលច្រើនឆ្នាំ ក្រោយមកត្រូវបានគេរកឃើញ ក្នុងតំបន់ Cashemire គេសង្កេតឃើញក្មេងទាំងពីរបាត់បង់គុណសម្បត្តិជាមូលដ្ឋានរបស់មនុស្សក្នុងសង្គមទាំងស្រុង ដូចជាមិនចេះនិយាយ ចេះដើរជើងបួន បាត់បង់សមត្ថភាពក្នុងការគិតជាដើម ។

ក្នុងករណីនេះ បញ្ជាក់ឱ្យឃើញថា ការអភិវឌ្ឍនៃកំណាកំណើតរបស់មនុស្សទាមទារឱ្យមានលក្ខខណ្ឌសង្គម និងទំនក់ទំនងសង្គម ។ ពេលមនុស្សរស់នៅក្នុងសង្គមសត្វ មនុស្សត្រូវបាត់បង់បុគ្គលិកលក្ខណៈ ជាមនុស្សរស់នៅក្នុងសង្គមមនុស្ស ។ គេដឹងច្បាស់ថា កុមារខ្លះ នៅពេលចាប់ផ្តើមចូលរៀនក្នុង

សាលាគេមាននិស្ស័យខាងតូរ្យតន្ត្រី ឬខាងគំនូរ ឬខាងគណិតវិទ្យា ឬខាងអក្សរសិល្ប៍តែម្តង ។ ត្រង់នេះបញ្ជាក់ថានិស្ស័យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅ នឹងលក្ខណៈពិសេសខាងផ្លូវចិត្តរបស់បុគ្គល ដោយពឹងផ្អែកលើប្រត្យក្សារម្មណ៍ ការគិត លំនឹក រូបារម្មណ៍ និងលក្ខណៈចិត្តផ្សេងទៀតរបស់បុគ្គលម្នាក់ៗ ។ ដូចជាកូនអ្នកចម្រៀងដ៏ល្បី ឈ្មោះម្នាក់ មិនបានហាត់ចៀងពីកុមារ ធ្វើឱ្យកត្តាពីកំណើត និងតំណពូជត្រូវបាត់បង់អស់ កូននោះ មិនបានក្លាយជាតារាចម្រៀងល្បីដូចឪពុកទេ តែផ្ទុយទៅវិញកូនកសិករដ៏ក្រីក្រដែល ស្រឡាញ់ និងព្យាយាមសិក្សាតាំងពីកុមារ អាចក្លាយទៅជាអ្នកមានមុខមាត់បាន ។

ចិត្តវិទ្យានិងគរុកោសល្យ មិនបានប្រានចោលនិស្ស័យពីកំណើត ឬតំណពូជរបស់បុគ្គលដែលមាននិស្ស័យកម្រិតខ្ពស់ទេ ។ ម្យ៉ាងទៀតចិត្តគរុកោសល្យអះអាងថាសម្បទារបស់បុគ្គលម្នាក់ៗអាចស្តែងឱ្យឃើញ និងអភិវឌ្ឍបានល្អ ឬមិនបានល្អ វាអាស្រ័យទាំងស្រុងទៅលើលក្ខខណ្ឌនៃជីវភាពរស់នៅ និងការអប់រំបណ្តុះបណ្តាលបុគ្គលឯណោះវិញទេ ។ លក្ខខណ្ឌទាំងនេះ កំណត់ឱ្យដឹងថា តើសិស្សានុសិស្ស ត្រូវបានយកមកអប់រំបណ្តុះបណ្តាលទៅតាមរូបភាពនៃសម្មភាពសមស្របទៅនឹងនិស្ស័យរបស់គេឬក៏អត់ ។ ចិត្តវិទូអាមេរិចកាំង E. Thorndike បាន អះអាងថា ស្នាដៃល្អក្នុងការសិក្សារបស់សិស្សខ្លះ ដែលគាត់យកមកប្រៀបធៀបគ្នារវាងជនជាតិស្បែកស និងស្បែកខ្មៅ គឺថាជនជាតិស្បែកសរៀនបានស្នាដៃខ្ពស់ជាង ។ គុណសម្បត្តិ ផ្លូវចិត្ត ផ្លូវកាយ និងនិស្ស័យ មានឥទ្ធិពលណាស់ក្នុងការអភិវឌ្ឍនៃបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ ។

## ខ- មជ្ឈដ្ឋានសង្គម

មជ្ឈដ្ឋានសង្គម គឺជាសំនុំនៃបាតុភូតប្លែកៗ គ្នាខាងក្រៅខ្លួនរបស់បុគ្គលហើយដែលធ្វើអំពើដោយឯកឯងមកលើបុគ្គល ។ បាតុភូតទាំងនេះជះឥទ្ធិពលខ្លាំងណាស់ចំពោះការអភិវឌ្ឍនៃបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ ។ មជ្ឈដ្ឋានធម្មជាតិ ឬមជ្ឈដ្ឋានភូមិសាស្ត្រ រួមមានអាកាសធាតុ លក្ខខណ្ឌធម្មជាតិ និងប្រភពនៃភោគទ្រព្យធម្មជាតិ ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើរបៀបរបបរស់នៅក្នុងតំបន់ដែលមានអាកាសធាតុក្តៅសើម ហើយមានវិស័យកសិកម្មកំពុងអភិវឌ្ឍ ។ លក្ខខណ្ឌភូមិសាស្ត្រខុសប្លែកគ្នានេះក៏មានឥទ្ធិពលពិតប្រាកដទៅលើអត្តចរិតរបស់មនុស្សផងដែរ ។ ឥទ្ធិពលនៃមជ្ឈដ្ឋានគ្រួសារសិស្សក៏ដូចជាមជ្ឈដ្ឋានសង្គម តែងតែជះឥទ្ធិពលខ្លាំងមកលើការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់សិស្ស ។ តាមទស្សនៈគរុកោសល្យកត្តាមជ្ឈដ្ឋានសង្គម ជាកត្តាមួយដ៏សំខាន់បំផុត និងជាកត្តាដែលមានកំណត់នាំមុខកត្តាផ្សេងទៀត ។ បើគ្មានមជ្ឈដ្ឋាន សង្គមគ្មានទំនាក់ទំនងក្នុងសង្គម នោះមនុស្សមិនអាចរស់នៅសក្តិសមជាមនុស្សពិតប្រាកដឡើយ ។ គ្មានទំនាក់ទំនងក្នុងសង្គម ក៏គ្មានទំនាក់ទំនងប្តូរបទពិសោធន៍ ។ មជ្ឈដ្ឋានសង្គមមានដូចជា គ្រួសារ សាលារៀន សមូហភាព សហគមន៍ ក្រុមអាជ្ញាធរ អង្គការ សមាគមនានា ទីផ្សារ វិស័យពាណិជ្ជកម្ម ឧស្សាហកម្ម ស្ថាប័ន...ហើយមជ្ឈដ្ឋានធម្មជាតិមានដូចជា តំបន់ភ្នំ ព្រៃដងស្ទឹងអូរ បឹងបួរ ទឹកធ្លាក់ ខ្ពស់រាប វាលទំនាប ស្រុកស្រែចំការ...។ល។

**ឧទាហរណ៍** ៖ បើកុមារចម្រើនវ័យក្នុងមជ្ឈដ្ឋានកម្មករ ឬកសិករក្រីក្រ នោះច្បាស់ជាគេមិនមានតម្រូវការផ្នែកវប្បធម៌ដូចកុមារដែលជាកូនបញ្ញវន្ត កូនមន្ត្រីរាជការ ឬកូនអ្នកមានទេ ។

### គ- សកម្មភាពផ្ទាល់ខ្លួន

ដើម្បីឱ្យបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ អភិវឌ្ឍបានល្អប្រសើរនោះ សកម្មភាពបុគ្គលមានតួនាទីសំខាន់ណាស់ព្រោះបើបុគ្គលមិនធ្វើសកម្មភាពទេ នោះបុគ្គលិកលក្ខណៈល្អ ក៏បុគ្គលមិនអាចអភិវឌ្ឍបានឡើយ ។ មនុស្សត្រូវធ្វើសកម្មភាពយ៉ាងទៀងទាត់ដើម្បីមានអត្ថិភាព និងមានអន្តរកម្មជាមួយបុគ្គលេទៀតក្នុងសង្គម ។ មនុស្សកើតមកមានសភាវគតិមួយសម្រាប់ការការពារទប់ទល់នឹងទង្វើដែលធ្វើឱ្យអន្តរាយដល់ជីវិត ។

តាមទស្សនៈសង្គមប្រវត្តិ គឺដោយសារសកម្មភាពបុគ្គលនៅក្នុងការប្រតិបត្តិនេះហើយដែលជម្រុញឱ្យមនុស្សឈានទៅសម្រេចបាននូវចំណេះដឹងដោយខ្លួនឯង ទៅតាមទិដ្ឋភាព ផ្សេងៗគ្នាដូចជាសុខភាពផ្លូវកាយ មូលដ្ឋានចំណេះដឹង សម្បទា បំណិនប្រសប់ ចរិតលក្ខណៈ គុណសម្បត្តិ សីលធម៌...។ ដោយសារសកម្មភាពធ្វើឱ្យមនុស្សអាចកែសម្រួលគុណវិបត្តិ និងអភិវឌ្ឍទៅមុខបាន ។ សកម្មភាពរបស់មនុស្សខុសប្លែកពីសត្វស្រឡះ ព្រោះសត្វមានតែ សភាវគតិប៉ុណ្ណោះ មិនមានការគិតកម្រិតខ្ពស់ដូចមនុស្សទេ ។ សកម្មភាពរបស់មនុស្ស មុនដំបូង គឺត្រូវឱ្យសមស្របជាមួយនឹងតម្រូវការសត្យានុម័តនៃសារពាង្គកាយដែលទាមទារឱ្យមាន តម្រូវការធម្មជាតិ ។ ប៉ុន្តែបុគ្គលិកលក្ខណៈរបស់មនុស្សត្រូវបានបណ្តុះបណ្តាលសន្សឹមៗ ជាមួយនឹងតម្រូវការ ការត្រេកអរ និន្នាការ និងឥរិយាបថសង្គមដ៏ពិតប្រាកដ ។ ការស្តែងចេញនូវទង្វើបែបណាមួយនោះ ត្រូវឱ្យមានលក្ខណៈសមស្របទៅនឹងទង្វើក្នុងមជ្ឈដ្ឋានសង្គម ។ មនុស្សដ៏សកម្មមានសកម្មភាពប្រតិបត្តិដែលមានឥទ្ធិពលជាកំណត់ទៅលើជីវភាពរស់នៅ និងការអភិវឌ្ឍរបស់បុគ្គល ។ មនុស្សកែប្រែធម្មជាតិ និងសង្គមតាមរយៈសកម្មភាពប្រតិបត្តិរបស់ខ្លួន ហើយក្នុងចំណោមសកម្មភាពទាំងនេះ សកម្មភាពដែលមានមូលដ្ឋានគ្រឹះដ៏សំខាន់ បំផុតនោះ គឺការងារផលិតកម្ម ។ ដើម្បីឱ្យសកម្មភាពប្រកបដោយថាមពលល្អ គេត្រូវកំណត់ឱ្យបាននូវការតម្រង់ទិសដ៏ល្អប្រសើរ និងកម្លាំងចលករដ៏ត្រឹមត្រូវ ។ ក្មេងនៅបឋមសិក្សាលេងល្បែងកំសាន្ត គឺជាសកម្មភាពដ៏សំខាន់ជាងគេ ។ សកម្មភាពសិក្សារបស់សិស្សមានដូចជា ល្បែងកំសាន្ត ការសិក្សា ការងារផលិតកម្ម សកម្មភាពសង្គម សកម្មភាពសិល្បៈ សកម្មភាពកីឡា និងសកម្មភាពផ្សេងៗទៀត ដែលស្ថិតនៅក្របខណ្ឌបណ្តុះបណ្តាលធនធានមនុស្ស ។ សាលារៀន ត្រូវបានរៀបចំសកម្មភាពសិស្សម្នាក់ៗ និងសមូហភាពសិស្សឱ្យបានសមស្រប ហើយប្រើប្រាស់សកម្មភាពទាំងនោះជាមធ្យោបាយអប់រំ ។

### ឃ- ការអប់រំ

មជ្ឈដ្ឋានអប់រំជាទង្វើមួយដែលកើតឡើងនៅខាងក្រៅខ្លួនបុគ្គលសម្រាប់ជម្រុញឱ្យបុគ្គលមានការអភិវឌ្ឍ ។ ការអប់រំតម្រង់ទិសទៅរកគោលបំណង នៃការអភិវឌ្ឍបុគ្គលិក លក្ខណៈរបស់បុគ្គលទៅតាមលំនាំមួយដែលអាចឱ្យយើងដឹងបានពីមុនពីលទ្ធផលនៃការអប់រំ ។ ការអប់រំក៏បានគ្រោងទុកជាមុនដែរនូវជម្រើស មធ្យោបាយអប់រំ វិធីអប់រំ និងរូបភាពរៀបចំកម្មវិធីអប់រំសំដៅធ្វើឱ្យបានសម្រេចនូវគោលបំណងដែលបានកំណត់ទុជាមុន គឺប្រកបដោយ លទ្ធផលល្អជាអតិបរិមា ។

ការអប់រំ និងការអភិវឌ្ឍបុគ្គលិកលក្ខណៈ មានចំណងទាក់ទងគ្នាយ៉ាងស្មុគស្មាញ ។ ការអភិវឌ្ឍនៃបុគ្គលិកលក្ខណៈ អាចប្រព្រឹត្តិទៅដោយមិនចាំបាច់មានការអប់រំតម្រង់ទិសជាកំណត់ ។ ក្មេងទទួលបានការអប់រំពីមនុស្សនៅជុំវិញខ្លួនពួកគេ ។ ដើម្បីកែប្រែសមត្ថភាពឱ្យទៅជាសម្បត្តិផ្ទាល់ខ្លួន ត្រូវមានលក្ខខណ្ឌដ៏សមរម្យ ពោល គឺការអប់រំដែលត្រូវបានរៀបចំឡើង ទៅតាមកម្មវិធីដែលមានកម្មវត្ថុជាកំណត់ ។ ការអប់រំ កំណត់បាននូវការស្តែងចេញឱ្យឃើញ និងការពង្រីកនូវទំហំរបស់ទ្រង់ទ្រាយនៃទង្វើចំពោះនិស្ស័យ និងសមត្ថភាពបុគ្គល ។ តាមរយៈទង្វើនៃការអប់រំនិស្ស័យដ៏ទន់ខ្សោយរបស់បុគ្គលក៏អាចអភិវឌ្ឍបានដែរ ។ ផ្ទុយទៅវិញការអប់រំ មិនល្អ អាចរារាំងទប់ស្កាត់ការអភិវឌ្ឍនៃនិស្ស័យរបស់បុគ្គល ដែលគេកត់សំគាល់ឃើញរួចស្រាប់មកហើយ ឬក៏អាចធ្វើឱ្យនិស្ស័យដ៏ទន់ខ្សោយរបស់បុគ្គលសាបរលាបបាត់បង់បាន ។ ដូច្នេះ ភារកិច្ចដ៏សំខាន់របស់គ្រូ គឺត្រូវកត់សំគាល់ និងមើលសកម្មភាពក្រៅសាលារបស់សិស្សដែលជាមធ្យោបាយមួយដ៏សំខាន់សម្រាប់ជួយគ្រូឱ្យមើលឃើញ និងត្រួតពិនិត្យបានទៅលើនិស្ស័យ ព្រមទាំងសមត្ថភាពរបស់គេដែលកំពុងអភិវឌ្ឍ ។ ការអភិវឌ្ឍនិស្ស័យ និងសមត្ថភាព របស់សិស្ស នៅក្នុងវិស័យសកម្មភាពប្រតិបត្តិខុសៗគ្នា ។ ម្យ៉ាងទៀតដើម្បីឱ្យនិស្ស័យរបស់មនុស្សមានការអភិវឌ្ឍទៅតាមសមត្ថភាព និងក្លាយជាបុគ្គលមានបំនិន បុគ្គលនោះត្រូវការ ឱ្យមានសមត្ថភាពខ្ពស់ និងគ្រប់គ្រាន់ក្នុងការងារ ព្រមទាំងសេចក្តីស្រឡាញ់ជាប់ចិត្តនឹងការងារ នោះផង ។ ការអប់រំអាចនឹងសម្រេចបានស្នាដៃល្អ តាមរយៈវិធីបង្រៀន និងវិធីអប់រំ ហើយឆ្លុះបញ្ចាំងឱ្យឃើញជានិច្ចនូវនយោបាយដឹកនាំរបស់របបគ្រប់គ្រងសង្គម ។ ការអប់រំក្នុងសាលារៀនត្រូវបានពង្រឹងឱ្យមានគុណភាពល្អ លុះត្រាតែរាជរដ្ឋាភិបាលចេះគួបផ្សំគ្នាទៅនឹងការអប់រំតាមរយៈមធ្យោបាយប្រើប្រាស់បណ្តាញផ្សព្វផ្សាយព័ត៌មាន ។ ប្រពន្ធ័ផ្សព្វផ្សាយត្រូវតែសហការរៀបចំពង្រឹងគុណភាពអប់រំឱ្យមានប្រសិទ្ធភាព ជាពិសេសការអប់រំកុមារ ។ ហាមដាច់ខាត ផ្សព្វផ្សាយព័ត៌មានអវិជ្ជមាន (វប្បធម៌បទេស ឃាតកម្ម ចាប់ជំរិត រំលោភ ចោរកម្ម ល្បែងស៊ីសង ការជួញដូរពេស្យាចារ) ដែលសុទ្ធតែជាការជះឥទ្ធិពលអាក្រក់ដល់ការអប់រំមនុស្សវ័យជំទង់ និងយុវជនទាំងនៅក្នុងគ្រួសារ និងទាំងនៅសាលារៀន។

សាលារៀន ត្រូវតែរៀបចំ និងអប់រំសិស្សដើម្បីជួយឱ្យពួកគេត្រៀមខ្លួនប្រឈមមុខប្រយុទ្ធនឹងហេតុការណ៍ និងបាតុភូតប្រកបដោយគ្រោះថ្នាក់ ។ អ្នកអប់រំត្រូវជួយសិស្សឱ្យប្រកាន់ឥរិយាបថត្រឹមត្រូវ នៅចំពោះមុខហេតុការណ៍ និងបាតុភូតអវិជ្ជមានទាំងឡាយនៅក្នុងសង្គម ។ ប្រសិនណាជាការអប់រំសិស្សក្នុងសាលាក៏ដូចជាការបណ្តុះបណ្តាលធនធានមនុស្ស ឬការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់សិស្សគ្មានប្រសិទ្ធភាព នោះបណ្តាលមកពីកំហុសឆ្គងនៅក្នុងខ្លឹមសារនៃកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនព្រមទាំងការអប់រំរបស់គ្រូ ។ គ្រូមិនមានឥទ្ធិពល ឬខ្វះសមត្ថភាពក្នុងការងារអប់រំសិស្ស ឬមិនយល់ពីអន្តរកម្មរវាងកត្តាតំនពូជ កត្តាមជ្ឈដ្ឋានរស់នៅ កត្តាគ្រួសារ កត្តាសកម្មភាពផ្ទាល់ខ្លួន និងកត្តាអប់រំក្នុងសាលារៀនដោយណែនាំសិស្សឱ្យចេះប្រយុទ្ធប្រឆាំងនឹងឥទ្ធិពលអាក្រក់នៅក្រៅសាលារៀន ។ គរុកោសល្យត្រូវរួមចំណែកទទួលខុសត្រូវទាំងស្រុងក្នុងករណីនេះ ។

## IV- **រចនាសម្ព័ន្ធនៃបុគ្គលិកលក្ខណៈ**

ចិត្តវិទូបានចាត់ទុករចនាសម្ព័ន្ធបុគ្គលិកលក្ខណៈ ជាប្រពន្ធ័មួយ ដែលមានធាតុសំខាន់ៗពីរគួបផ្សំគ្នា គឺគុណធម៌ និងសម្បទា ។ ពួកចិត្តវិទូខ្លះទៀតបានកំណត់រចនាសម្ព័ន្ធបុគ្គលិកលក្ខណៈរបស់បុគ្គលមាន៤ គឺទំនោរ អត្តចរិត ឫកពា និងសម្បទា ។

**ក- ទំនោរ**

ទំនោរ ជាលក្ខណៈចិត្តដ៏ស្មុគស្មាញ និងជាកម្លាំងចលករខាងក្នុងផ្លូវចិត្តដែលបុគ្គលកំណត់ជ្រើសរើសយកឥរិយាបទ និងចរិតសកម្មចំពោះមជ្ឈដ្ឋានរស់នៅ ព្រមទាំងតថភាព សត្យានុម័ត ។ ទំនោរជាកម្លាំងចលករដែលតម្រង់ទិសបុគ្គលឱ្យមានទង្វើតាមទិសដៅណាមួយ ។

**ឧទាហរណ៍** ៖ កសិករមានទំនោរជ្រើសរើសយកពូជធញ្ញជាតិល្អសម្រាប់ការដាំដុះបានផលច្រើន។ អ្នកចូលចិត្តអក្សរសាស្ត្រ មានទំនោររកឯកសារទាក់ទងអក្សរសាស្ត្រច្រើន សម្រាប់ទុកអាន ។ អ្នកស្រឡាញ់មុខរបរគ្រូបង្រៀន ព្យាយាមប្រឡងចូលសាលាគរុកោសល្យ ។ ទំនោររបស់បុគ្គលស្តែងចេញឱ្យឃើញតាមរយៈតម្រូវការ ចំណង់ចំណូលចិត្ត លោកទស្សនៈ និងឧត្តមគតិ ។

**១- តម្រូវការ**

តម្រូវការជាធាតុមួយដ៏សំខាន់របស់ទំនោរ ។ តម្រូវការជាសំណូមពរ និងជាបំណងប្រាថ្នាដែលមានភាពចាំបាច់សម្រាប់ជួយមនុស្សឱ្យមានជីវភាពរស់នៅដ៏សមស្រប និងចុះសម្រុងក្នុងសង្គម។

**ឧទាហរណ៍** ៖ បុគ្គលមានតម្រូវការម្ហូបឆ្ងាញ់ពិសាសម្រាប់ពេលអាហារ ។ តម្រូវការនេះជម្រុញឱ្យបុគ្គលខិតខំទៅរកភោជនីយដ្ឋាន ឬកន្លែងលក់ម្ហូបអាហារល្អៗ និងឆ្ងាញ់ៗ ។ មនុស្សម្នាក់ៗ មានតម្រូវការច្រើនប្រភេទណាស់ តាមលោក Maslow (១៩៨៧) ជឿថាបុគ្គលម្នាក់ៗ មានតម្រូវការប្លែកៗពីគ្នា ។ លោកបានធ្វើចំណាត់ថ្នាក់របស់បុគ្គលទៅតាមឋានានុក្រម ។ តម្រូវការទាំងនោះមានដូចខាងក្រោម ៖

- តម្រូវការផ្នែកជីវសាស្ត្រ ៖ មានដូចជាតម្រូវការខ្យល់អាកាសល្អ ទឹកស្អាត ហូបចុក ជម្រក ការដេក ការស្លៀកពាក់ជាដើម ។
- តម្រូវការផ្នែកសុវត្ថិភាព ៖ មានដូចជា ការរស់នៅមានសន្តិសុខល្អ កន្លែងធ្វើការនិងសា លារៀនមិនមានការគំរាមកំហែង ។ល។
- តម្រូវការផ្នែកសេចក្តីស្រឡាញ់និងកម្មសិទ្ធិ ៖ ដូចជារបស់ប្រើប្រាស់ ឃើញស្អាតល្អ ទិញយកប្រើធ្វើជាកម្មសិទ្ធិ ការស្រឡាញ់រវាងឪពុកម្តាយ កូន ប្តីប្រពន្ធ និយោជកនិងនិយោ ជិក គ្រូនិងសិស្ស ។ល។
- តម្រូវការផ្នែកតម្លៃផ្ទាល់ខ្លួន ៖ បុគ្គលខ្លះចង់ឱ្យគេគោរព និងវាយតម្លៃដ៏សមស្របមកលើសមត្ថភាពខ្លួន និងជីវភាពរស់នៅរបស់ខ្លួន ។
- តម្រូវការផ្នែកបញ្ញា ៖ បុគ្គលស្វែងរកការសិក្សា និងស្រាវជ្រាវបណ្តុះបណ្តាលជំនាញណាមួយសម្រាប់អនាគតរបស់ពួកគេ ។

- តម្រូវការផ្នែកសិល្បវិទ្យា ៖ បុគ្គលត្រូវការតុបតែងកាយ គេហដ្ឋាន រថយន្ត ការស្លៀក ពាក់ ឱ្យបានស្អាតល្អទៅតាមចំណង់ចំណូលចិត្តរបស់ពួកគេ ។
- តម្រូវការផ្នែកអត្ថិភាវូនីយកម្ម ៖ បុគ្គលប្រាថ្នាចង់បានអាយុវែង ឱ្យប្រកាន់យកជំនឿ សាសនាផ្សេងៗ។




*Source*: BitSize Learning

### ២- ចំណង់ចំណូលចិត្ត

ចំណង់ចំណូលចិត្តស្តែងចេញឱ្យឃើញនូវឥរិយាបថរបស់បុគ្គលចំពោះវត្ថុទាំងឡាយដែលធ្វើឱ្យគេមានការជាប់ជំពាក់ចិត្ត ចង់បានជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយមានអត្ថន័យសំខាន់ណាស់សម្រាប់ជីវភាពរស់នៅរបស់គេ ។

**ឧទាហរណ៍** ៖ បុគ្គលចូលចិត្តខាងសិល្បៈចំរៀង គេចូលចិត្តច្រៀង ហើយគេប្រាថ្នាចូលរួមរៀងប្រឡងយកស្នាដៃជាដើម ។

### ៣- លោកទស្សនៈ

លោកទស្សនៈជាប្រពន្ធ័ទស្សនៈ ឬជាបញ្ញត្តិផ្ទាល់ខ្លួនរបស់បុគ្គល ចំពោះសង្គម ចំពោះធម្មជាតិ និងចំពោះមនុស្សឯទៀតក្នុងសង្គម ។ លោកទស្សនៈជាត្រីវិស័យនៃសកម្មភាពបុគ្គល លោកទស្សនៈកំណត់ឥរិយាបថរបស់បុគ្គលម្នាក់ៗ ចំពោះតថភាពសត្យានុម័ត ។ លោក ទស្សនៈ ជាមូលដ្ឋានគ្រឹះនៃសីលធម៌ និងគុណធម៌របស់បុគ្គលម្នាក់ៗ ។

**ឧទាហរណ៍** ៖ បុគ្គលមានទស្សនៈស្អប់អំពើពុករលួយ និងបក្សពួកនិយម ស្អប់ការកាប់បំផ្លាញព្រៃឈើ ស្អប់សត្រូវ ឈ្លានពានទឹកដី ។ល។

### ៤- ឧត្តមគតិ

ឧត្តមគតិ ជារូបភាពដ៏ល្អឥតខ្ចោះរបស់បុគ្គល និងសង្គម ។ ឧត្តមគតិជាកម្លាំងចិត្តរបស់បុគ្គលដែលប្រកាន់យកគោលដៅមួយក្នុងឆាកជីវិតរបស់គេ ។ ឧត្តមគតិជារូបភាពមួយនៃការ ស្រមៃហើយសណ្ឋិតជាប់បានយូរណាស់ក្នុងសតិអារម្មណ៍របស់បុគ្គល ។ ឧត្តមគតិ ជាគោលដៅដែលមានលក្ខណៈសកម្មក្នុងជីវិតបុគ្គល ។ ឧត្តមគតិពេលខ្លះផ្សារភ្ជាប់ទៅនឹងភាពអណ្តែតអណ្តូង ហើយនិងការពិត ។

**ឧទាហរណ៍** ៖ ឧត្តមគតិរបស់ពលរដ្ឋខ្មែរម្នាក់ៗ គឺស្រឡាញ់សន្តិភាព សេរីភាព ឯករាជ្យភាព និងលទ្ធិប្រជាធិបតេយ្យ ។

សរុបមកឧត្តមគតិ ជាធាតុដ៏សំខាន់នៃទំនោរផង និងជាចលករផងដែលបានដឹកនាំ និងជម្រុញលើរាល់សកម្មភាពរបស់មនុស្សដើម្បីឈានទៅសម្រេចបានតាមគោលដៅ ។

### ខ- អត្តចរិត

អត្តចរិត ជាលក្ខណៈចិត្តរបស់បុគ្គល ។ អត្តចរិតស្តែងឱ្យឃើញតាមរយៈឥរិយាបថ ឬអាកប្បកិយា និងជីវភាពរស់នៅក្នុងសង្គម ។ បុគ្គលម្នាក់ៗ មានអត្តចរិតដោយឡែកពីគ្នា ។ សមាជិកក្នុងគ្រួសារតែមួយ ឬសិស្សដែលរៀនក្នុងថ្នាក់តែមួយ មិនអាចមានអត្តចរិតដូចគ្នាបបេះបិទនោះទេ ។ អត្តចរិតរបស់បុគ្គលម្នាក់ៗ ត្រូវបានគេវាយតម្លៃទៅតាមសីលធម៌ ដូចជាអត្តចរិតល្អ អត្តចរិតស្លូតបូត អត្តចរិតមិនស្មោះត្រង់ ។ អត្តចរិតល្អជាគុណសម្បត្តិ ឯអត្តចរិតមិនល្អជាគុណវិបត្តិរបស់បុគ្គលម្នាក់ៗ ។

**ឧទាហរណ៍** ៖ មករៀនទាន់ពេល ព្យាយាមសិក្សា មានស្មារតីទទួលខុសត្រូវ គោរពពាក្យសច្ចៈ សុភាពរាបសារ រួសរាយរាក់ទាក់ ចេះគួរសម សុទ្ធតែជាគុណសម្បត្តិ ហើយភាពអាត្មានិយម ក្រអឺតក្រទម មិនស្មោះត្រង់ និយាយមិនទៀង ... ជាគុណវិបត្តិ ។

ក្នុងឆាកជីវិតរបស់បុគ្គលម្នាក់ៗ អត្តចរិតអាចត្រូវបានបុគ្គលនោះពង្រឹងដោយខ្លួនគេ តែអត្តចរិតអាចផ្លាស់ប្តូរទៅតាមលក្ខខណ្ឌនៃសង្គម និងតាមរយៈការអប់រំលត់ដំ។ ចំពោះ សិស្សអត្តចរិត ពិតជាអាចផ្លាស់ប្តូរបាន តាមរយៈការអប់រំនិងទម្លាប់។ អត្តចរិតរបស់បុគ្គល ម្នាក់ៗ គួបផ្សំគ្នាដោយឥរិយាបថបីយ៉ាងដូចជា ឥរិយាបថចំពោះសង្គម ឥរិយាបថចំពោះការ ងារ និងឥរិយាបថចំពោះខ្លួនឯង។

### គ- ឫកពា

ឫកពា ជាលក្ខណៈចិត្តរបស់បុគ្គលម្នាក់ៗដែលស្តែងចេញឱ្យឃើញនូវលក្ខណៈដោយឡែកនៃអាកប្បកិរិយា និងសកម្មភាពបុគ្គល ។ ក្នុងជីវភាពរស់នៅរាល់ថ្ងៃ គេសង្កេតឃើញចិត្ត គំនិតអ្នកជិតខាងស្តែងចេញតាមរយៈសកម្មភាព ទង្វើ ទឹកមុខ និងកាយវិកាប្លែកៗពីគ្នា ។ ឆ្លងតាមរយៈសកម្មភាពសង្កេត

តាមដាននេះ គេឃើញបុគ្គលមានអត្តចរិតមិនដូចគ្នាទេ ។ ក្នុងករណីនេះ គេកំណត់បានថាបុគ្គលម្នាក់ៗមានឫកពាខុសគ្នា ។

**ឧទាហរណ៍** ៖ សិស្សក្នុងថ្នាក់រៀនមួយមានការបំផុសគំនិតធ្វើការដូចគ្នា ។ សិស្សខ្លះធ្វើការបានយ៉ាងឆាប់រហ័សដោយខ្លួនឯង សិស្សខ្លះទៀតពិភាក្សាជាមួយមិត្តភក្តិ តែនៅទីបំផុតកិច្ចនោះបានបញ្ចប់ដូចៗគ្នា ។ ក្នុងករណីនេះ ទោះបុគ្គលត្រូវធ្វើសកម្មភាពឱ្យដូចៗ គ្នាក៏ដោយ តែឫកពារបស់បុគ្គលមិនដូចគ្នាទេ ។ លក្ខណៈនៃអាកប្បកិរិយាខុសគ្នាបែបនេះ ដែលគេហៅថាឫកពា ។

តាមការបកស្រាយពីឫកពារបស់លោក Hypocrates ដែលលោកជាគ្រូពេទ្យជនជាតិក្រិចដ៏ល្បីល្បាញ ដោយសំអាងទៅលើវត្ថុរាវបួនប្រភេទ ដែលមាននៅក្នុងខ្លួនមនុស្សដូចតទៅ ៖

**ប្រភេទទី១** ៖ ឫកពាចិត្តមុត ឬឈាមរាវ ចំពោះអ្នកដែលមានឈាមច្រើន គឺជាប្រភេទ មនុស្សឫកពាសកម្ម ហើយក្លៀវក្លា។

**ប្រភេទទី២** ៖ ឫកពានៃចិត្តរឹងប៉ឹង ចំពោះអ្នកដែលមានជាតិអ៊ុយម៉ររច្រើន គឺជាប្រភេទមនុស្សមានឫកពានឹងនរ មិនងាយប្រឡេតខឹង។

**ប្រភេទទី៣** ៖ ឫកពាកាច ចិត្តស្រាល ចំពោះអ្នកដែលមានទឹកប្រមាត់លឿងច្រើនក្នុងថ្លើម គឺជាប្រភេទមនុស្សដែលមានឫកពាឆាប់ស្រៀវ ឆាប់ប្រឡេតខឹង ឬឆាប់ឆេវឆាវ។

**ប្រភេទទី៤** ៖ ឫកពាព្រួយច្រើន ឬអណ្តែតអណ្តូង ចំពោះអ្នកដែលមានទឹកប្រមាត់ខ្មៅច្រើនក្នុងថ្លើម ជាប្រភេទមនុស្ស ដែលព្រួយបារម្ភ សង្រេងសង្រៃ ហើយចូលចិត្តនៅម្នាក់ឯង ។

ក្រោយមកមានសរីរៈវិទូជាតិរូស្សីដ៏ល្បីឈ្មោះ គឺលោក Pavlov (1846-1936) បានបកស្រាយពន្យល់ ពីភាពខុសគ្នានៃឫកពា ដោយសំអាងទៅលើសកម្មភាពនៃប្រពន្ធ័សរសៃប្រសាទ ។ សកម្មភាពប្រពន្ធ័សរសៃប្រសាទ មានលំនាំពីរគឺរំញោច និងការទប់រំញោច ។ ចំពោះបុគ្គលលំនាំទាំងពីរនេះ អាចបណ្តាលឱ្យមានសកម្មភាពសរសៃប្រសាទខ្លាំង ឬខ្សោយ មានលំនឹង ឬគ្មានលំនឹងរហ័សរហួន ឬមិនរហ័សរហួន ។ សកម្មភាពនៃសរសៃប្រសាទបែបនេះ ជាមូលដ្ឋានសរីរវិទ្យា នៃការសម្តែងចេញជាឫកពារបស់បុគ្គល ។ លោកក៏បានណត់ប្រភេទឫក ពារបស់មនុស្សមានចំនួន៤ដែរគឺ ៖

**ប្រភេទទី១** ៖ បុគ្គលដែលមានសកម្មភាពសរសៃប្រសាទខ្លាំង មានលំនឹង រហ័សរហួនស្វាហាប់ ចិត្តមុតឈាមរាវ ឆាប់ភ្ញាក់រលឹក ឆាប់យល់ដឹងភ្លាមៗ ហើយឆាប់មានសញ្ចេតនា រួសរាយរាក់ទាក់ណាស់ ហើយជាបុគ្គលដែលងាយនឹងសម្របខ្លួន តាមមជ្ឈដ្ឋានថ្មី ។

**ឧទាហរណ៍** ៖ សិស្សដែលមានទឹកមុខរួសរាយ រហ័សរហួន ចេះសម្របសម្រួលទៅតាមវិន័យសាលា ឆាប់យល់មេរៀន ធ្វើឱ្យគ្រូស្រឡាញ់ពេញចិត្ត ។ តម្រូវការប្រភេទសិស្សនេះ គឺសកម្មភាព ថ្មី ហើយប្លែកៗ ។

**ប្រភេទទី២** ៖ បានដល់បុគ្គលដែលមានសកម្មភាពសរសៃប្រសាទខ្លាំង មានលំនឹង តែមិនរហ័សរហួន ចិត្តរឹងប៉ឹង មិនងាយបត់បែន ស្ងប់ស្ងៀម ប្រុងប្រយ័ត្ន ស្ថិតស្ថេរ ចេះពិចារ ណាថ្លឹងថ្លែងគ្រប់ជ្រុងជ្រោយសិន មុននឹងសម្រេចចិត្តធ្វើកិច្ចការណាមួយ។

**ឧទាហរណ៍** ៖ សិស្សដែលមានអត្តចរិតស្ងប់ស្ងៀម ព្យាយាមសិក្សា ស្តាប់គ្រូ រៀនបានស្នាដៃល្អ ។ សិស្សប្រភេទនេះ ចេះគោរពកោតខ្លាចគ្រូ សញ្ញាតនាជាមួយគ្រូមិនងាយបាត់បង់ ។

**ប្រភេទទី៣** ៖ រំញោចលើសការទប់បានដល់បុគ្គលដែលមានសកម្មភាពសរសៃប្រសាទខ្លាំង ខ្វះលំនឹង ឆាប់ខឹងឆេវឆាវ ឆាប់ច្រឡោត កាចហើយចិត្តស្រាលណាស់ ឆាប់មាន ប្រតិកម្មចំពោះឧបសគ្គ ស្មោះត្រង់មិនលាក់លៀម ចិត្តភ្លើងចំបើង ខ្វះស្មារតីម្ចាស់ការ តែឆាប់ រំសាយកំហឹង។

**ឧទាហរណ៍** ៖ សិស្សដែលមិត្តភក្តិលេងសើចឆាប់ច្រឡោតខឹង សិស្សដែលធ្វើកិច្ចការដោយ តក់ក្រហល់ ទៅតាមការយល់ដឹងរបស់ខ្លួន ។

**ប្រភេទទី៤** ៖ រំញោចក៏ខ្សោយការទប់រំញោចក៏ខ្សោយបានដល់បុគ្គលដែលមានសកម្មភាព សរសៃប្រសាទខ្សោយ ប្រភេទឫកពាខ្វល់ខ្វាយច្រើន គិតច្រើន អណ្តែតអណ្តូង ស្លូតបូត ខ្វះទំនុកចិត្តលើ ខ្លួនឯង ឆាប់អស់សង្ឃឹមនៅចំពោះមុខបរាជ័យ ពិបាកសម្របសម្រួលពេល ទៅរស់នៅមជ្ឈដ្ឋានថ្មី ។

**ឧទាហរណ៍** ៖ សិស្សមានចរិតឧស្សាហ៍ព្យាយាម តែទុយមុយនៅ ចំពោះមុខមនុស្សច្រើន មិន ហានបញ្ចេញមតិយោបល់ ។ សិស្សប្រភេទនេះ ឆាប់ភ័យ ខ្វះសេចក្តីក្លាហាន បើធ្វើលំហាត់ ឬវិញ្ញាសាបាន ពិន្ទុតិចឆាប់អស់សង្ឃឹម ។

**ឃ- សម្បទា**

សម្បទា គឺជាលទ្ធផលដែលកើតចេញពីលក្ខខណ្ឌសង្គមប្រវត្តិ និងការអប់រំ ។ សម្បទាកើត និងរីក លូតលាស់នៅក្នុងសកម្មភាពព្យាយាមប្រតិបត្តិទៅតាមចំណង់ចំណូលចិត្ត និងតម្រូវការរបស់បុគ្គល ។ សម្បទាជាលក្ខណៈចិត្តរបស់បុគ្គល ហើយជាលក្ខខណ្ឌនៃបំនិន ប្រសប់ដ៏ចាំបាច់ ដើម្បីធ្វើសកម្មភាព អនុវត្តជាក់ស្តែងឱ្យបានល្អប្រសើរ ។ បុគ្គលអនុវត្តសកម្ម ភាពទៅតាមទង្វើដោយមានសម្បទាជាមូល ដ្ឋាន។ កាលណាបុគ្គលថ្មីក្នុងសកម្មភាពប្រតិបត្តិដ៏ល្អ គេទៅជាមានបំនិនប្រសប់ ។ បំនិនប្រសប់តាមមុខ វិជ្ជាជីវៈណាមួយធ្វើឱ្យបុគ្គលមានបទពិសោធន៍ និងសម្បទាផ្ទាល់ខ្លួនកម្រិតខ្ពស់ ។ សិស្សមធ្យមសិក្សា ម្នាក់ៗ មិនអាចមានសម្បទាគ្រប់មុខវិជ្ជាឯកទេសបានទេ ។ បុគ្គលដែលប្រកបមុខវិជ្ជាជីវៈដូចគ្នា ឬសិស្ស ដែលរៀនពូកែ ខាងមុខវិជ្ជាឯកទេសណាមួយដូចគ្នា ក៏មិនអាចមានសម្បទាដូចគ្នាបេះបិទដែរ ។

**ឧទាហរណ៍** ៖ សិស្សម្នាក់ ដែលមានសម្បទាខាងគណិតវិទ្យា មិនអាចមានសម្បទាខាងអក្សរ សិល្ប៍ឡើយ សិស្សពីរនាក់ ដែលរៀនពូកែខាងរូបវិទ្យា គីមីវិទ្យា ក៏មិនមានសម្បទាដូចគ្នាដែរ ។

សម្បទា ត្រូវបានគេចែកជាបីកម្រិតដូចខាងក្រោម ៖

- សម្បទា ឬកម្រិតជម្មតា
- កោសល្យ ឬកម្រិតខ្ពស់
- ទេពកោសល្យ ឬកម្រិតខ្ពស់បំផុត

## សំណួរ

១- ដូចម្តេចដែលហៅថាអភិវឌ្ឍក្នុងន័យចិត្តវិទ្យា?

២- តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈ?

៣- ដូចម្តេចដែលហៅថាទំនោរ? តើទំនោរមានជាតុសំខាន់ៗដូចម្តេចខ្លះ? ចូរពន្យល់។

៤- ចូរពន្យល់ពីតម្រូវការតាមឋានានុក្រមរបស់លោក Maslow?

៥- តើលោក Hypocrates និងលោក Pavlov បានពន្យល់ឫកពាដូចម្តេចខ្លះ?

៦- តើរចនាសម្ព័ន្ធបុគ្គលិកលក្ខណៈមានអ្វីខ្លះ? ចូរពន្យល់ពីចំណុចនីមួយៗដោយសង្ខេប។

# មេរៀនទី៤ ៖ លក្ខណៈពិសេសវ័យជំទង់

## I- វត្ថុបំណង

ក្រោយពីបញ្ចប់មេរៀននេះ សិស្សនឹង ៖

- រៀបរាប់ពីលក្ខណៈរបស់វ័យជំទង់ទាំងសរីរាង្គកាយ និងផ្លូវចិត្ត
- សរសេរខ្លឹមសារសង្ខេបពីការអភិវឌ្ឍផ្នែកចិត្តគំនិត និងរាងកាយរបស់ជំទង់។ អធិប្បាយបានត្រឹមត្រូវនូវទំនាក់ទំនងរបស់ជំទង់ក្នុងសង្គម
- ឱ្យតម្លៃខ្ពស់ និងយកចំណេះដឹងដែលទទួលបានពីលក្ខណៈពិសេសរបស់ជំទង់ ទៅអនុវត្តក្នុងវិជ្ជាជីវៈរបស់ខ្លួន និងក្នុងជីវភាពរស់នៅ។

## II- សេចក្តីផ្តើម

ក្នុងការរស់នៅប្រចាំថ្ងៃ ឪពុកម្តាយ អាណាព្យាបាល និងគ្រូបង្រៀនតែងជួបប្រទះបញ្ហាជាច្រើនដែលវ័យជំទង់បានបង្កឡើងជារឿយៗ ។ អាស្រ័យហេតុនេះ គឺវាទាមទារឱ្យឪពុកម្តាយ អាណាព្យាបាល និង គ្រូបង្រៀន យល់ដឹងពីលក្ខណៈពិសេសរបស់វ័យជំទង់ដើម្បីអប់រំពួកគេឱ្យក្លាយជាពលរដ្ឋល្អ ពលរដ្ឋជំនាញ និងពលរដ្ឋថ្លៃថ្នូរនៅក្នុងសង្គម ។

## III- ខ្លឹមសារ

### ១- ទស្សនៈទូទៅស្តីពីវ័យជំទង់

វ័យជំទង់គិតពីអាយុ១៤-១៥ឆ្នាំ ដល់១៧-១៨ឆ្នាំ ។ មានទស្សនៈជាច្រើនបានចាត់ទុកវ័យជំទង់ជាវ័យដែលមានការវិវត្តផ្លូវចិត្ត និងសរីរាង្គ ។ ក្នុងជីវិតមនុស្សទាំងមូល វ័យជំទង់ជាវ័យដែលត្រូវគេទិចតៀន ស្តីបន្ទោសច្រើនជាងគេ ។ ក្នុងក្របខណ្ឌចិត្តវិទ្យា ពពួកចិត្តវិទូសិក្សាស្វែងយល់លើ ៖

- ការវិវត្តផ្នែករាងកាយ
- ការវិវត្តផ្នែកចិត្តគំនិត ឬ អត្តមនសិការ
- ការវិវត្តផ្នែកសកម្មភាពសិក្សា និងសកម្មភាពក្នុងសង្គម
- ការសេពគប់ជាមិត្តភក្តិវ័យស្រករគ្នា
- ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈជំទង់ឱ្យចុះសម្រុងក្នុងសង្គម
- ចំណង់ចំណូលចិត្តចំពោះវិជ្ជាជីវៈក្នុងសង្គម
- វ័យជំទង់ជាវ័យឆ្លងកាត់ពីកុមារភាព ទៅរកវ័យគ្រប់ការ ។

ហើយពពួកចិត្តវិទ្យាក៏សិក្សាស្វែងយល់ទៅលើវ័យជំទង់ទៅតាមក្រឹត្យក្រមចិត្ត-សង្គម គួបផ្សំជាមួយក្រឹត្យក្រមជីវសាស្ត្រ និងឥទ្ធិពលនៃមជ្ឈដ្ឋានសង្គម ។ ក្នុងវ័យនេះ ជំទង់ជួបប្រទះនឹងបញ្ហាច្រើនណាស់ ។ ឪពុកម្ដាយជាច្រើនបានពិនិត្យពិច័យឃើញថា កាលកូនរបស់គាត់ឈានដល់វ័យនេះ កូនរបស់គាត់ត្រូវឆ្លងកាត់គុណវិបត្តិជាច្រើន ។ ជារឿយៗ ក្មេងជំទង់ច្រើនមិនស្ដាប់បង្គាប់មនុស្សចាស់ដែលមានភាពស្និតស្នាលជាមួយគេ ។

## ២- បន្លាស់ប្ដូរផ្នែកសរីរាង្គកាយ

វ័យជំទង់ ជាវ័យឈានទៅរកវ័យគ្រប់ការ និងវ័យមនុស្សចាស់ ។ មុខងារផ្លូវចិត្ត និងសរីរាង្គកាយដ៏ថ្មីស្រឡាងរបស់វ័យជំទង់បានលេចធ្លោឡើង គួរឱ្យកត់សម្គាល់មានដូចតទៅ ៖

- ចាប់ពីអាយុ១៣-១៤ឆ្នាំឡើងទៅ គេឃើញមានលេចមុន នៅលើផ្ទៃមុខ
- សំឡេងចាប់ផ្លាស់ប្ដូរពីសំឡេងកុមារទៅជាគ្រលរបន្តិច
- ចំពោះជំទង់ជាក្មេងស្រី ចាប់ផ្ដើមមានឈាមរដូវពីអាយុ១២-១៤ឆ្នាំទៅ
- កត់សម្គាល់ឱ្យឃើញនូវភាពគ្រប់ការចំពោះជំទង់ប្រុស ស្រីបែបនេះ បានលេចធ្លោឱ្យឃើញនូសភាព ចិត្តថ្មីមួយ។

ជំទង់ដឹងខ្លួនឯងថា គេមិនមែនស្ថិតក្នុងវ័យកុមារទៀតទេ ។ គេកំពុងបោះជំហានទៅរកវ័យមនុស្សចាស់ ។ សញ្ចេតនាក៏កើតឡើងនៅក្នុងញាណរបស់គេដែរ ។ ជាទូទៅ នៅក្នុងជីវភាពរស់នៅនៃវ័យជំទង់ទាំងពីរប្រភេទ គេពិនិត្យឃើញមានដំណាក់កាលបីយ៉ាងលេចធ្លោឡើង ៖

- មុនវ័យគ្រប់ការ
- ចូលវ័យគ្រប់ការ
- ការវិវត្តទៅរកការបញ្ចប់វ័យគ្រប់ការ។

ប៉ុន្តែក្នុងវ័យនេះ ជំទង់ត្រូវឆ្លងកាត់តែពីរដំណាក់កាលទេ គឺមុនវ័យគ្រប់ការ និងវ័យគ្រប់ការ ។ ក្នុងប្រទេសមូលធនដែលកំពុងអភិវឌ្ឍខ្លាំង ភាគរយនៃឧក្រិដ្ឋជន កើតចេញពីជួរវ័យជំទង់នេះឯង ដូចជាក្រុមបនល្បែង ពេស្យាចារ ឃាតកម្ម ចោរកម្ម គ្រឿងញៀន រំលោភ ។ សង្គមបានទម្លាក់ឧក្រិដ្ឋជនទាំងនេះទៅលើក្រុមក្មេងជំទង់ ។ ក្នុងវ័យនេះការលូតលាស់នៃសរីរាង្គកាយ និងផ្លូវចិត្ត ជាដំណាក់កាលលោតផ្លោះ ឬ បន្លាស់ប្ដូរដ៏ឆាប់រហ័សនៃកត្តាទាំងពីរនេះជះឥទ្ធិពលយ៉ាងខ្លាំងដល់ការប្រកាន់យកអាកប្បកិរិយា បែបណាមួយនោះរបស់វ័យជំទង់ ។ ការលូតលាស់នៃសរីរាង្គកាយថ្មី និងចិត្តគំនិតថ្មីបែបនេះ ធ្វើឱ្យជំទង់មានតម្រូវការ និងចំណង់ចំណូលចិត្តថ្មី ក្នុងការសេពគប់រកមិត្តភាព និងសកម្មភាពបែបណាមួយនោះ ដែលជួនកាលធ្វើឱ្យ សង្គម និងសាលារៀនជួបវិបត្តិ និងការលំបាកគួរឱ្យបារម្ភ ។ សង្គមអាចជួបវិបត្តិ និងផលវិបាកដ៏ធ្ងន់ធ្ងរ បើរដ្ឋាភិបាល បណ្ដាញព័ត៌មានអប់រំ គ្រួសារ សង្គម សាលារៀន មិនមានវិធានការទប់ស្កាត់ឥទ្ធិពលអាក្រក់ សកម្មភាពមិនល្អរបស់ជំទង់ ។

ក្នុងវ័យនេះគ្រោងឆ្អឹងលូតលាស់រហ័សណាស់ ។ ឆ្អឹងដៃ និងឆ្អឹងជើងលូតវែង ធ្វើឱ្យជំទង់មានរាងកាយស្គមស្តើង ។ កម្ពស់របស់ជំទង់អាចលូតបានពី៥ទៅ៦ស.ម និងទម្ងន់កើនឡើងពី២.៥០គ.ក្រ ទៅ៤គ.ក្រ ក្នុងមួយឆ្នាំៗ ។ ដោយសារប្រព័ន្ធឆ្អឹង កម្ពស់ ទម្ងន់ រីកលូតលាស់បែបនេះហើយ បានជាជំទង់ចង់ធ្វើអ្វីៗឱ្យដូចមនុស្សចាស់ ដូចជាគេចង់យួរវ៉ាលីស ឬរបស់ធ្ងន់ៗឱ្យដូចមនុស្សពេញវ័យ ។

ក្នុងវ័យនេះ ខួរក្បាលរបស់ជំទង់ ចាប់ផ្តើមមានទម្ងន់ និងមានទំហំប្រហែលនឹងខួរក្បាលយុវជន ។ សម្បកខួរក្បាល ឬក័រតិចខួរ និងទំហំខួរក្បាលរីកចម្រើនរហ័សណាស់ ។ មុខងារ និងប្រព័ន្ធសរសៃប្រសាទកាន់តែជួបលក្ខណៈស្មុគស្មាញ ។ អ្នកប្រាជ្ញចិត្តវិទ្យាមួយចំនួនបានបកស្រាយពន្យល់ពីលក្ខណៈស្មុគស្មាញនេះ ដូចតទៅ ៖

- កង្វះលំនឹងផ្នែកសរីរៈ នាំឱ្យជំទង់ខ្វះលំនឹងផ្នែកសរីរាង្គកាយទាំងមូល ។ ករណីនេះ ជួនកាលបណ្តាលមកពីជំងឺ ឬអាការៈរោគពីកំណើត ឬសួពូជ ឬក៏បណ្តាលមកពីរបបអាហារ ឬកង្វះសកម្មភាពកីឡា ។
- ចំពោះក្មេងជំទង់ស្រី ក្នុងអាយុ១៤ទៅ១៥ឆ្នាំ ប្រវែងឆ្អឹងហាក់ដូចជាលូតលឿនជាងទំហំសាច់ដុំធ្វើឱ្យរាងកាយប្រែប្រួល ជួនកាលមានភាពសង្ហារ គួរជាទីចាប់អារម្មណ៍ដល់អ្នកផង ។
- ក្នុងវ័យនេះ ជំទង់ច្រើនជួបវិបត្តិ និងទទួលរងការស្តីបន្ទោសពីមនុស្សចាស់ ដូចជាករណីកាន់របស់អ្វីមួយធ្វេសប្រហែសឱ្យធ្លាក់ពីដៃ ឬជ្រុះបាក់បែក ប្រើប្រាស់របស់ដូចជាយានជំនិះ ធ្វើឱ្យបាក់បែក ឬទុកដាក់របស់ប្រើប្រាស់មិនត្រូវតាមទំនង ។
- កាលណាចាប់ផ្តើមមានឈាមរដូវ បេះដូងក្មេងជំទង់ស្រី ចាប់ផ្តើមរីកលូតលាស់ចំនួនពីរដងធំជាងទំហំសរសៃឈាម ។ ក្នុងករណីនេះ របត់ឈាមក្នុងខ្លួនប្រាណមានដំណើរការយឺតបន្តិច ។ ពេលមានឈាមរដូវ បើបេះដូងផ្តល់ឈាមទៅឱ្យណឺរ៉ូនមិនគ្រប់គ្រាន់ទេ ធ្វើឱ្យគេធាប់អស់កម្លាំង ។ ដូច្នេះ គេត្រូវធ្វើចលនាសាច់ដុំ និងឆ្អឹងឱ្យបានញយដង ។

ភាគច្រើននៃក្មេងជំទង់ប្រុស-ស្រី ច្រើនមានប្រតិកម្មអវិជ្ជមានចំពោះបន្លាស់ប្តូររាងកាយរបស់ខ្លួនពីវ័យកុមារមកវ័យជំទង់ ។ បន្លាស់ប្តូរ និងការលូតលាស់នៃរាងកាយនេះត្រូវបានជំទង់ចាប់អារម្មណ៍ និងយល់ដឹងដោយខ្លួនឯង ។ ក្នុងពេលជាមួយគ្នានេះបញ្ញត្តិផ្ទាល់ខ្លួនដែលទទួលបានពីការសិក្សាក្នុងសាលារៀនតាមរយៈមុខវិជ្ជាសិក្សានានាក៏ចាប់ផ្តើមអភិវឌ្ឍដែរ ។ ក្នុងពេលនេះហើយដែលបុគ្គលិកលក្ខណៈរបស់ជំទង់ចាប់ផ្តើមអភិវឌ្ឍ ។ ការអភិវឌ្ឍនៃទំហំរាងកាយកង្វះបំណិនប្រសប់ភាពឆ្គាំឆ្គង ភាពមិនរហ័សរហួន ឬភាពប៉ិនប្រសប់ឈ្លាសវៃបែបណានោះ ត្រូវបានទទួលការវាយតម្លៃពីមនុស្សចាស់ ឬអ្នកដទៃ ។ ជំទង់ខ្លះមានកម្ពស់ ទម្ងន់ និងពណ៌សម្បុរ ស្បែក សមាមាត្រសមរម្យទៅនឹងដងខ្លួន ខ្លះទៀតមិនសមាមាត្រទៅនឹងដងខ្លួន ។ ក្មេងជំទង់ស្រី ច្រើនមិនសូវពេញចិត្តនឹងដងខ្លួន ចង្កេះ ដើមទ្រូង ត្រគាក កម្ពស់ មាឌ និងទម្ងន់ ។ ក្មេងជំទង់ស្រី ចង់បានមុខមាត់មូលស្រស់បស់ និងរាងកាយស្រួចស្រាវ ។ ចំពោះក្មេងជំទង់ប្រុសវិញ គេចង់បានស្មាទូលាយ ត្រគាកចង្អៀត ។ ក្មេងជំទង់ប្រុសច្រើនមានមាឌស្តើងខ្ពស់ ។

ជាទូទៅ ចាប់ពីអាយុ១៨ឆ្នាំឡើងទៅ ភាពគ្រប់ការលេចធ្លោឱ្យឃើញច្បាស់ ។ រាងកាយមានបន្លាស់ ប្តូរទៅតាមលក្ខណៈជីវសាស្ត្រ ពោល គឺរបបអាហារ និងរបបប្រព្រឹត្តកីឡា ។ គឺក្នុងពេលនេះហើយដែលជំទង់បង្ហាញឱ្យឃើញនូវសមត្ថភាពរបស់គេក្នុងការបន្តពូជបាន ។ ចំពោះក្មេងជំទង់ស្រីធាប់មានវ័យចំណាស់ជាងក្មេងជំទង់ប្រុសចំនួនពីរឆ្នាំ ។ កត្តាចិត្តគំនិត និងកត្តាសង្គមធ្វើអភិវឌ្ឍក្នុងពេលដែលជំទង់ផ្តើមចូលរៀនថ្នាក់មធ្យមសិក្សា ។ ចូលដល់វ័យយុវជន ឬទីបញ្ចប់នៃវ័យជំទង់ យុវសិស្សមានកម្លាំងស្មើនឹងមនុស្សពេញវ័យធម្មតា ។ អាស្រ័យដោយរបបអាហារ និងការអប់រំកាយ ជំទង់ ឬយុវជន អាចដណ្តើមបានលទ្ធផលល្អក្នុងការប្រកួតកីឡា ។ ចាប់ពីអាយុ១៨ឆ្នាំឡើងទៅ ជំទង់ឈានដល់ដំណាក់កាលចុងក្រោយនៃការលូតលាស់ផ្នែកជីវសាស្ត្រ ។ ដំណាក់កាលនេះមានលក្ខណៈជាទូទៅមិនថាជនជាតិណាមួយឡើយ ។ កត្តាលូតលាស់នៃសរីរាង្គកាយនេះត្រូវពឹងផ្អែកលើរបបចំណីអាហារ សេដ្ឋកិច្ចគ្រួសារ និងកម្រិតជីវភាពរស់នៅទូទៅក្នុងសង្គម ។ ចូលដល់វ័យយុវជន គិតពីអាយុ ១៨ឆ្នាំឡើងទៅ យុវជនមានសិទ្ធិផ្នែកនយោបាយ និងទទួលខុសត្រូវចំពោះមុខច្បាប់ ។

### ៣- ការអភិវឌ្ឍផ្នែកចិត្តគំនិត ឬ អត្តមនសិការ

វ័យជំទង់ជាវ័យដែលស្ថិតនៅចំណុះឪពុកម្តាយ ឬអ្នកអាណាព្យាបាល ។ ចាប់ពីវ័យ ១៥-១៦ឆ្នាំឡើងទៅសមត្ថភាពបញ្ញារបស់ជំទង់ចាប់ផ្តើមអភិវឌ្ឍន៍ស្របពេលដែលជំទង់កំពុងរៀនក្នុងថ្នាក់មធ្យមសិក្សា ។ គេចាប់ផ្តើមជួបប្រទះនឹងសកម្មភាពដ៏ស្មុគស្មាញក្នុងការសិក្សា ។ គេចាប់ផ្តើមប្រកាន់យកជំហរដ៏រឹងមាំក្នុងការសិក្សា ។ គេមានចិត្តប្រកួតប្រជែងក្នុងការដណ្តើមយកស្នាដៃក្នុងការសិក្សា និងការហ្វឹកហ្វឺនបញ្ញា ។ គេត្រូវបំពេញនូវកាតព្វកិច្ចជាច្រើនក្នុងពេលដែលគេរៀននៅថ្នាក់មធ្យមសិក្សា ។ ជំទង់ចាប់ផ្តើមមានគំនិត និងចំណង់ចំណូលចិត្ត ស្រឡាញ់ និងជ្រើសរើសមុខវិជ្ជាជីវៈណាមួយក្នុងសង្គមសម្រាប់អនាគតរបស់គេ ។ វិចារណញ្ញាណរបស់គេតម្រង់មុខសញ្ញាទៅរកការយល់ស៊ីជម្រៅចំពោះខ្លឹមសារវត្ថុ និងបាតុភូតដែលគេត្រូវសិក្សា ។ គេមានគំនិត និង ស្មារតីយល់ស៊ីជម្រៅចំពោះសម្រាយបំភ្លឺរបស់គ្រូទៅតាមលក្ខណៈវិទ្យាសាស្ត្រ ។ បញ្ញត្តិផ្ទាល់ខ្លួន ឬសតិបញ្ញារបស់គេ ចាប់ផ្តើមអភិវឌ្ឍតាមរយៈ ៖

- ការចេះបកស្រាយពន្យល់ដ៏លម្អិត
- ការចេះប្រៀបធៀប
- ការចេះវិនិច្ឆ័យ
- ការចេះសំយោគ
- ការចេះធ្វើអរូបីកម្ម
- ការធ្វើទូទៅកម្ម
- ការចេះវាយតម្លៃ
- ការចេះទិតៀន
- ការចេះទាញសន្និដ្ឋាន
- ការបញ្ចេញមតិយោបល់។

អាកប្បកិរិយារបស់គេចេះតែវិវត្តន៍ ជួនកាលមានស្ថេរភាព ជួនកាលផ្លាស់ប្តូរទៅតាមចំណេះដឹង និងបទពិសោធន៍ដែលគេមាន និងកំពុងទទួលបាន ។ គេចាប់ផ្តើមចាប់អារម្មណ៍ទៅនឹងមុខរបរផ្សេងៗក្នុងសង្គម ។ គេមាននមនោសញ្ចេតនា និងទំនាក់ទំនងស្វែងរកមិត្តភាព ជាមួយអ្នកដែលមានវ័យស្រករគ្នា ។ គេកំពុងយកចិត្តទុកដាក់ដល់ទំនាក់ទំនងរបស់គេ ជាមួយនឹងសមូហភាពចំពោះភារកិច្ចសិក្សា ដើម្បីតម្រង់មុខសញ្ញាទៅរកអនាគតដ៏ត្រចះត្រចង់របស់គេ ។ ជំទង់ច្រើនតែមានការងឿងឆ្ងល់ និងចិត្តរំភើបចំពោះការវិវត្តផ្នែកសរីរៈ និងការផុសចេញនូវគំនិតផ្ទាល់ខ្លួនរបស់គេ ។

ក្នុងន័យនេះ សកម្មភាពជាគន្លឹះរបស់ក្មេងជំទង់ គឺតម្រង់មុខសញ្ញាស្វែងយល់ ចង់ឃើញ ចង់ដឹងពីទំនាក់ទំនងរវាងប្រុស និងស្រី ស្រ្តី និងស្ត្រី ជាពិសេសមនុស្សពេញវ័យក្នុងទំនាក់ទំនងស្នេហា ។ ចិត្តគំនិតជំទង់ខុសប្លែក កាលពីនៅវ័យកុមារ ។ កុមារធាប់ចងមិត្តភាពជាមួយគ្នាណាស់ទោះជាគេមិនទាន់ស្គាល់គ្នាច្បាស់លាស់នៅឡើយក៏ដោយ ។

**ឧទាហរណ៍ ៖** កុមារអាយុ៦-៧ឆ្នាំ គេចែកនំគ្នាញ៉ាំ ឬលេងកំសាន្តជាមួយគ្នា ។

ចំពោះជំទង់វិញមិនដូច្នោះទេ ។ គេត្រូវប្រើពេលដ៏យូរបង្គួរមុននឹងចងមិត្តភាពជាមួយអ្នកស្រករវ័យ ។ ជំទង់មានទំនាក់ទំនងគ្នាកាន់តែស្មុគស្មាញ និងសំបូរបែប ។ ជំទង់ច្រើនតែមានប្រតិកម្មផ្លូវចិត្តចាត់ទុកខ្លួនឯងស្មើនឹងមនុស្សចាស់ ។ គេចង់ពង្រឹងពង្រីក និងកែទម្រង់ទំនាក់ទំនងរបស់គេជាមួយមនុស្សចាស់ ។ កាលពីនៅវ័យកុមារ គេមិនអាចបោះបង់ចោល ឬកែប្រែអាកប្បកិរិយា ចរិត និងសកម្មភាពកុមារបានឡើយចំពោះមុខមនុស្សចាស់ ។ ជំទង់ចង់បានសមភាពជាមួយមនុស្សចាស់ ។ ជំទង់ខំបញ្ចេញកម្លាំង និងធ្វើការឱ្យមានស្នាដៃដូចមនុស្សចាស់ ។ គេហ៊ានកាច់ដៃល្បងកម្លាំងជាមួយមនុស្សពេញវ័យ ។ កាលណាគេធ្វើការជាមួយមនុស្សចាស់ ឬមនុស្សពេញវ័យ ជួនកាលជំទង់ខំធ្វើការងារនេះឱ្យទាល់តែបានល្អប្រសើរជាងមនុស្សចាស់ ។ ពេលខ្លះជំទង់ចង់ឱ្យ មនុស្សចាស់គោរពខ្លួនគេ ។ គឺត្រង់ចំណុចនេះហើយ ដែលជំទង់បង្កឱ្យមានបដិបក្ខជាមួយមនុស្សចាស់ ។ ជួនកាល ជំទង់ត្រូវបានគេគោរពស្មើភាពគ្នានឹងមនុស្សចាស់ដែរ ក៏ប៉ុន្តែចាស់ៗភាគច្រើន ច្រើនតែចាត់ទុកជំទង់ថាជាក្មេងៗទៅវិញ ។ ចាស់ៗខ្លះចាត់ទុកថាទំនាក់ទំនងរវាងជំទង់ និងមនុស្សចាស់ជាទំនាក់ទំនងធម្មតា ។ ចាស់ៗខ្លះទៀត ខ្វះការយល់ដឹងនិងខ្វះមធ្យោបាយអប់រំជំទង់ជាកូន ចូលចិត្តជេរស្តី ស្តីបន្ទោស ឬវាយកូន នៅពេលហូបបាយ នៅចំពោះមុខភ្ញៀវ ឬនៅចំពោះមុខមិត្តភក្តិរបស់កូន នៅពេលដែលជំទង់មានទំនាស់ ឬហ៊ានប្រឆាំងបន្តិចបន្តួចជាមួយមនុស្សចាស់ ឬមនុស្សពេញវ័យ ដូចជា ឪពុកម្តាយ ឬបងប្រុសស្រីជាដើម ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគួរអប់រំមាតាបិតាកុំឱ្យធ្វើបែបនេះ ហើយគួរបង្ហាញ និងណែនាំពីវិធី និងមធ្យោបាយដ៏ល្អសម្រាប់អប់រំកូន ចំពោះឪពុកម្តាយបែបនេះផង ។ គ្រូបង្រៀន និងសាស្ត្រាចារ្យ គួរតែយល់ស៊ីជម្រៅទៅលើប្រការនេះ ។ ការអប់រំជំទង់បានល្អ វាអាស្រ័យទៅលើទឹកចិត្តអត់ធ្មត់ អហឹង្សា និងកម្រិតយល់ដឹងឪពុកម្តាយ។

**ឧទាហរណ៍ ៖** ក្មេងប្រុសជំទង់កំពុងលេងអុក ។ ម្តាយកំពុងធ្វើម្ហូបអាហារ ។ ពេលខ្វះទឹកត្រី ម្តាយបានស្រែកហៅកូនឱ្យទៅទិញទឹកត្រីមួយភ្លែត ព្រោះម្តាយមិនអាចទៅចោលចង្ក្រានបាន ។ កូនដែលកំពុងជាប់លេងអុកឆ្លើយថា ចាំមួយភ្លែតសិន ។ លុះចាំយូរពេក ម្តាយក៏ស្ទុះទៅច្បាមយកកូនអុកក្រវែងចោល

ទៅផ្លូវថ្នល់ ហើយឡូឡាដេរស្ដីអ៊្រូទាំយ៉ាងយូរ ។ គ្រួសារមួយផ្សេងទៀត ជួបប្រទះនឹងករណីប្រហែលនេះដែរ នៅពេលដែលកូនជាប់មាត់ជជែកគ្នាជាមួយមិត្តភក្តិ ។ ម្ដាយបានហៅប្រាប់កូន ឱ្យទៅទិញប៊ីចេងឱ្យម្ដាយ ។ ជំទង់បានប្រាប់មិត្តភក្តិរបស់គេ ឱ្យចាំមួយភ្លែត រួចគេក៏រត់ទៅទិញប៊ីចេងឱ្យម្ដាយ ។

ដូចនេះ ការអប់រំជំទង់ឱ្យយល់ពីខ្លួនឯង ឱ្យមានទម្លាប់ល្អ វាអាស្រ័យទៅលើឪពុកម្ដាយ ឬបងប្រុសស្រីក្នុងគ្រួសារ ដែលចេះនិយាយលួងលោមអប់រំណែនាំជំទង់ឱ្យល្អជាជាងប្រើអំពើហឹង្សាក្នុងគ្រួសារ។ ឪពុកម្ដាយត្រូវទម្លាប់អប់រំកូនឱ្យល្អ តាំងពីកូននៅតូច ឬនៅវ័យកុមារ។ ក្មេងជំទង់ខ្លះមានទម្លាប់ចេះគួរសម ឬចេះលើកដៃសំពះមនុស្សចាស់ ឬក្មៀវតាំងពីនៅកុមារ។ ជំទង់បែបនេះ ត្រូវអ្នកផងវាយតម្លៃថា ជាកូនមានពូជអំបូរល្អ។

ជំទង់ដែលតាំងខ្លួនឯងថា ជាមនុស្សពេញវ័យ គឺជា ឆន្ទៈ និងតម្រូវការផ្ទាល់ខ្លួនរបស់គេ។ តម្រូវការនេះនឹងក្លាយទៅជាកម្លាំងចលករមួយ ដែលជំរុញជំទង់ឱ្យហ៊ានធ្វើអ្វីមួយ ដោយអាងលើសមត្ថភាពរបស់គេដូចមនុស្សចាស់។

**ឧទាហរណ៍ ៖** ឪពុកម្ដាយ ឬបងប្រុសស្រីខ្លះ បណ្ដោយឱ្យកូន ឬប្អូនបើករថយន្ត។ ថ្ងៃមួយមនុស្សពេញវ័យមិននៅផ្ទះ ជំទង់អាចហ៊ានបើករថយន្តទៅឆ្ងាយបាន។

មនុស្សចាស់ ដូចជាឪពុកម្ដាយ មាមីង អាណាព្យាបាល និងគ្រូបង្រៀន ត្រូវតាមដាន និងយកចិត្តទុកដាក់ចំពោះឥរិយាបថ និងសកម្មភាពរបស់ជំទង់។ គេត្រូវអប់រំ និងពន្យល់ណែនាំជំទង់ឱ្យចេះប្រើប្រាស់កម្លាំងចលករ ឬចំណង់ចំណូលចិត្តឱ្យសមស្របទៅតាមកាលៈទេសៈ បើមិនដូច្នេះទេកម្លាំងចលកអោចជំរុញជំទង់ឱ្យជួបគ្រោះថ្នាក់ ឬជាប់បទល្មើសជាមិនខាន។

**ឧទាហរណ៍ ៖** មិនត្រូវបណ្ដែតបណ្ដោយកូនឱ្យរៀន ចេះផឹកស្រា ស្រាបៀរ ចេះជក់បារី ចេះលេងបៀរជាមួយឪពុកម្ដាយ បណ្ដោយឱ្យកូនអាយុ១៨ឆ្នាំបើករថយន្ត បណ្ដោយឱ្យកូនមើលខ្សែភាពយន្តវីដេអូ រឿងហេតុកម្ម ឬ រឿងអាសអាភាស។ល។

ជាគោលការណ៍ មជ្ឈដ្ឋានសង្គម និងស្ថាប័នអប់រំ និងវប្បធម៌ ត្រូវរួមចំណែកជួយបណ្ដុះបណ្ដាល និង ជួយអប់រំបុគ្គលិកលក្ខណៈរបស់ជំទង់ឱ្យចុះសម្រុងក្នុងសង្គម តាមរយៈនៃកម្មវិធីផ្សព្វផ្សាយរបស់ បណ្ដាញព័ត៌មាន។ ក្នុងវ័យដែលផ្លូវចិត្តជំទង់កំពុងលូតលាស់ មជ្ឈដ្ឋានគ្រួសារ និងសាលារៀន គួរណែនាំជំទង់ឱ្យស្គាល់ស្ថានភាពថ្មី និងមជ្ឈដ្ឋានប្លែកៗជាច្រើនដើម្បីជួយពង្រីកគំនិតសតិបញ្ញារបស់ជំទង់ដូចជា៖

- ឪពុកម្ដាយត្រូវនាំកូនចូលពិសារភោជនាហារក្នុងភោជនីយដ្ឋានធំៗ នាំកូនចូលផ្សារធំៗ ដើម្បីទិញអីវ៉ាន់ប្រើប្រាស់ ណែនាំកូនឱ្យយល់ដឹង និងចេះប្រើប្រាស់ឧបករណ៍នៅក្នុងគ្រួសារមានយានជំនិះ ទូរទស្សន៍ ម៉ាញេ វីដេអូ ។ល។
- សាលារៀនត្រូវនាំសិស្សជំទង់ទៅមើលកន្លែងកំសាន្ត ឆ្នេរសមុទ្រ រមណីយដ្ឋានទេសចរណ៍ រោងចក្រ មណ្ឌលចិញ្ចឹមសត្វ ចិញ្ចឹមត្រី មណ្ឌលផលិតកម្មសំខាន់ៗ ។ល។

អ្នកអាណាព្យាបាល និងអ្នកអប់រំ គប្បីជួយពន្យល់ណែនាំជំទង់ឱ្យចេះស្វែងយល់ពីផលល្អ ឬផលអាក្រក់ និងគ្រោះថ្នាក់ដែលបណ្ដាលមកពីទង្វើ ឬសកម្មភាពផ្សេងៗដូចជា ៖

ការមិនគោរពច្បាប់សាធារណៈ

- ការមិនគោរពតាមក្បួនអនាម័យ
- ការប្រើប្រាស់របស់ផ្ទាល់ខ្លួនមិនសមហេតុផល
- ការសេពគប់មិត្តភក្ដិ
- ការនិយមវប្បធម៌បរទេស
- ទំនាក់ទំនងស្នេហា និងចំណងមិត្តភាពជាមួយអ្នកស្រករវ័យ
- ការប្រើអំពើហឹង្សា
- ការចេះគោរពសិទ្ធិមនុស្ស
- ការចេះគោរពទំនៀមទម្លាប់ប្រពៃណីសាសនា
- ចំពោះបទឧក្រិដ្ឋ និង ឃាតកម្ម
- គ្រឿងញៀន បនល្បែង និង បនពេស្យាចារ
- អត្ថប្រយោជន៍នៃការសិក្សា
- លទ្ធផលនៃការធ្វេសប្រហែស និងការមិនយកចិត្តទុកដាក់ក្នុងការសិក្សា។

មជ្ឈដ្ឋាន និងកត្តានៃឥទ្ធិពលអាក្រក់ងាយអូសទាញជំទង់ណាស់ ហើយវប្បធម៌ជាតិក៏ងាយនឹងស្រុតចុះសាបសូន្យបានដែរ។ បើវប្បធម៌ជាតិមិនត្រូវបានសង្គមឱ្យតម្លៃ និងលើកតម្កើងហើយ មនុស្សមិនអាចរស់នៅមានភាពសុខដុមរមនាឡើយ។ គេមានការភ័យព្រួយបារម្ភជានិច្ច ចំពោះសុវត្ថិភាពរបស់គេ និងសមាជិកគ្រួសារគេ។ មនុស្សកើតមកល្អជាទេ តែឥទ្ធិពលអាក្រក់ក្នុងសង្គមទេ ដែលបង្រៀនមនុស្សឱ្យទៅជាអាក្រក់វិញ។

មនុស្សចាស់ មិនត្រូវបង្ខិតបង្ខំជំទង់ឱ្យធ្វើការផ្លូវអាក្រក់ ដើម្បីទទួលផលកម្រៃឡើយ។ ក៏ប៉ុន្តែនៅតាមគ្រួសារនីមួយៗ ឪពុកម្ដាយ ឬអាណាព្យាបាលគួរទម្លាប់កូនឱ្យចេះជួយ ៖

- ការងារផ្ទះ
- ការងារលក់ដូរ
- ការងារស្រែចម្ការ
- ការងារដទៃទៀតសមស្របទៅតាមសមត្ថភាពរបស់ជំទង់ និងទុកពេលវេលាឱ្យកូនបានរៀននៅ ផ្ទះ។

**ឧទាហរណ៍** ៖ ក្មេងប្រុសជំទង់អាចជួយឃ្វាលគោក្របីពេលថ្ងៃសម្រាករៀន ។ ក្មេងស្រីជំទង់អាចជួយលក់ដូរ ជួយមើលប្អូន ជួយដាំស្ល ជួយកិច្ចការផ្ទះ។

ទំនាក់ទំនងដ៏ជិតស្និទ្ធរវាងគ្រួសារជំទង់ និងសាលារៀន មានអត្ថន័យសំខាន់ ចំពោះការអប់រំបុគ្គលិកលក្ខណៈរបស់ជំទង់ឱ្យចុះសម្រុងក្នុងសង្គម។ ពេលដឹងថា ជំទង់សេពគប់ក្នុងចំណោមមិត្តភក្តិអាក្រក់ បានផលយកកម្រៃបំពេញកង្វះខាតបន្តិចបន្តួចក្នុងគ្រួសារ ឪពុកម្ដាយ ឬអាណាព្យាបាលមិនត្រូវបណ្ដោតបណ្ដោយកូនទេ ត្រូវតែសហការជាមួយសាលារៀន ដើម្បីអប់រំណែនាំកូនឱ្យទាន់ពេលវេលា។

**ឧទាហរណ៍ ៖** កូនស្ថិតនៅក្នុងសមាសភាពបានប្រព្រឹត្តបទល្មើស។ ពេលបានទទួលព័ត៌មានពីអ្នកដទៃ ឪពុកម្ដាយមិនត្រូវកាន់ជើងកូន ឬបណ្ដោតបណ្ដោយធ្វើជាមិនអើពើនឹងកូនឡើយ។

### ៤- ជំទង់មានមនសិការ

ជំហានកំណត់នៅក្នុងវ័យជំទង់ គឺអំណះអំណាងថា គេមានមនសិការដូចមនុស្សពេញវ័យ។ ជំទង់មានការភ្ញាក់រឭកចំពោះខ្លួនឯង និងចំពោះសង្គម។ មុនដំបូង គឺការឱ្យតម្លៃរបស់មនុស្សចាស់ចំពោះស្នាដៃ និងអាកប្បកិរិយារបស់ជំទង់ ដែលនាំឱ្យជំទង់មានការភ្ញាក់រឭកចំពោះខ្លួនឯង។ ជំទង់ឆាប់ស្រៀវ ឆាប់ភ្ញាក់រឭក និងឆាប់រាងរៃណាស់។ ជោគជ័យពិតប្រាកដ ឬជាចៃដន្យរបស់ជំទង់ក្នុងស្នាដៃការងារ ឬស្នាដៃសិក្សា អាចធ្វើឱ្យជំទង់មានមោទនភាព និងវាយតម្លៃខ្ពស់លើខ្លួនឯង។ ផ្ទុយទៅវិញ បរាជ័យក្នុងការតស៊ូ ឬក្នុងទង្វើណាមួយ ដែលនាំមកនូវគ្រោះថ្នាក់ ឬទទួលការទិតៀនពីមនុស្សចាស់ ឬអ្នកអប់រំ អាចធ្វើឱ្យជំទង់មានចិត្ត អល់អែក។

**ឧទាហរណ៍ ៖** ជំទង់រៀនបានចំណាត់ថ្នាក់ល្អ ជំទង់ចេះទទួលភ្ញៀវ ជំទង់មានស្នាដៃក្នុងទំនួលខុសត្រូវ លើកិច្ចការណាដែលមនុស្សចាស់ ឬគ្រូប្រគល់ឱ្យ ត្រូវបានលើកសរសើរនោះ ធ្វើឱ្យជំទង់មានមោទនភាពចំពោះខ្លួនឯង។

ជំទង់ទទួលបរាជ័យក្នុងការប្រកួតកីឡា ត្រូវអ្នកអប់រំ ឬមនុស្សចាស់បន្ទះបង្អាប់ ឬស្ដីបន្ទោសធ្វើឱ្យជំទង់មានស្មារតីអល់អែក ក្នុងការហ្វឹកហាត់កីឡា និងការប្រកួតលើកក្រោយៗទៀត ។

ក្នុងរង្វាយតម្លៃទៅលើសិស្សមធ្យមសិក្សា គ្រូត្រូវយកចិត្តទុកដាក់គិតដល់: ភាពរួស ភាពឆាប់ភ្ញាក់រឭក ភាពក្លាហាន អំណត់ធ្មត់ សេចក្ដីព្យាយាម អាកប្បកិរិយា សកម្មភាព ស្មារតីម្ចាស់ការច្នៃប្រឌិត ស្នាដៃសិក្សា និង សីលធម៌ក្នុងទំនាក់ទំនងជាមួយគ្រូ និងបុគ្គលិកសិក្សាឯទៀត។ គ្រូបង្រៀន ឬអ្នកអប់រំអាចអប់រំជំទង់បានល្អ ប្រសិនណាគ្រូចេះយល់ស៊ីជម្រៅទៅលើ ៖

- ចំណង់ចំណូលចិត្តរបស់ជំទង់
- ស្គាល់ច្បាស់ពីមជ្ឈដ្ឋានរស់នៅរបស់ជំទង់
- អត្តចរិតផ្ទាល់ខ្លួនរបស់ជំទង់
- សេចក្ដីព្យាយាមអត់ធ្មត់របស់ជំទង់ក្នុងការសិក្សា
- ភាពទៀងទាត់ក្នុងម៉ោងសិក្សាក្នុងថ្នាក់
- ការចេះគោរពវិន័យសាលារៀន

- សីលធម៌ក្នុងការទំនាក់ទំនងជាមួយគ្រូ ជាមួយបុគ្គលិកសិក្សាឯទៀត
- ស្នាដៃសិក្សា ។

ការអប់រំជំទង់ទាមទារឱ្យគ្រូ ឬសាស្ត្រាចារ្យ ៖

- ចេះលើកទឹកចិត្តសរសើរផ្ទាល់មាត់
- ប្រកាន់ចិត្តអហឹង្សា និងអំណត់ធ្មត់
- ចេះលួងលោមសម្ដីទន់ភ្លន់
- ចេះជួយពន្យល់ណែនាំ និងឱ្យតម្លៃទៅលើស្នាដៃពិតប្រាកដ។

ជំទង់ចូលចិត្តការលើកសរសើរ និងការនិយាយសម្ដីទន់ភ្លន់ពីមនុស្សចាស់ទៅរកគេ។ ក៏ប៉ុន្តែបើជំទង់ វាយតម្លៃទៅលើអ្នកដទៃវិញ គឺគេវាយតម្លៃតែលក្ខណៈខាងក្រៅខ្លួនតែប៉ុណ្ណោះ។ គេវាយតម្លៃទៅលើអ្នកដទៃទាំងខុសឆ្គង ឬមិនបានត្រឹមត្រូវទេ ទោះជានៅពេលណាក៏ដោយ។ ពេលខ្លះទៀត គេឃើញជំទង់រៀនត្រាប់តាមមនុស្សចាស់ទាំងខុសឆ្គង ឬមិនត្រូវតាមទំនងទាល់តែសោះ ។

**ឧទាហរណ៍ ៖** ជំទង់អាយុ១៤-១៥ឆ្នាំ ឃើញមនុស្សចាស់ជក់បារី គេរៀនជក់តាមមនុស្សចាស់ដែរ។ មុនដំបូងគេជក់សាកល្បងជាអាថ៌កំបាំងពីមុខមនុស្សចាស់។ ក្រោយមកគេហ៊ានជក់ជាមួយមនុស្សចាស់តែម្ដង។

ចំពោះក្មេងជំទង់ស្រីក្នុងអាយុ១៤ទៅ១៥ឆ្នាំ គេទៅអ៊ុតសក់ ធ្វើសក់ និងស្លៀកពាក់តាមបងស្រីរបស់គេ ឬតាមមនុស្សស្រីពេញវ័យ ។

ក្នុងករណីបែបនេះ មានតែមាតាបិតា បងប្រុសស្រី និងអ្នកអប់រំជំទង់ដោយផ្ទាល់ទេ ដែលរស់នៅនិងធ្វើការយ៉ាងជិតស្និទ្ធនឹងជំទង់ ដែលមានលទ្ធភាពអាចជួយពន្យល់ណែនាំជំទង់បាន គឺឆ្លៀតពេលពន្យល់វែកញែកប្រាប់ជំទង់ឱ្យយល់ពីតម្លៃខុសគ្នារបស់មនុស្សចាស់ មនុស្សពេញវ័យ យុវជន និងជំទង់។ ពេលខ្លះទៀតគេកត់សម្គាល់ឃើញថា ជំទង់ខ្លះរៀនត្រាប់តាមមនុស្សចាស់ ដោយមិនបានវិភាគលើអត្តចរិតនិងអាកប្បកិរិយារបស់មនុស្សចាស់នោះ ឱ្យបានត្រឹមត្រូវគ្រប់ជ្រុងជ្រោយឡើយ។ លក្ខណៈដែលធ្វើឱ្យក្រុមចិត្តវិទូវាយតម្លៃបាននោះ គឺ ជំទង់ចូលចិត្តត្រាប់តាមសេចក្ដីក្លាហានរបស់មនុស្សពេញវ័យ ឬមនុស្សចាស់។

**ឧទាហរណ៍ ៖** ឃើញមនុស្សពេញវ័យ ឬមនុស្សចាស់លោតចុះពីលើរថភ្លើង ឬ រថយន្តដែលរត់ សន្សឹមៗថ្ងៃក្រោយជំទង់រៀនត្រាប់ធ្វើតាម។ ការពិតអ្នកដែលលោតចុះពីលើរថភ្លើង ឬ រថយន្តជាចោរ ឬ ជាឧក្រិដ្ឋជនសោះ។ ឃើញគេជិះម៉ូតូហោះ ជំទង់ត្រាប់តាម។

មានជំទង់ខ្លះទៀត ដើម្បីបង្ហាញឱ្យអ្នកផងគេឃើញថា ខ្លួនមានភាពរហ័សរហួន និងមានសេចក្ដីអង់អាច ក្លាហានដ៏ពិតប្រាកដនោះ គេបានខំព្យាយាមស្វ័យហ្វឹកហ្វឺន និងស្វ័យអប់រំ ដើម្បីឱ្យបំណងប្រាថ្នាដែលគេបានគិតទុកមកនោះ ក្លាយទៅជាការពិត និងបានសម្រេចដូចចិត្ត។

**ឧទាហរណ៍** ៖ ដើម្បីបង្ហាញឱ្យគេឃើញនូវឆន្ទៈដ៏ក្លាហានរបស់ខ្លួន ជំទង់ហ៊ានរត់ឆ្លងផ្លូវថ្នល់ ពេលដែលរថយន្តមកជិតដល់ ឬ ជិះម៉ូតូឆាបចន្លោះជួររថយន្តដែលកំពុងចរាចរតាមផ្លូវ។ ពេលខ្លះនៅក្នុងចំណោមមនុស្សដ៏ច្រើន ជំទង់ហ៊ានលើកផ្ទាំង ឬកំសៀវទឹកដែលកំពុងពុះលើចង្ក្រានដោយមិនបាច់មានក្រណាត់ ឬក្រដាសទ្រាប់ដៃ។

អាណាព្យាបាល ឬអ្នកអប់រំ គប្បីសហការ និងឯកភាពគ្នា យកចិត្តទុកដាក់អប់រំជំទង់ឱ្យបានជិតដល់មែនទែន ដូចជា ជួយពន្យល់ប្រាប់ និងជួយណែនាំជំទង់ ឱ្យបានយល់ពីគ្រោះថ្នាក់នៃទង្វើនីមួយៗ និងផលវិបាកដែលជាបន្ទុករបស់គ្រួសារ ឬអ្នកអាណាព្យាបាលដែលត្រូវទទួលចៀសមិនផុត ដែលបណ្ដាលមកពីមូលហេតុនៃទង្វើអាក្រក់មិនគួរប្រព្រឹត្ត ឬមិនត្រូវព្យាយាមត្រាប់តាម។ ការអប់រំណែនាំជំទង់ទាមទារឱ្យមនុស្សចាស់ទាញហេតុផលមកពន្យល់ជំទង់ឱ្យឃើញជាក់ស្ដែង។ វ័យជំទង់ ជាវ័យដែលសរីរាង្គកាយត្រូវលូតលាស់ ជាវ័យដែលចិត្តគំនិតត្រូវវិវត្ត ជាវ័យមានវិបត្តិថ្លោះធ្លោយ ជាវ័យទទួលរងការស្ដីបន្ទោស ជាវ័យទទួលគ្រោះថ្នាក់ ជាវ័យដែលទទួលការអប់រំបុគ្គលិកលក្ខណៈ ឬចុះសម្រុងក្នុងសង្គម និងជាវ័យចង់ឃើញ ចង់យល់ ចង់ស្គាល់។ ក្នុងន័យនេះរដ្ឋាភិបាល និងបណ្ដាញព័ត៌មានក្នុងស្រុក គួរយកចិត្តទុកដាក់គិតគូរអប់រំ វ័យជំទង់ ឱ្យយល់ពីគ្រោះថ្នាក់ ដែលបណ្ដាលមកពីទង្វើរបស់ជំទង់ក្នុងសង្គម ជួយផ្សព្វផ្សាយព័ត៌មានអប់រំឱ្យមជ្ឈដ្ឋានគ្រួសារជំទង់យល់ស៊ីជម្រៅ ពីការហូរចូលខុសច្បាប់នូវវប្បធម៌ពាលាអាវាសែរបស់បរទេស និងការចាប់វិធានការទប់ស្កាត់ឱ្យទាន់ពេលវេលាក្នុងសង្គមខ្មែរ ដែលងាយធ្វើឱ្យវប្បធម៌ទំនៀមទម្លាប់ដ៏មានតម្លៃរបស់ខ្មែរ ចេះតែសាបរលាបបាត់បង់ទៅ។

អត្តចរិត អាកប្បកិរិយា និងទង្វើរបស់ជំទង់មានច្រើនរូបភាព។ ជំទង់ត្រូវទទួលការអប់រំពីសាលារៀនផង ពីគ្រួសារផង ពីមជ្ឈដ្ឋានសង្គមផង ពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផង និងទទួលឥទ្ធិពលអាក្រក់ពីការសេពគប់មិត្តភក្តិផង និងការនិយមរកវប្បធម៌បរទេសផង។ មជ្ឈដ្ឋានសាលារៀន គ្រួសារ សង្គម និងជួរអាជ្ញាធរមានសមត្ថកិច្ច គួរតែសហការគ្នា និងឯកភាពគ្នា ក្នុងការយកចិត្តទុកដាក់អប់រំជំទង់ ដោយចាត់វិធានការ ឬយុទ្ធវិធីអប់រំឱ្យបានជិតដល់ទៀងទាត់ និងទាន់ពេលវេលា ដូចជា ៖

- បនល្បែងស៊ីសងៈ ហ្គេម កាស៊ីណូ បុកប៊ីយ៉ា បៀរ អាប៉ោង
- មជ្ឈដ្ឋានពេស្យាចារៈ ស្រីពេស្យាចារ ការជួញដូរផ្លូវភេទ ការចាប់រំលោភ
- ខ្សែភាពយន្តអាសអាភាសស៊ិចស៊ី ដែលមានដាក់លក់ជាសាធារណៈ និងទស្សនាវដ្ដីអាសអាភាស ទំព័រសាព័ត៌មានអាសអាភាសក្នុងស្រុក
- ខ្សែភាពយន្តហឹង្សា ឃាតកម្ម ចោរកម្ម ចាប់ជំរិត បាញ់សម្លាប់ អត្តឃាត គ្រឿងញៀន
- ជំទង់ឆាប់មានចិត្តរំភើបចង់យល់ ចង់ដឹង ចង់សាក រួចត្រាប់តាម។

### ៥- ស្មារតីម្ចាស់ការរបស់ជំទង់

ជំទង់ចង់ឱ្យអ្នកដទៃទទួលស្គាល់ និងវាយតម្លៃលើគុណសម្បត្តិស្នាដៃ និងសេចក្ដីក្លាហានរបស់ខ្លួន ស្មើនឹងមនុស្សពេញវ័យ ឬមនុស្សចាស់។ ជំទង់ចង់ឱ្យអ្នកនៅជុំវិញខ្លួនទទួលស្គាល់សិទ្ធិរបស់គេ ក្នុងការស្វ័យសម្រេចចិត្តលើទង្វើផ្សេងៗ ។ ស្មារតីម្ចាស់ការនេះ សឱ្យឃើញតាមរយៈទិដ្ឋភាពពីរយ៉ាងគឺ ៖

- ទិដ្ឋភាពទី ១ ៖ ផ្នែកសរីរាង្គ និងប្រតិកម្មផ្លូវចិត្ត ដែលរីកលូតលាស់តាមបែបលោតផ្លោះ ទាមទារឱ្យជំទង់ប្រកាន់យកស្មារតីម្ចាស់ការតែម្ដង។
- ទិដ្ឋភាពទី ២ ៖ ជំទង់ខិតខំពង្រឹងស្មារតីម្ចាស់ការរបស់ខ្លួន។ គេជឿថា គេមានសមត្ថភាពឈានទៅរក សុភមង្គលបានដោយខ្លួនគេ។

ក្នុងទិដ្ឋភាពទី២ ជំទង់អាចទទួលគ្រោះដោយសារតែវង្វាយតម្លៃដោយភាន់ច្រឡំ ឬខុសឆ្គងទៅលើសមត្ថភាពរបស់ខ្លួនឯង។ គេមានទំនុកចិត្តលើខ្លួនគេថា គេអាចវិនិច្ឆ័យបានដោយត្រឹមត្រូវទៅលើកិច្ចការ ឬ ទង្វើណាមួយដែលគេបម្រុងនឹងប្រព្រឹត្តបានដោយខ្លួនគេផ្ទាល់ មិនចាំបាច់សុំយោបល់ ឬទទួលដំបូន្មានពីអ្នកដទៃឡើយ។ ជួនកាលជំទង់វាយតម្លៃថា ដំបូន្មានរបស់ឪពុកម្ដាយ ឬរបស់គ្រូជាការត្រឹមត្រូវហើយ តែបើគេទ្រាំគោរពតាមដំបូន្មាននោះ ខ្លួនគេហាក់ដូចជាគ្មានភាពម្ចាស់ការ ឬឯករាជ្យភាព។ ឪពុកម្ដាយ ឬ អ្នកអប់រំ គប្បីពន្យល់ណែនាំឱ្យបានយល់ស៊ីជម្រៅថា ស្មារតីម្ចាស់ការមិនមែនស្ថិតនៅលើការមិនគោរព ឬ ការមិន ស្ដាប់បង្គាប់ពាក្យទូន្មានរបស់មនុស្សចាស់ទេ តែជំទង់ត្រូវការឱ្យមានការជួយជ្រោមជ្រែងពីមនុស្សចាស់ ដែលមានបទពិសោធន៍ប៉ុណ្ណោះ។ ជំទង់ត្រូវខិតខំព្យាយាមសិក្សា ឬធ្វើការដោយគ្រាប់តាមមនុស្សចាស់ដែលឆ្លងកាត់បទពិសោធន៍។

ពិភពលោកទាំងមូល ទាំងផ្នែកជីវភាពរស់នៅ ទាំងផ្នែកការងារ ទាំងផ្នែកបណ្ដុះបណ្ដាលធនធានមនុស្ស ទាំងផ្នែកផលិតកម្ម ទាមទារឱ្យមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកទេស ហើយដែលតម្រូវឱ្យជំទង់ និងយុវជន មានការខិតខំប្រឹងប្រែងក្នុងការសិក្សា។

គេកត់សម្គាល់ឃើញថា ពេលមានពិធីបុណ្យទានក្នុងវត្តអារាមម្ដងម្កាល ក្មេងជំទង់ប្រុស-ស្រីក្នុងអាយុ ១៣-១៤ឆ្នាំ មិនព្រមដើរតាម ឬអង្គុយជិតឪពុកម្ដាយទេ។ អ្នកអាណាព្យាបាល និងអ្នកអប់រំ គួរពន្យល់ណែនាំជំទង់ ឱ្យបានយល់ពីស្មារតីម្ចាស់ការលើរាល់ទង្វើផ្សេងៗ ។ ការពន្យល់ណែនាំនេះ អាចធ្វើដោយផ្ទាល់ក៏បាន ជាប្រយោលក៏បាន ទើបអាចឆ្លើយតបបាននឹងសំណូមពររបស់សង្គម ក្នុងការបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈរបស់ជំទង់ឱ្យចុះសម្រុងក្នុងសង្គម។

**ឧទាហរណ៍** ៖ ជំទង់មិនសូវយល់ពីកិច្ចការដែលគ្រូដាក់ឱ្យធ្វើនៅផ្ទះ។ គេបានពឹងឪពុកម្ដាយ ឬ បងប្រុសស្រីឱ្យជួយវា។ មនុស្សចាស់ ឬមនុស្សពេញវ័យ គ្រាន់តែជួយពន្យល់ណែនាំប៉ុណ្ណោះ មិនត្រូវធ្វើកិច្ចការនេះជួសគេទេ ដើម្បីកុំឱ្យជំទង់មានទម្លាប់អាក្រក់។

ចំណាត់តាំងកិច្ចការឱ្យធ្វើជាបុគ្គល ឬធ្វើជាក្រុមក្នុងថ្នាក់ ទាមទារឱ្យគ្រូតាមដាន ឬសង្កេតឱ្យបានដិតដល់ ទើបសម្រេចបានតាមវត្ថុបំណងនៃការសិក្សា។ តែបើគ្រូបណ្តែតបណ្តោយនេះ ជំទង់នឹងធ្វើកិច្ចការនោះទៅតាមទំនើងចិត្តយល់ឃើញរបស់គេ ដើម្បីបង្ហាញឱ្យឃើញស្មារតីម្ចាស់ការរបស់គេ។

## ៦- ស្មារតីរាប់រកមិត្តភក្តិ និង ស្មារតីសមូហភាព

វ័យកុមារក៏ដោយ វ័យជំទង់ក៏ដែរ សុទ្ធតែមានតម្រូវការខ្ពស់ក្នុងការសេពគប់ និងរាប់រកមិត្តភក្តិស្រករ វ័យ។ កាលពីវ័យកុមារ គេស្តាប់បង្គាប់ និងធ្វើតាមឪពុកម្តាយ និងគ្រូបង្រៀនរបស់គេ។ កុមារងាយចងមិត្តភាព ជាមួយគ្នាណាស់ ទោះណាជាវាមិនទាន់ស្គាល់គ្នាច្បាស់ក៏ដោយ។ លុះដល់វ័យជំទង់ចូលរៀនថ្នាក់មធ្យមសិក្សា គេចាត់ទុកខ្លួនគេថា ជាបុគ្គលម្នាក់មានតម្លៃណាស់ក្នុងចំណោមមិត្តភក្តិស្រករវ័យ និងក្នុង សង្គម។ ចំណងមិត្តភាពរវាងជំទង់ និងជំទង់អាចស្ថិតស្ថេរបានយូរ គឺអាស្រ័យទៅលើសេចក្តីស្មោះត្រង់នឹងគ្នា ហើយចំណងមិត្តភាពអាចបាត់បង់ទៅវិញបាន កាលណាគេទទួលបានគុណវិបត្តិ។ ការសេពគប់រាប់រកមិត្តភក្តិក្តី សកម្មភាពផ្សេងៗក្តីរបស់ជំទង់ ទាមទារឱ្យអ្នកអាណាព្យាបាល និងអ្នកអប់រំតាមដាន និងពន្យល់ណែនាំជំទង់ឱ្យបានដិតដល់ ហើយមិនអាចបណ្តែតបណ្តោយបានទេ ទើបចៀសផុតដំណើរថ្លោះធ្លោយ ឬគុណវិបត្តិ ឬបទល្មើសផ្សេងៗ ដែលអាចនឹងកើតមានដល់ជំទង់។ អ្នកអាណាព្យាបាលក្តីអ្នកអប់រំក្តី ត្រូវប្រើសញ្ចេតនាពន្យល់អប់រំជំទង់ឱ្យយល់ពីការសេពគប់មិត្តភក្តិ និង ទង្វើផ្សេងៗដែលនាំឱ្យមានផលវិបាកដល់គ្រួសារ និង សាលារៀន។ ជំទង់ចូលចិត្តប្រកាន់យកអាកប្បកិរិយាមិនចេះរណបគេ។ ជំទង់មានទំនុកចិត្តលើខ្លួនឯងច្រើន។

ជំទង់ជាប់ជំពាក់ចិត្តទៅនឹងទំនាក់ទំនងរវាងបុគ្គល និងសមូហភាព និងទំនាក់ទំនងជាមួយមិត្តស្រករ វ័យ។ បញ្ញត្តិផ្ទាល់ខ្លួនដែលរួមចំណែកដល់ការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់ជំទង់មានច្រើនទ្រង់ទ្រាយណាស់ ហើយអភិវឌ្ឍទៅតាមស្ថានភាពពិសេសផ្សេងៗគ្នា។ សូម្បីតែជំទង់ដែលរស់នៅក្នុងមជ្ឈដ្ឋានសង្គម និងមជ្ឈដ្ឋានសាលារៀនជាមួយគ្នាក៏ដោយ មិនអាចមានបុគ្គលិកលក្ខណៈជាពុម្ពតែមួយបានឡើយ។

ក្នុងវ័យរៀនដល់ថ្នាក់វិទ្យាល័យ ក្មេងជំទង់ប្រុសចាប់ផ្តើមមានបំណិនប្រសប់ និងទំនាក់ទំនងអាថ៌កំបាំង ជាមួយក្មេងស្រីជំទង់វ័យស្រករគ្នាក្នុងសង្គម ឬក្នុងសាលារៀន។ មុនដំបូងទំនាក់ទំនងនេះ មានលក្ខណៈជាមិត្តភាព ក្រោយមកអាចក្លាយទៅជាទំនាក់ទំនងស្នេហាអាថ៌កំបាំងពីមុខមនុស្សចាស់។ ក្មេងប្រុសជំទង់ចង់បានកិត្យានុភាព និងមានមោទនភាពណាស់ ចំពោះស្នាដៃសិក្សា ស្នាដៃប្រកួតកីឡា និងស្នាដៃសម្តែងសិល្បៈ។ ក្នុងពេលចាប់ចូលរៀននៅអនុវិទ្យាល័យ ជំទង់ត្រូវបានឪពុកម្តាយ និងគ្រូ ប្រគល់ឱ្យមានទំនួលខុសត្រូវជាបុគ្គល ឬជាសមូហភាពចំពោះរបស់ប្រើប្រាស់ ឬភារកិច្ចផ្សេងៗ ។

**ឧទាហរណ៍ ៖** ឪពុកម្តាយទិញនាឡិកា កង់ ម៉ូតូ ឱ្យកូនប្រើប្រាស់ជិះទៅរៀន។

គ្រូទទួលបន្ទុកថ្នាក់ប្រគល់ ឬចែកវេនឱ្យក្រុមសិស្សទទួលខុសត្រូវក្នុងការថែទាំសួនច្បារមុខថ្នាក់រៀន ការថែរក្សាសម្ភារៈក្នុងថ្នាក់រៀន អនាម័យក្នុងថ្នាក់រៀន។ ចំពោះក្មេងជំទង់ស្រីៗ នៅពេលដែលគេមានបន្លាស់ប្តូររូបភាពផ្លូវកាយ និងទឹកមុខ គេច្រើនបាត់បង់ ប្រជាប្រិយភាព និងសេចក្តីរាប់អានមិត្តភក្តិ។ គេមានភាពប្របូកប្រប្រល់ក្នុងទំនាក់ទំនងជាមួយក្មេងជំទង់ ប្រុសៗវ័យស្រករគ្នា ដោយសារតែការចំអែចំអន់លេងសើចច្រើនក្នុងចំណោមមិត្តភក្តិ។ ជំនួបការលំបាកបែបនេះ គឺពេលក្មេងជំទង់ស្រីឈានចូលវ័យគ្រប់ការ ឬវ័យដែលគេកំពុងរៀននៅថ្នាក់វិទ្យាល័យ។ ក្មេងជំទង់ស្រីឆាប់ជឿជាងក្មេងជំទង់ប្រុស។ ក្មេងជំទង់ស្រីមានការអៀនខ្មាស់ច្រើនណាស់។ ក្មេងជំទង់ស្រីដែលរៀននៅសាលាមត្តេយ្យ សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដែលមានទីតាំងនៅជិតគ្នា គ្មានបង្ហាញឱ្យឃើញនូវហេតុផលអវិជ្ជមានចំពោះឥរិយាបថបែបនេះឡើយ។ ចំពោះក្មេងជំទង់ស្រីដែលគ្រួសារផ្លាស់ប្តូរទីលំនៅ ឬត្រូវផ្លាស់ប្តូរសាលារៀន ឆ្ងាយពីបឋមសិក្សាមកអនុវិទ្យាល័យ ឬ ពីអនុវិទ្យាល័យទៅវិទ្យាល័យ ការស្រាវជ្រាវបង្ហាញឱ្យឃើញថា ក្មេងជំទង់ស្រីបញ្ចេញនូវហេតុផលអវិជ្ជមានក្នុងការសិក្សា ឬសកម្មភាពសម្ភាហភាព។ ចំពោះក្មេងជំទង់ប្រុសវិញ គេច្រើនប្រកាន់អាកប្បកិរិយាប្រកួតប្រជែង ប្រៀបធៀប ចង់បានស្នាដៃលើសគេ ចេះវាយតម្លៃខ្លួនឯង និងចេះគ្រប់គ្រងខ្លួនឯង

## ៧- សកម្មភាពសិក្សា និង ការអភិវឌ្ឍនៃបញ្ញា

ជំទង់តម្រង់ទិសនៃការសិក្សារបស់ខ្លួននៅក្នុងសាលារៀន ទៅរកសកម្មភាពជាសមូហភាពជាក្រុម ឬជាដៃគូ។ គេត្រូវមកសាលារៀនរាល់ថ្ងៃ។ ដោយសារសកម្មភាពសិក្សាក្នុងរយៈពេលដ៏យូរនៅមធ្យមសិក្សា សតិបញ្ញា បញ្ញត្តិផ្ទាល់ខ្លួន ចរិតលក្ខណៈ ចំណង់ចំណូលចិត្ត សម្បទា ឫកពា ឧត្តមគតិ ពោលគឺកត្តាដែលគួបផ្សំគ្នាក្នុងការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់ជំទង់ ចេះតែអភិវឌ្ឍឡើងសំបូរបែប។

ក្នុងដំណាក់កាលនេះ គ្រូត្រូវយកចិត្តទុកដាក់ពន្យល់ណែនាំ និងអប់រំជំទង់ឱ្យចេះរៀនពិចារណាលើខ្លួនឯង ជាពិសេសចំពោះបញ្ញត្តិដែលគេសិក្សាក្នុងថ្នាក់រៀន អាកប្បកិរិយា និងបទពិសោធន៍របស់មនុស្ស ចាស់។ ជំទង់ចាប់ផ្តើមមានបុគ្គលិកលក្ខណៈ និងចេះវាយតម្លៃលើខ្លួនឯងទៅលើស្នាដៃ និងជោគជ័យក្នុងការសិក្សា។ ជំទង់ដែលរស់នៅក្នុងមជ្ឈដ្ឋានផ្សេងៗគ្នាក៏ដោយ មជ្ឈដ្ឋានសង្គមជាមួយគ្នាក៏ដោយមិនអាចមានចិត្តគំនិត និង បុគ្គលិកលក្ខណៈដូចគ្នាបេះបិទទេ។

**ឧទាហរណ៍ ៖** ជំទង់ខ្លះ អះអាងថា ខ្លួនគេជាអ្នកមានជោគជ័យ និងស្នាដៃខ្ពស់ក្នុងការសិក្សា និងក្នុងការប្រកួតកីឡា។ ជំទង់ខ្លះបែរជាពោលថា សមត្ថភាពរបស់គេស្ថិតនៅរណបមិត្តរួមថ្នាក់នៅឡើយ។

ជាទូទៅសិស្សជំទង់ប្រុស-ស្រី ដែលរៀនពូកែនៅមធ្យមសិក្សា មានលក្ខណៈគួរឱ្យកត់សម្គាល់បានប្រាំមួយ យ៉ាង ៖

- មានចំណង់ចំណូលចិត្តស្វែងយល់ដឹងទៅលើខ្លឹមសារមេរៀន
- មានស្មារតីប្រុងប្រយ័ត្នក្នុងពេលរៀនក្នុងថ្នាក់

- មានគំនិតច្នៃប្រឌិត សកម្ម ហើយធ្វើកិច្ចការដោយផ្ចិតផ្ចង់
- ចូលចិត្តត្រួតពិនិត្យ និងភ្ញាក់រឭកទៅលើការយល់ដឹងរបស់ខ្លួន
- មានវិធីសិក្សាផ្ទាល់ខ្លួនល្អត្រឹមត្រូវទៀងទាត់ក្នុងថ្នាក់រៀន និង នៅផ្ទះ
- ចេះគោរពវិន័យសាលា និងស្ដាប់ដំបូន្មានរបស់ឪពុកម្ដាយ និងគ្រូ។

ការស្រាវជ្រាវរបស់ពពួកចិត្តវិទូបច្ចឹមប្រទេស បានបង្ហាញឱ្យឃើញថា សិស្សជំទង់ដែលរៀនបានចំណាត់ថ្នាក់មធ្យមមិនអាចមានចំណាត់ថ្នាក់ល្អលើសគេទេ តែជំទង់ដែលរៀនបានចំណាត់ថ្នាក់ក្រោមមធ្យម អាចរៀនបានចំណាត់មធ្យមបាន។ ជំទង់ខ្លះ រៀនបានចំណាត់ខ្ពស់នៅបឋមសិក្សា លុះដល់ពេលគេចូលរៀននៅមធ្យមសិក្សា គេអាចបានចំណាត់ថ្នាក់ទាប ឬមធ្យមទៅវិញក៏មានដែរ។ កុមារ និងវ័យជំទង់ឆាប់ទទួលឥទ្ធិពល ឬ កំណត់គំនិតតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាស់ ដូចជា: ទូរទស្សន៍ វិទ្យុ ខ្សែភាពយន្តវីដេអូ និង សារព័ត៌មានក្នុងស្រុក។ ជំទង់ដែលមិនបានបន្តការសិក្សានៅមធ្យមសិក្សា និងជំទង់ដែលបានបន្តការសិក្សានៅមធ្យមសិក្សា មានការអភិវឌ្ឍនៃបញ្ញត្តិផ្ទាល់ខ្លួន និងការអភិវឌ្ឍបុគ្គលិកលក្ខណៈមិនដូចគ្នាទេ។ ជំទង់ខ្លះ មានការអភិវឌ្ឍនៃបញ្ញត្តិផ្ទាល់ខ្លួន មិនឆ្លើយតបបានទៅនឹងការធំធាត់នៃរាងកាយរបស់គេទេ។

**ឧទាហរណ៍** ៖ ចាស់ៗច្រើនពោលថា Belរៀនចេះដឹងច្រើន ពេលចម្រើនវ័យ។ កាន់តែធំកាន់តែភ្លើហើយល្ងង់។

នៅក្នុងលំនាំនៃការបង្រៀន និងការអប់រំក្នុងសាលារៀន កត្តាដែលធ្វើឱ្យជំទង់អាចវាយតម្លៃបានទៅ សមត្ថភាព ឬសម្បទារបស់ខ្លួនគឺ ៖

- ការដាក់ពិន្ទុ
- ការដាក់និទ្ទេស
- ការធ្វើចំណាត់ថ្នាក់
- ការផ្ដល់រង្វាន់ ឬ ប័ណ្ណសរសើរ
- ការសរសើរលើកទឹកចិត្ត

ក្នុងថ្នាក់រៀន កត្តាដែលរួមចំណែកដល់ការបណ្ដុះបណ្ដាលបញ្ញត្តិផ្ទាល់ខ្លួន និងបុគ្គលិកលក្ខណៈរបស់ជំទង់មាន ៖ គ្រូបង្រៀន មិត្តរួមថ្នាក់ វិធីបង្រៀន ខ្លឹមសារមេរៀន ចំណាត់តាំងសកម្មភាពសិស្ស ការពង្រឹងចំណេះដឹង និងការដាក់កិច្ចការឱ្យសិស្សធ្វើ។ ការលូតលាស់ផ្នែកសរីរាង្គកាយ ពិតជាជាប់ពាក់ព័ន្ធ និងមានលក្ខណៈសមាមាត្រទៅនឹងការលូតលាស់នៃបញ្ញត្តិផ្ទាល់ខ្លួន តែចំពោះជំទង់ដែលកំពុងបន្តសិក្សានៅមធ្យមសិក្សា មានការលូតលាស់តែបទពិសោធន៍ក្នុងពលកម្មប៉ុណ្ណោះ។ ការសិក្សា និងការអប់រំជំទង់ត្រូវផ្សារភ្ជាប់ទៅនឹង ការអប់រំកាយ ធាតុអាកាស កម្រិតជីវភាពរស់នៅ ឬ សេដ្ឋកិច្ចសង្គម ការអប់រំក្នុងគ្រួសារ និង បរិយាកាសសង្គម។ ឪពុកម្ដាយ និងគ្រូបង្រៀនត្រូវជួយពន្យល់ណែនាំ និងអប់រំជំទង់ឱ្យយកចិត្តទុកដាក់ខិតខំព្យាយាមសិក្សាគ្រប់មុខវិជ្ជាសិក្សា ទាំងវិទ្យាសាស្ត្រសង្គម ទាំងវិទ្យាសាស្ត្រពិត ដូចជា ៖

- ណែនាំជំទង់ឱ្យសេពគប់តែមិត្តភក្តិដែលស្រឡាញ់ការសិក្សា ចេះស្តាប់ដំបូន្មានឪពុកម្តាយ និងគ្រូ។
- ពន្យល់ណែនាំកូនឱ្យយល់ និងមើលឃើញអត្ថប្រយោជន៍នៃការសិក្សាទាំងវិទ្យាសាស្ត្រពិត ទាំងវិទ្យា សាស្ត្រសង្គម។

ឪពុកម្តាយក្នុងគ្រួសារជំទង់ខ្លះ មានកម្រិតយល់ដឹង និងបទពិសោធន៍ទន់ខ្សោយក្នុងការអប់រំជំទង់ ដែលកំពុងរៀននៅមធ្យមសិក្សា ដូចជាបណ្តោតបណ្តោយកូន ទម្រើសកូន ឬកាន់ជើងកូន។ ក្មេងជំទង់ប្រុស ដែលឪពុកម្តាយបណ្តោតបណ្តោយហួសហេតុ ច្រើនមានអាកប្បកិរិយា និងទទួលផលវិបាកដូចតទៅ ៖

- មានអាកប្បកិរិយាច្រឡឹម
- ស្វែងយល់ការសិក្សាក្នុងថ្នាក់តាមបែបបង្ខិតបង្ខំ
- មិនចុះសម្រុងក្នុងសង្គម និងក្នុងចំណោមមិត្តភក្តិល្អ
- ជួបការលំបាកក្នុងការស្វែងយល់ទៅលើមជ្ឈដ្ឋានថ្មី
- មិត្តស្រករវ័យមិនសេពគប់រាប់រក
- ផ្តាច់ខ្លួនចេញពីក្រុមមិត្តរួមថ្នាក់
- ឆាប់អាក់អន់ចិត្ត
- កម្រមានស្នាដៃរៀនពូកែ
- សេពគប់បនប្រព្រឹត្តល្មើស

នៅប្រទេសខ្លះ រដ្ឋាភិបាលរៀបចំឱ្យមានយុទ្ធវិធី សម្រាប់ទប់ស្កាត់ជំទង់មិនឱ្យទទួលឥទ្ធិពលអាក្រក់ ក្នុងសង្គម។ នៅក្រៅម៉ោងសិក្សាក្នុងសាលារៀន គេរៀបចំឱ្យមានកម្មវិធីដូចតទៅៈ សកម្មភាពសិល្បៈ សកម្ម ភាពសិក្សាវិទ្យាសាស្ត្រ និងបច្ចេកទេស សកម្មភាពប្រកួតកីឡាគ្រប់ប្រភេទ កម្មវិធីសិក្សាតូរ្យតន្ត្រី ល្បែង កំសាន្តតាមលក្ខណៈប្រពៃណី ទៅតាមពេលវេលា និងរដូវនៃពិធីបុណ្យជាតិ បុណ្យប្រពៃណីបុណ្យ សាសនា។ ចង់អប់រំជំទង់ឱ្យល្អ មជ្ឈដ្ឋានគ្រួសារ សង្គម និងសាលារៀន គួរសហការគ្នាឱ្យបានជិតស្និទ្ធ និង ឯកភាពគ្នា ដូចជា ៖

- តាមដានសកម្មភាព និងការសិក្សារបស់ជំទង់
- ប្រាស្រ័យទាក់ទងពីជំទង់ជាកូន ជាមួយគ្រូ ជាមួយសាលារៀន ជាមួយភ្នាក់ងារសង្គម
- ជួយជំទង់ឱ្យចេះស្វែងយល់ពីសកម្មភាពផ្សេងៗ និងស្ថានភាពថ្មីៗ
- គួបផ្សំការអប់រំក្នុងគ្រួសារទៅនឹងការអប់រំក្នុងសាលារៀន ក្នុងសង្គម
- ចាប់អារម្មណ៍ និងវាយតម្លៃទៅលើទង្វើរបស់ជំទង់ជាមួយមនុស្សក្នុងសង្គម ជាមិត្តភក្តិស្រករវ័យជាមួយមនុស្សចាស់។

ក្នុងម៉ោងបង្រៀនមុខវិជ្ជានីមួយៗ គ្រូគប្បីគ្រប់គ្រងវិន័យសមូហភាពសិស្សឱ្យបាន ទើបវត្ថុបំណង នៃ ការបង្រៀនមេរៀនណាមួយនោះ បានសម្រេចតាមគោលដៅដែលបានគ្រោងទុក។ ក្នុងប្រការនេះ គ្រូ ត្រូវ អប់រំជំទង់ឱ្យចេះ ៖

- ត្រិះរិះពិចារណាទៅលើស្ថានភាពមានបញ្ហា
- ប្រមូលផ្តុំស្មារតីប្រុងប្រយ័ត្ន
- ប្រកាន់សតិអារម្មណ៍នឹងនរ
- គ្រប់គ្រងពេលវេលាឱ្យបាន
- បង្ក្រាបការព្រួយបារម្ភ និងសតិអារម្មណ៍មិននឹងនរឱ្យបាន

### ៨- ចំណង់ចំណូលចិត្តចំពោះវិជ្ជាជីវៈ

វ័យជំទង់ ជាវ័យដែលជាប់ពាក់ព័ន្ធទៅនឹងទិដ្ឋភាពសង្គមៈ ជម្រើសវិជ្ជាជីវៈ ជំនឿលើខ្លួនឯង ជំនឿលើអ្នកដទៃ និងការប្រព្រឹត្តិល្មើស។ វ័យជំទង់ជាវ័យមានវិបត្តិ និងទទួលរងការទិតៀន ស្តីបន្ទោសពីមនុស្សចាស់។ ជំទង់ច្រើនមានការត្រិះរិះ និងជម្រើសវិជ្ជាជីវៈមិនទាន់ប្រាកដប្រជាក្នុងចិត្ត។ ជំទង់ច្រើនប្រកាន់អាកប្បកិរិយាពយមាយ។ ជម្រើសវិជ្ជាជីវៈក្នុងសង្គមរបស់ជំទង់ច្រើនស្ថិតនៅក្នុងការស្រមៃ។ ការស្រមៃ និងឧត្តមគតិរបស់ជំទង់សំបូរបែបណាស់ តែមិនបិតនៅទៀងទាត់ ឬបិតបេះបានយូរក្នុងចិត្តគំនិតគេឡើយ។

**ឧទាហរណ៍ ៖** ថ្ងៃនេះ គេស្រមៃថា ខ្លួនគេនឹងក្លាយទៅជាអ្នកបើកយន្តហោះ វាយសម្រុកទម្លាក់គ្រាប់ បែកទៅលើពួកសត្រូវឈ្លានពានមាតុភូមិ។ ថ្ងៃស្អែក គេចង់ក្លាយខ្លួនទៅជា អ្នកប្រកួតកីឡាបាល់ទាត់ ដណ្តើមបានពានរង្វាន់ផ្តាច់ព្រ័ត្រពិភពលោក។ ថ្ងៃបន្ទាប់មក គេចង់ធ្វើខ្លួនគេឱ្យទៅជាសិល្បករចម្រៀងដ៏ល្បីឈ្មោះ។

បំណងប្រាថ្នា និង ចំណង់ចំណូលចិត្តរបស់ជំទង់ផ្សារភ្ជាប់ទៅនឹងការតស៊ូ សេចក្តីព្យាយាម និងការ ខិតខំប្រឹងប្រែង និងទាមទារឱ្យមានជំនួយជ្រោមជ្រែងពីមនុស្សចាស់ផង មានឪពុកម្តាយ និងមជ្ឈដ្ឋានសាលារៀនជាដើម។ ជំទង់មានភាពខ្ជិលច្រអូស មិនអាចធ្វើឱ្យការស្រមៃក្លាយទៅជាការពិតតាមបំណងប្រាថ្នារបស់ខ្លួនឡើយ។ គេងាយនឹងបោះបង់ចោលបំណងរបស់គេ ចំពោះវិជ្ជាជីវៈក្នុងសង្គមណាស់។ ចំពោះជំទង់ដែលមានការតស៊ូ ព្យាយាម និង អំណត់ធ្មត់ គួបផ្សំនឹងជំនួយជ្រោមជ្រែងផ្នុងផ្តើមពីអ្នកអាណាព្យាបាល ឬពីអ្នកអប់រំផងនោះ បំណងប្រាថ្នារបស់គេចំពោះវិជ្ជាជីវៈណាមួយនោះ អាចនឹងបានសម្រេចដូចដែលគេគិតទុក។

**ឧទាហរណ៍ ៖** ជំទង់ម្នាក់ចង់ក្លាយខ្លួនទៅជាអ្នកចម្រៀង ឬជាតន្ត្រីករដ៏ប៉ិនប្រសប់ អាស្រ័យដោយ មានជំនួយជ្រោមជ្រែងពីអ្នកអាណាព្យាបាល។ ដោយជំទង់នេះ ព្យាយាម និងមាន លំងប់ខ្លាំងទៅលើមុខរបរនេះ ទៅថ្ងៃអនាគតដ៏ខ្លី គេពិតជាអ្នកចម្រៀង ឬ ជាតន្ត្រីករ ជាប់ចំណាត់ថ្នាក់មែន។

ជំទង់ខ្លះ ចាប់ផ្តើមប្រព្រឹត្ត និងប្រកាន់យកអាកប្បកិរិយាតាមមនុស្សចាស់ៗ បុគ្គលដែលគេរស់នៅស្និតស្នាលជាមួយ សម្រាប់អនាគតរបស់គេ ជាពិសេសគឺគ្រូបង្រៀនដ៏មានប្រជាប្រិយណាម្នាក់នោះ ដែល

គេ ចូលចិត្តជាងគេ។ ការគិត ការក្តាប់បានបញ្ញត្តិ និងការអភិវឌ្ឍសតិបញ្ញារបស់គេមិនទាន់ទុំជោរទេ។ ពេលខ្លះ ជំទង់មិនអាចយល់ច្បាស់ និងកសាងបាននូវបញ្ញត្តិអរូបីឡើយ។ គេត្រូវការឱ្យមានឧទាហរណ៍ ឬជំនួយពី មនុស្សចាស់ ឬអ្នកមានបទពិសោធន៍។ ពេលខ្លះទៀត ជំទង់ហ៊ានធ្វើការត្រាប់តាមកាយវិការ និងសម្តីនិយាយរបស់មនុស្សចាស់ ជាពិសេសគ្រូរបស់ខ្លួន ក្នុងន័យកំប្លែងសើចលេងសប្បាយ ដោយខ្វះពិចារណាឱ្យបានត្រឹមត្រូវ ឬជួនកាលទៀត គេហ៊ានដល់ទៅដាក់ងារហៅឈ្មោះក្រៅមួយទៀតឱ្យមិត្តភក្តិរបស់គេ សម្រាប់ជាការបន្ទុះបង្អាប់សើចលេងកែអផ្សុក កាលណាគេស្ថិតនៅក្នុងចំណោម។

**ឧទាហរណ៍** ៖ ពេលជំទង់ត្រូវធ្វើពលកម្មសង្គមក្រៅសាលារៀន ជំទង់ម្នាក់ធ្វើត្រាប់ដូចគ្នាបេះបិទ តាមសម្តីនិយាយ និងកាយវិការរបស់គ្រូគេម្នាក់ ដែលចូលចិត្តនិយាយកំប្លែងក្នុង ម៉ោងបង្រៀន ធ្វើឱ្យមិត្តភក្តិគេផ្ទុះសំណើច ... ។

## ៩- ទណ្ឌកម្ម និង ការគាបសង្កត់

ការដាក់ទណ្ឌកម្ម ការគាបសង្កត់ ឬការអប់រំដោយប្រើហឹង្សាទៅលើជំទង់ ក៏ទទួលនូវផលវិបាក ឬលទ្ធផលជាអវិជ្ជមានដែរ។ ការដាក់ទណ្ឌកម្ម ឬការធ្វេសប្រហែសចំពោះកូន ត្រូវបានពពួកចិត្តវិទូឱ្យនិយម ន័យថា ជាការធ្វើឱ្យកូនមានរបួសខាងផ្លូវកាយ និងផ្លូវសតិអារម្មណ៍។ មជ្ឈមណ្ឌលជាតិតាមឃ្លាំមើលកុមារ និងជំទង់ដែលមានទីតាំងនៅក្នុងសហរដ្ឋអាមេរិក បានឱ្យដឹងថា កុមារ និងជំទង់ស្លាប់អស់ជាង២០០០នាក់ ជារៀងរាល់ឆ្នាំ ដោយសារតែការធ្វើបាប ដោយការដាក់ទណ្ឌកម្មទៅលើរាងកាយ និងសតិអារម្មណ៍នេះ។ អ្នកដាក់ទណ្ឌកម្មទៅលើកូន ឬធ្វើបាបកូន បានន័យថា ខ្លួនធ្លាប់ត្រូវបានគេដាក់ទណ្ឌកម្មដូចកូនខ្លួនឯងដែរ។ ជួនកាល ការបង្កឱ្យមានវិបត្តិរហូតដល់ទៅដាក់ទណ្ឌកម្មកូននោះ បណ្តាលមកពីកូនដែលធ្វើឱ្យឪពុកម្តាយ ពិបាកគ្រប់គ្រង ចចេសរឹងរូស និយាយស្តីប្រដៅមិនស្តាប់សោះ។ ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ដែល ប្រកាន់យកឥទ្ធិពលនៃការដាក់ទណ្ឌកម្មទៅលើកូន ជួនកាលជាអ្នកចូលចិត្តបង្កើតឱ្យមានហេតុការណ៍តាន តឹងក្នុងគ្រួសារ និងចូលចិត្តបង្កឱ្យមានរឿងអាក្រក់ ដើម្បីចាប់កំហុសកូន។ កូនដែលកើតមកមានទម្ងន់ស្រាល កូនខ្វះការអប់រំល្អក្នុងគ្រួសារ កូនដែលបែកឆ្វេងក្នុងការលូតលាស់សរីរាង្គកាយ កូនកើតមកពិការសរីរាង្គណាមួយ ងាយនឹងឈឺចាប់ និងអាក់អន់ចិត្តណាស់ កាលណាវាទទួលរងទណ្ឌកម្មនេះ ជួនកាល បណ្តាលមកពីកត្តាផ្សេងៗដូចជា ៖ រស់នៅឆ្ងាយពីគេឯង រស់នៅមិនបានទទួលព័ត៌មានអំពីការអប់រំកូន សេដ្ឋកិច្ចគ្រួសារទន់ខ្សោយមិនអាចឆ្លើយតបនឹងតម្រូវការកម្រិតខ្ពស់ក្នុងគ្រួសារ។ ក្មេងជំទង់ខ្លះ ឆាប់ហត់ហេវ ឬ ងងុយដេកក្នុងថ្នាក់រៀន បណ្តាលមកពីជំងឺប្រចាំកាយនេះក៏បណ្តាលមកពីការធ្វេសប្រហែសរបស់អ្នកអាណាព្យាបាលដែរ។ អង្គការការពារសិទ្ធកុមារនៅសហរដ្ឋអាមេរិកចាត់ទុក ការដាក់ទណ្ឌកម្ម ការគាបសង្កត់ និងការធ្វេសប្រហែសចំពោះកុមារ និងជំទង់ ដោយអនុវត្តច្បាប់ តម្រូវឱ្យអ្នកអាណាព្យាបាលជាប់ទណ្ឌកម្មតាមកម្រិតបទល្មើសថ្នាក់មជ្ឈឹម ត្រូវជាប់គុក៦ខែ ឬពិន័យជាប្រាក់៥០០ដុល្លារ។

**លក្ខណៈធ្វេសប្រហែសរបស់ឪពុកម្តាយចំពោះកុមារ និងជំទង់ អាចត្រូវគេកត់សម្គាល់ បានដោយងាយដូចជា ៖**

- សម្លៀកបំពាក់មិនជាទីគាប់ចិត្ត
- សម្លៀកបំពាក់រហែក ហើយមិនបានបោកគក់
- រាងកាយសុទ្ធតែក្អែល ខ្វះអនាម័យ ធុំក្លិន
- សិស្សឯទៀតមិនរាប់រក ព្រោះធុំក្លិនអាក្រក់
- ខ្វះជីវជាតិអាហារ ដែលមានរសជាតិឆ្ងាញ់
- ច្រើនឆាប់ហេវហត់ និង ងងុយដេកក្នុងថ្នាក់រៀន
- ជួនកាលមកដល់សាលារៀនមុនគេ ឬក៏អវត្តមានញយដង
- ពេលសាលាលុបឈ្មោះចោលលែងឱ្យរៀន ច្រើនតែមកលេងក្បែរៗសាលារៀន។

ក្រុមអ្នកចិត្តវិទូ ពិបាកកំណត់វែកញែកឱ្យច្បាស់លាស់ ចំពោះការដាក់ទណ្ឌកម្ម ការគាបសង្កត់ និង ការធ្វេសប្រហែសចំពោះកូនរបស់អ្នកអាណាព្យាបាល។ ការដាក់ទណ្ឌកម្ម ការគាបសង្កត់ និងការធ្វេស ប្រហែសរបស់អ្នកអាណាព្យាបាល ធ្វើឱ្យកុមារ និងជំទង់ទទួលរងផលវិបាកផ្សេងៗ ដូចជា ៖

- ការព្រួយបារម្ភក្នុងចិត្ត ការខកចិត្ត ការអស់សង្ឃឹម
- មានការភ័យខ្លាច កើតជំងឺបាក់ស្បាត
- ទទួលបានពិន្ទុកម្រិតទាប
- ភាពអៀនខ្មាស់ក្នុងចំណោមមិត្តភក្តិ
- ភាពមិនអាចសម្របសម្រួលខ្លួនបានក្នុងដំណោះស្រាយបញ្ហា
- ភាពមិនចុះសម្រុងនឹងមិត្តភក្តិ ឬវិបត្តិផ្លូវចិត្តជាមិត្តភក្តិភេទផ្ទុយគ្នា
- មានវិបត្តិផ្លូវចិត្តក្នុងគ្រួសារ និង ការគាបសង្កត់ខ្លាំងពេក
- ដឹងខ្លួនថា មិនមានអនាគតភ្លឺស្វាងដូចគេ ... ។

កត្តាទាំងនេះអាចជំរុញឱ្យជំទង់ ឬយុវសិស្សឱ្យឈានទៅរកការធ្វើអត្តឃាត ឬបោះបង់ចោលគ្រួសារ។ ការធ្វេសប្រហែសខ្លះ បណ្តាលមកពីឪពុកម្តាយ ឬគ្រូមិនមានលក្ខណៈជិតស្និទ្ធនឹងជំទង់ ដូចជា ៖

- មិនទម្លាប់ឱ្យកូនជិះរថយន្តជាមួយ ទោះជាស្ថិតក្នុងស្ថានភាពបន្ទាន់ក៏ដោយ
- ឪពុកម្តាយមិនធ្លាប់នាំកូនដើរលេង ឱ្យស្គាល់មជ្ឈដ្ឋានច្រើន
- ឪពុកម្តាយដែលមិនធ្លាប់អោបរឹតកូន
- កូនរបួសបន្តិចបន្តួចមិនព្រមព្យាបាលនៅផ្ទះ
- គ្រូមិនអនុញ្ញាតឱ្យសិស្សជំទង់ទៅលេងដល់ផ្ទះ
- គ្រូដែលចោទប្រកាន់សិស្សតាមបែបខុសឆ្គង
- គ្រូដែលនិយមបង្កើតឱ្យមានភាពតានតឹងជាមួយសិស្ស ... ។

ការគាបសង្កត់ ការដាក់ទណ្ឌកម្ម ការធ្វេសប្រហែស សុទ្ធតែជាកត្តា និងជាមូលហេតុ ធ្វើឱ្យជំទង់ងាយនឹងបោះបង់ចោលសាលារៀន និងគ្រួសារ ទៅតាមការអូសទាញរបស់បនខិលខូច បក្សពួកបងធំ ផ្កា

ច់ ខ្លួនចេញពីឪពុកម្តាយ ទៅជួលផ្ទះរស់នៅជាមួយក្រុម ដើម្បីប្រព្រឹត្តបទល្មើសផ្សេងៗក្នុងសង្គម។ ជំទង់ខ្លះត្រូវ ឥទ្ធិពលបនខិលខូចអូសទាញបាន ហើយចចេសមានះនឹងឪពុកម្តាយ ដើម្បីត្រាប់តាមកូនអ្នកមានសំបូរ បែប។ ជំទង់បែបនេះច្រើនអវត្តមានញឹកញយដងក្នុងម៉ោងរៀនក្នុងថ្នាក់ ហើយរៀនបានចំណាត់ថ្នាក់ពីមធ្យម មកខ្សោយ។ ជំទង់ប្រភេទនេះ មានអាកប្បកិរិយាគួរឱ្យកត់សម្គាល់បានដូចជា ៖

- មិនឆ្លៀតពេលរៀន ឬជួយធ្វើការឪពុកម្តាយនៅផ្ទះ
- ដើរបាត់ពីផ្ទះ ទៅនៅបនល្បែង ហ្គេម ប៊ីយ៉ា
- មករៀនក្នុងថ្នាក់មិនទៀងទាត់
- ចូលផ្ទះ ឪពុកស្តី ម្តាយជេរ
- ទាមទារសម្ភារៈប្រើប្រាស់ត្រាប់តាមកូនអ្នកមាន ... ។

ក្នុងករណីបែបនេះ អ្នកអាណាព្យាបាល ត្រូវប្រើសញ្ចេតនាអប់រំជំទង់ តាមរយៈការពន្យល់ណែនាំដូចជា ៖

- ពន្យល់ឱ្យជំទង់យល់ពីស្ថានភាពគ្រួសារជួបកង្វះខាត
- ទម្លាប់កូនឱ្យដើរផ្លូវល្អ ខំព្យាយាមសិក្សា
- អប់រំណែនាំកូនឱ្យយល់ពីរបៀបស្លៀកពាក់ របៀបហូបចុក អនាម័យ ការប្រើប្រាស់ថែទាំសម្ភារៈ ចេះសន្សំសំចៃ ចេះជួយការងារផ្ទះ ចេះឆ្លៀតពេលរៀននៅផ្ទះ ...
- អប់រំកូនកុំឱ្យសេពគប់សមាសភាពមិត្តមិនល្អ កូនស្រីនឹងត្រូវគេទិតៀន កូនប្រុសនឹងជាប់បទប្រព្រឹត្ត ល្មើស ...
- អប់រំកូនកុំឱ្យត្រាប់តាមកូនអ្នកមានសំបូរបែប
- បង្កលក្ខណៈងាយស្រួលខាងផ្លូវចិត្ត ខាងផ្នែកសម្ភារៈសមរម្យដល់កូនក្នុងការសិក្សា
- អប់រំកូន ឬដាស់តឿនកូនឱ្យចេះគួរសម ចេះប្រកាន់យកសីលធម៌ល្អ
- សហការជាមួយសាលារៀន ដើម្បីតាមដានកូន ... ។

### ១០- ការលំបាករបស់សាលារៀនចំពោះជំទង់

ចំណង់ចំណូលចិត្តរបស់សិស្សជំទង់ប្រុស-ស្រី ក្នុងការសិក្សាមុខវិជ្ជាឯកទេសនៅមធ្យមសិក្សាមិនដូចគ្នាទេ សិស្សខ្លះចូលចិត្តវិទ្យាសាស្ត្រពិត ខ្លះចូលចិត្តវិទ្យាសាស្ត្រសង្គម។ មជ្ឈដ្ឋានសាលារៀនខ្លះខ្វះ សម្ភារៈ និង ឯកសារសិក្សា លក្ខខណ្ឌសេដ្ឋកិច្ចក្នុងសង្គម ឬ ក្នុងតំបន់មានកម្រិតទាប ធ្វើឱ្យជំទង់មានកម្រិតយល់ដឹងខ្សោយ ហើយជួនកាលមិនអាចបន្តការសិក្សាទៅមុខបានទៀតឡើយ។ ជំទង់ខ្លះរៀនបានត្រឹមចប់ ថ្នាក់បឋមសិក្សា។ សាលាមធ្យមសិក្សានៅឆ្ងាយពីផ្ទះ ហើយសេដ្ឋកិច្ចគ្រួសារជួបប្រទះការខ្សត់ខ្សោយ ឪពុក ម្តាយគ្មានលទ្ធភាពឱ្យកូនបន្តការសិក្សា។ តំបន់ឆ្ងាយដាច់ស្រយាលខ្លះ មិនមានសិស្សស្រីជំទង់រៀនចប់វិទ្យាល័យ មកបន្តការសិក្សានៅឧត្តមសិក្សាឡើយ។ ជំទង់ខ្លះរៀនចប់ថ្នាក់បឋមសិក្សា ឬបោះបង់ចោលថ្នាក់ មធ្យមសិក្សា ដើម្បីស្វែងរកការងារតាមសហគ្រាស ឬតាមរោងចក្រ ឬទៅសាងផ្នួស ឬនៅជួយ

ការងារក្នុង គ្រួសារ។ ក្មេងស្រីជំទង់មានគំនិតអាងច្រើនជាងក្មេងប្រុសជំទង់។ គេសង្ឃឹមថា ក្រោយពេលរៀនចប់មធ្យមសិក្សា គេនឹងបានរៀបការ ឬឪពុកម្ដាយទុកដាក់ឱ្យមានគូរស្រេករឆាប់ៗ ។

ចំពោះពេលសិក្សាក្នុងថ្នាក់រៀន គេសង្កេតឃើញសិស្សជំទង់ប្រុស-ស្រី មានអាកប្បកិរិយាមិនដូចគ្នា ទេ។ ជួនកាលគ្រូជួបការលំបាក និងវាយតម្លៃមិនបានត្រឹមត្រូវ។

ចំពោះក្មេងជំទង់ស្រី ៖

- មានចរិតស្ងប់ស្ងាត់
- មានស្មារតីប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ក្នុងរយៈពេលយូរជាងសិស្សប្រុសៗ
- ច្រើនមានស្នាដៃខ្ពស់ និងទទួលបានពិន្ទុខ្ពស់ផ្នែកវិទ្យាសាស្ត្រសង្គម
- ស្ថិតស្វាញក្នុងការសិក្សា
- ត្រូវការគ្រូគាំទ្រ និងវាយតម្លៃខ្ពស់ទៅលើសម្បទា

ចំពោះក្មេងជំទង់ប្រុស ៖

- មានចរិតឈ្លានពាន និងមាត់កច្រើន
- ទទួលរងការស្ដីបន្ទោសពីគ្រូជាញឹកញយដង
- មានចរិតសកម្ម ហើយត្រូវបានគ្រូប្រាស្រ័យទាក់ទងច្រើនជាងក្មេងស្រី
- ជួនកាលទទួលចំណាត់ថ្នាក់ទាបលើសម្បទា និងស្នាដៃ
- ច្រើនបានពិន្ទុខ្ពស់ផ្នែកវិទ្យាសាស្ត្រពិត ។

កត្តាសំខាន់ៗ ដែលគួបផ្សំគ្នាអាចមានលក្ខណៈងាយស្រួល ឬផលវិបាកស្មុគស្មាញក្នុងការបង្រៀន និងការអប់រំវិស័យជំទង់នេះ ៖

- កត្តាសង្គមៈ ឥទ្ធិពលបរិយាកាសសង្គម សេដ្ឋកិច្ច ធាតុអាកាស និងតួនាទីរបស់អាជ្ញាធរ
- កត្តាគ្រួសារៈ ការអប់រំឪពុកម្ដាយ
- កត្តាសាលារៀនៈ គ្រូ មិត្តភក្ដិ វិធីបង្រៀន ខ្លឹមសារមេរៀន កិច្ចការ សកម្មភាពផ្សេងៗ
- កត្តាជីវសាស្ត្រៈ សុខភាពពីកំណើត របបអាហារប្រចាំថ្ងៃ
- កត្តាបណ្ដាញព័ត៌មានក្នុងសង្គមៈ វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្ដី
- កត្តាឥទ្ធិពលវប្បធម៌បរទេសៈ ខ្សែភាពយន្ត វីដេអូអាសអាភាស បនល្បែង ពេស្យាចារ ខារ៉ាអូខេ ឃាតកម្ម ចោរកម្ម ចាប់ជំរិត ចាប់រំលោភ គ្រឿងញៀន ... ។
- កត្តាសកម្មភាពក្រៅសាលាៈ ទង្វើ ឬសកម្មភាពផ្សេងៗជាមួយមិត្តភក្តិ។

តើជំទង់ដែលបង្កឱ្យមានការលំបាកដល់មជ្ឈដ្ឋានសាលារៀន លេចចេញពីប្រភពណាខ្លះ ?

ប្រភពដ៏សំខាន់នោះ គឺមជ្ឈដ្ឋានគ្រួសារតែម្តង ពោលគឺឪពុកម្តាយ និងអ្នកអាណាព្យាបាលជំទង់ ដែលមានបញ្ហាច្រើនដូចជា ៖ ទំនាស់ក្នុងគ្រួសារ សេដ្ឋកិច្ចគ្រួសារ កម្រិតយល់ដឹង និងបទពិសោធន៍ទន់ខ្សោយក្នុងការអប់រំ ដូចជា ៖

- កូនដែលឪពុកម្តាយទម្រើស និងបណ្តែតបណ្តោយហួសហេតុ
- កូនដែលធាប់អាក់អន់ចិត្ត
- កូនដែលផ្តាច់ខ្លួនចេញពីចំណោមមិត្តភក្តិដ៏ល្អ
- កូនដែលមានអារម្មណ៍មិនសប្បាយរីករាយ ក្នុងការសិក្សាស្វែងយល់ដោយខ្លួនឯង
- កូនដែលគ្មានទំនុកចិត្តលើខ្លួនឯង ហើយសិក្សាស្វែងយល់ក្នុងថ្នាក់តាមបែបបង្ខំ
- កូនធ្វើអ្វីៗទៅតាមទំនើងចិត្ត មិនចេះពិចារណា ឬ ស្វ័យត្រួតពិនិត្យ
- កូនដែលដើរបាត់ពីផ្ទះ មិនចេះឆ្លៀតពេលរៀន ឬជួយធ្វើការឪពុកម្តាយ
- កូនដែលទទួលរងការគាបសង្កត់ក្នុងគ្រួសារ
- កូនដែលបាត់បង់ជំនឿជាមួយឪពុកម្តាយ គ្រូ និងសាលារៀន
- កូនកំព្រា និងកូនដែលឪពុកម្តាយលែងលះគ្នា
- កូនដែលឪពុកម្តាយផ្តល់លុយកាក់ ឬសម្ភារៈសិក្សាមិនគ្រប់គ្រាន់
- កូនដែលមានអាកប្បកិរិយាច្រឡឹម
- កូនដែលពិការពីកំណើតដោយជំងឺ ឬពិការដោយគ្រោះថ្នាក់ណាមួយ
- កូនដែលសេពគប់មិត្តបន មានសមាសភាពមិនល្អ
- កូនដែលមើលមិនឃើញអត្ថប្រយោជន៍នៃការសិក្សា
- កូនដែលគ្មានគំនិតប្រកួតប្រជែង មិនចេះស្វ័យគ្រប់គ្រង មិនចេះស្វ័យវាយតម្លៃ មិនចេះភ្ញាក់រឭកក្នុង ការសិក្សា
- កូនដែលឪពុកម្តាយមិនតាមឃ្លាំមើលសកម្មភាព
- កូនដែលឪពុកម្តាយនិយាយស្តីមិនស្តាប់

## IV- សន្និដ្ឋាន

ដើម្បីអប់រំបុគ្គលិកលក្ខណៈជំទង់ឱ្យចុះសម្រុងក្នុងសង្គម មជ្ឈដ្ឋានគ្រួសារ សាលារៀន សង្គមប្រព័ន្ធ ផ្សព្វផ្សាយព័ត៌មាន គួរតែឯកភាពគ្នា និងសហការគ្នា។ ការអប់រំជំទង់ទាមទារឱ្យមនុស្សចាស់ ឬអ្នកអប់រំប្រើ សញ្ចេតនា អំណត់ធ្មត់ ភាពទន់ភ្លន់ និងអហឹង្សា។ បើមជ្ឈដ្ឋានអប់រំទាំងអស់មិនឯកភាពគ្នាទេ វប្បធម៌ ប្រពៃណីកាន់តែថយចុះ ហើយសង្គមទាំងមូលពោលពេញទៅដោយភាពអនាធិបតេយ្យ និងអសន្តិសុខ ដែលបង្កឡើយដោយបទឧក្រិដ្ឋ ធ្វើឱ្យសង្គមគ្មានវឌ្ឍនភាពគ្រប់វិស័យទាំងអស់។

## សំណួរ

១- ដើម្បីជំរុញទឹកចិត្តជំទង់ឱ្យចង់រៀន តើគ្រូបង្រៀនត្រូវធ្វើដូចម្តេចខ្លះ?

២- តើក្នុងថ្នាក់រៀនមួយ កត្តាអ្វីខ្លះដែលរួមចំណែកដល់ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់ជំទង់?

៣- តើក្នុងគ្រួសារ និងក្នុងសាលារៀន អ្នកអាណាព្យាបាល និងអ្នកអប់រំ ត្រូវអប់រំជំទង់យ៉ាងណាខ្លះ?

៤- តើអាកប្បកិរិយារបស់ជំទង់ខុសប្លែកគ្នា បណ្តាលមកពីអ្វីខ្លះ?

៥- តើបុគ្គលិកលក្ខណៈរបស់ជំទង់លេចធ្លោឡើងឱ្យឃើញនូវពេលណា?

៦- ហេតុអ្វីបានជាគ្រូបង្រៀនត្រូវធ្វើការវាយតម្លៃសម្បទា និងស្នាដៃសិក្សារបស់ជំទង់?

## មេរៀនទី៥ ៖ ឥន្ទ្រិយារម្មណ៍

ಌಌಌ

### ១- និយមន័យ

ឥន្ទ្រិយារម្មណ៍ គឺជាលំនាំផ្លូវចិត្តដែលឆ្លុះបញ្ចាំងបានទៅលើលក្ខណៈនីមួយៗដាច់ដោយឡែកពីគ្នានៃវត្ថុ និងបាតុភូតទាំងឡាយ កាលណា វត្ថុ ឬ បាតុភូតនោះ ធ្វើអំពើដោយត្រង់ៗមកចំសរីរាង្គវិញ្ញាណរបស់យើង។

### I- ឥន្ទ្រិយារម្មណ៍មានលក្ខណៈបីយ៉ាងគឺ ៖

- ឥន្ទ្រិយារម្មណ៍គឺជា លំនាំផ្លូវចិត្ត។ ឥន្ទ្រិយារម្មណ៍មិនមែនជាសភាពផ្លូវចិត្ត ហើយវាក៏មិនមែនជាលក្ខណៈផ្លូវចិត្តផងដែរ។
- ឥន្ទ្រិយារម្មណ៍ឆ្លុះបញ្ចាំងបានលើរាល់លក្ខណៈនីមួយៗដាច់ដោយឡែកពីគ្នា ចំពោះ វត្ថុ ឬ បាតុភូតទាំងឡាយ។ ឥន្ទ្រិយារម្មណ៍មិនអាចឆ្លុះបញ្ចាំងបានទៅលើសភាពទូទៅរបស់វត្ថុ និង បាតុភូតបានឡើយ។
- ឥន្ទ្រិយារម្មណ៍ឆ្លុះបញ្ចាំងដោយផ្ទាល់ទៅលើវត្ថុ ឬ បាតុភូតទាំងឡាយ ដែលកំពុងមានអំពើមកលើសរីរាង្គវិញ្ញាណរបស់យើង។ ឥន្ទ្រិយារម្មណ៍មិនឆ្លុះបញ្ចាំងដោយប្រយោលទៅលើវត្ថុ និង បាតុភូតឡើយ។

ដើម្បីអោយយល់កាន់តែច្បាស់ថាអ្វីទៅជាឥន្ទ្រិយារម្មណ៍នោះ អ្នកអាចធ្វើពិសោធន៍មួយដ៏សាមញ្ញដូចតទៅនេះ។ អ្នកយកក្រណាត់រុំភ្នែកមនុស្សម្នាក់អោយជិត រួចអ្នកប្រគល់របស់មួយដ៏ចម្លែកជូនគាត់ដោយសួរគាត់ថា របស់ដ៏ស្រាលនោះ ជាអ្វីទៅ? ឬក៏របស់ដ៏ធ្ងន់នេះ ជាអ្វីទៅ? បុរសនោះមិនអាចប្រាប់ឈ្មោះរបស់នោះអោយអ្នកដឹងបានឡើយ ដោយហេតុថា គាត់អាចស្គាល់បាននូវលក្ខណៈដោយឡែកៗរបស់វត្ថុនោះបាន (ធ្ងន់ ឬ ស្រាល) តែគាត់មិនអាចឆ្លុះបញ្ចាំងដឹងបាន ទៅលើវត្ថុទាំងមូលបានឡើយ។

ដូច្នេះ ឥន្ទ្រិយារម្មណ៍ ជាលំនាំផ្លូវចិត្តដ៏សាមញ្ញបំផុត។ វាមិនអាចជួយយើងអោយទទួលស្គាល់បាន ឬ ញែកដាច់បាន ទៅលើវត្ថុណាមួយបានឡើយ។

### ២- មូលដ្ឋានសរីរៈវិទ្យារបស់ឥន្ទ្រិយារម្មណ៍

ឥន្ទ្រិយារម្មណ៍ប្រព្រឹត្តទៅបាន លុះត្រាតែមាន វត្ថុ ឬ បាតុភូត ណាមួយ ធ្វើអំពើមកលើសរីរាង្គវិញ្ញាណ ឬ សរីរាង្គវិភាគរបស់យើង។

សរីរាង្គវិភាគនីមួយៗ ចែកចេញជា បី ផ្នែក សំខាន់ៗគឺ ៖

សរីរាង្គទទួលរូបភាពវត្ថុ ឬ បាតុភូត គឺជាចុងសរសៃប្រសាទ ដែលទទួលវេទនារម្មណ៍។

**ឧទាហរណ៍ ៖** សរីរាង្គវិភាគរបស់ចក្ខុវិញ្ញាណ គឺ កែវភ្នែក។

សរសៃប្រសាទ ដែលនាំរូបភាពចូលមជ្ឈមណ្ឌលនៃសរសៃប្រសាទ គឺជាសរសៃប្រសាទ ដែលនាំ រំញោចពីសរីរាង្គទទួលរំញោចទៅកាន់ខួរក្បាល។

**ឧទាហរណ៍ ៖** សរសៃប្រសាទនៃចក្ខុវិញ្ញាណ។

កោសិកាសរសៃប្រសាទ ដែលជាប់ទាក់ទិនទៅនឹង អឌ្ឍគោលខួរក្បាល ហើយដែលជាផ្នែក កណ្តាលនៃសរីរាង្គវិភាគ។

**ឧទាហរណ៍ ៖** ចំពោះសរីរាង្គចក្ខុវិញ្ញាណ គឺកំពកខួរកញ្ចឹងក ដែលនាំព័ត៌មានទៅកាន់សំបកខួរ ក្បាល។

ឥន្ទ្រីយារម្មណ៍ កើតមានឡើងនៅត្រង់ផ្នែកទី៣នេះឯង ពោលគឺនៅក្នុងមជ្ឈមណ្ឌលនៃសរសៃប្រសាទ ដែលជាប់ទាក់ទិនទៅនឹងសំបកខួរក្បាល។ ដើម្បីអោយឥន្ទ្រីយារម្មណ៍ កើតមានឡើងបាននោះ ផ្នែកទាំងបីនៃសរសៃប្រសាទនេះ ត្រូវមានសកម្មភាពដំណាលៗគ្នា។ បើផ្នែកណាមួយហើយគ្មានសកម្មភាពនោះ គេមិនអាចមានឥន្ទ្រីយារម្មណ៍បានឡើយ។

សរុបសេចក្តីមក មូលដ្ឋានសរីរៈវិទ្យារបស់ឥន្ទ្រីយារម្មណ៍គឺជា សកម្មភាពដែលកើតមកពីសរីរាង្គវិភាគនីមួយៗដែលស្ថិតនៅជាប់ពីគ្នា។

នៅក្នុងការស្តែងឡើងដ៏ងាយៗ វេទនារម្មណ៍ ជាលក្ខណៈមួយ ដែលកើតមានតាំងពីកំណើតរបស់មនុស្សម្នាក់ៗ ហើយជារ៉េផ្លិចដែលគ្មានលក្ខខណ្ឌផង។ ប៉ុន្តែភាពខុសប្លែកគ្នានៃឥន្ទ្រីយារម្មណ៍របស់មនុស្សម្នាក់ៗ គឺ អាស្រ័យដោយលទ្ធផលនៃការអភិវឌ្ឍន៍ និង ការអប់រំដែលបណ្តុះបណ្តាលឡើង ចំពោះមនុស្សដោយឈរលើមូលដ្ឋាននៃសកម្មភាពរបស់រ៉េផ្លិចមានលក្ខខណ្ឌ។

## ៣- ចរិតសង្គមនៃឥន្ទ្រីយារម្មណ៍របស់មនុស្ស

ឥន្ទ្រីយារម្មណ៍ ជាបាតុភូតផ្លូវចិត្តដែលមិនមែនកើតមានឡើងតែនៅក្នុងខ្លួនមនុស្សប៉ុណ្ណោះទេ វាថែមទាំងកើតមានឡើងនៅក្នុងខ្លួនសត្វទៀតផង។ ប៉ុន្តែឥន្ទ្រីយារម្មណ៍របស់មនុស្សមានលក្ខណៈខុសប្លែកគ្នាខាងផ្នែកគុណសម្បត្តិពីឥន្ទ្រីយារម្មណ៍របស់សត្វ។ ចរិតសង្គមនៃឥន្ទ្រីយារម្មណ៍របស់មនុស្ស ស្តែងចេញអោយឃើញ នូវហេតុការណ៍ទាំងឡាយដូចតទៅៈ

- វត្ថុដែលឆ្លុះបញ្ចាំងចូលក្នុងឥន្ទ្រីយារម្មណ៍របស់មនុស្ស មិនគ្រាន់តែមានរូបភាពវត្ថុ និង បាតុភូតដែលកើតមានពីមុននៅក្នុងធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងមានរូបភាពផលិតផល ដែលបង្កើតឡើងដោយមនុស្ស នៅពេលដែលគេធ្វើការងារកែប្រែធម្មជាតិនោះទៀតផង។
- ចលនាការផ្លូវចិត្តនៃឥន្ទ្រីយារម្មណ៍របស់មនុស្ស មិនមែនកំណត់ព្រំដែននៅត្រឹមប្រព័ន្ធសញ្ញាការទី១ ប៉ុណ្ណោះទេ វាក្តោបក្តាប់ចលនាការផ្លូវចិត្តដែលកើតមាននៅក្នុងប្រព័ន្ធសញ្ញាការទី២ទៀតផង។
- ចំពោះមនុស្សឥន្ទ្រីយារម្មណ៍ គឺជាកំរិតទី១ ហើយជាកំរិតដ៏សាមញ្ញបំផុត នៅក្នុងការបត់បែនបាន ហើយមិនមែនជាកំរិតដ៏ខ្ពស់បំផុតឡើយ។ វាជាកំរិតតែមួយគត់ (ដូចឥន្ទ្រីយារម្មណ៍របស់សត្វដែរ)។

ឥន្ទ្រិយារម្មណ៍របស់មនុស្សអភិវឌ្ឍន៍ឡើងយ៉ាងខ្លាំងក្លា ហើយស្ថិតនៅក្នុងបែបបទខុសប្លែកគ្នាក្រោមឥទ្ធិពលនៃសកម្មភាពរបស់មនុស្ស និង ការអប់រំមនុស្ស។ ឧទាហរណ៍ៈ ដោយសារសកម្មភាពនៃវិជ្ជាជីវៈជាងតម្បាញម្នាក់អាចញែកដាច់នូវពណ៌ខ្មៅ ដែលលាយឡំគ្នា ដល់ទៅ ហុកសិបពណ៌។ បទពិសោធន៍ក្នុងការងារ ឬ ជីវភាពរស់នៅអាចស្រាយបំភ្លឺអោយយើងដឹងបានថា ដោយសារការហ្វឹកហ្វឺនដៃរបស់យើងអាចដើរតួជំនួសភ្នែករបស់យើងបាន។

## ៤- តួនាទីរបស់ឥន្ទ្រីយារម្មណ៍

ថ្វីត្បិតតែឥន្ទ្រីយារម្មណ៍ ជារូបភាពនៃចំណាំងផ្លូវចិត្តដ៏សាមញ្ញបំផុតយ៉ាងណាក៏ដោយ ឥន្ទ្រីយារម្មណ៍បំពេញតួនាទីមួយដ៏សំខាន់បង្គួរនៅក្នុងជីវភាពរស់នៅរបស់មនុស្សៈ

- ឥន្ទ្រីយារម្មណ៍ ជារូបភាពទី១នៃដំណៅទិសរបស់មនុស្ស ( រីឯសត្វក៏ដូច្នេះដែរ ) ហើយជាប្រភពដែលផ្គត់ផ្គង់សំភារៈ ដើម្បីអោយមនុស្សធ្វើសកម្មភាពញាណសក្តិ តាមរូបភាពផ្សេងទៀត អោយមានកំរិតកាន់តែខ្ពស់ឡើងៗ។ យើងមិនអាចស្គាល់បានច្បាស់ពីរូបភាពនៃសំភារៈ និង រូបភាពនៃចលនាបានឡើយ ដោយសារតែឥន្ទ្រីយារម្មណ៍របស់យើងនោះ។
- ដោយឡែក ចំពោះមនុស្សពិការ ( គរ ខ្វាក់ ថ្លង់ ... ) ឥន្ទ្រីយារម្មណ៍ ដែលមានប្រសិទ្ធភាពខ្លាំងជាងគេនោះគឺ ឥន្ទ្រីយារម្មណ៍ ដែលចូលក្នុងខ្លួនគេ តាមរយៈកាយវិញ្ញាណនោះឯង។
- ក្រៅពីតួនាទីនៃការយល់ដឹងខាងលើនេះ ឥន្ទ្រីយារម្មណ៍ គឺជាលក្ខខណ្ឌដ៏សំខាន់ថែមទៀត សំដៅធានាបាននូវសភាពរំញោច នៅក្នុងសំបកខួរក្បាលរបស់មនុស្ស។ គឺដោយសារហេតុការណ៍នេះហើយ ដែលធ្វើអោយគេធានាបាន នូវសកម្មភាពស្មារតីធម្មតារបស់មនុស្ស។

# II- ចំណែកថ្នាក់របស់ឥន្ទ្រីយារម្មណ៍

គេបានឈានដល់ ការធ្វើចំណែកថ្នាក់របស់ឥន្ទ្រីយារម្មណ៍ ទៅតាមទីតាំងរំញោច ដែលបង្កអោយមានឥន្ទ្រីយារម្មណ៍នៅក្នុងខ្លួនមនុស្ស។ ដោយឈរលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យបែបនេះ គេចែកឥន្ទ្រីយា រម្មណ៍ជា ពីរក្រុម គឺៈ ឥន្ទ្រីយារម្មណ៍ដែលស្ថិតនៅខាងក្រៅខ្លួនមនុស្ស ជាឥន្ទ្រីយារម្មណ៍ដែលបង្កើតឡើងដោយរំញោច ដែលស្ថិតនៅខាងក្រៅសព៌ាង្គកាយរបស់មនុស្សយើង និង ឥន្ទ្រីយារម្មណ៍ដែលស្ថិតនៅខាងក្នុងខ្លួនមនុស្ស ជាឥន្ទ្រីយារម្មណ៍ដែលបង្កឡើងដោយសាររំញោចនៅខាងក្នុងខ្លួន។

## ១- ឥន្ទ្រីយារម្មណ៍ខាងក្រៅខ្លួនមនុស្ស

ឥន្ទ្រីយារម្មណ៍ខាងក្រៅខ្លួនមនុស្សមាន ៖

### ១.១ ឥន្ទ្រីយារម្មណ៍តាមរយៈចក្ខុវិញ្ញាណ

ឥន្ទ្រីយារម្មណ៍ប្រភេទនេះកើតមានឡើង ដោយស្ថិតក្រោមឥទ្ធិពលនៃរលកពន្លឺ ដែលជារលកនៃអគ្គីសនីចុម្ពិត ហើយពន្លឺនោះជាពន្លឺដែលចាំងមកពីវត្ថុដែលនៅជុំវិញខ្លួនយើង។ មូលដ្ឋានសរីរៈវិទ្យារបស់

ឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណនេះ ស្ថិតនៅក្នុងសកម្មភាពនៃសរសៃប្រសាទសំរាប់ធ្វើវិភាគ តាមរយៈចក្ខុវិញ្ញាណ។

ដោយសារឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណនេះហើយ យើងអាចស្គាល់បាននូវរូបភាព ឬ ទំរង់រស្មីភាព ពណ៌សម្បុររបស់វត្ថុ វិមាត្ររបស់វត្ថុ មាឌ និង ចម្ងាយ។ ឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណបំពេញតួនាទីមួយយ៉ាង សំខាន់នៅក្នុងការស្គាល់បានចំពោះពិភពខាងក្រៅខ្លួនរបស់មនុស្ស។

### ១.២ ឥន្ទ្រីយារម្មណ៍នៃសោតវិញ្ញាណ

គឺជាឥន្ទ្រីយារម្មណ៍ដែលបង្កឡើងដោយរលកសម្លេង ពោលគឺតាមរយៈរំញ័រនៃខ្យល់។ រលកសម្លេង ផ្សព្វផ្សាយទៅគ្រប់ទិសទីទាំងអស់ គឺចេញពីវត្ថុដែលជាប្រភពនៃសម្លេង ទៅកាន់ត្រចៀកគូសន្នា។ មូលដ្ឋានសរីរៈវិទ្យារបស់ឥន្ទ្រីយារម្មណ៍នៃសោតវិញ្ញាណ គឺសកម្មភាពនៃឧបករណ៍វិភាគរបស់សោតវិញ្ញាណ។

ឥន្ទ្រីយារម្មណ៍នៃសោតវិញ្ញាណ ឆ្លុះបញ្ចាំងបាននូវលក្ខណៈរបស់សម្លេងៈ កំរិតរលកនៃសម្លេង កម្លាំងរលកនៃសម្លេង ហើយនឹងទ្រង់ទ្រាយនៃរលកសម្លេង។ ឥន្ទ្រីយារម្មណ៍នៃសោតវិញ្ញាណទទួលបន្ទុកផងដែរនូវតួនាទីដ៏សំខាន់ក្នុងជីវភាពរស់នៅរបស់មនុស្ស។ ដោយសារឥន្ទ្រីយារម្មណ៍នៃសោតវិញ្ញាណនេះហើយ ដែលយើងអាចមានទំនាក់ទំនងបានជាមួយនឹងអ្នកឯទៀត យើងមានសមត្ថភាពផ្ទៀងផ្ទាត់ និងបញ្ជាក់បានចំពោះភាសារបស់យើង ក្នុងករណីដែលយើងត្រូវការយើងអាចកែតំរូវបាននូវសំដីដែលយើងនិយាយ។

### ១.៣ ឥន្ទ្រីយារម្មណ៍នៃឃានវិញ្ញាណ

គឺជាឥន្ទ្រីយារម្មណ៍ដែលបង្កឡើង ដោយផ្នែកតូចលំអិតនៃសារជាតិ ឬ ឧស្ម័នដែលធ្វើចលនានៅលើ ស្បែកស្រទាប់ស្តើងក្នុងរន្ធច្រមុះ តាមរយៈខ្យល់ដែលដកដង្ហើមចេញចូល។

ចំពោះមនុស្សសព្វថ្ងៃនេះ ឧបករណ៍វិភាគរបស់ឃានវិញ្ញាណ មានការអភិវឌ្ឍន៍តិចតួចណាស់ បើធៀបទៅនឹងបុព្វបុរសរបស់គេពីសម័យមុន។ តាមពិត ឥន្ទ្រីយារម្មណ៍នៃឃានវិញ្ញាណមានអត្ថប្រយោជន៍ណាស់។ ក៏ប៉ុន្តែនៅពេលណាដែលឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណ និង សោតវិញ្ញាណខូចបង់ទៅ ឥន្ទ្រីយា រម្មណ៍នៃឃានវិញ្ញាណ និង ឥន្ទ្រីយារម្មណ៍ឯទៀត ដែលនៅសល់បំពេញតួនាទីដ៏សំខាន់ៗដោយឡែកពីគ្នា។

### ១.៤ ឥន្ទ្រីយារម្មណ៍នៃជីវ្ហាវិញ្ញាណ

គឺជាឥន្ទ្រីយារម្មណ៍ ដែលមានប្រភពចេញមកពីសកម្មភាពនៃលក្ខណៈគីមី របស់សារជាតិដែលរលាយនៅក្នុងទឹកមាត់ស្ថិតនៅលើសរីរាង្គទទួលរសជាតិរបស់អណ្តាត។

ឥន្ទ្រីយារម្មណ៍នៃជីវ្ហាវិញ្ញាណរួមមានបួនប្រភេទគឺ ឥន្ទ្រីយារម្មណ៍ទទួលការឈឺចាប់ ឥន្ទ្រីយារម្មណ៍ទទួលរសជាតិជូរ ឥន្ទ្រីយារម្មណ៍ទទួលរសជាតិល្វីង និង ឥន្ទ្រីយារម្មណ៍ទទួលរសជាតិប្រៃ។ ភាពប្រៃ

ប្រួលនៃរសជាតិអាហារអាស្រ័យដោយការរួមផ្សំគ្នា នៃឥន្ទ្រីយារម្មណ៍ទាំងនេះ ហើយវាក៏អាស្រ័យដោយការគួបផ្សំគ្នាពីសំណាក់ឥន្ទ្រីយារម្មណ៍នៃឃានវិញ្ញាណផងដែរ។ បើគេត្រូវខ្ទប់ច្រមុះនូវឥន្ទ្រីយារម្មណ៍នៃឃាន វិញ្ញាណ នោះគេច្បាស់ជាពិបាកនឹងដឹងស្គាល់បានចំពោះរសជាតិអាហារផ្សេងៗគ្នាណាស់។

### ១.៥ ឥន្ទ្រីយារម្មណ៍នៃកាយវិញ្ញាណ

គឺជាឥន្ទ្រីយារម្មណ៍ ដែលកើតឡើងដោយសាររំញោចនៃចលនា និងកំដៅ។ ឥន្ទ្រីយារម្មណ៍នេះចែកចេញជាប្រាំប្រភេទគឺៈ ឥន្ទ្រីយារម្មណ៍ដែលកើតមកពីការប៉ះពាល់ឥន្ទ្រីយារម្មណ៍ ដែលកើតមកពីសម្ពាធឥន្ទ្រីយារម្មណ៍ដែលកើតមកពីកំដៅ ឥន្ទ្រីយារម្មណ៍ដែលកើតមកពីត្រជាក់ និង ឥន្ទ្រីយារម្មណ៍ដែលកើតមកពីការឈឺចាប់។ នៅលើផ្ទៃស្បែកមនុស្សយើង មានអង្គុល្លិតធ្នារនៃកាយវិញ្ញាណ។ អង្គុល្លិតធ្នារនេះមាន ប្រាំប្រភេទ។ វាស្ថិតនៅខាងចុងសរសៃប្រសាទរបស់ឥន្ទ្រីយារម្មណ៍ ហើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងឥន្ទ្រីយារម្មណ៍ទាំងប្រាំប្រភេទដូចបានពិពណ៌នារួចមកហើយ។

វេទនារម្មណ៍ ដែលកើតឡើងពីផ្នែកផ្សេងៗនៃស្បែករបស់មនុស្ស ចំពោះរំញោចនីមួយៗមិនមានលក្ខណៈដូចគ្នាទេ។ ឥន្ទ្រីយារម្មណ៍ដែលកើតឡើងដោយសារការប៉ះពាល់នេះមានលក្ខណៈស្រៀវជាងគេបង្អស់នៅត្រង់អណ្តាត និង ម្រាមដៃយើង។ ខ្នងរបស់មនុស្សយើងមិនសូវមានលក្ខណៈស្រៀវទេ។ ស្បែកនៃផ្នែកផ្សេងៗរបស់មនុស្សយើង ដែលមានសុខភាពមាំមួនក៏មានលក្ខណៈឆាប់ស្រៀវណាស់ដែរ ចំពោះឥន្ទ្រីយារម្មណ៍នៃកំដៅ និង ត្រជាក់។

## ២- ឥន្ទ្រីយារម្មណ៍ខាងក្នុងខ្លួនមនុស្ស

ឥន្ទ្រីយារម្មណ៍ខាងក្នុងខ្លួនមនុស្សមាន ៖

### ២.១ ឥន្ទ្រីយារម្មណ៍ចលករ និង ឥន្ទ្រីយារម្មណ៍ទទួលការប៉ះពាល់

ឥន្ទ្រីយារម្មណ៍ចលករគឺជា ឥន្ទ្រីយារម្មណ៍ដែលឆ្លុះបញ្ចាំងបន្លាស់ប្តូរនៅក្នុងសរីរាង្គនៃចលនា។ ឥន្ទ្រីយារម្មណ៍នេះសំរាប់ប្រាប់អោយដឹងពីកំរិតនៃការកន្ត្រាក់ទាញចុះឡើងនៃសរសៃពួររបស់សាច់ដុំ និងឥរិយាបថនៃដងខ្លួនរបស់យើង។

ការជួបប្រសព្វគ្នានៃឥន្ទ្រីយារម្មណ៍ចលករ និង ការប៉ះពាល់ជាមួយវត្ថុបង្កើតបានជា ឥន្ទ្រីយារម្មណ៍ទទួលការប៉ះពាល់។ ដៃរបស់មនុស្សក្នុងឋានៈជាសរីរាង្គទទួលការប៉ះពាល់ កើតមានជាដំបូងបង្អស់ក្នុងខ្លួនសត្វស្វា។ ប៉ុន្តែចំពោះមនុស្សវិញ ដៃបានអភិវឌ្ឍន៍ឡើងទៅតាមបែបបទមួយដ៏ត្រឹមត្រូវ ហើយបានក្លាយទៅជាឧបករណ៍សំរាប់ការងារ និង ការយល់ដឹងរបស់មនុស្ស។ ឥន្ទ្រីយារម្មណ៍ទទួលការប៉ះពាល់បំពេញតួនាទីមួយដ៏សំខាន់នៅក្នុងន័យតួបនីយកម្មនៃចលនាការងារ ជាពិសេសចំពោះចលនានៃការងារដែលទាមទារនូវភាពប្រាកដប្រជាយ៉ាងខ្លាំងសម្បើម។

### ២.២ ឥន្ទ្រីយារម្មណ៍លំនឹង

គឺជាឥន្ទ្រីយារម្មណ៍ដែលឆ្លុះបញ្ចាំងពីឥរិយាបថ និង ចលនានៃក្បាលរបស់មនុស្ស។ សរីរាង្គឥន្ទ្រីយា រម្មណ៍នៃលំនឹង ស្ថិតនៅត្រង់ផ្នែកខាងក្នុងនៃត្រចៀក ហើយដែលមានចង្អូរកងបីកំណាត់ជាប់គ្នា។ សរីរាង្គនៃលំនឹងបំរើការអោយទំនាក់ទំនង ដ៏ជិតស្និទ្ធជាមួយនឹងសរីរាង្គក្នុងខ្លួនផ្សេងទៀត។ កាលណាវាមានរំញោចខ្លាំងពេក វានឹងបង្កអោយមានការវិលមុខ និង ចលនាពុលរលកសមុទ្រ។ ដោយសារការអប់រំដ៏ទៀងទាត់ ពេលវេលានេះហើយដែលធ្វើអោយស្ថេរភាពទ្រទ្រង់លំនឹងអោយមានដំណើរការអភិវឌ្ឍន៍បានល្អ។

## ២.៣ ឥន្ទ្រីយារម្មណ៍នៃរំញ័រ

គឺជាឥន្ទ្រីយារម្មណ៍ម្យ៉ាង ដែលមានលក្ខណៈដោយឡែក ហើយដែលបង្កឡើងដោយអំពើនៃរំញ័ររបស់ខ្យល់ដែលមកប៉ះនៅលើផ្ទៃនៃខ្លួនរបស់មនុស្សយើង។ រំញ័រទាំងនេះមានប្រភពចេញមកពីការរញ្ជួយ និង ចលនានៃវត្ថុ។ រហូតមកដល់សព្វថ្ងៃនេះ គេមិនទាន់ឈានដល់ការរកឃើញសរីរាង្គ ដែលទទួលវេទនារម្មណ៍សំរាប់ឥន្ទ្រីយារម្មណ៍នៃរំញ័រនេះឡើយ។ គេចាត់ទុកឥន្ទ្រីយារម្មណ៍នេះថា ជាឥន្ទ្រីយារម្មណ៍កើតមានក្នុងខ្លួនមនុស្ស តាំងពីសម័យដែលមនុស្សចាប់កើតមាននៅលើផែនដីមកម្ល៉េះ ហើយថាផ្នែកដ៏តូចលំអិតនៃសព៌ាង្គកាយរបស់មនុស្សយើងអាចឆ្លុះបញ្ចាំងបាននូវរំញ័រ ដែលកើតមកពីមជ្ឈដ្ឋានជុំវិញខាងក្រៅខ្លួន និង ខាងក្នុងខ្លួនមនុស្ស។ ចំពោះមនុស្សដែលមានសោតវិញ្ញាណធម្មតា ឥន្ទ្រីយារម្មណ៍ប្រភេទនេះមិនសូវ អភិវឌ្ឍន៍បានប្រសើរឡើយ។ ប៉ុន្តែចំពោះមនុស្សថ្លង់ ដោយឡែកចំពោះមនុស្សដែលខ្វាក់ផង ថ្លង់ផង ឥន្ទ្រីយារម្មណ៍ប្រភេទនេះមានដំណើរការអភិវឌ្ឍន៍ល្អណាស់ ហើយវាសំរាប់យកទៅប្រើប្រាស់ជាមូលដ្ឋាន សំរាប់បត់បែនតំរូវទៅតាមទិសនៃពិភពដែលនៅជុំវិញខ្លួនយើង។

## ២.៤ ឥន្ទ្រីយារម្មណ៍នៃសរីរាង្គ

គឺជាឥន្ទ្រីយារម្មណ៍ ដែលឆ្លុះបញ្ចាំងពីសភាពនៃអាការៈខាងក្នុងខ្លួនមនុស្សយើង។ ឥន្ទ្រីយារម្មណ៍នៃ សរីរាង្គរួមមានៈ ការឃ្លាន ការឆ្អែតស្កល់ ការខ្ពើមរអើម ឬដំណើររកកលក្អួត ការឈឺចាប់នៅក្នុងអាការៈខាង ក្នុង។

**ឧទាហរណ៍ ៖** ការឈឺចាប់ក្នុងក្រពះដោយជម្ងឺរលាកក្រពះ។

កាលណាអាការៈខាងក្នុងខ្លួនយើងមានដំណើរការប្រព្រឹត្តទៅល្អជាធម្មតា ជានិច្ចជាកាលយើងនឹងមិនមានកើតឡើងនូវឥន្ទ្រីយារម្មណ៍នៃសរីរាង្គណាមួយឡើយ។ ឥន្ទ្រីយារម្មណ៍នៃសរីរាង្គកើតមានឡើងលុះណាតែ មនុស្សយើងមានភាពកង្វល់ នៅក្នុងដំណើរការប្រព្រឹត្តិនៃអាការៈខាងក្នុង ឬ គ្រឿងក្នុងណាមួយក្នុងខ្លួនយើង។

## III- ច្បាប់របស់ឥន្ទ្រីយារម្មណ៍

ឥន្ទ្រីយារម្មណ៍ក៏ដូចជាប្រភេទផ្លូវចិត្តដទៃទៀតដែរ។ ចំពោះមនុស្សឥន្ទ្រីយារម្មណ៍ប្រព្រឹត្តទៅតាមក្រឹត្យក្រមជាកំណត់របស់វា។ វាជាការចាំបាច់ហើយសំខាន់ណាស់ ដែលយើងត្រូវយល់ដឹងពីក្រឹត្យក្រមនៃ

ឥន្ទ្រីយារម្មណ៍ ហើយយើងត្រូវតែទទួលយកមកគិតពិចារណានៅក្នុងជីវភាពរស់នៅរបស់យើង និង នៅក្នុងសកម្មភាពអប់រំសិស្សរបស់យើង។

## ១- ច្បាប់ព្រំកំណត់នៃឥន្ទ្រីយារម្មណ៍

ដើម្បីអោយមានឥន្ទ្រីយារម្មណ៍ គេត្រូវអោយមានរំញោចមកលើសរីរាង្គឥន្ទ្រីយ៍។ ក៏ប៉ុន្តែគេមិនកំណត់បានថា ជារំញោចប្រភេទណាមួយទេ ដែលអាចបង្កអោយមានឥន្ទ្រីយារម្មណ៍នោះ។ រំញោចដ៏ខ្សោយបំផុតមិនអាចបង្កអោយមានឥន្ទ្រីយារម្មណ៍ឡើយ ហើយផ្ទុយទៅវិញរំញោចដ៏ខ្លាំងបំផុតនោះ ក៏ធ្វើអោយខូចដល់ឥន្ទ្រីយារម្មណ៍ដែរ។ ដូច្នេះដើម្បីបង្កអោយមានឥន្ទ្រីយារម្មណ៍កម្លាំងនៃរំញោចត្រូវមានព្រំដែនកំណត់ដ៏ច្បាស់លាស់។ ព្រំដែនកំណត់នៃកម្លាំងរំញោច ដែលធ្វើអោយមានឥន្ទ្រីយារម្មណ៍នេះ ហៅថា ព្រំកំណត់នៃឥន្ទ្រីយារម្មណ៍។ ព្រំកំណត់នៃឥន្ទ្រីយារម្មណ៍មានពីរប្រភេទ គឺ ព្រំកំណត់នៃឥន្ទ្រីយារម្មណ៍កំរិតទាប និង ព្រំកំណត់នៃឥន្ទ្រីយារម្មណ៍កំរិតខ្ពស់។ ព្រំកំណត់កំរិតទាបគឺជា កម្លាំងអប្បបរិមានៃរំញោចដ៏គ្រប់គ្រាន់ល្មម ដែលអាចបង្កអោយមានឥន្ទ្រីយារម្មណ៍បាន។ រីឯព្រំកំណត់កំរិតខ្ពស់គឺជា កម្លាំងអតិបរមានៃរំញោចពីខាងក្រៅខ្លួន ដែលបង្កអោយមានឥន្ទ្រីយារម្មណ៍។

**ឧទាហរណ៍ ៖** ព្រំកំណត់កំរិតទាបរបស់ឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណគឺជា រលកនៃពន្លឺដែលមានបណ្តោយរលកប្រវែង 390 mμ ហើយព្រំកំណត់កំរិតខ្ពស់មានបណ្តោយរលកប្រវែងដល់ទៅ 780 mμ ។ នៅរវាងព្រំកំណត់កំរិតខ្ពស់ និង ព្រំកំណត់កំរិតទាបរបស់ឥន្ទ្រីយារម្មណ៍នីមួយៗ មានតំបន់មួយដែលទទួលចំណាំងបានល្អប្រសើរ។

**ឧទាហរណ៍ ៖** តំបន់ដែលទទួលចំណាំងបានល្អប្រសើរនៃពន្លឺចំពោះភ្នែករបស់មនុស្សយើងគឺជា រលកនៃពន្លឺដែលមានបណ្តោយរលកទៅដល់ 565 mμ ។ រលកនៃសម្លេងសំរាប់ត្រចៀកគឺ 1000 Hz ។

ឥន្ទ្រីយារម្មណ៍របស់មនុស្សអាចឆ្លុះបញ្ចាំងបានថែមទៀតពីភាពខុសប្លែកគ្នានៃរំញោច។

ការឃ្លាតពីគ្នាជាអប្បបរិមានៃកម្លាំងរំញោច និងលក្ខណៈនៃរំញោចពីរអាចធ្វើអោយយើងញែកដាច់បាន នៃរំញោចទាំងពីរនោះ គេហៅថា ព្រំកំណត់ខុសគ្នានៃឥន្ទ្រីយារម្មណ៍។

## ២- ច្បាប់សំរបសំរួលនៃឥន្ទ្រីយារម្មណ៍

ដើម្បីធានាបាននូវចំណាំងដ៏ល្អប្រសើរ និង ដើម្បីការពារប្រព័ន្ធសរសៃប្រសាទ ឥន្ទ្រីយារម្មណ៍របស់ មនុស្សយើងមានសមត្ថភាពនឹងសំរបសំរួលបានទៅតាមរំញោច។

ការសំរបសំរួលនេះគឺជាសតិមួយដែលអាចធ្វើអោយវេទនារម្មណ៍របស់ឥន្ទ្រីយារម្មណ៍ផ្លាស់ប្តូរបាន គឺសំដៅធ្វើអោយបន្លាស់ប្តូរនៃកម្លាំងរំញោចមានភាពសមស្រប ឬ ត្រូវតាមទំនង។ កាលណាកម្លាំងរំញោចចេះតែកើនឡើង នោះវេទនារម្មណ៍ក៏ចេះតែកើនឡើង។

**ឧទាហរណ៍ ៖** ក្នុងពេលថ្ងៃយើងចូលទៅក្នុងរោងបញ្ចាំងខ្សែភាពយន្តមួយ ដើម្បីទស្សនាខ្សែភាពយន្ត មុនដំបូងយើងមើលមិនឃើញអ្វីទាំងអស់លុះយូរបន្តិចមកតាមរយៈចក្ខុវិញ្ញាណរបស់យើង យើងអាចញែកដាច់នូវវត្ថុដែលមានជុំវិញខ្លួនយើង។ នៅក្នុងករណីនេះ គេនិយាយថា មកពីវេទនារម្មណ៍របស់យើងមាន

កម្រិតកើនឡើង ការសំរបសំរួលនេះកើតមាននៅក្នុងឥន្ទ្រីយារម្មណ៍គ្រប់ប្រភេទទាំងអស់ ប៉ុន្តែឥន្ទ្រីយារម្មណ៍ខ្លះទៀតមានសមត្ថភាពអាចសំរបសំរួលបានយ៉ាងខ្សត់ខ្សោយបំផុត ហើយជួនកាលឥន្ទ្រីយារម្មណ៍ខ្លះស្ទើរតែបាត់បង់អស់នូវសមត្ថភាពនៃការសំរបសំរួលតាមនោះ (ឧទាហរណ៍: ឥន្ទ្រីយារម្មណ៍នៃការឈឺចាប់)។

ដោយសារតែសកម្មភាពនៃការងារ និង ការអប់រំ សមត្ថភាពនៃការសំរបសំរួលរបស់ឥន្ទ្រីយារម្មណ៍អាចមានឥទ្ធិពលកើនឡើងយ៉ាងខ្លាំង។ ឧទាហរណ៍: កម្មករក្នុងរោងចក្រស្លដែក អាចធន់បានរាប់ម៉ោងជាធម្មតានូវសីតុណ្ហភាពពី 50° ទៅ 60°C ។ អ្នកមុជទឹកដោយប្រើស្រោមខ្លួនអាចធន់បាននឹងសម្ពាធដែលមានកម្លាំងពីរ បរិយាកាសនៅក្នុងទឹករាប់សិបនាទី ឬ រាប់ម៉ោងក៏មានដែរ។

### ៣- ច្បាប់នៃអំពើបញ្ច្រាសគ្នារវាងឥន្ទ្រីយារម្មណ៍

ឥន្ទ្រីយារម្មណ៍របស់មនុស្សយើង មិនអាចកើតឡើងដាច់ដោយឡែកពីគ្នាបានឡើយ។ ឥន្ទ្រីយារម្មណ៍ទាំងអស់ទទួលរងអំពើបញ្ច្រាសរវាងគ្នានិងគ្នា។ សកម្មភាពដែលមានលក្ខណៈជាអន្តរកម្មរវាងឥន្ទ្រីយារម្មណ៍ទាំងនោះប្រព្រឹត្តទៅតាមច្បាប់ទូទៅមួយដូចតទៅ: រំញោចដែលមានកម្លាំងខ្សោយកើតមានមកលើសរីរាង្គវិភាគណាមួយរបស់មនុស្សយើង ធ្វើអោយវេទនារម្មណ៍របស់សរីរាង្គវិភាគមួយទៀតកើនឥទ្ធិពលឡើង ហើយរំញោចដែលមានកម្លាំងខ្លាំងកើតមានមកលើសរីរាង្គវិភាគណាមួយនោះ ធ្វើអោយវេទនារម្មណ៍នៃសរីរាង្គវិភាគណាមួយទៀតនោះថយចុះនូវឥទ្ធិពល។

**ឧទាហរណ៍ ៖** ឥន្ទ្រីយារម្មណ៍នៃជីវ្ហាវិញ្ញាណដែលមានភាពទន់ខ្សោយ ធ្វើអោយវេទនារម្មណ៍នៃចក្ខុវិញ្ញាណមានឥទ្ធិពលកើនឡើងយ៉ាងខ្លាំង។

កំណើនឥទ្ធិពលរបស់វេទនារម្មណ៍ដែលកើតឡើង ដោយសារតែអំពើបញ្ច្រាសគ្នារបស់ឥន្ទ្រីយារម្មណ៍ ព្រមទាំងដោយសារការអប់រំតាមលក្ខណៈប្រព័ន្ធកម្ម ហៅថាការធ្វើអោយឆាប់ដឹងខ្លួន ឬ ការធ្វើអោយឆាប់ភ្ញាក់រំលឹក។ នៅក្នុងលំនាំនៃការបង្រៀន ដើម្បីឆ្លៀតឱកាសស៊ីជំរៅទៅលើការបង្កើនវេទនារម្មណ៍ដល់សិស្សានុសិស្ស គ្រូបង្រៀនគប្បីឈ្លាសវៃក្នុងការបង្កើតអោយមាននឹងការពិនិត្យមើល ទៅលើរបបនៃការផ្តល់ពន្លឺដ៏គ្រប់គ្រាន់ល្មម នឹងសីតុណ្ហភាពនៃភាពទូលំទូលាយដ៏សមស្របនៅក្នុងថ្នាក់រៀន ដែលជះឥទ្ធិពលយ៉ាងខ្លាំងមកលើសរីរាង្គឥន្ទ្រីយ៍របស់សិស្សម្នាក់ៗ ។

**ឧទាហរណ៍ ៖** វិធីបង្រៀននៅក្នុងសោតទស្សន៍។

### ៤- ច្បាប់ផ្ទុយគ្នានៃឥន្ទ្រីយារម្មណ៍

ភាពផ្ទុយគ្នានេះកើតឡើងពីបាតុភូតនៃទង្វើបញ្ច្រាសគ្នារវាងឥន្ទ្រីយារម្មណ៍ ដែលមានប្រភេទដូចគ្នា។ គឺបន្លាស់ប្តូររបស់កម្លាំង និង គុណភាពនៃឥន្ទ្រីយារម្មណ៍ដែលស្ថិតនៅក្រោមឥទ្ធិពលនៃរំញោចមួយទៀតនោះ (តែ ជារំញោចដែលមានប្រភេទដូចគ្នា) ដែលប្រព្រឹត្តទៅ ឬ កើតមានឡើងមុនពេល ឬ ដំណាលពេលគ្នាតែម្តង។

**ឧទាហរណ៍ ៖** បើយើងយកក្រដាសពីរសន្លឹកដែលមានពណ៌ប្រផេះដូចគ្នា ដោយដាក់សន្លឹកក្រដាសទី១ នៅលើសាច់ក្រណាត់ពណ៌ស និង សន្លឹកក្រដាសទី២ដាក់នៅលើសាច់ក្រណាត់ពណ៌ខ្មៅ យើងហាក់ដូចជាឃើញសន្លឹក ដែលដាក់នៅលើសាច់ក្រណាត់ពណ៌ស មានភាពស្រអាប់ជាង សន្លឹកក្រដាសដែលដាក់នៅលើសាច់សំពត់ពណ៌ខ្មៅ។ នេះគេហៅថា " ភាពផ្ទុយគ្នានៃឥន្ទ្រីយារម្មណ៍ " ។

បន្ទាប់ពីបានទទួលរំញោចនៃភាពត្រជាក់ ហើយភ្លាមៗគ្រាន់តែអោយប៉ះរំញោចមួយ ដែលមានភាពក្តៅដ៏ស្រាល ឥន្ទ្រីយារម្មណ៍របស់យើងហាក់ដូចជាទទួលរំញោចក្តៅណាស់។ នេះហើយហៅថា ភាពបញ្ច្រាសគ្នានៃឥន្ទ្រីយារម្មណ៍។

ច្បាប់ផ្ទុយគ្នានៃឥន្ទ្រីយារម្មណ៍ ត្រូវបានគេយកទៅអនុវត្តយ៉ាងហ្មត់ចត់នៅក្នុងវិចិត្រកម្មផ្នែកគំនូរ។ នៅក្នុងការបង្រៀនសិស្ស ច្បាប់នេះក៏ត្រូវបានគេយកទៅអនុវត្តជាញឹកញាប់ផងដែរនៅក្នុងការប្រៀបធៀប ឬ នៅក្នុងការធ្វើអោយមានតំលៃជាក់ស្តែង ទៅលើសំភារៈបង្រៀននៅចំពោះមុខសិស្ស។

### ៥- ច្បាប់វិបល្លាសដែលកើតមានក្នុងវេទនារម្មណ៍

យើងគប្បីធ្វើពិសោធន៍ដូចតទៅនេះ : យើងយកចង្កឹះឫស្សីពីរ ឬ យកអំបែងកែវពីរមកត្រដុសលើគ្នា យើងនឹងដឹងថា: មានអ្វីមួយដែលកើតឡើងនៅលើសរសៃប្រសាទរបស់យើង។ ដូច្នេះយើងឃើញថារំញោច ដែលកើតមានមកលើសោតវិញ្ញាណបង្កអោយមានឥន្ទ្រីយារម្មណ៍នៅក្នុងសរីរាង្គរបស់យើង។

នៅក្នុងភាសាណាក៏ដោយ គេតែងតែជួបប្រទះការសម្តែងចេញនូវវាចារដែលឆ្លុះបញ្ចាំងអោយឃើញបាតុភូតនៃវិបល្លាស ដែលកើតមានក្នុងវេទនារម្មណ៍របស់មនុស្ស ដូចជាការប្រើល្បិចបោកបញ្ឆោត ការប្រើសំដីផ្អែមល្ហែម។

ដោយសារច្បាប់នៃវិបល្លាស ដែលកើតមាននៅក្នុងវេទនារម្មណ៍របស់មនុស្ស គេអាចឈានដល់ការ ផលិតបាននូវឧបករណ៍ដែលមានលទ្ធភាពផ្លាស់ប្តូរសញ្ញានៃសម្លេង អោយទៅជាសញ្ញាភ្លើងពណ៌។ ឧបករណ៍នេះបង្កើតបានជាសម្បទានៃសរីរាង្គដែលទទួលបាននូវអារម្មណ៍តាមសង្វាក់តូរ្យតន្ត្រី និង ជំរៅរបស់វា សំរាប់អ្នកស្តាប់នៅក្នុងបន្ទប់សំរាប់ប្រគុំតូរ្យតន្ត្រី (គេហៅថា តូរ្យតន្ត្រីដែលលំអដោយពន្លឺភ្លើងពណ៌) ។ ដោយឈរលើមូលដ្ឋាននៃគោលការណ៍នេះ គេបានបង្កើតរួចមកហើយនូវឧបករណ៍សំរាប់ផ្លាស់ប្តូរសញ្ញានៃពន្លឺ អោយទៅជាសញ្ញានៃសម្លេងសំរាប់មនុស្សខ្វាក់ ហើយដោយសារតែឧបករណ៍នេះ មនុស្សខ្វាក់អាចអានសៀវភៅបែបណាក៏បាន។

## IV- សេចក្តីសន្និដ្ឋាន:

ច្បាប់ឥន្ទ្រីយារម្មណ៍ដែលយើងបានសិក្សារួចមកហើយនេះ មានអត្ថន័យដ៏ធំធេងក្នុងការបង្រៀនសិស្ស នៅគ្រប់កំរិតសិក្សា។ យើងជាសាស្ត្រាចារ្យត្រូវចេះយកចំណេះដឹងពីឥន្ទ្រីយារម្មណ៍នេះទៅអនុវត្តអោយបានគ្រប់ជ្រុងជ្រោយក្នុងការបង្រៀនសិស្សនៅតាមមុខវិជ្ជាឯកទេសរបស់យើង ដូចជារៀបចំបន្ទប់រៀនអោយមានអនាម័យល្អ មានពន្លឺគ្រប់គ្រាន់ល្មមមានខ្យល់អាកាសចេញចូលល្អ និង ហ្វឹកហ្វឺនសិស្សអោយចេះសំរបសំរួលឥន្ទ្រីយារម្មណ៍។ យើងជាសាស្ត្រាចារ្យ ត្រូវចៀសវាងកុំនិយាយខ្លាំងពេក កុំនិយាយតិចពេក។ រីឯសំភារៈបង្រៀន ត្រូវធ្វើអោយបានត្រឹមត្រូវ និង សមស្រប។ ពេលបង្រៀនត្រូវលៃលកអោយសិស្សរបស់យើងបានឃើញ ពិនិត្យ សង្កេត និង ស្គាល់សំភារៈនោះគ្រប់ៗគ្នា។

## សំណួរ

១- ដូចម្តេចហៅថា ឥន្ទ្រីយារម្មណ៍ ?

២- ចូរបង្ហាញពីលក្ខណៈសំខាន់ៗរបស់ឥន្ទ្រីយារម្មណ៍ ?

៣- លក្ខណៈសង្គមនៃឥន្ទ្រីយារម្មណ៍របស់មនុស្សយើងស្តែងអោយឃើញនូវចំណុចណាខ្លះ ?

៤- ចូររៀបរាប់ពីច្បាប់នៃឥន្ទ្រីយារម្មណ៍ និង ការអនុវត្តច្បាប់ទាំងនោះ ?

៥- ឥន្ទ្រីយារម្មណ៍មានប្រយោជន៍យ៉ាងណាខ្លះ ក្នុងការបង្រៀនយុវសិស្ស ?

# មេរៀនទី៦ ៖ ប្រត្យក្សារម្មណ៍

## ១.និយមន័យ

នៅក្នុងមេរៀនមុន យើងបានដឹងហើយថា ដោយសាតឥន្ទ្រីយារម្មណ៍ យើងអាចឆ្លុះបញ្ចាំងបានលើរាល់លក្ខណៈនីមួយៗដាច់ដោយឡែកនៃវត្ថុ និងបាតុភូត។ ចំណែកឯវត្ថុ និង បាតុភូតដែលបិតនៅក្នុងតថភាពជុំវិញខ្លួនយើងនោះបាននាំមកនូវភាពស្មុកស្មាញទាំងស្រុងក្នុងការខុលប្លែកគ្នាខាងផ្នែកគុណភាព និងលក្ខណៈ។ ព្រោះហេតុដូច្នេះហើយបានជា ដើម្បីឆ្លុះបញ្ចាំងឱ្យបានគ្រប់គ្រាន់ និងប្រាកដប្រជាទៅលើវត្ថុ និងបាតុភូតឥន្ទ្រីយារម្មណ៍ដែលបិតនៅដោយឡែកត្រូវបានធ្វើសំយោគនៅលើសំបកខួរក្បាលដោយបង្កើតបានជារូបភាពទាំងមូល (image integrate) ត្រឹមត្រូវតែតខ្មោះដែលជាប់ពាក់ព័ន្ធនិងវត្ថុ ឬបាតុភូតនោះ។ ចំណាំងនៃតថភាពនៅក្នុងកំរិតនេះហោះថា ប្រត្យក្សាយារម្មណ៍។

ប្រត្យក្សារម្មណ៍គឺជាលំនាំផ្លូវចិត្តដែលឆ្លុះបញ្ចាំងបានទាំងស្រុងនូវលក្ខណៈរបស់វត្ថុនិងបាតុភូតទាំងឡាយកាលណាវាធ្វើអំពើដោយផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍របស់យើង។

ដូច្នេះប្រត្យក្សារម្មណ៍ជាសំណុំនៃចលនាការ និងជាលំនាំដែលសរីរាង្គឥន្ទ្រីយារម្មណ៍របស់មនុស្សយើងអាចទទួលការឥន្ទ្រីយារម្មណ៍ទេ។ ប្រត្យក្សាយារម្មណ៍មិនឆ្លុះបញ្ចាំងលក្ខណៈដែលស្ថិតនៅដាច់ស្រលះរបស់វត្ថុ និងបាតុភូតឡើយ។ ប្រត្យក្សារម្មណ៍ឆ្លុះបញ្ចាំងទៅលើលក្ខណៈទូទៅរបស់វត្ថុ និងបាតុភូត (ដូចជាវត្ថុដែលយើងត្រូវយកវាមកធ្វើសំយោគខាងផ្នែកលក្ខណៈរបស់វា)។ នេះមិនមែនមានន័យថា ប្រត្យក្សា

ម្មណ៍ជាផលបូកអោយឥន្ទ្រីយារម្មណ៍ដែលបិតនៅដាច់ដោយឡែកឡើយ។ ក៏ប៉ុន្តែប្រត្យក្សារម្មណ៍ជាកម្រិតថ្មីនៃការយល់ដឹងតាមរយៈសរីរាង្គឥន្ទ្រីយ៍ដោយមានចរឹករបស់ជាកំណត់ច្បាស់ដូចជាបូរណភាព (Intégrité) កម្មវិស័យភាព(Objectivité) លក្ខណៈរចនាសម្ព័ន្ធសកម្មភាព (Activité) និង ចរឹកសកម្មជាដើម។

ប្រត្យក្សាយារម្មណ៍ខុលប្លែកពីឥន្ទ្រីយារម្មណ៍ត្រង់ដែលប្រត្យក្សាយារម្មណ៍ឆ្លុះបញ្ចាំងទៅលើភាពទាំអស្រុង និងមានចរិតដ៏សំខាន់ ( Caractere principle) ប្រត្យក្សាយារម្មណ៍ផ្តល់ឱ្យយើងដឹងនូវរូបភាពទាំងស្រុងទៅលើ វត្ថុ និងបាតុភូត។ បើទុកណាជារូបភាពនោះមានលក្ខណៈមិនគ្រប់គ្រាន់ក៏ដោយ។

**ឧទាហរណ៍ ៖** គ្រាន់តែក្រឡេកឃើញវា យើងអាចដឹងបានថា រូបភាពនោះជារង្វង់ (cercle) និង

ត្រីកោណ (Triangle) គឺមិនចាំបាច់អីដល់ទៅវាមានគំនូស និងចំណុចគ្រប់គ្រាន់អីទេ។



ភាពទាំងស្រុងរបស់ប្រត្យក្សារម្មណ៍ត្រូវមានលក្ខខ័ណដោយភាពទាំងស្រុងជាសត្យានុម័តរបស់វត្ថុ និង

បាតុភូត។ ចំពោះមនុស្សយើងដោយសាតែបទពិសោធន៍ និងចំណេះដឹងរបស់គេ ទើបគេអាចក្រឡេកឃើញនូវផ្នែកដែលដាច់ដោយឡែករបស់វត្ថុ ឬបាតុភូត ដោយធ្វើសំយោគទៅលើផ្នែកផ្សេងៗនៃ វត្ថុ ឬ បាតុភូតនោះសំខាន់បង្កើតបានរូបភាពទាំងស្រុងដែលជាប់ពាក់ពន្ធ័នឹងវត្ថុ ឬបាតុភូត នេះឯង។

ដោយសារតែទង្វើរបស់វត្ថុ ឬ បាតុភូតជាក់ស្តែកពីភពជុំវិញខ្លួនយើងមកលើសរីរាង្គឥន្ទ្រីយារម្មណ៍របស់យើង ទើបកម្មវិស័យភាពនៃប្រត្យក្សារម្មណ៍បង្កើតបានជារូបភាពជាក់ស្តែង ដែលផ្តល់ឱ្យយើងតាមរយៈប្រត្យក្សារម្មណ៍នោះជារូបភាពដ៏បរិសុទ្ធសោធពិតប្រាកដរបស់វត្ថុ និងបាតុភូត ដែលពិតភពខាងក្រៅកំណត់ឱ្យយើងស្គាល់។ កម្មវិស័យនៃប្រត្យក្សារម្មណ៍បំពេញតួនាទីមួយយ៉ាងសំខាន់ គឺវាបង្កើតបានជាមូលដ្ឋាននៃមុខងារតំរង់ទិស (Fonction d'orientation) សម្រាប់អាកប្បកិរិយា និង សកម្មភាពរបស់យើង។

ដូចដែលយើងបានរៀបរាប់ខាងលើរួចមកហើយ ប្រត្យក្សារម្មណ៍មិនមែនជាផលបូកឱ្យឥន្ទ្រីយារម្មណ៍ទេ។ កាលណាយើងធ្វើឱ្យកើតមានប្រត្យក្សារម្មណ៍នៃវត្ថុណាមួយនោះតាមពិតគឺយើងក្រឡេកឃើញច្បាស់នៃរចនាសម្ព័ន្ធនេះ ទូទៅ ( structure generale) របស់វត្ថុនោះ។

**ឧទាហរណ៍** យើងទទួលដឹងទៅលើសំដីរបស់អ្នកដទៃ ពីព្រោះសំដីរបស់គេប្រើប្រាស់នោះត្រឹមត្រូវទៅតាមរចនាសម្ព័ន្ធកំណត់មួយ ជាមួយដឹងចំណងទាក់ទងគ្នាទៅវិញទៅមករវាងជាតុនៃរចនាសម្ព័ន្ធនេះ។ ចំណាំនេះមិនមែនកើតមានឡើងពីមុនទេ វាកើតឡើងនៅចំពេលដែលមានដំណើរការប្រត្យក្សារម្មណ៍។ នេះហៅថា លក្ខណៈរចនាសម្ព័ន្ធ ( Caractere structure) របស់ប្រត្យក្សារម្មណ៍។

ប្រត្យក្សារម្មណ៍គឺជាលំនាំផ្លូវចិត្តមួយដ៏សកម្មដែលផ្សារភ្ជាប់ទៅនឹងសកម្មភាពរបសើមនុស្ស។

តាមធម្មតាប្រត្យក្សារម្មណ៍របស់មនុស្សយើងប្រកាន់យកនូវលក្ខណៈភ្ញាក់រលឹកជានិច្ច។

ប្រត្យក្សារម្មណ៍មិនមែនជាលំនាំផ្លូវចិត្តដែលកើតឡើងពីការសង្កេតដ៏អសកម្ម និង ដ៏សាមញ្ញឡើយ។ ប្រត្យក្សារម្មណ៍ជាសមិទ្ធិផលដែលសំរេចបានពីភារកិច្ចជាក់ស្តែងនៃចំណេះដឹងរបស់មនុស្ស។ ស្នាដៃសិក្សាស្រាវជ្រាវក្នុងចិត្តវិទ្យាទំនើបបានបង្ហាញឱ្យយើងដឹងថា ប្រត្យក្សារម្មណ៍គឺជាទង្វើមួយដ៏សកម្មហើយជាលទ្ធផលដែលកើតចេញពីកិច្ច សហការគ្នាដ៏ស្អិតរមួតនៃជាតុទាំងឡាយរបស់ឥន្ទ្រីយារម្មណ៍ និងជាតុរបស់ចលនា។

## ២.មូលដ្ឋានសរីរៈវិទ្យារបស់ប្រត្យក្សារម្មណ៍

សរីរវិទូជាតិរុស្សីដ៏ល្បីល្បាញឈ្មោះលោក I P. Pavlov បានស្រាយបំភ្លឺថា មូលដ្ឋានសរីរាង្គវិទ្យារបស់ប្រត្យក្សារម្មណ៍គឺរ៉េផ្លិចមានលក្ខខ័ណ្ឌ (Reflexes conditionnels) ។ ទំនាក់ទំនងនៃសរសៃប្រសាទក្នុងមួយរយៈពេលកើតមានឡើងនៅក្នុងសំបកខួក្បាល កាលណាវត្ថុ ឬបាតុភូត នៃពិភពខាងក្រៅធ្វើអំពើមកលើសរីរាង្គឥន្ទ្រីរបស់យើង។

វត្ថុ ឬបាតុភូតធ្វើអំពើមកលើសរីរាង្គឥន្ទ្រិយារម្មណ៍ក្នុងឋានៈជាអ្នកញ៉ាំងឱ្យមានរំញោចដ៏ស្មុគស្មាញ។ មជ្ឈមណ្ឌលដែលឋិតនៅលើសំបកខួក្បាល សរីរាង្គកើតមានឡើងទៅតាមលំនាំនៃការវិភាគ និងសំយោគ នៅលើអ្នកញ៉ាំងឱ្យមានរំញោចស្មុគស្មាញនេះ។ ការវិភាគជានាបាននូវតួនាទីកាត់ផ្តាច់វត្ថុដែលយើងមើលឃើញពីទីតាំងដែលវាឋិតនៅ។ ឈរលើមូលដ្ឋាននៃការវិភាគបែបនេះ រាល់លក្ខណៈនៃវត្ថុទាំងឡាយដែលយើងមើលឃើញត្រូវបានយើងសំយោគគេឱ្យបានគ្រប់គ្រាន់ទៅលើវា ទើបយើងអាចបង្កើតបានរូបភាពនៃវត្ថុនោះទាំងស្រុង និង ដ៏ពេញលេញគ្រប់គ្រាន់ក្នុងខួរក្បាលរបស់យើង។

គឺដោយសារតែចំណងទាក់ទងដែលកើតឡើងរវាងសរីរាង្គវិភាផ្សេងៗគ្នានេះហើយ ដែលយើងអាចឆ្លុះបញ្ចាំងបាននូវលក្ខណៈរបស់វត្ថុ ឬបាតុភូតដែលមិនមានឧបករណ៍វិភាគរបស់វា នៅពេលដែលលំនាំនៃប្រត្យក្សារម្មណ៍បានប្រព្រឹត្តទៅ។

**ឧទាហរណ៍ ៖** វិមាត្ររបស់វត្ថុ ដង់ស៊ីតេរបស់វត្ថុ ។ល។

ព្រោះហេតុដូច្នេះហើយបានជាប្រត្យក្សារម្មណ៍ជួយយើងឲ្យស្គាល់ពិភពខាងក្រៅខ្លួនបានប្រសើរជាងឥន្ទ្រិយារម្មណ៍។

សរុបសេចក្តីមកមូលដ្ឋានសរីរវិទ្យារបស់ប្រត្យក្សារម្មណ៍ គឺជាសកម្មភាពចុះសំរុងគ្នាពីសំណាក់សរីរាង្គវិភាគជាច្រើនក្នុងខ្លួនយើង។

## II- **ចំណែកថ្នាក់នៃប្រត្យក្សារម្មណ៍** (Classification des perceptions)

តាមធម្មតាមានបែបបទពីយ៉ាង ដែលនាំឱ្យគេអាចធ្វើចំណាត់ថ្នាក់បានទៅលើប្រត្យក្សារម្មណ៍។

- គេអាចធ្វើចំណាត់ថ្នាក់ទៅលើប្រត្យក្សារម្មណ៍ ដោយយោងទៅតាមរូបភាពផ្សេងៗគ្នានៃអត្ថិភាព ( F. xi-stence) របស់វត្ថុ និងបាតុភូត។
- យោងទៅតាមលក្ខណៈវិនិច្ឆ័យទី១ យើងមានប្រត្យក្សារម្មន៍ដូចតទៅនេះ :

ប្រត្យក្សារម្មណ៍នៃចក្ខុវិញ្ញាណ ( Perception visuelle) ប្រត្យក្សារម្មណ៍នៃសោតវិញ្ញាណ ( Perception auditive)ប្រត្យក្សារម្មណ៍នៃកាយវិញ្ញាណ ( perception cutanee)។ល។

- យោងទៅតាមលក្ខណៈវិនិច្ឆ័យទី២ យើងមានប្រត្យក្សារម្មណ៍ដូចតទៅៈ ប្រត្យក្សារម្មណ៍នៃលំហ (perception de l'espece) ប្រត្យក្សារម្មណ៍នៃពេលវេលា (Perception du temps) និង ប្រត្យក្សារម្មណ៍នៃចលនា(Perception du movement)។

### ១.ប្រត្យក្សារម្មណ៍នៃលំហ

ប្រត្យក្សារម្មណ៍នៃលំហគឺជាចំណាំងនៃលំហ ដែលកើតមានឡើងតាមរបៀបសត្យានុម័ត ដែលរួមមានទំរង់(La fome) វិមាត្រ(Dimonsion) ទីតាំង(position) របស់វត្ថុនីមួយៗធៀបទៅនឹងវត្ថុមួយផ្សេងទៀតដូចជា សណ្ឋាន (Relief) របស់វា, ចម្ងាយរបស់វា (Leur distance) និង ដំណៅទិសរបស់វា (Leur orientation)។ប្រត្យក្សារម្មណ៍នៃលំហបំពេញទួនាតីមួយយ៉ាងសំខាន់នៅក្នុងអន្តរកម្ម

(Interaction) រវាងមនុស្សនិងមជ្ឈដ្ឋានជុំវិញ។ ប្រត្យក្សារម្មណ៍បានបង្កើតបានជាលក្ខខណ្ឌមួយដ៏ចាំបាច់សម្រាប់ការតំរង់ទិសរបស់មនុស្សនៅក្នុងមជ្ឈដ្ឋានជុំវិញ។

### ក.ប្រត្យក្សារម្មណ៍នៃរូបភាពរបស់វត្ថុ

ប្រត្យក្សារម្មណ៍នៃរូបភាពរបស់វត្ថុកើតមានឡើងតាមរយៈសរីរាង្គវិភាគរបស់ចក្ខុវិញ្ញាណ ( Les analysateure de la vue) សរីរាង្គវិភាពរបស់កាយវិញ្ញាណ(les analysateurs de contact)សរីរាង្គវិភាគរបស់ឥន្ទ្រីយារម្មណ៍ ដែលកើតពីចលនានៃផ្នែកផ្សេងៗរបស់ខ្លួនយើង(Analysateurs kinesthesiques)។

នេះជាផ្នែកមួយដ៏សំខាន់បំផុតដែលគេត្រូវញែកឱ្យដាច់នៅពេលដែលគេក្រឡេកឃើញវត្ថុមួយនិងស្ថានភាពជុំវិញ។ វាមានកំរិតព្រំដែនច្បាស់លាស់ណាស់រវាងរូបភាពនៃវត្ថុ និងទីតាំងដែលវត្ថុនោះស្ថិតនៅ។

ដោយសារចលនាដ៏តិចតួចនៃភ្នែករបស់យើង យើងអាចកំណត់បានច្បាស់នូវព្រំដែនរបស់វត្ថុ (ស្ថានភាពជុំវិញនិងលក្ខណៈលំអិតខ្លះៗរបស់វត្ថុនោះ)។ តាមមើលទៅទំនងជាចលនាទាំងនេះធ្វើឲ្យមានភាពកាន់តែច្បាស់លាស់ឡើងក្នុងការញែកឲ្យដាច់នូវស្ថានភាពជុំវិញវត្ថុ ហើយចលនានេះបង្កើតបានជាលក្ខខណ្ឌដ៏ចាំបាច់ដើម្បីបង្កើតបានជារូបភាពនៃទ្រង់ទ្រាយរបស់វត្ថុនៅក្នុងខួរក្បាលរបស់យើង។ លោក I.M Setchenov បានមានប្រសាសន៍ថា ភ្នែករបស់មនុស្សយើងហាក់ដូចជាប៉ះពាល់ទៅនឹងវត្ថុផ្ទាល់តែម្តង។

នៅក្នុងប្រត្យក្សារម្មណ៍នៃកាយវិញ្ញាណក៏មានលំនាំដូចគ្នាបេះបិទនេះដែរ។ ដើម្បីកំណត់បានរូបភាពនៃវត្ថុមួយដែលគ្មានចលនា ដោយការប៉ះពាល់ទៅលើវត្ថុនោះ គឺយើងគប្បីកាន់វត្ថុនោះតែម្តងដោយយកដៃកាន់វត្ថុនោះត្រឡប់ចុះត្រឡប់ឡើង។ រូបភាពនៃវត្ថុត្រូវបានបង្កើតឡើងក្នុងខួរក្បាលយើងដោយឈរលើមូលដ្ឋាននៃការចុះសម្រុងគ្នារវាងឥន្ទ្រីយារម្មណ៍នៃកាយវិញ្ញាណនិងឥន្ទ្រីយារម្មណ៍នៃចលករ។

### ខ. ប្រត្យក្សារម្មណ៍នៃវិមាត្ររបស់វត្ថុ

វិមាត្រនៃវត្ថុមួយដែលយើងក្រឡេកទៅឃើញវា ត្រូវបានយើងកំណត់ទៅលើវិមាត្រនៃរូបភាពរបស់វត្ថុនោះនៅលើស្រទាប់ស្បែកស្តើងនៃកែវភ្នែក (Retine) របស់យើង និង តាមរយៈចម្ងាយនៃវត្ថុនោះមកភ្នែករបស់យើង។ ដោយសារការសម្លឹងមើលវត្ថុនោះឱ្យច្បាស់ (Accommodation) និង ចំណុចរួមនៃការសម្លឹងមើលនោះ គេឃើញមានបន្លាស់ប្តូរមួយដែលជាប់ពាក់ព័ន្ធគ្នារវាងវិមាត្ររបស់វត្ថុ និងវិមាត្ររបស់រូបភាពនៅលើស្បែកនៃកែវភ្នែករបស់យើង បានន័យថា បើវត្ថុនោះធំ រូបភាពវានៅលើស្បែកកែវភ្នែកក៏ធំ បើវត្ថុតូចរូបភាពវាក៏តូចដែរ។

### គ.ប្រត្យក្សារមណ៍នៃជម្រៅ និង ចម្ងាយរបស់វត្ថុ

ចំពោះប្រត្យក្សារម្មណ៍នៃជម្រៅ និងចម្ងាយរបស់វត្ថុ ការមើលឃើញច្បាស់ដោយភ្នែកទាំងសងខាង (Vision binoculair) បំពេញតួនាទីយ៉ាងសំខាន់។ ការមើលឃើញវត្ថុច្បាស់ដោយភ្នែកតែមួយ

(Vision monos culaire) ធ្លុះបញ្ចាំងបានច្បាស់តែចម្ងាយនៃវត្ថុនោះ នៅក្នុងប្រវែងចម្ងាយដែលកំណត់ច្បាស់ប៉ុណ្ណោះ។

ចំពោះប្រត្យក្សារម្មណ៍នៃជម្រៅ ឥន្ទ្រីយារម្មណ៍នៃចលករ ( Sensation motrice) ទទួលបន្ទុកនូវតួនាមួយបានល្អឥតល្អៀង។ ឥន្ទ្រីយារម្មណ៍ទាំងនេះកើតមានឡើងនៅពេលណាដែលមានកាកន្ទ្រាក់ និង ការរួញនៃសាច់ដុំភ្នែករបស់យើង ( Contraction et relachements des muscles des yeux) កាលណាមានចលនាឆ្ពោះទៅរកទីដៅរួម (contraction) ឬ ចលនាចេញពីចំណុចរួមគ្នា (Divergence) នៃភ្នែករបស់យើងឬក៏នៅពេលណាដែលចលនានៃភ្នែករបស់យើងត្រូវសម្លឹងមើលវត្ថុ ឬ បាតុភូតណាមួយឱ្យបានច្បាស់។

កាលណាវត្ថុនៅឆ្ងាយពីភ្នែករបស់យើង ការបែងចែកដែលកើតឡើងផ្ទុយគ្នារវាងពន្លឺនិងភាពងងឹតដែលអាស្រ័យដោយទីតាំងរបស់វត្ថុនោះ មានអត្ថន័យសំខាន់ណាស់។ មនុស្សយើងបានរកឃើញចរិតបែបនេះ ហើយបានសិក្សាប្រើប្រាស់ពន្លឺ និង ភាពងងឹត ដើម្បីកំណត់ឱ្យបានយ៉ាងច្បាស់លាស់ពីទីតាំងរបស់វត្ថុនៅក្នុងលំហ។

នៅពេលដែលមានប្រត្យក្សារម្មណ៍នៃលំហជាទូទៅ ដោយឡែកនៅពេលដែលយើងវាយតម្លៃទៅលើចម្ងាយនៃវត្ថុណាមួយក្នុងលំហនោះ តែងតែមានការចូលរួមពីសំណាក់ឥន្ទ្រីយារម្មណ៍នៃឃានវិញ្ញាណ និងសោតវិញ្ញាណ។ ឧទាហរណ៍ ដោយឈរលើមូនដ្ឋាននៃរូបភាពដែលញុំងវិញ្ញាណរបស់យើងឱ្យត្រេកត្រអាលយើងដឹងខ្លួនយើងអាចដឹងបានថា បុគ្គលណាម្នាក់នោះកំពុងតែដើរមកជិតយើង ឬ ដើរទៅឆ្ងាយពីយើង។

## ឃ. ប្រត្យក្សារម្មណ៍នៃការតម្រង់ទិស

កត្តាមួយនៅក្នុងចំណោមកត្តានៃការញែកដាចពីទស្សនៈស្តីពីលំហ គឺប្រត្យក្សរម្មណ៍ នៃការតំរង់ទិសនៃវត្ថុបើធៀបទៅនឹងវត្ថុឯទៀត ឬ ធៀបទៅនឹងការពិនិត្យសង្កេត។ ការតំរង់ទិសរបស់វត្ថុដែលយើងក្រឡេកឃើញ ត្រូវបានកំណត់ដោយទីតាំងនៃរូបផាពរបស់វត្ថុនោះនៅលើកែវភ្នែករបស់យើង ហើយនិងទីតាំងរបស់ខ្លួនយើងដោយធៀនទៅនឹងវត្ថុឯទៀតដែលនៅជុំវិញខ្លួនយើង។ ចំពោះមនុស្សយើងឥរិយាបថឈរត្រង់នៃដងខ្លួនកដោយធៀបទៅនឹងប្លង់ផ្តេក (plan horizontal) នៃផែនដី គឺជាទីតាំងដែលមានលក្ខណៈពិសេស ( Position Caracteristique)។ ឥរិយាបថបែបនេះដែលកើតមកពីរធម្មជាតិនៃសង្គម (Nature sociale) និង ការងាររបស់មនុស្ស គឺជាឥរិយាបថជាមូលដ្ឋានសម្រាប់កំណត់បាននូវការតំរង់ទិសរបស់វត្ថុ ដែលស្ថិតនៅក្រៅក្របខ័ណ្ឌ របស់ឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណឥន្ទ្រីយារម្មណ៍ចលករនៃភ្នែកនិងដៃ គេត្រូវរាប់បញ្ចូលថែមទៀតពីឥន្ទ្រីយារម្មណ៍នៃស្ថិតិ ( sensations statiques)។ ម្យ៉ាងវិញទៀតឥន្ទ្រីយារម្មណ៍នៃសោតវិញ្ញាណ និង ឃានវិញ្ញាណ ក៏ចូលរួមចំណែកផងដែល នៅក្នុងប្រត្យក្សារម្មណ៍នៃការតំរង់ទិស។ ប្រត្យក្សារម្មណ៍នៃការតំរង់ទិសទៅលើសម្លេងដែលយើងស្តាប់ឮ ប្រព្រឹត្តទៅដោយសារតែជំនួយនៃសោតវិញ្ញាណទាំងសងខាង។ បទពិសោធន៍បានជួយសម្រួលឱ្យយើងយល់ដឹងបានថា មូលដ្ឋាន

នៃការញែកដាច់ទៅលើដំណៅទិសនៃសម្លេង គឺកាខុសប្លែកគ្នានៃរយៈពេលពីរដងដែលរំញោចនៃសម្លេងរត់មកប៉ះនឹងត្រចៀកយើងទាំងពីរ។

សម្លេងដែលរត់មកប៉ះត្រចៀកត្រូវបានគេកំណត់ទីតាំង មិនត្រឹមតែខាងឆ្វេង ខាងស្តាំ ពីមុខពីក្រោយប៉ុណ្ណោះទេ ប៉ុន្តែគេអាចកំណត់ទីតាំងរបស់វាបាន ពីលើឬពីក្រោមទៀតផង។ នៅក្នុងករណីចុងក្រោយនេះចលនានៃក្បាលរបស់មនុស្សយើង ត្រូវគូបផ្សំដោយលក្ខខ័ណ្ឌមួយយ៉ាងសំខាន់។

## ២. ប្រត្យក្សារម្មណ៍នៃពេលវេលា

ប្រត្យក្សារម្មណ៍នៃពេលវេលា គឺជាចំណាំងនៃរយៈពេល នៃល្បឿន និង លក្ខណៈផ្សារភ្ជាប់រដឹកជាសត្យានុម័តនៃបាតុភូតទាំងឡាយដែលស្ថិតនៅក្នុងតថភាព។ ដោយសារប្រត្យក្សារម្មណ៍នៃពេលវេលាបន្លាស់ប្តូរដែលកើតមានឡើងនៅក្នុងពិភពជុំវិញខ្លួនយើង ត្រូវបានឆ្លុះបញ្ចាំង។

លំហនៃពេលវេលាត្រូវបានកំណត់ឡើងដោយលំនាំនៃសកម្មភាពកើតមាននៅក្នុងសំពាង្គកាយរបស់យើង ដោយយោលទៅតាមសង្វាក់ជាក់ស្តែងដូចជា៖ សង្វាក់នៃជីពចរបេះដូង សង្វាក់របស់ចលនានៃការដកដង្ហើម សង្វាក់នៃការឆ្លាស់គ្នាទៅតាមពេលវេលានៃសកម្មភាពក្នុងការភ្ញាក់ពីដំណេក និងការចូលដំណេក។ល។ សង្វាក់នៃជីវភាពរស់នៅជាប្រចាំរាល់ថ្ងៃនេះ ជះឥទ្ធិពលយ៉ាងខ្លាំងដល់ការបណ្តុះបណ្តាលរ៉េផ្លិចមានលក្ខខណ្ឌដែលអាស្រ័យដោយពេលវេលា។ រ៉េផ្លិចទាំងនេះគឺ ពិតជាមូលដ្ឋានសរីរវិទ្យានៃលំនាំរបស់ប្រត្យក្សារម្មណ៍ពេលវេលា។ មានតែលំហដ៏ខ្លីនៃពេលវេលាទេ ដែលត្រូវបានមនុស្សយើងមានប្រត្យក្សារម្មណ៍ដោយផ្ទាល់ហើយប្រាកដប្រជាផង។

ប្រត្យក្សារម្មណ៍នៃពេលវេលាកើតឡើងអាស្រ័យដោយកត្តាជាច្រើនរួមគ្នាដូចជា៖

- ខ្លឹមសានៃសកម្មភាពរបស់មនុស្ស។ **ឧទាហរណ៍៖** ពេលវេលាដែលមនុស្សយើងត្រូវធ្វើការងារណាមួយដ៏សំខាន់ ហើយប្រកបទៅដោយផលប្រយោជន៍នោះ ហាក់ដូចជាកន្លងផុតទៅឆាប់រហ័សណាស់ រីឯការងារដែលធ្វើឱ្យយើងធុញទ្រាន់ ឬនឿយហត់អស់កម្លាំង ហាក់ដូចជាស៊ីពេលវេលាយូណាស់។
- ទំនួលផ្លូវចិត្តរបស់បុគ្គល។ **ឧទាហរណ៍៖** ដោយរស់នៅក្នុងព្រឹត្តិកាណ៍មួយដ៏សោកសៅក្រៀមក្រំគេហាក់ដូចជាមានអារម្មណ៍មួយថា ពេលវេលានោះកន្លងទៅឆាប់ពេក ផ្ទុយទៅវិញកាលណាគេរស់នៅក្នុងព្រឹត្តិកាណ៍មួយដែលមានសុភមង្គល គេហាក់ដូចជាមានអារម្មណ៍មួយថា ពេលវេលាកន្លងទៅយឺតណាស់។
- វ័យរបស់មនុស្ស។ **ឧទាហរណ៍៖** ក្មេងៗច្រើនតែមានអារម្មណ៍មួយថាពេលវេលាកន្លងទៅយឺតណាស់ រីឯចាស់ៗវិញ ហាក់ដូចជាចេះតែព្រួយបារម្ភថា ពេលវេលាកន្លងទៅរហ័សណាស់។

ដោយសាបទពិសោធន៍ និងសកម្មភាពប្រតិបត្តមនុស្សយើងអាចជៀសផុតបានពីភាពអត្តនោម័ត (subjective) ចំពោះប្រត្យក្សារម្មណ៍នៃពេលវេលានៅក្នុងបទពិសោធន៍នៃការងារដែលមនុស្សធ្លាប់ធ្វើ។

ឧទាហរណ៍ៈ សាស្ត្រាចារ្យដ៏មានបទពិសោធន៍ម្នាក់អាចឱ្យតម្លៃទៅលើពេលវេលានៃការងារ និងបែងចែកបានយ៉ាងច្បាស់លាស់នៃពេលវេលា ដែលកាត់ត្រូវបង្រៀនដោយមិនបាច់ប្រើនាឡិការ។

### ៣. ប្រត្យក្សារម្មណ៍នៃចលនា

ប្រត្យក្សារម្មណ៍ចលនា គឺជាចំណាំងនៃបន្លាស់ប្តូរទីតាំងរបស់វត្ថុទាំងឡាយ ដែលស្ថិតនៅក្នុងលំហ ចំពោះប្រត្យក្សារម្មណ៍នៃចលនា ឥន្ទ្រីយារម្មណ៍នៃចក្ខុវិញ្ញាណ និង ចលករ ដើរតួនាទីសំខាន់ណាស់។ ល្បឿន និង បន្លាស់ប្តូរល្បឿន ព្រមទាំងទិសដៅនៃចលនា ( Direction du movement) គឺជាគុណភាពកំណត់របស់ចលនា(Parametres du movement)។ គេអាចទទួលពត៌មានបានពីបន្លាស់ប្តូរនៃទីតាំងរបស់វត្ថុ ដែលស្ថិតនៅក្នុងលំហតាមរបៀបពីយ៉ាងផ្សេងពីគ្នា គឺៈ

- ក្រឡេកមើលឃើញដោយផ្ទាល់ ចំពោះចលនានៃវត្ថុដែលស្ថិតនៅក្នុងលំហ។
- សន្និដ្ឋានបាន ចំពោះចលនានៃវត្ថុ ដោយពិនិត្យពិច័យឃើញថា បន្ទាប់ពីរយៈពេលមួយជាកំណត់ វត្ថុនោះ ស្ថិតនៅក្នុងទីតាំងមួយផ្សេងទៀត។

ករណីទី១ កើតមានឡើងតែនៅពេលណាដែលវត្ថុមានចលនាដោយកម្លាំងនៃល្បឿនដ៏ខ្លាំងក្លារហូតទាល់តែចម្ងាយផ្លូវធ្វើដំណើរបានរបស់វត្ថុនោះនៅក្នុងមួយឯកតានៃពេលមិនខ្លីដូចចម្ងាយផ្លូវចរដែលយើងអាចក្រឡេកមើលឃើញដោយផ្ទាល់នឹងភ្នែករបស់យើងពីមុននេះ។
ករណីទី២ កើតមានឡើងកាលណាចលនានៃវត្ថុនោះយឺតពេក។ នៅក្នុងករណីនេះគេក្រឡេកឃើញតែលទ្ធផលនៃចលនាប៉ុណ្ណោះ ដោយមើលមិនឃើញចលនានៃវត្ថុឡើយ។

**ឧទាហរណ៍ៈ** ការសន្និដ្ឋានបានទៅលើទ្រនិចនាឡិកាដែលចង្អុលម៉ោង។

ប្រត្យក្សារម្មណ៍នៃចលនាអាចកើតមានឡើងដោយសារតែសរីរាង្គវិភាគរបស់សោតវិញ្ញាណ។យើងអាចពិនិត្យពិច័យឃើញថាភាពស្តាប់ឮនៃសម្លេង ដែលយើងក្រឡេកទៅឃើញចេះតែបង្កើននូវកម្លាំងរបស់វានៅពេលណាដែលប្រភពនៃសម្លេងនោះចូលមកជិតយើង ហើយកម្លាំងនៃសូរនោះថយចុះជាលំដាប់កាលណាប្រភពនៃសម្លេងរថយឆ្ងាយទៅៗពីយើង។

## III. ច្បាប់នៃប្រត្យក្សារម្មណ៍

លំនាំនៃប្រត្យក្សារម្មណ៍របស់មនុស្សប្រព្រឹត្តទៅតាមក្រិតក្រមដូចតទៅ:

### ១.ច្បាប់ប្រមូលផ្តុំនៃប្រត្យក្សារម្មណ៍

វត្ថុ និងបាតុភូត ដែលនៅជុំវិញខ្លួនយើងមានលក្ខណៈជាពហុសណ្ឋានផ្សេងៗគ្នា។ មនុស្សយើងមិនអាចក្រឡេកឃើញវត្ថុ និងបាតុភូតទាំងនោះតែមួយដងបានទេ។ គេអាចកាត់ផ្តាច់វាបានតែមួយចំនួនខ្លះដែលគេសម្លឹងឃើញតែប៉ុណ្ណោះ។ តាមធម្មជាតិរបស់វាប្រត្យក្សារម្មណ៍គឺជាលំនាំនៃការប្រមូលផ្តុំ (processus de la selection) ពោលគឺជាលំនាំដែលកាត់ផ្តាច់វត្ថុពីទីតាំងរបស់វា។ ការក្រឡេកឃើញវត្ថុណាមួយនោះមានន័យថាកាត់ផ្តាច់វត្ថុនោះពីវត្ថុដទៃទៀតនៅជុំវិញវា។ ដូច្នេះដរាបណាដែលវត្ថុ ឬ លក្ខណៈនៃវត្ថុ

នោះខុសប្លែកពីរទីតាំងរបស់វាដរាបនោះគេកាន់តែមើលឃើញវត្ថុនោះយ៉ាងងាយ ហើយគ្រប់គ្រាន់ទៅតាមអត្ថន័យរបស់វាផង។ ការប្រមូលផ្ដុំស្មារតីនៅក្នុងប្រត្យក្សារម្មណ៍មិនមានលក្ខណៈនឹងថ្កល់ឡើង។ តួនាទីរបស់វត្ថុនិងតួនាទីនៃទីតាំងរបស់វាអាចផ្លាស់ប្ដូរគ្នាទៅវិញទៅមក។ កាលណាគេកើតមានប្រត្យក្សារម្មណ៍ទៅលើវត្ថុអ្វីមួយ ដែលស្ថិតនៅជុំវិញវត្ថុនោះគឺជាទីតាំងរបស់វា។ កាលណាគេសម្លឹងមើលវត្ថុមួយផ្សេងទៀតវត្ថុទី១ នោះក្លាយទៅជាទីតាំងរបស់វត្ថុទីពីរនេះទៅវិញ។

ភាពប្រមូលផ្ដុំនៃប្រត្យក្សារម្មណ៍ពឹងផ្អែកលើចំណង់ចំណូលចិត្ត ទំនួលផ្លូវចិត្ត និងតម្រូវការរបស់បុគ្គលនោះ។ ទំនាក់ទំនងរបស់មនុស្សជាមួយនឹងវត្ថុដែលគេក្រឡេកឃើញ ហើយនឹងឥរិយាបថរបស់មនុស្សនោះចំពោះវត្ថុ និង កំណត់បានយ៉ាងដាច់ណាត់នូវចំណាត់តាំងនិងការប្រព្រឹត្តទៅនៃលំនាំរបស់ប្រត្យក្សារម្មណ៍។

តាមពិតភាសាមនុស្សយើងសំខាន់ណាស់ក្នុងការធ្វើឲ្យប្រត្យក្សារម្មណ៍កើតមានឡើង។ ដូច្នេះមានន័យថាសេចក្ដីណែនាំរបស់គ្រូបង្រៀនដែលញ៉ាំងឲ្យ សិស្សមានប្រត្យក្សារម្មណ៍ទៅលើឯកសារ សម្ភារសិក្សា ឬការបង្រៀនដោយប្រើផែនទី រូបភាព គំនូសតាង...។

ច្បាប់នៃប្រត្យក្សារម្មណ៍ត្រូវបានគេយកមកអនុវត្តយ៉ាងទូលំទូលាយនៅក្នុងតថភាព។ ដើម្បីឱ្យវត្ថុមានចំណាំងកាន់តែប្រសើរឡើង គេគប្បីរកមធ្យោបាយកាត់ផ្ដាច់វត្ថុនោះឱ្យដាច់ស្រឡះពីរផ្ទៃ ឬ ពីទីតាំងរបស់វា។ ឧទាហរណ៍សសេរដីសរពណ៌សនៅលើក្ដាខៀនពណ៌ខ្មៅ ឬ ពណ៌បៃតង ប្រើប្រាស់ពណ៌ខ្មៅក្រហមដើម្បីគូសបន្ទាត់នៅលើពាក្យដែលសំខាន់ៗ។ ដើម្បីធ្វើឱ្យប្រត្យក្សារម្មណ៍ជួបការលំបាកលើវត្ថុ គេគប្បីធ្វើឱ្យវត្ថុនោះលាយឡំ ឬច្របូកច្របល់ទៅនឹងផ្ទៃ ឬទីតាំងរបស់វា។

**ឧទាហរណ៍:** ការក្លែងបន្លំខ្លួននៅពេលមានសង្គ្រាម ឬ ពេលចម្បាំង។





ដោយក្រឡេកមើលគំនូរធរណីមាត្រនេះ គេជឿថា AB > BC តែតាមពិតគឺថា AB = BC។



នេះជាបំណាកស្រាយខុសឆ្គងទៅលើទិន្នន័យឥន្ទ្រីយារម្មណ៍។ ការសម្លឹងមើលវត្ថុប្រហាក់ប្រហែលគ្នាបណ្តាលឱ្យមានការព្រឹលភ្នែក។ ការមើលឃើញខុសឆ្គងនេះ ជាប់ពាក់ព័ន្ធទៅនឹងទំហំ (Grandeur) ទម្រង់ (Forme) វិមាត្រ ( Dimension) និងពណ៌របស់វត្ថុ (Couluer) ។ ការមើលឃើញខុសឆ្គងនេះច្រើនតែកើតមានទៅលើរូបគំនូរធរណីមាត្រ ដែលគេឱ្យឈ្មោះថា (Illusion optico- geometrique) ។ រូបភាពបែបនេះកើតមានគ្រប់បុគ្គលទាំងអស់ ក្នុងការឱ្យតម្លៃទៅលើក្រឡាផ្ទៃ ( Surface) បណ្តោយ (Longueur) ទិសដៅ (Direction)។




F1-រង្វង់តូចពីប៉ុនគ្នា បើគេយករង្វង់មួយទៅដាក់ឱ្យចរិកនៅក្នុងរង្វង់ធំមួយ វាហាក់ដូចជាធំជាងរង្វង់តូចដែលមិនចារឹកក្នុងរង្វង់ធំ (ការពិសោធន៍របស់លោក Delboeuf)។



F2 -បន្ទាត់ a និង bមើលទៅហាក់ដូចជាកោង ប៉ុន្តែតាមពិតបន្ទាត់ទាំងពីរត្រង់ហើយស្របគ្នា។

(ការពិសោធន៍របស់Hering)។



F3- យោងទៅតាមទីតាំងរបស់អង្កត់ផ្ចិតរបស់បន្ទាត់ទាំងពីរ គឺវាស្មើគ្នា តែយើងក្រឡេកមើលទៅ វាហាក់ដូចជាមានប្រវែងខុសគ្នា។ តែគេមើលទៅឃើញថា a > b ។ បទពិសោធន៍របស់លោក )Muller) ។

## ២ .ច្បាប់អត្ថន័យនៃប្រត្យក្សារម្មណ៍

ប្រត្យក្សារម្មណ៍កើតមានឡើង ដោយសារទង្វើផ្ទាល់របស់រំញោចមកលើសរីរាង្គឥន្ទ្រីយារម្មណ៍របស់យើង ក៏ប៉ុន្តែរូបភាពនៃប្រត្យក្សារម្មណ៍តែងតែនាំមកជានិច្ចនូវអត្ថន័យមួយជាកំណត់ ពោលគឺជាអត្ថន័យនៃការក្រឡេកឃើញវត្ថុដែលជាហេតុឱ្យគេអាចកំណត់ឈ្មោះវត្ថុនោះបាននៅក្នុងខួក្បាលរបស់គេ។ គេអាចធ្វើចំណាត់ថ្នាក់វត្ថុនេះបានទៅតាមក្រុមរបស់វា ឬ នៅក្នុងចំណាត់ថ្នាក់ណាមួយជាកំណត់នៃវត្ថុនោះ ហើយមនុស្សយើងអាចធ្វើទូទៅកម្មបានទៅលើវត្ថុនោះដោយពាក្យ ឬ សម្ដីជាក់ស្ដែង។ សូម្បីតែកាលណាគេត្រូវក្រឡេកឃើញវត្ថុចម្លែកមួយគេតែងតែរិះរកផងដែរក្នុងការធ្វើចំណាត់ថ្នាក់វត្ថុនោះទៅក្នុងប្រភេទនៃវត្ថុដែលមានលក្ខណៈដូចគ្នា។ អត្ថន័យរបស់ប្រត្យក្សារម្មណ៍ធ្វើឱ្យយល់ដឹងបានថា ប្រត្យក្សារម្មណ៍ គឺជាលំនាំមួយដ៏សកម្មដែលមនុស្សយើងចាប់ផ្ដើមធ្វើសកម្មភាពញាណសក្តិ ដើម្បីបង្កើតបានជារូបភាពដែលជាប់ពាក់ព័ន្ធនឹងវត្ថុនោះនៅក្នុងខួក្បាលរបស់មនុស្សយើង។

ដោយយកច្បាប់នេះទៅអនុវត្តក្នុងការប្រតិបត្តិនៅក្នុងការបង្ហាញអំពីវត្ថុថ្មី បាតុភូត ឬសញ្ញាណណាមួយដល់សិស្ស យើងជាគ្រូបង្រៀនគប្បោះផ្ដត់ផ្ដង់ឲ្យសិស្សដឹងច្បាស់ពីឈ្មោះនៃផ្នែកផ្សេងៗព្រមទាំងពាក្យច្បាស់លាស់របស់វត្ថុនោះ។

## ៣. ច្បាប់ស្ថេរភាពនៃប្រត្យក្សារម្មណ៍

ស្ថេភាពនៃប្រត្យក្សារម្មណ៍គឺជាសតិ(Faculte) សម្រាប់ឆ្លុះបញ្ចាំងតាមបែបនឹងផ្ដល់ទៅលើវត្ថុកាលណាលក្ខខណ្ឌនៃប្រត្យក្សារម្មណ៍នោះផ្លាស់ប្ដូរ។

ឧទាហរណ៍: នៅពីមុខយើងមានកុមារម្នាក់នៅពីក្រោយកុមារនោះ ឆ្ងាយមានតាចាស់ម្នាក់។ នៅលើស្បែកកែវភ្នែករបស់យើង រូបភាពកុមារ ធំជាងរូបភាពរបស់តាចាស់។ ប៉ុន្តែតាមពិតយើងក្រឡេកឃើញថា តាចាស់ធំជាងកុមារ។ ឬក៏យើងអានអត្ថបទមួយនៅលិចង្កៀងអគ្គីសនីពណ៌ខៀវ តាមការត្រិះរិះយើងថាសៀវភៅយើងទៅជាមានពណ៌ខៀវ។ ប៉ុន្តែនៅក្នុងពេលនោះតែម្តងយើងគិតថា សៀវភៅយើងពណ៌សទេ។

ដូច្នេះតើស្ថេរភាពនៃប្រត្យក្សារម្មណ៍កើតមកពីណា ? តើជាចលនាការពីកំណើតឬ? ស្នាដៃស្រាវជ្រាវអំពីប្រត្យក្សារម្មណ៍ចំពោះអ្នកដែលរស់នៅក្នុងព្រៃស្រោងហើយនិងអ្នកដែលរស់នៅក្នុងតំបន់វាលទំនាបបានបង្ហាញឲ្យយើងដឹងថា ស្ថេរភាពនៃប្រត្យក្សារម្មណ៍ចំពោះចម្ងាយ និងកំពស់ត្រូវបានកាត់ផ្ដាច់។ ចំពោះអ្នកដែលរស់នៅក្នុងព្រៃស្រោងស្ទើរមួយជីវិតតែងតែក្រឡេកឃើញវត្ថុដែលស្ថិតនៅឆ្ងាយពីខ្លួននោះមានរាងតូច ហើយចំពោះអ្នកណាដែលឆ្លងកាត់ធាកជីវិតរបស់ខ្លួននៅតាមវាលទំនាប ក៏

តែងតែមើលឃើញវត្ថុដែលស្ថិតនៅកន្លែងទាបជាងកន្លែងដែលខ្លួនឈរនៅ (កំពូលភ្នំនិងជើងភ្នំ) ជាវត្ថុតូចដែរ។នេះមានន័យថា ស្មារតីនៃប្រត្យក្សារម្មណ៍ត្រូវបានបណ្តុះបណ្តាលក្នុងខួរក្បាលរបស់តាមរយៈបទពិសោធន៍។ បទពិសោធន៍ទាំងនេះត្រូវបានគេប្រមូលផ្តុំទុកក្នុងខួរក្បាលនៅពេលមនុស្សយើងប្រកបជីវភាពរស់នៅផ្ទាល់ខ្លួនម្នាក់ៗ។

ស្មារតីនៃប្រត្យក្សារម្មណ៍ គឺជាលក្ខខណ្ឌមួយដ៏ចាំបាច់ នៅក្នុងជីវភាពរស់នៅ និងសកម្មភាពរបស់មនុស្ស។ បើគ្មានស្មារតីនេះ មនុស្សយើងមិនអាចតំរង់ទិសដោយខ្លួនឯងបាននៅក្នុងពិភពដែលមានទ្រង់ទ្រាយច្រើនបែបយ៉ាង ហើយដែលមនុស្សអាចកែប្រែខ្លួនឯងបានជាប់ជាប្រចាំ។

## ៤. ច្បាប់នៃការយល់ដឹង

ប្រត្យក្សារម្មណ៍មិនគ្រាន់តែទទួលរងបាននូវឥទ្ធិពលរបស់កត្តាខាងក្រៅខ្លួនយើងប៉ុណ្ណោះទេ ប៉ុន្តែវាក៏ទទួលរងឥទ្ធិពលពីកត្តាខាងក្នុងខ្លួនយើងដែលស្ថិតនៅជាប្រធានវិស័យ (sujet) របស់ប្រត្យក្សារម្មណ៍នេះទៀតផង។ ក៏មិនមែនជាភ្នែកទាំងពីរ ហើយក៏មិនមែនជាត្រចៀកទាំងពីររបស់យើងឡើយ ដែលបំរើការដោយខ្លួនឯងសម្រាប់ប្រត្យក្សារម្មណ៍នោះ។ ប្រត្យក្សារម្មណ៍នេះចាប់ផ្តើមកើតឡើងជានិច្ចចំពោះមនុស្សជាក់ស្តែង។ ហេតុដូចនេះហើយបានជាចរិតនៃបុគ្គលិកលក្ខណៈរបស់មនុស្ស ដែលឱ្យកំណើតដល់ប្រត្យក្សារម្មណ៍តំរូវការ (Besoions) ចំណង់ចំណូលចិត្ត (Interets) រស់ជាតិ (gouts) ហើយនិងសញ្ចេតនា (Sentiments) ត្រូវបានស្តែងឡើងឱ្យ ឃើញជានិច្ចទៅតាមកំរិតមួយជាកំណត់នៅក្នុងប្រត្យក្សារម្មណ។ ភាពពឹងអាស្រ័យនៃប្រត្យក្សារម្មណ៍ក្នុងខ្លឹមសារនៃជីវិតផ្លូវចិត្តរបស់មនុស្សយើង និងចរិកបុគ្គលិកលក្ខណៈរបស់គេនេះហើយដែលគេឱ្យឈ្មោះថា ការយល់ដឹងបាន (Aperception) ។

ឧទាហរណ៍: លទ្ធផលរបស់ប្រត្យក្សារម្មណ៍ទៅលើទេសភាពដែលនៅជុំវិញខ្លួនយើង ប្រែប្រួលទៅតាមភាពផ្លូវចិត្តរបស់យើង (Notre etat d'ame) ។ កាលណាយើងក្រៀមក្រំផ្លូវចិត្តទេសភាពនៅជុំវិញខ្លួនយើងហាក់បីដូចជាងងឹត (Sombre) ហើយអួរអាប់ ( Terne) ។ ក៏ប៉ុន្តែកាលណាយើងទទួលបានដំណឹងថ្មីមួយតួជាទីរីករាយក្នុងចិត្ត ទេសភាពដែលនៅជុំវិញខ្លួនយើងទៅជាស្រស់បំព្រងវិញ។ មានសុភាសិតមួយឃ្លាចែងថា "ឃ្លានឆ្ងាញ់ស្រលាញ់ល្អ"។

បញ្ហាទាំងនេះបង្ហាញឲ្យឃើញថាប្រត្យក្សារម្មណ៍ជាលំនាំមួយដ៏សកម្មដែលមនុស្សយើងអាចដឹកនាំវាបាន។

ប្រត្យក្សារម្មណ៍អាចកើតឡើងយ៉ាងពេញទំហឹងបាន ហើយប្រកបទៅដោយជោគជ័យលុះត្រាតែមានការយល់ដឹងដ៏សមស្របផងដែរ។ ដូច្នេះនៅក្នុងលំនាំនៃការបង្រៀន និងអប់រំសិស្សគ្រូបង្រៀនត្រូវគិតដល់បទពិសោធន៍ ចំណេះដឹង និន្នាការ ចំណង់ចំណូលចិត្ត និងទំនួលផ្លូវចិត្តរបស់សិស្សកាលណាសិស្សនោះត្រងត្រាប់នូវការពន្យល់របស់គ្រូ។

## ៥. ច្បាប់មាយាការរបស់ប្រត្យក្សារម្មណ៍

មាយាការរបស់ប្រត្យក្សារម្មណ៍គឺជាចំណាំងដ៏ខុសឆ្គងជាសត្យានុម័តរបស់វត្ថុ ឬបាតុភូតចំពោះមនុស្ស។ ចំណាំងដ៏ខុសឆ្គងនេះមានលក្ខណៈសមស្របទៅនឹងច្បាប់របស់វា។ បាតុភូតនេះត្រូវបានគេជួបប្រទះជាធម្មតាចំពោះបុគ្គលគ្រប់រូបទាំងអស់។ ដូច្នេះគេគប្បីញែកឱ្យដាច់មាយាកាពីសញ្ញាវិបល្លាស។ សញ្ញាវិបល្លាសជាជម្ងឺម្យ៉ាង។ មាយាការរបស់ប្រត្យក្សារម្មណ៍កើតមាននៅគ្រប់ប្រភេទប្រត្យក្សារម្មណ៍ទាំងអស់ដូចជាប្រត្យក្សារម្មណ៍នៃលំហ ប្រត្យក្សារម្មណ៍នៃពេលវេលា និងប្រត្យក្សារម្មណ៍នៃចលនាជាដើម។



នៅក្នុងរូបគំនូរនេះយើងឃើញចង្កឹះនេះហាក់ដូចជាបាក់ តែតាមការពិតចង្កឹះនៅក្នុងរូបកែវទឹកមិនបាក់ទេ។

រាល់មាយាការរបស់ប្រត្យក្សារម្មណ៍ សុទ្ធតែមានហេតុដ៏ច្បាស់លាស់ត្រឹមត្រូវរបស់វាខុសប្លែកពីមាយាការដទៃទៀត។

ជាទូទៅយើងឃើញថា វាមានមូលហេតុបីប្រភេទ ដែលបង្កឱ្យមានមាយាការរបស់ប្រត្យក្សារម្មណ៍គឺ ៖

- មូលហេតុផ្លូវកាយ ( Causes Physique )
- មូលហេតុសរីរៈវិទ្យា ( Causes Physiologiques )
- មូលហេតុផ្លូវចិត្ត (Causes Psychiques )

នៅក្នុងការបង្រៀនសិស្ស យើងជាគ្រូបង្រៀនគប្បីជៀសវាងមាយាការជាអតិបរមានៅក្នុងប្រត្យក្សារម្មណ៍របស់សិស្សដោយរៀបចំឱ្យបានត្រឹមត្រូវនូវសម្ភារៈឧបទ្ទេសសិក្សាដូចជាៈ រូបថត ផ្ទាំងគំនូរ រូបភាព គំនូរវាស រូបចាក់ពុម្ព...។ គ្រូត្រូវបង្ហាញវត្ថុទាំងអស់នេះឲ្យសិស្សឃើញទៅតាមលក្ខណៈវិទ្យាសាស្ត្រដ៏ច្បាស់លាស់ព្រមទាំងដឹកនាំសិស្សឲ្យយកចិត្តទុកដាក់ពិនិត្យសង្កេតសម្ភារៈដែលយកមកបង្រៀនឲ្យបានយ៉ាងហ្មត់ចត់។ ផ្ទុយទៅវិញនៅក្នុងវិស័យលាបព៌ណផ្ទាំងគំនូរ ការតុបតែងបន្ទប់ គេតែងតែឆ្លៀតបង្កើតឱ្យមានមាយាការរបស់ប្រត្យក្សារម្មណ៍។

## IV. **ការពិនិត្យសង្កេត និងសម្មតភាពពិនិត្យសង្កេត**

ការពិនិត្យសង្កេតជារូបភាពដ៏សកម្មបំផុត និង ជាកំរិតដ៏ខ្ពស់បំផុតរបស់ប្រត្យក្សារម្មណ៍។ ការពិនិត្យសង្កេតនេះជាប្រត្យក្សារម្មណ៍ប្រកបដោយឆន្ទៈ (perception volontaire) ដែលស្ថិតនៅក្រោមទំរង់នៃសកម្មភាពដែលមានលក្ខណៈម្ចាស់ការ និង ស៊ីពេលវេលាដ៏យូបង្គួរ សំដៅឆ្លុះបញ្ចាំងបានទាំងស្រុង និងយ៉ាងច្បាស់លាស់ផងទៅលើវត្ថុ និងបាតុភូត ព្រមទាំងបន្ទាស់ប្តូររបស់វត្ថុ និង បាតុភូតនោះផង។

មនុស្សគ្រប់រូបសុទ្ធតែមានសមត្ថភាពពិនិត្យសង្កេតបាន។ ក៏ប៉ុន្តែលទ្ធផលនៃការពិនិត្យសង្កេតនេះមិនដូចគ្នាបេះបិទទេពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ រឿងនេះកើតឡើងពីមូលហេតុជាច្រើន ហើយនៅក្នុងចំណោមមូលហេតុទាំងនោះជាដំបូងបង្អស់នោះគេអាចរាប់បានពីមូលហេតុនៃការខុសប្លែកគ្នាចំពោះសមត្ថភាពពិនិត្យសង្កេតរបស់បុគ្គលម្នាក់ៗ។

សមត្ថភាពនៃការពិនិត្យសង្កេតគឺជាសតិដែលមនុស្សយើងក្រឡេកទៅឃើញយ៉ាងរហ័ស និងយ៉ាងច្បាស់លាស់លើរាល់ចំណុចសំខាន់ៗនិងដោយឡែករបស់វត្ថុ និងបាតុភូតទាំងឡាយ ទោះណាជាចំណុចទាំងនោះវាពិបាកនឹងក្រឡេកមើលឃើញ ឬក៏វាលេចធ្លោឡើងក្នុងលក្ខណៈដែលមិនសំខាន់ចំពោះយើងក៏ដោយ។

សតិនេះត្រូវបានបណ្តុះបណ្តាលក្នុងខួរក្បាលរបស់យើងតាមរយៈសកម្មភាពអប់រំ និងការហ្វឹក ហាត់។

ដើម្បីពិនិត្យសង្កេតមើលវត្ថុ ឬ បាតុភូតណាមួយឱ្យបានច្បាស់លាស់ គេគប្បីយកចិត្តទុកដាក់ប្រយ័ត្នប្រយែងទៅនឹងលក្ខខណ្ឌទាំងឡាយដូចតទៅ:

១. កំណត់ឲ្យបានច្បាស់លាស់នូវអត្ថន័យ( Signification) គោលបំណង(But) តម្រូវការនៃការពិនិត្យសង្កេត (Besion de l'observation) រួចយោងទៅលើលក្ខណៈអស់ទាំងនេះគប្បីឱ្យនិយមន័យទៅលើឥរិយាបថ (Attitude) និង ភារកិច្ចនៃការពិនិត្យសង្កេតផង។

២. មុននឹងពិនិត្យសង្កេត គប្បីត្រៀមលក្ខណៈឲ្យបានច្បាស់លាស់ ដូចជាទិសដៅនៃការយល់ដឹង និងមធ្យោបាយពិនិត្យសង្កេត។

៣. ចាប់ផ្តើមពិនិត្យសង្កេតទៅតាមគម្រោងដែលរៀបចំរួចជាស្រេច និងតាមលក្ខណៈប្រព័ន្ធកម្មផង។

៤. នៅពេលពិនិត្យសង្កេត គេគប្បីប្រើប្រាស់ឲ្យបានយ៉ាងសកម្មខាងមធ្យោបាយភាសា។

៥. ចំពោះកុមារគេគប្បីបង្កើតឲ្យមាននូវលក្ខខណ្ឌងាយស្រួលដល់គេ សំដៅឲ្យគេប្រមូលផ្តុំសរីរាង្គឥន្ទ្រីយ៍ជាច្រើនក្នុងការពិនិត្យសង្កេត។

៦. កត់ត្រាលទ្ធផលនៃការពិនិត្យសង្កេតរួចទាញចេញជាសេចក្តីសន្និដ្ឋានផង។

៧. យកលទ្ធផលនៃការសង្កេតទៅប្រើប្រាស់ឲ្យបានសកម្ម។

ក្រៅពីលក្ខខណ្ឌដូចបានលើកឡើងមកនេះ គេគប្បីកត់សម្គាល់ឱ្យបានល្អិតល្អន់នូវភាពខុសប្លែកគ្នារវាងបុគ្គលទាំងឡាយនៅលើផែនការនៃប្រត្យក្សារម្មណ៍។ មានប្រត្យក្សារម្មណ៍ និងការពិនិត្យសង្កេតបួនប្រភេទដូចតទៅ:

- ប្រភេទនៃការពិនិត្យសង្កេត ដោយប្រើសំយោគវិធី

(Type d'observation synthetique)

- ប្រភេទនៃការពិនិត្យសង្កេត ដោយប្រើការវិភាគ

(Type d'observation analytique)

- ប្រភេទនៃការពិនិត្យសង្កេត ដោយធ្វើសំយោគផង វិភាគផង

( Type d'observation analytico – synthetique)

- ប្រភេទនៃការពិនិត្យសង្កេត តាមលក្ខណៈនៃចិត្តរំជួល

( Type d'observation emotive )

## V. ប្រត្យក្សារម្មណ៍ជាទង្វើញាណសត្តិ

ដោយដាច់ស្រឡះពីទស្សនៈជីវសាស្ត្រ ចិត្តវិទ្យាញាណសត្តិមានគោលបំណង ធ្វើឱ្យទ្រឹស្តីនៃប្រត្យក្សារម្មណ៍ មានសភាពថ្មីថ្មោង តាំងពីដើមទសវត្សឆ្នាំ ១៩៧០ ដោយស្នើឡើងនូវរបៀបធ្វើវិភាគ (Mode d'analyse) ដែលដាក់បញ្ចូលតាមរយៈទ្រឹស្តីក្នុងម៉ាស៊ីនកុំព្យូទ័រ និង ឧបករណ៍នៃទំនាក់ទំនង។ និន្នាការនៃចិត្តវិទ្យាពិសោធន៍នេះត្រូវបានគេបង្កើតឡើងដែលឈរលើមូលដ្ឋាននៃកម្រិតមួយដែលថាប្រត្យក្សារម្មណ៍ជាទង្វើញាណសត្តិ។ ក្នុងន័យនេះគឺថា បាតុភូតដែលគេយល់ដឹងបានតាមរយៈទង្វើនេះ គឺជាលទ្ធផលនៃការទទួលពត៌មានជាអត្តនោម័ត ( Traitement subjectif) ដែលដឹកនាំដោយកម្មវិធីមួយហើយគឺកម្មវិធីនេះឯងដែលតំរង់ទិសឱ្យយុទ្ធសាស្ត្រនៃអាកប្បកិរិយារបស់មនុស្ស។ ដូច្នេះពាក្យថា "ញាណសត្តិ (Cognition)" គ្រោបក្តាបលំនាំទាំងអស់ហើយតាមរយៈលំនាំទាំងនោះព័ត៌មានដែលសាមីជនបានទទួលនោះ ត្រូវបានប្រែក្លាយ តាក់តែង និង រក្សាទុកក្នុងលំនឹកសម្រាប់ឱ្យមនុស្សប្រើប្រាស់។ នេះជាគំនិតរបស់លោក Neisser ដែលបានស្រាវជ្រាវក្នុងឆ្នាំ ១៩៦៧។ ដោយគ្មានការទាមទារដើម្បីធ្វើឱ្យទ្រឹស្តីនៃប្រត្យក្សារម្មណ៍នេះមានភាពថ្មីស្រឡាងដោយផ្អែកលើមួយស័ព្ទដើមនៃបញ្ហាដែលលើកឡើងនៅក្នុងការសិក្សាស្រាវជ្រាវអំពីប្រត្យក្សារម្មណ៍នេះ ចិត្តវិទ្យាញាណសត្តិបានផ្តល់ឱ្យឱ្យយ៉ាងពិតប្រាកដនូវមាគាមួយដែលខិតចូលទៅជិតមុខងារ ដែលគេអាចទាញបាននូវរូបមន្តរបស់សប្បតិកម្មថ្មី ដោយពឹងផ្អែកលើសំណង់ចិត្តវិទ្យា )Constructions Psychiques) ដែលបកស្រាយបំភ្លឺពីលក្ខណៈពិសេសរបស់សកម្មភាពញាណសត្តិក្នុងខ្លួនមនុស្សយើង។ សកម្មភាពនេះផ្សាភ្ជាប់ទៅនឹងទស្សនៈនៃការងារស្រាវជ្រាវពីមុនរបស់លោក D.A Broadhent ក្នុងឆ្នាំ ១៩៥៨ ស្តីអំពីទំនាក់ទំនងរវាងប្រត្យក្សារម្មណ៍ និង ឧបកណ៍ទំនាក់ទំនង ព្រមជាមួយនឹងការងាររបស់លោក Jean Piaget ផង។

## VI. ប្រត្យក្សារម្មណ៍ និង បញ្ហារបស់មនុស្ស

មាននៅសល់បញ្ហាជាច្រើនទៀត ដែលត្រូវធ្វើឱ្យប្រត្យក្សារម្មណ៍ និង ទំនាក់ទំនងរវាងសកម្មភាពប្រត្យក្សារម្មណ៍ និងបញ្ហារបស់មនុស្សអភិវឌ្ឍន៍ឡើង។ ដោយមិនអាចជំរឿនបាន (Recenser) និងការងារដ៏ច្រើនបែបនេះដែលត្រូវសិក្សាស្រាវជ្រាវពីដំណើរការអភិវឌ្ឍរបស់ប្រភេទផ្សេងៗនៃប្រត្យក្សារម្មណ៍ គេក៏បានកំណត់យកត្រឹមកិច្ចពិភាក្សាទៅលើនិក្ខេបទខ្លះជាមូលដ្ឋាន ជាពិសេសនិក្ខេបទដែលឡើងការពារដោយលោក Jean Piaget ហើយត្រូវបានគេបោះពុម្ពផ្សាយយ៉ាងទូលំទូលាយ។ ក្នុងនិក្ខេបបទលោក Piaget បានសរសេរថា "ប្រត្យក្សារ ម្មណ៍គឺជាចំណេះដឹងដែលយើងទទួលបានពីវត្ថុ ឬបាតុភូតនិងចលនារបស់វាតាមរយៈការប៉ះពាល់វាដោយផ្ទាល់ ឬក៏ជួបប្រទះជាប្រចាំក្នុងជីវភាពរស់នៅ។ ចំណែកឯបញ្ញាគឺជាចំណេះដឹងដែលស្ថិតនៅក្នុងខួក្បាលយើង ដែលធ្វើឱ្យមានការបទបែននិង ចម្ងាយក្នុងលំហាធ្វើអន្តរាគមន៍និង កើនឡើង រវាងមនុស្ស និងវត្ថុ"។ និយមន័យនេះ មានពាក់ពន្ធ័បន្តិចបន្តួចប៉ុណ្ណោះទៅនឹងការស្រាវជ្រាវរបស់លោក Sherrington ។ ចំពោះលោក Piaget គឺជាការត្រឹមត្រូវហើយដែលថាប្រត្យក្សារម្មណ៍ និង បញ្ញាផ្សាភ្ជាប់គ្នានោះ ពីព្រោះគេមានករណីពីរនៅក្នុងលំនាំដែលកើតចេញពីការធ្វើឱ្យ

មានលំនឹងនៅទីបញ្ចប់ ( Equilibration terminale) គឺការរៀបចំឱ្យមានរចនាសម្ព័ន្ធនឹងននៅក្នុងវិស័យប្រត្យក្សារម្មណ៍ និង ការរៀបចំឱ្យបានដំណើរការដ៏នឹងនរនៅក្នុងវិស័យបញ្ហា។ ទ្រឹស្ដីដែលឡើងការពារដោយលោក Piaget បើកទូលាយឱ្យការពិនិត្យអង្កេតទៅលើទ្រឹស្ដីប្រត្យក្សារម្មណ៍។ ទ្រឹស្ដីរបស់លោក Piaget នេះទទួលស្គាល់លក្ខណៈជីវសាស្ត្រទី១ របស់ទំរង់ ប៉ុន្តែប្រានចោលនូវគំនិតនៃបម្រែបម្រួលទៅតាមច្បាប់រៀបចំនៅពេលដែលសតិអារម្មណ៍ចេះតែអភិវឌ្ឍឡើង។

គោលការណ៍ផ្សេងៗគ្នាដែលលោក Piaget បានលើកឡើងមានលក្ខណៈដូចតទៅៈ

- រចនាសម្ពន្ធ័នៃប្រត្យក្សារម្មណ៍ ត្រូវបានបញ្ជាក់ច្បាស់លាស់ទៅលើភាពទាំងស្រុង តាមរយៈផលនៃបន្លាស់ប្តូរផ្ទៃក្នុងតាមផ្នែករបស់វា។ រចនាសម្ព័ន្ធនៃដំណើរការរបស់បញ្ហាមិនប្រែប្រួលឡើយទោះជាមានបន្លាស់ប្តូរផ្ទៃក្នុងយ៉ាងណាក៏ដោយ។ នេះក៏ដោយសាតែអន្តរាគមន៍នៃការទូទាត់តាមផ្លូវបញ្ញា ហើយក៏គឺជាភាពអាចត្រឡប់ប្រែប្រួលបានរបស់បញ្ញាដែរ។
- នៅក្នុងសកម្មភាពរបស់ប្រត្យក្សារម្មណ៍លើរាល់ការបម្រែបម្រួលទិសមិនមានលក្ខណៈដូចគ្នាទេ ហើយការខុសប្លែកគ្នានេះ ត្រូវបាកែតំរូវវិញតាមរយៈវិមជ្ឈការ (Decentration) ។ សកម្មភាពនៃបញ្ញាចាប់ផ្ដើមកើតមានផងដែរតាមរយៈវិមជ្ឈការ ក៏ប៉ុន្តែវិមជ្ឈការនេះនៅទៅបញ្ចប់ បានឈានដល់វត្ថុវិស័យភាព (Objectivities) តាមរយៈមាគាទាំងឡាយដែលជាសរសៃប្រសាទដ៏ទន់ផ្ចារ ហើយមានចំនួនដ៏ច្រើនអនេក។
- នៅក្នុងប្រត្យក្សារម្មណ៍ វិជ្ឈការបង្កឱ្យមានភាពខូចទ្រង់ទ្រាយ ពីព្រោះវិមជ្ឈកាលនេះ កើតមានឡើងនៅក្នុងចំនួនដែលកំរិតច្បាស់សំដៅកំណត់បានការធ្វើវិមជ្ឈការទាំងស្រុងលើវត្ថុវិសយ័ភាព។ ដូច្នេះរចនាសម្ព័ន្ធរបស់ប្រត្យក្សារម្មណ៍ស្ថិតនៅក្នុងភាពមិនទាន់ប្រាកដច្បាស់លាស់នៅឡើយ។ ភាពប្រែត្រឡប់បានដែលមានលក្ខណៈជាប់ៗគ្នា គឺផ្ទុយគ្នាស្រឡះទៅនឹងភាពដែលអាចប្រែត្រឡប់បាន ( Reversibilite) របស់វិមជ្ឈការដ៏ពេញលេញ (Decentration compete) របស់ទង្វើនៃបញ្ញាActe de l’ intelligence) ។ ទង្វើនិងភាពខុសប្លែកគ្នានេះលោក J piaget បានបង្ហាញឱ្យដឹងនូវចរិតជាច្រើនដែលមើលទៅហាក់ដូចជា ប្រត្យក្សារម្មណ៍ និងបញ្ញនេះស្ថិតនៅរួមគ្នា។ ដោយឡែកគាត់បានវាយតម្លៃថា លំនាំនៃនិយតកម្មដែលបកស្រាយបំភ្លឺតាមរយៈបទអន្តរាគមន៍របស់វិមជ្ឈកាលដ៏ត្រឹមត្រូវនោះ លេចធ្លោឡើងស្រាប់ហើយនៅក្នុងទង្វើនៃបញ្ញាពីព្រោះវារួមចំណែកដល់ការកាត់បន្ថយលក្ខណៈប្រហាក់ប្រហែលរបស់ប្រត្យក្សារម្មណ៍។ភស្តុតាងផ្សេងៗទៀតជាច្រើនដែលបានលើកឡើងជាពិសេសពីការសិក្សាស្រាវជ្រាវរកបម្រែបម្រួលរបស់មាយាការ (Variations des illusions) ។ទៅតាមមុខងារនៃវ័យរបស់មនុស្សត្រូវបានគេលើកមកជជែកការពារនៅក្នុងអត្ថន័យដូចគ្នា។ គេអាចអះអាងបានទៅលើការប្រមើមើលរបស់លោក Piaget ថាការពិនិត្យសង្កេតបែបនេះបានគូសបញ្ជាក់ពីសកម្មភាពប្រត្យក្សារម្មណ៍ (Activities cognitive ) របស់បុគ្គលម្នាក់ដែលកើតឡើងផ្ទុយគ្នា និងបុគ្គលម្នាក់ទៀតដែលស្ថិតនៅក្រោមទិដ្ឋភាពតែមួយដូចគ្នា។ នេះមិនមែនជាគុណបំណាច់ដ៏តូចតាចស្តួចស្តើងទេ ការវិភាគរបស់លោក Piaget បានបង្ហាញឱ្យឃើញថា ការសិក្សាអំពីរដើមកំណើតនៃចលនារបស់សតិអារម្មណ៍ (Operations

mentales) ពឹងផ្អែកជាចាំបាច់ទៅលើកាខិតចូលឱ្យជិតតាមលក្ខណៈជីវសាស្ត្រ ចំពោះទង្វើប្រត្យក្សារម្មណ៍ (Actes percetifs) ។

## សំណួរ

១- ចូរប្រៀបធៀបភាពដូចគ្នា និង ភាពខុសគ្នារវាងឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍។

២- ចូរលើកឧទាហរណ៍ពី លំនាំចិត្ត សភាពចិត្ត និង លក្ខណៈចិត្ត។

៣- លើកឡើងពីអត្ថប្រយោជន៍នៃឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍ ក្នុងការបង្រៀនសិស្ស។

៤- អត្ថប្រយោជន៍របស់ឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍ក្នុងវិស័យផ្សេងៗទៀត។ ចូរលើកឧទាហរណ៍

# មេរៀនទី៧ ៖ លំនឹក

យើងបានដឹងរួចមកហើយថា ចិត្តមនុស្សមានតួនាទីតម្រែតម្រង់ទង្វើ ឬ សកម្មភាពរបស់មនុស្ស។ ភាពស្មុគស្មាញនៃអំពើរបស់មនុស្សនេះ កើតមានឡើងបន្តិចម្តងៗ ដោយសារតែការប្រមូលផ្តុំនៃបទពិសោធន៍របស់បុគ្គលម្នាក់ៗ ។ បទពិសោធន៍នេះមិនអាចបណ្តុះបណ្តាលក្នុងខ្លួនមនុស្សយើងម្នាក់ៗបានទេ ប្រសិនណាជា រូបភាពនៃពិភពខាងក្រៅខ្លួន ដែលជិតជាប់នៅលើសំបកខួរក្បាល ត្រូវបានរលុបបាត់ទាំង ស្រុង។ នៅក្នុងតថភាព រូបភាពទាំងនេះមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក។ រូបភាពទាំងនេះត្រូវបានពង្រឹងពង្រីក រក្សាទុក ហើយកើតឡើងសារជាថ្មី កាលណាជីវភាពរស់នៅ និង សកម្មភាពការងាររបស់បុគ្គលម្នាក់ៗត្រូវការវា។ លំនាំនៃការរក្សាទុកបទពិសោធន៍ និង ការបញ្ចេញនូវបទពិសោធន៍នោះឡើងវិញ ហៅថា លំនឹក។ ដោយសារលំនឹកនេះ ហើយទើបសកម្មភាពញាណសក្តិរបស់មនុស្សយើងឈានដល់កំរិតថ្មីមួយ គឺឆ្លុះបញ្ចាំងដោយប្រយោល ទៅលើវត្ថុ និង បាតុភូត។

## I - សញ្ញាណទូទៅស្តីអំពីលំនឹក

### ១ - និយមន័យ

លំនឹក គឺជាលំនាំផ្លូវចិត្ត ដែលឆ្លុះបញ្ចាំងបទពិសោធន៍របស់បុគ្គលម្នាក់ៗ ដោយស្ថិតនៅក្រោមរូបភាពនៃរូបតំណាង។

ដោយមានភាពស្រដៀងគ្នានឹងឥន្ទ្រីយារម្មណ៍ ហើយនិងប្រត្យក្សារម្មណ៍ លំនឹកក៏គឺជាលំនាំផ្លូវចិត្តមួយផងដែរ។ ប៉ុន្តែលំនឹកឈានដល់កំរិតមួយខ្ពស់ជាង បើធៀបទៅនឹងឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍។ លំនឹក ឆ្លុះបញ្ចាំងបាននូវវត្ថុ និង បាតុភូត ដែលបានធ្វើអំពើមកលើសរីរាង្គឥន្ទ្រីយ៍របស់យើងពីមុន ដោយមិនបាច់ត្រូវការ អំពើរបស់វាក្នុងបច្ចុប្បន្នកាល។ ពិសេសណាស់ទៅទៀត លំនឹកឆ្លុះបញ្ចាំងបាននូវបទពិសោធន៍របស់មនុស្ស។ បទពិសោធន៍របស់មនុស្សអាចជាអ្វីមួយ ឬក៏ជារូបភាពជាក់ស្តែង ( ឧទា: គេអាចចងចាំបាននូវទឹកមុខដ៏ស្រស់របស់នរណាម្នាក់ ) ឬក៏ជាចិត្តរំភើប ( ឧទា: គេអាចចងចាំបានថា គេធ្លាប់មានចិត្តរំភើប ពេលដែលដឹងថា គេប្រលងជាប់ហើយ ) ឬក៏ជាវិញ្ញាណ ( ឧទា: សាស្ត្រាចារ្យអាចចងចាំបានពីចិត្តរំភើបជាលើកដំបូងបង្អស់ នៅពេលដែលគាត់បានបកស្រាយពន្យល់មេរៀនមួយដល់សមូហភាពសិស្ស ) ឬក៏ជាការត្រិះរិះការគិត ( ឧទា: បន្ទាប់ពី បានសិក្សាទស្សនៈនយោបាយរួចហើយ គេចងចាំបានជានិច្ចនូវទស្សនៈខុសឆ្គងទៅលើបញ្ហាបច្ចុប្បន្នភាពនយោបាយសព្វថ្ងៃនេះត្រង់ចំណុចណាមួយ ) ឬក៏ជាអំពើ ( ឧទា: គេចងចាំបានជានិច្ចនូវចលនានៃមេរៀនកាយសម្ព័ន្ធ។

ដោយហេតុថា ខ្លឹមសារនៃចំណាំងរបស់លំនឹកមានលក្ខណៈទូលំទូលាយបែបណានោះ ក្នុងបច្ចុប្បន្ន កាលនេះគេយល់ឃើញថា លំនឹកមិនគ្រាន់តែកើតមាននៅត្រង់ចន្លោះព្រំដែននៃសកម្មភាពញាណសក្តិប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជាផ្នែកមួយដែលបណ្តុះបណ្តាលបាននូវបុគ្គលិកលក្ខណៈរបស់មនុស្សទៀត ផង។ ចរិតលក្ខណៈខាងផ្លូវចិត្តនៃបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ ត្រូវបានបណ្តុះបណ្តា

លឡើង ដោយឈរលើមូលដ្ឋាននៃបទពិសោធន៍លើគ្រប់ទិដ្ឋភាពទាំងអស់របស់បុគ្គលនោ គឺបទពិសោធន៍នេះហើយ ដែលមនុស្សយើងម្នាក់ៗ ត្រូវបញ្ចេញអោយឃើញតាមរយៈលំនឹក។

ផលិតផលនៃលំនឹក គឺជារូបតំណាង។ ដូច្នេះតើត្រង់ចំណុចណាខ្លះទៅដែលផលិតផលរបស់លំនឹកខុសប្លែកគ្នាពីផលិតផលរបស់ឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍ (រូបភាព)? រូបតំណាងរបស់លំនឹកគឺជារូបភាពនៃវត្ថុ និង បាតុភូត ដែលលេចធ្លោឡើងនៅក្នុងខួរក្បាលរបស់មនុស្សយើង កាលណាអំពើរបស់វត្ថុ និង បាតុភូត នោះមិនមានសកម្មភាពដោយផ្ទាល់មកលើសរីរាង្គឥន្ទ្រីយ៍របស់មនុស្សយើង។ មូលដ្ឋានសរីរៈវិទ្យារបស់រូបតំណាង គឺជាស្នាមគំនូសរបស់រំញោចដែលមានពីមុន ដែលជិតជាមជាប់នៅលើសំបកខួរក្បាល។ ក្រោមអំពើនៃរំញោចណាមួយ ទំនាក់ទំនងពីមុននៅក្នុងសរសៃប្រសាទរបស់ខួរក្បាលរស់ឡើងវិញ ហើយធ្វើអោយលេចធ្លោ ឡើងនូវរូបភាពវត្ថុ ឬបាតុភូតណាមួយ។

រូបតំណាង គឺ ពិតជាលទ្ធផលនៃការទទួលព័ត៌មាន ឬ រូបភាព និង ទូទៅកម្មនៃរូបភាពខាងក្នុងខួរក្បាល ដែលទទួលយកតាមរយៈប្រត្យក្សារម្មណ៍។ បើគ្មានប្រត្យក្សារម្មណ៍ទេនោះក៏គ្មានរូបតំណាងដែរ។ ឧទាហរណ៍ៈ មនុស្សខ្វាក់ពីកំណើត មិនមានរូបតំណាងខាងផ្នែកពណ៌សម្បុរ ឬ ទេសភាពល្អទេ។ អ្នកថ្លង់ពីកំណើតក៏គ្មានរូបតំណាងខាងផ្នែកសម្លេងដែរ។

រូបតំណាងខុសប្លែកពីរូបភាពរបស់ប្រត្យក្សារម្មណ៍ត្រង់ចំណុចដែលថា រូបតំណាងឆ្លុះបញ្ចាំងទៅលើវត្ថុ តាមបែបបទដ៏ទូទៅបំផុត។ រូបតំណាងឆ្លុះបញ្ចាំងសញ្ញាដែលមានលក្ខណៈពិសេសច្បាស់លាស់របស់វត្ថុ និង បាតុភូត។ រូបតំណាងមានលក្ខណៈជាក់ស្តែងផង និង លក្ខណៈទូទៅផង។ ភាពស្រដៀងគ្នាជាមួយនឹងរូបភាពរបស់ប្រត្យក្សារម្មណ៍ស្ថិតនៅត្រង់លក្ខណៈជាក់ស្តែង។ ប៉ុន្តែជាមួយនឹងចរិតទូទៅរូបតំណាងស្ថិតនៅត្រង់កំរិតមួយរវាងចំណេះដឹងឥន្ទ្រីយ៍ និង ចំណេះដឹងវិចារណ៍។

ដោយឈរលើមូលដ្ឋាននៃកំរិតទូទៅកម្មរបស់រូបតំណាង មនុស្សយើងម្នាក់ៗ មានរូបតំណាងជាលក្ខណៈបុគ្គលផង និង រូបតំណាងដែលមានលក្ខណៈទូទៅផង។ ឧទាហរណ៍ៈ រូបតំណាងនៃទន្លេមួយដែលមានលក្ខណៈទូទៅ និង រូបតំណាងនៃទន្លេមួយជាក់ស្តែងច្បាស់លាស់។ ប្រសិនណាជាប្រភេទប្រត្យក្សា រម្មណ៍ផ្សេងៗ ត្រូវបានគេយកមកប្រើប្រាស់ជាមូលដ្ឋាន ដើម្បីធ្វើចំណាត់ថ្នាក់ទៅលើប្រត្យក្សារម្មណ៍ គេ មានៈ

- រូបតំណាងរបស់ចក្ខុវិញ្ញាណ
- រូបតំណាងរបស់សោតវិញ្ញាណ
- រូបតំណាងរបស់ឃានវិញ្ញាណ
- រូបតំណាងរបស់ជីវ្ហាវិញ្ញាណ
- រូបតំណាងរបស់កាយវិញ្ញាណ

រូបតំណាងរបស់ប្រត្យក្សារម្មណ៍ដែលកើតពីចលនានៃសាច់ដុំ បង្កឡើងនូវអ្វីដែលគេហៅថា អំពើជាអាទិ៍ ឬ អំពើនៃការចូលរួមរបស់រូបតំណាង និង ចលនាការនៃសរសៃប្រសាទ។ អំពើនេះជួយអោយគេបកស្រាយ

ពន្យល់បាននូវបាតុភូតផ្សេងៗ (អំនានលើគំនិត) នៅក្នុងខ្សែភាពយន្តរបស់រុស្ស៊ីដែលដាក់ចំណងជើងថា: " ប្រាំពីរជំហានឈានដល់ជើងមេឃ " ។

## ២ - ចំណែកថ្នាក់នៃលំនឹក

លំនឹកមានប្រភពចេញមកពីជីវភាពរស់នៅ និង សកម្មភាពច្រើនបែបយ៉ាងរបស់មនុស្សម្នាក់ៗ ។ ដូច្នេះហើយបានជាទំរង់នៃការស្តែងចេញរបស់លំនឹកក៏ខុសប្លែកគ្នាដែរ។ គេធ្វើចំណាត់ថ្នាក់លំនឹក ដោយយោលទៅតាមលក្ខណៈវិនិច្ឆ័យដូចតទៅ:

- ប្រភព
- ខ្លឹមសារដែលឆ្លុះបញ្ចាំងនៅក្នុងលំនឹក
- គោលបំណងរបស់លំនឹក
- ពេលវេលាពង្រឹងពង្រីក និង ចងចាំឯកសាររបស់លំនឹក
- សរីរាង្គឥន្ទ្រីយ៍ដែលគ្រប់គ្រងចលនានៅពេលមានលំនឹក

### ក - លំនឹកដោយខ្សែក និង លំនឹករបស់បុគ្គល

លំនឹកដោយខ្សែក គឺជាលំនឹកដែលកើតមានឡើងនៅក្នុងលំនាំនៃកំណកំណើត និង ការវិវត្តរបស់សត្វ និង រុក្ខជាតិ។ លំនឹកនេះត្រូវបានពង្រឹងពង្រីក នឹងផ្ទេរតាមរយៈតំណពូជមនុស្សពីជំនាន់មួយទៅជំនាន់មួយទៀត ហើយលំនឹកនេះមានជាប់ជាប់នូវចរិតទូទៅគ្រប់ប្រភេទទាំងអស់។ លំនឹកដោយខ្សែកស្តែងចេញអោយឃើញទៅតាមរូបភាពនៃសភាវគតិ និង រ៉េផ្លិចគ្មានលក្ខខណ្ឌ។ ចំនែកឯលំនឹករបស់បុគ្គលវិញ គឺជា លំនឹកដែលកើតមានឡើងនៅពេលដែលមានដំណើរអភិវឌ្ឍន៍នៃរាងកាយរបស់មនុស្ស។ លំនឹកនេះខុសប្លែកពីលំនឹកដោយខ្សែក ហើយវាខុសប្លែកគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត។ ការរីកដុះដាលរបស់វា កើតមានឡើងនៅក្នុងជីវភាពរស់នៅ និង តាមរយៈសកម្មភាពរបស់បុគ្គលម្នាក់ៗ ។ លំនឹកបែបនេះក៏កើតមានដែរចំពោះសត្វ ហើយស្តែងអោយឃើញតាមរយៈនៃភាពប៉ិនប្រសប់ បទពិសោធន៍ និង រ៉េផ្លិចមានលក្ខខណ្ឌ។ ចំពោះមនុស្ស លំនឹករបស់បុគ្គល ស្តែងចេញអោយឃើញតាមរយៈភាពស៊ីជំរៅផ្ទាល់ខ្លួនទៅលើបទពិសោធន៍ផ្សេងៗគ្នា។

### ខ - លំនឹកចលករ លំនឹកជាប់ជំពាក់ក្នុងចិត្ត លំនឹករូបភាព និង លំនឹកទៅលើវាចាន័ ត្រឹមត្រូវ

នៅក្នុងសកម្មភាពផ្សេងៗគ្នា មនុស្សយើងក៏ស្តែងចេញនូវប្រភេទនៃលំនឹកផ្សេងៗពីគ្នាដែរ ដូចជា:

➢ **លំនឹកចលករ** ជាលំនឹកដែលឆ្លុះបញ្ចាំងចលនា និង ប្រព័ន្ធនៃចលនា។ អត្ថន័យដ៏ធំធេងនៃលំនឹកនេះ ស្ថិតនៅត្រង់វាសំរាប់ប្រើប្រាស់ជាមូលដ្ឋាន ដើម្បីបណ្តុះបណ្តាលទម្លាប់ផ្សេងៗក្នុងមុខវិជ្ជាជីវៈ និង ទម្លាប់ក្នុងការងារ។ ឧទាហរណ៍: ភាពស្វ័យប្រវត្តិក្នុង

ការដើរ ភាពស្វ័យប្រវត្តិក្នុងសំណេរ ។ល។ បើគ្មាន លំនឹកចលករទេ ម្តងណាក៏ដោយអោយតែគេចង់ធ្វើអំពើបែបណាមួយនោះ គេគប្បីរៀនធ្វើវាសារជាថ្មីសិន។ ទឹកដៃប៉ិនប្រសប់ និង ទឹកដៃមាស គឺសុទ្ធតែជាសញ្ញារបស់លំនឹកចលករដ៏ល្អប្រពៃ។

- **លំនឹកជាប់ជំពាក់ចិត្ត** ជាលំនឹកដែលឆ្លុះបញ្ចាំងនូវវិញ្ញាសារគួរអោយរំភើបក្នុងខ្លួនមនុស្ស។

លំនឹកនេះ បំពេញតួនាទីដ៏សំខាន់នៅក្នុងជីវិតរស់នៅរបស់មនុស្សយើងម្នាក់ៗ ។ វិញ្ញាសារគួរអោយរំភើបដែលយើងចងចាំបាននៅក្នុងលំនឹក នឹងស្តែងចេញអោយឃើញជាសញ្ញាដែលធ្វើអោយយើងមានរំញោច ឬ កាត់បន្ថយអំពើដែលយើងធ្វើពីមុនដោយបង្កអោយមានចិត្តរំភើបជាវិជ្ជមាន ឬ ចិត្តរំភើបអវិជ្ជមាន។ សតិនៃការ សម្តែងចេញនូវសមានចិត្តជាមួយនឹងអ្នកដទៃ ឬ ជាមួយនឹងតួអង្គក្នុងរឿងប្រលោមលោក សណ្ឋិតនៅក្នុងខ្លួនយើង ដោយឈរលើមូលដ្ឋានរបស់លំនឹកជាប់ជំពាក់ក្នុងចិត្តនេះឯង។

- **លំនឹករូបភាព** ជាលំនឹកដែលឆ្លុះបញ្ចាំងនូវរូបភាព និង រូបតំណាងដែលកើតឡើងតាមរយៈចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ ចំពោះវត្ថុ និង បាតុភូត ដែលធ្វើអំពើពីមុនមកលើសរីរាង្គឥន្ទ្រីយ៍របស់យើង។ លំនឹកនេះអាចឈានដល់កំរិតមួយខ្ពស់ខុសពីធម្មតាក្នុងការអភិវឌ្ឍន៍ នៅពេលណាដែលវាត្រូវការទូទាត់ ឬ ជំនួសអោយលំនឹកណាមួយទៀតដែលត្រូវលុបសាបសូន្យបាត់ទៅ។ នេះគឺជាករណីរបស់មនុស្សខ្វាក់ មនុស្សថ្លង់។ លំនឹករូបភាពអភិវឌ្ឍដោយឡែកចំពោះបុគ្គលទាំងឡាយណាដែលធ្វើសកម្មភាពសិល្បៈ។ ជួនកាលយើងជួបប្រទះនឹងមនុស្សដែលជាប់ជំពាក់ទៅនឹងរបស់ដែលហៅថា អារម្មណ៍ដក់ជាប់នឹងរូបភាព ពោលគឺ លំនឹកដែលមានរូបតំណាងលេចផ្លោឡើងនៅក្នុងខួរក្បាលតាមរបៀបដ៏រស់រវើក ហាក់បីដូចជា វត្ថុ ឬ បាតុភូត ស្ថិតនៅ ឬ កើតមានឡើងចំពោះភ្នែកស្រស់ជាក់ស្តែង។ គេហាក់ដូចជាមានអារម្មណ៍ គេអាចមើលឃើញវត្ថុដែលលែងស្ថិតនៅពីមុខគេទៀតនោះ ជាក់ស្តែងហើយគេនៅឮសូរសម្លេងរបស់វត្ថុ ឬ បាតុភូតណាមួយដែលលែងកើតមានទៀតនោះ។ នេះគឺជារូបតំណាងម្យ៉ាងដោយឡែកដែលមានលក្ខណៈលំអិត ហើយគ្រប់គ្រាន់ដូចគ្នានឹងរូបភាពរបស់ប្រត្យក្សារម្មណ៍ដែរ។

- **លំនឹកនៅលើវាចាដ៏សមហេតុផល** ជាលំនឹកដែលឆ្លុះបញ្ចាំងបាននូវឧត្តមគតិ ឬ ការគិតរបស់ មនុស្សយើង។ បើគ្មានភាសា គ្មានវាក្យស័ព្ទ នោះឧត្តមគតិ និង ការគិតរបស់មនុស្សមិនអាចមានអត្ថិភាពបាន ឡើយ ព្រោះដូច្នេះហើយបានជាគេហៅលំនឹកនេះថា ជាលំនឹកទៅលើវាចាដ៏សមហេតុផល។

ប្រព័ន្ធសញ្ញាការទីពីរ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងលំនឹកនេះ។ លំនឹកបែបនេះស្ថិតនៅបានចំពោះតែមនុស្សយើងប៉ុណ្ណោះ។ សត្វមិនមានលំនឹកប្រភេទនេះទេ។ ឈរលើមូលដ្ឋាននៃការអភិវឌ្ឍន៍នៃលំនឹករូបភាព លំនឹកជាប់ជំពាក់ចិត្ត និង លំនឹកចលករនេះហើយ ដែលធ្វើអោយលំនឹកទៅលើវាចាដ៏សមហេតុផលក្លាយទៅជា លំនឹកដែលមានតួនាទីដឹកនាំលំនឹកឯទៀតៗក្នុងខ្លួនមនុស្សយើង។ លំនឹកនេះទទួលបន្ទុកនូវតួនាទីដ៏សំខាន់ ក្នុងការប្រមូលផ្តុំចំណេះដឹងរបស់សិស្ស ក្នុងពេលដែលលំនាំនៃការសិក្សាប្រព្រឹត្តទៅ។

### គ - លំនឹកអឆន្ទៈ និង លំនឹកឆន្ទៈ

- **លំនឹកអឆន្ទៈ** គឺជាប្រភេទនៃលំនឹកម្យ៉ាងដែលធ្វើអោយលំនឹកកម្ម ការចងចាំ នឹងការរំលឹកឡើងវិញទៅលើវត្ថុណាមួយ ដែលកើតមានឡើងដោយមិនតំរង់មុខសញ្ញាទៅរកគោលដៅ ដែលបានកំណត់ទុកជាមុនឡើយ។
- **លំនឹកឆន្ទៈ** ចំណែកឯលំនឹកឆន្ទៈវិញ គឺជាលំនឹកផ្ទុយពីលំនឹកអឆន្ទៈ។ លំនឹកឆន្ទៈកើតមានឡើងដោយយោលទៅលើគោលដៅ ដែលបានកំណត់ទុកជាមុន។

ប្រភេទនៃលំនឹកអឆន្ទៈ និង លំនឹកឆន្ទៈ ទាំងពីរនេះ គឺជាកំរិតពីរដែលកើតមានជាបន្តបន្ទាប់គ្នាក្នុងការអភិវឌ្ឍន៍របស់លំនឹក។ លំនឹកទាំងពីរប្រភេទនេះបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពរស់នៅ និងសកម្មភាពក្នុងការងាររបស់បុគ្គលម្នាក់ៗ ។

### ឃ - លំនឹកក្នុងរយៈពេលខ្លី និង លំនឹកក្នុងរយៈពេលវែង

ឯកសារណាមួយ ដែលត្រូវបានពង្រឹងពង្រីកនៅក្នុងលំនឹក តំរូវអោយយើងចងចាំវា ទៅតាមរបៀបមួយដ៏សមរម្យ។ ការចងចាំនេះទាមទារនូវរយៈពេលខ្លះដែលគេហៅថា រយៈពេលនៃការពង្រឹងពង្រីកផ្លាកស្នាម។ ប្រសិនណាជារយៈពេលនេះខ្លី ហើយជាផលវិបាកទៅវិញនោះ ផ្លាកស្នាមនៃព័ត៌មាននេះត្រូវបានរក្សាទុកក្នុងរយៈពេលដ៏ខ្លីផងដែរ នោះគេហៅថា លំនឹកក្នុងរយៈពេលដ៏ខ្លី។ លំនឹកក្នុងរយៈពេលដ៏ខ្លី ត្រូវបានគេយកមកប្រើប្រាស់នៅក្នុងករណី ដែលគេត្រូវធ្វើអោយបានសំរេចនូវអំពើទាំងឡាយ ប្រមាណវិធីដ៏ឆាប់រហ័សដែលត្រូវការរយៈពេលខ្លី។ កាលណាអំពើ និង ប្រមាណវិធីទាំងនេះត្រូវបានគេអនុវត្តសំរេចហើយ លំនឹកនេះនឹងក្លាយទៅជាលំនឹកមិនចាំបាច់ទៅវិញ។ ហេតុដូច្នេះហើយបានជាគេហៅលំនឹកនេះម្យ៉ាងទៀតថាជា លំនឹកនៃប្រមាណវិធី។ ប្រសិនណាជាពេលវេលា ពង្រឹងពង្រីកស្នាមគំនូសត្រូវការរយៈពេលយូរបន្ទាប់ពីមានប្រមាណវិធី និង ការអនុវត្តជាច្រើនដង ហើយផ្ទុយទៅវិញស្នាមគំនូសទាំងនោះត្រូវបានរក្សាទុកក្នុង រយៈពេលយូរ នោះគេនឹងមានលំនឹកក្នុង រយៈពេលវែង។

លំនឹកទាំងពីរប្រភេទនេះ ទទួលនូវតួនាទីដ៏សំខាន់នៅក្នុងជីវភាពរស់នៅ និង ក្នុងសកម្មភាពរបស់មនុស្សយើងម្នាក់ៗ ។ កំរិតដ៏សំខាន់ចំពោះលំនឹកនីមួយៗ អាស្រ័យដោយភារកិច្ច និងតំរូវការដាក់ស្តែងក្នុង សកម្មភាពនីមួយៗរបស់មនុស្សយើងម្នាក់ៗ ។

### ង - លំនឹករបស់ចក្ខុវិញ្ញាណ លំនឹករបស់សោតវិញ្ញាណ លំនឹកចលករ

ដោយឈរលើមូលដ្ឋាននៃតួនាទីដ៏សំខាន់របស់សរីរាង្គវិភាគរបស់លំនឹក គេអាចបែងចែកជាៈ លំនឹក របស់ចក្ខុវិញ្ញាណ ដែលមានភ្នែករបស់យើងសំរាប់ទទួលបន្ទុកនូវតួនាទីដ៏សំខាន់ លំនឹករបស់សោតវិញ្ញាណ ដែលមានត្រចៀកជាអ្នកដើរតួដ៏សំខាន់ លំនឹកចលករ ដែលមានឥន្ទ្រីយារម្មណ៍ចលករ ជាអ្នកបំពេញតួនាទីក្នុងករណីនេះ។ ក្នុងចំណោមមនុស្សយើងម្នាក់ៗតែងតែមានការលំអៀង ទៅលើលំនឹកណាមួយក្នុងចំណោមលំនឹកទាំងបីដូចបានរៀបរាប់មកនេះ។ នេះគឺជាចរិតរបស់បុគ្គលម្នាក់ៗចំពោះលំនឹក។ នៅពេលហ្វឹកហ្វឺនលំនឹក យើងគប្បីយកចិត្តទុកដាក់អោយបានជិតដល់ចរិតរបស់មនុស្សម្នាក់ៗ ។

### ៣ - តួនាទីរបស់លំនឹក

លំនឹកដើរតួនាទីមួយយ៉ាងសំខាន់ណាស់ នៅក្នុងជីវភាពរស់នៅរបស់មនុស្ស។ បើគ្មានលំនឹកនោះ មនុស្សយើងក៏គ្មានបទពិសោធន៍ដែរ។ ហើយបើគ្មានបទពិសោធន៍សោះ នោះក៏គេមិនអាចធ្វើសកម្មភាព បាន ឡើយ។

លោក LM Setchénov បានមានប្រសាសន៍តាមរបៀបកំប្លែង ប៉ុន្តែជាសំដីដែលនិយាយយ៉ាង ត្រឹមត្រូវថា បើមនុស្សយើងគ្មានលំនឹកទេនោះ ជានិច្ចជាកាលគេនឹងរស់នៅប្រៀបដូចទារក។

យើងនឹងជួបប្រទះនូវភាពកង្វល់ខុសពីប្រក្រតី ចំពោះជីវភាពរស់នៅរបស់អ្នកឯណាដែលបាត់បង់ ឬ ខូចបង់នូវលំនឹករបស់ខ្លួនដូចជា គេភ្លេចឈ្មោះ និង អាយុរបស់គេ។ គេលែងដឹងបានថា តើខ្លួនគេស្ថិត នៅទីណានោះ។ ទាំងនេះសអោយឃើញថា បើគ្មានបទពិសោធន៍ដែលគេអាចប្រមូលផ្តុំបាននោះទេ ជីវិត របស់មនុស្សនឹងជួបសេចក្តីកង្វល់ជាមិនខាន ហើយមនុស្សនោះនឹងលែងមានបុគ្គលិកលក្ខណៈជាមនុស្ស ទៀត ឡើយ។

ក្នុងឋានៈជាលក្ខខណ្ឌមួយក្នុងការប្រែក្លាយ ចំណេះដឹងឥន្រ្ទីយ៍អោយទៅជាចំណេះដឹងវិចារណ៍ ហើយជាផ្នែកមួយដែលស្ថិតនៅក្នុងសមាសភាពរបស់បុគ្គលិកលក្ខណៈ លំនឹកបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងជីវិតផ្លូវចិត្តរបស់មនុស្សយើងម្នាក់ៗ ។ បណ្តុះបណ្តាលលំនឹកអោយដល់សិស្សានុសិស្ស ហើយនឹង ហ្វឹកហ្វឺនសិស្សអោយមានលំនឹកដ៏ល្អ គឺជាភារកិច្ចមួយដ៏សំខាន់របស់គ្រូបង្រៀន។ ការហ្វឹកហ្វឺន និង ការ អភិវឌ្ឍន៍នៃគំនិតច្នៃប្រឌិតចំពោះសិស្សានុសិស្សមិនអាចកាត់ផ្តាច់បានពីការហ្វឹកហ្វឺន និង ការអភិវឌ្ឍន៍នៃ លំនឹកបានឡើយ។ ដោយហេតុថា គ្មានសកម្មភាពស្មារតីណាមួយដែលពឹងផ្អែកលើចំណេះដឹងជាក់ស្តែង បានឡើយ។ មនុស្សយើងម្នាក់ៗ អាចក្លាយទៅជាបញ្ញវន្តទទួលការអប់រំដ៏ល្អប្រពៃបាន លុះត្រាតែគេអាច ធ្វើ អោយលំនឹករបស់គេទៅលើចំណេះដឹងរបស់មនុស្សជាតិ ដែលអ្នកប្រាជ្ញបានចងក្រងទុកសំបូរបែប ឡើងក្នុងស្មារតីរបស់គេបាន។

### II - ចលនាការរបស់លំនឹក

ក្នុងបច្ចុប្បន្នកាលនេះ បញ្ហាដែលទាក់ទាញចិត្តមនុស្សអោយមានការយកចិត្តទុកដាក់ខ្លាំងជាងគេ នៅក្នុងស្នាដៃស្រាវជ្រាវទៅលើលំនឹកនោះ គឺចលនាការរបស់វា។ រហូតមកដល់សព្វថ្ងៃនេះ គេមិនឃើញ មានទ្រឹស្តីណាមួយដែលឈានដល់ដំណោះស្រាយ អោយបានឯកភាពគ្នាទៅតាមគោលការណ៍ដ៏ត្រឹមត្រូវ ច្បាស់ លាស់លើបញ្ហានេះឡើយ។

តាមលក្ខណៈទូទៅ គេអាចលើកឡើងនូវទស្សនៈខ្លះនៅក្នុងការស្រាវជ្រាវអំពីលំនឹក ទៅតាម ទិដ្ឋភាពទាំងឡាយដូចជា: ទិដ្ឋភាពចិត្តសាស្ត្រ ទិដ្ឋភាពកោសិកាសរីរៈសាស្ត្រ ទិដ្ឋភាពរូបជីវសាស្ត្រ និង ទិដ្ឋភាពជីវគីមី។ ចំពោះផែនការចិត្តសាស្ត្រ ទ្រឹស្តីចំណុចរួមនៃរូបតំណាង និង បញ្ញត្តិរបស់លំនឹកនេះ កើត មានតាំងពីយូរយារណាស់មកហើយ។ សញ្ញាណជាស្នូលនៃទ្រឹស្តីនេះ គឺជាសញ្ញាទ្រឹស្តីចំណុចរួមនៃរូប

តំណាង និង បញ្ញត្តិ ហៅថា បណ្តុំ ពេលគឺការផ្សារភ្ជាប់គ្នា និង ការឯកភាពគ្នា ហើយសញ្ញាណនេះត្រូវបានគេចាត់ទុកថា ជាគោលការណ៍ សំរាប់បកស្រាយពន្យល់បំភ្លឺលើរាល់ការបណ្តុះបណ្តាលខាងផ្លូវចិត្ត របស់ មនុស្ស។ ខ្លឹមសារនៃគោលការណ៍នេះ មានដូចតទៅនេះ : " ប្រសិនណាជាការបណ្តុះបណ្តាលផ្លូវចិត្ត ទៅតាមកម្មវិធីកំណត់ត្រូវបានប្រព្រឹត្តទៅក្នុងពេលដំណាលគ្នា ឬក៏បន្តបន្ទាប់គ្នានៅក្នុងមនសិការរបស់មនុស្ស នោះខ្លឹមសារនៃការបណ្តុះបណ្តាលនោះ នឹងមានការផ្សារភ្ជាប់គ្នាឆ្ពោះទៅរកគោលបំណងរួមមួយ។ ហើយការលេចធ្លោឡើងវិញនៃផ្នែកណាមួយ របស់សមាសភាពនៃការផ្សារភ្ជាប់គ្នានេះ ប្រាកដជាបង្កបង្កើតអោយមានរូបតំណាងរបស់ផ្នែកសមាសភាពទាំងអស់ ដែលនៅសល់ក្នុងមនសិការរបស់មនុស្ស។ " អ្នកប្រាជ្ញខាងទ្រឹស្តីឯកភាពគ្នាក្នុងសញ្ញាណនេះ យល់ឃើញថា លក្ខខណ្ឌដ៏ចាំបាច់ហើយគ្រប់គ្រាន់ សំរាប់បង្កើតឡើងនូវទំនាក់ទំនងគ្នារវាងផលពីរដែលកើតមាននៅក្នុងចិត្តមនុស្ស គឺការកើតមានដំណាលគ្នានៃការលេចធ្លោឡើងនូវផលនៃសញ្ញាណនេះក្នុងមនសិការរបស់មនុស្ស។ អ្នកប្រាជ្ញខាងទ្រឹស្តីនេះ បានគ្រាន់តែតំរង់ទិសទៅរកការស្រាវជ្រាវចំពោះលក្ខណៈនៃលក្ខខណ្ឌ ដែលកើតមានខាងក្រៅខ្លួនមនុស្ស ជាចាំបាច់សំរាប់ការបណ្តុះ បណ្តាល ផលទាំងឡាយដែលកើតមានដំណាលគ្នាក្នុងចិត្តរបស់មនុស្ស។ តាមគំនិតអ្នកប្រាជ្ញអស់ទាំងនោះ លក្ខខណ្ឌទាំងអស់អាចបែងចែកជាបីប្រភេទ គឺៈ

- ការយល់ដឹងបានទៅតាមទស្សនៈនៃលំហ និង ពេលវេលារវាងវត្ថុទាំងឡាយ។
- ភាពស្រដៀងគ្នារវាងវត្ថុ និង វត្ថុ។
- ភាពខុសប្លែកគ្នា ឬ ភាពផ្ទុយគ្នារវាងវត្ថុទាំងឡាយ។

ក្នុងហេតុការណ៍នេះ មានការផ្សារភ្ជាប់គ្នាទៅរកគោលបំណងរួម បី ប្រភេទ គឺៈ

- ចំណុចរួមនៃរូបតំណាង និង បញ្ញត្តិ : តាមរយៈការយល់ដឹង
- ចំណុចរួមនៃរូបតំណាង និង បញ្ញត្តិ : តាមរយៈភាពស្រដៀងគ្នា
- ចំណុចរួមនៃរូបតំណាង និង បញ្ញត្តិ : តាមរយៈភាពផ្ទុយគ្នា។

ទ្រឹស្តីដែលមានភាពផ្ទុយគ្នាយ៉ាងម៉ឺងម៉ាត់ឆ្ពោះទៅរកទ្រឹស្តីចំណុចរួមនៃរូបតំណាង និង បញ្ញត្តិ គឺទ្រឹស្តីនៃរូបភាពរបស់លំនឹក។ សញ្ញាណដ៏សំខាន់របស់ទ្រឹស្តីនេះ គឺជាសញ្ញាណនៃទំរង់ ដែលតាមភាសា អាល្លឺម៉ង់មានន័យថា រចនាសម្ព័ន្ធដ៏គ្រប់គ្រាន់ ហើយដែលមានន័យថា មិនមែនជាការបន្ថែមទៅផ្នែកនៃសមាសភាគណាមួយឡើយ។ គោលការណ៍ដ៏សំខាន់របស់ទ្រឹស្តីនេះ គឺការធ្វើសំយោគទៅលើធាតុ និង ភាពនៃវត្ថុដែលឥតមានរខិតបន្តិចសោះ។ ក៏ប៉ុន្តែក៏ដូចជាទ្រឹស្តីចំណុចរួមនៃរូបតំណាង និង បញ្ញត្តិដែរ ទ្រឹស្តីរូបភាពរបស់លំនឹកឆ្លងកាត់ផ្សេងគ្នាពីសកម្មភាពរបស់សាម៉ីជនតែម្តង។

ដោយផ្ទុយគ្នាស្រឡះពីការផ្សារភ្ជាប់គ្នាទៅរកគោលបំណងរួម និង ទ្រឹស្តីផ្សេងទៀត (ចំពោះអ្នកឯណាដែលចាត់ទុកមនសិការ ជាវត្ថុមានលក្ខណៈអវិជ្ជមាន និង អសកម្ម) និន្នាការជាច្រើនផ្សេងទៀតនៅក្នុងចិត្តវិទ្យា ចង់និយាយទទូចអះអាងទៅលើលក្ខណៈសកម្មរបស់មនសិការនៅក្នុងលំនាំរបស់លំនឹក។ ប៉ុន្តែនិន្នាការទាំងនេះ បានចាត់ទុកលក្ខណៈនេះថា ជាលក្ខណៈសកម្មដ៏សុទ្ធសាធរបស់មនសិការទៅវិញ ហើយនេះជាហេតុនាំអោយ គ្មានទំនាក់ទំនងជាមួយសកម្មភាពរបស់មនុស្ស។

លុះដល់មករយៈពេលយូរមកទៀត ពពួកមនោនិយមទាំងឡាយដូចជាលោក Bergson ជាអាទិ៍បាន ញែកដាច់ទំនាក់ទំនងនេះ ជាពីរប្រភេទ គឺការផ្សារភ្ជាប់គ្នានៃចំណុចរួមរបស់រូបតំណាង និង បញ្ញត្តិ និង ការផ្សារភ្ជាប់គ្នាតាមអត្ថន័យ។ យោលទៅតាមហេតុការណ៍នេះមានលំនឹកពីរយ៉ាង គឺលំនឹកចលនាការ ជាប្រភេទលំនឹកទៅលើរូបធាតុ និង លំនឹកដ៏សមហេតុផល ជាប្រភេទនៃលំនឹកទៅលើព្រលឹងដាច់ខាត លំនឹកនេះមិនអាស្រ័យដោយរូបធាតុទេ។

ចិត្តវិទ្យាទំនើបទទួលយល់ព្រមតាមទ្រឹស្តីដែលអះអាងថា សញ្ញាណដ៏សំខាន់របស់ចិត្តវិទ្យាត្រូវបានចាត់ទុកថាជាសញ្ញាណនៃសកម្មភាពរបស់បុគ្គលម្នាក់ៗ ក្នុងឋានៈជាកត្តាកំណត់ក្នុងការបណ្តុះបណ្តាលលើគ្រប់លំនាំផ្លូវចិត្តទាំងអស់របស់មនុស្សដោយរាប់បញ្ចូលទាំងលំនាំរបស់លំនឹកផង។ និក្ខេបបទដ៏មានអត្ថន័យរបស់ទ្រឹស្តីនេះ គឺថាការបណ្តុះបណ្តាលទំនាក់ទំនង រវាងរូបតំណាងផ្សេងគ្នាពីរនោះត្រូវបានកំណត់ច្បាស់ដោយមិនអាស្រ័យទៅលើឯកសារជារឿងសំខាន់នោះទេ ហើយសំខាន់បំផុតនោះ គឺថា អ្វីៗដែលសាម៉ីជន (មនុស្ស) ប្រាថ្នា ធ្វើអោយឯកសារនេះទៅជាយ៉ាងណានោះទៅវិញទេ។

ដោយសំអាងទៅលើកំរិតនៃកោសិកាសរីរៈ កោសិកានៃកាយវិភាគ កោសិកាអគ្គីសនីជីវៈ និង កោសិកាជីវៈគីមី ជាបឋមនោះ គេគប្បីនិយាយដល់ទ្រឹស្តីរ៉េផ្លិចមានលក្ខខណ្ឌរបស់លោក I.P Pavlov :

យោលទៅតាមទ្រឹស្តីនេះ លំនឹកគឺជាលំនាំនៃការបណ្តុះបណ្តាល ការពង្រឹងពង្រីក និង ការបង្កើតឡើងវិញបាននូវទំនាក់ទំនងសរសៃប្រសាទមួយរយៈកាលនៅលើសំបកខួរក្បាល។

ទំនាក់ទំនងសរសៃប្រសាទមួយរយៈកាល គឺជាបាតុភូតសរីរៈដែលគេយល់ដឹងច្រើនជាងគេក្នុងពិភពសត្វ និង ពិភពមនុស្សយើង។ ទំនាក់ទំនងនេះ ក៏គឺជាបាតុភូតផ្លូវចិត្តមួយទៀតដែរ ដែលចិត្តវិទូបានហៅថា ចំណុចរួមនៃរូបតំណាង និង បញ្ញត្តិ។ លុះដល់ពេលក្រោយមកទៀត សិស្សរបស់លោក I.P Pavlov ដូចជាលោក P.K Anokhin បានបន្ថែមគំនិតសំខាន់ៗក្នុងបញ្ហានេះទៀត ដូចជា សញ្ញាណកងរ៉េផ្លិច ទំនាក់ទំនងបញ្ច្រាស ។ល។

ក្នុងពេលថ្មីៗកន្លងទៅនេះចិត្តវិទ្យាទំនើបបានធ្វើសម្បទានយ៉ាងសំខាន់ ដោយចាប់ផ្តើមបកស្រាយបំភ្លឺពីចលនាការជាក់ស្តែងរបស់លំនឹក។ គេអាចសង្ខេបបានទៅលើទ្រឹស្តីទំនើបស្តីពីចលនារបស់លំនឹកជា ទស្សនៈខ្លះ ដូចតទៅ:

1- នៅក្នុងមជ្ឈមណ្ឌលនៃប្រព័ន្ធប្រសាទមានចំណុចភ្ជាប់ណឺរ៉ូនមួយចំនួនធំ។ ប៉ុន្តែចំណុចភ្ជាប់ណឺរ៉ូនទាំងនោះមិនចូលរួមគ្រប់សកម្មភាពទេ។ ចំនួននៃចំណុចភ្ជាប់ណឺរ៉ូនដែលចូលរួមក្នុងសកម្មភាពកើនឡើងទៅតាមកំរិតនៃការសិក្សា និង ភាពផ្សេងគ្នារបស់លំនឹក។ លក្ខណៈបែបនេះបង្កអោយមានភាពងាយស្រួលដល់ការប្រែក្លាយរំញោចដោយឆ្លងកាត់ចំណុចភ្ជាប់ណឺរ៉ូនទាំងនោះ។ ដូច្នេះមូលដ្ឋានសរីរៈវិទ្យារបស់លំនឹក ហើយនិងការសិក្សា គឺជាការកេណ្ឌប្រមូល ចំណុចភ្ជាប់ណឺរ៉ូនដែលមានទ្រង់ទ្រាយកាន់តែធំឡើងអោយចូលរួមក្នុងសកម្មភាព។
2- នៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធប្រសាទមានវង្វង់ជាច្រើន ដែលចែកចេញជាជួរណឺរ៉ូនជាប់ៗគ្នា។

ណឺរ៉ូន មួយដែលកំពុងធ្វើសកម្មភាព នឹងជះឥទ្ធិពលរំញោចទៅលើណឺរ៉ូនមួយទៀត ហើយចំណុចសាយចេញនៃរំញោច ដែលបញ្ជូនមកក្នុងជួរណឺរ៉ូននេះ នឹងធ្វើសកម្មភាពសារជាថ្មីទៅលើណឺរ៉ូនទី១វិញ។

3- ដោយចូលទៅក្នុងមជ្ឈមណ្ឌលប្រព័ន្ធប្រសាទ និង អាស្រ័យដោយស្ថានភាពជាក់ស្តែង ការជំរុញនៃ សរសៃប្រសាទ នឹងធ្វើអោយកើតមានរំញោចទៅលើកោសិកាជាកំណត់នៅលើសំបកខួរក្បាល។ ប្រសិនណាជាការធ្វើអោយមានរំញោចនោះមិនបានកើតឡើងផ្ទួនៗទេនោះ ចំណុចនៃរំញោចខាងក្នុង ក៏មិនដំណើរការដែរ ហើយវាមិនបានបន្សល់ទុកនូវស្នាមគំនូសណាមួយនៅលើណឺរ៉ូនឡើយ។ ករណីនេះគឺជាចលនាការរបស់លំនឹកក្នុងរយៈពេលខ្លី។ ប្រសិនណាជារំញោចកើតមានជាច្រើនដងពិតប្រាកដនោះ គេនឹងឃើញមានកើតឡើងនៅលើសំបកខួរក្បាល និង ត្រង់ផ្នែកភ្ជាប់នៃសំបកខួរក្បាលនេះ នូវអ្វីម្យ៉ាងនោះ ដែលលោក Hebb បានហៅថា ជាចំណុចរួមនៃរូបតំណាង និង បញ្ញត្តិរបស់កោសិកា ដែលកំពុងមានដំណើរការដូចគ្នានឹងជួរចំណាំង។ ប្រសិនណាជា រំញោចនេះចេះតែបន្តបញ្ជូនទៅអោយ ណឺរ៉ូននេះតទៅទៀត កំណើននៃរចនាសម្ព័ន្ធរបស់សរសៃប្រសាទកាន់តែកើតមានខ្លាំងឡើងនៅក្នុងជួរចំណាំង នេះជាហេតុធ្វើអោយចុងសរសៃប្រសាទរបស់ណឺរ៉ូនប៉ោងឡើង។ ចំណុចរួមរបស់កោសិកា ដែលកើតមានឡើងនៅលើសំបកខួរក្បាល និង ផ្នែកភ្ជាប់នៃសំបកខួរក្បាលគួបផ្សំជាមួយនឹងបន្លាស់ប្តូររចនាសម្ព័ន្ធនៃសរសៃប្រសាទនេះ គឺជាមូលដ្ឋានរបស់លំនឹកក្នុង រយៈពេលវែង។

4- នៅក្នុងលំនាំនៃការសិក្សា គេនឹងឃើញមានបន្លាស់ប្តូរអណ្តូជាច្រើនសណ្ឋាន នៅក្នុងណឺរ៉ូនទាំងឡាយ ដោយឡែកគឺបន្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធនៃជាតិជូរក្នុងកោសិកា។ ជាតិជូរនេះគឺជាគំរូលំនាំ សំរាប់ធ្វើវិភាគទៅលើអណ្តូជាច្រើនសណ្ឋាន។ ដូច្នេះហើយបានជាអណ្តូដែលមានជាតិអាស៊ីតផូស្វ័រក្នុងកោសិកា ដែលត្រូវបានជិតដាមទៅតាមគំរូ ដែលមានរួចមកហើយនោះ នឹងកាន់តែមានគុណភាពថ្មីច្រើនជាង អណ្តូដែលផ្គត់ផ្គង់អោយតាមរយៈលំនឹក។ ដូច្នេះដើម្បីចងចាំនូវព័ត៌មានថ្មីៗ វាតំរូវអោយមានការថតពុម្ពទៅលើអណ្តូនៃជាតិជូរក្នុងកោសិកា ដែលទទួលបន្ទុកនៃភារកិច្ចចងចាំព័ត៌មាន និង រក្សាទុកព័ត៌មាន ដែលទទួលបានពីមុនៗផង។

នាពេលថ្មីៗកន្លងទៅនេះ នៅពេលដែលធ្វើការសិក្សាស្រាវជ្រាវអំពីចលនាការរបស់លំនឹក គេបានយកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះអ្វីដែលគេហៅថា "សំណុំសរីរាង្គដែលបង្កអោយមានឥន្ទ្រីយារម្មណ៍ក្នុងមនសិការ"។ សំណុំសរីរាង្គនេះមានទំនាក់ទំនងជាមួយនឹងដំណាក់កាលទីមួយនៃជីវិតរបស់មនុស្ស។

រំញោចខ្លះដែលកើតមានខាងក្រៅខ្លួនជាលើកដំបូងត្រូវបានសរីរាង្គទទួលដឹង ហើយត្រូវបានពង្រឹងទុកក្នុងរយៈពេលដ៏យូរបង្គួរ។ ដោយសារការពិសោធន៍ដែលធ្វើឡើងមកលើសត្វស្វា គេបានរកឃើញថា សំណុំសរីរាង្គដែលបង្កអោយមានឥន្ទ្រីយារម្មណ៍ក្នុងមនសិការ ជាលើកដំបូងបង្អស់នៃជីវិតរស់នៅមានអត្ថន័យយ៉ាងធំធេង ចំពោះការអភិវឌ្ឍន៍របស់ខ្លួនសត្វទៅថ្ងៃអនាគត។

## III - លំនាំរបស់លំនឹក និង ច្បាប់របស់វា

លំនឹករបស់មនុស្សយើងគឺជាសកម្មភាពមួយ ដែលមានលក្ខណៈសកម្មស្មុគស្មាញ ហើយដែលចែក ចេញជាលំនាំផ្សេងៗគ្នាដូចជាៈ លំនឹកកម្ម ការរក្សាទុកព័ត៌មាន ការនឹកឃើញព័ត៌មានឡើងវិញ ការបង្កើត ព័ត៌មានឡើងវិញ។

### ១ - លំនាំរបស់លំនឹកកម្ម

នេះគឺជាដំណាក់កាលទី១ របស់សកម្មភាពនៃការចាំទុកមិនអោយភ្លេចទៅតាមលក្ខណៈជាក់ស្តែង។ លំនឹកកម្មគឺជាលំនាំនៃការបណ្តុះបណ្តាលព័ត៌មានក្នុងស្មារតី ដែលជាផលនៃចំណាប់អារម្មណ៍ទៅលើវត្ថុ ឬ បាតុភូត ដែលយើងអាចទទួលដឹងបាន (ពោលគឺដូចជាឯកសារដែលត្រូវចងចាំ) នៅលើសំបកខួរក្បាល។ លំនឹកកម្មជាលំនាំនៃការបង្កើតបាននូវទំនាក់ទំនងគ្នារវាងព័ត៌មានថ្មី និង ព័ត៌មានចាស់ ក៏ដូចជាលំនឹកកម្មរវាងផ្នែកជាសមាសភាពរបស់ព័ត៌មានថ្មីដែរ។

តាមរយៈការសិក្សាស្រាវជ្រាវ គេឃើញមានប្រភេទនៃលំនឹកជាច្រើនៈ

#### ក - លំនឹកកម្មអឆន្ទៈ និង លំនឹកកម្មឆន្ទៈ

លំនឹកកម្មឆន្ទៈ គឺជាលំនឹកកម្មដែលប្រព្រឹត្តទៅដោយមិនចាំបាច់ត្រូវការកំណត់ជាមុន នូវគោលបំណងធ្វើអោយមានលំនឹកឡើយ។ លំនឹកកម្មនេះមិនទាមទារអោយមានការខិតខំប្រឹងប្រែងខាងផ្លូវឆន្ទៈឡើយ។ លំនឹកកម្មនេះ ហាក់ដូចជាប្រព្រឹត្តទៅតាមលក្ខណៈធម្មជាតិរបស់វា។ ប៉ុន្តែបែបបទនៃការមានលំនឹកតាមលក្ខណៈអឆន្ទៈទៅលើព្រឹត្តិការណ៍ និង បាតុភូតនៃតថភាពដែលនៅជុំវិញខ្លួនយើងមិនមែនចេះតែដូចគ្នារហូតនោះទេ។ ដំបូងបង្អស់ស្ថេរភាពនៃរយៈពេលរបស់លំនឹកកម្មអឆន្ទៈ អាស្រ័យដោយពណ៌សម្បុរ ការផ្លាស់ប្តូរទីកន្លែង និង លក្ខណៈផ្សេងទៀតរបស់វត្ថុ។ លំនឹកកម្មអឆន្ទៈទទួលបាននូវលទ្ធផលល្អកាលណាវាផ្សារភ្ជាប់ទៅនឹងចិត្តរំភើប ដែលមានលក្ខណៈជាការពិនិត្យសង្កេត ហើយមានសភាពខ្លាំងក្លា។

ចំណង់ចំណូលចិត្តរបស់មនុស្សបំពេញតួនាទីមួយយ៉ាងសំខាន់ចំពោះលំនឹកអឆន្ទៈ។ លំនឹកអឆន្ទៈមានអត្ថន័យមួយយ៉ាងសំខាន់នៅក្នុងជីវភាពរស់នៅរបស់មនុស្ស។ លំនឹកអឆន្ទៈបើកទូលាយ និង ធ្វើអោយសំបូរបែបនូវអត្ថរសនៃជីវភាពរស់នៅ ដោយមិនទាមទារអោយមានការខិតខំប្រឹងប្រែងដ៏តិចតួចឡើយ។

ស្នាដៃស្រាវជ្រាវរបស់ចិត្ត-គរុកោសល្យបានស្រាយបំភ្លឺថា បើគ្រូបង្រៀនសំណូមពរអោយសិស្សមាន លំនឹកយ៉ាងឆាប់រហ័សពេកទៅលើឯកសារសិក្សា នោះច្បាស់ជាឥទ្ធិពលបរាជ័យកើតមានឡើងមកលើការយល់ដឹងទៅលើឯកសារសិក្សា ពីព្រោះនៅក្នុងករណីនេះភារកិច្ចដ៏សំខាន់របស់សិស្ស គឺត្រូវត្រិះរិះពិចារណាទៅលើឯកសារសិក្សាថ្មី រីឯលំនឹកកម្មទៅលើឯកសារទាំងនេះ នឹងប្រព្រឹត្តទៅតាមលក្ខណៈ អឆន្ទៈនៅពេលដែលលំនាំនៃការត្រិះរិះពិចារណានេះប្រព្រឹត្តទៅតែម្តង។

ស្នាដៃសិក្សាស្រាវជ្រាវរបស់ចិត្តវិទូ A.A Sonirnov និង P.L Zinchenko បានជួយសំរួលអោយយើងយល់ដឹងបានថា អ្វីៗដែលមានទំនាក់ទំនងជាមួយនឹងគោលដៅនៃសកម្មភាព ឬជាមួយនឹងខ្លឹមសារដ៏សំខាន់នៃសកម្មភាពនឹងត្រូវបានយកមករំលឹកឡើងវិញតាមរបៀបអធន្ទៈ។

លំនឹកកម្មធន្ទៈជាលំនឹកម្យ៉ាងដែលប្រព្រឹត្តទៅដោយយោលទៅតាមគោលដៅ ដែលបានកំណត់ទុកពីមុន ពោលគឺគេបានផ្តល់អោយដល់ខ្លួនគេនូវភារកិច្ចក្នុងការរំលឹកឡើងវិញទៅលើឯកសារសិក្សាមួយ។ ចំពោះលំនឹកធន្ទៈ មនុស្សយើងត្រូវមានការខិតខំប្រឹងប្រែងតាមផ្លូវធន្ទៈដ៏ពិតប្រាកដ ដូចជាប្រមែប្រមូលស្មារតីខិតខំប្រឹងប្រែងសំដៅពង្រឹងពង្រីកអោយបានល្អប្រសើរទៅលើឯកសារដែលត្រូវរំលឹកឡើងវិញ ហើយទន្ទឹមនឹងនោះ គេត្រូវប្រើប្រាស់ល្បិចជាក់ស្តែង និង វិធីដ៏ពិតប្រាកដផងសំរាប់លំនឹកកម្មប្រភេទនេះ។ សកម្មភាពសិក្សារបស់សិស្ស និង សកម្មភាពបង្រៀនរបស់គ្រូ គប្បីពឹងផ្អែកជាសារវន្តទៅលើលំនឹកកម្មធន្ទៈនេះ។

### ខ - លំនឹកកម្មចលនាការ និង លំនឹកកម្មមានអត្ថន័យ

លំនឹកកម្មធន្ទៈប្រព្រឹត្តទៅតាមរយៈវិធីពីរយ៉ាងគឺៈ លំនឹកកម្មចលនាការ និង លំនឹកកម្មមានអត្ថន័យ។ លំនឹកកម្មចលនាការគឺជាលំនឹកកម្ម ដែលឈរលើមូលដ្ឋាននៃការថាឡើងវិញផ្ទួនៗដងដ៏សាមញ្ញតាមរយៈ ប្រត្យក្សារម្មណ៍នៃឯកសារសិក្សា។ ការស្តែងឡើងជាគំរូសំរាប់លំនឹកកម្មនេះចំពោះសិស្ស គឺជាទង្វើការងារយ៉ាងស្វាហាប់ក្នុងការសិក្សា ឬ ទន្ទេញឃ្លាប្រយោគដ៏ពិបាកយល់ អោយងាយចងចាំបាន។

លំនឹកកម្មចលនាការនឹងក្លាយទៅជាទម្លាប់របស់សិស្ស ប្រសិនណាជាគ្រូបង្រៀននៅតែទាមទារអោយសិស្សផ្តល់នូវចម្លើយទៅលើសំនួរមេរៀនតាមខ្លឹមសារអត្ថបទដកស្រង់ចេញពីសៀវភៅសិក្សា។ ជានិច្ចជាកាល វិធីចោទឡើងជាសំនួរដោយគ្រូបង្រៀននៅក្នុងថ្នាក់រៀន គឺសំដៅកំណត់វិធីរំលឹកមេរៀនឡើងវិញអោយដល់សិស្ស។ លំនឹកកម្មចលនាការបង្កបានយ៉ាងងាយនូវការយល់ជ្រួតជ្រាបទៅលើរូបភាពនៃចំណេះដឹង ដែលសិស្សបានសិក្សារួចមកហើយ។ ម្យ៉ាងវិញលំនឹកកម្មមិនមែនជាការសន្សំសំចៃពេលវេលាទេ។ លំនឹកកម្មទាមទារអោយមានពេលវេលាកាន់តែច្រើនឡើងថែមទៀត ដូចគ្នានឹងលំនឹកកម្មមានអត្ថន័យដែរ។ ក៏ប៉ុន្តែនៅក្នុងករណីបែបនេះ យើងត្រូវពឹងផ្អែកលើលំនឹកកម្មចលនាការ។ ឧទាហរណ៍ៈ ដូចជាគេត្រូវរំលឹកដល់លេខទូរស័ព្ទ កាលបរិច្ឆេទនៃ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ... ។ល។

លំនឹកកម្មមានអត្ថន័យគឺជាប្រភេទនៃលំនឹកកម្ម ដែលពឹងផ្អែកទៅលើការយល់ដឹងបានពីខ្លឹមសាររបស់ឯកសារ និងចំណេះដឹងនៃទំនាក់ទំនងដ៏សមហេតុផល រវាងផ្នែកនានាជាសមាសភាគរបស់ឯកសារ។ លំនឹកកម្មនេះ ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងលំនាំនៃការគិតរបស់មនុស្ស។ រូបភាពប្រកបដោយ លក្ខណៈពិសេសរបស់លំនឹកកម្មប្រភេទនេះ នៅក្នុងសកម្មភាពសិក្សារបស់សិស្ស ឬវិធីរំលឹកខ្លឹមសារឯកសារសិក្សា ដោយពឹងផ្អែកលើចំណុចសំខាន់ៗជាទីបង្អែក។

លំនឹកកម្មមានអត្ថន័យជាប្រភេទនៃលំនឹកកម្មម្យ៉ាងដ៏សំខាន់នៅក្នុងការសិក្សារបស់សិស្ស។ លំនឹកកម្មនេះ ទទួលបន្ទុកនូវការយល់ជ្រួតជ្រាបស៊ីជំរៅ និង ពង្រឹងពង្រីកបានទៅលើចំណេះដឹង ហើយក្នុង

ករណីដែលគេភ្លេចភ្លាំងចំណេះដឹងទាំងនោះ វាជាការងាយស្រួលបំផុតក្នុងការរំលឹកចំណេះដឹងនោះឡើងវិញបាន។ តាមធាតុពិត លំនឹកកម្មនេះទាមទារពេលវេលាដ៏តិចតួចទេ បើធៀបទៅនឹងលំនឹងកម្មចលនាការ ក៏ប៉ុន្តែវាត្រូវការថាមពលច្រើនជាងលំនឹកកម្មចលនាការទៀតផង។

### គ - ការរៀនអោយឆាប់ចេះ និង ការបង្កើតស្មារតីលំនឹកតាមរយៈលំហាត់

នៅក្នុងសកម្មភាពសិក្សា និង បង្រៀន ចំពោះករណីខ្លះ គេត្រូវទន្ទេញឯកសារសិក្សាអោយចាំ ស្ទាត់។

ឧទាហរណ៍ៈ រៀនអោយចាំស្ទាត់ចំពោះនិយមន័យ ច្បាប់ អត្ថបទ ... ។ល។ រៀនអោយឆាប់ចេះបានន័យថា ចេះគួបផ្សំគ្នាបានរវាងលំនឹកកម្មមានអត្ថន័យ និង លំនឹកកម្មចលនាការ ពោលគឺប្រើប្រាស់លំនឹកចលនាការដោយឈរលើមូលដ្ឋាននៃការយល់ដឹងបានទៅលើឯកសារ ដែលត្រូវរំលឹកចងចាំឡើងវិញ។

ការបង្កើនស្មារតីលំនឹកតាមរយៈលំហាត់ គឺជាលំនឹកកម្មធន្ទៈដែលគេបង្កើតឡើងបានតាមរយៈទំនាក់ទំនងខ្លឹមសារខុសឆ្គង រវាងទំនាក់ទំនងដ៏ត្រឹមត្រូវច្បាស់លាស់សំរាប់ការរំលឹកចងចាំ។ ឧទាហរណ៍ៈ គេចងក្រងពាក្យដាច់ដោយឡែក សំរាប់ចងចាំឃ្លា ឬ សរសេរឃ្លាដោយប្រើកំណាព្យមានចុងចួន ដើម្បីធ្វើអោយលំនឹកកម្ម មានភាពងាយស្រួល។ ដើម្បីចងចាំការសរសេរឃ្លាប្រយោគជាឯកវចនៈ និង ពហុវចនៈជាមួយពាក្យថា Tout ក្នុងភាសាបារាំងគេអាចរំលឹកបានយ៉ាងងាយថា Tout le → Tout " t " , Tous les → Tous " s " ។ ដើម្បីចងចាំ លេខក្នុងផ្នែកទសភាគ 3,1415926535 គេនឹកឃើញដល់ឃ្លាមួយ ដែលគ្មានទំនាក់ទំនងអ្វីជាមួយនឹងលេខទាំង នោះសោះ ប៉ុន្តែជាឃ្លាយ៉ាងល្អសំរាប់អោយយើងនឹកឃើញ $\pi$ = 3,1415926535 គឺឃ្លា : Que j'aime à faire connaître ce nombre utile aux sages ។

### ឃ - លំនឹកកម្មរយៈពេលខ្លី និង លំនឹកកម្មរយៈពេលវែង

កាលណាគេរំលឹកទៅលើឯកសារ ឬព័ត៌មានណាមួយ ទៅតាមភារកិច្ច ឬគោលបំណងផ្សេងៗគ្នានៃ លំនឹកកម្ម គេចាំបាច់ត្រូវតែរំលឹក ឬក៏គេត្រូវការប្រើប្រាស់ឯកសារនោះក្នុងរយៈពេលយូរអង្វែង ឬក៏គេត្រូវការ ដោះស្រាយបញ្ហាជាបន្ទាន់តែប៉ុណ្ណោះក្នុងរយៈពេលមួយដ៏យ៉ាងរហ័សបំផុត។ ដូច្នេះយើងឃើញថា ករណីទី១នេះ គឺគេត្រូវការប្រើលំនឹកកម្មរយៈពេលវែង រីឯករណីទី២ គឺលំនឹកកម្មរយៈពេលខ្លី។

### ង - លំនឹកកម្មដោយប្រើភ្នែក ដៃ និង ត្រចៀក

លំនឹកកម្មដោយប្រើភ្នែក គឺជាលំនឹកកម្មម្យ៉ាងដែលឈរលើមូលដ្ឋានរបស់ប្រត្យក្សារម្មណ៍នៃចក្ខុវិញ្ញាណ។ លំនឹកកម្មដោយប្រើដៃ គឺជាប្រភេទលំនឹកកម្មដែលឈរលើមូលដ្ឋាននៃចលនារបស់ដៃ រីឯលំនឹកកម្មដោយប្រើត្រចៀក គឺជាប្រភេទលំនឹកកម្ម ដែលយើងត្រូវពឹងផ្អែកលើប្រត្យក្សារម្មណ៍នៃសោតវិញ្ញាណ។

## ២ - លំនាំនៃការរក្សាព័ត៌មានទុក

ការរក្សាព័ត៌មានទុក គឺជាលំនាំនៃការពង្រឹងពង្រីកផ្លាកស្នាមព័ត៌មាន ដែលបានបណ្តុះបណ្តាលរួចមកហើយ នៅលើសំបកខួរក្បាលនៅពេលដែលមានលំនឹកកម្ម។ ការរក្សាព័ត៌មានទុកមានពីរប្រភេទគឺ ការរក្សាព័ត៌មានទុកតាមបែបអសកម្ម និង ការរក្សាព័ត៌មានទុកតាមបែបសកម្ម។ ការរក្សាព័ត៌មានទុកតាមបែបអសកម្ម គឺ ជាការរក្សាទុកដែលឈរលើមូលដ្ឋាននៃការថាឡើងវិញយ៉ាងសាមញ្ញ ហើយផ្ទួនៗដងតាមរយៈប្រត្យក្សារម្មណ៍នៃឯកសារ ចំណែកឯការរក្សាព័ត៌មានទុកតាមបែបសកម្មវិញ គឺជាការរក្សាទុកដែលធ្វើឡើងដោយមានការរំលឹកឡើងវិញទៅលើឯកសារ ដែលគេបានចងចាំរួចមកហើយ។ នៅក្នុងការសិក្សាគេហៅ លំនឹកកម្មនេះថា ការសិក្សាសារឡើងវិញយ៉ាងសកម្ម និង ការថាឡើងវិញផ្ទួនៗយ៉ាងសកម្ម។

## ៣ - ការនឹកឃើញព័ត៌មានឡើងវិញ និង ការបង្កើតព័ត៌មានឡើងវិញ

លទ្ធផលរបស់លំនាំនៃលំនឹកកម្ម និង ការរក្សាទុកព័ត៌មាន ត្រូវបានស្តែងចេញអោយឃើញនៅក្នុងលំនាំនៃការនឹកឃើញព័ត៌មានឡើងវិញ និង ការបង្កើតព័ត៌មានឡើងវិញ។

ការនឹកឃើញព័ត៌មានឡើងវិញ គឺជាការរំលឹកឡើងវិញទៅលើវត្ថុណាមួយ កាលណាគេមានអារម្មណ៍មួយទទួលដឹងទៅលើវត្ថុនោះសារជាថ្មី។ ការនឹកឃើញព័ត៌មានឡើងវិញប្រព្រឹត្តទៅបាន លុះណាតែវត្ថុដែលគេកំពុងតែមានអារម្មណ៍ទទួលដឹងទៅលើវា នោះស្រដៀងគ្នានឹងវត្ថុដែលគេមានអារម្មណ៍ទៅលើវាកាលពីពេលមុន។ កាលណាគេមានអារម្មណ៍សារជាថ្មី វត្ថុដែលគេធ្លាប់ឃើញវាពីមុននោះ ផុសចេញយ៉ាងទន់ហន់នូវឥន្ទ្រីយារម្មណ៍មួយដោយឡែកហើយយ៉ាងស្និទ្ធស្នាលផង។ នេះគឺជាឥន្ទ្រីយារម្មណ៍ដែលជាមូលដ្ឋាននៃការនឹកឃើញ ព័ត៌មានឡើងវិញ។

ការបង្កើតព័ត៌មានឡើងវិញ ខុសប្លែកគ្នាពីការនឹកឃើញព័ត៌មានឡើងវិញនៅត្រង់ចំណុចដែលថាៈ រូបភាពដែលត្រូវបានរក្សាទុកពីមុនរួចមកហើយនៅក្នុងលំនឹកនោះ មានជីវិតរស់ឡើងវិញ ដោយម្ចាស់ខ្លួនមិនបាច់ទទួលដឹងអារម្មណ៍សារជាថ្មីទៅលើវត្ថុដែលផ្តល់រូបភាពនេះនៅក្នុងខួរក្បាលឡើយ។

ការនឹកឃើញព័ត៌មានឡើងវិញ និង ការបង្កើតព័ត៌មានឡើងវិញអាចមានលក្ខណៈជាឆន្ទៈ ឬ អឆន្ទៈ។

ការបង្កើតព័ត៌មានឡើងវិញដោយឆន្ទៈ ទាមទារនូវការខិតខំប្រឹងប្រែងខាងផ្នែកឆន្ទៈ ហើយដែលទាមទារនូវភាពជំនះបានទៅលើការលំបាក ហៅថា ការរំលឹកព័ត៌មានឡើងវិញ។ ការបង្កើតរូបភាព ឬព័ត៌មានចាស់ៗឡើងវិញ ដែលត្រូវស្ថិតនៅក្នុងលំហមួយ និង រយៈពេលមួយជាក់ណាត់នោះ គេហៅថា ការនឹកឃើញព័ត៌មាន ឬ រូបភាពឡើងវិញក្រោយពេលដែលភ្លេចវា។ នៅក្នុងការនឹកឃើញព័ត៌មាន ឬ រូបភាពឡើងវិញ ក្រោយពេលដែលភ្លេចវានោះ មិនគ្រាន់តែធ្វើអោយយើងរំលឹកបានដោយខ្លួនយើងទៅលើព័ត៌មាន ឬ រូបភាពពីអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជួយយើងអោយកំណត់បានថែមទៀតទៅលើរូបភាពរបស់វានៅក្នុងរយៈពេលមួយជាក់ណាត់ ឬ ទីកន្លែងណាមួយជាក់ស្តែង។

## ៤ - គំរិតនៃលំនឹក ការភ្លេចភ្លាំង និង របៀបប្រយុទ្ធប្រឆាំងនឹងការភ្លេចភ្លាំង

លំនឹកកម្ម និង ការរក្សាព័ត៌មានទុកផ្តល់អោយយើងនូវលទ្ធផលផ្សេងៗពីគ្នា ពិសេសណាស់ទៅទៀត លំនឹករបស់មនុស្សយើងមានអត្ថិភាពទៅតាមកំរិតខុសប្លែកពីគ្នា។ ក្នុងន័យនេះគេចែកលំនឹកជា បី កំរិតៈ

ក- លំនឹកក្នុងន័យបង្កើតព័ត៌មានឡើងវិញ

ខ- លំនឹកក្នុងន័យរំលឹកព័ត៌មានឡើងវិញ

គ- លំនឹកក្នុងន័យបង្កលក្ខណៈងាយស្រួល

តាមជាតុពិត រវាងលំនឹកទាំងបីកំរិតនេះ នៅមានលំនឹកជាខ្សែរយៈ ឬ ជាស្ពានចម្លងអោយលំនឹកទាំងបីកំរិតនេះទៀតផង។

ដូច្នេះស្នាមគំនូសព័ត៌មានដែលទទួលបាន និង ចំណាប់អារម្មណ៍នៅក្នុងខួរក្បាលរបស់យើងមិនត្រូវបានរក្សាទុក ហើយក៏មិនចេះតែផុសឡើងវិញបានតាមរបៀបដូចគ្នារហូតទេ ពោលគឺនៅក្នុងលំនឹករបស់យើងវាតែងតែកើតមានឡើងនូវអ្វីដែលគេហៅថា " ការភ្លេចភ្លាំង " ។

ការភ្លេចភ្លាំងក៏មានច្រើនកំរិតដែរ ដូចជា ការភ្លេចភ្លាំងទាំងស្រុង បានន័យថា មិនអាចនឹកឃើញឡើងវិញ ហើយក៏មិនអាចបង្កើតឡើងវិញបានដែរ។ ការភ្លេចភ្លាំងតាមផ្នែកៗខ្លះ ជាការភ្លេចភ្លាំងដែលមិនអាចបង្កើតព័ត៌មានឡើងវិញបាន តែគេមានសមត្ថភាពអាចនឹកឃើញព័ត៌មានបានខ្លះៗ ។ ប៉ុន្តែសូម្បីតែការភ្លេចភ្លាំងទាំងស្រុងមិនមានអត្ថន័យអ្វីក៏ដោយ ក៏ស្នាមគំនូសព័ត៌មានដែលរក្សាទុកក្នុងខួរក្បាលត្រូវលុបបាត់អស់ដែរ។ វាមិនអាចបន្សល់ទុកបាននូវស្នាមបន្តិចណាសោះ។ របកគំហើញរបស់លោក Penfield បានស្រាយបំភ្លឺអោយយើងដឹងថា គ្មានការភ្លេចភ្លាំងទាំងស្រុងដាច់ណាត់ណាមួយទេ ថ្វីត្បិតតែយើងមិនអាចនឹកឃើញព័ត៌មានឡើងវិញ ឬក៏យើងមិនអាចបង្កើតវាឡើងវិញបានទាល់តែសោះ ចំពោះអ្វីៗដែលយើងបានជួបប្រទះរួចមកហើយក៏ដោយ វាតែងតែរក្សាទុកបានជានិច្ចនូវផ្លាកស្នាមព័ត៌មាននៅលើសំបកខួរក្បាលរបស់ យើង។

ក្រៅពីការភ្លេចភ្លាំងឥតកំណត់បាននេះ នៅមានការភ្លេចភ្លាំងបណ្តោះអាសន្នថែមទៀត ពោលគឺក្នុង រយៈពេលមួយដ៏យូរអង្វែង យើងមិនអាចបង្កើតព័ត៌មាននោះបានឡើងវិញទេ ក៏ប៉ុន្តែនៅក្នុងរយៈពេលណាមួយនោះ ស្រាប់តែយើងនឹកឃើញព័ត៌មាន ឬ រូបភាពនោះឡើងវិញ។ នេះជាបាតុភូតម្យ៉ាងដែលគេហៅថា ការនឹកឃើញដោយមិនដឹងខ្លួន។

បើអញ្ចឹងតើអ្វីទៅជាមូលហេតុនៃការភ្លេចភ្លាំង ?

គ្មានទ្រឹស្តីណាមួយដែលបកស្រាយបំភ្លឺអោយបាន ច្បាស់លាស់ពីបញ្ហានេះឡើយ គឺៈ

- ការភ្លេចភ្លាំងកើតមានឡើងដោយហេតុថា ស្នាមគំនូសនៃព័ត៌មានត្រូវលុបរលាយសាបសូន្យ។ នៅ ពេលនោះឯង ដែលទ្រឹស្តីនេះមិនអាចបកស្រាយពន្យល់បានពីការនឹកឃើញព័ត៌មានឡើងវិញ ហើយនឹងការនឹកឃើញដោយមិនដឹងខ្លួន។

- ការភ្លេចភ្លាំងត្រូវបានបង្កឡើងដោយការរៀបចំឡើងវិញ នូវស្នាមគំនូសព័ត៌មានក្នុងខួរក្បាល។ ទស្សនៈនេះមានប្រភពចេញមកពីទ្រឹស្តីមនោនិយម របស់លោក Wundt ដោយឈរលើមូលដ្ឋានបទពិសោធន៍ ដែលធ្វើឡើងក្នុងអំឡុងឆ្នាំ ១៩២០ និង ១៩២១។ ដោយសារបទពិសោធន៍ដោយឡែករបស់គាត់នេះហើយ ទើបលោក Wundt អាចធ្វើអោយទ្រឹស្តីមនោនិយមបោះជំហានទៅមុខ ដោយយល់ឃើញថាស្នាមគំនូសព័ត៌មានមិនបាត់បង់ទៅណាទេ ទោះជាក្នុងរយៈពេលបែបណាក៏ដោយ ក៏ប៉ុន្តែស្នាមគំនូសព័ត៌មាននេះមាននិន្នាការក្នុងការធ្វើអោយ ខ្លួនឯងមានភាពកាន់តែសុក្រឹតឡើង។ ទ្រឹស្តីនេះមិនមានលទ្ធភាពឈានដល់បំណកស្រាយពន្យល់បានពីការនឹកឃើញដោយមិនដឹងខ្លួន និង ការនឹកឃើញព័ត៌មានឡើងវិញបានឡើយ។

សរុបសេចក្តីមក ទ្រឹស្តីពីរដូចបានជម្រាបខាងលើនេះ បកស្រាយបំភ្លឺអំពីការភ្លេចភ្លាំងនេះថា បណ្តាលមកពីបន្លាស់ប្តូរស្នាមគំនូសព័ត៌មាន ឬ រូបភាពក្នុងខួរក្បាល។

ទ្រឹស្តីស្តីអំពីការទប់ស្កាត់មិនអោយបង្កើតព័ត៌មានបានឡើងវិញនេះ អួតអាងថា ការភ្លេចភ្លាំងនឹងកើតមានឡើងនៅពេលណាដែលឯកសារសិក្សា ដែលត្រូវទន្ទេញអោយចាំស្ទាត់នោះ វាស្រដៀងគ្នានឹងឯកសារដែលគេធ្លាប់បានរៀនពីមុនរួចមកហើយ។ ច្បាស់លាស់ជាងនេះទៅទៀត ការសិក្សាពីឯកសារណាមួយនោះនឹងជះឥទ្ធិពលជាអវិជ្ជមានទៅលើការរំលឹកឡើងវិញ ចំពោះឯកសារដែលបានសិក្សាពីមុនរួចមកហើយ ហើយឯកសារដែលសិក្សាចាំស្ទាត់រួចមកហើយនោះ នឹងបង្កអោយមានភាពលំបាកទៅលើការសិក្សាឯកសារថ្មីមួយទៀតដែលមានភាពស្រដៀងគ្នានឹងឯកសារមុននោះ។

នៅក្នុងករណីទី១ គឺជាការទប់ស្កាត់តាមលក្ខណៈប្រតិសកម្ម រីឯករណីទី២ គឺជាការទប់ស្កាត់តាម លក្ខណៈឆ្ពោះទៅរកសកម្មភាព។ ដើម្បីបកស្រាយបំភ្លឺនូវបាតុភូតខាងលើនេះ ក្រុមអ្នកនិពន្ធទ្រឹស្តីនេះបានបោះជំហានទៅរកសញ្ញាណ " ប្រកួតប្រជែងគ្នា " ។ ពួកគេយល់ឃើញថា កាលណាគេរំលឹកឡើងវិញទៅលើ បញ្ហាណាមួយ ពេលនោះវាកើតមាននូវការប្រកួតប្រជែងគ្នា រវាងចម្លើយដែលស្រដៀងគ្នា ហើយចម្លើយណា ដែលមានឥទ្ធិពលខ្លាំងនឹងបានជោគជ័យលើចម្លើយឯទៀត។ ក៏ប៉ុន្តែក្រុមអ្នកនិពន្ធអស់ទាំងនោះ មិនអាចបក ស្រាយពន្យល់បានថា តើហេតុអ្វីបានជាចម្លើយ ឬ ប្រតិកម្មដែលមានភាពស្រដៀងគ្នានេះ បែរទៅជាប្រកួត ប្រជែងគ្នាមួយទៅនឹងមួយទៀតអញ្ចឹង។ តាមពិតគឺភាពស្រដៀងគ្នានេះហើយ ដែលជាកិច្ចជាកាលជួយយើង អោយរំលឹកបញ្ហាបានឡើងវិញយ៉ាងងាយស្រួល។

ទ្រឹស្តីរបស់លោក I.P Pavlov ស្តីអំពីសកម្មភាពសរសៃប្រសាទផ្នែកខាងលើក្នុងខ្លួនមនុស្សយើងបានផ្តត់ផ្គង់នូវមូលដ្ឋានវិទ្យាសាស្ត្រជាច្រើនដល់យើងសំរាប់បកស្រាយពន្យល់ពីមូលហេតុនៃការភ្លេចភ្លាំងនេះ។ ដោយឈោលទៅលើករណីជាក់ស្តែងបែបនេះ មូលហេតុនៃការភ្លេចភ្លាំង គឺជាវិសេសានុមានវិជ្ជមាន ឬក៏ជាការទប់ស្កាត់ដែលមានលក្ខណៈខ្ពស់ជាអតិបរមា ឬក៏ជាការទប់ស្កាត់តាមលក្ខណៈឥទ្ធិពលពីខាងក្រៅ។ វាជាការច្បាស់លាស់ដែលថា ការទប់ស្កាត់រំញោចគ្រាន់តែបង្កអោយមានការភ្លេចភ្លាំងជាបណ្តោះអាសន្នប៉ុណ្ណោះ។ បាតុភូតនៃការភ្លេចភ្លាំងរបស់មនុស្សយើងក៏មានច្បាប់របស់វាដែរ។ ការយល់ដឹងបានទៅលើក្រឹត្យក្រមទាំងនេះ ជួយអោយយើងប្រយុទ្ធប្រឆាំងបានយ៉ាងមានប្រសិទ្ធភាពចំពោះការភ្លេចភ្លាំងនេះ។

**ច្បាប់នៃការភ្លេចភ្លាំងមានដូចតទៅ:**

- គេតែងតែភ្លេចភ្លាំងជានិច្ចជាកាល ចំពោះអ្វីៗដែលគ្មានទំនាក់ទំនង ឬក៏មានទំនាក់ទំនងតិចតួច ស្តួចស្តើងពេកជាមួយនឹងជីវភាពរស់នៅ ឬក៏អ្វីៗដែលមិនសមស្របទៅនឹងចំណង់ចំណូលចិត្តរស ជាតិតំរូវការរបស់មនុស្សយើងម្នាក់ៗ ។
- ចំពោះអ្វីៗដែលគេមិនបានប្រើប្រាស់វាអោយបានញឹកញយដងនៅក្នុងសកម្មភាពជាប្រចាំរាល់ថ្ងៃ ក៏គេអាចភ្លេចភ្លាំងបានយ៉ាងងាយដែរ។
- ការភ្លេចភ្លាំងតែងតែកើតមានជានិច្ចក្នុងខ្លួនមនុស្សយើង នៅពេលណាដែលមានរំញោចដ៏ចម្លែក ឬក៏ រំញោចដែលមានឥទ្ធិពលខ្លាំងពេក។
- ជាគោលការណ៍ការភ្លេចភ្លាំង គឺជាបាតុភូតមួយដែលសមស្រប ហើយមានប្រយោជន៍ផង។
- ការភ្លេចភ្លាំងប្រព្រឹត្តទៅបានបន្ទាប់ពីមានបទបញ្ហាមួយជាកំណត់។ មុនដំបូងគេភ្លេចភ្លាំងនូវផ្នែក លំអិតបន្ទាប់បន្សំ ដល់រួចមកគេភ្លេចភ្លាំងផ្នែកសំខាន់ទូទៅតែម្តង។
- ការភ្លេចភ្លាំងមិនអាចប្រព្រឹត្តទៅបានទេ នៅក្នុងល្បឿនថេរមួយ ពោលគឺនៅក្នុងដំណាក់កាលទី១ ល្បឿននៃការភ្លេចភ្លាំងមានកម្លាំងខ្លាំងក្លាណាស់ រួចដំណាក់កាលនេះចុះថយល្បឿនទៅតាម លំដាប់ (ច្បាប់របស់លោក Ebbinghause )។

### ៥ - តើត្រូវធ្វើដូចម្តេច ដើម្បីអោយមានលំនឹកល្អ?

ដូចយើងបានពិពណ៌នារួចមកហើយនៅផ្នែកខាងមុនថា លំនឹកចែកចេញជាបួនដំណាក់កាល សំខាន់ៗ គឺ លំនឹកកម្ម ការរក្សាព័ត៌មាន ឬ រូបភាពទុក ការនឹកឃើញព័ត៌មានឡើងវិញ និងការបង្កើត ព័ត៌មានឡើងវិញ។ នៅក្នុងលំនាំទាំងបួននេះលំនាំពីរខាងដើម គឺជាផលដំបូងនៃលំនឹក ហើយដំណាក់នៃ លំនាំទី៣ គេហៅថា កន្សោមលំនឹក។ ប្រសិនណាជាលំនឹកកម្ម និង ការរក្សាព័ត៌មានទុកមានដំណើរការ ប្រព្រឹត្តទៅល្អ នោះការនឹកឃើញព័ត៌មានឡើងវិញ និង ការបង្កើតព័ត៌មានឡើងវិញនឹងផ្តល់អោយយើងនូវ លទ្ធផលល្អ ហើយប្រសិនណាជា លំនឹកកម្ម និង ការរក្សាព័ត៌មានទុកមានដំណើរការប្រព្រឹត្តទៅមិនល្អ នោះការនឹកឃើញ និង ការបង្កើតព័ត៌មានឡើងវិញ ក៏មិនបានទទួលនូវលទ្ធផលល្អដែរ។ ដូច្នេះហើយបាន ជាវិធានការណ៍ ដែលតំរង់មុខសញ្ញាទៅរកលំនឹកដ៏ល្អប្រសើរនោះ នឹងប្រមូលផ្តុំគ្នាយ៉ាងសំខាន់នៅក្នុង លំនាំទាំងពីរ គឺលំនឹកកម្ម និង ការរក្សាព័ត៌មានទុក។

#### ក - តើធ្វើដូចម្តេច ដើម្បីចងចាំព័ត៌មានអោយបានល្អ?

ស្នាដៃសិក្សាស្រាវជ្រាវផ្នែកចិត្តវិទ្យា បានបង្ហាញអោយឃើញថា លទ្ធផលរបស់លំនឹកកម្ម ពឹងផ្អែក លើកត្តាបីយ៉ាងសំខាន់ៗ គឺ:

- ប្រភេទនៃលំនឹកកម្ម
- ឥរិយាបថរបស់មនុស្ស ចំពោះឯកសារសិក្សា ដែលត្រូវចងចាំដូចជា បម្រុងប្រយ័ត្ន ចំណង់ ចំណូលចិត្ត ទំនួលផ្លូវចិត្ត។

- ល្បិចរបស់លំនឹកកម្ម សិប្បនិម្មិត។ ដោយឈរលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានដូចបានរៀបរាប់មក នេះ ដើម្បីចងចាំព័ត៌មានអោយបានល្អ គេគប្បី:
  - ប្រមូលផ្ដុំ និង សំរបសំរួលអោយបានសមរម្យបំផុត នូវប្រភេទលំនឹក ដែលសមស្របទៅនឹង ខ្លឹមសារឯកសារ ឬ វត្ថុ និង គោលបំណងរបស់លំនឹកកម្ម។
  - ធ្វើសម្បទានដល់បម្រុងប្រយ័ត្នអោយបានយ៉ាងហ្មត់ចត់ (ផ្ចង់ស្មារតីប្រុងប្រយ័ត្ន) នៅពេលដែលមានលំនឹកកម្ម មានចំណង់ចំណូលចិត្ត មានសញ្ចេតនាដ៏ជ្រាលជ្រៅ ចំពោះឯកសារដែលត្រូវចងចាំ ត្រូវមានការភ្ញាក់រលឹកចំពោះអត្ថប្រយោជន៍នៃឯកសារ ហើយបង្កើតបាននូវទំនួលផ្លូវចិត្ត ទៅលើលំនឹកកម្មដ៏យូរអង្វែង ចំពោះឯកសារនេះ។
  - ធ្វើសមកាលកម្ម ទៅលើឯកសារ ឬវត្ថុ បានន័យថា ទទួលស្គាល់វត្ថុ ឬ ឯកសារថា មានខ្លឹមសារថ្មីស្រឡាងដោយប្រើប្រាស់អស់សរីរាង្គឥន្ទ្រីយ៍ ដែលមានក្នុងខ្លួនសំដៅចងចាំវាអោយបានល្អ។

## ខ - តើត្រូវធ្វើដូចម្ដេច ដើម្បីរក្សាទុកព័ត៌មានអោយបានល្អប្រសើរ?

ដើម្បីរក្សាទុកព័ត៌មានអោយបានល្អ (ធ្វើការពិពណ៌នាសង្ខេបអោយបានល្អ) ដោយឈរលើមូលដ្ឋានច្បាប់នៃការភ្លេចភ្លាំងព័ត៌មាន និង ច្បាប់នៃការរក្សាព័ត៌មានទុក យើងសូមស្នើចុះនូវវិធានការណ៍ដូចតទៅ:

- គប្បីធ្វើការពិពណ៌នាសង្ខេបទៅលើខ្លឹមសារឯកសារសិក្សាអោយបានយ៉ាងសកម្ម ពោលគឺបង្កើតខ្លឹមសារសំខាន់ៗរបស់ឯកសារនោះឡើងវិញ។
- គប្បីធ្វើការពិពណ៌នាសង្ខេបភ្លាមៗ ទៅលើខ្លឹមសារឯកសារ ឬព័ត៌មានដោយមិនដំអក់ទុកយូរពេលនៅក្រោយដែលមានលំនឹកកម្មទៅលើឯកសារនោះហើយ។
- គប្បីធ្វើការសិក្សាសារដើមឡើងវិញ ដោយឆ្លាស់ពេលវេលា ហើយមិនត្រូវធ្វើការសិក្សាសារដើមវិញជាបន្តបន្ទាប់គ្នារហូតតែលើមេរៀនសំរាប់មួយមុខវិជ្ជាប៉ុណ្ណោះទេ។
- ការពិពណ៌នាដ៏សង្ខេបមិនត្រូវធ្វើឡើងជាប់ៗគ្នារហូតនោះទេ ហើយគេក៏មិនត្រូវប្រើពេលវេលាដ៏យូរ អង្វែង ដើម្បីធ្វើការពិពណ៌នាដ៏សង្ខេបទៅលើខ្លឹមសារនៃឯកសារណាមួយឡើយ។
- ស្របពេលគ្នានឹងការធ្វើសង្ខេបទៅលើខ្លឹមសារឯកសារនោះ គេគប្បីលៃពេលសំរាកខ្លះផង។
- គប្បីផ្លាស់ប្ដូររូបភាព និង វិធីនៃការធ្វើសង្ខេបទៅលើព័ត៌មាន ឬខ្លឹមសារឯកសារ។
- គប្បីយកចំណេះដឹងដែលយល់ជ្រួតជ្រាបមកហើយទៅអនុវត្តអោយបានដិតដល់។

## គ - តើត្រូវធ្វើដូចម្ដេច ដើម្បីរំលឹក ឬ បង្កើតខ្លឹមសារព័ត៌មានឡើងវិញអោយបានល្អ ប្រសើរ?

ការរំលឹក ឬ ការបង្កើតខ្លឹមសារព័ត៌មានដែលគេបានភ្លេចភ្លាំង មានអត្ថន័យដ៏ធំធេងនៅក្នុងជីវភាពរស់នៅ និង ក្នុងការសិក្សា។ ដើម្បីធ្វើអោយការរំលឹក ឬ ការបង្កើតខ្លឹមសារព័ត៌មានឡើងវិញប្រកបដោយប្រសិទ្ធភាពខ្ពស់ចំពោះឯកសារដែលគេបានភ្លេចភ្លាំង អ្នកប្រាជ្ញខាងចិត្តវិទ្យាបានទូន្មានយើងអោយផ្ចិតផ្ចង់ប្រុងប្រយ័ត្នចំពោះចំណុចទាំងឡាយដូចតទៅ:

- គប្បីច្រានចោលនូវគំនិតខុសឆ្គង ដែលយល់ឃើញថា យើងបានភ្លេចភ្លាំងព័ត៌មានទាំងស្រុង ហើយ យើងមិនចងចាំបានអ្វីបន្តិចសោះ។ គេគប្បីជឿថា យើងមានលទ្ធភាពដើម្បីរំលឹក ឬ បង្កើតខ្លឹមសារ ព័ត៌មានឡើងវិញបាន។
- យើងគប្បីព្យាយាម។ ប្រសិនណាជាការរំលឹក ឬ ការបង្កើតខ្លឹមសារព័ត៌មានឡើងវិញ មិនបានផ្តល់អោយយើងនូវលទ្ធផលល្អជាលើកទី១ទេនោះ យើងមិនត្រូវអស់សង្ឃឹមឡើយ។
- កាលណានៅលើកទី១ទទួលការបរាជ័យហើយលើកក្រោយៗបន្ទាប់មកទៀត គំរូវអោយយើងផ្លាស់ប្តូរវិធីថ្មីមួយយកមកចាប់ផ្តើមអនុវត្តសារឡើងវិញ ហើយយើងមិនត្រូវអនុវត្តតាមវិធីចាស់ទៀត ឡើយ។
- គប្បីធ្វើការប្រៀបផ្ទឹមគ្នា ឬការប្រៀបធៀបនឹងគំនិតដែលបានរក្សាទុកផ្សេងទៀត ដែលមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងទស្សនៈនៃខ្លឹមសារព័ត៌មាន សំរាប់យកមកផ្ទៀងផ្ទាត់ទៅនឹងភាពត្រឹមត្រូវច្បាស់លាស់នៃគំនិតរក្សាទុកពីមុន ហើយដែលយើងត្រូវរំលឹកវាឡើងវិញផងដែរនោះ។
- វាជាការចាំបាច់ណាស់ដែរត្រូវប្រើប្រាស់ការគិតថា ជាមធ្យោបាយសំរាប់ទ្រទ្រង់សកម្មភាពនៃការរំលឹក ឬ ការបង្កើតខ្លឹមសារព័ត៌មានឡើងវិញ។
- គេត្រូវប្រើប្រាស់ដោយខានមិនបាន នូវសំណុំរូបតំណាង និង បញ្ញត្តិ ជាពិសេសគឺសំណុំរូបតំណាងពីហេតុទៅផល សំដៅសំរេចបានយ៉ាងងាយស្រួល និង ប្រកបទៅដោយជោគជ័យ ចំពោះការរំលឹក ឬ ការបង្កើតខ្លឹមសារព័ត៌មានសារឡើងវិញនេះ។

## IV - **លំនឹក និង បុគ្គលិកលក្ខណៈ**

វាងមនុស្សពីរនាក់ គឺលំនឹកមានភាពខុសគ្នាស្រឡះដែរ

១ -ចរិតរបស់បុគ្គលចំពោះទស្សនៈនៃលំនឹកអាស្រ័យដោយចរិតរបស់បុគ្គលិកលក្ខណៈរបស់បុគ្គលនោះ។ សូម្បីតែអ្នកទាំងឡាយណាដែលមានលំនឹកល្អយ៉ាងណាក៏ដោយ ក៏មិនអាចរំលឹកឡើងវិញបានលើរាល់វត្ថុ ឬ ខ្លឹមសារព័ត៌មានបានឡើយ ហើយអ្នកឯណាដែលមានលំនឹកក្នុងរយៈពេលខ្លីក៏សុទ្ធតែមិនមានចេះតែភ្លេចអស់វត្ថុ ឬ ខ្លឹមសារព័ត៌មានទាំងស្រុងទេ។ ដោយហេតុថាលំនឹករបស់មនុស្សយើងមានលក្ខណៈប្រមូលផ្តុំគ្នា។ នេះជាការសមស្របទៅនឹងចំណង់ចំណូលចិត្តរបស់មនុស្ស និង តំរូវការរបស់មនុស្សដែលត្រូវបានរំលឹកឡើងវិញតាមបែបបទដ៏ឆាប់រហ័ស ហើយរក្សាទុកវាបានយូរអង្វែងផង។

២ - ការខុសប្លែកគ្នារវាងបុគ្គល និង បុគ្គល ស្តែងចេញអោយឃើញតាមរយៈគុណសម្បត្តិរបស់លំនឹក។ លំនឹករបស់បុគ្គលម្នាក់ខុសប្លែកគ្នាពីបុគ្គលម្នាក់ទៀត ត្រង់ដែលអ្នកណាម្នាក់នោះមានភាពរហ័សរហួនខាងលំនឹកកម្ម រយៈពេល ស្ថេរភាពក្នុងការរក្សាព័ត៌មានទុក និង ភាពងាយស្រួលក្នុងការបង្កើតព័ត៌មានបានឡើង វិញ។ គុណសម្បត្តិទាំងនេះត្រូវបានលាយចំរុះគ្នាទៅតាមបែបបទជាច្រើនប្លែកៗពីគ្នា។ លំនឹករបស់បុគ្គលម្នាក់ អាចមានឥទ្ធិពលខ្លាំងនៅក្នុងទិដ្ឋភាពបែបនេះ ក៏ប៉ុន្តែលំនឹកនេះមានភាពទន់ខ្សោយចំពោះទិដ្ឋភាពផ្សេងទៀត។

គេអាចមានសមាយោគ ដូចតទៅ:

- មានលំនឹកកម្ម (ការចងចាំ) យ៉ាងឆាប់រហ័ស ហើយមិនងាយនឹងភ្លេចភ្លាំងបាន (ល្អប្រសើរ)។
- មានលំនឹកកម្មឆាប់រហ័ស ហើយក៏ងាយភ្លេចឆាប់រហ័សដែរ។
- មានលំនឹកកម្មដោយពិបាក ប៉ុន្តែក៏មិនងាយនឹងភ្លេចភ្លាំងបានទៅដែរ។
- មានលំនឹកកម្មដោយពិបាក ហើយឆាប់ភ្លេចទៅវិញណាស់ (មិនល្អសោះ)។

៣ - លំនឹករបស់បុគ្គលក៏មានភាពខុសប្លែកគ្នាពីម្នាក់ ទៅម្នាក់ទៀតដែរ ដោយយោលទៅតាមវ័យ ភេទ និង មុខរបរ។

តាមយោបល់របស់លោក Karsakov ជាគ្រូពេទ្យព្យាបាលជម្ងឺវិកលចរិត ជាតិរុស្ស៊ីបានកំណត់ថាៈ ក្នុងវ័យពី ១ឆ្នាំ ទៅ ២៥ឆ្នាំ មនុស្សយើងមានលំនឹកអភិវឌ្ឍន៍ឡើងល្អ ហើយរហ័សរហួនផង។ ពីវ័យ ២៥ ឆ្នាំ ទៅ ៤៥ឆ្នាំ លំនឹករបស់មនុស្សយើងមានភាពនឹងនរ ហើយចាប់ពីវ័យ ៤៥ឆ្នាំ ឡើងទៅ លំនឹករបស់មនុស្សចាប់ផ្តើមចុះខ្សោយវិញ។ គេបានរកឃើញថែមទៀតថា លំនឹករបស់ស្ត្រី មានភាពល្អប្រសើរជាងលំនឹករបស់បុរស។ ក៏ប៉ុន្តែ ការខុសប្លែកគ្នានេះ មិនជាច្រើនខ្លាំងណាស់ណាទេ។

មុខរបរផ្សេងៗគ្នា បង្កើតអោយមនុស្សមានប្រភេទនៃលំនឹកផ្សេងៗគ្នាដែរ ដូចជា លំនឹករបស់ចក្ខុវិញ្ញាណ (ចំពោះជាងគំនូរ) លំនឹករបស់សោតវិញ្ញាណ (ចំពោះតន្ត្រីករ) លំនឹករបស់ចលនានៃខ្លួនប្រាណ (ចំពោះ ក្រុមកីឡាករ)។

ដើម្បីបង្ហាត់បង្រៀនសិស្សអោយបានល្អប្រសើរ គ្រូបង្រៀនម្នាក់ៗគប្បីយកចិត្តទុកដាក់អោយបានជិតដល់ចំពោះការខុសប្លែកគ្នានៃលំនឹក រវាងសិស្សម្នាក់ទៅសិស្សម្នាក់ទៀត។

## សំណួរ

១- ហេតុអ្វីបានជាគេនិយាយថា លំនឹកគឺជាកំរិតថ្មីមួយនៃចំណេះដឹងរបស់មនុស្ស បើធៀបទៅនឹងឥន្ទ្រីយារម្មណ៍ និង ប្រត្យក្សារម្មណ៍?

២ - ចូររកភាពខុសប្លែកគ្នា និង ភាពស្រដៀងគ្នា រវាងរូបភាពរបស់ប្រត្យក្សារម្មណ៍ និង រូបតំណាងរបស់លំនឹក?

៣ - តើត្រូវធ្វើដូចម្តេច ដើម្បីអោយមានលំនឹកល្អ?

៤ - តើត្រូវធ្វើដូចម្តេច ដើម្បីចងចាំព័ត៌មានអោយបានល្អ?

## មេរៀនទី៨ ៖ បម្រុងប្រយ័ត្ន ( L' ATTENTION )

លំនាំផ្លូវចិត្តទាំងអស់មានមុខងារសម្រាប់ឆ្លុះបញ្ចាំងបាននូវតថភាពសត្យានុម័ត។ ប្រសិទ្ធិភាព និង គុណភាពនៃចំណាំងអាស្រ័យដោយសភាពចិត្តមួយផ្នែកធំ ដែលកើតឡើងជានិច្ចជាមួយនឹងលំនាំផ្លូវចិត្ត ទាំងអស់នោះ។ សភាពចិត្តនេះគេហៅថា បម្រុងប្រយ័ត្ន។

### I. សញ្ញាណទូទៅ (Notion Générale)

ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ គេតែងជួបប្រទះជានិច្ចជាកាលនឹងករណី ដែលមនុស្សត្រូវការស្តាប់ សម្លឹង មើល និង អនុវត្តការងារមួយយ៉ាងយកចិត្តទុកដាក់ ហើយគេស្ទើរតែមិនដឹងទាល់តែសោះពីអ្វីៗ ដែលកើតឡើងជុំវិញខ្លួនគេ។ ការអនុវត្ត និងការផ្ចង់គំនិតនេះហៅថា បម្រុងប្រយ័ត្ន។

#### ក. និយមន័យ (Définition)

បម្រុងប្រយ័ត្នជាសភាពចិត្តដែលតាមប្រកិតនឹងលំនាំចិត្ត ហើយមានតួនាទីប្រមូលផ្តុំលំនាំចិត្តនោះ ដោយបាញ់ឆ្ពោះទៅរកវត្ថុបំណងមួយជាក់លាក់សំដៅឆ្លុះបញ្ចាំងបានទៅលើវត្ថុបំណងនោះឲ្យកាន់តែប្រសើរ។

**ឧទាហរណ៍៖** បម្រុងប្រយ័ត្នរបស់សមូហភាពសិស្សពេលស្តាប់សាស្ត្រាចារ្យពន្យល់មេរៀន។ បម្រុង ប្រយ័ត្នរបស់បេក្ខជនក្នុងការផ្ទៀងផ្ទាត់ចម្លើយក្នុងវិញ្ញាសាឡើងវិញមុននឹងប្រគល់វិញ្ញាសាឲ្យអនុរក្ស។

បម្រុងប្រយ័ត្នក្នុងការតាមដាន ធ្វើការពិសោធន៍ នៅក្នុងមន្ទីរពិសោធន៍។ បម្រុងប្រយ័ត្នក្នុងការជិះ ម៉ូតូ ឬបើកបររថយន្តពេលចរាចរណ៍ចង្អៀត។  ពេលប្រមូលស្មារតីប្រុងប្រយ័ត្ន មនុស្សតែងតែប្រើចលនា សរីរាង្គវិញ្ញាណ ដើម្បីធ្វើសកម្មភាព។

**ឧទាហរណ៍ ៖** ពេលស្តាប់សាស្ត្រាចារ្យពន្យល់ យុវសិស្សប្រើភ្នែក ដើម្បីមើលកាយវិការរបស់ សាស្ត្រាចារ្យ ត្រចៀកផ្ទៀងស្តាប់ ដៃកត់ត្រាអត្ថន័យសំខាន់ៗ។

ពេលជិះម៉ូតូ ឬបើកបររថយន្ត ពេលមានចរាចរណ៍ចង្អៀត ភ្នែកខំសម្លឹងមើលទៅមុខ ដៃកាន់ចង្កូត និង ប្តូរលេខ ជើងជាន់ហ្វ្រាំង ឬ ហ្គារ។

បម្រុងប្រយ័ត្នជាសភាពចិត្តពិសេសមួយដែលមិនអាចកាត់ផ្តាច់បានពីលំនាំចិត្តដែលវាត្រូវដើរតា ម។ បម្រុងប្រយ័ត្នតាមប្រកៀកលើគ្រប់លំនាំផ្លូវចិត្តទាំងអស់ ជាពិសេសគឺលំនាំចំណេះដឹង របស់មនុស្ស ដូចជា ប្រត្យក្សារម្មណ៍ លំនឹក រូបារម្មណ៍ និងការគិត...។

**ឧទាហរណ៍៖** ពេលធ្វើវិញ្ញាសារប្រឡងគ្រប់មុខវិជ្ជាសិក្សាទាំងអស់ បេក្ខជនឃើញវិញ្ញាសារហើយ យល់សំណួរទាំងអស់ (ប្រត្យាក្សារម្មណ៍)។ បេក្ខជនខំនឹករកអត្ថន័យ (លំនឹក) ដើម្បីឆ្លើយសំណួរ។ បេក្ខជនអាចឆ្លើយបានគ្រប់សំនួរ (ចិត្តរំភើប) បេក្ខជនខំឆ្លើយ សរសេរយ៉ាងយកចិត្តទុកដាក់ រួចហើយ ផ្ទៀងផ្ទាត់ឡើងវិញ (បម្រុងប្រយ័ត្ន) ។ អ្នកជិតខាងខ្សឹបសួរចម្លើយសំនួរណាមួយ បេក្ខជនចិត្តមិនដាច់

( សញ្ចេតនា ) ក៏ជួយប្រាប់ចម្លើយសម្រាប់សំនួរមួយទៅអ្នកជិតខាង ។ អនុរក្សឃើញក៏ស្ទុះទៅចាប់បេក្ខជនទាំងពីរ ( ធន្ទះ ) ។

នៅក្នុងលោកយើងនេះ មានវត្ថុ និង បាតុភូតជាច្រើនប្រភេទខុសប្លែកគ្នា ហើយដែលយើងមិនអាចស្គាល់ វាក្នុងពេលតែមួយបានទេ ។ បម្រុងប្រយ័ត្នទាមទារឲ្យយើងផ្ដោតអារម្មណ៍ ឬ ស្មារតីទៅលើវត្ថុ ឬ បាតុភូត ណាមួយតាមការជ្រើសរើសរបស់យើង ដើម្បីឲ្យយើងឆ្លុះបញ្ចាំង ឬ ស្គាល់វត្ថុ - បាតុភូតណាមួយ ឲ្យបានច្បាស់លាស់ ។

**ឧទាហរណ៍៖** ពេលរៀនវាយកុំព្យូទ័រ យុវជនម្នាក់ខំផ្ដោតស្មារតីយ៉ាងផ្ចិតផ្ចង់ទៅលើចំណុច ដែលខ្លួនត្រូវអនុវត្ត និង បញ្ជាកុំព្យូទ័រ ឲ្យសម្រេចតាមគោលបំណងរបស់ខ្លួន សំដៅប្រតិបត្តិទៅលើសញ្ញាណណាមួយ ក្នុងកុំព្យូទ័រ ដើម្បីឲ្យខ្លួនបានស្ទាត់ជំនាញ ។

បម្រុងប្រយ័ត្នកើតមានឡើងនៅក្នុងពេលពលកម្មបញ្ញា និង ពលកម្មកម្លាំងកាយ។ យើងជាសាស្ត្រចារ្យយើងត្រូវហ្វឹកហ្វឺន និង អប់រំ យុវសិស្សឲ្យមានបម្រុងប្រយ័ត្នទៅលើការសិក្សាមេរៀនថ្មីក្នុងថ្នាក់, ក្នុងមន្ទីរពិសោធន៍ ក្នុងការតាមដានបំណកស្រាយពន្យល់របស់សាស្ត្រាចារ្យ ក្នុងពេលធ្វើពលកម្ម និង ពេលធ្វើកិច្ចការដែលសាស្ត្រាចារ្យដាក់ឲ្យធ្វើ។ បម្រុងប្រយ័ត្នជាទម្លាប់ដ៏ល្អក្នុងការសិក្សា និង ក្នុងការងារ។ បម្រុងប្រយ័ត្នជាប្រភពនៃការផ្ដោតស្មារតី និងការភ្ញាក់រំលឹកទៅលើអ្វីដែលល្អ និង មានប្រយោជន៍ដល់ជីវភាពរស់នៅ និង ការងារក្នុងសង្គម ។

## II. **បំណកស្រាយពន្យល់តាមបែបសរីរៈសាស្ត្រ** ( **Explication physiologique** )

តាមសរីរៈវិទ្យា គេពន្យល់សភាពចិត្តនេះ ដូចតទៅ :

**ក.** កាលណាភ្ញោចថ្មីណាមួយកើតមានឡើង ប្រព័ន្ធសរសៃប្រសាទ ទាំងមូលធ្វើប្រតិកម្មទៅរកទិសដែលមានភ្ញោចនោះ។ លោក ប៉ាវ ឡូវ ឲ្យឈ្មោះថា រ៉េផ្លិចតម្រង់ទិស។ រ៉េផ្លេចតម្រង់ទិសនេះមានលក្ខណៈដូចតទៅនេះ :

- រ៉េផ្លិចកើតឡើងឯងៗមិនថាមនុស្ស ឬ សត្វ។ រីឯទារកក៏មានរ៉េផ្លិចនេះដែរ។
- រ៉េផ្លិចនេះកើតមានជានិច្ចឲ្យតែរំញោចនោះមានលក្ខណៈថ្មីប្លែកពីធម្មតា
- រ៉េផ្លិចនោះបាត់បង់ទៅវិញ កាលណារំញោចមានលក្ខណៈច្រំដែល។ នេះជារ៉េផ្លិចគ្មានលក្ខខណ្ឌ

( Reflexe inconditionnel )

- រ៉េផ្លិចគ្មានលក្ខខណ្ឌនេះមានប្រភេទពិសេសមួយ ( Type special ) ដែលរួមមាន:
    - ការតម្រង់ទិសសរីរាង្គឥន្ទ្រីយ៍ទៅរកវត្ថុភ្ញោចដែលស្ថិតនៅក្រោមការបញ្ជារបស់មជ្ឈមណ្ឌលសរសៃប្រសាទ ។

- ត្រៀមសាច់ដុំកាយទាំងមូល ដើម្បីធ្វើប្រតិកម្មឆ្លើយតបទៅនឹងរំញោច ។ ការត្រៀមលក្ខណៈនេះត្រូវបានបញ្ជាឡើងដោយបណ្ដុំសរសៃប្រសាទ ដែលស្ថិតនៅក្រោមសំបកខួរក្បាល ។
- ការបង្កើតបាននូវមជ្ឈមណ្ឌលនៃរំញោចដែលកើតមានច្រើនជាងនៅក្នុងស្រោមខួរក្បាលហើយ និងការលេចឡើងនូវនិចលភាព (Inhibition) នៅតាមផ្នែកផ្សេងទៀតនៃខួរក្បាល ។

ចលនាការនេះបកស្រាយពន្យល់ថា ហេតុអ្វីបានជានៅពេលដែលគេផ្ដោតស្មារតីប្រុងប្រយ័ត្នទៅលើវត្ថុមួយជាកំណត់ គេហាក់ដូចជាមិនដឹងពីអ្វីសោះ ដែលកើតឡើងនៅជុំវិញខ្លួនគេ ។

តណ្ហាកើតមានឡើងចំពោះអំណានសៀវភៅមួយដ៏សំខាន់ បង្កឲ្យមានមជ្ឈមណ្ឌលនៃរំញោចដែលកើតមានឡើងជាច្រើនជាងនៅក្នុងតំបន់សម្រាប់ទទួលចក្ខុឥន្រ្ទីយារម្មណ៍ និង និចលភាពនៃតំបន់ផ្សេងទៀត ដូចជា សោតវិញ្ញាណ, ឃានវិញ្ញាណ, និង កាយវិញ្ញាណ ។

ជាទូទៅដរាបណាដែលមនុស្សមានការភ្ញាក់រលឹក វាតែងតែកើតមានជានិច្ចនូវមជ្ឈមណ្ឌលនៃរំញោច ដែលកើតមានឡើងមិនដាច់នៅលើសំបកខួរក្បាល ដែលទាមទារឲ្យមនុស្សផ្ចង់ស្មារតីប្រុងប្រយ័ត្ន គឺបានន័យថា មនុស្សនោះគ្មានការប្រយ័ត្ន ។ កាលណានិយាយថា មនុស្សខ្វះការប្រុងប្រយ័ត្ន គឺបានន័យថា មនុស្សនោះគ្មានការប្រយ័ត្នប្រយែង ចំពោះអ្វីដែលកើតមានឡើង និង ចំពោះអ្វីដែលត្រូវធ្វើ។




## ខ. សភាពនៃបម្រុងប្រយ័ត្នស្តែងចេញឲ្យឃើញជាធម្មតាតាមរយៈឥរិយាបថដ៏សមស្រប

(L′etat d′attention se manifeste d′ordinaire par des attitudes appropriees)

1. សម្លឹងមើលផ្ចឹងទៅលើអ្វីមួយយ៉ាងជក់ចិត្ត (Regarder fixement) សម្លឹងមើលអ្វីមួយឥតព្រិចភ្នែក (Regarder sans clinger les yeux) ។ នេះហៅថា បម្រុងប្រយ័ត្ននៅក្នុងប្រត្យក្សារម្មណ៍នៃចក្ខុវិញ្ញាណ (Perception visuelle) ។

2. ចោលភ្នែកសម្លឹងទៅឆ្ងាយ (Avoir le regard perdu dans le lointain) ហើយជ្រួញចិញ្ចើម (Froncer les soucils) ។ នេះហៅថា បម្រុងប្រយ័ត្នឆ្ពោះទៅរកពិភពខាងក្រៅ ។

3. ផ្ទៀងត្រចៀកស្ដាប់ (Tendre les oreilles) ធ្វើមាត់ច្រហ (Rester bouche bee) តាមដានស្ដាប់សាស្រ្ដាចារ្យពន្យល់ ។ នេះហៅថា បម្រុងប្រយ័ត្ននៅក្នុងប្រត្យក្សារម្មណ៍នៃសោតវិញ្ញាណ ។

4. ឈរផ្ទឹង មិននិយាយស្ដី ឈរស្ងៀម (Se tenir coi) ។ នេះហៅថា បម្រុងប្រយ័ត្នក្នុងការតាមដានទៅលើចលនាណាមួយ ។

ជួនកាលបម្រុងប្រយ័ត្នប្រព្រឹត្តទៅរួមជាមួយនឹងកាយវិការ ដែលសំរបសំរួលតាមចលនានៃវត្ថុ ។ ជារឿយៗគេសង្កេតឃើញកុមារធ្វើចលនាមាត់ និង បបូរមាត់ កាលណាគេប្រើប្រាស់កន្ត្រៃ ដើម្បីកាត់របស់អ្វីមួយ។ មនុស្សជាច្រើន ស្ដាប់ភ្លេងដោយធ្វើចលនាជើង។ បម្រុងប្រយ័ត្នប្រព្រឹត្តទៅនៅខាងក្នុងខ្លួនផងដែរ ដូចជាការដកដង្ហើមចេញចូលឲ្យត្រូវបានបន្ថយល្បឿន។

គេដកដង្ហើមចេញចូលជាធម្មតា។ ដោយសារការសិក្សាវិភាគទៅចលនានៃខួរក្បាលគេអាចឃើញមានបម្រែបម្រួលនៃចរន្ដជីវៈអគ្គីសនី(Courant bio-electrique) នៅក្នុងខួរក្បាល នៅពេលដែលមនុស្សយើងផ្ដោតស្មារតីប្រុងប្រយ័ត្ន។

## III. **ចំណែកថ្នាក់របស់បម្រុងប្រយ័ត្ន** (Classification de l'attention)

គេអាចចែកបម្រុងប្រយ័ត្នជាពីរប្រភេទ គឺបម្រុងប្រយ័ត្នមិនគ្រោងទុកមុន និងបម្រុងប្រយ័ត្នគ្រោងទុកមុន(L'attention préméditeé) ។

**ក. បម្រុងប្រយ័ត្នមិនគ្រោងទុកមុន** (L'attention non-préméditeé) ឬបម្រុងប្រយ័ត្នតាមធម្មជាតិ គឺជាបម្រុងប្រយ័ត្នអចន្ទៈ(Attention involontaire)។ លើរាល់វត្ថុថ្មីទាំងអស់ សុទ្ធតែអាចទាក់ទាញបម្រុងប្រយ័ត្នរបស់យើង។

**ឧទាហរណ៍៖**

- ពេលកំពុងស្ដាប់សាស្រ្ដាចារ្យពន្យល់មេរៀនក្នុងថ្នាក់ ស្រាប់តែមានយន្ដហោះមួយហោះយ៉ាងទាបពីលើសាលារៀន។ វត្ថុភ្ញោចថ្មីនេះ ធ្វើឲ្យយុវសិស្សទាំងអស់ បំបែរការប្រុងប្រយ័ត្ន ទៅរកយន្ដហោះនោះ។

- ពេលកំពុងធ្វើដំណើរដោយយានជំនិះតាមដងវិថីស្រាប់តែគេឮសូរស៊ីរ៉ែនពីក្រោយ ធ្វើឲ្យគេប្រុងប្រយ័ត្នបើកបរយានជំនិះ អែបមកខាងចិញ្ចើមវិថីភ្លាម។ ទាំងនេះហៅថា បម្រុងប្រយ័ត្នមិនបានគ្រោងទុកមុន។

បម្រុងប្រយ័ត្នមិនបានគ្រោងទុកមុននេះ ជាប្រភេទបម្រុងប្រយ័ត្នម៉្យាងដែលមិនបញ្ជាដាច់ណាត់ដោយមនសិការហើយក៏មិនពឹងផ្អែកទៅលើមធ្យោបាយពិសេសណាមួយដែលស្ថិតនៅក្រៅលក្ខណៈពិសេសនៃវត្ថុ និងចំណងទាក់ទងរបស់វា ជាមួយនឹងនិន្នាការរបស់យើងឡើយ។

**លក្ខណៈពិសេសនៃវត្ថុដែលទាក់ទាញបម្រុងប្រយ័ត្នមាន**

- កម្លាំងនៃការធ្វើឲ្យមានរំញោច (ឥទ្ធិពលនៃទស្សនៈខាងផ្លូវចិត្ត ជីវសាស្ត្រ និងសង្គម)។

**ឧទាហរណ៍ ៖** ពេលយើងកំពុងទទួលទានអាហារក្នុងភោជនីយដ្ឋាន ឬក្នុងពិធីជប់លៀងមួយកាលណាយើងឮសូរកែវធ្លាក់ពីតុ យើងតែងតែបំបែរបម្រុងប្រយ័ត្នរបស់យើងទៅរកសម្លេងថ្មីនោះដោយត្រិះរិះរកប្រភពដែលនាំឲ្យកែវធ្លាក់បែក។

- ភាពផ្ទុយគ្នារវាងវត្ថុភ្ញោច និងមជ្ឈដ្ឋាន(ពណ៌សម្បុរ,ទ្រង់ទ្រាយ, មាឌ, ចរិត, អត្ថន័យ)។

**ឧទាហរណ៍ ៖** សាស្ត្រាចារ្យស្លៀកពាក់ខុសប្លែកពីសព្វមួយដង ចូលមកបង្រៀនក្នុងថ្នាក់ធ្វើឲ្យយុវសិស្សកើតមានបម្រុងប្រយ័ត្នមិនបានគ្រោងទុកមុន។ បម្រុងប្រយ័ត្ននេះកើតមានពីភាពផ្ទុយគ្នារវាងវត្ថុភ្ញោច និង មជ្ឈដ្ឋាន។

- ចលនា និងបន្លាស់ប្តូរ

**ឧទាហរណ៍ ៖** យុវសិស្សម្នាក់បើកបររថយន្តចង្កូតស្តាំ។ ថ្ងៃមួយយុវជននោះបានទៅធ្វើដំណើរកំសាន្តតាមរថយន្តមិត្តភក្តិរបស់ខ្លួនម្នាក់ ដែលមានចង្កូតឆ្វេង។ ពេលដែលមិត្តរបស់គេមិនស្រួលខ្លួនយុវជននោះត្រូវបើករថយន្តជំនួស ជាហេតុដែលធ្វើឲ្យគេកើតមានបម្រុងប្រយ័ត្នមិនបានគ្រោងទុកមុន ពេលដូរល្បឿន និងពេលបត់បែន។

- ទំនាក់ទំនងគ្នារវាងវត្ថុភ្ញោច និងទំនោររបស់បុគ្គលម្នាក់ៗ (តម្រូវការ និងចំណង់ចំណូលចិត្ត)។

**ឧទាហរណ៍ ៖** យុវសិស្សម្នាក់ដែលចូលចិត្តសិក្សាផ្នែកអក្សរសាស្ត្រខ្មែរ ពេលដែរយុវសិស្សនោះចូលក្នុងបណ្ណាគារ ឬបណ្ណាល័យ ភ្នែករបស់គេរំពៃតែសៀវភៅនានាដែលពាក់ព័ន្ធនឹងអក្សរសិល្ប៍។

បម្រុងប្រយ័ត្នមិនបានគ្រោងទុកមុន ជាប្រភេទនៃបម្រុងប្រយ័ត្នដែលកើតឡើងដោយគ្មានបំណងគិតទុកមុន គ្មានមធ្យោបាយគិតទុកថានឹងធ្វើឲ្យបានសម្រេច, គ្មានការត្រៀមលក្ខណៈទុកនៅក្នុងមជ្ឈមណ្ឌលនៃសរសៃប្រសាទ ក៏ប៉ុន្តែបម្រុងប្រយ័ត្នបែបនេះក៏មិនកើតនៅក្នុងខ្លួនមនុស្សយូរណាស់ដែរ។

## ខ. បម្រុងប្រយ័ត្នគ្រោងទុកមុន

បម្រុងប្រយ័ត្នគ្រោងទុកមុន ជាប្រភពបម្រុងប្រយ័ត្នដែលបញ្ជាក់ចំណាត់ការដោយមនសិការរបស់មនុស្ស ហើយប្រព្រឹត្តិទៅតាមផែនការមួយជាកំណត់ ហើយពឹងផ្អែកលើមធ្យោបាយណាមួយដ៏ជាក់លាក់ផង។ បម្រុងប្រយ័ត្នប្រភេទនេះ ត្រូវបានកើតឡើងនៅក្នុងសកម្មភាពការងារ ក្នុងការបង្រៀន, ក្នុងសិក្សា, ពលកម្ម, សិល្បៈ, ល្បែងកំសាន្ត និងកីឡា។ ចរិតលក្ខណៈខាងផ្លូវចិត្តនៃបម្រុងប្រយ័ត្នទុកមុននេះទាមទារឲ្យមនុស្សមានការខិតខំប្រឹងប្រែង ឬយកចិត្តទុកដាក់ប្រកបដោយឆន្ទៈជានិច្ច។

**ឧទាហរណ៍ ៖** យុវសិស្សស្តាប់ និងតាមដានបំណកស្រាយពន្យល់មេរៀនរបស់សាស្ត្រាចារ្យ យ៉ាងយកចិត្តទុកដាក់។ នៅក្នុងមហាសន្និបាតមួយ អ្នកចូលរួមយកចិត្តទុកដាក់ស្តាប់អ្នកឡើងរាយការណ៍យ៉ាងប្រុងប្រយ័ត្ន។ នៅក្នុងការប្រកួតកីឡាបាល់ទាត់ ទស្សនិកជនផ្តោតស្មារតីតាមដានការបណ្តើរបាល់ទៅរកកន្លែងដែលត្រូវទាត់បញ្ចូលទី។ នៅក្នុងសាលមហោស្រព ទស្សនិកជនខំយកចិត្តទុកដាក់ស្តាប់ និង

តាមសម្លឹងតួអង្គដែលមានប្រជាប្រិយភាពជាងគេ។ ក្នុងការបង្រៀនអក្សរសិល្ប៍ សាស្ត្រាចារ្យត្រូវរៀបចំមេរៀនសម្រាប់ពន្យល់សិស្សឲ្យបានល្អ។ ថ្ងៃស្អែកប្រលង ពីរ បីថ្ងៃមុននេះយុវសិស្សម្នាក់ៗបានយកចិត្តទុកដាក់មើលមេរៀនសារឡើងវិញយ៉ាងហ្មត់ចត់។ ទាំងនេះសុទ្ធតែជាបម្រុងប្រយ័ត្នគ្រោងទុកមុន។

បម្រុងប្រយ័ត្នគ្រោងទុកមុនមានសារៈប្រយោជន៍ណាស់ក្នុងការបង្រៀន និងការអប់រំសិស្ស។ សាស្ត្រាចារ្យត្រូវប៉ិនប្រសប់ប្តូរបម្រុងប្រយ័ត្នមិនគ្រោងទុកមុន ឲ្យទៅជាបម្រុងប្រយ័ត្នគ្រោងទុកមុន សំដៅញ៉ាំងការសិក្សារបស់យុវសិស្សឲ្យទទួលបានផលល្អ ហើយម្យ៉ាងទៀតដើម្បីកាត់បន្ថយការនឿយហត់របស់សាស្ត្រាចារ្យ និងសិស្សទៀតផង។

**ឧទាហរណ៍ ៖** ក្នុងមេរៀនជីវវិទ្យាមួយអំពីត្រីក្អែក។ សាស្ត្រាចារ្យបាននាំយកត្រីក្អែកមួយចូលក្នុងថ្នាក់។ លក្ខណៈទាំងមូលរបស់ត្រីក្អែកធ្វើឲ្យសិស្សមានបម្រុងប្រយ័ត្នមិនបានគ្រោងទុក។ លុះដល់សាស្ត្រាចារ្យ ចោទសួរសិស្សថា ៖ ត្រីក្អែកមានព្រុយ, ស្រកា និងកន្ទុយយ៉ាងដូចម្តេច ជាហេតុធ្វើឲ្យយុវសិស្សមានបម្រុងប្រយ័ត្នគ្រោងទុកមុន។

ក្នុងមេរៀនភូមិវិទ្យាមួយ សាស្ត្រាចារ្យបានយកផែនទីពិភពលោកចូលក្នុងថ្នាក់ ហើយណែនាំសិស្សឲ្យរកទ្វីបអាហ្វ្រិក និងទ្វីបអឺរ៉ុប(បម្រុងប្រយ័ត្នគ្រោងទុកមុន)។

ក្នុងការបង្រៀន អក្សរសិល្ប៍អំពីរឿងទុំទាវចប់ ស្រាប់តែសាស្ត្រាចារ្យលើកជាបញ្ហាមួយឲ្យសិស្សដោះស្រាយ "មតិមួយពោលថា ៖ ទុំ និងទាវស្លាប់ព្រោះរឿងស្នេហា មតិមួយទៀតថា ៖ ទុំ និងទាវស្លាប់ព្រោះអរជូន និង ជូនផាន់" តើមតិមួយណាត្រឹមត្រូវជាង ? យុវសិស្សមានបម្រុងប្រយ័ត្នមិនបានគ្រោងទុកមុន ។

បម្រុងប្រយ័ត្នគ្រោងទុកមុន មានវិធីសាស្ត្រដោះស្រាយ និង បង្អែកដាក់លាក់ ។ បម្រុងប្រយ័ត្នប្រភេទនេះមានបំណង, ភារៈកិច្ច , មធ្យោបាយ, តម្រូវការ , ការខិតខំប្រឹងប្រែងប្រកបដោយឆន្ទៈ ហើយមានទំនាក់ទំនងយ៉ាងជិតស្និត ទៅនឹងប្រព័ន្ធសញ្ញាទី២ គឺភាសា ។ អ្នកប្រាជ្ញចិត្តវិទ្យាខ្លះបានហៅ បម្រុងប្រយ័ត្ននេះថា ជាបម្រុងប្រយ័ត្នសកម្ម ឬ បម្រុងប្រយ័ត្នដោយឆន្ទៈ ។

**ឧទាហរណ៍ ៖** ថ្ងៃមួយបុរសម្នាក់បានជិះម៉ូតូជូនគ្រួសារគាត់ទៅផ្សារទិញអីវ៉ាន់ ។ គ្រួសារគាត់បានចូលទៅកន្លែងលក់បន្លែ ត្រី និងសាច់ ។ គាត់ចាំគ្រួសារគាត់នៅខាងក្រៅផ្សារ ។ គ្រួសារគាត់ពាក់អាវក្រហម និងស្លៀកសំពត់ក្រម៉ៅ ។ ដោយរង់ចាំយូរពេកគាត់ផ្តោតអារម្មណ៍សម្លឹងទៅរកអ្នកពាក់អាវក្រហមក្នុងចំណោមមនុស្សដ៏ច្រើនកុះករ ។

ដើម្បីរក្សាបម្រុងប្រយ័ត្នគ្រោងទុកមុន ដែលមានអត្ថប្រយោជន៍ដល់ការបង្រៀន និងការអប់រំឲ្យស្ថិតស្ថេរបានយូរអង្វែង គេគប្បីចាត់ចែងមជ្ឈដ្ឋានជុំវិញតាមបែបណាមួយនោះ កុំឲ្យកើតមាននៅពេលដែលមនុស្សកំពុងផ្តោតស្មារតីទៅលើខ្លឹមសារ ឬ កម្មវិធីដ៏សំខាន់ណាមួយ ដូចជា មូលហេតុពីខាង

ក្រៅមានការលំអរតុបតែង, ពន្លឺភ្លើង, សម្លេង និងមូលហេតុខាងក្នុងខ្លួនមាន សញ្ចេតនាអវិជ្ជមាន, ភាពទាល់ច្រក, កង្វះសេចក្តីក្លាហាន, សេចក្តីអស់សង្ឃឹម ។ល។

**ឧទាហរណ៍ ៖** មិនត្រូវសង់សាលារៀនជិតផ្សារ, ជិតចំណតរថយន្ត, ជិតកន្លែងសិប្បកម្ម ឬ បង្កើតកន្លែងបនពាលាអាវាសែ ឬ ល្បែងស៊ីសងជិតសាលារៀន ។

ឪពុកម្តាយឈ្លោះប្រកែកគ្នាស្ទើររាល់ថ្ងៃ ឬលែងលះគ្នា ឬ សិស្សរស់នៅក្នុងមជ្ឈដ្ឋានមិនល្អក្នុងសង្គម ធ្វើឲ្យសិស្សមានអារម្មណ៍មិនមូលក្នុងការសិក្សា ។

## IV.បន្លាស់ប្តូរបម្រុងប្រយ័ត្នប្រភេទមួយទៅបម្រុងប្រយ័ត្នប្រភេទមួយទៀត

( Transmutations réciproques entre ces deux categories d'attention )

ដូចដែលដឹងរួចមកហើយថា បម្រុងប្រយ័ត្នមិនបានគ្រោងទុកមុន ប្រព្រឹត្តឡើងមិនមែនក្នុងរយៈពេលយូរទេ ក៏ប៉ុន្តែវាក៏មិនតម្រូវឲ្យយើងប្រឹងប្រែងបញ្ចេញថាមពលច្រើនណាស់ណាដែរ ។ រីឯបម្រុងប្រយ័ត្នគ្រោងទុកវិញ វាប្រព្រឹត្តទៅក្នុងរយៈពេលយូរអង្វែង និងមានប្រសិទ្ធិភាពខ្លាំងជាង ប៉ុន្តែវាធ្វើឲ្យយើងមានសភាពធាប់នឿយហត់ ។ យើងគប្បីចេះផ្សារភ្ជាប់រវាងបម្រុងប្រយ័ត្នទាំងពីរប្រភេទនេះ ។ យើងអាចផ្សារភ្ជាប់វាបានដោយធ្វើឲ្យបម្រុងប្រយ័ត្នទាំងពីរប្រភេទនេះមានការផ្លាស់ប្តូរពីប្រភេទមួយទៅប្រភេទមួយទៀត ។

បម្រុងប្រយ័ត្នគ្រោងទុកមុនអាចផ្លាស់ប្តូរឲ្យទៅជាបម្រុងប្រយ័ត្នមិនគ្រោងទុកមុនបាន។ នៅពេលចាប់ផ្តើមសិក្សាអត្ថបទអំណានមួយ សិស្សខិតខំប្រឹងប្រែងផ្ចង់ស្មារតីទៅលើភារៈកិច្ចរបស់ខ្លួនក្នុងអំណានដើម្បីកំណត់បាននូវចំណេះដឹង ដែលត្រូវក្តាប់យកតាមរយៈនៃវិធីអំណាន ។ ក៏ប៉ុន្តែបន្តិចម្តងៗសិស្សមានទម្លាប់តាមរយៈការហ្វឹកហាត់ ហើយវាទទួលបានជោគជ័យ ទៅជាខ្លឹមសារនៃអត្ថបទក្នុងសៀវភៅ ហើយបម្រុងប្រយ័ត្នបានក្លាយទៅជាមានលក្ខណៈអចន្ទៈវិញ ពីព្រោះបម្រុងប្រយ័ត្នស្ថិតនៅក្រោមការបញ្ជាដាច់ខាតតាមលក្ខណៈពិសេសរបស់វត្ថុប៉ុណ្ណោះ។ បន្លាស់ប្តូរនៃបម្រុងប្រយ័ត្នអាចកើតមានឡើង នៅពេលណាដែលសិស្សបោះជំហានចូលក្នុងការសិក្សាមុខវិជ្ជាថ្មីមួយទៀត ( ឧទាហរណ៍ ភាសាបរទេស ) ដែលបណ្តាលមកពីភាពថ្មីស្រឡាងនៃវត្ថុភ្ញោច។ បន្តិចម្តងៗតាមការភ្ញាក់រលឹកចំពោះអត្ថប្រយោជន៍នៃការសិក្សាមុខវិជ្ជាថ្មីនេះ បានជំរុញឲ្យសិស្សមានការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ធ្វើឲ្យវិធីសិក្សានោះ មានភាពកាន់តែសុក្រឹតឡើងដើម្បីសម្រេចតាមគោលដៅរបស់ខ្លួន។

បន្លាស់ប្តូរនៃបម្រុងប្រយ័ត្ននេះ មានភាពចាំបាច់ណាស់នៅក្នុងលំនាំនៃការអប់រំ ការបង្រៀន និង ការសិក្សា។ នៅក្នុងវិធីបង្រៀនឲ្យសិស្សដោះស្រាយបញ្ហាត្រូវពឹងផ្អែកលើលក្ខណៈនៃបម្រុងប្រយ័ត្ន ដែលគ្រោងទុកមុននេះឯង។ នៅពេលចាប់ផ្តើមមេរៀន សិស្សត្រូវបំពេញភារកិច្ចដោះស្រាយបញ្ហាដែលសាស្ត្រាចារ្យចោទឡើង។ ក្នុងរយៈពេលក្រោយៗមកទៀត សិស្សមានទម្លាប់ក្នុងការហ្វឹកហ្វឺន ហើយទទួលជោគជ័យបាន តាមរយៈភាពសមហេតុផលក្នុងដំណោះស្រាយបញ្ហា ហើយបម្រុងប្រយ័ត្នរបស់សិស្សក្លាយទៅជាមានលក្ខណៈទៅតាមធម្មជាតិ ហើយស្ថិតនៅបានយូរអង្វែង។

## V. **លក្ខណៈជាមូលដ្ឋានគ្រឹះនៃបម្រុងប្រយ័ត្ន** ( Propriétés fondamentales )

បម្រុងប្រយ័ត្នធន្ទៈ និង បម្រុងប្រយ័ត្នអធន្ទៈ មានលក្ខណៈពិសេសមួយចំនួន ដែលអាចធ្វើឲ្យគេញែកដាច់ពីគ្នាបានយ៉ាងងាយ។ វាជាការសំខាន់ណាស់ ដើម្បីស្គាល់ច្បាស់អំពីលក្ខណៈពិសេសទាំងនេះ ពីព្រោះសកម្មភាពនីមួយៗរបស់ពួកយើង ទាមទារនូវប្រភេទនៃបម្រុងប្រយ័ត្នដ៏សមស្រប ហើយបុគ្គលម្នាក់ៗមានលក្ខណៈពិសេសផ្សេងៗគ្នា ខាងបម្រុងប្រយ័ត្ននេះ។

### ១. **ការផ្តោតស្មារតីប្រុងប្រយ័ត្ន**

ការផ្តោតស្មារតីប្រុងប្រយ័ត្ននេះ គឺជាការប្រើប្រាស់ចំណាំងទៅលើមជ្ឈដ្ឋាន ឬបញ្ហាអ្វីមួយ ដែលមានព្រំដែនកំណត់ច្បាស់លាស់។ ដរាបណាដែលការផ្តោតស្មារតីប្រុងប្រយ័ត្នកាន់តែខ្លាំង ដរាបនោះការឆ្លុះបញ្ចាំងបានទៅលើបញ្ហាអ្វីមួយក៏កាន់តែច្បាស់ឡើងដែរ។ ការផ្ចង់ស្មារតីប្រុងប្រយ័ត្ននេះ ត្រូវបានបកស្រាយពន្យល់តាមរយៈការកកើតឡើងនូវរំញោចយ៉ាងខ្លាំង ត្រង់តំបន់ណាមួយនៃខួរក្បាល រីឯមជ្ឈដ្ឋានដែលស្ថិតនៅក្បែរតំបន់នេះជាមជ្ឈដ្ឋានដែលកាត់បន្ថយរំញោចនោះ។

**ឧទាហរណ៍ ៖** វិចិត្រករ រ៉ូដាំង ភ្លេចគិតដល់មិត្តភ័ក្តិរបស់គាត់ ដែលនាំគ្នាទៅមើលរូបចម្លាក់ដែលគាត់កំពុងឆ្លាក់ ពីព្រោះគាត់កំពុងតែផ្ចង់ស្មារតីរបស់គាត់ ដើម្បីនឹងឆ្លាក់រូបសំណាកមួយដែលមិនទាន់បានល្អ។

### ២. **ចំណែកនៃបម្រុងប្រយ័ត្ន**

ការបែកខ្ញែកនៃស្មារតីប្រុងប្រយ័ត្នកើតមានឡើងនៅពេលណា ដែលមនុស្សប្រើសតិផ្ចង់បម្រុងប្រយ័ត្នទៅលើវត្ថុ ឬ សកម្មភាពជាច្រើន ក្នុងពេលជាមួយគ្នា។

**ឧទាហរណ៍៖** នៅពេលបកស្រាយពន្យល់មេរៀនសាស្ត្រាចារ្យត្រូវផ្តោតស្មារតីប្រុងប្រយ័ត្នទៅលើខ្លឹមសារនៃមេរៀនផង ទៅលើអាកប្បកិរិយារបស់សមូហភាពសិស្សក្នុងថ្នាក់ផង និងការប្រើប្រាស់សម្ភារៈឧបទេសផងដែរ។

បទពិសោធន៍បានបង្ហាញឲ្យដឹងថា បម្រុងប្រយ័ត្នមិនបែកខ្ញែកផងទេ នៅក្នុងអំពើដែលកើតឡើងបញ្ច្រាសគ្នា។ អំពើណាមួយនៅក្នុងចំណោមអំពើទាំងនោះ តែងតែមានឥទ្ធិពលខ្លាំងក្នុងការទាក់ទាញបម្រុងប្រយ័ត្ន រីឯអំពើផ្សេងទៀតមិនខ្លាំងក្លា ត្រូវបានក្លាយទៅជាអំពើបន្ទាប់បន្សំ ។ ដើម្បីនឹងសម្រួលដល់ការបែកខ្ញែកនៃបម្រុងប្រយ័ត្ន ដែលកើតឡើងនៅលើអំពើដ៏ច្រើននេះ គេត្រូវឲ្យអំពើខ្លះនៃអំពើទាំងអស់នោះ ក្លាយទៅជាមានភាពស្និទ្ធស្នាល និងមានលក្ខណៈស្វ័យប្រវត្តិ ដើម្បីងាយស្រួលដល់ការផ្តោតស្មារតីប្រុងប្រយ័ត្នទៅលើអំពើទាំងឡាយ ដែលទើបនឹងលើកឡើងថ្មី។

**ឧទាហរណ៍ ៖** អ្នកវាយអង្គុលីលេខ ឬវាយកុំព្យូទ័រ ដោយគ្រាន់តែប្រើភ្នែកសម្លឹងមើលអត្ថបទ ដែលត្រូវវាយចម្លងប៉ុណ្ណោះ រីឯម្រាមដៃរបស់គេ មានចលនារស់រវើក ក្នុងការវាយតួអក្សរទៅ តាមលក្ខណៈស្វ័យប្រវត្តិ ។

សិស្សដែលតាមដានស្តាប់សាស្ត្រាចារ្យពន្យល់ផង និង ប្រើកត់ត្រាខ្លឹមសារមេរៀនផង បាន ផ្តោតស្មារតីយ៉ាងខ្លាំងខាងការស្តាប់ចាប់បាន រីឯដៃសរសេរមានលក្ខណៈស្វ័យប្រវត្តិ ជាស្រេច។

### ៣. ទំហំនៃបម្រុងប្រយ័ត្ន

គឺជាចំនួននៃវត្ថុបំណង ដែលបម្រុងប្រយ័ត្នក្រសោបយកបានក្នុងពេលជាមួយគ្នា ហើយ នឹងកម្រិតឆ្លុះបញ្ចាំងដែលមានភាពស្មើគ្នាផង។ ទំហំនៃបម្រុងប្រយ័ត្នជាអនុគមន៍ចំនួនវត្ថុបំណងនោះ ។ លក្ខណៈនៃបម្រុងប្រយ័ត្នបែបនេះមានភាពចាំបាច់ណាស់សម្រាប់គ្រូបង្រៀន និងសាស្ត្រាចារ្យ ពីព្រោះគាត់ត្រូវផ្តោតស្មារតីប្រុងប្រយ័ត្នទៅលើហេតុជាច្រើនពេលព្រមគ្នា កាលណាគាត់បកស្រាយពន្យល់នៃមេរៀនណាមួយ ។ គេអាចធ្វើទៅបានលុះត្រាតែគេមានបទពិសោធន៍ជាច្រើន ហើយធ្លាប់ស្គាល់វត្ថុបំណងទាំងនោះទៀតផង ។

### ៤. លំនឹងនៃបម្រុងប្រយ័ត្ន

គឺជាសតិ ដែលផ្ទង់ស្មារតីប្រុងប្រយ័ត្នទៅលើវត្ថុបំណងមួយ ឬ វត្ថុច្រើននៅក្នុងរយៈពេលមួយ ដ៏យូរបង្គួរ ដោយគ្មានគិតដល់ដំណើរប្រែប្រួលនៃវត្ថុបំណងផ្សេងទៀត។

**ឧទាហរណ៍ ៖** សិស្សបឋមសិក្សាអាចផ្ទង់ស្មារតីប្រុងប្រយ័ត្នស្តាប់គ្រូពន្យល់មេរៀន ក្នុងរយៈពេលពី ១០ ទៅ ១៥ នាទី។ សិស្សអនុវិទ្យាល័យអាចផ្ទង់ស្មារតីបានពី ២០ ទៅ ២៥ នាទី។ សិស្ស វិទ្យាល័យអាចផ្ទង់ស្មារតីពី ៤៥ ទៅ ៥០ នាទី។

### ៥. បម្លាស់បម្រុងប្រយ័ត្ន

បម្លាសបម្រុងប្រយ័ត្ន គឺជាសតិដែលផ្ទង់ស្មារតីប្រុងប្រយ័ត្នទៅលើវត្ថុបំណងមួយ ហើយផ្លាស់វត្ថុបំណងនោះឲ្យទៅជាករណីនៃតម្រូវការថ្មី តាមវត្ថុបំណងមួយផ្សេងទៀត។ សតិនេះមិនអាចមានគ្រប់គ្នាទេ។ មានសិស្សខ្លះក្នុងករណីផ្លាស់ប្តូរការសិក្សាពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត ជួបការលំបាកយ៉ាងខ្លាំងក្នុងការផ្លាស់ប្តូរបម្រុងប្រយ័ត្ន។ រីឯសិស្សខ្លះទៀតផ្តោតស្មារតីប្រុងប្រយ័ត្នយ៉ាងងាយបំផុត ទៅលើការសិក្សាមុខវិជ្ជាថ្មី តាំងពីនាទីដំបូងម្ល៉េះ។

សភាពបែបនេះ មិនមែនផ្ទុយនឹងស្ថេរភាពនៃបម្រុងប្រយ័ត្នទេ ហើយវាក៏ខុសប្លែកផងដែរពីការបែកខ្ញែកនៃបម្រុងប្រយ័ត្ន។ បម្រុងប្រយ័ត្នចាកចោលយ៉ាងងាយបំផុតពីវត្ថុបំណងចាស់ ដើម្បីផ្តោតមកលើបំណងថ្មីតាមកម្លាំងដដែល។ សតិបែបនេះមានសភាពចាំបាច់ណាស់សម្រាប់សិស្សនៅក្នុងមេរៀនសង្កេត និង ការធ្វើពិសោធន៍។

## VI. ការអប់រំបម្រុងប្រយ័ត្ន និងការប្រយុទ្ធតទល់នឹងភាពរាយមាយ

(Education de l’attention et lutte contre la distraction)

បម្រុងប្រយ័ត្នកើតមានអស់មួយជីវិតផ្លូវចិត្តរបស់មនុស្ស។ វាជាលក្ខខណ្ឌមួយដ៏សំខាន់ និងចាំបាច់សម្រាប់សកម្មភាពទាំងឡាយរបស់យើង។ វារឹតតែមានតួនាទីចាំបាច់ថែមទៀតនៅក្នុងការសិក្សារបស់សិស្ស។ បើគ្មានបម្រុងប្រយ័ត្ន នោះក៏គេមិនអាចទទួលចំណេះដឹងបានដែរ ហើយការបង្ហាត់របស់សាស្ត្រាចារ្យចំពោះសិស្សច្បាស់ជាខ្វះប្រសិទ្ធភាពមិនខាន។ ហេតុដូច្នេះហើយបានជាគេ មិនគ្រាន់តែយកចិត្តទុកដាក់នឹងខ្លឹមសារ ដ៏ត្រឹមត្រូវតាមលក្ខណៈវិទ្យាសាស្ត្រ និងវិធីដែលទាក់ទាញបម្រុងប្រយ័ត្នរបស់សិស្សប៉ុណ្ណោះទេ ប៉ុន្តែគេត្រូវយកចិត្តទុកដាក់ដល់ការអប់រំបម្រុងប្រយ័ត្ននោះទៀតផង។ រីឯលក្ខខណ្ឌនៃការអប់រំឲ្យមានបម្រុងប្រយ័ត្នល្អ មានដូចខាងក្រោម៖

១- គប្បីណែនាំសិស្សឲ្យមើលឃើញនូវចំណង់ចំណូលចិត្តដ៏ធំធេង និងយូរអង្វែង ទៅលើវត្ថុបំណងរបស់បម្រុងប្រយ័ត្ន។

២-គប្បីហ្វឹកហ្វឺនសិស្សឲ្យមានទម្លាប់ក្នុងការប្រកាន់យកនៅបម្រុងប្រយ័ត្នប្រកបដោយឆន្ទៈ (បម្រុងប្រយ័ត្នគ្រោងទុកមុន) ទៅវត្ថុ ឬបាតុភូតដែលលើកមកសិក្សា។ ការហ្វឹកហ្វឺនបម្រុងប្រយ័ត្ននេះត្រូវប្រព្រឹត្តទៅនៅក្នុងស្ថានភាពមួយមិនសូវល្អ ប្រយោជន៍ដើម្បីឲ្យសិស្សរៀនពុះពារឧបសគ្គ។

**ឧទាហរណ៍៖** ទម្លាប់សិស្សជម្នះសូរសទ្ទខ្ញុំខ្ញារ ឬបទភ្លេងនៅជុំវិញខ្លួនក្នុងពេលដែលតម្រូវឲ្យសិស្សផ្ដោតស្ដាប់បំណកស្រាយពន្យល់ពីបញ្ហាអ្វីមួយ។ ទម្លាប់ឲ្យសិស្សផ្ចង់ស្មារតីប្រុងប្រយ័ត្នជានិច្ចទៅលើការងារ ឬកិច្ចការដែលត្រូវធ្វើ។ នៅទីបំផុត គប្បីណែនាំសិស្សឲ្យស្ដាប់ពីលក្ខណៈពិសេសផ្ទាល់ខ្លួនម្នាក់ៗចំពោះបម្រុងប្រយ័ត្ន ដើម្បីផ្នែកល្អអភិវឌ្ឍឡើង និងប្រយុទ្ធតទល់នឹងផ្នែកអាក្រក់។ជំណាលពេលគ្នានឹងការអប់រំបម្រុងប្រយ័ត្ន យើងគួរតែប្រយុទ្ធតទល់នឹងភាពរាយមាយផងដែរ។ ភាពរាយមាយ គឺជាកង្វះខាតផ្ចង់ស្មារតីប្រុងប្រយ័ត្នទៅវត្ថុ បាតុភូត ឬខ្លឹមសារមេរៀនដែលមានភារៈកិច្ចដែលត្រូវលើកមកសិក្សា។ តាមធម្មតាគេតែងតែចាត់ទុកភាពរាយមាយនេះថា ផ្ទុយនឹងបម្រុងប្រយ័ត្ន។ តាមពិតភាពរាយមាយនេះ កើតមានឡើងទៅតាមទម្រង់ដូចតទៅនេះ ៖

ការបែកខ្ញែកនៃបម្រុងប្រយ័ត្ន នេះគឺជាតថភាពដ៏ខ្សត់ខ្សោយបំផុត ក្នុងការផ្ចង់ស្មារតីប្រុងប្រយ័ត្ន ឬក៏ជាបម្រុងប្រយ័ត្ន ដែលកើតមានឡើងមិនសូវជាយូរប៉ុន្មាន ទៅលើវត្ថុបំណងមួយ ដែលគេបានកំណត់រួចមកហើយ ហើយនោះគឺជាកង្វះខាតខាងរបៀបចាត់ចែង នៅក្នុងបំណែកចែក និងដំណើរប្រព្រឹត្តទៅ ឬការប្រែប្រួលរបស់បម្រុងប្រយ័ត្ននោះផង។

ឧទាហរណ៍ ស្វាបហិមៗ។

ភាពរាយមាយរបស់អ្នកប្រាជ្ញ នោះគឺជាការផ្ដោតស្មារតីប្រុងប្រយ័ត្នយ៉ាងខ្លាំងទៅលើក្របខ័ណ្ឌដែលមានព្រំដែនកំណត់ច្បាស់ ហើយនឹងការបាត់បង់បម្រុងប្រយ័ត្នទាំងស្រុង ទៅលើទិដ្ឋភាពដែលនៅសេសសល់ ឬជាទិដ្ឋភាពបន្ទាប់បន្សំពីព្រំដែនកំណត់នោះ។ លំងប់ទៅលើបញ្ហាមួយ ឬប្រធានបទណាមួយ ជាមូលហេតុនាំឲ្យមានភាពរាយមាយនេះតែម្ដង។

**ឧទាហរណ៍៖** លោក Newton ផ្តោតស្មារតីទៅលើការស្រាវជ្រាវរបស់គាត់ខ្លាំងពេករហូតដល់ទៅមិនដឹងថា គាត់ហូបបាយហើយឬនៅ? ករណីបែបនេះ ដូចគ្នានឹងលោក Rodin ដែរ ដែលភ្លេចស្វាគមន៍មិត្តភក្តិដែលគាត់បានអញ្ជើញឲ្យមកទស្សនារោងជាងចម្លាក់របស់គាត់។ លោក Archimède ងើបចេញពីអាងមុជទឹកភ្លេចស្លៀកខោ ពាក់អាវ ដោយគាត់ផ្តោតស្មារតីទៅលើរបកគំហើញរបស់គាត់។

ភាពរាយមាយបណ្តាលមកពីជម្ងឺ (Distraction pathologique) នោះគឺជាកង្វះសមត្ថភាពក្នុងការផ្តោតស្មារតីប្រុងប្រយ័ត្ន ដោយមូលហេតុមានជម្ងឺ ភាពទន់ខ្សោយកម្លាំង និងការនឿយហត់ផ្នែកសរសៃប្រសាទ។ ទម្រង់នីមួយៗនៃភាពរាយមាយនេះអាចត្រូវប្រយុទ្ធតទល់ ឬកម្រិតវាបាន ដោយប្រើវិធានការណ៍ដ៏សមស្របគឺករណីទី១ ការងារសតិអារម្មណ៍ករណីទី២ លំហាត់ និងការហ្វឹកហ្វឺន រីឯករណីទី៣ ត្រូវរកគ្រូពេទ្យព្យាបាលទើបបាន។

គួរឲ្យកត់សម្គាល់ថា តាមទស្សនៈជាច្រើនបានឲ្យដឹងថា ការងារប្រើកម្លាំងកាយ គឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធិភាព ក្នុងការធ្វើឲ្យបម្រុងប្រយ័ត្នអភិវឌ្ឍឡើង ហើយនេះក៏គឺជាមធ្យោបាយប្រយុទ្ធតទល់នឹងភាពរាយមាយផងដែរ។

# សំណួរ

១- ចូរឲ្យនិយមន័យ និងឧទាហរណ៍របស់បម្រុងប្រយ័ត្ន។

២- រកឧទាហរណ៍ ពាក់ព័ន្ធនឹងបម្រុងប្រយ័ត្នគ្រោងទុកមុន និងឧទាហរណ៍មួយទៀត ទាក់ទិននឹងបម្រុងប្រយ័ត្នមិនបានគ្រោងទុកមុន។

៣- ចូរនិយាយត្រួសៗ ពីតួនាទីរបស់បម្រុងប្រយ័ត្ន ក្នុងការបង្រៀន និងការសិក្សា។

៤- ធ្វើដូចម្ដេច ដើម្បីឲ្យសិស្សមានបម្រុងប្រយ័ត្នក្នុងម៉ោងបង្រៀន?

# មេរៀនទី៩ ៖ ភាសា ( Langue )

ᨢ

## I - សញ្ញាណទូទៅ

**ក** -ដោយសារការងារពលកម្ម ភាសាគឺជាលក្ខណៈពិសេសជាមូលដ្ឋានគ្រឹះមួយ ដែលញែកមនុស្សឲ្យដាច់ស្រឡះពីសត្វ។ មុនដំបូងបង្អស់ គេគប្បីញែកដាច់ស្រឡះរវាងភាសារបស់ជាតិមួយ និង ភាសារបស់បុគ្គលម្នាក់ៗ ។

### ខ - និយមន័យ

ភាសារបស់ជាតិមួយជាប្រព័ន្ធនៃសញ្ញាដែលស្តែងចេញជាពាក្យ។ ជាតិនីមួយៗ ឬ ក្រុមជនជាតិនីមួយៗ មានភាសាកំណើតផ្ទាល់របស់ខ្លួន។

**ឧទាហរណ៍:** ប្រជាពលរដ្ឋខ្មែរនិយាយភាសាខ្មែរ ប្រជាពលរដ្ឋបារាំងនិយាយភាសាបារាំង។ ភាសារបស់បុគ្គលម្នាក់ៗ គឺជាបាតុភូតបុគ្គល ហើយដែលបុគ្គលម្នាក់ៗប្រើប្រាស់នៅក្នុងទំនាក់ទំនង ជា មួយនឹងសមាជិកឯទៀតក្នុងសង្គម។ ភាសារបស់បុគ្គលម្នាក់ៗ គឺជាការប្រើប្រាស់ភាសាជាតិមួយសម្រាប់បុគ្គលម្នាក់ៗ ។

**ឧទាហរណ៍:** ភាសាអ្នកស្រុកនៅខាងសៀមរាបខុសពីភាសាអ្នកស្រុកខាងតាកែវបន្តិចបន្តួច។ ភាសាអ្នកស្រុកនៅខាង អម្លាំង ព្រៃក្មេង ខុសពីភាសាអ្នកស្រុកនៅខាង បែកចាន ឬ ថ្នល់ទទឹង។

ដូច្នេះ យើងឃើញថា ភាសា ជា:

- មធ្យោបាយនៃចំណងទាក់ទងគ្នាក្នុងសង្គម។
- ឧបករណ៍នៃសកម្មភាពបញ្ញារបស់មនុស្ស។
- សកម្មភាពផ្លូវចិត្ត
- លំនាំមួយដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងលំនាំនៃចំណេះដឹង ជាពិសេសគឺការគិត។

ប្រជាជាតិនីមួយៗ ឬក៏ក្រុមជនជាតិភាគតិចនីមួយៗសុទ្ធតែមានភាសារបស់ខ្លួន ដែលរួមមានប្រព័ន្ធសូរវិទ្យា គ្រឹះសន្ទានុក្រម វេយ្យាករណ៍ និង បែបបទផ្សេងទៀត ខាងវោហារសាស្ត្រ។ ភាសារបស់មនុស្សមាន ដំណើរវិវត្តទៅតាមពេលវេលា ព្រឹត្តិការណ៍សង្គម និងទស្សនៈរបស់ជាតិ។ ភាសាមួយបង្កើតបានជាបេតិកភណ្ឌ ផ្នែកស្មារតី សម្រាប់ប្រជាជាតិនីមួយៗ។ ភាសារបស់បុគ្គលម្នាក់ៗត្រូវបានបណ្តុះបណ្តាល និងអភិវឌ្ឍឡើងទៅតាមការអភិវឌ្ឍផ្នែកសតិអារម្មណ៍ និងទទួលរងឥទ្ធិពលពីលក្ខណៈពិសេសខាងផ្លូវចិត្តរបស់បុគ្គលម្នាក់ៗ ។ ចិត្តវិទ្យា សិក្សាអំពីភាសារបស់បុគ្គលម្នាក់ៗ មិនមែនសិក្សាពីភាសារបស់ជាតិមួយឡើយ។

### គ - ភាពខុសប្លែកគ្នារវាងភាសារបស់ជាតិ និង ភាសារបស់បុគ្គល

ភាសាជាតិ និងសារបុគ្គល ជាបាតុភូតប្រវត្តិសាស្ត្រ ដែលកើតមានឡើងនៅក្នុងការងារពលកម្ម ក្នុងសកម្មភាពផ្សេងៗរបស់មនុស្ស និងក្នុងទំនាក់ទំនងផ្នែកស្មារតីក្នុងសង្គម។ ក្នុងទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក បុគ្គលម្នាក់ៗតែងតែទទួលព័ត៌មានយ៉ាងច្រើនពីអ្នកដទៃ ហើយផ្តល់ព័ត៌មានទៅអ្នកដទៃវិញ តាមរយៈភាសានេះឯង។ ដូច្នេះ ភាសា ជាឧបករណ៍សម្រាប់ទំនាក់ទំនង រវាងបុគ្គល និង បុគ្គលក្នុងសង្គម។

## ឃ. ភាសា ជាមធ្យោបាយដ៏សំខាន់សម្រាប់ជួយមនុស្សឲ្យធ្វើមធ្វើសកម្មភាពពិសេសគឺ ការគិត

ក្នុងសង្គមសត្វ យើងឃើញថាសត្វចេះឆ្លើយតបទៅនឹងរំញោចក្នុងមជ្ឈដ្ឋានជុំវិញខ្លួនវា តាមរយៈបទពិសោធន៍ ដោយពឹងផ្អែកលើប្រព័ន្ធរ៉េផ្លិចមានលក្ខខណ្ឌ និងរ៉េផ្លិចឥតលក្ខខណ្ឌ។ មនុស្សខុសពីសត្វត្រង់ដែលមនុស្សមានមនសិការ និង ភាសានេះឯង។ ភាសាជាឧបករណ៍សម្រាប់ជួយឲ្យមនុស្ស គិតទុកជាមុនពី ផែនការការងារក្នុងគោលដៅធ្វើឲ្យបានសម្រេចនូវសកម្មភាពណាមួយ។ មនុស្សប្រើប្រាស់ភាសា ដើម្បីប្រៀបធៀបលទ្ធផលដែលខ្លួនសម្រេចបានក្នុងសកម្មភាពមួយទៅនឹងបំណងប្រាថ្នា ដែលគេបានគ្រោងទុកពីមុន។ គ្មានភាសាសង្គមមនុស្ស ក៏គ្មានការអភិវឌ្ឍដែរ។ តថភាពសត្យានុម័តតែងតែបង្កឲ្យបុគ្គលម្នាក់ៗជួបប្រទះនឹង ស្ថានភាពមានបញ្ហាជានិច្ច។ បុគ្គលត្រូវបង្កើតកម្មវិធីនៃទង្វើ ដើម្បីប្រឈមមុខដោះស្រាយបញ្ហា។ ភាសាជា ឧបករណ៍ដ៏សំខាន់ដែលជួយមនុស្សឲ្យបង្កើតបាន និង សម្រេចបាន តាមកម្មវិធីនៃទង្វើនេះ។

បុគ្គលម្នាក់មិនគ្រាន់តែមានទំនាក់ទំនងជាមួយអ្នកដទៃក្នុងសង្គម តែតាមរយៈការគិតរបស់ខ្លួនប៉ុណ្ណោះទេប៉ុន្តែបុគ្គលថែមទាំងមាន ឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ ចិត្តរំភើប សញ្ចេតនា ឆន្ទៈ បំណង សេចក្តីប្រាថ្នា ទៀតផង។ ដោយសារភាសា អ្វីៗដែលមនុស្សឆ្លុះបញ្ចាំងបានក្លាយទៅជាមានការភ្ញាក់រលឹកក្នុងខ្លួនមនុស្ស។

**ឧទាហរណ៍:** គ្រាប់ខ្សាច់មួយធ្លាក់ចូលទៅក្នុងភ្នែករបស់យើង ➔ ធ្វើឲ្យយើងមានរ៉េផ្លិចឥតលក្ខខណ្ឌយើងបិទភ្នែក ➔ នេះជាចំណាំងខ្វះការភ្ញាក់រលឹក។ ប៉ុន្តែកាលណាបុគ្គលស្រែកថា គ្រាប់ខ្សាច់មួយចូលក្នុងភ្នែកខ្ញុំ ➔ រំញោច និង ចម្លើយនោះក្លាយទៅជាចំណាំងប្រកបដោយការភ្ញាក់រលឹក។

ដោយសារភាសា បុគ្គលម្នាក់ៗទទួលបាននូវបទពិសោធន៍ ដែលមានលក្ខណៈជាសង្គមប្រវត្តិរបស់ មនុស្សជាតិ ហើយប្រែក្លាយបទពិសោធន៍នោះឲ្យទៅជាបទពិសោធន៍ផ្ទាល់ខ្លួនវិញ។ យោលទៅតាមគុណសម្បត្តិនៃឧបករណ៍របស់ការគិត និង ឧបករណ៍នៃទំនាក់ទំនង ភាសាបានក្លាយទៅជាមធ្យោបាយមួយសម្រាប់ធ្វើឲ្យមនសិការសំរុះសំរួលបាន ចំពោះអាកប្បកិរិយារបស់បុគ្គល។

### ខ - និយមន័យទូទៅ

ភាសាបុគ្គលជាលំនាំផ្លូវចិត្ត ដែលជួយមនុស្សឲ្យប្រែក្លាយបាននូវអ្វីៗ ដែលគេបានឆ្លុះបញ្ចាំងពីពិភពខាងក្រៅខ្លួនគេ ឲ្យទៅជាសំភារៈតាមផ្លូវបំពង់សម្លេង ដោយធ្វើឲ្យវាមានមនសិការ និង អាចផ្ទេរវាទៅឲ្យអ្នកដទៃយល់ដឹងបាន។

## II - ចលនការសរីរៈវិទ្យានៃសកម្មភាពភាសាបុគ្គល

សកម្មភាពនៃភាសារបស់បុគ្គល គឺជាសកម្មភាពរំញ្ជិចដែលឈរលើមូលដ្ឋានរបស់ប្រព័ន្ធសញ្ញាការទី២។ ចំពោះមនុស្សធម្មតា ប្រព័ន្ធសញ្ញាការទី២នេះ រួមមានការប្រទាក់គ្នានៃសរសៃប្រសាទក្នុងមួយរយៈពេល ដែលបង្កើតឡើងដោយសកម្មភាពចលករ (និយាយ) សកម្មភាពនៃសំណេរ (សរសេរ) សកម្មភាពនៃការស្តាប់ (យល់ សំដីនិយាយ) និង សកម្មភាពមើលឃើញ (យល់សំណេរ)។ មជ្ឈមណ្ឌលសរសៃប្រសាទ ដែលបញ្ជាសកម្មភាពទាំងនេះ ស្ថិតនៅក្នុងសំបកខួរក្បាល ដូចជា សំបកខួរក្បាលត្រង់តំបន់ថ្ងាស ជាតំបន់ផ្តើមចេញនូវចលនារបស់បុគ្គល និង សំបកខួរក្បាលត្រង់ម្ដុំសៀតផ្កា ជាតំបន់ផ្តើមចេញនូវការយល់ភាសានិយាយ។ បណ្តុំនៃសរសៃប្រសាទដ៏វែង ដែលកើតឡើងផ្ទួនៗទៅលើវត្ថុ ឬ បាតុភូតមួយដោយប្រើពាក្យសម្រាប់កំណត់ ដើម្បីផ្សាយចេញជាសំដី (និយាយ) និង ការស្តាប់ឮ "ពាក្យ" របស់វត្ថុ ឬ បាតុភូត ដែលគេកំណត់នោះ។ ដូច្នេះពាក្យបានក្លាយទៅជា រូបតំណាងនៃវត្ថុ ឬ បាតុភូត ពោលគឺសញ្ញាដែលគេចាប់ផ្តើមប្រើចំពោះវត្ថុ ឬ បាតុភូតនោះ។ ជាផលវិបាក ប្រព័ន្ធប្រទាក់គ្នានៃសរសៃប្រសាទលើសំបកខួរក្បាលនេះផ្សារភ្ជាប់គ្នានូវពាក្យដែលគេប្រើចំពោះវត្ថុ ឬ បាតុភូត ណាមួយនោះ ហៅថា ប្រព័ន្ធសញ្ញាការទី២។ រីឯប្រព័ន្ធសញ្ញាការទី១ គឺជាប្រព័ន្ធដែលឆ្លុះបញ្ចាំងពិភពខាងក្រៅរបស់ វត្ថុ និង បាតុភូត តាមរយៈសរីរាង្គឥន្ទ្រីយ៍។ គេអាចនិយាយបានថា ភាសាបុគ្គល គឺជាប្រព័ន្ធសញ្ញាការទី២។ ដូច្នេះ គេអាចបកស្រាយពន្យល់ពីសកម្មភាពភាសារបស់បុគ្គលបាន តាមរយៈការផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធរវាងប្រព័ន្ធសញ្ញាការទី១ និង ប្រព័ន្ធសញ្ញាការទី២ របស់មនុស្ស ពីព្រោះមានតែមនុស្សទេ ដែលមានភាសានិយាយ។ ភាសាកើតឡើងពីការងារពលកម្មក្នុងសង្គម និង តម្រូវការនៃទំនាក់ទំនងក្នុងការងារនេះឯង។

ការត្រួតត្រាលើធម្មជាតិ ដែលចាប់ផ្តើមឡើងតាមរយៈដំណើរការអភិវឌ្ឍនៃចលនាដៃរបស់មនុស្ស និង ការងារពលកម្ម បានបើកទូលាយឲ្យមនុស្សម្នាក់ៗមានវឌ្ឍនភាពឥតព្រំដែន។ ចំពោះវត្ថុនៅក្នុងធម្មជាតិវិញ មនុស្សនៅតែរកឃើញកម្មសិទ្ធិថ្មីរបស់ខ្លួនជានិច្ច។ ម្យ៉ាងវិញទៀត ដំណើរអភិវឌ្ឍនៃការងារក្នុងសង្គមចាំបាច់ឲ្យមនុស្សរួមសាមគ្គីគ្នាក្នុងសង្គម ដោយបង្កើនឡើងនូវសាមគ្គីភាព ការជួយយកអាសារគ្នាទៅវិញទៅមក កិច្ចសហការរួមគ្នា ដោយធ្វើឲ្យបុគ្គលម្នាក់ៗ មានមនសិការយល់ដឹងច្បាស់ពីអត្ថប្រយោជន៍នៃកិច្ចរួមសហការគ្នានេះ។ សរុបសេចក្តីមក មនុស្សដែលគេបណ្តុះបណ្តាលក្នុងសង្គម នឹងឈានដល់ទស្សនៈមួយ ដែលគេចេះជួយគ្នាទៅវិញទៅមក និង ចេះប្រាស្រ័យទាក់ទងគ្នាពីបញ្ហាផ្សេងៗ តាមរយៈភាសាបុគ្គល។

**ឧទាហរណ៍:** ការពិភាក្សាគ្នា ដើម្បីដោះស្រាយបញ្ហាការងារក្នុងសង្គម។

## III - សកម្មភាពភាសាបុគ្គល

### ១ - បញ្ញត្តិសកម្មភាពនៃភាសារបស់បុគ្គល

សកម្មភាពនៃភាសារបស់បុគ្គល គឺជាលំនាំនៃការប្រើប្រាស់ភាសារបស់បុគ្គលម្នាក់ៗ ដើម្បីប្រាស្រ័យ ទាក់ទងគ្នាទៅវិញទៅមក និង ប្រមូលផ្ដុំបទពិសោធន៍ដែលមានលក្ខណៈជាសង្គមប្រវត្តិ ពីសមាជិកសង្គម ម្នាក់ៗ សំដៅសម្រេចនូវសកម្មភាពណាមួយ តាមកម្មវិធីកំណត់។ ភាសាបុគ្គលជាមធ្យោបាយនៃទំនាក់ទំនង។ រីឯសកម្មភាពភាសារបស់បុគ្គលវិញ គឺជាលំនាំប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកក្នុងសង្គម។ សកម្មភាពនៃភាសារបស់បុគ្គលមានទិដ្ឋភាពពីរយ៉ាងគឺ ការបន្លឺសម្លេង និង ការយល់អត្ថន័យនៃសម្លេង។

### ក - ការបន្លឺសម្លេង

មនុស្សត្រូវការបន្លឺសម្លេងនៅពេលដែលមនុស្សចាប់ផ្ដើមចេញពីការគិត (នៅក្នុងខួរក្បាល) ទៅជាភាសានិយាយ (ការបញ្ចេញសម្លេងតាមរយៈបំពង់ខ្យល់ កន្លើត និង អណ្ដាត)។ លំនាំនៃការចាប់ផ្ដើមពីការគិតទៅការនិយាយនេះកើតមានឡើងនៅពេលណាដែលមនុស្សម្នាក់ៗ ត្រូវការនិយាយ ឬ ប្រាស្រ័យទាក់ទងពីបញ្ហាអ្វីមួយ ទៅកាន់មនុស្សម្នាក់ទៀត ឬ មនុស្សច្រើនគ្នា។

**ឧទាហរណ៍:** និស្សិត A និយាយទៅកាន់និស្សិត B ថា : ឯងក្ដៅស្អុះទេ ? ឯងស្រេកទឹកឬទេ ? ម៉ោងប៉ុន្មានហើយ ? ដល់ម៉ោងសម្រាកហើយឬនៅ ? នេះជាប្រត្យក្សារម្មណ៍នៃការបន្លឺសម្លេង។

### ខ - ការយល់អត្ថន័យនៃសម្លេង

ការយល់ពីអត្ថន័យនៃសម្លេងនេះ ជាលំនាំមួយដែលផ្ទុយពីការបន្លឺសម្លេង។ លំនាំនេះកើតឡើងក្រោយការបន្លឺសម្លេង។ ការយល់អត្ថន័យនៃសម្លេងជាលំនាំផ្លូវចិត្តមួយ ដែលឆ្លុះបញ្ចាំងពីបរិមាណនៃអត្ថន័យរបស់ព័ត៌មានដែលចេញពីមាត់របស់បុគ្គលម្នាក់ទៀត។ លំនាំនេះប្រព្រឹត្តទៅជាវិជ្ជមានក្រោមរូបភាពពីរយ៉ាងគឺ :

- តាមរយៈប្រត្យក្សារម្មណ៍ច្បាស់លាស់ពីការបន្លឺសម្លេង។

**ឧទាហរណ៍:** និស្សិត A សួរទៅនិស្សិត B ថា: ថ្ងៃសៅរ៍នេះ ឯងទៅស្រុកឬទេ ? និស្សិត B ឆ្លើយថា: គ្នាមិនទាន់ទៅទេ ព្រោះម្ដាយគ្នាទើបនឹងមក។

នេះជាប្រត្យក្សារម្មណ៍យល់ច្បាស់ពីការបន្លឺសម្លេង។

- ការយល់បានពីខ្លឹមសារនៃភាសារបស់បុគ្គល ពោលគឺយល់ច្បាស់ពីខ្លឹមសារ ដែលគេផ្សព្វផ្សាយនោះ ដោយផ្សារភ្ជាប់ទៅនឹងបទពិសោធន៍ផ្ទាល់ខ្លួន។

**ឧទាហរណ៍:** និស្សិត X សួរទៅនិស្សិត Y ថា: " ម៉េចបានជាឯងមករៀនយឺតអញ្ចឹងថ្ងៃនេះ ? "

និស្សិត Y ឆ្លើយថា: " គ្នាជាប់ជួយជញ្ជូនឥវ៉ាន់ម៉ាក់យកទៅដាក់លក់ក្នុងផ្សារ " ។

និស្សិត X ស្ដាប់ឮយល់សំដីរបស់និស្សិត Y ព្រោះគេធ្លាប់ឆ្លងកាត់បទពិសោធន៍ជួយសមាជិកគ្រួសាររបស់គេ ក្នុងការលក់ដូរនៅទីផ្សារដែរ។

នៅពេលណាដែលគេទទួលប្រត្យក្សារម្មណ៍ច្បាស់លាស់ ពីភាសារបស់បុគ្គលម្នាក់ នោះគេអាចធ្វើវិភាគ ធ្វើទូទៅកម្ម ឬ ធ្វើការប្រៀបធៀបទៅលើភាសានិយាយរបស់បុគ្គលម្នាក់ទៀតបានតាមរយៈកាយវិការ ឬ សកម្មភាព។

**ឧទាហរណ៍:** នៅពេលធ្វើសិក្ខាសាលាមួយស្តីពីការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា អ្នកធ្វើបទអត្ថាធិប្បាយ ជាជនជាតិអង់គ្លេស។ គាត់និយាយភាសាអង់គ្លេសតាមរយៈអ្នកបកប្រែភាសាខ្មែរម្នាក់ ទៅកាន់សមាជិកចូលរួមសិក្ខាសាលា។ សមាជិកអង្គសិក្ខាសាលាមិនអាចយល់ភាសាអង់គ្លេសបានទាំងអស់គ្នាទេ។ គេអាចយល់បានតាមរយៈអ្នកបកប្រែជាភាសាខ្មែរប៉ុណ្ណោះ។

សរុបសេចក្តីមក ក្នុងសកម្មភាពភាសារបស់បុគ្គលមានលំនាំពីរបដិបក្ខនឹងគ្នា: ការគិតមកជាភាសាក្រៅ ហៅថា ការបន្លឺសម្លេង ហើយលំនាំកែប្រែភាសាក្រៅទៅជាភាសាក្នុង ឬ ទៅជាការគិត ដោយភ្ជាប់ជាមួយនឹងបទពិសោធន៍របស់បុគ្គល គេហៅថា " ការយល់អត្ថន័យនៃសម្លេង "។

## ២ - ទម្រង់សកម្មភាពភាសារបស់បុគ្គល

តាមទស្សនៈចិត្តវិទ្យា គេសង្កេតឃើញភាសាមានទម្រង់ពីរយ៉ាង គឺភាសាក្នុង និង ភាសាក្រៅ។ ភាសាក្រៅ ចែកចេញជាភាសានិយាយ និង ភាសាសរសេរ។

### ២.១ - ភាសាក្រៅ

#### ២.១ - ១ ភាសានិយាយ

ភាសានិយាយ គឺជាទម្រង់ភាសាដែលកើតឡើងមុនគេបង្អស់។ ភាសានិយាយ និងភាសាសន្ទនា មានលក្ខណៈពិសេសដូចតទៅ:

- ភាសានិយាយអាចត្រូវបំពេញឲ្យខ្លី ដោយសារតែមធ្យោបាយផ្សេងទៀត នៃការសំដែងចេញរបស់មនុស្សដូចជា កាយវិការ ទឹកមុខ ការធ្មេចភ្នែក សំណើច ... ។
- ភាសានិយាយច្រើនតែបង្កើតបានជាប្រតិកម្ម ដូចជាសំដីរបស់បុគ្គលម្នាក់ដែលនិយាយណែនាំ បុគ្គលម្នាក់ទៀត ដែលជាគូសន្ទនា។
- ភាសានិយាយប្រែប្រួលទៅតាមកាលៈទេសៈ ហើយផ្សារភ្ជាប់ទៅនឹងកម្មវត្ថុ ដែលគេលើកមកនិយាយ ឬ សន្ទនា។
- ភាសាសន្ទនាជាភាសាដែលគេនិយាយចេញពីមាត់ ដោយមិនគ្រោងទុក។ ជាទូទៅភាសាសន្ទនាជារចនាសម្ព័ន្ធនៃភាសាមួយ ដែលមានលក្ខណៈរៀបចំមិនបានត្រឹមត្រូវទៅតាមឃ្លាប្រយោគ ហើយគេគ្រាន់តែប្រើឃ្លា ឬ ប្រយោគដ៏ងាយៗប៉ុណ្ណោះ។
- ភាសាឯកវាទ រីកចំរើនពីភាសាសន្ទនា។ ភាសាឯកវាទ កើតឡើងអាស្រ័យដោយមានតម្រូវការផ្សព្វផ្សាយព័ត៌មាន ឬ ដំណឹងផ្សេងៗដល់មហាជន។ ដោយសារតម្រូវការនៃទំនាក់ទំនង និង ព័ត៌មាន ចេះតែមានកម្រិតកើនឡើង ទម្រង់ផ្សេងៗនៃភាសាឯកវាទមានដំណើរការ

អភិវឌ្ឍយ៉ាងខ្លាំងនាបច្ចុប្បន្ននេះ ដូចជា ការនិទានរឿង ការធ្វើរបាយការណ៍ ការថ្លែងសន្ទរកកថា ការធ្វើបឋកថា ការធ្វើសន្និសិទ ការពន្យល់មេរៀន។

### ២.១ - ២ ភាសាសរសេរ

ភាសាសរសេរ ត្រូវបានបង្កើតឡើង ដោយផ្តើមចេញពីភាសានិយាយ តម្រូវការនៃការស្តែងចេញជា ពាក្យសំដី ឬ ការផ្ទេរព័ត៌មានឲ្យទៅអ្នកដទៃ។ ភាសាក្នុងអភិវឌ្ឍឡើងបាន ដោយឈរលើមូលដ្ឋាននៃភាសានិយាយប៉ុណ្ណោះ។ ភាសាសរសេរជាភាសាដែលស្ថិតនៅពីក្រោមភាសានិយាយ។ នៅក្នុងដំណាក់កាលដំបូងនៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ មនុស្សមានតម្រូវការក្នុងការចងចាំព័ត៌មានបានយូរ ដើម្បីយកទៅផ្សព្វផ្សាយដល់ក្រុមមនុស្សដែលនៅឆ្ងាយដាច់ស្រយាល។ ភាសាសរសេរជាភាសាដែលគេគិតទុកមុន។ ភាសាសរសេរជាភាសាដែលមនុស្សមានតម្រូវការរក្សាទុក នូវពាក្យសំដីរបស់ខ្លួនឲ្យបានយូរនៅក្នុងឯកសារ ឬ តាម

រយៈសៀវភៅសិក្សាសម្រាប់មនុស្សជំនាន់ក្រោយ។ តម្រូវការនេះហើយដែលធ្វើឲ្យលេចឡើងនូវអក្ខរវិធីរបស់ជនជាតិ អេហ្ស៊ីប ក្នុងសម័យបុរាណ ដែលប្រើសញ្ញាជាតំណាងឲ្យវត្ថុនានា ឬ អត្ថន័យផ្សេងៗ ។ សំណេរនោះប្រើជារូបភាពនៃនិមិត្តសញ្ញាផ្សេងៗ ហើយត្រូវគេប្រើប្រាស់ក្នុងរយៈដ៏យូរក្នុងប្រវត្តិសាស្ត្រ តាមលក្ខណៈពិបាកយល់ឲ្យបានត្រូវ។ ក្រោយមកសំណេរនោះ ត្រូវបានបកស្រាយពន្យល់ ឲ្យមានអំណានច្បាស់ក្នុងឆ្នាំ ១៨២២ ដោយអ្នកប្រាជ្ញ ខាងភាសាម្នាក់ ដែលជាជនជាតិបារាំង ឈ្មោះលោក Champollion ( 1790 – 1832 ) ។

បន្ទាប់មកគេប្រើអក្សរគំនិត ដែលជាតំណាងឲ្យដោយត្រង់ៗតែម្តង ទៅលើគំនិតតាមរយៈសញ្ញា ដែលជាតំណាងឲ្យវត្ថុ។ នោះគឺជាករណីនៃតួអក្សរក្នុងភាសាចិន។ គេបានកំណត់សញ្ញា ឬ ឲ្យទៅជា សញ្ញាសរសេរ រួចមកទើបគេបង្កើតអក្សរឡើង។

**ឧទាហរណ៍:** មុនដំបូងបង្អស់ គេបង្កើតសញ្ញាតាមរយៈអក្សរគំនិត ដូចជា៖




នៅទីបំផុត ប្រព័ន្ធអក្ខរក្រមផ្សេងៗក៏ចាប់ផ្តើមកើតមានឡើង។ នោះគឺជាប្រព័ន្ធនៃសំណេរ ដែលពឹងផ្អែកលើអក្ខរក្រម។ អក្សរនីមួយៗមិនគ្រាន់តែតំណាងឲ្យគំនិតមួយប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងតំណាងឲ្យ សម្លេងមួយទៀតផង ( ស្រះផ្សំ និង ព្យញ្ជនៈ )។ នេះគឺជាប្រព័ន្ធនៃកំណត់ត្រាសម្លេងតាមរយៈសទ្ទសាស្ត្រ។

ការបង្កើតសំណេរតាមលក្ខណៈអក្ខរក្រម បានបង្កលក្ខណៈងាយស្រួលយ៉ាងខ្លាំងដល់ដំណើរអភិវឌ្ឍផ្នែកវប្បធម៌របស់មនុស្សជាតិ។ ភាសាសរសេរ មិនមែនជាការប្រាស្រ័យទាក់ទងដោយផ្ទាល់ទៅគូសន្ទនាឡើយ។ ភាសាសរសេរទាមទារឲ្យមានការប្រិតប្រៀនផ្នែកគំនិត ឬ ទស្សនៈយ៉ាងខ្លាំង។ ភាពស្រឡះល្អ ការបញ្ជាក់ច្បាស់ និង ការចងក្រងគំនិត ត្រូវផ្សារភ្ជាប់គ្នាទៅតាមទម្រង់មួយដ៏ត្រឹមត្រូវ និងយ៉ាងសុក្រឹតក្នុងសំណេរ។

### ២.១ - ៣ ភាសាក្នុង

ភាសាក្នុង គឺជាទម្រង់អត្ថិភាពនៃគំនិតរបស់មនុស្ស។ ភាសាក្នុងមានរចនាសម្ព័ន្ធដូចគ្នានឹងភាសាក្រៅដែរ។ ក៏ប៉ុន្តែភាសាក្នុងមានលក្ខណៈបំព្រួញខ្លីជាងភាសាក្រៅច្រើនណាស់។ ភាសាក្នុងប្រព្រឹត្តទៅនៅក្នុងសន្ទុះដ៏ខ្លាំងក្លា ទើបមានលទ្ធភាពតាមដានចលនានៃការគិតបាន។

ដូច្នេះមេរៀនដ៏វែងអន្លាយ អាចរំលឹកឡើងវិញក្នុងរយៈពេលដ៏ខ្លីបាន ឬ ក៏ការរៀបចំក្នុងរយៈពេលពីរបីនាទីជាការគ្រប់គ្រាន់ ចំពោះសន្ទរកថាមួយដ៏វែងអន្លាយ ហើយឥតបានគ្រោងទុកជាមុន។ ចំពោះភាសាក្នុង ឃ្លាប្រយោគទាំងឡាយមានលក្ខណៈសាមញ្ញទាំងអស់។ ភាសាក្នុងមានតែប្រធានបទ កន្សោមកិរិយា និង ពាក្យពីរបីម៉ាត់ប៉ុណ្ណោះ ហើយអាចមានបរិមាណនៃព័ត៌មានយ៉ាងច្រើនសន្ធឹកសន្ធាប់។ ភាសាក្នុងទទួលលទ្ធផលតាមរយៈការស្តែងចេញរបស់ភាសាក្រៅ។ កាលណាគេនិយាយ ឬ គេសរសេរ ភាសាក្នុងនេះស្តែងចេញមកក្រៅតាមរយៈភាសាផ្ទាល់មាត់ ឬ ភាសាសរសេរ។ ភាសាក្នុងជាភាសាដែលគេគិតក្នុងចិត្ត តែមិនទាន់បញ្ចេញមកក្រៅ។ ភាសាក្នុងជាទម្រង់របស់ការគិត។

## IV - តួនាទីរបស់ភាសាបុគ្គល

### ក - នៅក្នុងសកម្មភាពនៃចំណេះដឹង

ភាសារបស់បុគ្គលផ្សារភ្ជាប់យ៉ាងស្និទ្ធស្នាលបំផុត ទៅនឹងមនសិការរបស់បុគ្គលអស់មួយជីវិតផ្លូវចិត្ត។ សតិនៃភាសាបុគ្គល ត្រូវបានឆ្លងកាត់បទពិសោធន៍នៅក្នុងជីវភាពសង្គម។ កុមារដែលរស់នៅក្នុងសង្គមសត្វក្នុងវ័យទាបបំផុតនឹងមិនចេះនិយាយភាសាមនុស្សទេ។ មនសិការរបស់កុមារបែបនេះ (ករណីកុមារី Amala និង Kalama) មិនមានការអភិវឌ្ឍតាមធម្មជាតិឡើយ។ ដំណើរការអភិវឌ្ឍផ្លូវចិត្តរបស់មនុស្សផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងដំណើរការអភិវឌ្ឍផ្នែកភាសា។

បញ្ញត្តិ ការវិនិច្ឆ័យ ការពិចារណា ព្រមទាំងរូបតំណាង និងប្រត្យក្សារម្មណ៍ សុទ្ធតែជាទម្រង់នៃចំណាំងរបស់តថភាពសត្យានុម័តនៅក្នុងមនសិការរបស់មនុស្ស ហើយកើតមានតែនៅក្នុងភាសារបស់បុគ្គលប៉ុណ្ណោះ។ តាមពិតប្រត្យក្សារម្មណ៍ក្លាយទៅជាមានអត្ថន័យចំពោះភាសា និងចំពោះពាក្យសំដីដែលគេនិយាយ។ អនុស្សាវរីយ៍ត្រូវបានគេរំលឹកឡើងវិញ ទៅតាមពេលវេលាតាមរយៈភាសាបុគ្គលនេះឯង។ ដោយ សារភាសាបុគ្គល អរូបីយ៍កម្ម ដែលជាចលនាដ៏សំខាន់របស់ការគិត ត្រូវបានមនុស្សធ្វើកើតទាំងអស់។

ភាសាផ្តល់នូវសំភារៈរូបឲ្យរូបារម្មណ៍។ លើសពីនេះទៅទៀត ភាសាក៏ផ្តល់នូវស្លាបសម្រាប់ហោះហើរឲ្យរូបារម្មណ៍ដែរ។

ជាផលវិបាក គ្រូបង្រៀន និងសាស្ត្រាចារ្យ គប្បីតាមដានឲ្យបានហ្មត់ចត់ដល់ដំណើរការអភិវឌ្ឍផ្នែកភាសារបស់សិស្សម្នាក់ៗ ពីព្រោះភាសាជាឧបករណ៍ដ៏មានតម្លៃសម្រាប់វិស័យក្តាប់យកចំណេះដឹង។

### ខ - នៅក្នុងចិត្តរំភើប និង សញ្ចេតនា

សញ្ចេតនាកើតចេញពីបាតុភូតនៃទំនាក់ទំនងខាងផ្នែកភាសា រវាងមនុស្ស និង មនុស្សក្នុងសង្គម។ ការសំដែងចេញនូវសញ្ចេតនារបស់មនុស្ស ធ្វើឡើងតាមរយៈកាយវិការ ហើយជាពិសេសតាមរយៈពាក្យសំដី និង ភាសាបុគ្គលនេះឯង។ សញ្ចេតនាជះឥទ្ធិពលយ៉ាងខ្លាំងមកលើការនិយាយលើកដាក់នៃសម្លេង និង របៀបនិយាយ។ ពាក្យសំដីសំដែងចេញនូវការសប្បាយរីករាយ ភាពកក់ក្តៅ កំហឹង សម្អប់ និង សេចក្តីក្រៀមក្រំក្នុងចិត្ត។

ភាសាបុគ្គលក្នុងឋានៈជាឧបករណ៍នៃទំនាក់ទំនងក្នុងសង្គម ក៏ក្លាយទៅជាឧបករណ៍នៃការចុះសម្រុងគ្នាក្នុងសង្គមដែរ។

ដូច្នេះ គ្រូបង្រៀន និងសាស្ត្រាចារ្យ គប្បី៖

- យកចិត្តទុកដាក់ធ្វើឲ្យភាសារបស់សិស្ស និងយុវសិស្ស ឲ្យមានភាពកាន់តែសុក្រឹតឡើង។
- ធ្វើឲ្យភាសាក្នុងការសន្ទនា និង អំណាន ប្រកបដោយការចេះលើកដាក់សម្លេង។
- ធ្វើឲ្យភាសាក្នុងការប្រាស្រ័យទាក់ទងក្នុងសង្គមមានលក្ខណៈល្អប្រណីត ទៅតាមកាលៈទេសៈ និង បរិយាកាសសង្គម។
- បង្រៀនសិស្ស និង យុវសិស្ស ឲ្យចេះសំដែងចេញនូវសញ្ចេតនា តាមរយៈពាក្យសំដីដ៏សមស្រប និង ប្រកបដោយលក្ខណៈគួរសម។

### គ - នៅក្នុងឆន្ទៈ និង អំពើឆន្ទៈ

ភាសាបុគ្គលមានតួនាទីសំខាន់ណាស់នៅក្នុង ការសំដែងចេញនូវឆន្ទៈ និង ការឆ្លើយឲ្យបានសម្រេចនូវអំពើឆន្ទៈ។ ឥរិយាបថរបស់បុគ្គលនៅក្នុងដំណោះស្រាយបញ្ហា ឬ ការញញើតស្ទាក់ស្ទើរក្នុងចិត្ត គឺជាការឈានដល់នៃការតស៊ូដ៏យូរអង្វែងក្នុងទឹកចិត្ត ដែលមិនមានអ្វីក្រៅពីការគិតដោះស្រាយក្នុងខ្លួនឯង ឬ ការប្រៀបធៀបគំនិត ដែលស្តែងចេញក្រោមរូបភាពនៃភាសាបុគ្គល។ ការសម្រេចបាននូវអំពើឆន្ទៈ ត្រូវពឹងផ្អែកលើបទពិសោធន៍ ដែលគេបានឆ្លងកាត់ និង ចំណេះដឹងថ្មី ដែលស្ថិតនៅក្រោមរូបភាពនៃភាសាប៉ុណ្ណោះ។

ដូច្នេះលើរាល់សកម្មភាពផ្លូវចិត្តរបស់មនុស្សមិនអាចកាត់ផ្តាច់ពីភាសាបានឡើយ ព្រោះភាសាបុគ្គល ជា៖

- ឧបករណ៍នៃទំនាក់ទំនងក្នុងសង្គម។
- ឧបករណ៍នៃទំទួលយកចំណេះដឹង និងបទពិសោធន៍។
- ការសំដែងចេញនូវសញ្ចេតនា និង ឆន្ទៈ ។

លក្ខណៈទាំងបីប្រភេទនេះហើយ ដែលកំណត់បាននូវលក្ខណៈពិសេសដោយឡែកនៃភាសារបស់បុគ្គល ម្នាក់ៗ

## V - ភាសារបស់បុគ្គល និង ការធ្វើវិក្រឹតការលើភាសាបុគ្គល

**ក** - ចំពោះបុគ្គលម្នាក់ និង បុគ្គលម្នាក់ទៀត ការខុសប្លែកគ្នានៃភាសាអាស្រ័យដោយធាតុទាំងឡាយដូចតទៅ:

- សូរវិទ្យា: សម្លេង ការលើកដាក់សម្លេង ថាមពលនៃសម្លេង សង្វាក់នៃការបញ្ចេញសម្លេង។ ភាសាបុគ្គល អាចមានលក្ខណៈច្បាស់លាស់ បង្អួសវែង គ្រលរ ស្រួយស្រេះ ត្រូវតាមសង្វាក់ ឬ អោក់អ្រួល។
- សន្ទានុក្រមៈ វាក្យស័ព្ទអាចមានលក្ខណៈសំបូរបែប ឬ ខ្សត់ខ្សោយ ជាភាសាជាតិសុទ្ធសាធ ឬ ប្រើតាមភាសាបរទេស ច្បាស់លាស់ ឬ ទូលំទូលាយ។
- វេយ្យាករណ៍ និង វោហារសាស្ត្រ ការសំដែងចេញជាភាសាបុគ្គលអាចត្រឹមត្រូវ ឬ មិនត្រឹមត្រូវ តាមក្បួនវេយ្យាករណ៍ សាមញ្ញងាយយល់ ឬ មានតម្លៃខ្ពស់ សំបូរដោយរូបារម្មណ៍ ឬ សោះកក្រោះ ពិរោះស្តាប់ ឬ គំរោះគំរើយ។
- គុណភាពនៃព័ត៌មានៈ ព័ត៌មានដែលគេទទួលបានតាមរយៈភាសាបុគ្គលអាចមានលក្ខណៈសំបូរបែប ឬ ខ្សត់ខ្សោយអត្ថន័យ សង្ខេបខ្លីងាយយល់ ឬ វែងអន្លាយឥតន័យ។

ការខុសប្លែកគ្នានេះ ក៏ពឹងផ្អែក ឬ អាស្រ័យដោយរចនាបថនៃភាសារបស់បុគ្គលថែមទៀតដែរ។ តាមទស្សនៈនេះគេបែងចែកភាសាបុគ្គលទៅតាមៈ

- រចនាបថនៃភាសាសន្ទនារាល់ថ្ងៃ
- រចនាបថនៃភាសាសិល្បៈ
- រចនាបថនៃភាសារដ្ឋបាល
- រចនាបថនៃភាសាវិទ្យាសាស្ត្រ

រចនាបថនេះ អាស្រ័យដោយមនុស្ស។ តាមពិតលើរាល់លក្ខណៈពិសេសដោយឡែករបស់បុគ្គលម្នាក់ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងជិតស្និទ្ធ តាមរយៈភាសារបស់គេ។

**ខ** - ដំណើរការអភិវឌ្ឍ និង ការធ្វើវិក្រឹតការ ទៅលើភាសារបស់បុគ្គល ត្រូវតែយកមកសិក្សានៅក្នុងលំនាំនៃការបង្រៀន និង ការអប់រំសិស្ស។ ការអភិវឌ្ឍ និង ការធ្វើវិក្រឹតការនេះ ត្រូវតែដើរទន្ទឹមគ្នានឹងការលើកកម្ពស់សតិបញ្ញារបស់សិស្ស ការយល់ជ្រួតជ្រាបលើផ្នែកវប្បធម៌ និង ការអភិវឌ្ឍខាងផ្នែកគុណសម្បត្តិនៃសញ្ចេតនា និង ឆន្ទៈ។ គ្មានវិធីណាដោយឡែក សម្រាប់ធ្វើឲ្យអភិវឌ្ឍភាសាបុគ្គល ក្រៅពីវិធីដែលតម្រង់មុខសញ្ញាទៅរកការអភិវឌ្ឍខាងៈ

- ផ្នែកសតិបញ្ញាខាងការពិនិត្យសង្កេត
- ផ្នែកសតិបញ្ញាខាងការត្រិះរិះ
- ផ្នែកសតិបញ្ញាខាងធ្វើឲ្យចំណេះដឹង សញ្ចេតនា និង បទពិសោធន៍ទូទៅសំបូរបែបបាន

ដំណើរការអភិវឌ្ឍ និង ការធ្វើវិក្រឹតការ ទៅលើភាសាបុគ្គល ត្រូវប្រព្រឹត្តទៅតាមលំនាំ និង ដើរតាមវិធីបង្រៀន វិធីអប់រំ និង វិធីសិក្សា។ ភាសាបុគ្គលផ្សារភ្ជាប់ជានិច្ចទៅនឹង:

- បាតុភូតចិត្ត
- លំនាំក្តាប់យកចំណេះដឹង (ការសិក្សា)
- លំនាំនៃការបង្រៀន និង ការអប់រំ
- ចិត្តរំភើប និង សញ្ចេតនា
- ឆន្ទៈ និង អំពើឆន្ទៈ
- ទំនាក់ទំនងការងារក្នុងសង្គម
- ការយល់ជ្រួតជ្រាបខាងផ្នែកវប្បធម៌។

## VI - ភាសា និង បុគ្គលិកលក្ខណៈ

អាកប្បកិរិយារបស់បុគ្គលម្នាក់ៗ មិនមែនស្តែងចេញតាមរយៈវត្ថុជាក់ស្តែងទេ តែវាត្រូវស្តែងចេញតាមរយៈសកម្មភាព និង ទង្វើរបស់បុគ្គលនោះ។ ទន្ទឹមនឹងនេះលក្ខណៈពិសេសនៃបុគ្គលិកលក្ខណៈរបស់បុគ្គលនោះ ក៏ស្តែងចេញឲ្យឃើញដែរ។ អាកប្បកិរិយា និង បុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗមិនដូចគ្នាទេ។

**ឧទាហរណ៍:** បងប្អូនបង្កើតពីរនាក់។ បងមានចិត្តធូន់ ហើយសំដីផ្អែមល្ហែម ចេះជួយយកអាសារអ្នកជិតខាង។ ឯប្អូនមានចិត្តឆេវឆាវ ឆាប់ខឹង សំដីគំរោះគំរើយ ជាមនុស្សមិនអើពើនឹងអ្នកជិតខាង។

### ១ - អត្តចរិត និង ភាសាបុគ្គល

ទំនាក់ទំនងភាសារវាងមនុស្ស និង មនុស្ស ក្នុងសង្គម កើតមានឡើងដោយសារតែមនុស្សមានតម្រូវការ។ ទំនាក់ទំនងបានឆ្លុះបញ្ចាំងឲ្យឃើញជានិច្ច ពីទឹកចិត្តស្មោះត្រង់ អាកប្បកិរិយាសុភាពរាបសារ ចិត្តស្លូតបូត សមានចិត្តល្អ ចិត្តបាន ចិត្តសប្បុរស ។ល។ ទាំងនេះគេចាត់ទុកថា ជាចរិតវិជ្ជមាន។ រីឯចិត្តឆេវឆាវ អំនួត ភាពឥតចេះអៀនខ្មាស គំនិតកេងប្រវញ្ច ត្រូវបានគេចាត់ទុកថា ជាចរិតអវិជ្ជមាន។

ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ពេលមនុស្សប្រាស្រ័យទាក់ទងនឹងគ្នា មនុស្សមានបំណងប្រាប់ដល់គូសន្ទនា ឬ អ្នកដទៃពី ការគិត ចិត្តរំភើប សញ្ចេតនា សំណូមពរ និង ចំណង់ចំណូលចិត្តរបស់ខ្លួន។

អត្តចរិតទាំងនេះ អាចផ្លាស់ប្តូរទៅតាមឫកពា និង ឆន្ទៈរបស់បុគ្គលម្នាក់ៗ ។ សីលធម៌ គុណធម៌ចិត្ត សប្បុរសធម៌ ក៏ស្តែងចេញតាមរយៈភាសារបស់បុគ្គលដែរ។ កាលណាគេសន្ទនាជាមួយអ្នកណាម្នាក់ទៀត គេ អាចដឹងបានថា អ្នកនោះមានទំនុកចិត្តលើខ្លួនឯង ចេះគិតគូរ និង ប្រមាណខ្លួនឯង ហ៊ានទទួល

ខុសត្រូវចំពោះទង្វើខ្លួន ជាមនុស្សស្លូតបូត ឬ ជាមនុស្សមានអំនួត ជាមនុស្សប្រណែននិន្ទាគេ ជាមនុស្សទុយមុយ ឬ ជាមនុស្សចូលចិត្តចំពោះទង្វើណាមួយ។

### ២ - ទំនោរ និង ភាសាបុគ្គល

ទំនោរនៃបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ ត្រូវបានស្តែងចេញតាមរយៈ តម្រូវការ ជំនឿជាក់ឧត្តមគតិ និង ចំណង់ចំណូលចិត្ត។ ទំនោរនៃបុគ្គលិកលក្ខណៈដឹកនាំជម្រើសនៃការតម្រង់ទិស និង ខ្លឹមសារនៃការ សន្ទនា។

ចរិតលក្ខណៈនៃភាសា អាចឆ្លុះបញ្ចាំងបានពីៈ

- សកម្មភាពបញ្ញា និង វិជ្ជាជីវៈ
- កម្រិតវប្បធម៌ និង បទពិសោធន៍ក្នុងវិជ្ជាជីវៈ

ក្នុងវិស័យបង្រៀន និង អប់រំ ភាសាជាមធ្យោបាយដ៏សំខាន់របស់គ្រូបង្រៀន និង សាស្ត្រាចារ្យ។

ដូច្នេះ លោកគ្រូ ឬ លោកសាស្ត្រាចារ្យ ម្នាក់ៗ គប្បីៈ

- ខិតខំបង្កើតអក្ខរាវិរុទ្ធ
- កែលំអរចនាបថភាសារបស់ខ្លួនឲ្យបានច្បាស់លាស់ត្រឹមត្រូវ។
- ធ្វើឲ្យភាសារបស់ខ្លួន ដែលនិយាយទៅកាន់សិស្ស សំបូរដោយរូបារម្មណ៍។

## VII - លំនាំអភិវឌ្ឍនៃភាសារបស់វ័យជំទង់

សតិនៃភាសារបស់ក្មេងអភិវឌ្ឍឡើងដោយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍផ្នែកការគិត រូបារម្មណ៍ រូបតំណាងឆន្ទៈ គុណសម្បត្តិផ្នែកសីលធម៌ និង លំនាំនៃការសិក្សា។ លុះឈានដល់វ័យជំទង់ ក្មេងត្រូវចូលរៀននៅថ្នាក់អនុវិទ្យាល័យ។ ពេលនោះសកម្មភាពសិក្សា ត្រូវបើកទូលាយផ្នែកចំណេះដឹងលើគ្រប់វិស័យ។ ពាក្យបច្ចេកទេស និង បញ្ញត្តិវិទ្យាសាស្ត្រ កម្រិតចំរើនឡើងយ៉ាងឆាប់រហ័សដែរ។ ការយល់ និង ក្តាប់បានប្រព័ន្ធបញ្ញត្តិច្រើនហើយសំបូរបែបតាមលក្ខណៈវិទ្យាសាស្ត្រ ជាហេតុធ្វើឲ្យចលនានៃការគិតរបស់វ័យជំទង់អភិវឌ្ឍឡើងយ៉ាងឆាប់រហ័ស ហើយភាពស្មុគស្មាញក្នុងការយល់ដឹងស៊ីជំរៅទៅលើខ្លឹមសារឯកសារក៏កើតមានដែរ ដូចជា សមត្ថភាពវិភាគ ការធ្វើទូទៅកម្ម អរូបីយ៍កម្ម តំហៀបធៀប ការធ្វើសំយោគ ។ល។

ភាសាជាតិនៅក្នុងថ្នាក់មធ្យមសិក្សា ជួយឲ្យភាសាជំទង់អភិវឌ្ឍឡើងកាន់តែច្បាស់លាស់ ហើយប្រកបដោយរូបភាពផង។ នៅក្នុងវ័យជំទង់នេះ ភាសាក្នុងរបស់សិស្សម្នាក់ៗក៏មានការអភិវឌ្ឍដូចភាសាក្រៅដែរ។ ជំទង់លេចឡើងនូវសញ្ចេតនាថ្មី ការគិតថ្មី និង ឆន្ទៈថ្មី។ ជំទង់ចាប់ផ្តើមចេះវិភាគលើសញ្ចេតនា និង សកម្មភាពរបស់ខ្លួន។ ភាសាក្នុង និង ភាសាក្រៅ ត្រូវបានជំទង់ប្រើប្រាស់ជាមធ្យោបាយសម្រាប់ស្គាល់ វាយ តំលៃ កែតំរូវ និង អប់រំខ្លួនឯង។

## សន្និដ្ឋាន

ជំទង់ជួបប្រទះនឹងគុណវិបត្តិខ្លះ នៅក្នុងការលូតលាស់ផ្នែកភាសាក្នុង និង ភាសាក្រៅ។ គ្រូបង្រៀន និង សាស្ត្រាចារ្យ ត្រូវតាមដានយកចិត្តទុកដាក់ក្នុងការបង្រៀនដល់ជំទង់ ពីបញ្ញត្តិវិទ្យាសាស្ត្រអក្ខរាវិរុទ្ធ និយមន័យ ច្បាប់វិទ្យាសាស្ត្រ ទ្រឹស្តី ឧត្តមគតិ។ ភាសារបស់បុគ្គលមិនគ្រាន់តែជាឧបករណ៍នៃការគិតប៉ុណ្ណោះទេ ប៉ុន្តែភាសាបុគ្គលជាឧបករណ៍នៃទំនាក់ទំនងក្នុងសង្គមទៀតផង។ ភាសាផ្សារភ្ជាប់ជានិច្ចទៅនឹងបាតុភូតផ្លូវចិត្តរបស់បុគ្គល។ ភាសាមានលក្ខណៈឯកភាពគ្នាជាមួយនឹងការរីកចំរើននៃការគិត និង មនសិការរបស់មនុស្ស។ រីឯគុណសម្បត្តិនៃបុគ្គលិកលក្ខណៈរបស់មនុស្សក៏ត្រូវស្តែងចេញ តាមរយៈសកម្មភាពភាសារបស់បុគ្គលផងដែរ។

## សំណួរ

១- ដូចម្តេចហៅថា ភាសាជាតិ ភាសាបុគ្គល ភាសាក្នុង ភាសាក្រៅ?

២- ចូរនិយាយពីតួនាទីនៃភាសា ក្នុងទំនាក់ទំនងសង្គម?

៣- គេអាចទាញសន្និដ្ឋានគរុកោសល្យបានយ៉ាងណាខ្លះ អំពីតួនាទីរបស់ភាសានៅក្នុងការបង្ហាត់បង្រៀន និង អប់រំសិស្ស?

# មេរៀនទី១០ ៖ ការគិត

ៜៜៜ

នៅក្នុងសកម្មភាពប្រតិបត្តិ មនុស្សយើងតែងតែជួបប្រទះនូវបញ្ហាជាច្រើន ដែលទាមទារនូវភាពប៉ិនប្រសប់ និង ភាពប្រញាប់បន្ទាន់ ។ នេះសឲ្យឃើញថា នៅក្នុងតថភាពសត្យានុម័ត ដែលស្ថិតនៅក្នុងមជ្ឈដ្ឋានជុំវិញខ្លួនយើង មានវត្ថុ បាតុភូត និង រឿងរ៉ាវជាច្រើន ដែលយើងមិនស្គាល់ មិនយល់ និង មិនបានដឹងមុន ។ បញ្ហាទាំងនេះ សុទ្ធតែមានលក្ខណៈជាអាថ៌កំបាំងចំពោះយើង។ ដូច្នេះ យើងត្រូវតែស្គាល់ស៊ីជម្រៅកាន់តែខ្លាំងឡើងទៅលើពិភព ដែលនៅជុំវិញខ្លួនយើងដូចជាៈ

- រកឃើញនូវលំនាំថ្មី
- រកឃើញលក្ខណៈថ្មី
- រកឃើញទំនាក់ទំនងថ្មី

បាតុភូត ឬ រឿងរ៉ាវ ដែលស្ថិតនៅក្នុងមជ្ឈដ្ឋានជុំវិញខ្លួនយើង ។

លំនាំនៃចំណេះដឹងនេះ ឈានដល់កម្រិតមួយ ដែលខ្ពស់ជាងលំនាំនៃចំណេះដឹងឥន្ទ្រីយ៍ ហៅថា ការគិត ។

## I- សញ្ញាណទូទៅស្ដីអំពីការគិត

### ១. និយមន័យ

ការគិតគឺជាលំនាំផ្លូវចិត្ត ដែលឆ្លុះបញ្ចាំងពីលក្ខណៈនៃធម្មជាតិ និង ទំនាក់ទំនងខាងក្នុងដែលមានចរិតជាក្រឹត្យក្រមនៃវត្ថុ និង បាតុភូត ដែលស្ថិតនៅក្នុងតថភាពសត្យានុម័ត ហើយដែលពីមុនយើងមិនទាន់បានស្គាល់នៅឡើយ(បានន័យថា ចំណេះដឹងឥន្ទ្រីយ៍មិនអាចឆ្លុះបញ្ចាំងទៅលើវាបាន) ។

ការគិត គឺជាកម្រិតថ្មីនៃចំណេះដឹង បើនិយាយទៅតាមទស្សនៈនៃគុណភាព ដោយប្រៀបធៀបទៅនឹងឥន្ទ្រិយារម្មណ៍ ហើយនឹងប្រត្យក្សារម្មណ៍។ ឥន្ទ្រិយារម្មណ៍ និងប្រត្យក្សារម្មណ៍គ្រាន់តែឆ្លុះបញ្ចាំងបានពីលក្ខណៈ និងទំនាក់ទំនងខាងក្រៅរបស់វត្ថុ និង បាតុភូតប៉ុណ្ណោះ រីឯការគិតវិញវាឆ្លុះបញ្ចាំងបាននូវលក្ខណៈខាងក្នុងនៃធម្មជាតិដែលជាលក្ខណៈមានចរិតក្រិត្យក្រមរបស់វត្ថុ និង បាតុភូតទាំងឡាយ ។

ការគិតក៏ខុសប្លែកគ្នាពីលំនឹកខាងផ្នែកគុណភាពផងដែរ ព្រោះលំនឹកឆ្លុះបញ្ចាំងបានពីអ្វីៗ ដែលយើងធ្លាប់បានដឹងរួចមកហើយ ចំណែកឯការគិតវិញឆ្លុះបញ្ចាំងបាននូវអ្វីៗដែលមានកម្រិតថ្មីស្រឡាង ហើយដែលពីមុនយើងមិនទាន់ស្គាល់នៅឡើយ ។

**ឧទាហរណ៍៖** សាស្ត្រាចារ្យ កែកិច្ចការសិស្ស គាត់យល់ដឹងពីលទ្ធផលនៃការសិក្សារបស់សិស្ស តាមរយៈការគិត ។

- យើងឈឺ ។ យើងទៅរកគ្រូពេទ្យព្យាបាល ។ គ្រូពេទ្យចោទជាសំនួរ។ យើងឆ្លើយប្រាប់គ្រូពេទ្យ។ គាត់អាចដឹងលក្ខណៈរោគតាមរយៈការគិត ។
  - រថយន្តយើងខូច។ យើងបើកទៅរកជាងជួសជុល។ ជាងដឹងពីមូលហេតុនៃការខូចនោះតាមរយៈការគិត។
  - យុវជនម្នាក់ដឹងថា យុវនារីម្នាក់ស្រឡាញ់ ឬ មិនស្រឡាញ់ខ្លួននោះ ដោយវិនិច្ឆ័យទៅលើអាកប្បកិរិយា វាចា និង សកម្មភាពនារីនោះតាមរយៈការគិត ។

**យើងនឹងលើកយកមកសិក្សាវិភាគស៊ីជំរៅ ទៅលើលក្ខណៈនៃការគិតនៅក្នុងផ្នែកផ្សេងៗនៃមេរៀននេះ៖**

## ២. ធម្មជាតិសង្គមនៃការគិត

ការគិតប្រព្រឹត្តទៅនៅក្នុងខួរក្បាលរបស់មនុស្សម្នាក់ ។ ការគិតរបស់មនុស្សម្នាក់ៗ មានលក្ខណៈជាធម្មជាតិនៃសង្គម ។ ធម្មជាតិសង្គមនៃការគិតស្តែងចេញឲ្យឃើញនូវលក្ខណៈទាំងឡាយដូចតទៅ:

- ការគិតរបស់មនុស្សយកភាសាជាមធ្យោបាយ ។ បទពិសោធន៍ជាច្រើនបានបកស្រាយពន្យល់ថា ការគិតរបស់មនុស្សផ្សារភ្ជាប់ទៅនឹងភាសាខាងក្នុងខ្លួនមនុស្ស ។ ភាសាជាផលិតផល ដែលកើតចេញពីជីវភាពរស់នៅក្នុងសង្គម ។ ដូច្នេះការគិតមានលក្ខណៈសង្គមច្បាស់លាស់ណាស់ ។
- បំណិនប្រសប់នៃការគិត និង សតិនៃការសំដែងចេញរបស់ភាសា ត្រូវបានបណ្តុះបណ្តាលឡើងនៅពេលដែលមាន:
  - ដំណើរការប្រព្រឹត្តទៅ នៃការអភិវឌ្ឍផ្នែកប្រវត្តិសាស្ត្រ ។
  - ដំណើរការប្រព្រឹត្តទៅ នៃការផលិតឧបករណ៍ពលកម្ម ។
  - ការប្រើប្រាស់ឧបករណ៍ពលកម្ម ។
  - ទំនាក់ទំនងរវាងមនុស្ស និង មនុស្សក្នុងសង្គម ។
- លើរាល់សមិទ្ធផលនៅក្នុងវិស័យវិទ្យាសាស្ត្រ វិស័យបច្ចេកទេស វិស័យឧស្សាហកម្ម វិស័យកសិកម្ម ។ល។ មិនមែនជាលទ្ធផលនៃការគិតដ៏យូរអង្វែងរបស់បុគ្គលម្នាក់ទេ តែវាជាលទ្ធផលនៃការគិតរបស់មនុស្សជាច្រើននាក់ និង មនុស្សជាច្រើនជំនាន់ ។
- ធម្មជាតិសង្គមនៃការគិត ស្តែងចេញឲ្យឃើញត្រង់ចំណុចដែលថា តើមនុស្សមានភារកិច្ចអ្វីខ្លះក្នុងការតម្រង់ទិសការគិតរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហា ។

អ្នកប្រាជ្ញ និង ពពួកបញ្ញវន្ត ប្រើការគិតច្រើនណាស់ក្នុងវិស័យស្រាវជ្រាវ វិទ្យាសាស្ត្រ ដើម្បីបំរើតម្រូវការរបស់មនុស្សជាតិ ។

## ៣. ការគិតរបស់មនុស្ស និង ការគិតរបស់ម៉ាស៊ីន

សព្វថ្ងៃនេះដោយសារមហាជោគជ័យរបស់វិទ្យាសាស្ត្រ និង បច្ចេកទេស មនុស្សឈានដល់ការផលិតបាននូវម៉ាស៊ីនស្វ័យប្រវត្តិ និង ម៉ាស៊ីនដែលគេអាចបញ្ជាបានច្រើនបែបយ៉ាង។ គេអាចយកសម្ភារៈបច្ចេកទេសទាំងនេះ មកប្រើការបានយ៉ាងរហ័ស ដូចជា ការរកឬសការេ ការបកប្រែភាសា ការវិនិច្ឆ័យរោគសញ្ញា.....។ នៅក្នុងសភាពការបែបនេះ ប្រទេសខ្លះបានយកគ្រឿងម៉ាស៊ីនស្វ័យប្រវត្តិមកប្រើជំនួសកម្លាំងមនុស្សនៅក្នុងខឿនផលិតកម្ម ។ វាជាការពិតហើយព្រោះកម្លាំងម៉ាស៊ីនស្វ័យប្រវត្តិអាចជំនួសកម្លាំងមនុស្សបានយ៉ាងរហ័ស ហើយផលិតផលមានគុណភាពល្អទៀតផង។ ទោះយ៉ាងណាក៏ដោយគ្រឿងម៉ាស៊ីនស្វ័យប្រវត្តិគ្រប់ប្រភេទជាលទ្ធផលនៃការគិតចេញពីខួរក្បាលមនុស្ស ។ គ្រឿងយន្តទាំងអស់មិនអាចផលិតចេញជាគ្រឿងយន្តផ្សេងទៀតបានឡើយ។ វាចាំបាច់ត្រូវការការគិតរបស់មនុស្ស ។ ដូច្នេះបានន័យថា ទោះណាជាគ្រឿងយន្តស្វ័យប្រវត្តិមានប្រាជ្ញាឈ្លាសវៃក្នុងការបំរើឲ្យតម្រូវការរបស់មនុស្សយ៉ាងណាក៏ដោយក៏វាមិនអាចប្រៀបធៀបបានទៅនឹងសមត្ថភាពដ៏អស្ចារ្យនៃការគិតរបស់មនុស្សបានឡើយ ។

- គ្រឿងយន្តស្វ័យប្រវត្តិគ្មានសមត្ថភាពឆ្នៃប្រឌិតឲ្យតម្រូវការរបស់មនុស្សបានឡើយ។ វាមានដំណើរការក្នុងការគិតបាន ក៏អាស្រ័យដោយកម្មវិធីដែលបង្កើតឡើងដោយមនុស្សដែរ ។
- គ្រឿងយន្តជាឧបករណ៍ ដែលគ្មានចិត្តរំភើបដូចមនុស្ស ។
- គ្រឿងយន្តគ្មានសមត្ថភាពព្យាករណ៍បានទៅលើអនាគតកាល ហើយវាក៏មិនអាចសម្របសម្រួលបានទៅតាមស្ថានភាពដែលមនុស្សចង់បានឡើយ ។

## ៤. ចិត្តវិទ្យា តក្កវិជ្ជា និង ទស្សនវិជ្ជា ស្ដីអំពីការគិត

ការគិតគឺជាកម្មវត្ថុនៃការសិក្សារបស់មែកធាងនៃវិទ្យាសាស្ត្រជាច្រើនដូចជា ទស្សនវិជ្ជា តក្កវិទ្យា ចិត្តវិទ្យា ។ ហើយក៏នៅមានវិទ្យាសាស្ត្រខ្លះទៀតក៏ចាត់ទុកបាតុភូតនៃការគិតនេះថា ស្ថិតនៅក្នុងក្របខណ្ឌនៃការ ស្រាវជ្រាវរបស់ខ្លួនដែរ ។

ទស្សនវិជ្ជា សិក្សាពីក្រឹត្យក្រម ដែលមានលក្ខណៈទូទៅបំផុតលើរាល់សកម្មភាពញ្ញាណសក្តិរបស់មនុស្សជាតិ ។ ឈរលើមូលដ្ឋានរបស់គោលការណ៍នៃទស្សនវិជ្ជាដែលមានលក្ខណៈទូទៅបំផុត របស់ទ្រឹស្ដីនៃចំណេះដឹង ការគិតរបស់មនុស្សត្រូវចាត់ទុកថាស្ថិតនៅក្នុងមែកធាងពីររបស់វិទ្យាសាស្ត្ររូបី គឺ តក្កវិជ្ជាទម្រង់ និង ចិត្តវិទ្យា ។

តក្កវិជ្ជាទម្រង់ សិក្សាអំពីទម្រង់ដ៏សមហេតុផលរបស់ការគិត បញ្ញត្តិ ការវិនិច្ឆ័យ និង អនុមាន ពោលគឺវិទ្យាសាស្ត្រនេះសិក្សាអំពីផលិតផលរបស់លំនាំនៃការគិត ។

ចំណែកឯចិត្តវិទ្យាវិញ សិក្សាអំពីលំនាំនៃការគិត ហើយដោយសារតែលំនាំនៃការគិតនេះហើយដែលមនុស្សម្នាក់ៗបណ្ដុះបាននូវគំនិតដែលស្ថិតនៅក្រោមរូបភាពនៃបញ្ញត្តិ ការវិនិច្ឆ័យ និង អនុមាន ។ ដោយលំនាំនៃការគិត និងផលិតផលរបស់វា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងគ្នានឹងគ្នា ចិត្តវិទ្យា និង

តក្កវិទ្យាក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងគ្នាដែរ ហើយបំពេញឲ្យគ្នាទៅវិញទៅមក នៅក្នុងការសិក្សាស្រាវជ្រាវអំពីការគិត ។

ការគិតជាលំនាំនៃចំណេះដឹង ដែលមានកម្រិតខ្ពស់ ។ ការគិតជាសត្តិដ៏មានតំលៃរបស់មនុស្សជាតិព្រោះមានតែមនុស្សទេ ដែលមានការគិត ។ ការគិតអាចធ្វើឲ្យមនុស្សស្គាល់វត្ថុ បាតុភូត និង ធម្មជាតិក្នុងលោកបាន។ ការគិតជួយមនុស្សឲ្យដណ្ដើមត្រួតត្រាពិភពលោកបាន ។ ដោយសាការគិត មនុស្សមិនគ្រាន់តែកែច្នៃខឿនផលិតកម្ម និង ផ្ទៃដីក្នុងពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែគេថែមទាំងដណ្ដើមត្រួតត្រាពីភពអវកាសទៀតផង ។

## II- ចរិតនៃការគិត

ក្នុងឋានៈកម្រិតខ្ពស់បំផុត នៃសកម្មភាពញាណសត្តិ ការគិតរបស់មនុស្សមានចរិតដូចតទៅៈ

### ១. ចរិតចោទជាបញ្ហារបស់ការគិត

ការគិតជាលំនាំផ្លូវចិត្ត ដែលតម្រង់មុខសញ្ញាទៅរកគោលមួយជានិច្ច ។ ភាពចាំបាច់នៃការគិតកើតមាននៅក្នុងជីវភាពរស់នៅ ឬ ក្នុងការប្រតិបត្តិ កាលណាមនុស្សផុសចេញក្នុងគំនិតនូវគោលបំណងថ្មីបញ្ហាថ្មី ស្ថានភាពថ្មី និង លក្ខខណ្ឌ នៃសកម្មភាពថ្មី ។

**ឧទាហរណ៍ៈ** សាស្ត្រាចារ្យជួបប្រទះនឹងករណី ដែលសិស្សម្នាក់ខិតខំព្យាយាមក្នុងការសិក្សាមានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការសិក្សា ហើយឥឡូវនេះស្រាប់តែសិស្សនោះ ឈប់យកចិត្តទុកដាក់ក្នុងការសិក្សា ។ នេះជាបាតុភូតដ៏ចម្លែក ដែលទាមទាឲ្យគ្រូគិតពិចារណាក្នុងករណីនេះ ។

តាមការពិតការគិតកើតមានតែនៅពេលណា ដែលមនុស្សជួបប្រទះនឹងស្ថានភាព ដែលត្រូវកើតឡើងនូវគោលបំណងថ្មី ហើយដែលមធ្យោបាយ និង វិធីចាស់ក្នុងសកម្មភាពដែលធ្លាប់មានពីមុន ធ្វើការមិនបានសម្រេចតាមសំណូមពរនៃគោលបំណង ។ ស្ថានភាពដែលស្រដៀងគ្នាបែបនេះហៅថា ស្ថានភាពចោទជាបញ្ហា ។

ដោយសារសកម្មភាពបញ្ហា ដែលកើតចេញពីស្ថានភាពបញ្ហានេះហើយ បានជាមនុស្សអាចបង្កើតនិងរកឃើញវិធីថ្មី មធ្យោបាយថ្មី ដើម្បីសម្រេចនូវគោលដៅ និង បំពេញសំណូមពរក្នុងតម្រូវការ ។

ការគិតគឺជាការសិក្សាស្រាវជ្រាវ ដែលនាំមនុស្សឲ្យដល់របកគំហើញថ្មី។ ក្នុងករណីដែលបញ្ហាត្រូវបានដោះស្រាយរួចហើយតាមរចនាបថនៃការងារដែលគេធ្លាប់ស្គាល់មកហើយ និង ដោយសារចំណេះដឹងបទពិសោធន៍ដែលគេមាន នោះគេមិនជួបប្រទះនូវស្ថានភាពមានបញ្ហាទេ ហើយនៅពេលនោះឯងគេមិនត្រូវការការគិតឡើយ។

**ឧទាហរណ៍ៈ** សិស្សអនុវិទ្យាល័យម្នាក់ មិនត្រូវការការគិតទេ កាលណាយើងសួរវាថា ពីរគុណ និង ពីរត្រូវជាប៉ុន្មាន?

តាមពិតរំញោចដែលបង្កឲ្យមានការគិតគឺ ស្ថានភាពមានបញ្ហា ប៉ុន្តែស្ថានភាពនេះមិនចាត់ទុកថាជាស្ថានភាពប្រភេទណាទេឲ្យតែចោទជាបញ្ហាឡើងចំពោះមនុស្ស សុទ្ធតែបង្កឲ្យមានរំញោចនៃការគិតទាំងអស់ ។ ដើម្បីបង្កឲ្យមានការគិត ស្ថានភាពមានបញ្ហា ត្រូវឲ្យមនុស្សស្គាល់សិន ហើយស្ថានភាពនោះត្រូវបានប្រែក្លាយ ទៅជាការគិតរបស់មនុស្ស ពោលគឺមនុស្សត្រូវកំណត់បាននូវអ្វីៗ ដែលគេស្គាល់រួចមក ហើយអ្វីៗដែលគេធ្លាប់ជួបប្រទះ និង អ្វីៗដែលគេមិនទាន់បានស្គាល់ ឬ អ្វីៗដែលគេស្វែងយល់ ។ តាមពិតទិន្នន័យទាំងនេះស្ថិតនៅក្រៅក្របខណ្ឌនៃចំណេះដឹងរបស់មនុស្ស។ ការគិតមិនអាចសម្រេចបានឡើយ ។ បានន័យថាសមត្ថភាពនៃការគិតមិនអាចឈានដល់គោលដៅ ។

**ឧទាហរណ៍:** សិស្សត្រូវដោះស្រាយបញ្ហាមួយមាន បួនចំណុច ។ សិស្សដោះស្រាយបានតែពីរចំណុច នៅសល់ពីរចំណុចទៀត សិស្សគ្មានសមត្ថភាពដោះស្រាយបាន ។ នេះគឺជាអសមត្ថភាពនៃការគិត ។

## ២. លក្ខណៈប្រយោលរបស់ការគិត

ការគិតរបស់មនុស្សមានលក្ខណៈជាប្រយោល។ ការគិតស្តែងចេញឡើងតាមរយៈភាសា ។ ការគិតពុំមែនជាចំណាំងផ្ទាល់ដូចឥន្ទ្រិយារម្មណ៍ និង ប្រត្យក្សារម្មណ៍ទេ ។

ឧទាហរណ៍: ខ្ញុំកំពុងដេកលក់ ។ ខ្ញុំពុំដឹងថាមានមេឃភ្លៀងទេ ។ លុះភ្ញាក់ឡើងចេញមកក្រៅផ្ទះ ដោយសំអាងលើសញ្ញាខាងក្រៅទើបខ្ញុំសន្និដ្ឋានថា មេឃភ្លៀងនៅពេលខ្ញុំកំពុងដេកលក់ដោយសំអាងលើដំណក់ទឹកជាប់នៅលើស្លឹកឈើ ដីសើម ។

ការគិតឆ្លុះបញ្ចាំងវត្ថុ ឬ បាតុភូត ដែលប្រព្រឹត្តទៅដោយប្រយោលមកលើសរីរាង្គឥន្ទ្រីយ៍របស់យើង ។ការគិតអាចជួយឲ្យយើងមានសមត្ថភាពយល់ដឹងបានពីលក្ខណៈខាងក្នុងរបស់វត្ថុ និង បាតុភូតដែលសរីរាង្គឥន្ទ្រីយ៍របស់យើងមិនអាចឆ្លុះបញ្ចាំងបាន ។ ដោយសារភាសា យើងអាចស្គាល់ដឹងបានពីអ្វីៗដែលយើងមិនដែលឃើញ មិនដែលឮ ។

**ឧទាហរណ៍:** តើយើងធ្លាប់ឃើញ សមុទ្រខ្សាច់ ឬ សមុទ្រទឹកកក ឬទេ? ដោយសារតែបំណកស្រាយពន្យល់ របស់គ្រូ យើងអាចដឹងស្គាល់ពីសមុទ្រខ្សាច់ ឬ សមុទ្រទឹកកកបាន ។

ការស្គាល់នេះគឺដោយសារភាសា ។ នេះក៏គឺចំណាំងប្រយោលរបស់ការគិត ។ ផលនៃការគិតគឺលទ្ធផលនៃចលនាបន្តបន្ទាប់មួយ ។ ក្រឹត្យក្រម ទំនាក់ទំនងរបកគំហើញរបស់អ្នកប្រាជ្ញ អ្នកគិតរបស់សញ្ជាតិនានាក្នុងសាកលលោកព្រមទាំងបទពិសោធន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗផង គឺជាគន្លឹះសម្រាប់ចំណេះដឹងរបស់គេក្នុងខ្លួនស្តីពីពិភពលោកនៅជុំវិញខ្លួនគេ និង សម្រាប់ដោះស្រាយបញ្ហាដ៏ថ្មីថ្មោងសម្រាប់ខ្លួនគេ ។

**ឧទាហរណ៍:** គ្រូពេទ្យធ្វើការបូកសរុបគ្រប់រោគលក្ខណៈទាំងអស់ ដែលគាត់ដឹងស្គាល់ គាត់វិភាគប្រៀបធៀប និង ធ្វើសំយោគទៅលើរោគលក្ខណៈទៅតាមចំណេះដឹងផ្នែកទ្រឹស្តី និង បទពិសោធន៍ក្នុងការអនុវត្តរបស់គាត់ ។ គាត់ទាញសេចក្តីសន្និដ្ឋានបានទៅលើរោគលក្ខណៈនេះ ។

នៅមានវត្ថុ បាតុភូត ក្នុងករណី មួយចំនួនទៀតដែលយើងមិនអាចគិត ពិនិត្យ ឬ ឆ្លុះបញ្ចាំងវាដោយផ្ទាល់បាន ។ អ្នកប្រាជ្ញវិទ្យាសាស្ត្រ និង បច្ចេកទេសបានផលិតឧបករណ៍ខ្លះសម្រាប់ផលប្រយោជន៍ និង តម្រូវការរបស់មនុស្សជាតិ ដូចជា ទែម៉ូម៉ែត ប្រដាប់វាស់ស្ទង់បន្លាស់ប្តូរសម្ពាធបរិយាកាស កុងទ័រប្រដាប់វាស់ឈាម ។ល។ សព្វថ្ងៃនេះអ្នកប្រាជ្ញបានបង្កើតឧបករណ៍កុំព្យូទ័រ ប្រដាប់វាស់ចលនាបេះដូង និង ខួរក្បាលទៀតផង ។ ករណីទាំងនេះ គឺជាលក្ខណៈចំណាំងប្រយោលរបស់ការគិត ។

## ៣. ចរិតអរូបី និង ចរិតទូទៅរបស់ការគិត

ខុសគ្នាស្រឡះពីចំណេះដឹងឥន្ទ្រីយ៍ ការគិតមិនអាចឆ្លុះបញ្ចាំងបានទៅតាមបែបបទអរូបិយ៍ និងដាច់ដោយឡែកទៅលើវត្ថុ និង បាតុភូតបានឡើយ ។ ការគិតមានសតិមួយសម្រាប់ធ្វើឲ្យមានលក្ខណៈអរូបិយ៍ទៅលើវត្ថុ និង បាតុភូតទាំងឡាយ ចំពោះលក្ខណៈរូបិយ៍ និង លក្ខណៈដោយឡែករបស់វា ហើយចងចាំបានតែចំពោះលក្ខណៈធម្មជាតិរបស់វាតែប៉ុណ្ណោះ គឺលក្ខណៈរួមចំពោះវត្ថុ និង បាតុភូតជាច្រើន ហើយតាមរយៈហេតុការណ៍នេះ ការគិតធ្វើទូទៅកម្មបានទៅលើវត្ថុ និង បាតុភូតដាច់ដោយឡែក ហើយខុសប្លែកគ្នាខាងផ្នែកលក្ខណៈ ធម្មជាតិដោយរៀបចំវាឲ្យស្ថិតនៅទៅតាមក្រុម តាមចំណែកថ្នាក់ ឬ តាមប្រភេទវាផង ។ ពិសេសណាស់ទៅទៀតការគិតមានចរិតអរូបិយ៍ និង ចរិតទូទៅ ។

**ឧទាហរណ៍:** កាលណាយើងគិតដល់ក្តាខៀន គឺកត្តាខៀនទូទៅ ហើមមិនមានក្តាខៀនណាដាក់ស្តែង ឬមានលក្ខណៈដាច់ដោយឡែកឡើយ ។

ចរិតអរូបី និង ចរិតទូទៅរបស់ការគិត មិនគ្រាន់តែជួយមនុស្សឲ្យដោះស្រាយបាននូវបញ្ហាទាំងឡាយក្នុងបច្ចុប្បន្នកាលប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជួយមនុស្សឲ្យគ្រោងទុកបាននូវបញ្ហាទាំងឡាយទៅអនាគតទៀតផង ពោលគឺដោះស្រាយបញ្ហាក្នុងគំនិតបានសម្រាប់ផែនការទៅអនាគត ។

ឧទាហរណ៍: គេក្តាប់បានពីការលូតនៃលោហធាតុដែលស្ថិតនៅក្រោមឥទ្ធិពលនៃស៊ីតុណ្ហភាពដូច្នេះហើយបានជាវិស្វករទុកចន្លោះតូចមួយរវាងចុងសងខាងនៃផ្លូវដែកសម្រាប់រថភ្លើង ។

ចំណាំងអរូបីនៃការគិត ជាចំណាំងដែលគេមិនអាចមើលឃើញ គេមិនអាចឮ ។ គេមិនអាចប៉ះពាល់វាបាន ។

**ឧទាហរណ៍:** ការគិតដែលឆ្លុះបញ្ចាំងឲ្យដឹងពីកម្រិតវប្បធម៌របស់សិស្សម្នាក់ ។ ការរៀបចំផែនការក្បត់របស់ជនម្នាក់ ចំពោះជនម្នាក់ទៀត ។ គម្រោងផែនការការងាររបស់មនុស្សម្នាក់ដែលស្ថិតនៅក្នុងគំនិតរបស់គេមិនអាចនរណាដឹងបាន ។

ដោយសារលក្ខណៈទូទៅរបស់ការគិត នៅពេលដែលដោះស្រាយបញ្ហា នៅក្នុងភារៈកិច្ចជាក់ស្តែងមួយ មនុស្សតែងតែគិតថា បញ្ហាអស់នោះមិនមានអ្វីគួរឲ្យចម្លែកទេ ។ គេអាចធ្វើចំណែកថ្នាក់វត្ថុ ឬបាតុភូតទៅតាមប្រភេទ តាមក្រុមដែលគេកំណត់រួចគេជ្រើសរើសបញ្ញត្តិ វិធាន និង វិធីដែលពាក់ព័ន្ធនឹងបញ្ហានេះដ៏ចាំបាច់ ដើម្បីរកច្រកដោះស្រាយបញ្ហានេះឲ្យចេញរួច ។ ដូចន្នេះការគិតឆ្លុះបញ្ចាំងបានទៅលើ

លក្ខណៈទូទៅរបស់វត្ថុ និង បាតុភូតផែនការការងារជាច្រើនដំពូក ហើយបង្កើតបានជាសញ្ញាណទូទៅមួយក្នុងខួរក្បាលមនុស្ស ។

**ឧទាហរណ៍:** -គោ ក្របី ឆ្កែ ឆ្មា ជ្រូក សេះ មានលក្ខណៈរួមត្រង់ដែលក្រុមសត្វទាំងនេះចិញ្ចឹមកូននឹងទឹកដោះ ហើយជាថិនិកសត្វ ។

-គោ ក្របី ឆ្កែ ឆ្មា បក្សាបក្សី មានលក្ខណៈរួម ត្រង់ដែលក្រុមសត្វទាំងនេះ ជាប្រភេទសត្វមានឆ្អឹងខ្នងដូចគ្នា ។ ពាក្យថា ថនិកសត្វ ប្រភេទសត្វចិញ្ចឹមកូននឹងទឹកដោះ និង ជា ប្រភេទសត្វមានឆ្អឹងខ្នង ជាសញ្ញាណទូទៅ ហើយមានលក្ខណៈអរូបី ។

## ៤. ការគិតមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងភាសា

ចរិតនៃការគិតរបស់មនុស្ស ដូចបានរៀបរាប់មកហើយនោះ ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធ ទៅនឹងភាសា ។ ទំនាក់ទំនងនេះត្រូវចាត់ទុកថា មានទស្សនៈយល់ឃើញខុសប្លែកគ្នាទៅតាមការសិក្សាស្រាវជ្រាវ និង និន្នាការចិត្តវិទ្យារបស់ក្រុមអ្នកប្រាជ្ញផ្សេងៗគ្នា ។ តាមនិន្នាការរបស់អ្នកប្រាជ្ញមនោនិយមយល់ឃើញថា ការគិតមិនមែនពឹងផ្អែកលើភាសាទេ ហើយភាសានេះក៏មិនពឹងអាស្រ័យលើការគិតដែរ។ ដូច្នេះតាមទស្សនៈ និង យោលទៅតាមភស្តុតាងរបស់ក្រុមអ្នកប្រាជ្ញទាំងនោះមនុស្សយើងអាចគិតដោយស្ងៀមស្ងាត់។ គេអាចគិតដល់មនុស្សណាម្នាក់ដោយនិយាយប្រាប់មនុស្សម្នាក់ផ្សេងទៀត ហើយគំនិតដែគេស្តែងចេញនេះអាចធ្វើបានតាមរយៈភាសាជាច្រើន ។

ក្នុងរណីនេះសឲ្យឃើញថា ការគិត និង ភាសាអាចស្ថិតនៅជាមួយគ្នាបាន តែមិនអាចអាស្រ័យគ្នាទៅវិញទៅមកឡើយ ។ នេះជាទស្សនៈយល់ខុសឆ្គង ។

ការគិតមិនអាចត្រូវបានកាត់ផ្តាច់ពីភាសាបានឡើយ។ ការគិតមិនអាចមានអត្ថិភាពនៅក្រៅក្របខ័ណ្ឌនៃភាសាឡើយ។ ផ្ទុយទៅវិញភាសាមិនអាចមានអត្ថិភាពឡើយ ប្រសិនបើវាមិនឈរលើមូលដ្ឋាននៃការគិត ។ ទំនាក់ទំនងរវាងការគិត និង ភាសា គឺជាទំនាក់ទំនងរវាងអត្ថរស (ពាក្យ និង ការសំដែងចេញ ) បើគ្មានភាសា នោះផលិតផលនៃការគិតមិនអាចស្តែងចេញឲ្យគេស្គាល់បានឡើយ។ ផ្ទុយទៅវិញប្រសិនណាជាគ្មានការគិតនោះភាសាបានត្រាន់តែជាសម្លេងនិយាយជាប់ៗគ្នាដោយឥតន័យ គ្មានអត្ថរសមិនខុសគ្នានឹងការឲ្យសញ្ញាជាសម្លេងនៅក្នុងពិភពសត្វឡើយ ។

ទោះជាក្នុងបែបបទណាក៏ដោយ ការគិតមិនមែនជាភាសាទេ។ គេសំអាងលើមតិយោបល់ ៣ យ៉ាងគឺៈ

- ការគិត និង ភាសា ជាលំនាំផ្លូវចិត្ត ដែលទទួលបន្ទុកនូវមុខងារផ្សេងៗគ្នា ។
- ការគិត និង ភាសា ផ្តល់នូវផលិតផលផ្សេងៗគ្នា ។
- ការគិត និង ភាសា គោរពតាមក្រឹត្យក្រមផ្សេងៗគ្នា ។

ភាសាជាលំនាំផ្លូវចិត្តដែលមានមុខងារសម្រាប់បង្ហាញពីលទ្ធផលនៃការគិត ។ បញ្ញត្តិត្រូវបានស្តែងចេញជាពាក្យមួយម៉ាត់ ឬ ជាភាសា ដែលមានលក្ខណៈជាច្បាប់ ឬ ជានិយមន័យ។ បញ្ញត្តិក៏ជារូបភាពរបស់វត្ថុ ឬ បាតុភូត ដែលស្ថិតនៅក្នុងពិភពសត្យានុម័តដែរ តែរូបភាពនេះវាខុសគ្នាពីរូបភាពរបស់ឥន្ទ្រិយារម្មណ៍ និង ប្រត្យក្សារម្មណ៍ ដែលយើងមានបញ្ញត្តិបង្កប់គ្រប់លក្ខណៈទាំងអស់នៃក្រិត្យក្រមរបស់វត្ថុ និង បាតុភូតទាំងឡាយ ។ ការគិតពិតជាប្រើភាសាទុកដូចជាឧបករណ៍ ។

**ឧទាហរណ៍**: ការគិតដល់គ្រួសារ និង ឪពុកម្តាយ ផ្ទះសម្បែង បងប្អូន ត្រូវបានសំដែងចេញជាពាក្យដូចជាឪពុកម្តាយ ផ្ទះសម្បែង បងប្អូន ។ពាក្យទាំងនោះ យើងមិនបានថា ឬ អានវាឡើយ យើងគ្រាន់តែអាចថាជាសម្ងាត់នៅក្នុងខួរក្បាលប៉ុណ្ណោះ ។ យើងមិនស្តែងចេញតាមរយៈ ពាក្យ ឬភាសាឡើយ ។

បញ្ញត្តិ " គ្រួសារ " បានដល់ឪពុកម្តាយ បងប្អូនប្រុសស្រី ដែលនៅជាមួយគ្នា ។

### ៥. ការគិតអាចជួយមនុស្សឲ្យឆ្លុះបញ្ចាំងបានដ៏ជាក់លាក់ ទៀងទាត់ហើយស៊ីជម្រៅ

### នៅលើធម្មជាតិនៃវត្ថុ និង បាតុភូត ដែលស្ថិតនៅក្នុងតថភាពសត្យានុម័ត

គឺមានតែការគិតទេ ដែលជួយមនុស្សឲ្យមានលទ្ធភាពឆ្លុះបញ្ចាំងបាននូវធម្មជាតិរបស់វត្ថុ និងបាតុភូតព្រមទាំងទំនាក់ទំនងដែលមានលក្ខណៈជាក្រិត្យក្រម ហើយដែលអាចឆ្លងកាត់កម្រិតដែលមើលឃើញជាក់ស្តែងរបស់ចំណេះដឹងឥន្ទ្រិយ៍។ ពិសេសណាស់ទៅទៀត ការគិតគឺជាកម្រិតខ្ពស់បំផុតរបស់សកម្មភាពញាណសត្តិពោលគឺកម្រិតនៃចំណេះដឹងវិចារណ៍។ ប៉ុន្តែនេះក៏មិនមែនមានន័យថា ការគិតចេះតែងឆ្លុះបញ្ចាំងបានត្រឹមត្រូវតែតខ្ជោះជានិច្ចទៅលើវត្ថុ ឬ បាតុភូតនោះទេ ។ ការគិតឆ្លុះបញ្ចាំងបានត្រឹមត្រូវតែតខ្ជោះ ឬ មិនបានត្រឹមត្រូវ អាស្រ័យដោយល្បិច និង វិធីដែលមនុស្សគិតទេ។

### ៦. ការគិតមានចំណងទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងចំណេះដឹងឥន្ទ្រិយ៍

ថ្វីត្បិតតែការគិតមានកម្រិតខ្ពស់ជាងចំណេះដឹងឥន្ទ្រិយ៍ក៏ដោយ (ឥន្ទ្រិយារម្មណ៍ និងប្រត្យក្សារម្មណ៍) ក៏ការគិតមិនអាចកាត់ផ្តាច់ពីចំណេះដឹងឥន្ទ្រិយ៍នេះបានឡើយ។ ទំនាក់ទំនងបញ្ច្រាស់គ្នា និងទំនាក់ទំនងឯកភាពគ្នារវាងការគិត និងចំណេះដឹងឥន្ទ្រិយ៍ស្តែងឡើយឲ្យឃើញនូវចំណុចទាំងឡាយដូចតទៅ៖

- ចំណេះដឹងឥន្ទ្រិយ៍គឺជាមូលដ្ឋាននៃការគិត។ ការគិតត្រូវពឹងផ្អែកលើចំណេះដឹងឥន្ទ្រិយ៍។ ចំណេះដឹងឥន្ទ្រិយ៍ គឺជាប្រភពដែលផ្គត់ផ្គង់សំភារៈឲ្យដល់សកម្មភាពនៃការគិត ។ លើរាល់ចំណេះដឹងទាំងអស់ចាប់ប្រភពចេញមកពីបទពិសោធន៍ ឥន្ទ្រិយារម្មណ៍ និង ប្រត្យក្សារម្មណ៍នេះឯង។ ប្រត្យក្សារម្មណ៍ គឺជាដំណាក់កាលមួយ និង ជាសមាសធាតុមួយនៅក្នុងសកម្មភាពនៃការគិត (គេត្រូវមើលឃើញស្ថានភាពមានបញ្ហាសិនមុននឹងកំណត់បាននូវភារកិច្ចនៃការគិត)។ ចំណេះដឹងឥន្ទ្រិយ៍បង្កើតបានជាមធ្យោបាយមួយថែមទៀតដែលជួយមនុស្សឲ្យត្រួតពិនិត្យបានទៅលើភាពត្រឹមត្រូវតែតល្អៀងរបស់ការគិត ។

– ផ្ទុយទៅវិញការគិត និង ផលិតផលរបស់វាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើលំនាំនៃចំណេះដឹង ឥន្ទ្រីយ៍ជម្រើស អត្ថន័យ និង ស្ថេរភាពរបស់ប្រត្យក្សារម្មណ៍ ។ វត្ថុ និង បាតុភូត ដែលចាំងចូលមកក្នុងចក្ខុវិញ្ញាណរបស់យើង មិនគ្រាន់តែនាំមកនូវឥន្ទ្រីយារម្មណ៍ ផ្សេងៗប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងមកនូវសកម្មភាពនៃការគិតទៀតផង ។

ដោយយោលទៅតាមចរិតរបស់លំនាំនៃការគិត ដូចដែលយើងបានពិសោធន៍រួចមកហើយនោះយើងអាចទាញសេចក្តីសន្និដ្ឋានគរុកោសល្យដ៏ចាំបាច់នៅក្នុងការបង្រៀន និង ការអប់រំដូចតទៅ:

**ក**-គប្បីយកចិត្តទុកដាក់ឲ្យបានដិតដល់ ចំពោះការអភិវឌ្ឍនៃការគិតរបស់សិស្ស ដោយហេតុថាសិស្សមិនមានសតិនៃការគិតទេ ហើយសិស្សក៏មិនអាចយកជោគជ័យបានលើធម្មជាតិ និង ធ្វើម្ចាស់ការលើសង្គមដោយខ្លួនឯងបានឡើយ ។

**ខ**- ការអនុវត្តនៃការគិត មិនអាចកាត់ផ្តាច់ពីវប្បធម៌នៃភាសាឡើយ ។ នៅពេលណាដែលសិស្សក្តាប់បានភាសាវិទ្យាសាស្ត្រ នៃមុខវិជ្ជាសិក្សានីមួយៗ ហើយសិស្សពិតជាមានមធ្យោបាយគ្រប់គ្រាន់ ដើម្បីធ្វើឲ្យការគិតនៅក្នុងវិស័យផ្សេងៗទៀតនៃវិទ្យាសាស្ត្រអភិវឌ្ឍឡើង ។

**គ**- ការអភិវឌ្ឍនៃការគិត មិនអាចជំនួសឲ្យការហ្វឹកហ្វឺនរបស់ឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ សតិនៃការសង្កេត និង លំនឹករបស់សិស្សបានឡើយ ។

**ឃ**- ការអភិវឌ្ឍការគិត ត្រូវមានដំណើរការប្រព្រឹត្តទៅស្របគ្នា និង ការផ្គត់ផ្គង់ចំណេះដឹង នឹងឆ្លងកាត់វិធីបង្រៀន និង អប់រំនេះទៀតផង ។

**ង**- បើគេចង់ធ្វើឲ្យខួរក្បាលរបស់សិស្សមានលក្ខណៈសកម្មដ៏ពិតប្រាកដ ដោយជំរុញសិស្សឲ្យចេះគិតគេត្រូវចេះបង្កើតឲ្យមានស្ថានភាពបញ្ហានៅចំពោះមុខសិស្ស ។ បែបបទដ៏ងាយស្រួលបំផុតក្នុងការអនុវត្តឲ្យបានសម្រេចតាមប្រការនេះ គេត្រូវចេះចោទជាសំនួរឲ្យស្របទៅតាមសមត្ថភាពសិស្សតាមកម្រិតសិក្សា នៅពេលដែលគេពន្យល់មេរៀន ។

## III- ការគិតជាលំនាំផ្លូវចិត្ត

ដូចដែលយើងបានពិពណ៌នារួចហើយ ការគិតជាលំនាំផ្លូវចិត្តដែលរួមមានដំណាក់កាលជាច្រើន ។ តាំងពីពេលដែលបុគ្គលជួបប្រទះស្ថានភាពមានបញ្ហា ហើយបុគ្គលមានការភ្ញាក់រលឹកចំពោះស្ថានភាពនេះ ហូតដល់ពេលណាដែលបញ្ហាត្រូវបានដោះស្រាយហើយរួចរាល់ ។ លំនាំនេះប្រព្រឹត្តទៅបានដោយសារតែចលនា តែចលនានៃបញ្ហា ដែលគេកំណត់បានទៅតាមដំណាក់កាលដ៏ច្បាស់លាស់ហើយគេក៏ទទួលលទ្ធផលនៃការគិតបានតទៅតាមការកំណត់ដែរ ។

### ១- ចលនានៃការគិត

ទង្វើរបស់ការគិតដែលសម្រេចបានតាមរយៈអំពើនៃបញ្ហា ជាកំណត់នោះហៅថាចលនានៃការគិត ។ តាមទស្សនៈធម្មជាតិ ការគិតគឺជាលំនាំផ្លូវចិត្តមួយដែលបុគ្គលបានប្រកាន់ភ្ជាប់តាមរយៈចលនានៃបញ្ហា ជាកំណត់ដើម្បីដោះស្រាយបញ្ហា ឬ ភារកិច្ចដែលចោទឡើងចំពោះខ្លួនគេ ។ បុគ្គលធ្វើការគិត ឬ មិនធ្វើ នោះវាអាស្រ័យដោយហេតុការណ៍ដែលមនុស្សនោះធ្វើ ឬ មិនធ្វើចលនានៃការគិតនៅក្នុងខួរក្បាលទេ ។ ព្រោះហេតុនេះហើយបានជាក្រុមចិត្តវិទូហៅចលនានៃការគិតជាក់ស្តែងដូចតទៅៈ

### ក- ការវិភាគ-ការធ្វើសំយោគ

ការវិភាគគឺជាលំនាំ ដែលប្រើចលនានៃខួរក្បាលរបស់មនុស្ស ហើយដែលត្រូវកាត់ផ្តាច់ពីវត្ថុ និង បាតុភូតចំពោះ ៖

– ទិដ្ឋភាពណាមួយ

– លក្ខណៈណាមួយ

– ផ្នែកផ្សេងៗដែលជាសមាសភាព

– ទំនាក់ទំនង

នេះគឺជាបំណែងចែកវត្ថុពីចំណេះដឹង ដែលមានរួចមកហើយនៅក្នុងខួរក្បាលមនុស្ស ឲ្យទៅជាធាតុ និង ផ្នែកផ្សេងៗពីគ្នា ។ មូលដ្ឋានសរីរៈរបស់ចលនានៃការវិភាគ គឺជាការរួមបញ្ចូលគ្នាជាកំណត់ រវាងការកើតមានរំញោច និង ការថយចុះនៃរំញោចនៅលើសំបកខួរក្បាលមនុស្ស ។

ការធ្វើសំយោគ ក៏គឺជាលំនាំដែលប្រើចលនានៃខួរក្បាលមនុស្សដែរ ដោយប្រមូលផ្តុំឡើងវិញនូវសមាសភាពទាំងឡាយណា ( ដែលកាត់ផ្តាច់ពីគ្នាដោយសារការវិភាគ ) ឲ្យបានគ្រប់គ្រាន់ត្រឹមត្រូវឡើងវិញ ។ មូលដ្ឋានសរីរៈរបស់លំនាំនៃសំយោគ គឺការបិទ មិនឲ្យមានទំនាក់ទំនងសរសៃប្រសាទជាបណ្តោះអាសន្ននៅលើសំបកខួរក្បាល ។ ការវិភាគ និង ការធ្វើសំយោគមានចំណងទាក់ទងគ្នាទៅវិញទៅមកយ៉ាងជិតស្និទ្ធ ហើយបង្កើតបានជាឯកតា មួយដែលមិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ ។ ការវិភាគត្រូវបានគេធ្វើឡើងដោយយោលទៅតាមទំនោរនៃការធ្វើសំយោគ ហើយការធ្វើសំយោគនេះប្រព្រឹត្តទៅដោយឈរលើមូលដ្ឋាននៃលទ្ធផលរបស់ការវិភាគ ។

### ខ- តំហៀបធៀប

តំហៀបធៀបគឺជាលំនាំដែលប្រើចលនានៃខួរក្បាលរបស់មនុស្ស ហើយសំដៅកំណត់បាននូវភាពដូចគ្នា ឬ ភាពខុសគ្នា ក្រុមមានអត្តសញ្ញាណ និង ក្រុមឥតមានអត្តសញ្ញាណ សមភាព ឬ វិសមភាព រវាងវត្ថុ និង បាតុភូតទាំងឡាយ ។ ចលនានៃតំហៀបធៀបមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងចលនានៃការវិភាគ និង ការធ្វើសំយោគ ។ នៅក្នុងដំណាក់កាលទី ១ នៃការសិក្សាស្រាវជ្រាវពិតពជុំវិញខ្លួនគេ ឲ្យស្គាល់ពីវត្ថុដែលខុសប្លែកពីគ្នាតាមរយៈតំហៀបធៀបនេះឯង ។

តំហៀបធៀប គឺជាមូលដ្ឋាននៃការគិត និង ចំណេះដឹងទាំងឡាយ ។

## គ- អរូបីកម្ម និង ទូទៅកម្ម

អរូបីកម្មគឺជាលំនាំផ្លូវចិត្ត ដែលប្រើខួរក្បាល ដើម្បីបញ្ជាក់ពីទិដ្ឋភាព លក្ខណៈ ចំណាងទាក់ទង ភាពបន្ទាប់បន្សំ ភាពឥតបានការ ដោយរក្សាទុកតែភាពចាំបាច់ក្នុងការគិតតែប៉ុណ្ណោះ ។

ទូទៅកម្មក៏ជាលំនាំផ្លូវចិត្ត ដែលប្រើខួរក្បាល ដើម្បីប្រមូលផ្តុំនូវវត្ថុ ឬ បាតុភូតជាច្រើនប្រភេទខុសប្លែកគ្នា ហើយដែលមានលក្ខណៈ និង ចំណាងទាក់ទងដូចគ្នា ហើយដែលកំណត់ទៅតាមក្រុម ឬ ថ្នាក់របស់វា ។ ទូទៅកម្មនាំមកនូវអ្វីដែលគេហៅថា លក្ខណៈរួម ។ លក្ខណៈរួមចំពោះវត្ថុច្រើនប្រភេទផ្សេងគ្នាចែកចេញជាពីរប្រភេទ ៖

– វត្ថុដែលមានលក្ខណៈស្រដៀងគ្នា

– វត្ថុដែលមានលក្ខណៈតាមធម្មជាតិរបស់វា

ហេតុដូច្នេះហើយគ្រប់លក្ខណៈតាមធម្មជាតិរបស់វត្ថុទាំងឡាយ គឺជាលក្ខណៈរួមរបស់វត្ថុ ឬ បាតុភូតមួយក្រុមដែលស្ថិតនៅក្នុងប្រភេទដូចគ្នា ។ ក៏ប៉ុន្តែលក្ខណៈរួមដែលស្រដៀងគ្នានេះមិនមែនចេះតែកើតចំពោះវត្ថុ និង បាតុភូតទាំងឡាយនោះទេ ។

ទូទៅកម្មដែលពឹងផ្អែកតែលើលក្ខណៈរួមដូចគ្នាប៉ុណ្ណោះនោះ ជានិច្ចកាលច្រើនតែជួបប្រទះនឹងកំហុសឆ្គង ។ ដើម្បីបង្ហាញពីសញ្ញារួមតាមលក្ខណៈធម្មជាតិ គេត្រូវធ្វើវិភាគ និង ធ្វើសំយោគដែរ ។ ទូទៅកម្មគឺពិតជាការធ្វើសំយោគក្នុងកម្រិតខ្ពស់មួយ ។

នេះគឺចលនាដ៏សំខាន់របស់ការគិត ។ នៅពេលដែលគេធ្វើវិភាគទៅលើចលនាទាំងនេះ នៅក្នុងលំនាំជាក់ស្តែងនៃការគិត គេត្រូវយកចិត្តទុកដាក់ទៅលើចំណុចទាំងឡាយដូចតទៅៈ

–ចលនានៃការគិតមានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធពីចលនាមួយទៅចលនាមួយទៀត ហើយចលនាទាំងនោះឯកភាពគ្នានៅក្នុងអត្ថន័យមួយជាកំណត់ ដែលស្តែងឡើងតាមរយៈភារកិច្ចនៃការគិត ។

–នៅក្នុងតថភាព ចលនានៃការគិតទាំងនេះ ជួនកាលដំណើរការជាមួយគ្នា ជួនកាលដំណើរការតាមផ្លូវផ្សេងគ្នា ។ ចលនានៃការគិតទាំងនេះមិនប្រព្រឹត្តទៅតាមលំដាប់លំដោយជាកំណត់ឡើយ ។

–ទោះជានៅក្នុងលំនាំបែបណាក៏ដោយ វាមិនចាំបាច់អីទៅអនុវត្តលើគ្រប់ចលនានៃការគិត ដែលបានរៀបរាប់មកហើយនេះទេ ។ នេះវាអាស្រ័យដោយភារកិច្ចនៃការគិត និង លក្ខខណ្ឌជាក់ស្តែងឯនោះវិញទេ ។

## ២- សភាពនៃលំនាំជាក់ស្តែងរបស់ការគិត

ចលនាដូចបានរៀបរាប់មកហើយនេះ ត្រូវបានគេយកទៅអនុវត្តលើគ្រប់ដំណាក់កាលនៃលំនាំជាក់ស្តែងរបស់ការគិត ។ មិនថាលំនាំនៃការគិតណាឡើយ វាចែកចេញជាដំណាក់កាលទាំងឡាយដូចតទៅៈ

### ក- ការលេចឡោឡើងនូវស្ថានភាពមានបញ្ហា

ដូចដែលយើងពិពណ៌នារួចមកហើយ នៅក្នុងផ្នែកខាងមុខនៃមេរៀននេះ មនុស្សយើងមានការគិតតែនៅពេលណាដែលជួបប្រទះនឹងស្ថានភាពមានបញ្ហា ។ ស្ថានភាពមួយអាចចោទជាបញ្ហាចំពោះបុគ្គលម្នាក់ តែវាមិនចោទជាបញ្ហាទេចំពោះបុគ្គលម្នាក់ផ្សេងទៀត ។

### ខ- ចំណេះដឹងដែលបានមកពីស្ថានភាពមានបញ្ហា

ស្ថានភាពមានបញ្ហាគឺជាលក្ខខណ្ឌមួយនៃការធ្វើឲ្យកើតមានការគិត ។ ប៉ុន្តែលក្ខខណ្ឌនៃស្ថានភាពនេះមិនអាចបង្កឲ្យមានការគិតបានឡើយ ។ ដើម្បីញ៉ាំងឲ្យការគិតកើតមានឡើងបុគ្គលគប្បី ស្គាល់ច្បាស់នូវភារកិច្ចនៃការគិត និង បញ្ហាដែលត្រូវដោះស្រាយ ។

### គ- ការលេចឡោឡើងនូវបណ្តុំ និង ចំណេះដឹង

នោះគឺបានដល់ក្បួនច្បាប់ ព្រឹត្តិការណ៍ ក្រឹត្យក្រម ដែលជាប់ពាក់ព័ន្ធទៅនឹងដំណោះស្រាយតាមភារកិច្ចរបស់ការគិត ។

### ឃ- ការចំរាញ់ បណ្តុំ ចំណេះដឹង និង ព័ត៌មានរបស់សម្មតិកម្ម

ក្នុងករណីនេះ គឺសំណូមពរនៃដំណោះស្រាយ ដែលមានលក្ខណៈប្រហាក់ប្រហែលរបស់ភារកិច្ចនៃការគិត ។

### ង- ការផ្ទៀងផ្ទាត់សម្មតិកម្មនៅក្នុងខួរក្បាល ឬ នៅក្នុងសកម្មភាពប្រតិបត្តិ

ការផ្ទៀងផ្ទាត់នេះច្រើនតែប្រព្រឹត្តទៅនៅក្នុងខួរក្បាលរបស់បុគ្គលដែលជួបប្រទះនិងស្ថានភាពមានបញ្ហា។

**ច**- ប្រសិនណាជាសម្មតិកម្មមិនត្រឹមត្រូវទេនោះ គេមានតែបោះបង់ចោលសម្មតិកម្មនោះ ឬ គេត្រូវបង្កើតសម្មតិកម្មថ្មីមួយទៀត ឬ មួយគេធ្វើសម្មតិកម្មនោះឲ្យមានលក្ខណៈកាន់តែសុក្រឹតឡើង រួចមកទើបគេធ្វើឲ្យសម្មតិកម្មបានសម្រេច ពោលគឺគេដោះស្រាយបញ្ហានោះ ឬ ជាភារកិច្ចនៃការគិត ។ កាលណាគេបំពេញភារកិច្ចនៃការគិត គេតែងជួបប្រទះនូវភាពលំបាកស្មុគស្មាញដែលបង្កឡើង ដោយមូលហេតុផ្សេងៗគ្នា ។ គេច្រើនតែជួបប្រទះនូវមូលហេតុពីរយ៉ាងគឺៈ

- អ្នកឯណាដែលអនុវត្តការគិត រកមិនឃើញលើគ្រប់ចំណុចនៃទិន្នន័យដែលតំរូវឲ្យគិត ។
- ជួនកាលគេមិនអាចឈានដល់ការបំពេញបាននូវភារកិច្ចនៃការគិត ពីព្រោះគេបានបញ្ចូនទៅក្នុងទិន្នន័យនៃការតំរូវឲ្យការគិតនោះ នូវលក្ខខណ្ឌដ៏ហួសកម្រិតណាមួយ ហើយដែលវាមិនស្ថិតនៅក្នុង ផ្លូវនៃការគិតនោះ ។

គេអាចសង្ខេបដំណាក់កាលនៃការគិតដូចបានពិពណ៌នាមកនោះនៅក្នុងគំនូសតាង ដូចតទៅនេះៈ




ដើម្បីធ្វើឲ្យជាក់ស្តែងនូវគំនូសតាងនេះ យើងលើកយកឧទាហរណ៍មួយពីប្រវត្តិនៃគោលការណ៍ ។ ស្តេចចង់ដឹងថា តើជាងទងលួចបន្លំមាសដោយដាក់ជំនួសលោហធាតុប្រាក់ ឬ ទេ ? ស្តេចបានត្រាស់បង្គាប់ឲ្យអ្នកប្រាជ្ញវិះរកឲ្យដឹងថា តើជាងទងលួចបន្លំមាសលាយប្រាក់ឬទេ(1) ? អ្នកប្រាជ្ញទទួលបញ្ហារបស់ស្តេច(2) ។ គាត់រិះរកដំណោះស្រាយផ្សេងៗ (3) ។ ទីបំផុតគាត់ដោះស្រាយបញ្ហានេះបានតាមរយៈគោលការណ៍ (4) ។ គាត់បញ្ជាក់គោលការណ៍នេះនៅក្នុងអាងមុជទឹកមួយ (5) ។ ពេលដែលគាត់ប្រាកដច្បាស់ពីរបកគំហើញការពិតនេះ គាត់ស្ទុះចេញអីអាងដោយភ្លេចស្លៀកពាក់ ហើយរត់បណ្តើរស្រែកបណ្តើរក្នុងទីក្រុងថា: " ខ្ញុំរកឃើញហើយ ! ខ្ញុំរកឃើញហើយ! " (6) ។

## ៣. ផលិតផលនៃការគិត គេហៅម្យ៉ាងទៀតថា រូបភាពនៃការគិត

ការសិក្សាអំពីផលិតផលនៃការគិត គឺជាភារកិច្ចរបស់តក្កវិជ្ជា។ ហេតុដូច្នេះហើយបានជាយើងសិក្សាដោយសង្ខេបអំពីផលិតផលទាំងនេះ ក្នុងឋានៈជាការបណ្តុះបណ្តាលផ្លូវចិត្ត ដែលបង្កើតឡើងដោយឈរលើ មូលដ្ឋានរបស់លំនាំនៃការគិត ។

## ក- អំពីបញ្ញត្តិ

បញ្ញត្តិគឺជាចំណេះដឹងដែលត្រូវបានធ្វើទូទៅកម្មរួចមកហើយទៅលើវត្ថុ ឬ បាតុភូតមួយក្រុម ដែលមានសញ្ញាប្រភេទដូចគ្នា ។ បញ្ញត្តិ ( ជាផលិតផលនៃការគិត ) និង រូបតំណាង (ជាផលិតផលនៃលំនឹក ) តែងតែមានការខុសប្លែកគ្នាពីមួយទៅមួយទៀត ។ ក៏ប៉ុន្តែវាមានទំនាក់ទំនងរវាងគ្នា និង គ្នាជានិច្ច តួយ៉ាងដូចជា៖

- បញ្ញត្តិមិនអាចកើតមានឡើងនៅក្រោមទម្រង់រូបីឥន្ទ្រីយ៍។ បញ្ញត្តិមានលក្ខណៈទូលំទូលាយ និងទូទៅជាងរូបតំណាង ។
- បញ្ញត្តិស្តែងឡើងឱ្យឃើញតាមរយៈពាក្យ។ ក៏ប៉ុន្តែពាក្យមួយម៉ាត់អាចសំដែងនូវបញ្ញត្តិជាច្រើនផ្សេងៗគ្នា។ ហើយជួនកាលបញ្ញត្តិអាចស្តែងចេញតាមរយៈពាក្យជាច្រើន។
- បញ្ញត្តិបែបណាក៏ដោយ ក៏វាជាផលិតផលនៃការអភិវឌ្ឍរបស់ប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃប្រទេសជាតិមួយ ឬ មនុស្សជាតិទាំងមូល ។ បញ្ញត្តិត្រូវបានបណ្តុះឡើងក្នុងខួរក្បាលរបស់មនុស្សដោយឈរលើមូលដ្ឋាននៃរបកគំហើញថ្មីរបស់វិទ្យាសាស្ត្រ បច្ចេកទេស និងផលិតកម្ម ។ ហេតុដូច្នេះហើយបានជាបញ្ញត្តិប្រកាន់យកនូវខ្លឹមសារដ៏កាន់តែសំបូរបែបហើយពេញលេញផង ។
- បញ្ញត្តិនីមួយៗត្រូវបានបណ្តុះឡើងនៅក្នុងខួរក្បាលរបស់មនុស្ស ដោយឈរលើមូលដ្ឋាននៃឥន្ទ្រីយារម្មណ៍ ក៏ប៉ុន្តែបញ្ញត្តិមិនមានរូបភាពឥន្ទ្រីយារម្មណ៍ទេ ។
- គ្មានព្រំដែនកំណត់ដាច់ខាតទេ រវាងរូបតំណាង និង បញ្ញត្តិ ។ ដោយប្រែក្លាយខ្លួនទៅជាមានលក្ខណៈទូទៅ រូបតំណាងចាប់ផ្តើមប្រកាន់យកនូវសញ្ញាសំគាល់របស់បញ្ញត្តិជាស្រេចទៅហើយ។ ហើយបន្ទាប់ពីបានក្លាយខ្លួនទៅជាបញ្ញត្តិហើយ វាក៏ប្រែក្លាយខ្លួនឯងទៅជារូបតំណាងវិញ ។

នៅពេលនោះចំណងទាក់ទងបញ្ច្រាសគ្នាទៅវិញទៅមករវាងរូបតំណាង និង បញ្ញត្តិកាន់តែ ស្មុគស្មាញ

ឡើង។ តំហៀបធៀបការទាក់ទងគ្នា រវាងរូបតំណាង និង បញ្ញត្តិកាន់តែធ្វើឲ្យយើងយល់បានថា ព្រឹត្តិការណ៍មួយតែងតែមិនមានភាពដូចគ្នាបេះបិទទៅនឹង ទស្សនៈទូទៅឡើយ ។

**ឧទាហរណ៍៖** សញ្ញាណនៃពាក្យថា " មនុស្ស " ជានិច្ចកាលវាតែងតែមានលក្ខណៈទូលំទូលាយជាងរូបតំណាងរបស់ស្ត្រីម្នាក់ ឬ បុរសម្នាក់ណា ដែលមានលក្ខណៈជាក់ស្តែង ។ នេះគឺជាបញ្ហាមួយដែលយើងត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបណ្តុះបាននូវបញ្ញត្តិក្នុងខួរក្បាលរបស់សិស្ស ជាពិសេសគឺសិស្សនៅកម្រិតបឋមសិក្សា ។

## ខ- ការវិនិច្ឆ័យ

ការវិនិច្ឆ័យក៏ជាផលិផលនៃការគិតដែរ ។ ការវិនិច្ឆ័យរួមបញ្ចូលមានអំណះអំណាងផង និង អវិជ្ជមានកម្មផង ចំពោះបញ្ហាមួយ ។

ឧទាហរណ៍:   - ចិត្តវិទ្យាជាវិទ្យាសាស្ត្រមួយ ។

- សព្វថ្ងៃនេះមេឃមិនភ្លៀងទេ ។

**គ- អនុមាន**

អនុមានជាផលិតផលនៃការគិត ដែលការវិនិច្ឆ័យមួយត្រូវបានចំរាញ់ចេញពីការវិនិច្ឆ័យមួយទៀត

**ឧទាហរណ៍:** ចិត្តរបស់មនុស្សប្រកាន់យកនូវប្រភេទមួយតាមលក្ខណៈសង្គម ព្រោះហេតុដូច្នេះហើយ បានជាឥន្ទ្រីយារម្មណ៍របស់ចិត្តប្រកាន់យកលក្ខណៈសង្គមដែរ ។

អនុមានមានពីប្រភេទគឺ ការពិចារណាតាមអនុមានរួម និង ការពិចារណាតាមអនុមានញែក ។ ការពិចារណាតាមអនុមានញែក គឺជាប្រភេទនៃអនុមានមួយ ដែលមានការវិនិច្ឆ័យដោយឡែក ត្រូវបានទាញចេញពីការវិនិច្ឆ័យទូទៅ ។ ការពិចារណាតាមអនុមានរួម គឺជាប្រភេទនៃអនុមានម្យ៉ាងដែលមានការវិនិច្ឆ័យទូទៅត្រូវបានទាញចេញពីការវិនិច្ឆ័យដោយឡែកៗជាច្រើនប្រភេទ ។

**ឧទាហរណ៍:** - ចំពោះមនុស្ស បាតុភូតផ្លូវចិត្ត គិតតាំងពីបាតុភូតផ្លូវចិត្តហូត រូបារម្មណ៍ សញ្ចេតនា ឆន្ទៈ ...... មានប្រភេទរបស់វាទៅតាមលក្ខណៈសង្គម ។

លំនាំនៃការគិតមានអនុមាន ដែលពឹងផ្អែកលើមូលដ្ឋាននៃការវិនិច្ឆ័យដ៏ត្រឹមត្រូវប្រាកដប្រជាដែលគេហៅថា ការគិតដ៏សមហេតុផល ។ រីឯវិទ្យាសាស្ត្រដែលសិក្សាពីទម្រង់ ក្រឹត្យក្រម របស់ការគិតដ៏ត្រឹមត្រូវប្រាកដប្រជានេះ ហៅថា តក្កវិជ្ជា ។

## IV- **ការយល់ និង ការថ្លុតគ្រងបញ្ញត្តិ**

### **១-ការថ្លុតគ្រងបញ្ញត្តិជាលំនាំមួយរបស់ការគិតដ៏សកម្ម**

ដូចដែលយើងបានដឹងរួចមកហើយ បញ្ញត្តិគឺជាចំណេះដឹងទាំងអស់ដែលមនុស្សជាតិបានចងក្រង និង ធ្វើទូទៅកម្ម ទៅលើប្រភេទនៃវត្ថុ និង បាតុភូត ។ បញ្ញត្តិគឺជាលទ្ធផលនៃការគិតរបស់បនុស្សជាតិក្នុងរយៈពេលធ្វើទូទៅកម្ម ទៅលើប្រភេទនៃវត្ថុ និង បាតុភូត ។ បញ្ញត្តិគឺជាលទ្ធផលនៃការគិតរបស់មនុស្សជាតិក្នុងរយៈពេលពីជំនាន់មួយទៅជំនាន់មួយទៀត តាមរយៈមធ្យោបាយសម្ភារៈនោះគឺ ពាក្យ ។ ពាក្យដែលចង្អុលបង្ហាញប្រាប់ពីបញ្ញត្តិហៅថា " ពាក្យបញ្ញត្តិ " ។ ចំណេះដឹងរបស់មនុស្សជាតិគឺជាលំនាំនៃការរកអភិវឌ្ឍឥតឈប់ឈរ ។ ជាផលវិបាកខ្លឹមសារនៃបញ្ញត្តិផ្លាស់ប្តូរឥតឈប់ឈរជាមួយនឹងបន្លាស់ប្តូរនៃសង្គមទៅតាមសម័យកាល ចំណែកឯពាក្យបញ្ញត្តិស្ថិតនៅដោយឥតប្រែប្រួលជានិច្ច ( តាមពិតនៅក្នុងដំណាក់កាលនីមួយៗនៃប្រវត្តិសាស្ត្រ ខ្លឹមសារនៃបញ្ញត្តិស្ថិតនៅដដែល) ។

លំនាំនៃការជ្រួតជ្រាបបញ្ញត្តិ គឺជាលំនាំដែលឆ្លុះបញ្ចាំងបាននៅក្នុងមនសិការរបស់មនុស្សម្នាក់ៗពីចំណេះដឹងដែលមនុស្សជាតិបានកំណត់អំពីបញ្ញត្តិណាមួយនោះ ។ លំនាំនៃការបណ្ដុះបណ្ដាលបញ្ញត្តិគឺការស្រាវជ្រាវ ការច្នៃប្រឌិតរបស់មនុស្សជាតិ លំនាំនៃការចងក្រងចំណេះដឹងដែលមានពីមុនហើយ ដែលគេកំណត់ច្បាស់រួចមកហើយ ។ លំនាំនៃការជ្រួតជ្រាបបញ្ញត្តិមិនមែនជាលំនាំមួយដែលមានលក្ខណៈងាយស្រួលក្នុងការផ្ទេរចំណេះដឹងរបស់មនុស្សជាតិ ដែលមានស្រាប់មកហើយទៅក្នុងខួរក្បាលរបស់សិស្សឡើយ។ តាមការពិតវាជាសកម្មភាពមួយដែលមានលក្ខណៈសកម្មបំផុត ព្រោះវាជាលំនាំមួយដែលមនុស្សបង្កើតបញ្ញត្តិដោយឈរលើមូលដ្ឋាននៃបទពិសោធន៍ផ្ទាល់ខ្លួន ។ នេះជាលំនាំនៃការគិតជាក់ស្តែង ។ ជ្រួតជ្រាបបញ្ញត្តិបានយ៉ាងត្រឹមត្រូវច្បាស់លាស់បានន័យថា ក្តាប់បានទៅលើបញ្ញត្តិប្រែក្លាយបញ្ញត្តិនោះឲ្យទៅជាបញ្ញត្តិផ្ទាល់ខ្លួន ។ នោះគឺយល់ស៊ីជម្រៅបានត្រឹមត្រូវទៅលើប្រភេទនៃបញ្ញត្តិ និង ចេះយកបញ្ញត្តិនោះទៅអនុវត្តបានទៀតផងនៅក្នុងការប្រតិបត្តិ ។

ដូចម្តេចហៅថា ការយល់? យល់ពីបញ្ហាអ្វីមួយ បានន័យថា ចេះផ្សារភ្ជាប់ ចេះសម្របសម្រួល វាឲ្យសមស្របតាមអត្ថរសនៃបទពិសោធន៍ផ្ទាល់ខ្លួន ។ ឧត្តមគតិមួយអាចជ្រួតជ្រាប ឬ យល់បានដោយមនុស្សម្នាក់ តែនៅពេលណាដែលឧត្តមគតិនោះជ្រាបចូលទៅក្នុងអត្ថរសនៃបទពិសោធន៍របស់គេហើយឧត្តមគតិបានជាចង្កោមមួយសណ្ឋិតក្នុងបទពិសោធន៍របស់គេ ។ ដូច្នេះបានន័យថា ការយល់គឺជាលំនាំនៃការគិតដ៏សកម្ម ។ បើគ្មានការគិតនោះក៏គ្មានការយល់ច្បាស់បានដែរ ។

ក៏ប៉ុន្តែត្រឹមត្រូវការយល់បញ្ញត្តិ នោះវាមិនទាន់គ្រប់គ្រាន់ក្នុងការក្តាប់បញ្ញត្តិបានច្បាស់ដែរ ។ សញ្ញាសំខាន់ទី២ របស់លំនាំយល់ស៊ីជំរៅទៅលើបញ្ញត្តិ គឺសតិនៃការអនុវត្តបញ្ញត្តិបានទៅតាមរូបភាពជាច្រើនយ៉ាងក្នុងការប្រតិបត្តិ ក្នុងការផលិតកម្ម ក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រ និង ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។ បើគ្មានការគិត នោះគេមិនអាចយកបញ្ញត្តិទៅអនុវត្តបានឡើយ ។

តាមពិតការយល់ជ្រួតជ្រាបបញ្ញត្តិ គឺជាលំនាំនាំការគិតដ៏សកម្ម ។ ការយល់ជ្រួតជ្រាបបញ្ញត្តិរបស់មនុស្សមានច្រើនកម្រិតផ្សេងៗគ្នា ។

## ២. កម្រិតជ្រួតជ្រាបបញ្ញត្តិ

ស្នាដៃសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រផ្នែកចិត្តវិទ្យាបានបង្ហាញឲ្យយើងដឹងថា ជានិច្ចជាកាលសិស្សមានកម្រិតជ្រួតជ្រាបបញ្ញត្តិដូចតទៅ:

ក-សិស្សយល់បានតែសញ្ញាខាងក្រៅ ឬ ក្តាប់បាននូវបទពិសោធន៍ជាក់ស្តែងខ្លះដែលជាប់ទាក់ទិនទៅនឹងបញ្ញត្តិ ។ សិស្សមិនអាចក្តាប់បាននូវសញ្ញាធម្មជាតិនៅឡើយ ។

**ឧទាហរណ៍៖** - បក្សីជាសត្វដែលហើរ ។

-ទំហំដែលមានលក្ខណៈសមាមាត្រដោយផ្ទាល់ គឺថាដរាបណាដែលពេលវេលានេះនៅតែបន្ថយដរាបនោះផ្លូវកាន់តែវែងឆ្ងាយ ។

ខ- សិស្សចាប់ផ្តើមក្តាប់បាននូវសញ្ញាធម្មជាតិ ក៏ប៉ុន្តែសិស្សមិនអាចរកឃើញសញ្ញានៃធម្មជាតិដ៏ត្រឹមត្រូវនៅឡើយ ចំពោះបញ្ញត្តិដែលមានលក្ខណៈសមស្របជាបញ្ញត្តិនោះ ។ ហេតុដូច្នេះហើយបានជាសិស្សយល់បញ្ញត្តិនេះ ជូនកាលទូលំទូលាយពេក ជូនកាលចង្អៀតពេក ។

**ឧទាហរណ៍:** -កំណាព្យ គឺជាឃ្លាដែលមានចុងចួន ។

-សម្ូហភាព គឺជាមនុស្សទាំងឡាយដែលស្ថិតនៅក្នុងក្រុមជាមួយគ្នា ។

គ- សិស្សយល់ពីសញ្ញាធម្មជាតិនៃបញ្ញត្តិ ប៉ុន្តែសិស្សមិនអាចឈរលើមូលដ្ឋាននៃបទពិសោធន៍ តាមរយៈឥន្ទ្រីយារម្មណ៍ដ៏ច្រើនបែបយ៉ាងឡើយ ។ ដូច្នេះការយល់នេះគឺយល់ទាំងបង្ខំតាមលក្ខណៈអរូបីហើយសិស្សក៏មិនមានលទ្ធភាព ឬក៏ ជួបការលំបាកក្នុងការអនុវត្តបញ្ញត្តិនោះ ។

**ឧទាហរណ៍៖** -សិស្សអាចសូត្រនិយមន័យបានច្បាស់លាស់ តែវាមិនចេះរកឧទាហរណ៍មកសំអាងលើនិយមន័យនេះបានឡើយ ។

ឃ-សិស្សយល់ និង អនុវត្តបានយ៉ាងច្បាស់លាស់ត្រឹមត្រូវទៅលើបញ្ញត្តិដែលខ្លួនបានយល់ជ្រួតជ្រាប ។

នេះគឺជាគំនិតដែលមានលក្ខណៈជាឧត្តមគតិ ។

សរុបសេចក្តីមក ដើម្បីយល់ជ្រួតជ្រាប់បញ្ញត្តិឲ្យបានត្រឹមត្រូវច្បាស់លាស់សិស្សត្រូវមានលក្ខខណ្ឌដូចតទៅ៖

– ត្រូវមានឯកសារត្រឹមត្រូវតាមលក្ខណៈឥន្ទ្រីយារម្មណ៍ ចំណេះដឹងអរូបី ដ៏សំបូរបែបបង្ហរចំពោះ បញ្ញត្តិ។

– ត្រូវប្រើការគិតឲ្យសកម្ម ដើម្បីចង្អុលបង្ហាញឲ្យឃើញពីសញ្ញាធម្មជាតិរបស់វត្ថុតាមរយៈឯកសាផ្ទាល់ខ្លួន ។ ជាការពិតណាស់ក្នុងករណីនេះ សាស្ត្រាចារ្យត្រូវការជួយណែនាំសិស្ស ។

– វាជាការចាំបាច់ណាស់ក្នុងករណីដែលតម្រូវឲ្យសិស្សធ្វើលំហាត់អនុវត្ត គឺពីលំហាត់ងាយស្រួលទៅលំហាត់ស្មុគស្មាញ ពីទ្រឹស្តីអរូបី ទៅការប្រតិបត្តជាក់ស្តែង ។

ចំណែកឯសាស្ត្រាចារ្យវិញ ដើម្បីឲ្យសិស្សយល់ជ្រួតជ្រាបបញ្ញត្តិដែលខ្លួនបានផ្តល់ឲ្យសិស្សរួចមកហើយគប្បីយកចិត្តទុកដាក់នឹងចំណុចទាំងឡាយដូចតទៅ ៖

– ត្រូវឈរលើមូលដ្ឋាននៃចំណេះដឹងដែលសិស្សក្តាប់បាន ដើម្បីបង្កើតឲ្យមានស្ថានភាពបញ្ហាចំពោះមុខសិស្ស ។

– វាជាការមានប្រយោជន៍ណាស់ ដែលសាស្ត្រាចារ្យត្រូវរំលឹកសិស្សពីឯកសារមេរៀន ដែលមានលក្ខណៈត្រឹមត្រូវតាមឥន្ទ្រីយារម្មណ៍ ឬ ចំណេះដឹងវិទ្យាសាស្ត្រ ដែលចាំបាច់ក្នុងការបណ្តុះបណ្តាលបញ្ញត្តិ ។

- សាស្ត្រាចារ្យត្រូវជំរុញសិស្សឲ្យមានការគិត ដើម្បីឲ្យសិស្សអាចរកឃើញនូវសញ្ញាធម្មជាតិដោយឈរលើមូលដ្ឋាននៃឯកសារមេរៀនដែលចងក្រងបាន ។
- វាជាកាចាំបាច់ណាស់ ដែលសាស្ត្រចារ្យត្រូវណែនាំសិស្សឲ្យធ្វើប្រព័ន្ធកម្មទូទៅលើបញ្ញត្តិទាំងឡាយ ដើម្បីឲ្យបញ្ញត្តិនោះមានលក្ខណៈត្រឹមត្រូវប្រាកដប្រជា និង ដើម្បីលពង្រឹងបញ្ញត្តិនោះផង។

V- **ចំណែកថ្នាក់នៃការគិត**

បើគេឈរលើមូលដ្ឋាននាំកំណក់កំណើត និង កម្រិតអភិវឌ្ឍនៃការគិត គេចែកការគិតជាបីប្រភេទគឺ:

ក- ការគិតរូបីតាមរយៈដៃ

ខ- ការគិតរូបីតាមរយៈរូបភាព

គ- ករគិតអរូបី

បើគេធ្វើការចែកចំណែកថ្នាក់ការគិតទៅតាមទម្រង់នៃការស្តែងឡើងនូវបញ្ហា គេបានប្រភេទនៃការគិតដូចតទៅៈ

**ក- ការគិតបែបប្រតិបត្តិ:** គឺជាការគិតម្យ៉ាងដែលមានភារកិច្ចរបស់វាចោទឡើងជាបញ្ហាជាក់ស្តែង ហើយស្ថិតនៅក្រោមទម្រង់រូបី និងបែបបទដោះស្រាយបញ្ហានេះ គឺទង្វើប្រតិបត្តិនោះឯង ។

**ឧទាហរណ៍:** ការគិតរបស់ជាងជួសជុលរថយន្ត កាលណារថយន្តខូច ។

**ខ- ការគិតរូបីតាមរយៈរូបភាព:** គឺជាប្រភេទនៃការគិតដែលមានភារកិច្ចរបស់វាស្តែងចេញឡើងតាមទម្រង់នៃរូបភាពជាក់ស្តែង ហើយដំណោះស្រាយបញ្ហាក៏ត្រូវពឹងផ្អែកលើរូបភាពជាក់ស្តែងដែលមានស្រាប់មកហើយដែរ ។

**ឧទាហរណ៍:** ក្នុងករណីដែលយើងត្រិះរិះ ដើម្បីរកផ្លូវដែលដើរពីសាលារៀនឆាប់ដល់ផ្ទះ ។

**គ- ការគិតបែបទ្រឹស្តី:** គឺជាប្រភេទនៃការគិតដែលមានភារកិច្ចរបស់វាស្តែងចេញឡើងតាមទម្រង់ទ្រឹស្តី ហើយដំណោះស្រាយរបស់ភារកិច្ចនេះត្រូវពឹងផ្អែកលើបញ្ញត្តិអរូបី និង ចំណេះដឹងផ្អែកទ្រឹស្តី ។

**ឧទាហរណ៍:** ការគិតរបស់សិស្សនៅពេលស្តាប់សាស្ត្រាចារ្យពន្យល់មេរៀននៅក្នុងថ្នាក់ ។

ការគិតរបស់លោកសាស្ត្រាចារ្យនៅពេលគាត់តែងកិច្ចការមេរៀនសម្រាប់បង្រៀនសិស្ស ។

នៅក្នុងតថភាព ជានិច្ចកាលមនុស្សចាស់មិនប្រើប្រាស់ប្រភេទនៃការគិតតែម្យ៉ាងទេ ។ នៅក្នុងសកម្មភាពរស់នៅរបស់មនុស្សតែងតែមានការសម្របសម្រួលគ្នារវាងប្រភេទនៃការគិតទាំងអស់ ហើយដែលក្នុងនោះមានប្រភេទនៃការគិតណាមួយនោះ ដែលសម្រេចបាននូវតួនាទីសំខាន់ជាងគេ ។

**ឧទាហរណ៍:** - កម្មករម្នាក់មិនគ្រាន់តែប្រើប្រាស់ប្រភេទនៃការគិតតាមបែបប្រតិបត្តិប៉ុណ្ណោះទេ ប៉ុន្តែគេត្រូវប្រើការ គិតតាមរយៈរូបភាព និង ទ្រឹស្តីទៀតផង ។

- ជាងគំនូរម្នាក់មិនគ្រាន់តែប្រើប្រាស់ការគិតតាមបែបទ្រឹស្តីប៉ុណ្ណោះទេ ប៉ុន្តែគេត្រូវកសាងឲ្យបានផ្ទាំងគំនូរដើម្បីសំដែងចេញនូវគំនិតជាក់ស្តែងទៀតផង ។

## V- ចរិតបុគ្គលក្នុងគម្រោងនៃការគិត

ចរិតបុគ្គលរបស់មនុស្សម្នាក់ៗ ក្នុងគម្រោង នៃការគិតស្តែងឡើងឲ្យឃើញតាមរយៈភាពខុសប្លែកគ្នាក្នុងការគួបផ្សំគ្នារវាងប្រភេទនៃការគិតក្នុងខ្លួនគេ ។ ចរិតបុគ្គលនៃការគិតនេះស្តែងចេញឲ្យឃើញនៅក្នុងគុណសម្បត្តិនៃសកម្មភាពញាណសក្តិ របស់មនុស្សម្នាក់ៗ ។ សកម្មភាពនៃចំណេះដឹងរបស់មនុស្សម្នាក់ៗមាន គុណសម្បត្តិដូចតទៅ៖

### ក- ស្មារតីម្ចាស់ការក្នុងការគិត

មុនដំបូងស្មារតីនេះស្តែងចេញឲ្យឃើញនៅក្នុងបំណិនប្រសប់នៃរបកគំហើញ និង កំណត់បាននូវបញ្ហាថ្មី ហើយនិងដំណោះស្រាយបញ្ហាបានដោយខ្លួនឯងពិតប្រាកដ ។ ស្មារតីច្នៃប្រឌិតនៃការគិតស្តែងចេញឲ្យឃើញយ៉ាងច្បាស់លាស់ក្នុងស្មារតីម្ចាស់ការនេះឯង ។

### ខ- ភាពទន់ភ្លន់នៃការគិត:

ភាពទន់ភ្លន់នេះស្ថិតនៅត្រង់ចំណេះធ្វើ ដែលអាចផ្លាស់ប្តូរបានយ៉ាងឆាប់រហ័ស និង យ៉ាងងាយស្រួលទៅតាមបែបបទនៃការសម្រេចបាននូវភារកិច្ចដែលគេកំណត់ឲ្យតាំងពីដើមទី ប្រសិនណាជាបែបបទនេះលែងសមស្របទៅនឹងដំណោះស្រាយភារកិច្ចនៃការគិត ។

### គ- ភាពរហ័សរហួននៃការគិត:

នោះគឺសតិនៃការសម្រេចបានជោគជ័យ ក្នុងភារកិច្ចនៃការគិត ក្នុងរយៈពេលដ៏ខ្លីបំផុត

### ឃ- ភាពទូលំទូលាយនៃការគិត:

ភាពទូលំទូលាយនៃការគិតនេះស្តែងចេញឲ្យឃើញក្នុងរង្វង់នៃសកម្មភាពណាមួយដ៏ធំសម្បើមរបស់វិស័យសម្រាប់ការគិតតាមបែបប្រតិបត្តិ ។ ភាពទូលំទូលាយស្តែងចេញឲ្យឃើញថែមទៀត ចំពោះចរិតដ៏ គ្រប់គ្រាន់ និង ច្នៃប្រឌិតនៅក្នុងវិធីសិក្សាស្រាវជ្រាវបញ្ហារបស់វិទ្យាសាស្ត្រ និង ការប្រតិបត្តិ ។

### ង- ជំរៅនៃការគិត:

ជំរៅនៃការគិតស្ថិតនៅត្រង់សមត្ថភាពដែលស៊ីជំរៅទៅលើធម្មជាតិនៃបញ្ហា ដែលស្មុគស្មាញបំផុតក្នុងជីវភាពរស់នៅ និង សតិ សម្លឹងមើលឃើញបញ្ហាដែលអ្នកឯទៀតមិនអាចរកឃើញ ។

### ច- ស្មារតីទិទៀននៃការគិត:

ស្មារតីទិទៀននេះស្តែងចេញឲ្យឃើញនៅក្នុងចំណេះធ្វើនៃវង្វាយតម្លៃ ដោយសត្យានុម័តទៅលើការគិតរបស់ខ្លួន និង ការគិតរបស់អ្នកដទៃដោយបកស្រាយបំភ្លឺបានយ៉ាងមឹងម៉ាត់ព្រមទាំងផ្ទៀងផ្ទាត់បានទាំងស្រុងហើយគ្រប់គ្រាន់ផងលើរាល់សម្មតិកម្ម និង សេចក្តីសន្និដ្ឋានទៅតាមគំនិតដ៏ជឿនលឿន ។

## សន្និដ្ឋាន

គុណសម្បត្តិនៃការគិតដូចបានពិពណ៌នាមកហើយនេះ អាស្រ័យដោយផ្ទាល់ទៅលើដំណើរការអភិវឌ្ឍទូទៅនៃបុគ្គលិកលក្ខណៈរបស់មនុស្សម្នាក់ៗ ។ គុណសម្បត្តិទាំងនេះ ក៏អាស្រ័យផងដែរដោយភាពខុសប្លែកគ្នា អត្ថន័យនៃបទពិសោធន៍ផ្ទាល់ខ្លួនម្នាក់ៗ ចរិតអប់រំ ភាពទូលំទូលាយ នៃចំណង់ចំណូលចិត្ត ជំរៅនៃសញ្ចេតនាដែលស្ថិតនៅក្នុងកម្រិតខ្ពស់ (ជាពិសេសសញ្ចេតនានៃបញ្ញា) និង ការអភិវឌ្ឍ នៃ

ឆន្ទៈរបស់មនុស្សម្នាក់ៗ ។ ហេតុដូច្នេះហើយបានជាគេកំណត់ថា ការអប់រំបញ្ញាជាផ្នែកមួយដ៏សំខាន់ នៅក្នុងការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈរបស់សិស្ស ។

ការគិតជាលំនាំចំណេះដឹងសំខាន់ជាងគេបង្អស់។ ការគិតគឺជាសត្តិដ៏មានតម្លៃបំផុតរបស់មនុស្សជាតិ ។មានតែមនុស្សទេដែលមានការគិត ។ ដូច្នេះសាស្ត្រាចារ្យត្រូវរិះរកគ្រប់មធ្យោបាយដើម្បីពង្រឹងការគិតរបស់សិស្សនៅក្នុងការអប់រំ ការបង្រៀន និង ការសិក្សា ដូចជា:

ក- បង្ហាត់សិស្សឲ្យធ្វើចលនានៃការគិត និង បង្កើតនូវបញ្ញត្តិដោយខ្លួនឯង ។

ខ- ពង្រីកការវិនិច្ឆ័យ និង ការត្រិះរិះរបស់សិស្ស ។ គ្រប់កិច្ចការដែលដាក់ឲ្យសិស្សធ្វើត្រូវមាន

គោលដៅច្បាស់លាស់ ។

គ- ត្រូវពង្រីកគ្រប់គុណភាពនៃការគិត ជាពិសេសគឺគំនិតទិទៀន និង គំនិតម្ចាស់ការ ។ ណែនាំសិស្សឲ្យចូលរួមក្នុងការពីភាក្សាបញ្ចេញមតិយោបល់ និង ប្រយុទ្ធទល់នឹងភាពខ្ជិលច្រអូស ។

## សំណួរ

១- ដូចម្ដេចហៅថា ការគិត ?

២- តើត្រង់ចំណុចណាខ្លះ ដែលបង្ហាញឲ្យដឹងថា ការគិតខុសប្លែកពីប្រត្យក្សារម្មណ៍ និង លំនឹក ?

៣- ចូរបង្ហាញពីចរិតនៃការគិត និង សេចក្ដីសន្និដ្ឋានដ៏ចាំបាច់ ?

៤- ហេតុអ្វីបានជាគេពោលថា ការជ្រើតជ្រាបបញ្ញត្តិ គឺជាលំនាំនៃការគិតដ៏សកម្ម ?

## មេរៀនទី ១១ ៖ រូបារម្មណ៍ ( L' IMAGINATION )

- **សញ្ញាណទូទៅស្ដីពីរូបារម្មណ៍**( Notion générale sur L' imagination )

ដូចដែលយើងបានដឹងរួចមកហើយនៅក្នុងមេរៀនមុន ការគិតគឺជាសកម្មភាពញាណសក្ដិដែលស្ថិតនៅក្នុងកម្រិតខ្ពស់។ ការគិតជួយមនុស្សឲ្យដោះស្រាយបាននូវភារកិច្ច និង បញ្ហាដែលចោទឡើងនៅក្នុងការប្រតិបត្តិ។ ការគិតកើតមានឡើងតែនៅពេលណាដែលមនុស្សស្ថិតនៅចំពោះមុខស្ថានភាពមានបញ្ហា។ ការគិតឆ្លុះបញ្ចាំងនូវអ្វីៗដែលមានសភាពថ្មីថ្មោង ហើយដែលមនុស្សមិនទាន់ស្គាល់នៅឡើយ។

នេះក៏មិនមែនមានន័យថា ទោះជាភារកិច្ចណាក៏ដោយ ឲ្យតែចោទឡើងនៅក្នុងការប្រតិបត្តិសុទ្ធតែដោះស្រាយរួចតាមរយៈការគិតនោះទេ។ នៅក្នុងករណីជាច្រើនកាលណាមនុស្សស្ថិតនៅចំពោះមុខស្ថានភាពមានបញ្ហា មនុស្សមិនចេះតែដោះស្រាយបញ្ហារួចទាំងអស់ដោយប្រើតែការគិតនោះទេ មនុស្សត្រូវពឹងផ្អែកលើលំនាំមួយទៀតនៃចំណេះដឹងដែលមានកម្រិតខ្ពស់គឺរូបារម្មណ៍។ ដូច្នេះអ្វីទៅជារូបបារម្មណ៍?

តើរូបារម្មណ៍មានភាពស្រដៀងគ្នា (Ressemblance) និង ភាពខុសប្លែកគ្នាជាមួយនឹងការគិតត្រង់ចំណុចណាខ្លះ? នៅត្រង់ករណីណាខ្លះដែលយើងប្រើប្រាស់ការគិត ហើយនៅពេលណាខ្លះដែលយើងត្រូវប្រើរូបារម្មណ៍ដើម្បីស្គាល់តថភាពសត្យានុម័ត?

### ១. និយមន័យ (Définition)

រូបារម្មណ៍ជាលំនាំផ្លូវចិត្តដែលឆ្លុះបញ្ចាំងវត្ថុនិងបាតុភូតទាំងឡាយ ដែលមិនទាន់កើតមានឡើងក្នុងបទពិសោធន៍របស់បុគ្គលម្នាក់ៗ ក្នុងន័យកសាងបានជារូបភាពថ្មី ដោយឈរលើមូលដ្ឋាននៃរូបតំណាងចាស់ៗដែលមានរួចមកហើយ។

**ឧទាហរណ៍**: - ព្រះគនេស ជាអាទិទេពដែលមានក្បាលដំរី ដងខ្លួនជាមនុស្ស។

- ក្នុងអក្សរសិល្ប៍បស្ចឹមប្រទេស គេមាននិទានពីសត្វស្មាំង ដែលជាសត្វ ម្យ៉ាងមានក្បាលជាមនុស្សស្រី ដងខ្លួនជាសត្វតោ។ នាងសុវណ្ណមច្ឆាមានដងខ្លួនជាសត្វត្រី និងក្បាយលជាមនុស្សស្រី។ នាងកៃវណាម៉ា ក្បាលជាសត្វសេះ ខ្លួនជាមនុស្សស្រី។ ពួកបច្ចឹមប្រទេសបានបង្កើតបិសាច មានស្នែង មានក្រចក មានកន្ទុយ និងមានទ្រនាប់ជើង។

ដំបូងបង្អស់ តាមទស្សនៈនៃខ្លឹមសារដែលឆ្លុះបញ្ចាំងបានគឺថា រូបារម្មណ៍ឆ្លុះបញ្ចាំងនូវអ្វីៗដែលមិនទាន់មាននៅឡើយនៅក្នុងបទពិសោធន៍របស់បុគ្គល ឬ នៅក្នុងសង្គម ពោលគឺរូបារម្មណ៍ជាលំនាំផ្លូវចិត្តមួយផងដែរ ដែលឆ្លុះបញ្ចាំងបាននូវអ្វីៗ ដែលមានសភាពថ្មីថ្មោង។ ត្រង់ចំណុចនេះយើងឃើញថារូបារម្មណ៍ស្រដៀងគ្នា និងការគិត។ ដូច្នេះហើយបានជាគេចាត់ទុកថា រូបារម្មណ៍ជាលំនាំនៃចំណេះដឹងដែលមានកម្រិតខ្ពស់ពោលគឺ ចំណេះដឹងវិចារណ៍នោះឯង។ ដូច្នេះរូបារម្មណ៍ក៏ដូចជាការគិតដែរ រូបារម្មណ៍កើតមានឡើងតែក្នុងពេលណាដែលមនុស្សជួបប្រទះនូវស្ថានភាពមានបញ្ហាដូចជាសំណូមពរនិង ការប្រតិបត្តិដែល

មានសភាពថ្មីថ្មោងក្នុងជីវភាពរស់នៅ។ កម្លាំង ចលករដែលបង្កើតល្បឿនរបស់លំនាំនៃរូបារម្មណ៍ គឺតម្រូវការ(តម្រូវការឲ្យឃើញ និងស្រាយបំភ្លឺពីអ្វីៗដែលថ្មីថ្មោងដែលគេមិនទាន់ស្គាល់ ឬ តម្រូវការនៃការបង្កើតឡើងនូវអ្វីៗដែលថ្មីស្រឡាង)។ ដូច្នេះ រូបារម្មណ៍ជាលំនាំនៃការបង្កើតនូវអ្វីៗដែលថ្មីស្រឡាងសម្រាប់បុគ្គល និងសម្រាប់សង្គម។

រូបារម្មណ៍ប្រើប្រាស់រូបតំណាងរបស់លំនឹង ប៉ុន្តែវាមិនបង្កើតឡើងវិញនូវរូបតំណាងដែលគេធ្លាប់ស្គាល់ ធ្លាប់ដឹងមកហើយនោះទេ។ រូបារម្មណ៍ផ្គុំរូបតំណាងដែលមានមកហើយនោះទៅតាមបែបបទមួយទៀត ដើម្បីបង្កើតរូបតំណាងថ្មីៗទាំងឡាយ នោះគឺរូបតំណាងច្នៃប្រឌិត។ រូបារម្មណ៍ជាលំនាំចំណេះដឹងវិចារណ៍ក្នុងករណីដែលការគិតរកចម្លើយពុំទាន់ឃើញនៅឡើយ ហើយរូបារម្មណ៍ក៏ចូលមកជំនួសការគិតវិញ។

**ឧទាហរណ៍:** បាតុភូតរន្ទះបាញ់។ កាលដើមឡើយវិទ្យាសាស្ត្រមិនទាន់រីកចំរើន ការគិតក៏មិនអាចដោះស្រាយបាតុភូតនេះបាន។ តែរូបារម្មណ៍ក៏ចូលមកជំនួសការគិតវិញ ដោយបកស្រាយពន្យល់ថារន្ទះនេះកើតឡើងដោយសារ រាមាសូរ ចោលពូថៅទៅលើនាងមុនីមេខលាដែលការកាន់កែវមុនីនៅដៃ។

ទាំងនេះជាការពន្យល់របស់រូបារម្មណ៍ដោយភ័ន្តច្រឡំ។ នៅមានរូបារម្មណ៍ខ្លះទៀតដែលកើតមានឡើងមុនពេលវេលាមកដល់របស់ព្រឹត្តិការណ៍ណាមួយ។

**ឧទាហរណ៍:** នៅក្នុងករណីប្រលោមលោករបស់លោក ស៊ុល វែន។ លោក ស៊ុល វែនបាននឹកគិតថាមានឧត្តមនាវីមួយក្រុម ដែលគេឲ្យឈ្មោះថា ណេម៉ូអាចកសាងបាននាវាមុចទឹក។ នាវាមុចទឹកអាចបើកក្រោមទឹកបានចម្ងាយ ២០.០០០យោជន៍។ លោក ស៊ុល វែន នឹកគិតយ៉ាងនេះដោយផ្អែកលើវិទ្យាសាស្ត្រនៅសម័យសតវត្សទី១៨។ នៅជំនាន់នោះមិនទាន់មាននាវាមុចនៅឡើយទេ។ លុះមកដល់សតវត្សទី២០យើងនេះ មាននាវាមុជទឹកមែន។ ទាំងនេះបញ្ជាក់ឲ្យដឹងថា ជារូបារម្មណ៍ដែលមកដល់មុនពេលវេលា។ គួរកត់សំគាល់ថាមានតែមនុស្សទេដែលមានរូបារម្មណ៍ និងការគិត។

តាមទស្សនៈនៃបែបបទដែលឆ្លុះបញ្ចាំងបាន លំនាំនៃការបង្កើតវត្ថុថ្មីរបស់រូបារម្មណ៍ចាប់ផ្តើមកើតឡើងតាមរយៈរូបតំណាងហើយប្រព្រឹត្តទៅនៅក្រោមទម្រង់នៃរូបភាពជាក់ស្តែង។ គឺត្រង់ចំណុចនេះហើយដែលរូបារម្មណ៍ខុសប្លែកពីការគិត។ ចំណាំងរបស់ការគិតប្រព្រឹត្តទៅនៅក្រោមរូបភាពរបស់បញ្ញត្តិ។

នៅក្នុងលំនាំរបស់រូបារម្មណ៍ រូបតំណាង និង ចំណេះដឹងស្តីពីលោកៈរបស់មនុស្សផ្គុំគ្នាទៅតាមបែបបទថ្មីមួយ ដើម្បីបង្កើតបានជារូភាពនៃរូបារម្មណ៍ ដែលជារូបភាពមានលក្ខណៈច្នៃប្រឌិតនិងស្ថិតនៅក្នុងការសន្មតទៅតាមទស្សនៈនៃខ្លឹមសារ។ នោះគឺជាបណ្តុំដោយខ្សែកនៃធាតុទាំងឡាយដែលស្ថិតនៅក្នុងវត្ថុ និង បាតុភូត។

ដូច្នេះ រូបារម្មណ៍ ជាលំនាំមួយដែលបង្កើតបានជារូបតំណាងថ្មី ដោយឈរលើមូលដ្ឋាននៃរូបតំណាងចាស់ដែលមានរួចមកហើយ។ រូបារម្មណ៍ក៏ជាចំណាំងនៃតថភាពសត្យានុម័តផងដែរ។

ក៏ប៉ុន្តែរូបតំណាងរបស់រូបារម្មណ៍ខុសប្លែកគ្នាខាងផ្នែកគុណភាពពីរូបារម្មណ៍របស់លំនឹក។ ដូចដែលយើងធ្លាប់ដឹងរួចមកហើយ រូបតំណាងរបស់លំនឹកគឺជារូបភាពរបស់វត្ថុ និង បាតុភូតដែលយើងធ្លាប់ប្រទះឃើញពីមុន ហើយឥឡូវនេះវត្ថុ និងបាតុភូតទាំងនោះមិនស្ថិតនៅចំពោះភ្នែកយើងទៀតទេ។ ចំណែកឯរូបតំណាងរបស់រូបារម្មណ៍វិញវាជារូបភាពមួយដ៏ថ្មីស្រឡាងហើយបង្កើតឡើងដោយឈរលើមូលដ្ឋាននៃរូបតំណាងរបស់លំនឹក។ ដូច្នេះវាជារូបតំណាងនៃរូបតំណាងជាច្រើន។ ចំណាំងរបស់រូបារម្មណ៍មានលក្ខណៈប្រយោលជាង និង ទូទៅជាងលក្ខណៈរបស់លំនឹក។

នៅចំពោះមុខស្ថានភាពមានបញ្ហា តើពេលណាដែលយើងប្រើការគិត ហើយនៅពេល ណាដែលយើងប្រើប្រាស់រូបារម្មណ៍? ករណីនេះ វាអាស្រ័យដោយការគិតដាច់ស្រេចទៅលើ ស្ថានភាពមានបញ្ហា។ ប្រសិនណាជាឯកសារដើមរបស់ភារកិច្ច ឬក៏ជាឯកសាររបស់បញ្ហាវិទ្យាសាស្ត្រ ជាឧទាហរណ៍ថា ជាឯកសារច្បាស់លាស់ ងាយយល់លំនាំនៃការសម្រេចបានលើភារកិច្ចនេះប្រព្រឹត្តទៅជាចាំបាច់ ដោយយោងទៅតាមក្រឹត្យក្រមនៃការពិត ( ក្រឹត្យក្រមផ្ទៃក្នុង នៃការពិត ពោលគឺចលនានៃការពិត)។ កាលណាការមិនដាច់ស្រេច ឬការមិនសម្រេចបានចំពោះស្ថានភាព មានបញ្ហាត្រូវបានកត់សម្គាល់ហើយនោះ វាពិបាកនឹងវិភាគឲ្យបានត្រឹមត្រូវណាស់ទៅតាមឯកសារដើម ( ចំណេះដឹង និងបទពិសោធន៍ដែលមានរួចហើយ ) ។ ដូច្នេះលំនាំនៃការសម្រេចបានចំពោះភារកិច្ចនេះ ប្រព្រឹត្តទៅដោយយោងទៅតាមចលនាការរបស់ រូបារម្មណ៍ ។

តាមពិតអាស្រ័យដោយលក្ខខណ្ឌផ្សេងៗគ្នារបស់ស្ថានភាពមានបញ្ហាភារកិច្ចនៃដំណោះបញ្ហាដូចគ្នាអាចត្រូវដោះស្រាយបានតាមរយៈរូបារម្មណ៍ផង ឬតាមរយៈការគិតដ៏សមហេតុផលក៏បាន។ មូលដ្ឋាននេះធ្វើឲ្យយើងសន្និដ្ឋានបានថារូបារម្មណ៍ប្រព្រឹត្តទៅតាមការកំណត់ចំណេះដឹងដែលភាពស្ទាក់ស្ទើររបស់បុគ្គលនៅចំពោះមុខស្ថានភាពមានបញ្ហា ត្រូវបានគេកំណត់សម្គាល់ឃើញយ៉ាងច្បាស់លាស់។ ដ៏រាបណាដែលស្ថានភាពមានបញ្ហាត្រូវបានគេស្គាល់យ៉ាងស្និទ្ធស្នាលគេអាចកំណត់បានក្នុងលក្ខណៈដ៏មានលំនឹងផងដរាបនោះ ការសន្មត(Fiction) មានភាពទូលំទូលាយណាស់។ វាជាការច្បាស់ណាស់ដែលថារូបារម្មណ៍មានភាពចាំបាច់ណាស់ចំពោះវត្ថុ និងបាតុភូតទាំងឡាយដែលមានក្រឹត្យក្រមដ៏សំខាន់ៗរបស់វាត្រូវបានគេស្រាយបំភ្លឺរួចទៅហើយ។ ផ្ទុយទៅវិញកាលណាយើងទទួលព័ត៌មានមិនសូវច្បាស់លាស់លើស្ថានភាពមានបញ្ហាហើយយើងជួបការលំបាកក្នុងដំណោះស្រាយបញ្ហាដោយប្រើការគិតពេលនោះរូបារម្មណ៍ក្លាយទៅជាមានភាពចាំបាច់ណាស់។ តម្លៃរបស់រូបារម្មណ៍ស្ថិតនៅត្រង់ដែលវាជួយយើងឲ្យឈានដល់ការសម្រេចចិត្ត (Decision) និងរកឃើញច្រកចេញរួចពីស្ថានភាពមានបញ្ហា សម្បីតែយើងមិនមានចំណេះដឹងដ៏ចាំបាច់គ្រប់គ្រាន់សម្រាប់ការគិតក៏ដោយ។ រូបារម្មណ៍ជួយយើងឲ្យឈានដល់ការសម្រេចចិត្តបានជាលទ្ធផលចុងក្រោយបង្អស់ ទោះជាយើងរំលងដំណាក់កាលខ្លះនៃការគិតក៏ដោយ។ ក៏ប៉ុន្តែភាពទន់ខ្សោយនៃការបង្កើតឲ្យមានស្ថានភាពបញ្ហានេះតាមរយៈរូបារម្មណ៍ ក៏អាស្រ័យពីការគិតរបស់មនុស្សដែរ។ ស្ថានភាពមានបញ្ហាចំពោះរូបារម្មណ៍ច្រើនតែខ្វះខាតភាពត្រឹមត្រូវទៀងទាត់ និងភាពខ្លាំងក្លា។ ក៏ប៉ុន្តែនៅក្នុងពិភពជុំវិញខ្លួនយើង តែងតែមានវិស័យជាច្រើនដែលគេមិនទាន់សិក្សាស្វែងយល់បាន។ យើងរស់នៅ និងធ្វើសកម្មភាពនៅក្នុងបរិយាកាសមួយដែលជានិច្ចកាលមិនបានផ្តត់ផ្គង់នូវព័ត៌មានដ៏ចាំបាច់ឡើយ។ នេះ

តម្រូវឲ្យមានការលេចធ្លោឡើងនូវរូបារម្មណ៍ស្រដៀងគ្នាចំពោះមនុស្សហើយភាពស្រដៀងគ្នានេះតែងតែមានប្រយោជន៍ជានិច្ច ។

**២. តួនាទីរបស់រូបារម្មណ៍** ( Role de l'imagination )

រូបារម្មណ៍មានភាពចាំបាច់ណាស់ ចំពោះសកម្មភាពរបស់មនុស្សគ្រប់ប្រភេទ ។ ភាពខុសប្លែកគ្នាដ៏សំខាន់រវាងការងាររបស់មនុស្ស និងសកម្មភាពដែលមានលក្ខណៈជាសភាវគតិរបស់សត្វ ស្ថិតនៅត្រង់រូបតំណាងនៃលទ្ធផលដែលបង្កើតឡើងដោយរូបារម្មណ៍ ។ អត្ថន័យសំខាន់បំផុតរបស់រូបារម្មណ៍គឺថា រូបារម្មណ៍មិនគ្រាន់តែជួយឲ្យយើងមើលឃើញនូវលទ្ធផលចុងក្រោយប៉ុណ្ណោះទេ ប៉ុន្តែវាជួយយើងឲ្យ មើលឃើញលទ្ធផលជាខ្សែរយៈនៃការងារទៀតផង។ ហេតុដូច្នេះហើយបានជារូបារម្មណ៍ជួយមនុស្សឲ្យតម្រង់ទិសបាននៅក្នុងពេលដែលលំនាំនៃសកម្មភាពប្រព្រឹត្តិ ទៅដោយបង្កើតបានជារូបសំណាកផ្លូវចិត្តនៃផលិតផលជាចុងបញ្ចប់ ឬលទ្ធផលជាខ្សែរយៈនៃការងារ។ នេះជាហេតុដែលជួយបំពេញបំណងឲ្យក្លាយទៅជាវត្ថុជាក់ស្តែងដែលកើតចេញពីលទ្ធផលទាំងនេះ។ អ្នកកវី វិស្វករ អ្នកវិទ្យាសាស្រ្ត ជាងគំនូរសុទ្ធតែត្រូវការរូបារម្មណ៍ ។ សូម្បីតែនៅក្នុងវិស័យគណិតវិទ្យាក៏ដោយក៏គេត្រូវការរូបារម្មណ៍ដែរ។ បើគ្មាន រូបារម្មណ៍ទេ គេមិនអាចរកឃើញលទ្ធផលដោយឡែកៗ និងលទ្ធផលសរុបបានឡើយ ។ រូបារម្មណ៍ជាគុណភាពដ៏មានតម្លៃជាទីបំផុត ។

តាមពិតរូបារម្មណ៍មានភាពចាំបាច់ណាស់ចំពោះអ្នកវិទ្យាសាស្រ្តនៅពេលណាគេកសាងសម្មតិកម្មលើកឡើងនូវសម្មតិកម្មចំពោះមូលហេតុរបស់បាតុភូត ឬទស្សន៍ទាយជាមុននូវព្រឹត្តិការណ៍ដែលនឹងកើតឡើយ ។ អ្នកនិពន្ធត្រូវបង្កើតឲ្យមានរូបារម្មណ៍ចំពោះរូបភាពតួអង្គ ដើម្បីបញ្ចូលតួអង្គទាំងនោះឲ្យបានសមស្របទៅក្នុងស្នាដៃអក្សរសិល្ប៍របស់គាត់ ។ ជាងគំនូរត្រូវរកឲ្យឃើញជាមុននៅក្នុងខួរក្បាលគាត់នូវផ្ទាំងគំនូរដែលគាត់ត្រូវគូរ ។ ក្នុងការរៀបចំបំណកស្រាយពន្យល់មេរៀន ដូចជាគ្រោងទុកនូវប្រតិកម្មដែលអាចកើតមានឡើងជាសំណួរ និងជាចម្លើយរបស់សិស្ស ។ ដោយអនុវត្តតាមសកម្មភាពអប់រំ អ្នកអប់រំត្រូវកសាងឲ្យបានជាមុននៅក្នុងខួរក្បាលរបស់ខ្លួននូវរូបភាពមនុស្ស ដែលគាត់ចង់បានក្នុងការបណ្តុះបណ្តាលសិស្សបើគ្មានការអភិវឌ្ឍពេញសមត្ថភាពរបស់រូបារម្មណ៍ទេនោះ សិស្សមិនអាចទទួលជោគជ័យក្នុងការសិក្សាបានឡើយ ។ ដោយសារអំណាន ឬការនិទានរឿងព្រេងនៅក្នុងស្នាដៃអក្សរសិល្ប៍ សិស្សត្រូវមានរូបារម្មណ៍នៅក្នុងខួរក្បាលរបស់គេ អំពីអ្វីៗដែលអ្នកនិពន្ធបានពណ៌នា ។

**ឧទាហរណ៍** : ដើម្បីសិក្សាមេរៀនភូមិវិទ្យា សិស្សនឹងលេចឡើងនៅក្នុងខួរ ក្បាលរបស់គេ អំពីរូបារម្មណ៍នៃទេសភាពណាមួយដែលគេមិនទាន់ឃើញនោះ ។ រូបារម្មណ៍ជួយមនុស្សឲ្យមានការអភិវឌ្ឍខាងផ្នែកវិទ្យាសាស្រ្ត បច្ចេកទេស និងសិល្បៈ ។

នៅពេលណាដែលសម្មតិកម្មត្រូវបានបញ្ជាក់ថា ត្រឹមត្រូវពិតប្រាកដមែនហើយ គេនឹងឈានដល់របកគំហើញថ្មីមួយ ។

**ឧទាហរណ៍** : លោក ប៉ាស្ទ័រ បានកំណត់ជាមុននូវសម្មតិកម្មស្តីពីជម្ងឺមួយចំនួន ដែលបណ្តាលមកពីអតិសុខុមប្រាណ ។ ការចងក្រងជាមុននូវសម្មតិកម្មនេះ គឺជាបាតុភូតនៃ រូបារម្មណ៍ ។

ផ្តល់ព័ត៌មានទាំងឡាយដល់អ្នកដែលនៅឆ្ងាយ ។ ដោយសាររូបារម្មណ៍គេបង្កើតបានជា ទូរស័ព្ទ វិទ្យុ និងទូរទស្សន៍សម្រាប់ផ្តល់ព័ត៌មាន ។ រូបារម្មណ៍ក៏ជួយមនុស្សដល់ការអភិវឌ្ឍនៃវិស័យបច្ចេកទេស និងដឹកជញ្ជូនផងដែរ ។

**ឧទាហរណ៍**: មនុស្សត្រូវការធ្វើដំណើរឲ្យបានរហ័ស ។ គេមិនសប្បាយចិត្តនឹងដើរដោយជើងទេ ។ គេបង្កើតបានជា កង់ ម៉ូតូ រថយន្ត កប៉ាល់ និងយន្តហោះ ។

រូបារម្មណ៍រួមចំណែកយ៉ាងសកម្ម នៅក្នុងវិស័យអក្សរសាស្ត្រ និង សិល្បៈ ។ រឿងរាមកេរ្តិ៍ជា ស្នាដៃអក្សរសិល្ប៍ដ៏ល្បីល្បាញក្នុងសកលលោក។ ស្នាដៃអក្សរសិល្ប៍នេះកកើតឡើងដោយសារ រូបារមណ៍ ។ រូបចម្លាក់ និងរូបសំណាកតាមជញ្ជាំងប្រាង្គប្រាសាទបុរាណ គឺពិតជាស្នាដៃដ៏ល្អៗរបស់ជាងចម្លាក់ ដែលសំបូរទៅដោយ រូបារម្មណ៍ ។ អក្សរសិល្ប៍ រូបារម្មណ៍ ធ្វើឲ្យអ្នកអានប្រលោមលោកជក់ចិត្ត និង មានចំណង់ចំណូលចិត្ត ខ្លាំងទៅលើអត្ថបទអក្សរសិល្ប៍។

**ឧទាហរណ៍:** លោក Victor Hugo ជាអ្នកនិពន្ធដែលសំបូរទៅដោយរូបារម្មណ៍។ ស្នាដៃរបស់គាត់ល្បីល្បាញ ដោយសាររូបារម្មណ៍នេះឯង។

ក្នុងអត្ថបទរឿងព្រេងខ្មែរ និង អត្ថបទកំណាព្យក៏សំបូរទៅដោយកថាខ័ណ្ឌ ដែលពិពណ៌នាអំពីធម្មជាតិក្នុងព្រៃព្រឹក្សា ភ្នំ សមុទ្រ ដ៏ពិរោះរណ្តំគួរឲ្យរំជួលចិត្ត តាមរយៈរូបារម្មណ៍នេះដែរ។

**ឧទាហរណ៍:** មើលភ្នំធំធេងវែងរលឹក មើលទឹករលករលាមសាយ មើលដី ដីដុះ វែងអន្លាយ មើលមេឃខ្ពស់ឆ្ងាយដូចឆ្ងាយស្រី ។

រូបារម្មណ៍ពិតជាមានតួនាទីសំខាន់ណាស់ក្នុងការបង្រៀន និង ការអប់រំសិស្ស បានន័យថា រូបារម្មណ៍មានភាពចាំបាច់ណាស់សម្រាប់គ្រូបង្រៀន សាស្ត្រាចារ្យ និង សិស្ស ។ ក្នុងការបង្រៀនអត្ថបទអក្សរសិល្ប៍ដល់ សិស្ស គ្រូបង្រៀននិងសាស្ត្រាចារ្យ ត្រូវប្រើសម្តីដែលសំបូរទៅដោយរូបារម្មណ៍ សំដៅដោយសិស្សចូលចិត្ត តាមដានស្តាប់បំណកស្រាយពន្យល់របស់គ្រូ។ បើសម្តីរបស់គ្រូ ឬសាស្ត្រាចារ្យ គ្មានរូបារម្មណ៍ទេនោះចំណេះដឹងរបស់សិស្សក៏មានកម្រិត ហើយក៏មិនទូលំទូលាយដែរ។

**ឧទាហរណ៍:** ក្នុងការបង្រៀនប្រវត្តិវិទ្យា សិស្សមិនអាចមើលឃើញសកម្មភាពនឹងភ្នែកផ្ទាល់បានឡើយ។ ដោយសារសម្តីសាស្ត្រាចារ្យសំបូរដោយរូបារម្មណ៍ សិស្សអាចយល់ដឹងបានពីការរស់នៅរបស់មនុស្សសម័យដើម ឬ សម័យអង្គរ។ ក្នុងការបង្រៀនពីភូមិវិទ្យា សិស្សមិនអាចមើលឃើញវាលខ្សាច់ ឬ សមុទ្រទឹកកកទេ។ ដោយបំណកស្រាយពន្យល់សំបូរដោយរូបារម្មណ៍ សិស្សអាចយល់ខ្លឹមសារមេរៀនបានយ៉ាងងាយ ។

សិល្បៈករ អ្នកនិយាយវិទ្យុ ឬ ទូរទស្សន៍ អ្នកធ្វើអត្ថាធិប្បាយ អ្នកសារព័ត៌មាន ក៏ត្រូវការប្រើ ឃ្លាប្រយោគ ឬ សម្តីសំបូរទៅដោយរូបារម្មណ៍ដែរ ដើម្បីទាក់ទាញទឹកចិត្តអ្នកស្តាប់ ទស្សនិកជន និង អ្នកអានឲ្យចូលចិត្តដែរ។

**ឧទាហរណ៍:** ពាក្យសម្តី និង កាយវិការរបស់សិល្បៈករ នៅក្នុងឆាកទស្សនីយភាពនិង អ្នកធ្វើអត្ថាធិប្បាយដែលសំបូរដោយទឹកដម និង រូបារម្មណ៍ ទាក់ទាញទស្សនិកជនឲ្យសប្បាយហ៊ោកញ្ជ្រៀវជានិច្ច ។

បើគ្មានការអភិវឌ្ឍដ៏ពេញលេញខាងផ្នែករូបារម្មណ៍ទេនោះ សិស្សមិនអាចមានជោគជ័យក្នុងការសិក្សាឡើយ ។ អំណាន ឬ ការនិទានស្នាដៃអក្សរសិល្ប៍ធ្វើឲ្យសិស្សមានរូបារម្មណ៍នៅក្នុងខួរក្បាល ហើយសិស្សអាចយល់ដឹងបានពីអត្ថន័យនៃខ្លឹមសារក្នុងអត្ថបទ ។

**ឧទាហរណ៍:** ការពិពណ៌នាពីធម្មជាតិ តាមរយៈអត្ថបទកំណាព្យ ឬ បទចម្រៀង ធ្វើឲ្យសិស្សមានរូបារម្មណ៍ អំពីទេសភាពធម្មជាតិ ដែលជួនកាលសិស្សមិនដែលធ្លាប់ឃើញសោះ។

ជួនកាលសិស្សមិនអាចយល់ជ្រួតជ្រាបបានទៅលើឯកសារមេរៀន ដែលត្រូវសិក្សាផង ។ នេះបណ្តាលមកពីសិស្សមិនមានលទ្ធភាព បង្កើតរូបារម្មណ៍តាមខ្លឹមសារឯកសារបាននៅក្នុងខួរក្បាលរស់ពួកគេ ។ គេមិនយល់ទាល់តែសោះនូវអ្វីៗ ដែលសាស្ត្រាចារ្យបកស្រាយពន្យល់ និង អ្វីៗ ដែលគេសរសេរនៅក្នុងឯកសារ។ នៅក្នុងការសរសេរអត្ថបទ តែងសេចក្តី ឬអត្ថាធិប្បាយរបស់សិស្ស រូបារម្មណ៍ក៏មានតួនាទីមួយសំខាន់ណាស់ដែរ។

រូបារម្មណ៍ជះឥទ្ធិពលយ៉ាងខ្លាំងនៅការអភិវឌ្ឍទូទៅខាងផ្នែកបុគ្គលិកលក្ខណៈរបស់សិស្ស ជាពិសេសការអប់រំសីលធម៌តែម្តង ។

**ឧទាហរណ៍:** រូបភាពគម្រូមនុស្ស ដែលជាបញ្ញវន្តប្រកបដោយសីលធម៌ល្អ ដែលយើងចង់បាន ត្រូវបានបង្កើតឡើងនៅក្នុងខួរក្បាលយើង ក្រោមឥទ្ធិពលនៃរូបារម្មណ៍ ។

ក្នុងឋានៈជាលក្ខខណ្ឌមួយរបស់សកម្មភាពនៃការងាររូបារម្មណ៍លេចធ្លោឡើងនៅក្នុងសកម្មភាពការងាររបស់មនុស្ស ។ រូបារម្មណ៍មានដំណើរអភិវឌ្ឍបន្តិចម្តងៗ ហើយមានលក្ខណៈកាន់តែសុក្រឹតឡើងទៅតាមកាលៈទេសៈ ទាំងក្នុងផែនការចលនារបស់ចិត្ត សរីរៈវិទ្យា ក៏ដូចជានៅក្នុងផែនការនៃទម្រង់ស្តែងចេញ ។ ដំណើរអភិវឌ្ឍរូបារម្មណ៍ប្រព្រឹត្តទៅ នៅក្នុងទំនាក់ទំនងគ្នាជាមួយនឹងដំណើរការអភិវឌ្ឍនៃតម្រូវការរបស់មនុស្ស ។ ការលេចចេញឡើងនូវតម្រូវការថ្មី និង ការអភិវឌ្ឍនៃតម្រូវការចាស់ខាងផ្នែកសម្ភារៈ និង ស្មារតី ជំរុញមនុស្សឲ្យដឹកនាំសកម្មភាពកាន់តែសកម្មឡើង ហើយមនុស្សបង្កើតបាននូវអនុភាពច្នៃប្រឌិត (Puissances créatrices) នៅក្នុងជីវភាពរស់នៅ ហើយខិតខំពង្រីកអនុភាពច្នៃប្រឌិតទាំងនេះឥតឈប់ឈរ។

សរុបសេចក្តីមក រូបារម្មណ៍ មានប្រភពចេញមកពីសង្គមមនុស្ស។ រូបារម្មណ៍ ត្រូវបាន គេបង្កើតឡើងនៅក្នុងការងារ។ ហេតុដូច្នេះហើយ រូបារម្មណ៍ កើតមានតែចំពោះមនុស្សទេ ។

## II -មូលដ្ឋានសរីរវិទ្យារបស់រូបារម្មណ៍ ( Base physiologique de l′ imagination )

### ១ ~ រូបារម្មណ៍គឺអាមុខងាររបស់ខួរក្បាល ( L′ imagination est une fonetion du cerveau )

ការលេចធ្លោឡើងនូវ រូបភាពរបស់រូបារម្មណ៍ កើតចេញពីសកម្មភាពរបស់ខួរក្បាល ។ ការបិទទាំងអស់ ( Fermeture complète ) នៃទំនាក់ទំនងសរសៃប្រសាទក្នុងខួរក្បាលមួយរយៈពេល និង ការរស់ឡើងវិញនៃទំនាក់ទំនងទាំងនេះ គឺជាមូលដ្ឋានសរីរវិទ្យាលំនឹក រីឯដំណើរការរបស់រូបារម្មណ៍និង ប្រព័ន្ធនៃទំនាក់ទំនងសរសៃប្រសាទ ដែលត្រូវបានបង្កើតឡើងអស់មួយជីវិតរបស់មនុស្ស ហាក់ដូចជា ចែកមុខងារសម្រាប់សរសៃប្រសាទនីមួយៗនិង រួមបញ្ចូលគ្នាវិញ ដោយបង្កើតបានជាប្រព័ន្ធសរសៃថ្មី។ ការរួមបញ្ចូលគ្នាវិញនោះកើតមានឡើងដោសារតែការកើតមានតំបន់មានរំញោច ដ៏គ្រប់គ្រាន់នៅលើសំបកខួរក្បាល។ តំបន់មានរំញោចនេះត្រូវបានបង្កើតឡើងដោយសារមនុស្សមានតម្រូវការ ឬ មានចំណាប់អារម្មណ៍ដោយផ្ទាល់ទៅលើអ្វីមួយ ។ ដូច្នេះចំពោះអ្នកឯណាដែលកើតមានរូបារម្មណ៍ ក្រុមណឺរ៉ូនត្រូវផ្សាភ្ជាប់គ្នាតាមរបៀបថ្មី ដើម្បីបង្កលក្ខណៈងាយស្រួលឲ្យរូបារម្មណ៍សណ្ឋិតនៅបាន ។ លក្ខណៈពិសេសថ្មីរបស់រូបភាពនៃរូបារម្មណ៍បើធៀបទៅនឹងរូបភាពរបស់លំនឹក និង អត្តសញ្ញាណកម្មតាមផ្នែករបស់រូបភាពទាំងនេះគឺថា រូបភាពនៃរូបារម្មណ៍សណ្ឋិត នៅបានយ៉ាងត្រឹមត្រូវក្នុងណឺរ៉ូនទាំងនោះ ។ ក៏ប៉ុន្តែភាពស្មុគស្មាញនៅក្នុងចលនាសម្ព័ន្ធរបស់រូបារម្មណ៍ ហើយនិងទំនាក់ទំនងរបស់វាជាមួយ និងចិត្តរំភើបធ្វើឲ្យយើងមានមូលដ្ឋានដ៏ត្រឹមត្រូវ ដើម្បីយល់ពីចលនាការ របស់សរីរវិទ្យានៃរូបារម្មណ៍ថាចលនាការនេះ មិនគ្រាន់តែស្ថិតនៅលើសំបកខួក្បាលប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងស្ថិតនៅក្នុងផ្នែកបន្ទាប់បន្សំនៃសំបកខួក្បាលនេះទៀតផង ។ ស្នាដៃសិក្សាស្រាវជ្រាវជាច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះបានស្រាយបំភ្លឺដូច្នេះឯង ។ ផ្នែកបន្ទាប់បន្សំដែលចូលរួមក្នុងលំនាំរបស់រូបារម្មណ៍ នៃប្រព័ន្ធ Thalamus – limbic ដែលជាផ្នែកមួយនៃខួរក្បាលសម្រាប់ទទួលព័ត៌មានរបស់ឥន្ទ្រិយារម្មណ៍ ។ បទពិសោធន៍បានស្រាយបំភ្លឺឲ្យយើងដឹងថា កាលណាផ្នែកនៃខួរក្បាលសម្រាប់ទទួលព័ត៌មានរបស់ឥន្ទ្រិយារម្មណ៍ត្រូវខូចបង់ មនុស្សយើងនិងកើតមានកង្វល់ខាងផ្លូវចិត្តជាមិនខាន។ បន្ទាប់ពីមានកម្មវិធីមួយជាកំណត់មនុស្សយើងនឹងបាត់បង់នូវសតិខាងផ្នែកគ្រប់គ្រងអំពើរបស់ខ្លួន ( Faculté de diriger ses actes ) ។ ដូច្នេះគេអាចសន្និដ្ឋានបានថា ផ្នែកនៃខួរក្បាលសម្រាប់ទទួលព័ត៌មានរបស់ឥន្ទ្រិយារម្មណ៍ ( Thalamus - limbic ) មានមុខងារសម្រាប់បង្កើតផែនការនៃអំពើ ( Plan des actes ) និង កម្មវិធីរបស់អំពើទៅអនាគត ។ នេះជាហេតុធ្វើឲ្យយើងយល់បានថា តួនាទីរបស់ផ្នែកខួរក្បាលដែលទទួលព័ត៌មានរបស់ឥន្ទ្រិយារម្មណ៍ ជាតួនាទីដែលយើងជួបរាល់ថ្ងៃ និង មានលក្ខណៈសាមញ្ញបំផុត ហើយជាតួនាទីរបស់រូបារម្មណ៍ដ៏សំខាន់បំផុត សម្រាប់ស្នើឡើងនូវគម្រោង ផែនការ និង កម្មវិធីនៃអំពើ ។

### ២ ~ រូបារម្មណ៍ និង លំនាំសរីរវិទ្យារបស់សារពាង្គកាយ ( L′ imagination et les processus physiologiques de l′organisme )

រូបភាពដែលបង្កើតឡើងដោយ រូបារម្មណ៍នៅលើសំបកខួរក្បាលបង្កឲ្យមានទង្វើដ៏ទៀងទាត់នៅលើផ្នែកផ្សេងៗជុំវិញសារពាង្គកាយ ហើយជាធាតុធ្វើឲ្យលំនាំនៃសកម្មភាពផ្លាស់ប្តូរបាន ។ នៅសម័យយុគកណ្ដាល (Moyen – Age) គេបានស្គាល់បាតុភូតវិសាមញ្ញ (Phénomènes extra-ordinaires) រួចស្រេចមកហើយដូចជា៖

ចំពោះមនុស្ស ជាពិសេសអ្នកដែលកើតជម្ងឺវិបល្លាសខាងប្រាជ្ញា (Hystérie) កាលណាគេគិតដល់ការឈឺចាប់របស់ព្រះយេស៊ូគ្រីស្តនៅលើឈើឆ្កាង នោះគេគិតដល់បាតដៃ និង បាតជើងដែលមានស្នាមប្រឡាក់ឈាម ព្រមទាំងដំបៅក្លាយ (Ulcères) ដែលបន្សល់ទុកនូវស្នាម ទណ្ឌកម្ម។

គេជួបប្រទះជាញឹកញយផងដែរ ចំពោះអ្នកខ្លះដែលសំបូរទៅដោយរូបារម្មណ៍ ហើយដែលធ្លាប់កើតមាននូវចំណាប់អារម្មណ៍ខ្លាំង និង ព្រឹត្តិការណ៍ដ៏សំខាន់ៗដែលជាប់ពាក់ព័ន្ធនឹងឥទ្ធិពលរបស់រូបារម្មណ៍ នៅលើលំនាំរបស់សរីរវិទ្យា ។

**ឧទាហរណ៍**: - លោក G. Flaubert ជាអ្នកនិពន្ធបារាំង ។ នៅដែលពិពណ៌នាអំពីឆាកមួយដែល Baravy ត្រូវពុលថ្នាំសន្លប់ ខ្លួនគាត់មានអាការៈដូចជាមានថ្នាំពុលនៅក្នុងមាត់ ។

- រាល់ឆ្នាំ លោក Voltaire កើតគ្រុនញាក់ នៅពេលល្ងាចថ្ងៃមួយដែលសាសនិកជន រាប់ពាន់នាក់ត្រូវធ្វើពិធីឧទ្ទិសមួយក្នុងជំនឿស៊ប់នៃសាសនា។ ការគិតច្រើនរបស់លោក Voltarie នៅថ្ងៃនោះធ្វើឲ្យលោកកើតគ្រុនញាក់ ។ សីតុណ្ហភាពក្នុងខ្លួនគាត់ឡើង ឯបេះដូងរបស់គាត់ដើរសង្វាក់ញាប់ ។

តាមរយៈបាតុភូតដូចបានពិពណ៌នាមកហើយនេះ បញ្ជាក់ឲ្យឃើញថា រូបារម្មណ៍ជះឥទ្ធិពលគួរឲ្យកត់សំគាល់បានមកលើដំណើរការប្រព្រឹត្តទៅនៃប្រព័ន្ធជាច្រើនក្នុងសារពាង្គកាយរបស់យើង ។ ករណីអស់ទាំងនេះជាប្រភពនៃធាតុពិត និង ជាអនុភាពនៃរូបារម្មណ៍របស់មនុស្ស ។

## III. វិធីកសាងរូបភាពថ្មីនៅក្នុងរូបារម្មណ៍ (Méthodes d'édifier I' image nouvelle dans I' imagination)

រូបភាពថ្មីរបស់រូបារម្មណ៍ ត្រូវបានបង្កើតឡើងទៅតាមបែបបទជាច្រើនផ្សេងគ្នា ដូចជា ៖

### ១. វិធីផ្លាស់ប្តូរវិមាត្រ និង ចំនួននៃផ្នែកជាសមាសធាតុរបស់វត្ថុ ( Méthode de changer les dimension et le nombre des parties composantes de I' objet )

ក្នុងករណីនេះ គេឃើញមានដូចជា ៖ រូបភាពរបស់យក្ស ( L' image des géants ) រូបសំណាក់របស់ព្រះពុទ្ធដែលមានដៃច្រើន ... ។ ញញួរសម្រាប់វាយសម្លង ជាញញួរធំហើយវាមិនមានរូបភាពដូចញញួរធម្មតាទេ ព្រោះវិមាត្ររបស់វាខុសប្លែកគ្នាពីញញួរធម្មតាច្រើនណាស់។

### ២. វិធីធ្វើឲ្យមានតម្លៃជាក់ស្តែង ( Méthode de mettre en relief )

គឺជាបែបបទបង្កើតឲ្យមានរូបភាពថ្មី ដោយកំណត់យកតែផ្នែកដោយឡែកនៃគុណភាព, ទំនាក់ទំនងណាមួយរបស់វត្ថុ ឬ បាតុភូត ជាមួយនិងវត្ថុ ឬ បាតុភូតផ្សេងទៀត ដោយយករូបភាពថ្មីរបស់វត្ថុ ឬ បាតុភូត ដែលទើបបង្កើតបាននោះ មកដាក់ក្នុងចំណាត់ថ្នាក់ទី១ វិញ ។ វិធីមួយផ្សេងទៀតដែលគេប្រើប្រាស់ក្នុងករណីនេះ គឺវិធីបំផ្លើស ។

**៣. វិធីផ្គុំផ្នែកផ្សេងៗបញ្ចូលគ្នា** ( Méthode d´ agglutination )

គឺជាវិធីបណ្តុះផ្នែកសមាសភាគជាច្រើនរបស់វត្ថុផ្សេងគ្នា ដោយបង្កើតបានតែរូបភាពថ្មីតែមួយ ។

**ឧទាហរណ៍ ៖** រូបភាពម៉ុងសាយចិន ។ រូបភាពរបស់ព្រះសិវៈ មានក្បាលជាដំរី និងខ្លួនជាមនុស្ស ។ រូបភាពរបស់សត្វស្វាំង មានក្បាលជាមនុស្ស ខ្លួនជាសត្វតោ ។ រូបភាពថ្មីនៃរូបារម្មណ៍នេះមានផ្នែកផ្សេងៗដែលជាសមាសធាតុផ្គុំបញ្ចូលគ្នានេះឥតមានរខិតបាត់ ឬ ផ្លាស់ឡើយ ។

**៤. វិធីលាយចម្រុះគ្នា** ( Méthode de combinaison )

គ្រាន់តែក្រឡេកឃើញភ្លាម យើងដឹងថា វិធីនេះមានភាពស្រដៀងគ្នាបន្តិចបន្តួច ទៅនឹងវិធីផ្គុំផ្នែកផ្សេងៗបញ្ចូលគ្នា ។ ក៏ប៉ុន្តែរូបភាពនេះមិនមែនជាបណ្តុះដ៏សាមាញ្ញ ឬ ការចាប់ផ្គុំយកទៅតាមធាតុដើមរបស់វាឡើយ ។ ដោយដាក់បញ្ចូលគ្នាឲ្យបានរូបភាពថ្មីមួយនោះ ធាតុដើមត្រូវផ្លាស់ប្តូរទ្រង់ទ្រាយទាំងអស់ ។ កាលណាផ្លាស់ប្តូររួច ធាតុទាំងនោះមានទំនាក់ទំនងថ្មីមួយ ។ ការលាយចម្រុះគ្នាគឺជាការធ្វើសំយោគតាមរបៀបច្នៃប្រឌិត (Synthése créatirce ) ហើយនេះក៏មិនមែនជាការដាក់បន្ថែមយ៉ាងសាមញ្ញទៅលើធាតុដែលគេស្គាល់មកហើយនោះទេ។ វិធីនេះត្រូវបានគេយកទៅប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងវិស័យបច្ចេកទេស វិទ្យាសាស្ត្រ អក្សរសិល្ប៍ និងសិល្បៈ ។

**៥. វិធីគំរូកម្ម** ( Méthode de typisation )

នេះគឺជាវិធីសាស្ត្របណ្តុះបណ្តាលរូបភាពថ្មី ដែលមានលក្ខណៈស្មុគស្មាញបំផុត ដែលក្នុងរូបភាពនេះមានលក្ខណៈគំរូ ( Propriétés typiques ) ចរិតលក្ខណៈរបស់បុគ្គលិកលក្ខណៈដែលជាតំណាងរបស់ស្រទាប់សង្គមមួយជាកំណត់ ។ វិធីនេះត្រូវបានគេយកមកប្រើប្រាស់នៅក្នុងសកម្មភាពបង្កើតស្នាដៃអក្សរសិល្ប៍ ( Création des œuvres littéraires ) ស្នាដៃសិល្បៈ( Œuvres artistiques ) និងក្នុងសិល្បៈចម្លាក់ ( Sculpture ) ។ ធាតុនៃចម្លាក់ដែលគេប្រើសម្រាប់ដាក់ក្លោងទ្វារ ( Chef de voûte ) តាមបែបគំរូកម្មនោះ គឺជាសំយោគច្នៃប្រឌិត ( Synthése créatirce ) និងទូទៅកម្មទៅលើលក្ខណៈផ្សេងៗ ដូចជាលក្ខណៈដោយឡែក និង គំរូរបស់បុគ្គលិកលក្ខណៈ ។

**៦. វិធីសទិសភាព** (Méthode d´ analogie)

កាលពីសម័យសង្គមបុព្វកាលរបស់មនុស្សជាតិ បុព្វបុរសរបស់យើងចេះបង្កើតឧបករណ៍ដ៏សាមញ្ញបំផុតរួចមកហើយ ទៅតាមសទិសភាពនៃការធ្វើដោយដៃ ។ ឧបករណ៍ទាំងនេះ ជាឧបករណ៍ការងារដែលគេផលិតសម្រាប់ប្រើប្រាស់ ។ មុននឹងផលិតបាននូវឧបករណ៍ការងារទាំងនោះមនុស្សបាន

រកឃើញសទិសភាពនៅក្នុងខួរក្បាលរបស់គេ ។ ដោយសារតែសទិសភាពនេះហើយ ទើបឧបករណ៍នៃការងារត្រូវបានគេធ្វើឡើងដោយគ្រាប់តាមទំនងនៃចលនានៃដៃរបស់មនុស្សដែលកាន់ឧបករណ៍នោះ ។ សព្វថ្ងៃនេះ ការយល់ដឹងពីទំនាក់ទំនងរវាង ជីវសាស្ត្រ និង អគ្គិសនី ( Bionique = Qui concerne la biologie et l´électronique ) គឺជាការ អភិវឌ្ឍក្នុងកម្រិតខ្ពស់បំផុតរបស់វិធីសទិសភាពនៅក្នុងលំនាំនៃរបកគហើញរបស់អ្នកវិទ្យាសាស្ត្រ ។

IV. **ចំណែកថ្នាក់របស់រូបារម្មណ៍** (Classification des imaginations)

គេធ្វើចំណែកថ្នាក់រូបារម្មណ៍ ដោយឈរលើមូលដ្ឋាននៃចរិតលក្ខណៈពីរយ៉ាងគឺ ចរិតសកម្ម និងជាតុពិត (Le caractère actif et l´ effectivité ) ។

**ក ~ រូបារម្មណ៍មិនគិតទុកមុន** ( Imagination non préméditée )

រូបារម្មណ៍នេះកើតឡើងដោយចៃដន្យ ដោយឈរលើមូលដ្ឋាននៃប្រត្យក្សារម្មណ៍ណាមួយ ។ នៅក្នុងជីវភាពរស់នៅមនុស្ស គេតែងតែជួបប្រទះនឹងរូបារម្មណ៍មិនគិតទុកមុននេះជានិច្ច ។

**ឧទាហរណ៍ ៖** យើងមើលឃើញដុំពពកទាំងឡាយនៅលើមេឃ ។ យើងឃើញដុំពពកទាំងនោះមានទ្រង់ទ្រាយទៅតាមទំនើងចិត្តរបស់វា ។ យើងអាចនឹកគិតថា ដុំពពកខ្លះមានរាងជាមនុស្ស ខ្លះជារូបភាពនៃវិមានមួយ ខ្លះទៀតជារូបសេះ ឬ រូបដំរី ។

- ក្នុងវង្វង់ព្រះច័ន្ទពេញបូរមី អ្នកខ្លះមើលឃើញថា ជាដើមពោធិ៍ អ្នកខ្លះទៀតមើលឃើញជារូបសត្វទន្សាយ ។

- ក្នុងពេលរាត្រីស្ងាត់ យើងស្តាប់ឮសូរសម្លេងចម្លែក និងស្នូរកាំភ្លើង ។ យើងគិតថា គឺជាចោរ ឬឧក្រិដ្ឋជន ម្នាក់ដែលត្រូវគេចាប់បាន ។

- យើងធុំក្លិនម្ហូប ដែលរសាត់ចេញពីផ្ទះបាយ ធ្វើឲ្យយើងនឹងឃើញទៅដល់ម្ហូបឆ្ងាញ់ពិសា ។

រូបារម្មណ៍ទាំងនេះ គឺជារូបារម្មណ៍ដែលមិនបានគិតទុកមុន វាកើតឡើងមកលើយើងដោយចៃដន្យ ហើយដោយសារប្រត្យក្សារម្មណ៍ណាមួយ ។

**ខ ~ រូបារម្មណ៍គិតទុកមុន** ( Imagination préméditée )

រូបារម្មណ៍នេះតម្រង់មុខសញ្ញាទៅរកតាមគោលដៅមួយដ៏ប្រាកដប្រជា ដោយមានផែនការ និងវិធីសាស្ត្រច្បាស់លាស់ ។ គេយករូបារម្មណ៍នេះមកប្រើប្រាស់នៅក្នុងការបង្រៀន ការអប់រំសិស្ស និងក្នុងការងារពលកម្ម ។

**ឧទាហរណ៍៖**

- ក្នុងការរៀបចំមេរៀន ដើម្បីបង្រៀនសិស្សផ្នែកអក្សរសាស្ត្រអំពីរឿងទុំទាវ សាស្ត្រាចារ្យត្រូវធ្វើឲ្យសិស្សចេះនឹកគិតដល់ សេដ្ឋកិច្ច របបសង្គម និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរក្នុងសង្គម

  លង្វែក។

- យើងបានស្គាល់លោក Christophe Colomb ។ មុននឹងចេញដំណើរពីទ្វីបអឺរ៉ុបទៅប្រទេសឥណ្ឌាតាមទិសខាងលិច លោក Christophe Colomb បានគិតថា បើផែនដីរាងមូលមែនគាត់ចេញដំណើរទៅទិសខាងលិចនេះ នឹងធ្វើឲ្យគាត់វិលចូលមកទ្វីបអឺរ៉ុបវិញមិនខាន ។ គាត់បានរកឃើញពិភពថ្មីមួយ ដែលគាត់មិនស្គាល់ ។ ប៉ុន្តែមុនពេលដែលគាត់ស្លាប់ គាត់ជឿថាគាត់បានទៅដល់ប្រទេសឥណ្ឌា។

ដូច្នេះរូបារម្មណ៍ប្រភេទនេះ ជារូបារម្មណ៍គិតទុកមុន និង បញ្ហាដោយគោលដៅមួយជាក់លាក់ ។ រូបារម្មណ៍គិតទុកមុន អាចចែកចេញជាពីរប្រភេទទៀតគឺៈ

- រូបារម្មណ៍បង្កើតឡើងវិញ ( Imagination reproductive )
- រូបារម្មណ៍ច្នៃប្រឌិត (Imagination Creatrice )

### **ខ.១ ~ រូបារម្មណ៍បង្កើតឡើងវិញ** (Imagination reproductive )

រូបារម្មណ៍នេះ គឺជារូបារម្មណ៍ដែលបង្កើតរូបភាពថ្មី ដោយផ្អែកលើបទពិសោធន៍ និង កត្តាដែលបានមកពីប្រត្យក្សារម្មណ៍ណាមួយ ។ ការកសាងរូបភាពថ្មីនេះ មានគោលដៅបណ្ដុះបណ្ដាលចំណេះដឹងថ្មីពីវត្ថុ ឬ បាតុភូតតាមរយៈការពិពណ៌នារបស់អ្នកដទៃ ។ រូបារម្មណ៍ប្រភេទនេះ បង្កើតបានជារូបភាពនៃរូបតំណាងទាំងឡាយដែលផ្អែកលើនិទានថា ឬ អត្ថាធិប្បាយណាមួយ ។

**ឧទាហរណ៍៖**

- សាស្ត្រាចារ្យធ្វើអត្ថាធិប្បាយពីការរស់នៅរបស់មនុស្សជំនាន់ដើមឲ្យសិស្សស្ដាប់ ។ សិស្សផ្ទៀងស្ដាប់ ហើយតាមរយៈអត្ថាធិប្បាយនោះ សិស្សអាចយល់ដឹងបានពី របៀបរស់នៅរបស់មនុស្សសម័យដើម ។
- សាស្ត្រាចារ្យធ្វើអត្ថាធិប្បាយពីវាលខ្សាច់ និង សមុទ្រទឹកកកឲ្យសិស្សស្ដាប់ ។ ដោយសំដីរបស់គ្រូសំបូរទៅរូបារម្មណ៍ សិស្សអាចយល់ដឹងបានពីវាលខ្សាច់ និង សមុទ្រទឹកកក ។ នេះជារូបារម្មណ៍បង្កើតឡើងវិញ ។

### **ខ.២ ~ រូបារម្មណ៍ច្នៃប្រឌិត** (Imagination creatrice)

រូបារម្មណ៍ប្រភេទនេះបង្កើតរូបភាពនៃរូបតំណាងថ្មី ។ សម្រាប់វត្ថុ និង បាតុភូត ដែលមិនទាប់មាននៅឡើយ ។ រូបភាពនៃរូបតំណាងនេះជារូបភាពដែលមិនទាន់មាននៅក្នុងតថភាពសត្យានុម័តនៅឡើយ។

**ឧទាហរណ៍៖**

- តាំងពីយូរយារណាស់មកហើយ មនុស្សបាននឹកស្រមៃដល់ការហោះហើរក្នុងអវកាស ។

នៅសតវត្សទី១៨ មិនទាន់មានវាមុជទឹកនៅឡើយ ។ ប៉ុន្តែលោក ស៊ុល វែន បានបង្កើតណូទីលីស ដែលជានាវាមុជទឹកមួយ ។

មុនសម័យកាលរបស់លោក Pasteur គ្មាននរណាម្នាក់ជឿថា មានមេរោគទេ ។

មុនសម័យលោក Newton គ្មាននរណាម្នាក់ពិតពីទំនាញផែនដីទេ ។ ទាំងនេះជារូបារម្មណ៍ច្នៃប្រឌិត ។

V - **ការស្រមៃ និង ឧត្តមគតិ** ( Le reve et l ideal )

**ក ~ ការស្រមៃ** ( Le reve )

ការស្រមៃ និង ឧត្តមគតិជាទម្រង់ពិសេសរបស់រូបារម្មណ៍ ។ ការស្រមៃ និង ឧត្តមគតិជារូបារម្មណ៍ដែលតម្រង់ទិសឆ្ពោះទៅអនាគត ។ ការស្រមៃ និង ឧត្តមគតិសំដែងចេញនូវចំណង់ចំណូលចិត្ត និង បំណងប្រាថ្នារបស់មនុស្ស ។ ការស្រមៃមានភាពស្រដៀងគ្នា និងរូបារម្មណ៍ច្នៃប្រឌិត ត្រង់ដែលវាស្ទើរតែជាលំនាំមួយនៃការបណ្តុះបណ្តាលតាមរបៀបដាច់ដោយឡែកឲ្យបានជារូបភាពថ្មី។ ដូច្នេះការស្រមៃជារូបភាពអនាគតមួយដែលគេប្រាថ្នាចង់ឃើញ និង ចង់បាន ។ ការស្រមៃក្លាយទៅជាមានប្រយោជន៍តែនៅពេលណាដែលវាជំរុញមនុស្សឲ្យក្រោកឈរឡើង ហើយប្រែក្លាយការស្រមៃនោះក្លាយទៅជាតថភាព ។ កាលណាការស្រមៃមិនអាចសម្រេចបានទៅតាមសមត្ថភាពជាក់ស្តែងរបស់មនុស្ស ការស្រមៃនោះក្លាយទៅជាការស្រមៃមិនបានសម្រេច ( Reve irrealisable ) ។ ជាការពិតណាស់ ការស្រមៃរបៀបនេះមិនអាចក្លាយទៅជាតថភាពបានឡើយ ។ ដូច្នេះការស្រមៃ អាចធ្វើឲ្យមនុស្សបាត់បង់សេចក្តីក្លាហាន ឬ អស់សង្ឃឹមទៅលើអ្វីមួយបាន ។ ការស្រមៃត្រូវមានអត្ថន័យចំពោះសង្គម ។

**ឧទាហរណ៍ ៖** កាលពីយើងនៅវ័យជំទង់ពីអាយុ ១៣ ទៅ ១៤ ឆ្នាំ យើងស្រមៃចង់ក្លាយទៅជាវីរបុរសម្នាក់ដែលជិះសេះ ហើយវាយសំរុកទៅលើពួកបច្ចាមិត្ត ឬ ម៉្យាងទៀតយើងស្រមៃចង់ក្លាយទៅជាអ្នកបើកយន្តហោះចំបាំង ។ នេះជាការស្រមៃរបស់វ័យជំទង់ ។

ការស្រមៃខ្លះលើកឡើងពីអនាគត ។ ប៉ុន្តែការស្រមៃខ្លះមានប្រយោជន៍បានន័យថា ការស្រមៃដែលជំរុញមនុស្សឲ្យតស៊ូ ពុះពារឧបស័គ្គ និង បញ្ចេញសកម្មភាព ។

**ឧទាហរណ៍ ៖** យើងស្រមៃថា ក្នុងមួយឆាកជីវិតរបស់យើង យើងនឹងក្លាយទៅជាអ្នកមាន យើងស្រមៃថានឹងមានភូមិគ្រឹះមួយនៅឆ្នេរសមុទ្រកែប កំពង់សោម ឬ បូកគោ ។ រាល់ថ្ងៃអាទិត្យ យើងនឹងបើករថយន្តដ៏ថ្មីស្រឡាង នាំគ្រួសាររបស់យើងទៅសម្រាកស្រូបយកខ្យល់ត្រជាក់នៅទីនោះ ។

ការស្រមៃខ្លះក្លាយទៅជាមិនបានសម្រេច ឥតប្រយោជន៍ធ្វើឲ្យយើងខាតពេល។ ក្នុងពេលសិក្សាក្នុងថ្នាក់អ្នកមិនត្រូវស្រមៃពីនេះពីនោះទេនាំឲ្យអារម្មណ៍របស់អ្នកឃ្លាតចាកពីមេរៀនដែលគ្រូកំពុងតែ

ពន្យល់ ។ ដូច្នេះគេត្រូវចៀសវាងការស្រមៃឥតប្រយោជន៍ ។ ការស្រមៃខ្លះទៀត តម្រង់សកម្មភាព និង ទឹកចិត្តមនុស្សឲ្យអនុវត្ត ភ្លាមៗតែម្តងសំដៅសម្រេចសកម្មភាពតាមគោលបំណង ។

**ឧទាហរណ៍ ៖** អ្នកស្រមៃថា នឹងក្លាយទៅជាសាស្ត្រាចារ្យបរិញ្ញាដ៏នៅវ័យក្មេងម្នាក់ ហើយមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅក្នុងវិទ្យាល័យមួយ ។ អ្នកនឹងក្លាយទៅជាសាស្ត្រាចារ្យ ដែលយុវសិស្សចូលចិត្ត ។

**ខ ~ ឧត្តមគតិ** ( I′ ideal )

ឧត្តមគតិជារូបភាពដ៏ល្អបំផុតរបស់ជនឧត្តុង្គឧត្តមម្នាក់ ។ ឧត្តមគតិអាចជារូបភាពរបស់សង្គមដ៏ល្អឥតខ្ចោះ ។ រូបភាពនេះអាចក្លាយទៅជា កម្លាំងមួយដែលទាក់ទាញសកម្មភាពអស់មួយឆាកជីវិតរបស់បុគ្គលណាម្នាក់ ឲ្យដើរតាមឧត្តមគតិរបស់ខ្លួន។

ការស្រមៃតាមធម្មតាកើតមានមួយដងមួយកាលទេ។ ការស្រមៃធម្មតាមិនស្ថិតនៅជាប់បានយូរទេ ឯឧត្តមគតិវិញជាទម្រង់មួយរបស់ការស្រមៃដែរ។ ឧត្តមគតិបណ្តិតនៅជាប់យូរណាស់ក្នុងខួរក្បាលមនុស្សប្រសើរជាងនេះទៀត គេនិយាយថា ឧត្តមគតិជាគោលដៅជិវិតមនុស្ស។ ជួនកាលឧត្តមគតិគឺជាកម្លាំង ដែលជម្រុញយើងឲ្យដល់គោលដៅ។ ឧត្តមគតិមានលក្ខណៈសកម្មភាពជាងស្រមៃ។ ឧត្តមគតិជារូបភាព ដ៏ស្រស់បំព្រង ហើយជាក់ស្តែងដែលមនុស្សប្រាថ្នាចង់បានទៅអនាគត។

**ឧទាហរណ៍ ៖** ឧត្តមគតិរបស់យើងទាំងអស់គ្នា គឺកសាងប្រព័ន្ធអប់រំកម្ពុជាឲ្យបានដូចប្រទេសជឿនលឿននានាក្នុសកលលោក។ យើងមានឧត្តមគតិមួយជួយប្រជាជនកម្ពុជា យើងឲ្យមានអរិយធម៌ វប្បធម៌ និងសង្គមធម៌។ នេះជាឧត្តមគតិរបស់យើងសព្វថ្ងៃ នេះ។ យើងម្នាក់ៗមានឧត្តមគតិរូបីយ៍របស់យើងផ្ទាល់។ យើងខំបណ្តុះបណ្តាល ខ្លួនយើងឲ្យទៅជាសាស្ត្រាចារ្យដ៏មានឈ្មោះល្បី។

## VI. ទំនាក់ទំនងរវាងរូបារម្មណ៍ និងការគិត ( Relation entre I′ imagination et la pensée )

រូបារម្មណ៍ក៏ដូចជាការពិតដែរ។ រូបារម្មណ៍ជួយយើងឲ្យគ្រោងទុកជាមុននូវផែនការការងារ ទៅអនាគត។ ការគិត និងរូបារម្មណ៍ជួយយើងឲ្យប្រមោលទុកមុននូវលទ្ធផលដែលបានទទួលពី ការងាររបស់យើង និងជួយកែតម្រូវសកម្មភាពដែលយើងបំរុងនឹងធ្វើ សំដៅឆ្លើយតប និងមជ្ឈដ្ឋាន សង្គមដែលផ្លាស់ប្តូរឥតឈប់ឈរ។ រូបារម្មណ៍ជួយយើងស្ថិតក្នុងស្ថានភាពមានបញ្ហាហើយដែលពេលនោះឥន្ទ្រីយារម្មណ៍ ប្រត្យក្សារម្មណ៍ និងការគិតគ្មានសមត្ថភាពដោះស្រាយបញ្ហានោះបាន។

**ឧទាហរណ៍ ៖** ពេលមេឃកំពុងភ្លៀង តើយើងត្រូវចេញដំណើរ ឬមិនទៅ ? កាលណាមជ្ឈដ្ឋានសង្គមសម្រាប់គ្រប់គ្រាន់ គេប្រើរូបារម្មណ៍ ដើម្បីដោះស្រាយវិញម្តង។

**ឧទាហរណ៍៖** ក្នុងរឿងព្រេងមានតួអង្គយក្ស។ យក្សថាតំណាងតួអង្គមនុស្សអាក្រក់មាន ចិត្តឃោរឃៅ។

**សន្និដ្ឋានគរុកោសល្យ** ( Conlusion pédagogique )

រូបារម្មណ៍មានសារៈសំខាន់ណាស់ក្នុងការបង្រៀន និងការអប់រំ។ ដូច្នេះគ្រូបង្រៀន និងសាស្ត្រាចារ្យគប្បី៖

១. ប្រើសម្ភីដែលសម្បូរទៅដោយរូបារម្មណ៍ ដើម្បីទាក់ទាញបម្រុងប្រយ័ត្ន និងចំណាប់ចំណូលចិត្ត របស់ក្នុងម៉ោងសិក្សា។

២. ជួយឲ្យរូបារម្មណ៍របស់សិស្សអភិវឌ្ឍ ដោយផ្តល់ឲ្យសិស្សនូវរូបភាពនៃរូបតំណាងសំខាន់ៗ សំដៅពង្រឹងពង្រីក រូបារម្មណ៍បង្កើតឡើងវិញ និងរូបារម្មណ៍ច្នៃប្រឌិតឲ្យសម្បូរបែប។

៣. ជួយសិស្សក្នុងការកសាងឧត្តមគតិសម្រាប់ឆាកជីវិតរបស់គេ។

## សំណួរ

១- ចូរប្រៀបធៀប រូបារម្មណ៍ ជាមួយនឹង លំនឹក។

២- ចូរប្រៀបធៀប រូបារម្មណ៍គិតទុកមុន និង រូបារម្មណ៍មិនគិតទុកមុន។

៣- ការគិតស្រមៃ និងឧត្តមគតិខុសគ្នា ត្រង់ចំណុចណាខ្លះ?

៤- ការគិត និង រូបារម្មណ៍ មានទំនាក់ទំនងនិងគ្នាយ៉ាងណាខ្លះ?

## មេរៀនទី១២ ៖ ចិត្តរំភើប និង សញ្ចេតនា ( ÉMOTION ET SENTIMENT )

- **សញ្ញាណទូទៅស្ដីអំពីចិត្តរំភើប និងសញ្ចេតនា** ( Notion général sur l'émotion et le sentiment )
- **បញ្ញត្តិស្ដីពីចិត្តរំភើប និងសញ្ចេតនា** ( Concept de l'émotion et du sentiment )

នៅក្នុងលំនាំនៃចំណេះដឹង ហើយនិងការប្រែក្លាយតថភាព មនុស្សយើងតែងតែមានឥរិយាបថមួយជាកំណត់ ចំពោះវត្ថុ និងបាតុភូតជាក់ស្ដែង។ ឥរិយាបថនេះ កើតមានឡើងទៅតាមតម្រូវការផ្នែកសម្ភារៈ និងផ្នែកស្មារតី ដែលជួនកាលធ្វើឲ្យមនុស្សពេញចិត្ត ជួលកាលមិនពេញចិត្តក៏មាន។ ឥរិយាបថបែបមួយនោះរបស់មនុស្សចំពោះតថភាព គេហៅថា សញ្ចេតនា ឬ ចិត្តរំភើប។ ដូច្នេះ ចិត្តរំភើប ឬ សញ្ចេតនា គឺជាឥរិយាបថរបស់មនុស្សចំពោះវត្ថុ និងបាតុភូតជាក់ស្ដែង ដែលជាប់ទាក់ទិនទៅនឹងការពេញចិត្ត ឬមិនពេញចិត្តនៅក្នុងតម្រូវការខាងផ្នែកសម្ភារៈ និងស្មារតីរបស់មនុស្ស។

តថភាពសត្យានុម័ត គឺជាប្រភពនៃសញ្ចេតនារបស់មនុស្ស។ ផ្ទុយទៅវិញនៅក្នុងលំនាំនៃចំណេះដឹង សញ្ចេតនារបស់មនុស្សមិនមែនជាចំណាំងរបស់តថភាពសត្យានុម័តទេ ក៏ប៉ុន្តែគឺជាទំនាក់ទំនងម៉្យាងរវាងវត្ថុ និងបាតុភូតជាក់ស្ដែង ហើយម៉្យាងទៀតគឺជាតម្រូវការ និងមូលហេតុនៃសកម្មភាពរបស់មនុស្សទៅវិញ។ តាមធម្មតា គេមិនយកចិត្តទុកដាក់ក្នុងករណីនេះប៉ុន្មានទេ គឺគេគ្រាន់តែប្រកាន់យកឥរិយាបថឆ្ពោះទៅរកវត្ថុ និងបាតុភូតដែលជាប់ពាក់ព័ន្ធនឹងតម្រូវការរបស់គេតែប៉ុណ្ណោះ។ ដោយយោងទៅតាមតម្រូវការដែលគេពេញចិត្ត ឬមិនពេញចិត្ត នោះមនុស្សបង្ហាញនូវចរិតសកម្ម ឬអសកម្ម ពេញចិត្ត សប្បាយរីករាយ គាប់ចិត្ត ឬមិនគាប់ចិត្ត ឈឺចាប់ ឬត្រេកអរ។ល។

តម្រូវការរបស់មនុស្សមានច្រើនប្លែកគ្នា ក៏ប៉ុន្តែបាតុភូតនៅក្នុងតថភាពក៏ស្មុគស្មាញណាស់ដែរ។ បាតុភូតបែបណាមួយនោះ អាចធ្វើឲ្យមនុស្សពេញចិត្តពេញថ្លើម ទៅលើតម្រូវការបែបនោះដែរ ក៏ប៉ុន្តែវាមិនអាចធ្វើឲ្យពេញចិត្តទៅលើតម្រូវការផ្សេងទៀតបានឡើយ។ នៅក្នុងជីវភាពប្រតិបត្តិ គេមិនសូវជួបប្រទះនឹងស្ថានការណ៍ដែលមានលក្ខណៈដូចតទៅនេះ៖ បាតុភូតដែលអាចបង្កបាននូវចិត្តរំភើបផ្សេងគ្នា ឬក៏បដិបក្ខមិនដូចគ្នាឡើយ។

**ឧទាហរណ៍៖** មនុស្សម្នាក់ដែលចូលចិត្តទិទៀនសម្លាញ់របស់ខ្លួនយ៉ាងស្វិតស្វាល និងយ៉ាងម៉ឺងម៉ាត់។ ដោយសារការទិទៀនគេ គាត់ពេញចិត្តទៅលើទស្សនៈសីលធម៌ ក៏ប៉ុន្តែទន្ទឹមនឹងនោះ គាត់មានការឈឺចាប់ កាលបើមាននរណាម្នាក់និយាយមើលងាយមិត្តសម្លាញ់របស់គាត់។

- **ការញែកឲ្យដាច់ពីគ្នារវាងចិត្តរំភើប និង សញ្ចេតនា ហើយនឹងចំណងទាក់ទងរវាងវា**

យើងត្រូវលើកឡើងនូវបញ្ហាដែលញែកឲ្យដាច់ចំពោះបញ្ញត្តិ "សញ្ចេតនា" ពីបញ្ញត្តិ "ចិត្តរំភើប"។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃបញ្ញត្តិទាំងពីរនេះហាក់ដូចជាប្រទាក់គ្នាហើយគេមិនអាចញែកឲ្យដាច់ស្រឡះឡើយ។ ថ្វីត្បិតតែយ៉ាងនេះក៏ដោយ ទទឹមនឹងនេះគេអាចធ្វើការញែកដាច់ពីគ្នាបានបន្តិចបន្តួចដែរ។

យើងអាចយល់ដឹងបានថា ចិត្តរំភើបគឺជាលំនាំផ្លូវចិត្ត រីឯសញ្ចេតនាវិញគឺជាលក្ខណៈចិត្ត ពោលគឺចិត្តរំភើបជាបាតុភូតមួយ ដែលមានចរិតបណ្តោះអាសន្ន ហើយវាស្តែងចេញឲ្យឃើញនៅក្នុងកាលៈទេសៈណាមួយដ៏ជាក់ស្តែង ចំណែកឯសញ្ចេតនាវិញ គឺជាបាតុភូតមួយដែលមានចរិតស្ថិតស្ថេរ ហើយសណ្ឋិតនៅក្នុងខ្លួនមនុស្ស។

**ឧទាហរណ៍៖** ការស្រលាញ់ម្តាយជាសញ្ចេតនាមួយ។ កាលណាកូនទទួលបានលទ្ធផលល្អចំពោះការសិក្សាម្តាលមានចិត្តត្រេកអរសប្បាយ (ការសប្បាយចិត្តជាចិត្តរំភើប)។ ក៏ប៉ុន្តែកាលណាកូនប្រព្រឹត្តខុសឆ្គងម្តាយកើតចិត្តខឹងលំបាកនឹងកូន (កំហឹងជាចិត្តរំភើប) ឬក៏កាលណាកូនឈឺ ម្តាយបញ្ចេញនូវទឹកមុខក្រៀមក្រំ ព្រួយបារម្ភ (ភាពក្រៀមក្រំ និង ការព្រួយបារម្ភនេះជាចិត្តរំភើប)។

ដូច្នេះមានន័យថា សញ្ចេតនានិងចិត្តរំភើប មានចំណងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ។ គេអាចនិយាយបានថា ចិត្តរំភើបចាត់ទុកថា ជាមូលដ្ឋាន និង ជាមធ្យោបាយនៃការស្តែងចេញនូវសញ្ចេតនា ហើយសញ្ចេតនាគឺជាលទ្ធផលនៃការធ្វើសំយោគ ការធ្វើទូទៅកម្ម និង ការពង្រឹងចិត្តរំភើបទៅតាមលំដាប់ថ្នាក់ដូចគ្នា។

- **លក្ខណៈពិសេសនៃចិត្តរំភើបនិងសញ្ចេតនា**

ចិត្តរំភើប និង សញ្ចេតនាមានលក្ខណៈពិសេសពីរយ៉ាងគួរឲ្យកត់សំគាល់បានដូចតទៅ៖

**១. លក្ខណៈពិសេសទី ១៖** គឺបដិវាទកម្មរវាងទស្សនៈ បើគេនិយាយពីការសប្បាយ បានន័យថាគេប្រៀបធៀបរួចមកហើយនៅក្នុងគំនិតគេទៅនឹងសេចក្តីទុក្ខក្រៀមក្រំ។ ការពេញចិត្ត ផ្ទុយនឹងការខឹងសម្បារ ភាពមានសុភមង្គល ផ្ទុយគ្នាទៅនឹងការឈឺចាប់ សេចក្តីស្នេហាផ្ទុយនឹងការប៉ោះបង់ចោល ឬ ការស្អប់ខ្ពើម។

**២. លក្ខណៈពិសេសទី ២៖** គឺចរិតទ្វេភាគី។ សញ្ចេតនា និង ចិត្តរំភើប ជាទូទៅមានពីរផ្នែក គឺផ្នែកវិជ្ជមាន និង ផ្នែកអវិជ្ជមាន។ គេពិបាកនឹងឆ្លើយដោះស្រាយ បានទៅនឹងបញ្ហានៃចរិតវិជ្ជមាន និង អវិជ្ជមានណាស់។ មូលហេតុគឺថា មានភាពសប្បាយជាវិជ្ជមាន ដូចជាការសប្បាយដែលកើតមានឡើងចំពោះការទទួលបានលទ្ធផលប្រសើរក្នុងការសិក្សា ឬ ក្នុងការងារ និង ការសប្បាយជាអវិជ្ជមាន ដូចជាការសប្បាយដែលកើតមានឡើងចំពោះ មិត្តភក្តិ ដែលស្ថិតនៅចំណុះខ្លួន។

លក្ខណៈពិសេសទីពីរនេះ តម្រូវឲ្យយើងត្រួតពិនិត្យជាប់រហូត ហើយយ៉ាងហ្មត់ចត់ផង ចំពោះសញ្ចេតនានិងចិត្តរំភើបរបស់យើង។ កាលណាចិត្តរំភើបស្តែងចេញឡើង យើងត្រូវត្រួតពិនិត្យឲ្យបានទាល់ពេលវេលា និង យ៉ាងបន្ទាន់បំផុត ចំពោះចរិត ខ្លឹមសារ និង ទិសដៅរបស់វា។

មនុស្សគ្រប់រូបសុទ្ធតែយល់ដឹងថា មានតណ្ហាជាច្រើនដែលត្រូវគេវាយតម្លៃថា ថ្លៃថ្នូរ ក៏ប៉ុន្តែត្រូវយល់ដឹងថាមានតណ្ហាខ្លះទៀត ដែលត្រូវមហាជនទិទៀន រិះគន់ ផងដែរ។

- **តួនាទីរបស់សញ្ចេតនានៅក្នុងសកម្មភាព និង ក្នុងទំនាក់ទំនងផ្សេងទៀត**

សញ្ចេតនាមានឥទ្ធិពលយ៉ាងខ្លាំង ក្នុងការរុញច្រានមនុស្សឲ្យមានសកម្មភាព។ សញ្ចេតនាដ៏សកម្មតែងតែដឹកនាំមនុស្សទៅរកទង្វើវិជ្ជមាន។ មនុស្សនឹងមានទង្វើវិជ្ជមានប្រកបដោយលក្ខណៈថ្លៃប្រឌិត ដរាបណា មនុស្សមានតណ្ហា ងប់ទៅលើងឧត្តមគតិ។ គេនឹងចូលរួមយ៉ាងសកម្ម នៅក្នុងការកសាងប្រទេសជាតិឡើងវិញ ដរាបណាគេមានសេចក្តីស្នេហាយ៉ាងជ្រាលជ្រៅចំពោះមាតុភូមិ។ គេមិនអាចទទួលបានលទ្ធផលល្អជាមួយសត្រូវបានទេ ប្រសិនណាជា គេស្អប់ខ្ពើមសត្រូវនោះពីមុនមកស្រាប់ ទោះណាជាគេចុះសម្រុងធ្វើការងារជាមួយសត្រូវនោះហើយក៏ដោយ។ ស្នាដៃដ៏ប្រសើរថ្លៃថ្លា របស់វីរជន ដែលបន្សល់ទុកឲ្យមនុស្សជំនាន់ក្រោយ ក៏អាស្រ័យមកពីសញ្ចេតនាដ៏មោះមុតរបស់វីរជននោះដែរ។

នៅក្នុងវិស័យទទួលចំណេះដឹង ឥទ្ធិពលរបស់សញ្ចេតនាក៏មានលក្ខណៈខ្លាំងខ្លាណាស់ដែរ។ បើមនុស្សគ្មានសញ្ចេតនាទេនោះ នោះក៏គ្មានអ្វីបន្សល់ទុកពីអតីតកាលមកបច្ចុប្បន្នកាល និង ទៅអនាគតកាល សម្រាប់ឲ្យយើងស្រាវជ្រាវរកសច្ចធម៌ចំពោះមនុស្សដែរ។ ចិត្តរំភើបមានឥទ្ធិពលក្នុងការបង្កើនបាននូវកម្លាំងកាយរបស់មនុស្សហើយរុញច្រានមនុស្សឲ្យធ្វើសកម្មភាពយ៉ាងខ្លាំងក្លា នោះគេហៅថា ចិត្តរំភើបដ៏សកម្ម ដូចជាការសប្បាយ និង សេចក្តីត្រេកអរ ជាដើម។ ចិត្តរំភើបដែលទប់ស្កាត់សកម្មភាពរបស់មនុស្ស ដោយធ្វើឲ្យកម្លាំងកាយរបស់មនុស្សចុះទន់ខ្សោយ នោះត្រូវបានគេហៅថា ចិត្តរំភើបអវិជ្ជមាន ដូចជា ការព្រួយបារម្ភ និង ការអេសង្សឹមជាដើម។

## មូលដ្ឋានកោសិកាសរីរៈ និង ការស្តែងចេញនូវសញ្ចេតនា និង ចិត្តរំភើប

### I. មូលដ្ឋានកោសិកាសរីរៈនៃចិត្តរំភើប និង សញ្ចេតនា

ដូចលំនាំផ្លូវចិត្តដទៃទៀតដែរ ចិត្តរំភើប និង សញ្ចេតនា ស្ថិតនៅក្រោមការដឹកនាំរបស់ស្រោមខួរក្បាល។ លំនាំសសៃប្រសាទនៃស្រោមខួរក្បាល បំពេញតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើឲ្យកើតមាន ចិត្តរំភើប និង សញ្ចេតនា។ ស្រោមខួរក្បាលចូលរួមចំណែក ក្នុងការបង្កើតឲ្យមានចិត្តរំភើបដ៏សាមញ្ញបំផុត។ នៅក្នុងជីវភាពរស់នៅរាល់ថ្ងៃ អំពើទាំងអស់ដែលស្តែងឲ្យឃើញ សញ្ចេតនារបស់មនុស្ស មានចរិតជារ៉ផ្លិចមានលក្ខខណ្ឌ។

ចិតត្តរំភើប និង សញ្ចេតនាមនុស្សមានទំនាក់ទំនងគ្នាផងដែរ ជាមួយនឹងស្លាកស្នាមនៃរូបភាពចិត្តដែលសណ្ឋិតនៅក្នុងស្រោមខួរក្បាលរបស់មនុស្ស។ កាលណារូបភាពចាស់ត្រូវសាបរលាបបាត់ទៅរូបភាពថ្មីក៏ចូលមកជំនួស។ រូបភាពថ្មីនេះ បង្កើតបានជា សញ្ចេតនាដ៏ធ្ងន់ តួយ៉ាងដូចជា បន្លាស់ប្តូរបែបបទនៃជីវភាពរស់នៅ ការផ្តាច់ទម្លាប់ ការឃ្លាតឆ្ងាយពីសាច់ញាតិ។ល។

តួនាទីដឹកនាំរបស់ស្រោមខួរក្បាល ត្រូវបានគេបកស្រាយពន្យល់ទៅតាមហេតុការណ៍ដែលថា វាអាចបញ្ជាបានលើរាល់ចិត្តរំភើប និង សញ្ចេតនា ក៏ដូចជាការស្តែងចេញនូវចិត្តរំភើប និង សញ្ចេតនានេះមកក្រៅឲ្យគេឃើញដែរ។

ម្យ៉ាងវិញទៀត ចិត្តរំភើប និង សញ្ចេតនារបស់មនុស្សមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយនឹងប្រព័ន្ធសញ្ញាកម្មទី ២។ តាមរយៈភាសា គេអាចបង្កឲ្យមានចិត្តរំភើប និង សញ្ចេតនា ចំពោះអ្នកដទៃទៀត ឬ ក៏ជួយទប់ស្កាត់ចិត្តរំភើប និង សញ្ចេតនាអវិជ្ជមានមិនឲ្យកើតមាន ចំពោះអ្នកដទៃ ក៏ដូចជាខ្លួនឯង។ ចំពោះសេចក្តីដូចបានពិពណ៌នាមកនេះ អាចបកស្រាយពន្យល់ឲ្យគេយល់ដឹងបានពីតួនាទីដឹកនាំរបស់ស្រោមខួរក្បាល ចំពោះការកើតមានចិត្តរំភើប។ ថ្វីត្បិតតែយ៉ាងនេះក៏ដោយ ផ្នែកខាងក្រោមនៃស្រោមខួរក្បាល ក៏បំពេញនូវតួនាទីសំខាន់ណាស់ដែរ នៅក្នុងការបង្កើត ឲ្យមានចិត្តរំភើប និង សញ្ចេតនារបស់មនុស្ស។ ប្រសិនណាជា ស្រោមខួរក្បាលមានតួនាទីក្នុងការធ្វើឲ្យមាននីយតកម្ម (regularity) ក្នុងការបញ្ជាបានទៅលើសញ្ចេតនា និង ចិត្តរំភើបនោះផ្នែកដែលស្ថិតនៅខាងក្រោមសំបកខួរក្បាលក៏មាននាទីរបស់វា ក្នុងការស្តែងចេញនូវចិត្តរំភើប និង សញ្ចេតនាដូចគ្នាដែរ។

## II. ការស្តែងចេញសញ្ចេតនា និង ចិត្តរំភើបតាមបែបសរីរៈ

នៅផ្នែកខាងក្រោមនៃស្រោមខួរក្បាល មានមជ្ឈមណ្ឌលសម្រាប់បញ្ជារបស់ប្រព័ន្ធសរសៃប្រសាទខាងចេតនាដែលជាផ្នែកបណ្តុំចិត្តរបស់មនុស្ស។ ប្រព័ន្ធសរសៃប្រសាទ (ការចិញ្ចឹមរាងកាយដោយអាហារ) ខាងចេតនានេះ ធ្វើឲ្យមានភាពទៀងទាត់ ទៅលើមុខងារសរីរាង្គខាងក្នុងខ្លួនរបស់មនុស្ស។ ហេតុនេះហើយបានជា ចិត្តរំភើប និង សញ្ចេតនា តែងតែផ្សារភ្ជាប់ជានិច្ច។ ទៅនឹងបន្លាស់ប្តូរខុសប្លែកៗគ្នាខាងផ្នែកសរីរៈនៃសារពាង្គកាយមនុស្សយើង។ យើងដឹងថា ស្រោមខួរក្បាល និង ផ្នែកខាងក្រោមរបស់វាមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នាទៀតផង ហើយទទឹមនឹងនេះ វាជះឥទ្ធិពលដល់គ្នាទៅវិញទៅមក ហើយស្រោមខួរក្បាលមានតួនាទីជាអ្នកដឹកនាំ។

មុនដំបូងបង្អស់ ចិត្តរំភើបរបស់មនុស្ស ត្រូវបានផ្សារភ្ជាប់ជាធម្មតា ទៅនឹងបន្លាស់ប្តូររបស់មុខងារសរីរៈនៃប្រព័ន្ធឈាមរត់។ នៅពេលដែលមនុស្សមានចិត្តរំភើប មនុស្សមានភាពកក់ក្តៅ ឬ ភាពព្រងើយកន្តើយ ទឹកមុខប្តូរព៌ណសម្បុរ ជួនកាលក្រហម ជួនកាលស្លេកស្លាំង ។ បន្លាស់ប្តូរទឹកមុខនេះ ត្រូវបានផ្សារភ្ជាប់ទៅនឹងដំណើរការបេះដូង។ គឺត្រង់ចំណុចនេះហើយ ដែលគេចាត់ទុកបេះដូងជា និមត្តរូបនៃសញ្ចេតនារបស់មនុស្ស។ គេអាចកត់សម្គាល់បានថា បេះដូងមិនមែនជាទីជម្រកដ៏សុខសាន្តរបស់សញ្ចេតនា ដែលជាមូលហេតុនៃការសប្បាយរីករាយ ឬ ការឈឺចាប់ដ៏ខ្លោចផ្សានោះទេ។ បេះដូងគ្រាន់តែជាទីកន្លែងដែលស្តែងចេញនូវចិត្តរំភើបនិង សញ្ចេតនាប៉ុណ្ណោះ។ ជារឿយៗ ចិត្តរំភើបផ្សារភ្ជាប់ទៅនឹង បន្លាស់ប្តូរមុខងារនៃការដកដង្ហើម។

**ឧទាហរណ៍៖** នៅក្នុងការព្រួយបារម្ភ គេដកដង្ហើមវែង។ គេមិនហ៊ានដកដង្ហើមខ្លាំងទេ មនុស្សយើង រត់ លោត សប្បាយកំសាន្ត..... គេដកដង្ហើមញាប់។

មុខងារនៃប្រណិធានរំលាយអាហារ ឆ្លុះបញ្ចាំងឲ្យឃើញពីសភាពនៃចិត្តរំភើបរបស់មនុស្សផងដែរ។ កាលណាមនុស្សមានការព្រួយបារម្ភ មនុស្សមិនចង់ទទួលទានអាហារទេ។ កាលណាមនុស្សមានការសប្បាយច្រើនហួសហេតុ មនុស្សក៏មិនមានចំណង់នៅក្នុងការទទួលទានដែរ។ ប្រសិនណាគេមានសេចក្តីត្រេកអរ សប្បាយក្នុងការងារ មនុស្សមានការរំលាយអាហារក្នុងខ្លួនយ៉ាងទន់ខ្សោយ ទៅលើអ្វីៗដែលគេបានទទួលទាន និង ផឹក។ ប៉ុន្តែគេរឹតតែជួបការលំបាកក្នុងការរំលាយអាហារទៅទៀត កាលណាគេមាន

ទុក្ខក្រៀមក្រំ។ ពោះវៀនត្រគួញរឹតរួត ពីព្រោះសរសៃឈាមបង្កឲ្យមានដំណើររមួលពោះវៀននេះឯង សរីរាង្គបញ្ចេញរសមោចនា ក៏ចូលរួមនៅក្នុងការស្តែងចេញនូវសញ្ចេតនារបស់មនុស្សដែរ។

**ឧទាហរណ៍៖** នៅពេលមនុស្សមានទុក្ខក្រៀមក្រំខ្លាំង ឬក៏គេសប្បាយខ្លាំងពេក ទឹកភ្នែកតែងតែហូរហៀរមក។

ប្រព័ន្ធក៏បំពេញមុខងារសំខាន់ដែរ នៅពេលមនុស្សយើងស្តែងចេញនូវចិត្តរំភើប។ ដូច្នេះនៅពេលដែលមនុស្សសប្បាយ មនុស្សបញ្ចេញកាយវិការទៅតាម អត្ថន័យនៃការសប្បាយ ទឹកមុខមានអាការៈផ្លាស់ប្តូរទៅតាមទ្រង់ទ្រាយនៃការសប្បាយ។ រីឯនៅពេលដែលគេមានកំហឹងវិញ គេខាំធ្មេញ គេក្រឡេកភ្នែកចុះឡើងតាមរបៀបខឹងច្រឡោត ហើយនៅពេលដែលគេមានទុក្ខក្រៀមក្រំវិញ គេមានទឹកមុខទន់ជ្រាយរិលរល់។ បន្លាស់ប្តូររាងកាយដែលបានពិព៌ណនាមកនេះ សុទ្ធតែមានមូលហេតុសរីរៈរបស់វា។

**ឧទាហរណ៍៖** បេះដូងមានដំណើរការកាន់តែខ្លាំង ដើម្បីឲ្យឈាមមានចរាចរ និងបំពេញសេចក្តីត្រូវការនៃចលនា ដែលមានឥទ្ធិពលខ្លាំង ក្រន្ថិដែលស្ថិតនៅលើក្រលៀនបញ្ចេញអរម៉ូន កាន់តែច្រើនដើម្បីបង្កើនជាតិផ្អែមនៅក្នុងឈាម និង ដើម្បីពង្រឹងចលនានៃសាច់ដុំផង បង្កើនសមត្ថភាពនៃការងាររបស់សរីរាង្គផង។

## រូបភាពនៃសញ្ចេតនា

សញ្ចេតនារបស់មនុស្សកើតមានសម្បូរបែប ហើយស្មុគស្មាញផង។ ប៉ុន្តែដោយឈរលើមូលដ្ឋាននៃល្បឿនក្នុងការលេចចេញនូវសញ្ចេតនា កម្លាំងនៃសញ្ចេតនា លក្ខណៈស្ថិតស្ថេរនៅបានយូរអង្វែង និងជម្រៅរបស់វា គេសង្កេតឃើញសញ្ចេតនាមានរូបភាពសំខាន់ៗដូចតទៅ៖

### I. សភាពនៃស្មារតី

សភាពនៃស្មារតី គឺជាសភាពនៃសញ្ចេតនា ដែលសណ្ឋិតនៅបានយូរអង្វែង ហើយ (ទឹកប្រមាត់) មានកម្លាំងមធ្យម ឬ ខ្សោយ។

សភាពនៃស្មារតីរបស់មនុស្ស អាចសណ្ឋិតនៅបានយូររាប់ថ្ងៃ រាប់សប្តាហ៍ រាប់ខែ ហើយជួនកាលយូរឆ្នាំក៏មានដែរ។ សភាពស្មារតីរបស់មនុស្សអាចមានសភាពសកម្ម ដូចជា សេចក្តីត្រេកអរ គំនិតសុទិដ្ឋិនិយម ស្នេហាជីវិត ស្នេហាប្តីប្រពន្ធ ស្នេហាមាតបិតា។ ពេលខ្លះសភាពនៃស្មារតីរបស់មនុស្សមានលក្ខណៈអវិជ្ជមានដូចជា គំនិតទុទិដ្ឋិនិយម ការបាត់បង់សេចក្តីក្លាហាន សេចក្តីក្រៀមក្រំ។

នៅក្នុងសភាពនៃស្មារតីដែលមានលក្ខណៈសកម្ម គេសង្កេតឃើញមនុស្សមានទឹកមុខស្រស់បស់ ក៏ប៉ុន្តែនៅក្នុងសភាពនៃស្មារតីអវិជ្ជមានវិញ គេសង្កេតឃើញមនុស្សមានជីវភាពរស់នៅតាមបែបខ្មៅងងឹត ហើយគេគិតថាមនុស្សនោះ នឹងជួបនឹងការលំបាកយ៉ាងណានោះ ជាមិនខាន។

ហេតុការណ៍ និង ព្រឹត្តិការណ៍ប្លែកៗដែលកើតមាននៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ បង្កើតឲ្យមនុស្សមានសភាពនៃស្មារតីផ្សេងៗគ្នា។ ប៉ុន្តែរឿងបែបណាមួយនោះ អាចធ្វើឲ្យយើងមានការសប្បាយរីករាយ និងមានគំនិតសុទិដ្ឋិនិយម។ ដំណឹងថ្មីបែបណាមួយនោះ អាចបង្កើតក្នុងខ្លួនយើងឲ្យមានការបាត់បង់សេចក្តី

ក្លាហាន ឬ ការឈឺចាប់ក្នុងចិត្ត។ សភាពនៃស្មារតីរបស់មនុស្សអាចជាសភាព ដែលកើតឡើងតាមរូបកាយ។ កាលណាមនុស្សមានសុខភាពមាំមួន សភាពនៃស្មារតីមានលក្ខណៈសប្បាយរីករាយ។

នៅក្នុងសភាពដែលមនុស្សមានការនឿយហត់ មានរោគាព្យាធិ មនុស្សមានសភាពក្រៀមក្រំ ឬឈឺចាប់។ តាមពិតការកើតមានជាក់ស្តែងនៃសភាពបែបណាមួយនោះ មានតិចតួចស្តួចស្តើងណាស់ ក៏ប៉ុន្តែវាមានប្រយោជន៍ ចំពោះយើងត្រង់ដែលធ្វើឲ្យយើង អាចផ្លាស់ប្តូរបាន ចំពោះប្រកពនៃសភាពស្មារតីរបស់យើង។

**ឧទាហរណ៍៖** ការទិទៀនស្រាលៗពីសំណាក់សាច់ញាតិរបស់យើង ធ្វើឲ្យយើងមានសភាពព្រួយបារម្ភយ៉ាងយូរ។ ការសរសើរលើកទឹកចិត្តរបស់សាស្ត្រាចារ្យ ចំពោះសិស្ស អាចធ្វើឲ្យសិស្សមានសភាពសប្បាយរាប់សប្តាហ៍ ឬ រាប់ខែ។

នៅក្នុងការអប់រំសញ្ចេតនា សាស្ត្រាចារ្យ ត្រូវណែនាំសិស្សឲ្យប្រយុទ្ធប្រឆាំងនឹង សភាពនៃស្មារតីដែលមានលក្ខណៈអវិជ្ជមាន ពីព្រោះសភាពនៃស្មារតីបែបនេះ ធ្វើឲ្យរាំងស្ទះដល់សកម្មភាពរបស់មនុស្ស។ ម្យ៉ាងវិញទៀតសាស្ត្រាចារ្យត្រូវចេះបង្កើតឲ្យមានបរិយាកាសដ៏កក់ក្តៅ និង សប្បាយរីករាយនៅក្នុងការសិក្សានិងនៅក្នុងការងារដទៃទៀត សំដៅកម្ចាត់ចោលនូវសភាពនៃស្មារតីដែលមានលក្ខណៈអវិជ្ជមាន។

## II. ចិត្តរំភើប

ចិត្តរំភើប គឺជាសភាពចិត្តដែលបង្កឡើងតាមរយៈការចាប់អារម្មណ៍យ៉ាងខ្លាំងក្លា ដែលកើតមានឡើងតាមរយៈពេលដ៏ខ្លី។ ក្នុងន័យនេះ គេសម្គាល់ឃើញ មនុស្សអាចមានចិត្តរំភើប ជាវិជ្ជមានដូចជា ការសប្បាយច្រើន ភាពកក់ក្តៅក្នុងចិត្ត ហើយពេលខ្លះមនុស្សក៏អាចមានចិត្តរំភើប ជាអវិជ្ជមានដែរ ដូចជា ការមិនសប្បាយចិត្ត សេចក្តីអសង្ឃឹម ការខឹងសម្បារ ការភ័យខ្លាច ។ល។

តាមធម្មតាចិត្តរំភើបកើតមានឡើងនៅពេលណាដែលមានហេតុការណ៍ដ៏សំខាន់បែបណាមួយនោះ ផុសចេញភ្លាមៗ នៅក្នុងជីវភាពរស់នៅរបស់យើង។ តាមទស្សនៈសរីរៈវិទ្យា កាលណាចិត្តរំភើបផុសចេញមកហើយ នៅក្នុងស្រោមខួរក្បាលមជ្ឈមណ្ឌលនៃរំញោចដ៏ខ្លាំងមួយ ក៏កើតមានឡើងដែរ។ យោងទៅតាមច្បាប់នៃបដិការ ។ មជ្ឈមណ្ឌលនៃរំញោចដែលមានអធិបតីភាពលើលគេនេះ បង្កឲ្យមានការទប់រំញោចនៅតាមផ្នែកដទៃទៀតនៃខួរក្បាល។ គឺក្នុងករណីនេះហើយ ដែលគេពន្យល់ហេតុការណ៍ថា នៅក្នុងចិត្តរំភើប ជួនកាលគេអាចប្រព្រឹត្តបទល្មើស ជួនកាលគេធ្វើកាយវិការផ្សេងៗ ដោយឥតបានត្រិះរិះពិចារណាឲ្យបានដិតដល់ ហើយដែលគេហៅថា លក្ខណៈពិសេសនៃចិត្តរំភើប។ ក៏ប៉ុន្តែក្នុងន័យនេះ គេមិនត្រូវប្រកាន់យកទស្សនៈមួយជឿជាក់ថា មនុស្សយើងគ្មានលទ្ធភាពគ្រប់គ្រងបាននូវសញ្ចេតនារបស់ខ្លួននោះទេ។ កាលណាចិត្តរំភើបអវិជ្ជមានកើតឡើងហើយ គេត្រូវប្រយុទ្ធបំបាត់វាជាបន្ទាន់។ ប្រព័ន្ធសញ្ញាការទី២ អាចជួយយើងឲ្យទប់ស្កាត់បាននូវការផ្ទុះឡើងនៃចិត្តរំភើបដ៏ឥតប្រយោជន៍នៅក្នុងការសិក្សា និង ក្នុងការងារ។

ចំពោះចិត្តរំភើប ដ៏សកម្មហើយមានប្រយោជន៍នោះ យើងមិនត្រូវប្រយុទ្ធ និង បំបាត់វាចោលឡើយ។ ក៏ប៉ុន្តែគេមិនត្រូវបណ្តោយឲ្យ ចិត្តរំភើបបែបនេះ កើតមានឡើងទៅតាមភាពរាយមាយ រហូតដល់

បាត់បង់ភាពភ្លឺស្វាង ដូចជាការសប្បាយច្រើនហួសហេតុ ដែលនាំឲ្យមនុស្សឆ្ពោះទៅរកការនិយាយលេងសើចច្រើន ឥតបានប្រយោជន៍នោះទេ។ ហេតុដូច្នេះហើយបានជា គេនិយាយថា ទឹកចិត្តដ៏ពុះកញ្ជ្រោលខ្លាំង ត្រូវដើរទទឹមគ្នានឹង ចិត្តត្រជាក់។

### III. តណ្ហា

តណ្ហាគឺជាសភាពចិត្ត ដែលកើតឡើងដោយសារចិត្តរំភើប ដែលមានលក្ខណៈខ្លាំង ស៊ីជម្រៅហើយសណ្ឋិតនៅយូរអង្វែង។ តណ្ហាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការតម្រង់ទិសជាមូលដ្ឋានគ្រឹះនៃអំពើ និង ការគិតរបស់មនុស្ស។ តណ្ហាមានពីរប្រភេទ គឺ តណ្ហាវិជ្ជមាន និង តណ្ហាអវិជ្ជមាន។

១. ដោយយោងទៅតាមទស្សនៈខាងផ្នែកសីលធម៌ ៖ តណ្ហាដែលមើលឃើញតែលុយកាក់ តណ្ហាទៅលើការជក់បារី ការប្រើប្រាស់គ្រឿងញៀន... ដែលធ្វើឲ្យមនុស្សប្រកាន់យកអំពើ ពាលាប៉ោវឡែ....ទាំងនេះត្រូវបានគេចាត់ទុកថា ជាតណ្ហាអវិជ្ជមាន ហើយ ជាតណ្ហាដ៏អាក្រក់នៅក្នុងសង្គមមនុស្សជាតិ។

នៅក្នុងសង្គមមនុស្ស ទោះជាក្នុងប្រទេសណាក៏ដោយ ជនមួយក្តាប់តូចបានសាបព្រោះនូវតណ្ហាអវិជ្ជមានទៅក្នុងជួរយុវជន ឲ្យពួកយុវជនលង់លក់ក្នុងសុរា ការប្រើប្រាស់គ្រឿងញៀន ការចេញចូលកន្លែងពាលាអាវ៉ាសែ សំដៅឲ្យយុវជន បាត់បង់ស្មារតីតស៊ូ និង ស្មារតីស្នេហាជាតិ។

២. ក៏ប៉ុន្តែនៅមានតណ្ហាមួយផ្សេងទៀត ជាតណ្ហាដ៏សកម្មដែលជំរុញមនុស្សឲ្យបំពេញភារកិច្ចបានយ៉ាងល្អប្រសើរដូចជា តណ្ហាក្នុងការសិក្សា តណ្ហាក្នុងវិជ្ជជីវៈ តណ្ហាក្នុងការស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស តណ្ហាក្នុងសិល្បៈ....។ តណ្ហាដ៏ល្អប្រពៃបែបនេះ ត្រូវបានគេហៅថា ជាតណ្ហាប្រកបដោយធម៌សប្បុរស។ តណ្ហាប្រភេទនេះ ស្តែងចេញឲ្យឃើញយ៉ាងច្បាស់លាស់នៅក្នុងសកម្មភាពច្នៃប្រឌិតរបស់មនុស្សក្នុងការងារ។ តណ្ហានេះមានឥទ្ធិពលយ៉ាងខ្លាំង ក្នុងការប្រមូលផ្តុំបាននូវកម្លាំងមនុស្ស ដែលជាកត្តាកំណត់មួយ សម្រាប់ជម្រុញមនុស្សឲ្យឈានទៅសម្រេចបាននូវជោគជ័យក្នុងវិជ្ជាជីវៈ។

## ប្រភេទនៃសញ្ចេតនា

នៅក្នុងចំណែកថ្នាក់នៃសញ្ចេតនា គេត្រូវឈរលើមូលដ្ឋានៃចរិត និង ខ្លឹមសារនៃសញ្ចេតនា គឺ៖ សញ្ចេតនាកម្រិតខ្ពស់ និង សញ្ចេតនាកម្រិតទាប។

### I. សញ្ចេតនាកម្រិតទាប

គឺជាសញ្ចេតនាដែលផ្សាភ្ជាប់ នឹងតម្រូវការផ្នែកសំភារៈរបស់មនុស្ស។

**ឧទាហរណ៍** កាលណាមនុស្សឃ្លានអាហារ មនុស្សមានទឹកមុខមិនសប្បាយចិត្ត។ កាលណាមនុស្សរងារមនុស្សគ្មានសំលៀកបំពាក់គួរជាទីកក់ក្តៅមនុស្សក៏មិនសប្បាយចិត្តដែរ។ កាលណាគេត្រូវការប៊ិចដើម្បីសរសេរ ហើយគេគ្មាន ឬ គេបាត់រករមិនឃើញ គេកើតមានចិត្តខឹង។ ផ្ទុយទៅវិញ កាលណាមនុស្សបំពេញតម្រូវការខាងផ្នែកផ្លូវកាយ ឬ ខាងផ្នែកសម្ភារៈកម្រិតខ្ពស់ បានសម្រេចដូចបំណង មនុស្សតែងតែមានសេចក្តីត្រេកអរសប្បាយរីករាយ។

សញ្ចេតនាកម្រិតទាប មិនមែនជាសញ្ចេតនាអាក្រក់ទេ។ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មនុស្ស គ្រប់រូប ត្រូវតែបំពេញតម្រូវការខាងផ្នែកសម្ភារៈ។ សញ្ចេតនាបែបណាមួយនោះដែលត្រូវគេចាត់ទុកថា ល្អ ឬ អាក្រក់ គឺអាស្រ័យ ទៅតាមតម្រូវការ ដែលគេសម្រេចបានស្របច្បាប់ ឬ ខុសច្បាប់ឯណោះវិញទេ។

**ឧទាហរណ៍** តណ្ហាទៅលើសុរា និង គ្រឿងញៀនពិតជាតណ្ហាដ៏អាក្រក់។

## II. សញ្ចេតនាកម្រិតខ្ពស់

គឺជាប្រភេទនៃសញ្ចេតនា ដែលមានជាប់ទាក់ទិនទៅនឹងតម្រូវការផ្នែកស្មារតីរបស់មនុស្ស។

សញ្ចេតនាកម្រិតខ្ពស់ មិនចាំអីតែសញ្ចេតនាណាមួយនោះ ដែលមានលក្ខណៈថ្លៃថ្នូរនោះទេ។ ចរិតរបស់ សញ្ចេតនាកម្រិតខ្ពស់ អាស្រ័យដោយចរិតនៃតម្រូវការខាងផ្នែកស្មារតីរបស់មនុស្សឯណោះទេ។ ប្រសិន ណាជាតម្រូវការផ្នែកស្មារតីទាំងនោះមានលក្ខណៈចោលម្សៀត ហើយថោកទាប ខ្វះសីលធម៌ មិនសម ស្របទៅនឹងទស្សនៈនៃសីល្បវិទ្យា មិនសមតាមគោលបំណងក្នុងសង្គម ហើយគ្មានភាពថ្លៃថ្នូរទេនោះ.... សញ្ចេតនាកម្រិតខ្ពស់បែបណាមួយនោះ ក៏គ្មានតម្លៃអ្វីក្នុងសង្គមដែរ។

សញ្ចេតនាកម្រិតខ្ពស់ ចែកចេញជា៖ សញ្ចេតនាប្រកបដោយសីលធម៌ សញ្ចេតនាផ្នែកសីល្បវិទ្យា និង សញ្ចេតនាបញ្ញា។

### ១. សញ្ចេតនាប្រកបដោយសីលធម៌

នៅក្នុងជីវភាពរស់នៅរាល់ថ្ងៃ យើងតែងតែសម្រួលឥរិយាបថខ្លួនរបស់យើងទៅនឹងអំពើរបស់អ្នកដទៃ ឬ របស់យើង។ យើងប្រៀបធៀបអំពើទាំងនោះទៅតាមនិយាមសីលធម៌ក្នុងសង្គម។ កាលណាអំពើទាំង នោះឆ្លើយតបបានទៅនឹងលក្ខណៈវិនិច្ឆ័យក្នុងសង្គម យើងក៏មានការសប្បាយត្រេកអរ មានសេចក្តី ស្រលាញ់ មានការស្ញើចសរសើរ។ ផ្ទុយទៅវិញ កាលណាអំពើទាំងនោះផ្ទុយនឹងនិយាមសីលធម៌សង្គម យើងមានការឈឺចាប់ យើងមិនសប្បាយចិត្ត យើងស្អប់ខ្ពើមវា ហើយយើងមើលស្រាលទៅលើវា។ លើរាល់ ឥរិយាបថទាំងនេះ គឺជាការស្តែងចេញដ៏ពិតប្រាកដនៃសញ្ចេតនាសីលធម៌។

ដូច្នេះសញ្ចេតនាសីលធម៌ គឺជាសញ្ចេតនាដែលមានទំនាក់ទំនងទៅនឹងសំណូមពររបស់មនុស្សក្នុង រឿងក្បួនច្បាប់ និង និយាមសីលធម៌ក្នុងសង្គមមួយជាកំណត់។ សញ្ចេតនារបស់មនុស្ស មិនអាចត្រូវបាន កាត់ផ្តាច់ ពីមនសិការផ្នែកសីលធម៌បានឡើយ។ យើងដឹងថា មូលដ្ឋាននៃក្បួនច្បាប់ និង និយាមសីលធម៌ គឺជាលក្ខខណ្ឌសម្ភារៈនៃអត្ថិភាព របស់សង្គម និង ជាទំនាក់ទំនងនៃផលិតកម្មក្នុងសង្គមផង។ ក្នុងសង្គម មានវណ្ណៈ សីលធម៌ក៏មានវណ្ណៈដែរ។ សញ្ចេតនារបស់មនុស្ស ច្រើនតែផ្សាភ្ជាប់ទៅនឹងសេចក្តីស្នេហាដ៏ ជ្រាលជ្រៅចំពោះមាតុភូមិរបស់ខ្លួន។

ដូច្នេះក្នុងជីវភាពរស់នៅ សញ្ចេតនាសីលធម៌ស្តែងចេញឲ្យឃើញនៅក្នុងសេចក្តីស្រលាញ់ការងារ សេចក្តីស្នេហាចំពោះមាតុភូមិ ចំពោះប្រជាពលរដ្ឋ ស្មារតីសមូហភាព ការរាប់រកគ្នាជាមិត្តភាព ភាតរភាព

និង ចំណងទាក់ទងអន្តរជាតិ។ មនុស្សដែលមានសញ្ចេតនាសីលធម៌ក្នុងសង្គម ត្រូវមានទឹកចិត្តមនុស្សធម៌ សប្បុរសធម៌ ចេះគោរពសុភមង្គលរបស់សមូហភាព និង មានស្មារតីទទួលខុសត្រូវខ្ពស់។

## ២. សញ្ចេតនាផ្នែកសិល្បវិទ្យា

សញ្ចេតនាផ្នែកសិល្បវិទ្យា គឺជាសញ្ចេតនាដែលមានទំនាក់ទំនងនៅនឹងការពេញចិត្ត ឬ ការមិនពេញចិត្តទៅលើតម្រូវការចំពោះសោភ័ណភាព។ តាមពិតសញ្ចេតនាប្រភេទនេះកើតឡើងនៅពេលណាដែលមនុស្សចេះស្ងើចសរសើរទៅលើស្នាដៃច្នៃប្រឌិតខាងផ្នែកសិល្បៈ។ ក៏ប៉ុន្តែនេះមិនមែនគ្រាន់តែជាផ្នែកមួយនៃ សិល្បៈដែលជាប្រភពនៃសញ្ចេតនាផ្នែកសិល្បវិទ្យាប៉ុណ្ណោះទេ។ សោភ័ណភាពក៏ត្រូវបានស្តែងឲ្យឃើញទៀតផងដែរ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ អ្វីៗដែលកើតមាននៅក្នុងតថភាពសត្យានុម័ត ហើយបំពេញ បានដោយឥតខ្ចោះដល់ផ្នែកសោភ័ណភាព នោះគឺជាប្រភពនៃសញ្ចេតនាផ្នែកសិល្បវិទ្យា។

**ឧទាហរណ៍:** ទេសភាពធម្មជាតិដ៏ស្រស់បំព្រង អំពើដ៏ថ្លៃថ្នូររបស់មនុស្ស វត្ថុជាគ្រឿងចម្លាក់ ទស្សនៈរបស់វរជន សំលៀកបំពាក់ដ៏ល្អ កាយវិការប្រកបដោយលក្ខណៈទាន់សម័យ ទឹកមុខស្វាគមន៍ រាក់ទាក់ សំដីគួរសម។ ដូចគ្នានឹងសញ្ចេតនាផ្នែកលីលធម៌ដែរ សញ្ចេតនាផ្នែកសិល្បវិទ្យា និង សោភ័ណភាព ត្រូវពឹងផ្អែកលើលក្ខខណ្ឌ សង្គម និងប្រវត្តិសាស្ត្រផងដែរ។ នៅក្នុងសម័យកាលនីមួយៗ នៃប្រវត្តិសាស្ត្រជាកំណត់នោះ គេតែងតែឃើញ មានលក្ខណៈវិនិច្ឆ័យជាកំណត់ទៅលើសោភ័ណភាព។ កាលណាគេមើលឃើញសោភ័ណភាព លក្ខណៈពិសេសរបស់វត្ថុ និង លក្ខណៈខាងក្រៅរបស់វា ដូចជា ទម្រង់ ពណ៌ សម្លេង... សុទ្ធតែត្រូវបានឆ្លុះបញ្ចាំងទៅក្នុងខួរក្បាលរបស់យើង តាមរយៈសរីរាង្គវិភាគ។

ក៏ប៉ុន្តែ គេត្រូវកត់សម្គាល់ថា លក្ខណៈពិសេសទាំងនេះមិនអាចស្ថិតនៅឃ្លាតឆ្ងាយពីខ្លឹមសាររបស់វត្ថុឡើយ។ ទម្រង់ និង ខ្លឹមសាររបស់វត្ថុ ត្រូវបានផ្សាភ្ជាប់គ្នា ទៅតាមបែបបទនៃការសេរិាង្គវិភាគ។ ទម្រង់ត្រូវបានកំណត់ឡើងដោយខ្លឹមសារ។ នេះជាទស្សនៈរបស់យើងខាងសិល្បវិទ្យា ។ ហេតុដូច្នេះហើយបានជាមានលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌសំខាន់ៗនៃការអប់រំសិល្បវិទ្យា នោះគឺការបណ្តុះបណ្តាលដល់កុមារ និង យុវសិស្ស នូវទស្សនៈចំពោះសោភ័ណភាព ខាងក្រៅរបស់វត្ថុឲ្យបានយ៉ាងត្រឹមត្រូវប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ពោលគឺគប្បីចាត់ទុកទម្រង់នៃវត្ថុថា ជាការស្តែងចេញនូវខ្លឹមសារមួយជាកំណត់។

តាមគំនិតយើង លក្ខណៈវិនិច្ឆ័យផ្នែកសិល្បវិទ្យា ជាមូលដ្ឋានគ្រឹះនោះ គឺសម្រាប់តម្លៃទៅលើស្នាដៃសិល្បៈទៅតាមលក្ខណៈនៃធាតុពិត។ លក្ខណៈវិនិច្ឆ័យទាមទាឲ្យស្នាដៃនៃសិល្បៈដែលត្រូវឆ្លុះបញ្ចាំងជាក់ស្តែងនោះ គឺជា ធាតុសំខាន់នៅក្នុងបាតុភូតសង្គម។ ចរិតជាមូលដ្ឋានរបស់មនុស្ស គឺបំរើជាតិ បំរើប្រជាពលរដ្ឋ និង បានផលកំរៃចិញ្ចឹមគ្រួសារខ្លួន។

សញ្ចេតនាផ្នែកសិល្បវិទ្យាមិនអាចកាត់ផ្តាច់ពីមនសិការ និង ឥរិយាបថ របស់មនុស្ស ចំពោះតថភាពសត្យានុម័តបានឡើយ។ ដូច្នេះហើយបានជា សញ្ចេតនាផ្នែកសិល្បវិទ្យា ត្រូវបានផ្សាភ្ជាប់យ៉ាងជិត

ស្និទ្ធ ទៅនឹងសញ្ចេតនា ផ្នែកសីលធម៌។ ឥរិយាបថរបស់យើង ចំពោះស្នាដៃសិល្បៈ ត្រូវបានកំណត់ច្បាស់ មិនត្រឹមតែរូបភាពនៃការស្តែងចេញនូវស្នាដៃទាំងនោះទេ ក៏ប៉ុន្តែសំខាន់បង្អស់នោះ គឺតម្លៃមនោគមវិជ្ជា និង អត្ថន័យនយោបាយរបស់ស្នាដៃសិល្បៈនោះទៀតផង។

៣. សញ្ចេតនាផ្នែកបញ្ញា (Sentiment intellectual)

សញ្ចេតនាផ្នែកបញ្ញា គឺជាប្រភេទនៃសញ្ចេតនាមួយ៉ាងដែលផ្សាភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹង សកម្មភាពទទួលភ្ជាប់យកចំណេះដឹងរបស់មនុស្ស។

**ឧទាហរណ៍៖** ការងឿងឆ្ងល់ ការចង់ឃើញ ចង់ដឹង (Curiosité) ចំណង់មិនចេះស្ងប់ក្នុងការយល់ដឹង (Avidité à Savoir) ចំណង់ចំណូលចិត្តក្នុងការសិក្សា (Passion de l'étude) ការទុកចិត្ត (Confiance) ការព្រួយបារម្ភ ការកើតសង្ស័យ តាមធម្មតាសញ្ចេតនាទាំងនេះ កើតចេញពីពំនោល (Enoncé) និង ដំណោះស្រាយបញ្ហា ផ្នែកទ្រឹស្តី និង ប្រតិបត្តិ ឬ នៅក្នុងរបកគំហើញ និង ការបង្កើតបានតាមស្នាដៃច្នៃប្រឌិត។

ការស្តែងចេញមួយយ៉ាងសំខាន់ខាងសញ្ចេតនាផ្នែកបញ្ញា គឺសេចក្តីស្រលាញ់ទៅលើអ្វីដែលមានភាពថ្មីថ្មោង។ នេះគឺជាសភាពនៃការពេញចិត្តត្រេតអរដោយឡែក ដែលជះឥទ្ធិពលទៅលើការពង្រឹងពង្រីកបានចំពោះសកម្មភាពនៃការសិក្សាស្រាវជ្រាវ និងការបង្កើតបានតាមស្នាដៃច្នៃប្រឌិត។

យើងត្រូវតែទទួលស្គាល់ថា សកម្មភាពទទួលភ្ជាប់បាននូវចំណេះដឹង ជាបុព្វហេតុនៃសញ្ចេតនាផ្នែកបញ្ញា ហើយក្នុងន័យនេះ សញ្ចេតនាផ្នែកបញ្ញាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសកម្មភាពទទួលចំណេះដឹង តាមរយៈការពង្រឹងបាននូវចំណេះដឹងនោះ ដោយបង្កើនល្បឿននិងលទ្ធផលរបស់ចំណេះដឹងនោះ រួចប្រែក្លាយចំណេះដឹងនោះឲ្យកាន់តែមានភាពសំបូរបែប និង កាន់តែត្រឹមត្រូវទៀតផង។

**ឧទាហណ៍:** គេខិតខំប្រឹងប្រែងសិក្សាស៊ីជម្រៅទៅលើបញ្ហាដែលកំពុងតែងឿងឆ្ងល់ ចង់ឃើញ ចង់ឃើញ ចង់យល់ គេគ្រាន់តែធ្វើការផ្ទៀងផ្ទាត់យ៉ាងម៉ឺងម៉ាត់ ទៅលើបញ្ហា ដែលគេមិនទាន់យល់ច្បាស់ ជាមួយនិងដំណោះស្រាយ ដែលគេយល់បានច្បាស់ រួចផ្តើមចេញពីដំណោះស្រាយនេះ គេទទួលបាននូវចម្លើយយល់ស៊ីជម្រៅកាន់តែត្រឹមត្រូវឡើង។

សញ្ចេតនាផ្នែកបញ្ញា ត្រូវបានស្តែងចេញឲ្យឃើញថែមទៀត តាមរយៈការពេញចិត្តពេញថ្លើម ចំពោះអ្វីៗដែលមានភាពសមហេតុផល ប្រកបដោយវិចារណញ្ញាណ។

**ឧទាហណ៍:** វិចារណញ្ញាណដ៏ភ្លឺស្វាង ដែលអាចអូសទាញមនុស្សឲ្យយល់ជឿតាម ដោយឈរលើមូលដ្ឋាននៃភស្តុងដ៏ប្រាកដប្រជា មានឥទ្ធិពលធ្វើឲ្យមនុស្សមានទំនុកចិត្តបាន។

ផ្ទុយទៅវិញ កាលណាគេមិនពេញចិត្ត ពេញថ្លើម ចំពោះអ្វីមួយគេក្លាយជាមនុស្ស ដែលមិនអាចទ្រាំទ្របាន កាលណាចរិតដ៏សមហេតុផលនោះ បែរទៅជាខុសឆ្គងវិញ។ សញ្ចេតនាផ្នែកបញ្ញាដ៏សកម្ម ស្តែងចេញឲ្យឃើញផងដែរនៅក្នុងសេចក្តី ត្រេតអរ កក់ក្តៅ ចំពោះពាក្យសំដីដ៏ ត្រឹមត្រូវទៀតទាត់ សម

ស្រប តាមក្បួនវេយ្យាករណ៍ សំបូរទៅដោយរូបារម្មណ៍របស់គួរសន្ទនា វាគ្មិនឬ អ្នកបើកសន្និសិទ្ធ។ ផ្ទុយទៅវិញ គេមានការធុញទ្រាន់ណាស់ កាលណាគេស្តាប់សំដីនិយាយច្រំដែលៗ មិនត្រឹមត្រូវទៀងទាត់ ឥតន័យ សោះកក្រោះ ពិបាកយល់....។

## បញ្ហាអប់រំសញ្ចេតនាចំពោះយុវសិស្ស

( La question d´education des sentiments aux jeunes eleves )

សញ្ចេតនាមានអត្ថន័យដ៏ធំធេង សម្រាប់ជីវភាពរស់នៅ និងការងារពីព្រោះសញ្ចេតនាជាកម្លាំងចលករមួយរបស់មនុស្ស។ អាស្រ័យដោយសញ្ចេតនាដ៏សកម្ម មនុស្សយើងអាចប្រែក្លាយធម្មជាតិ កសាងសង្គមថ្មី ប្រកបដោយកម្លាំងពលំដ៏ស្វាហាប់ និងថាមពលដ៏មាំមួនរបស់ខ្លួន។ ការអប់រំសញ្ចេតនាជាភារៈកិច្ចដ៏សំខាន់ណាស់ របស់សាលារៀនមធ្យមសិក្សាចំណោះទូទៅ។ នៅក្នុងការអប់រំសីលធម៌ឲ្យជំនាន់យុវវ័យ សាស្ត្រាចារ្យ មិនគ្រាន់តែបណ្តុះបណ្តាលឲ្យយុវសិស្សនូវសញ្ញាណសីលធម៌ល្អ របស់មនុស្សជាតិ ដែលជាជំនឿស៊ប់ដ៏ស៊ីជម្រៅក្នុងគុណធម៌ និងទម្លាប់សិស្សឲ្យប្រកាន់ភ្ជាប់នូវអំពើប្រកបដោយសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែត្រូវអប់រំដល់យុវសិស្សនូវសញ្ចេតនាសីលធម៌ទៀតផង។

តាមទស្សនៈសិល្បវិទ្យា តួនាទីរបស់សញ្ចេតនាក៏សំខាន់ណាស់ដែរ។ ការអប់រំបញ្ញា ត្រូវបានជម្រុញឡើងដោយសារសញ្ចេតនាផ្នែកបញ្ញានេះឯង។ សញ្ចេតនាជួយយុវសិស្សឲ្យមានចំណង់ចំណូលចិត្តក្នុងការក្តាប់យកចំណេះដឹងក្នុងការស្រាវជ្រាវរកសច្ចធម៌ និងក្នុងការយល់ស៊ីជម្រៅទៅលើចំណេះដឹងវិទ្យាសាស្ត្រ។

១. ដើម្បីរៀបចំបណ្តុះបណ្តាល យុវសិស្សឲ្យក្លាយទៅជា ពលរដ្ឋល្អ បញ្ញវន្តប្រកបដោយសីលធម៌នៅក្នុងសង្គម សាស្ត្រាចារ្យត្រូវបំប៉ន សញ្ចេតនាដ៏សកម្ម មានឥទ្ធិពលខ្លាំង និងស្ថិតនៅបានយូរអង្វែង ហើយប្រែក្លាយសញ្ចេតនាទាំងនោះឱ្យទៅជាមានភាពកក់ក្តៅ សប្បាយរីករាយ ប្រកបដោយការភ្ញាក់រលឹកនៅក្នុងការសិក្សា និង កិច្ចការដើម្បីនឹងពង្រឹងលើរាល់សកម្មភាព របស់យុវសិស្សសំដៅជួយគេទាំងឡាយឲ្យទទួលបានទិន្នផលល្អ ក្នុងការកសាងប្រទេសជាតិ។

២ ការអប់រំសញ្ចេតនាសីលធម៌ចែកចេញជាពីរផ្នែក ៖ ផ្នែកទី ១ គឺជាការអប់រំចិត្តរំភើប និង សញ្ចេតនាដ៏សកម្ម រីឯផ្នែកទី ២ ការធ្វើជាម្ចាស់ការបានទៅលើចិត្តរំភើប និង សញ្ចេតនាអវិជ្ជមាន។ ការយល់ជ្រួតជ្រាបបានទៅលើសញ្ចេតនាដ៏ល្អ គឺជាលក្ខខណ្ឌដ៏សំខាន់នៃភាពធ្វើជាម្ចាស់ការបានទៅលើសញ្ចេតនាអាក្រក់។ ចំពោះសញ្ចេតនាអវិជ្ជមាន សាស្ត្រាចារ្យ មិនត្រូវហាមប្រាមយុវសិស្ស មិនឲ្យប្រព្រឹត្តប្រឆាំងនឹងខ្លួនឯងតាមបែបដ៏សាមញ្ញពេក ឬ តាមបែបដ៏កំរោលពេកទេ។ ការហាមប្រាមតឹងរឹងពេក ច្រើនតែផ្ទុះ ឬផាបឆេះ រោលកាន់តែខ្លាំងនូវសញ្ចេតនាអវិជ្ជមាននោះ ហើយសាស្ត្រាចារ្យពិបាកនឹងបង្រាប ឬ បំបាត់ចោលណាស់។ យកល្អ គឺសាស្ត្រាចារ្យ ត្រូវរកឲ្យឃើញនូវមូលហេតុត្រឹមត្រូវ  យល់ស៊ីជម្រៅ បានលើស្ថានភាពរស់នៅរបស់សិស្សម្នាក់ៗ នឹងមុនដោះស្រាយឲ្យបាន។

៣ តាមធម្មតា កាលណាគេត្រូវផ្លាស់ប្តូរទម្លាប់ ឬ ក៏ផ្លាស់ប្តូរនៃជីវិតរស់នៅ សញ្ចេតនា និង ចិត្តរំភើប ជាអវិជ្ជមាន កើតមានឡើងយ៉ាងងាយ។ ក្នុងន័យនេះ យើងជាសាស្ត្រាចារ្យ ត្រូវចេះប្រយ័ត្នប្រយែង អត់ធ្មត់ ហើយប្រើពាក្យសំដី ទន់ភ្លន់ ហើយបើចាំបាច់ទៅទៀតនោះ សាស្ត្រាចារ្យត្រូវប្រើល្បិចផ្លាស់ប្តូរទម្លាប់ និង បែបបទរស់នៅរបស់សិស្ស ទៅតាមស្ថានភាព និង ពេលវេលាដ៏សមគួរ។

៤ តាមធម្មតា កាលណាសញ្ចេតនា របស់សិស្ស ត្រូវបានផ្សាភ្ជាប់ទៅនឹងរូបារម្មណ៍។ ហេតុដូច្នេះហើយ លើរាល់មធ្យោបាយ ដែលអាចយកមកអប់រំសិស្សបាន ត្រូវរំលឹកឡើងក្នុងស្មារតី ស្មារតីសិស្សពីរូបភាពនៃការសប្បាយរីករាយ និងសុភមង្គលទៅអនាគត។ តាមលក្ខណៈធម្មជាតិ សាស្ត្រាចារ្យ ត្រូវប្រើប្រាស់ឲ្យបានពេញលេញលើរាល់មធ្យោបាយដែលមានលក្ខណៈជាសិល្បៈដូចជា អក្សរសិល្ប៍ កំណាព្យ តន្ត្រី របាំ ល្ខោន ខ្សែភាពយន្ត វីដេអូ សំដៅធ្វើបទសំណេះសំណាល ទៅលើសញ្ចេតនារបស់សិស្ស។ ការអប់រំសញ្ចេតនារបស់សិស្ស តាមរយៈសិល្បៈបែបនេះ មិនមែនមានន័យថា ទាមទាឲ្យសាស្ត្រាចារ្យ ដើរតួរជាអ្នកសំដែងនៅក្នុងរឿងទេ។ សាស្ត្រចារ្យ គ្រាន់តែស្តែងចេញឲ្យឃើញ នូវសញ្ចេតនារបស់ខ្លួនប្រកបដោយភាពស្និតស្នាលជាមួយសិល្បប៉ុណ្ណោះទេ តែត្រូវចៀសវាងឲ្យបានលើសញ្ចេតនាតាមរបៀបបោកបញ្ឆោត និងចិត្តរំភើប ដែលមានលក្ខណៈបំផ្លើស ដូចអ្នកលេងល្ខោន។

## សន្និដ្ឋានគរុកោសល្យ

(conclusions pedagogiques)

សាស្ត្រចារ្យត្រូវបង្ហាញឲ្យឃើញជាគំរូល្អប្រពៃដល់សិស្សានុសិស្ស ដើម្បីឲ្យគេទាំងឡាយត្រាប់តាមហើយនេះជាល្បិចដ៏ល្អប្រសើរ ក្នុងការអប់រំសញ្ចេតនា។ គំរូដ៏ល្អរបស់វីរជន និងតួអង្គ ជាច្រើនក្នុងអត្ថបទអក្សរសិល្ប៍ដែលសាស្ត្រចារ្យលើកយកមកធ្វើការវែកញែករកគុណសម្បត្តិ និង គុណវិបត្តិក៏ជះឥទ្ធិពលល្អដល់សិស្សក្នុងការអប់រំសញ្ចេតនា និងចិត្តរំភើបដែរ។ ម្យ៉ាងវិញទៀត មិនត្រូវភ្លេចខ្លួនថា សាស្ត្រចារ្យ ខ្លួនឯងគឺជាជនគំរូប្រកបដោយសីលធម៌ល្អគ្រប់គ្រាន់ ដល់យុវសិស្សរបស់ខ្លួនជារៀងរាល់ថ្ងៃ។

## សំណួរ

១- ដូចម្ដេចហៅថា ចិត្តរំភើប? ដូចម្ដេចហៅថា សញ្ចេតនា?

២- សញ្ចេតនា និង ចិត្តរំភើប អាចញែកដាច់ពីចំណេះដឹងដ៏ជៅជ្រះរបស់មនុស្សបានដែរទេ? ព្រោះអ្វី?

៣- សញ្ចេតនា និង ចិត្តរំភើប មានលក្ខណៈពិសេសដូចម្ដេចខ្លះ?

៤- ការអប់រំសញ្ចេតនាដល់សិស្សមានអត្ថប្រយោជន៍យ៉ាងណាខ្លះ?

៥- សាស្ត្រាចារ្យ ត្រូវប្រកាន់យកចំណុចល្អណាខ្លះ ដើម្បី អប់រំសញ្ចេតនាដល់សិស្សរបស់ខ្លួន?

៦- ដូចម្ដេចហៅថា ធន្ទៈ?

៧- ចូរពន្យល់អំពី អំពើធន្ទៈ?

៨- អំពើធន្ទៈ និង អំពើអធន្ទៈ ខុសគ្នាយ៉ាងដូចម្ដេច?

៩- អំពើធន្ទៈ មានដំណាក់កាលសំខាន់ៗប៉ុន្មានយ៉ាង?

១០- ចូរវិភាគ អំពីសេចក្ដីប្រាថ្នារបស់មនុស្ស។

# មេរៀនទី១៣ ៖ ឆន្ទៈ និង អំពើឆន្ទៈ ( LA VOLONTE ET L’ACTE VOLONTAIRE )

## I. សញ្ញាណទូទៅស្ដីអំពីអន្ទៈ និង អំពីឆន្ទៈ (Notion generale sur la volonte et l’acte volontaire)

## II. និយមន័យ ( Definition)

ពេលមានទង្វើ មនុស្សមិនគ្រាន់តែស្គាល់ពិភពជុំវិញខ្លួន និង ស្ដែងចេញនូវសញ្ចេតនាប៉ុណ្ណោះទេ ប៉ុន្តែមនុស្សថែមទាំងធ្វើអំពើទៅលើតថភាពសត្យនុម័ត ដើម្បីប្រែក្លាយតថភាពសត្យានុម័យនោះ ឲ្យទៅជាតម្រូវការផ្ទាល់ខ្លួន និង តម្រូវការរបស់សង្គមទៀតផង។ មនុស្សអាចធ្វើរបៀបនេះ ពីព្រោះគេមានឆន្ទៈ ហើយគេស្ដែងចេញនូវឆន្ទៈនេះនៅក្នុងទង្វើរបស់គេ។ ដូច្នេះ ឆន្ទៈ ជាសមត្ថភាពរបស់មនុស្ស ដែលកំណត់បានច្បាស់ នូវគោលបំណងតម្រង់ទិសនៃទង្វើរបស់ខ្លួន ហើយ និងដឹកនាំទង្វើនោះ ទៅតាមគោលបំណង និងការតម្រង់ទិស ដូចដែលបានកំណត់មកហើយ។ ឆន្ទៈរបស់មនុស្ស ស្ដែងចេញឲ្យឃើញ ជានិច្ចនៅក្នុងទង្វើ ហើយទង្វើនេះ គេឲ្យឈ្មោះថា ទង្វើឆន្ទៈ។ នៅក្នុងទង្វើឆន្ទៈ បុគ្គលតែងតែជ្រើសរើសទុកបានជានិច្ច នូវមធ្យោបាយ និងល្បិច សំដៅឈានដល់សម្រេចបានតាមគោលបំណង។ មនុស្សខិតខំប្រឹងប្រែង ដើម្បីជំនះបានលើការលំបាកសព្វបែបយ៉ាង ហើយនិងឧបសគ្គដែលគេអាចជួបប្រទះ នៅពេលដែលគេមានទង្វើ ដើម្បីឆ្ពោះទៅសម្រេចបានតាមគោលដៅ។

## III. ភាពខុសគ្នារវាងទង្វើឆន្ទៈ និងអឆន្ទៈ

( Distinction entre l’action volontaire et l’action involontaire )

គេអាចបែងចែកជា ទង្វើឆន្ទៈ និង ទង្វើអឆន្ទៈ ឬទង្វើសភាវគតិ។

**១ អឆន្ទៈ** (Actions involontaires)

**១ អំពើអឆន្ទៈ** (Action Involontaire)

ទង្វើអឆន្ទៈបែកចេញជា រ៉េផ្លិចទាំងឡាយដូចជា ការក្អក (La toux) ការកណ្ដាស់ (L’eternument) ការព្រិចភ្នែក (Le elignement des yeux) ការកន្ត្រាក់ដៃចេញក្នុងករណីមុតម្ជុល ឬរលាកភ្លើង ( Le retrait de la main en cas de piqure ou de brulure)។ អំពើអឆន្ទៈដ៏ស្មុគស្មាញ គឺជាអំពើសភាវគតិ ដែលមានមូលដ្ឋានសរីរវិទ្យារបស់វាត្រូវបានបង្កើតឡើងដោយកំរងរ៉េផ្លិចឥតលក្ខខណ្ឌ (Chaines de reflexes inconditionnels) ។ អំពើដែលសំដែងចេញនូវចិត្តរំភើបរបស់មនុស្ស គឺជាអំពើអឆន្ទៈពីកំណើតដែរ ( Actes volontaires innes) ដូចជាទឹកមុខឡើងក្រហម (Le visage rougit) ស្លឹកត្រចៀកឡើងក្រហម (Les oreilles rougits) ស្លឹកត្រចៀកឡើងក្រហម ( Les oreilles deviennt

pourpres) ការភ័យខ្លាច (Tremblement de peur) ការភ័យរន្ធត់ញ័រចំប្រប់ (Frissonnement d' horreur)។

១. ជាទូទៅ អំពើអឆន្ទៈរបស់មនុស្សកើតឡើងតាមបែបអចេតនា ក៏ប៉ុន្តែនៅក្នុងការលៈទេសៈខ្លះ អំពើទាំងនោះ ត្រូវបានគេមើលឃើញនៅពេលមនុស្សមានទង្វើ ហើយជាពិសេសនៅពេលដែលទង្វើរបស់ខ្លួនត្រូវចប់រួចរាល់។ បញ្ហានេះស្តែងឲ្យយើងនៅក្នុងឥរិយាបថដ៏ត្រឹមត្រូវ ឬ មិនពេញចិត្តរបស់មនុស្ស នៅចំពោះមុខអំពើអឆន្ទៈរបស់ខ្លួន។ គេវិនិច្ឆ័យអំពើនោះ ទៅតាមភាពចាំបាច់ អត្ថប្រយោជន៍ និងនិយាមសីលធម៌។ នេះគឺជាចំណុចមួយគួរឲ្យកត់សំគាល់បានទៅលើអំពើអចេតនារបស់មនុស្ស។២ ផ្ទុយស្រឡះពីអំពើអចេតនា អំពើចេតនា និង អំពើឆន្ទៈ ស្ថិតនៅជាអំពើ ប្រកបដោយការភ្ញាក់រលឹក ជានិច្ច។ ឆន្ទៈស្តែងឲ្យឃើញក្នុងករណីនេះ តាមរយៈការកំណត់នូវគោលដៅ បំណងនៃអំពើ តាមរយៈជម្រើសដែលគិតទុកមុន នូវមធ្យោបាយ និងល្បិច នៅក្នុងការប្រតិបត្តិ និង ក្នុងកិច្ចខិតខំប្រឹងប្រែង សំដៅសម្រេចបាននូវ ភារៈកិច្ច។

អំពើឆន្ទៈ ឬ អំពើចេតនា មិនមែនជាអំពើដែលកើតឡើងឯង ហើយស្ថិតនៅដាច់ស្រឡះពីមូលហេតុនោះទេ។ នៅក្នុងករណីនេះ យើងត្រូវមានទស្សនៈមួយដ៏ត្រឹមត្រូវ និង ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ។ យើងត្រូវប្រឆាំង យ៉ាងស្វាហាប់ ទល់នឹងទស្សនៈផ្ទុយនឹងវិទ្យាសាស្ត្រ និង ទស្សនៈប្រតិបត្តិ ដែលចាត់ទុកឆន្ទៈរបស់មនុស្ស ជាកម្លាំង ស្មារតី ម្យ៉ាងដោយឡែក ដែលស្ថិតនៅដាច់ស្រឡះពីមូលហេតុ ជាសន្យានុម័ត ពីលំនាំសរីរៈវិទ្យា នៃសារពាង្គកាយ ហើយដឹកនាំអំពើរបស់មនុស្សទាំងអស់។ តាមទស្សនៈវិទ្យាសាស្ត្រដ៏ត្រឹមត្រូវ គេបានកំណត់ថា អំពើឆន្ទៈរបស់មនុស្ស ទទួលរងជានិច្ច នូវលក្ខខណ្ឌសង្គម ប្រវត្តិ ដែលមនុស្សរស់នៅ និង ប្រព្រឹត្តអំពើ។ S 2- **ដំណាក់កាលសំខាន់ៗរបស់លំនាំនៃឆន្ទៈ** (Les Principales phases du processus de la volonte)

## III. **កំណើតនៃសេចក្តីប្រាថ្នារបស់មនុស្ស** (Naissance de l' aspiration)

លំនាំនៃឆន្ទៈចាប់ផ្តើមកើតឡើងជានិច្ចតាមរយៈសេចក្តីប្រាថ្នា។ សេចក្តីប្រាថ្នាកើតចេញពីតម្រូវការរបស់មនុស្ស។ សេចក្តីប្រាថ្នានេះ តម្រង់មុខសញ្ញាទៅរកវត្ថុបំណងមួយដ៏ជាក់លាក់ ហើយដែលលទ្ធភាពបំពេញសេចក្តីត្រូវការ ឬ ក៏កម្មវត្ថុណាមួយដ៏ពិតប្រាកដដែលមនុស្សស្វែងរក ឬចង់បង្កើតឲ្យមានឡើង។

សេចក្តីប្រាថ្នារបស់មនុស្សសំបូរបែប មានច្រើនប្រភេទផ្សេងគ្នាៗ ហើយស្មុគស្មាញណាស់។ គេអាចធ្វើចំណែកថ្នាក់របស់មនុស្សទៅតាមកម្រិតនៃការចូលរួមពីសំណាក់មនសិការរបស់មនុស្ស។ ដោយឈរលើមូលដ្ឋាននៃកម្រិតចូលរួមរបស់មនសិការនេះ គេអាចចែកសេចក្តីប្រាថ្នារបស់មនុស្សជាពីរប្រភេទផ្សេងៗគ្នា៖

### ១. **បំណង** (L' intention)

គឺជាសេចក្តីប្រថ្នារបស់មនុស្ស ដែលស្ថិតនៅក្នុងកម្រិតទាបជាចំណង់ដែលមិនប្រាកដប្រជា ដែលគ្រាន់តែស្តែងចេញឲ្យឃើញនៅក្នុងការព្រួយបារម្ភ នៅក្នុងការមិនពេញចិត្តពេញថ្លើម ចំពោះមុខនៃសភាពបែបណាមួយមិនពិតប្រាកដតែប៉ុណ្ណោះ ប៉ុន្តែមិនមែនជាកម្មវត្ថុ ឬ គោលបំណងដ៏ពិតប្រាកដ នោះឡើយ។

បំណង គឺជាសភាពផ្លូវចិត្តរបស់មនុស្សដែលមនុស្សដឹងខ្លួននៅពេលណាដែលមនុស្សប្រទះឃើញរបស់អ្វីមួយដែលហាក់ដូចជាមានប្រយោជន៍ចាំបាច់ចំពោះខ្លួនគេ ប៉ុន្តែមនុស្សមិនទាន់យល់ដឹងច្បាស់ពីវត្ថុនោះនៅឡើយ ពោលគឺមនុស្សមិនទាន់មានសញ្ញាណណាមួយ ដ៏ច្បាស់លាស់នៅក្នុងស្មារតីរបស់គេ។ កាលណាមនុស្សគ្រាន់តែមានមនុស្ស តាមធម្មតា មនុស្សមិនទាន់គិតដល់នៅឡើយ ចំពោះមធ្យោបាយ និង ល្បិចដែលគេត្រូវយកមកប្រើប្រាស់ដើម្បីឈានទៅសម្រេចតាមគោលដៅរបស់គេ។ ពេលនោះមនុស្សមិនអាចសម្រេចបាននូវទង្វើរបស់ខ្លួននៅឡើយ។

**២. ចំណង់** ( Le desir )

ចំណង់ គឺជាសេចក្តីប្រាថ្នា ដែលបង្ហាញឲ្យឃើញច្បាស់លាស់ជាបង្គួរ។ មនុស្សដែលមានចំណង់គឺជាមនុស្សដែលស្គាល់ច្បាស់លាស់នូវវត្ថុបំណង និង គោលដៅនៃសេចក្តីប្រាថ្នារបស់គេ ក៏ប៉ុន្តែមនុស្សមិនទាន់ស្គាល់ ឬស្ទាប់ស្ទង់បាននៅឡើយ ចំពោះមធ្យោបាយ និង ល្បិច ដែលខ្លួនត្រូវយកមកប្រើប្រាស់ដើម្បីឈានទៅសម្រេចតាមគោលបំណងដែលកំណត់ទុកនោះ។ តាមធម្មតាចំណង់ ត្រូវបានផ្សាភ្ជាប់យ៉ាងជិតស្និទ្ធ ទៅនឹងសកម្មភាពនៃរូបារម្មណ៍ ហើយជួនកាលផ្សារភ្ជាប់ ទៅនឹងអានុភាពនៃការស្រមើស្រមៃទៀតផង។ កាលបើមនុស្សមានចំណង់ហើយ តាមធម្មតាមនុស្សតែងតែគិតរិះរកល្បិច និង មធ្យោបាយ ឃើញហើយ ចំណង់របស់មនុស្ស ត្រូវបានគេសង្កេតឃើញយ៉ាងច្បាស់លាស់ ពោលគឺចំណង់នោះបានក្លាយទៅជាសេចក្តីប្រាថ្នារបស់មនុស្សទៅតាមអត្តន័យដ៏ត្រឹមត្រូវ ហើយមនុស្សអាចចាប់ផ្តើមសម្រេចនូវទង្វើរបស់ខ្លួនបាន។ ហេតុដូច្នេះហើយ អំពើឆន្ទៈឬ អំពើចេតនា របស់មនុស្ស គឺពិតជាអំពើដែលមនុស្សសម្រេចបាន ទៅតាមចំណង់ដែលមនុស្សបង្កើតឡើងបានយ៉ាងគ្រប់គ្រាន់នៅក្នុងផ្លូវចិត្ត។

## IV. ការតស៊ូខាងក្នុងខ្លួនមនុស្ស ( La lute interieure )

ដោយយោងទៅតាមបទពិសោធន៍ យើងអាចមានចំណង់ជាច្រើននៅក្នុងពេលដំណាលគ្នា និង សេចក្តីប្រាថ្នាដ៏សំបូរបែប ពីព្រោះនៅក្នុងពលជាមួយគ្នានោះ មនុស្សយើងមានតម្រូវការជាច្រើន ដែលត្រូវបំពេញទៅតាមបំណងរបស់ខ្លួន។

**ឧទាហរណ៍:** នៅពេលល្ងាចមួយ យើងត្រូវសិក្សាមេរៀនសម្រាប់ថ្ងៃស្អែកផង សរសេរសំបុត្រផ្ញើរទៅសំឡាញ់ចាស់ម្នាក់ផង ហើយត្រូវបង្ហើយលំហាត់ដែលសាស្ត្រាចារ្យដាក់ឲ្យធ្វើផង។

ចំណង់ និង សេចក្តីប្រាថ្នា ព្រមទាំងគោលបំណងដែលកើតឡើងក្នុងពេលជាមួយគ្នានោះ អាចឲ្យមនុស្សមានល្បិច និង មធ្យោបាយជាច្រើន ដើម្បីឈានទៅសម្រេចតាមចំណង់ចំណូលចិត្តរបស់ខ្លួន

ហើយមនុស្សអាចប្រព្រឹត្តអំពើជាច្រើនផ្សេងៗគ្នា។ អំពើនីមួយៗ អាចធ្វើឲ្យមនុស្សសម្រេចបាននូវលទ្ធផល ដែលគេបានគ្រោងទុកដ៏ពិតប្រាកដ។ ដូច្នេះយោលទៅតាមតថភាព យើងត្រូវចេះជ្រើសរើសសេចក្ដីប្រាថ្នា គោលបំណង ល្បិច និង បធ្យោបាយ?

ទាំងនេះគឺជាការផុសចេញនូវមូលហេតុ។ អំពើធន្ទៈខុសប្លែកគ្នាពីអំពើអធន្ទៈ ត្រង់ដែល អំពើធន្ទៈជំរុញមនុស្ស តាមរយៈការផុសចេញ នូវមូលហេតុមួយដ៏ពិតប្រាកដ។ លំនាំនៃជម្រើសរបស់សេចក្ដីប្រាថ្នា គោលបំណង ល្បិច និង មធ្យោបាយ មានលក្ខណៈជាការបំផុតចេញនូវអំពើរបស់មនុស្ស។ ការតស៊ូនៅខាងក្នុងខ្លួនមនុស្សនេះ គឺពិតជាការតស៊ូរវាងការបំផុសចេញនូវអំពើរបស់មនុស្ស។ ការតស៊ូនេះ អាចហៅម្យ៉ាងទៀតថា ការតស៊ូរវាងការបំផុសចេញនូវមូលហេតុ និង គំនិត ជាច្រើន។

នៅក្នុងការតស៊ូរវាងការផុសចេញនូវមូលហេតុទាំងនេះ តាមធម្មតាគេសង្កេតឃើញថា ការផុសចេញនូវមូលហេតុបែបណាមួយនោះ មានលក្ខណៈត្រឹមត្រូវប្រកបដោយវិចារណញ្ញាណជាងគេ ហើយមូលហេតុខ្លះទៀត មានលក្ខណៈទន់ខ្សោយ។

នៅក្នុងករណីជាច្រើន ការតស៊ូរវាងការផុសចេញនូវមូលហេតុទាំងឡាយបានក្លាយទៅជាតស៊ូរវាងវិចារណញ្ញាណ និង សញ្ចេតនារបស់មនុស្សទៅវិញ។ ជូនកាលមនុស្សដឹងខ្លួនថា ខ្លួនស្ថិតនៅក្នុងសភាពដ៏លំបាកលំបិន មានចិត្តស្ទាក់ស្ទើរ ហើយមិនអាចលំអៀងទៅរកផ្នែកសញ្ចេតនា ឬ ផ្នែកវិចារណញ្ញាណ បានឡើយ។ ក្នុងករណីនេះ ធ្វើឲ្យមនុស្សកើតមានសេចក្ដីប្រាថ្នា គោលបំណង និង មធ្យោបាយ ប្រកបដោយវិចារណញ្ញាណដ៏ត្រឹមត្រូវ ប៉ុន្តែនៅពេលនោះមនុស្សក៏កើតមាននូវសញ្ចេតនាអវិជ្ជមានដែរ ឬ ក៏កាលណាគោលបំណងនៃសេចក្ដីប្រាថ្នារបស់មនុស្សសមស្របទៅនឹង សញ្ចេតនាវិញនោះ ធ្វើឲ្យមនុស្សកើតមាននូវសភាពចិត្តមួយគួរជាទីពេញចិត្ត តែវាមិនសមស្របទៅនឹងវិចារណញ្ញាណទេ។

ជួនកាលការតស៊ូ នៃការផុសចេញនូវមូលហេតុទាំងឡាយ ស្តែងចេញឲ្យឃើញក្រោមរូបភាព នៃការតស៊ូរវាងសញ្ចេតនារបស់បុគ្គលិកលក្ខណៈ ចំណងមិត្តភាព និង បុគ្គលនិយមទៅវិញ។ សាស្ត្រាចារ្យមានភារៈកិច្ចលើកទឹកចិត្តសិស្ស ឲ្យខិតខំប្រឹងប្រែងព្យាយាម ដើម្បីទទួលសម្រេចបាននូវជោគជ័យក្នុងការតស៊ូរ នៃភាពលំបាកខាងក្នុងខ្លួន ដែលកើតមានឡើងរៀងរាល់ថ្ងៃ។ ឧត្តមគតិជាតិ និង មនសិការនយោបាយ ចំពោះមាតុភូមិបំពេញតួនាទីជាកំណត់ នៅក្នុងជម្រើសនៃការផុសចេញនូវមូលហេតុទាំងឡាយ ដែលជំរុញមនុស្សឲ្យប្រព្រឹត្តនូវអំពើល្អ។ វាចារបស់ សាស្ត្រាចារ្យ និង មតិយោបល់របស់សមូហភាពសិស្ស ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសិស្សម្នាក់ៗ។ វាចារបស់សាស្ត្រាចារ្យ ជួយសិស្សម្នាក់ៗឲ្យជំនះបានលើរាល់ទស្សនៈខុសឆ្គង និង សញ្ចេតនាអវិជ្ជមាន។

## V. **សេចក្ដីសម្រេចចិត្ត** ( La decision )

លំនាំនៃការតស៊ូខាងក្នុងខ្លួនមនុស្ស និង ការតស៊ូរវាងមូលហេតុទាំងឡាយដែលផុសចេញខាងក្នុងខ្លួន អាចមានលក្ខណៈងាយស្រួល ឬ លំបាក យូរ ឬ ឆាប់ ប៉ុន្តែវាអាចបញ្ចប់បានជានិច្ច អាស្រ័យដោយសេចក្តីសម្រេចចិត្តមួយដ៏ពិតប្រាកដរបស់មនុស្ស។ សម្រេចចិត្តមានន័យថា សម្រេចយកទៅតាមគោលបំណងណាមួយ ល្បិចណាមួយនិង មធ្យោបាយណាមួយ ជាកំណត់ ហើយចាំបាច់ណាស់ដើម្បីឈានទៅសម្រេចបានតាមបំណងណាមួយនោះ។ នេះគឺបានន័យថា រវាងការផុសចេញនៃមូលហេតុពិតប្រាកដទាំងឡាយ មានមូលហេតុតែមួយគត់ក្នុងចំណោមនោះ ដែលដើរតួនាទីជាកំណត់។

ការតស៊ូរវាងការផុសចេញនៃមូលហេតុទាំងឡាយខាងក្នុងមនុស្ស ជួនកាលមានភាពងាយស្រួល ជួនកាលមានលក្ខណៈស្មុគស្មាញ ជួនកាលងាយស្រួលក្នុងការសម្របសម្រួល ជួនកាលទៀតពិបាកនឹងដោះស្រាយណាស់។

**ឧទាហរណ៍:** ព្រឹកថ្ងៃអាទិត្យមួយ យើងចង់ទៅដើរលេងផង យើងចង់ទៅមើលខ្សែភាពយន្តផង។ បន្ទាប់ពីថ្លឹងថ្លែងក្នុងគំនិតអស់រយៈពេលយ៉ាងខ្លី យើងសម្រេចចិត្តថា ទៅដើរលេងវិញ។ ដូច្នេះ យើងបានសម្រេចចិត្តយ៉ាងរហ័ស ហើយទន្ទឹមនឹងនោះ យើងជឿជាក់ទៅលើលទ្ធភាពនៃការសម្រេចបានបែបណាមួយតាមរយៈការសម្រេចចិត្តនេះ។ ក្នុងករណីនេះ យើងបញ្ចេញនូវភាពស្វាហាប់។

សិស្សម្នាក់ដែលទើបនឹងប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាកម្រិត II ចង់ប្រឡងចូលរៀននៅមហាវិទ្យាល័យ តែខ្លួនមិនដឹងជ្រើសរើសយកមហាវិទ្យាល័យណាមួយដែលសមស្រប។ នេះគឺជាការជ្រើសរើសមុខរបទៅអនាគត : គេអាចក្លាយខ្លួនជាវិស្វករ ទៅជាសាស្ត្រាចារ្យ ទៅជាអ្នកបរិញ្ញាខាងច្បាប់ ទៅជាវេជ្ជបណ្ឌិត ។ ល។ ការជ្រើសរើសមុខរបនេះ គឺជាការលំបាកណាស់។ គេស្ថិតនៅក្នុងភាពរាំងស្ទះក្នុងចិត្តអស់ រយៈពេលយ៉ាងយូរ។ លុះដល់ពេលមួយដ៏ពិតប្រាកដ គេក៏សម្រេចចិត្ត ប៉ុន្តែគេមិនទាន់ជឿថា គេមានសមត្ថភាពគ្រប់គ្រាន់ទេ គេស្ទាក់ស្ទើរក្នុងចិត្តហើយគេបោះបង់ចោលនូវសេចក្តីសម្រេចចិត្តនោះ។ នេះគឺជាការស្តែងចេញនៃសេចក្តីស្ទាក់ស្ទើរក្នុងចិត្ត។ ចរិតដ៏ស្វាហាប់ច្រើនតែអមទៅដោយ សភាពនៃសញ្ចេតនា គួជាទីពេញចិត្ត។ ប៉ុន្តែសភាពនៃសញ្ចេតនាដ៏ស្ពឹកស្រពន់ ពិបាកក្នុងចិត្តតែងតែ ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធ ចរិត អល់អែក ក្នុងចិត្តជានិច្ច។

ការសម្រេចចត្តិបានយ៉ាងឆាប់រហ័ស អាស្រ័យដោយមូលហេតុជាច្រើនគួបផ្សំគ្នា ជាពិសេសគឺតម្រូវការ កម្លាំងនៃការផុសចេញនូវមូលហេតុ ស្ថានភាពជាក់ស្តែង សភាពចិត្តផ្នែកសញ្ចេតនា កម្រិតវប្បធម៌ បទពិសោធន៍ ចំណេះដឹងមតិយោបល់របស់សមូហភាព សេចក្តីទូន្មានពីសំណាក់មនុស្សដែលជិតស្និតរាល់ថ្ងៃ ហើយនឹងសាស្ត្រាចារ្យ។

នៅក្នុងករណីខ្លះ ដើម្បីសម្រេចចិត្តឲ្យបានត្រឹមត្រូវ គេគប្បីថ្លឹងថ្លែង ត្រិះរិះឲ្យហ្មត់ចត់ លើរាល់ការផុសចេញនូវមូលហេតុនីមួយៗខាងក្នុងខ្លួន។ នៅក្នុងករណីជាច្រើន គេត្រូវតែសម្រេចចិត្តឲ្យបានយ៉ាងឆាប់រហ័ស ទោះបីជាការងារនោះស្មុគស្មាញយ៉ាងណាក៏ដោយ។

**ឧទាហរណ៍:** ការបង្រៀនរបស់សាស្ត្រាចារ្យក្នុងថ្នាក់។ អំពើបង្រៀនមិនគ្រាន់តែទាមទារនូវបច្ចេកទេស គរុកោសល្យ និង សម្ភារៈឧបទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទាមទារនូវសេចក្តីសម្រេចចិត្ត របស់សាស្ត្រាចារ្យ ឲ្យបានយ៉ាងឆាប់រហ័សទៀតផង។

តាមធម្មតាមេរៀនដែលត្រៀមសម្រាប់បង្រៀនរួចមកហើយ មិនសមស្របត្រឹមត្រូវទៅនឹង ស្ថានភាពជាក់ស្តែង របស់សមូហភាពសិស្សឡើយ។ សាស្ត្រាចារ្យ ត្រូវកែតំរូវ និងបន្ថែម បន្ថយខ្លឹមសារខ្លះទៀតក្នុងមេរៀន ដើម្បីឲ្យសមស្របទៅនឹងកម្រិតយល់ដឹងរបស់សិស្ស។ នៅក្នុងករណីបែបណានោះ សាស្ត្រាចារ្យ ត្រូវសម្រេចចិត្តឲ្យបានយ៉ាងរហ័ស។ ប្រសិនណា ជា សាស្ត្រាចារ្យ ស្ទាក់ស្ទើរក្នុងចិត្ត មេរៀនត្រូវបានផ្អាក ហើយបរិយាកាសថ្នាក់រៀនទៅជា មានសភាពធូន់ធូរ សមូហភាពសិស្សទៅជាអនាធិបតេយ្យគ្មានវិន័យ។ ដូច្នេះចរិតស្វាហាប់ របស់សាស្ត្រាចារ្យ មិនគ្រាន់តែស្តែងចេញនៅក្នុងការសម្រេចចិត្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ធ្វើឲ្យលទ្ធផលនៃការងារបានសម្រេចយ៉ាងរហ័សទៀតផង។

## VI. ការធ្វើឲ្យសេចក្តីសម្រេចចិត្តបានសម្រេច ( La realization de la decision )

ការធ្វើឲ្យសេចក្តីសម្រេចចិត្តបានសម្រេចដូចបំណង គឺជាតំណាក់កាលមួយដ៏សំខាន់របស់លំនាំធ ន្ទៈ។ គេអាចពោលបានថា ការធ្វើឲ្យសេចក្តីសម្រេចចិត្តបានសម្រេចតាមបំណងបែបនេះ គឺជាការស្តែង ចេញដ៏ជាក់ស្តែងបំផុតនៃឆន្ទៈរបស់មនុស្ស។

អំពើអន្ទៈ ឬ អំពើចេតនារបស់មនុស្ស ស្តែងចេញឲ្យឃើញតាមរយៈកាយវិការ អំពើរបស់មនុស្ស ហើយវានឹងការបាត់បង់ទៅវិញ ចំពោះការបញ្ចេញកាយវិការ និង អំពើដែលមិនចាំបាច់។ ការធ្វើឲ្យមានសេ ចក្តីសម្រេចចិត្តបែបនេះ ទាមទាឲ្យមានភាពត្រឹមត្រូវ និង ភាពទៀងទាត់ទៀតផង។ សេចក្តីសម្រេចចិត្ត ដែលទទួលផលមិនបានសម្រេចទៅតាមភាពត្រឹមត្រូវ នៅក្នុងរយៈពេលមួយជាកំណត់នោះ នាំឲ្យបាត់បង់ នូវតម្លៃរបស់សេចក្តីសម្រេចចិត្តនេះតែម្តង។

នៅក្នុងករណីបែបណាមួយនោះ សេចក្តីសម្រេចចិត្តបានគ្រាន់តែជាការប៉ាន់ប្រមាណ ឬ ជាគំនិត មួយដែលគេមានតាំងពីមុនរួចមកហើយ។ ការធ្វើឲ្យសេចក្តីសម្រេចចិត្តបានសម្រេច ទាមទារនូវការ បញ្ចេញថាមពល និង កិច្ចខិតខំប្រឹងប្រែង ដ៏ពិតប្រាកដដើម្បីជំនះបានលើរាល់ឧបសគ្គ និង ការលំបាក។

ដើម្បីធ្វើឲ្យសេចក្តីសម្រេចចិត្តបានសម្រេច និងការប្រែក្លាយសេចក្តីសម្រេចចិត្តនោះ ឲ្យទៅជា អំពើ មិនមែនជាការងាយស្រួលទេ។ នេះទាមទាឲ្យមានការខិតខំប្រឹងប្រែងពីសំណាក់ឆន្ទៈរបស់មនុស្សទៀតផ ង។ កិច្ចខិតខំប្រឹងខាងផ្នែកឆន្ទៈនេះ គឺជាកត្តាមួយដ៏សំខាន់យ៉ាងដាច់ណាត់។ តាមធម្មតា សេចក្តី សម្រេចចិត្តមិនអាចប្រែក្លាយបានយ៉ាងទាន់ហន់ ទៅជាទង្វើបានទេ ប៉ុន្តែវាទាមទារឲ្យមានការតស៊ូជាបន្ត ទៀតនៅខាងក្នុងខ្លួនមនុស្ស ទើបមានការសម្រេចបានដ៏ត្រឹមត្រូវ និង ទាន់ពេលវេលា។ ហេតុដូច្នេះ បាន ជាកិច្ចខិតខំប្រឹងប្រែងខាងផ្នែកឆន្ទៈនេះ មានលក្ខណៈចាំបាច់ណាស់។កិច្ចខិតខំប្រឹងប្រែងខាងផ្នែកឆន្ទៈ

ស្តែងឡើងនៅក្នុងធាតុតានតឹង នៃសកម្មភាពសរសៃប្រសាទផ្នែកខាងលើកំនើននៃសកម្មភាពរបស់សំបកខួរក្បាល ភាពតានតឹងរវាងចំណុចទាំងឡាយនៃទឹកមុខរបស់មនុស្ស និង ការស្តែងចេញនូវកាយវិការដៃជើង។ កិច្ចខិតខំប្រឹងប្រែងនេះ គឺជាចរិតមួយរបស់លំនាំនៃឆន្ទៈ ដែលជាចរិតលក្ខណៈមួយនៃអំពើឆន្ទៈដែលញែកដាច់ស្រឡះពីអំពើដែលកើតមានឡើងឯង។ ដោយគ្មានគោលបំណងច្បាស់លាស់។ អំពើឆន្ទៈស្តែងចេញឲ្យឃើញកាន់តែច្បាស់ នៅក្នុងកិច្ចខិតខំព្យាយាមប្រឹងប្រែង ដើម្បីជំនះបានលើរាល់ ឧបសគ្គ និងការលំបាក។ ដូច្នេះបានន័យថា មនុស្សស្តែងចេញនូវឆន្ទៈរបស់ខ្លួននៅពេលណាដែលមនុស្សត្រូវពុះពារជំនះលើរាល់ការលំបាក។ ការលំបាកមានពីរយ៉ាងគឺៈ ការលំបាកដែលមានលក្ខណៈជាអត្តនោម័ត និង ការលំបាកដែលមានលក្ខណៈសត្យានុម័ត។

## ក. ការលំបាកដែលមានលក្ខណៈអត្តនោម័ត (Les difficulties subjectives)

គឺជាការលំបាកក្នុងខ្លួនបុគ្គលម្នាក់ៗ ហើយរួមមានសភាពនៃស្មារតីអវិជ្ជមាន ដែលទប់ស្កាត់មិនឲ្យសេចក្តីសម្រេចចិត្តបានសម្រេចដូចបំណង។ ជារឿយៗ បុគ្គលច្រើនតែស្ថិតនៅក្នុងសភាពអសកម្ម ដូចជាៈ ការសម្រាក ការនឿយហត់ ការមានជម្ងឺ ការដេកលក់ ។ល។ ក្នុងរយៈពេលបែបនេះ ងាយធ្វើឲ្យកើតមានឡើងនូវ សភាពផ្លូវចិត្តដែលមិនអនុគ្រោះដល់ការធ្វើឲ្យសេចក្តីសម្រេចចិត្តបានសម្រេច។

**ឧទាហរណ៍ៈ** ភាពនៃសេចក្តីខ្ជិលច្រអូស។ គឺដោយសារកិច្ចខិតខំប្រឹងប្រែងនៃឆន្ទៈ ដែលមនុស្សប្រែក្លាយអំពើអសកម្ម និងអំពើអវិជ្ជមាន ឲ្យទៅជាអំពើអវិជ្ជមាន ឲ្យទៅជាអំពើមានភាពសកម្មវិញ។ កាលណាធាតុអាកាសត្រជាក់យើងសម្រាក។ ស្រាប់តែយើងនឹកឃើញថា មានកិច្ចការមួយដែលយើងត្រូវដោះស្រាយជាបន្ទាន់។ ពេលនោះយើងក្រោកឡើងប្រកបដោយការខិតខំព្យាយាមខាងផ្នែកឆន្ទៈពុះពារ និង ធាតុអាកាសដ៏ត្រជាក់ ដើម្បីចាប់ផ្តើមកិច្ចការនោះ ឲ្យបានសម្រេចសិន។

ដោយសារកិច្ចខិតខំប្រឹងប្រែងខាងផ្នែកឆន្ទៈនេះហើយ ទើបយើងតំរូវឲ្យខួរក្បាលយើងចាប់ផ្តើមធ្វើការ។ នៅក្នុងម៉ោងសិក្សានៅក្នុងថ្នាក់រៀន បើសិស្សមិនមានឆន្ទៈដ៏ចាំបាច់ទេនោះ សិស្សមិនអាចផ្ចង់ស្មារតីប្រុងប្រយ័ត្នបានទៅលើមេរៀន ហើយនឹងមិនអាចបញ្ចេញឥទ្ធិពលបាននៅក្នុងលំនាំនៃការភ្ជាប់យកចំណេះដឹងបានទៀតផង។ ការលត់ដំ លះបង់ចោលនូវទំលាប់អាក្រក់ ក៏ទាមទារឲ្យមានការខិតខំប្រឹងប្រែងខាងផ្នែកឆន្ទៈនេះច្រើនទៀតដែរ។

## ខ. ភាពលំបាកដែលមានលក្ខណៈសត្យានុម័ត (Les difficulties objectives)

គឺជាការលំបាកខាងក្រៅខ្លួនមនុស្ស ដែលមនុស្សត្រូវជំនះឲ្យបាន ដោយសារកិច្ចខំប្រឹងប្រែងខាងផ្នែកឆន្ទៈ។ ការលំបាកនេះកើតចេញពីឧបសគ្គដែលមាននៅក្នុងមជ្ឈដ្ឋានរស់នៅ។ លោក សត្យានុម័តមានដំណើរប្រព្រឹត្តទៅ ទៅតាមក្រិត្យក្រមដ៏ច្បាស់លាស់ និង ល្បិចដ៏ពិតប្រាកដរបស់វា។ ហេតុដូច្នេះហើយនៅក្នុងតថភាពសត្យានុម័ត មនុស្សមិនអាចគេចផុតពីការលំបាក និង ការប៉ះទង្គិចគ្នា ខាងពាក្យ

សំដី នៅក្នុងសកម្មភាពរបស់ខ្លួនឡើយ។ មានពេលខ្លះបុគ្គលស្ថិតនៅក្នុងស្ថានភាពទាល់ច្រក។ លំនាំនៃទង្វើរបស់មនុស្សទៅលើធម្មជាតិ និងការប្រែក្លាយធម្មជាតិ ទៅតាមតម្រូវការរបស់ខ្លួន គឺជាលំនាំនៃការតស៊ូជាសាវន្ត និងការទទួលាបានជោគជ័យលើឧបសគ្គ និង ភាពលំបាករបស់ខ្លួន ហើយបង្កើតបាននូវតម្លៃថ្មីខាងផ្នែកសម្ភារៈ និង ស្មារតីទៀតផង។ ហេតុដូច្នេះហើយ លើរាល់រូបភាពនៃសកម្មភាព និងគ្រប់ប្រភេទនៃការងារទាំងអស់របស់មនុស្សទាមទារជាចាំបាច់ នូវកិច្ចខិតខំប្រឹងប្រែងខាងផ្នែកឆន្ទៈនេះឯង។ ការងាររបស់មនុស្ស គឺពិតជាការស្តែងចេញខាងផ្នែកឆន្ទៈរបស់គេ។ ឆន្ទៈរបស់មនុស្សកើត និង អភិវឌ្ឍឡើងឥតឈប់ឈរ នៅក្នុងលំនាំនៃការងារលំនាំនៃការសិក្សា និង សកម្មភាព។

លំនាំនៃការសិក្សារបស់សិស្ស ក៏គឺជាលំនាំនៃការតស៊ូមួយផងដែរ ដើម្បីទទួលបានជោគជ័យលើឧបសគ្គ និង ការលំបាក។ ការសិក្សា គឺជាប្រភេទនៃការងារមួយដ៏នឿយហត់។ បើគ្មានកិច្ចខិតខំប្រឹងប្រែងខាងផ្នែកឆន្ទៈនោះទេ នោះយុវសិស្សមិនអាចទទួលបានលទ្ធផលល្អក្នុងការសិក្សាឡើយ។

**សន្និដ្ឋានគរុកោសល្យ** ( Conclusions pedagogiques )

សាស្ត្រាចារ្យ ត្រូវជួយសិស្សឲ្យពុះពារលើរាល់ការលំបាកខាងក្នុងខ្លួន និងការលំបាកខាងក្រៅខ្លួន ក្នុងពេលដំណាលគ្នា។ ដោយមើលឃើញថា សិស្សកំពុងតែសិក្សាមេរៀន គេហាក់ដូចជាយល់ឃើញថា គ្មានអ្វីកើតឡើងក្នុងខ្លួនសិស្សទេ ក៏ប៉ុន្តែតាមការពិត សិស្សកំពុងតែជំនះ លើរាល់ការលំបាកដែលមានលក្ខណៈអត្តនោម័ត និងសត្យានុម័ត ដូចជាៈ សំឡេងរំខាននៅជុំវិញខ្លួនសិស្ស អ្នកដើរទៅមកក្បែរថ្នាក់រៀននិយាយគ្នា ឬ ស្រែកហៅគ្នាធាតុអាកាសដ៏ត្រជាក់ ភាពតានតឹងខាងផ្នែកសរសៃប្រសាទ ដែលត្រូវផ្ចង់ស្មារតី ទៅលើមេរៀន ឬ ទៅលើកិច្ចការដែលកំពុងធ្វើ ដោយឡែក គឺមេរៀន ឬ កិច្ចការ ដ៏លំបាក ដែលតំរូវឲ្យសិស្សបញ្ចេញនូវចំណង់ចំណូលចិត្តរបស់ខ្លួនក្នុងការសិក្សា។

# ឯកសារពិគ្រោះ


Aggarwal, J. C. (2010). *Essentials of educational psychology*. Vikas Publishing House.

Alexander, P. A., & Winne, P. H. (2012). *Handbook of educational psychology*. Routledge.

Chauhan, S. S. (2009). *Advanced educational psychology*. Vikas Publishing House.

Cunningham, D. J. (1992). Beyond educational psychology: Steps toward an educational semiotic. *Educational Psychology Review*, *4*, 165-194. https://link.springer.com/article/10.1007/BF01322343

Dandi, D., & Veronica, M. (2023). Educational psychology, subjective narratives of consequences of games performance. *Socio-Economic and Humanistic Aspects for Township and Industry*, *1*(2), 138-144. https://doi.org/10.59535/sehati.v1i2.123

Dembo, M. H. (1994). *Applying educational psychology*. Longman/Addison Wesley Longman.

Geary, D. C. (2002). Principles of evolutionary educational psychology. *Learning and Individual Differences*, *12*(4), 317-345. https://doi.org/10.1016/S1041-6080(02)00046-8

Good, T. L., & Brophy, J. E. (1990). *Educational psychology: A realistic approach*. Longman/Addison Wesley Longman.

Good, T. L., & Brophy, J. E. (1995). *Contemporary educational psychology*. Longman/Addison Wesley Longman.

Krause, K. L., Bochner, S., Duchesne, S., & McMaugh, A. (2010). *Educational psychology: For learning and teaching*. Cengage Learning Australia.

Langford, P. E. (2004). *Vygotsky's developmental and educational psychology*. Psychology Press.

Lindgren, H. C., & Suter, W. N. (1967). *Educational psychology in the classroom* (Vol. 956). Wiley.

Lindsay, G. (2007). Educational psychology and the effectiveness of inclusive education/mainstreaming. *British Journal of Educational Psychology*, *77*(1), 1-24. https://doi.org/10.1348/000709906X156881

Mangal, S. K. (2002). *Advanced educational psychology*. PHI Learning Pvt. Ltd.

Mayer, R. E. (1992). Cognition and instruction: Their historic meeting within educational psychology. *Journal of Educational Psychology, 84*(4), 405–412. https://doi.org/10.1037/0022-0663.84.4.405

Mayer, R. E. (1999). *The promise of educational psychology: Learning in the content areas* (Vol. 1). Pearson Educación.

McInerney, D. M. (2013). *Educational psychology: Constructing learning*. Pearson Higher Education AU.

O'Donnell, A. M., Reeve, J., & Smith, J. K. (2011). *Educational psychology: Reflection for action*. John Wiley & Sons.

Ormrod, J. E., Anderman, E. M., & Anderman, L. H. (2023). *Educational psychology: Developing learners*. Pearson.

Santrock, J. W. (2011). *Educational psychology*. McGraw-Hill.

Slavin, R. E. (2018). *Educational psychology: Theory and practice*. Pearson.

Sternberg, R. J., & Williams, W. M. (2002). *Educational psychology*. Boston, MA.

Thorndike, E. L. (1913). *Educational psychology* (Vol. 2). Teachers' College, Columbia University.

Tutoo, D. N. (1998). *Educational psychology*. Sterling Publishers Pvt. Ltd.

Woolfolk, A. (2016). *Educational psychology*. Pearson.

9 789924 995616 >